ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
# ២០១៤-២០១៨

ជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព
ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
## ស្តីពី
# ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ២០១៤ - ២០១៨

**មាត្រា ១.-**

អនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤ - ២០១៨ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤ - ២០១៨ នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៤

[illegible]

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
**ហត្ថលេខា**
**ឆាយ ថន**

លេខ: [illegible] ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវគោលនយោបាយសាមគ្គីជាតិ ក្នុងការប្រមូលកម្លាំងប្រជាជាតិទាំងមូលជាធ្លុងមួយពីគ្រប់មជ្ឈដ្ឋាន និន្នាការនយោបាយទាំងក្នុងនិងក្រៅប្រទេស ក្រោមបាវចនា «ជាតិ សាសនា ព្រះមហាក្សត្រ» ដើម្បីធ្វើឱ្យប្រទេសមានឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សុខសន្តិភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពថ្កើងថ្កាន។ ជាមួយនេះ កម្ពុជាបាននិងកំពុងទទួលបាននូវ «ផលចំណេញពីសន្តិភាពពេញលេញ» ដោយសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់និងការកាត់បន្ថយភាពក្រីក្រ និងបានចូលរួមវិភាគទានយ៉ាងថ្លៃថ្លាក្នុងសមាហរណកម្មសេដ្ឋកិច្ចតំបន់និងពិភពលោក។ ស្ថិរភាពនយោបាយពេញលេញដែលទើបទទួលបានកាលពីទសវត្សរ៍កន្លងទៅ បានអនុញ្ញាតឱ្យកម្ពុជាមានលទ្ធភាពអនុវត្តនូវកិច្ចការកំណែទម្រង់គ្រប់វិស័យ សំដៅកសាងសមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច និងបង្កើតបរិយាកាសរឹងមាំ ដើម្បីទាក់ទាញវិនិយោគទុនទាំងក្នុងនិងក្រៅប្រទេស ក្នុងគោលដៅធានាឱ្យទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្របន្ថែមទៀត។

ក្នុងរយៈពេលពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់នូវការផ្លាស់ប្តូរយ៉ាងច្រើន មិនត្រឹមតែក្នុងទិដ្ឋភាពនយោបាយនិងសន្តិសុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការប្រែប្រួលក្នុងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមផងដែរ។ ស្ថិរភាពនយោបាយ សុខសន្តិភាព និងសុវត្ថិភាពបែបនេះ គឺជាបុរេលក្ខខណ្ឌសម្រាប់កម្ពុជាប្រើប្រាស់បានពេញលេញនូវសក្តានុពលសង្គមនិងសេដ្ឋកិច្ចរបស់ខ្លួន។ ការបោះឆ្នោតសកលឆ្នាំ១៩៩៣ បាននាំមកនូវការអនុវត្តគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារ និងការគោរពសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូរបស់មនុស្ស។ ទន្ទឹមនឹងនេះ នៅឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលបានរៀបចំឡើងនូវកម្មវិធីជាតិសម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី១ (១៩៩៦-២០០០) សម្រាប់កំណត់ចក្ខុវិស័យនៃការកសាង និងការអភិវឌ្ឍប្រទេសជាតិឡើងវិញ ដោយផ្តោតជាសំខាន់លើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រ។

លើសពីនេះទៀត ដំណាក់កាលនៃការផ្លាស់ប្តូរមុខមាត់របស់កម្ពុជាដ៏គួរឱ្យកត់សម្គាល់ គឺនៅក្នុងឆ្នាំ១៩៩៨-២០០៣ ដែលជារយៈពេលប្រវត្តិសាស្ត្រដ៏សំខាន់ ដែលមិនត្រឹមតែមានការផ្លាស់ប្តូរទិដ្ឋភាពសង្គមសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការផ្លាស់ប្តូរនូវទិដ្ឋភាពនយោបាយទៀតផង។ ជាក់ស្តែង ការបោះឆ្នោតសកលនាឆ្នាំ១៩៩៨ ការអនុវត្តដោយជោគជ័យនូវនយោបាយ «ឈ្នះ-ឈ្នះ» ដែលបានរំលាយអង្គការចាត់តាំងនយោបាយនិងយោធារបស់ខ្មែរក្រហម បាននាំមកនូវសុខសន្តិភាពពេញផ្ទៃប្រទេស និងការធ្វើសមាហរណកម្មនៃអតីតកងទ័ពខ្មែរក្រហម និងបងប្អូនខ្មែរដែលរស់នៅក្នុងតំបន់អតីតខ្មែរក្រហមកាន់កាប់ ឱ្យចូលមករស់នៅ

ក្នុងសង្គមកម្ពុជាវិញ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើងនូវផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី២(២០០១-២០០៥) ដើម្បីផ្តល់ការតម្រង់ទិសដល់ការបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ព្រមទាំងបានអនុវត្តដោយជោគជ័យនូវ «យុទ្ធសាស្រ្តត្រីកោណ» ដែលបានផ្តោតលើគោលដៅសំខាន់ចំនួនបី គឺ៖ ១-ការធានាឱ្យមានសន្តិភាព ស្ថិរភាព និងសន្តិសុខ ២-ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងការធ្វើឱ្យមានទំនាក់ទំនងល្អឡើងវិញជាមួយនឹងសហគមន៍អន្តរជាតិ និង៣-ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច។ ប្រការនេះបានប្រែក្លាយកម្ពុជាពីប្រទេសមួយដែលធ្លាប់មានអស្ថិរភាព សង្រ្គាម ជម្លោះផ្ទៃក្នុង និងភាពអន់ថយ ឱ្យក្លាយទៅជាចំណុចកណ្តាលមួយនៃសន្តិភាពដ៏រឹងមាំ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការគោរពលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស កិច្ចសហប្រតិបត្តិការ និងកិច្ចអភិវឌ្ឍដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ។ ទិដ្ឋភាពមួយទៀតនៃការវិវឌ្ឍជាវិជ្ជមាន និងគួរឱ្យកត់សម្គាល់ដែលកើតមានឡើងចាប់តាំងពីឆ្នាំ២០០៣ រហូតមកដល់បច្ចុប្បន្ន រួមមានការបោះឆ្នោតសកល នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដោយមានលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និងមានតម្លាភាព ដែលត្រូវបានទទួលស្គាល់ថាជា «អច្ឆរិយហេតុនៃទន្លេមេគង្គ»ម្តងទៀត និងសមិទ្ធផលជាច្រើនដែលសម្រេចបានតាមរយៈការអនុវត្តដោយជោគជ័យនូវ**ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី២ (២០០១-២០០៥) និងយុទ្ធសាស្រ្តចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព**។ ជាក់ស្តែង កម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងវឌ្ឍនភាពសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ក្នុងនោះកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំ មានកម្រិត ៨,៤% ក្នុងរវាងឆ្នាំ១៩៩៤-២០០៦ និងចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៦ កំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំមានកម្រិតដល់ទៅ ៩%។ ជាការពិត សមិទ្ធផលទាំងអស់នេះមិនអាចកាត់ផ្តាច់ពីការចូលរួមវិភាគទានដ៏ថ្លៃថ្លារបស់ដៃគូអភិវឌ្ឍន៍នានារបស់កម្ពុជា ហើយក៏បានឆ្លុះបញ្ចាំងឱ្យឃើញផងដែរអំពីប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ ដែលត្រូវបានកែលម្អឱ្យកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការគ្រប់ប្រភេទដែលកម្ពុជាទទួលបានពីដៃគូសហប្រតិបត្តិការរបស់ខ្លួន ក្នុងរយៈពេលកន្លងមកនេះ។ ជាការពិតណាស់ ការដាក់ចេញនិងការអនុវត្តដោយជោគជ័យនូវផែនការជាតិ និងយុទ្ធសាស្រ្តអភិវឌ្ឍន៍ផ្សេងៗនាពេលកន្លងមក បានផ្តល់នូវផែនទីតម្រង់ទិសសម្រាប់រាជរដ្ឋាភិបាលធ្វើដំណើរឆ្ពោះទៅរកការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ការអនុវត្តយុទ្ធសាស្រ្តចតុកោណ គឺជាការបន្តពង្រឹងនូវសមិទ្ធផលនានាដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងរយៈពេលកន្លងមក ដើម្បីធ្វើឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ កែលម្អនិងបង្កើនសមត្ថភាពរបស់ស្ថាប័នសាធារណៈ លើកស្ទួយអភិបាលកិច្ច និងធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ ក្នុងទិសដៅលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ក្នុងសង្គម និងបង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈ ព្រមទាំងការពារសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិដែលទាំងអស់នេះ សុទ្ធតែជាកត្តាគន្លឹះដ៏សំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ការធ្វើឱ្យការអភិវឌ្ឍជាតិសម្រេចបានជោគជ័យក្នុងក្របខ័ណ្ឌនៃទស្សនៈនេះ តម្រូវឱ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំងកែលម្អ និងពង្រឹងនូវអាទិភាពគោលនយោបាយ បន្តកែលម្អនូវយុទ្ធសាស្រ្តតាមផ្នែកឱ្យឆ្លុះបញ្ចាំងនូវសភាពការណ៍ជាក់ស្តែងរបស់កម្ពុជា ដោយឈរលើបទពិសោធន៍ជាក់ស្តែងនៃការអនុវត្តយុទ្ធសាស្រ្តចតុកោណសម្រាប់នីតិកាលទី៣ នៃរដ្ឋសភាក្នុងពេលកន្លងមក។

ដើម្បីបន្តពង្រីកបន្ថែមនូវវឌ្ឍនភាពដែលសម្រេចបានក្នុងនីតិកាលទី៣ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានរៀបចំយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ដែលជាមូលដ្ឋានគ្រឹះនៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០០៦-២០១០ ជាផែនការថ្មី និងត្រូវបានរៀបចំឡើងដោយប្រើទម្រង់របស់យុទ្ធសាស្ត្រចតុកោណ។ ក្នុងការរៀបចំ ផ.យ.អ.ជ. ២០០៦-២០១០ រាជរដ្ឋាភិបាលបានប្រើប្រាស់ភាពជាម្ចាស់ពេញលេញក្នុងការគ្រប់គ្រងដំណើរការរៀបចំដោយធានាឱ្យមានការចូលរួមពិគ្រោះយោបល់ និងការផ្តល់អនុសាសន៍ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ស្ថិតក្នុងជំហរម៉ឺងម៉ាត់ និងឥតងាករេក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ និង ផ.យ.អ.ជ. ២០០៦-២០១០ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវបរិស្ថានអំណោយផល និងលក្ខខណ្ឌចាំបាច់ជាច្រើនដែលអាចនាំកម្ពុជាបោះជំហានទៅមុខប្រកបដោយជំនឿទុកចិត្តយ៉ាងមុតមាំនៅលើមាគ៌ានៃកំណែទម្រង់ និងការអភិវឌ្ឍស្របគ្នាជាមួយនឹងគោលបំណង ឧត្តមគតិ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពុះពារបម្រើជាតិ និងប្រជាជនក្នុងគ្រប់កាលៈទេសៈ ស្របតាមឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាជន។

ជាក់ស្តែង យើងមានយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ព្រមទាំងឯកសារជាច្រើនទៀតដែលមានលក្ខណៈជាផែនការ គោលនយោបាយ កម្មវិធីវិនិយោគ និងថវិកាជាតិ។ ផ.យ.អ.ជ. គឺជាឯកសារគោលនយោបាយសំខាន់ទី២ របស់រាជរដ្ឋាភិបាលកម្ពុជា និងជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្រចតុកោណ។ ដើម្បីធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារ និងលំដាប់លំដោយនៃការអនុវត្តរវាងឯកសារទាំងអស់នេះ រាជរដ្ឋាភិបាលបានបន្សុីអាណត្តិរបស់ ផ.យ.អ.ជ. ជាមួយនឹងអាណត្តិរបស់កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណ។

ក្នុងបរិការណ៍នេះ ផ.យ.អ.ជ. ២០០៦-២០១០ ត្រូវបានធ្វើបច្ចុប្បន្នភាពទៅជា ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដើម្បីសម្រេចឱ្យបាននូវគោលដៅអាទិភាពចំនួនពីរ គឺគោលដៅទី១៖ បន្សុីអាណត្តិរបស់ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ជាមួយនឹងអាណត្តិរបស់រាជរដ្ឋាភិបាល សំដៅធានាថា សកម្មភាពដែលបានគ្រោងទុកទាំងឡាយរបស់ក្រសួង-ស្ថាប័នទាំងអស់ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពនានារបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ និងគោលដៅទី២៖ ដើម្បីធានាថាការងារដែលត្រូវលើកឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងនេះ ត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់ផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោកដែលអាចកើតមានមកលើសេដ្ឋកិច្ចរបស់កម្ពុជា។

ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រដែលមានលក្ខណៈប្រសើរជាងមុន ពីព្រោះថា វិធីសាស្ត្រនេះបានផ្តោតលើចំណុចបី គឺ៖ ទី១-ការបញ្ជាក់ច្បាស់ពីក្រសួង-ស្ថាប័នទទួលខុសត្រូវ ក្នុងការអនុវត្តគោលនយោបាយអាទិភាពទាំងឡាយក្នុងមុំនីមួយៗនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ទី២-ការបញ្ជាក់ពីសកម្មភាពជាក់លាក់ដែលក្រសួង-ស្ថាប័នបានរៀបចំឡើងដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយ និងទី៣-ការកំណត់តម្លៃដែលក្រសួង-ស្ថាប័នត្រូវប៉ាន់ស្មានឱ្យបាន

ត្រឹមត្រូវបំផុត ដើម្បីអនុវត្តសកម្មភាពទាំងឡាយដែលបានគ្រោងសម្រាប់អំឡុងឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣។ ការរៀបចំ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ មានការចូលរួមនិងពិគ្រោះយោបល់ទូលំទូលាយ ទាំងក្នុងរង្វង់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីគ្រប់គ្រងនូវដំណើរការពង្រឹងសុខដុមនីយកម្មរវាងការរៀបចំផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងធនធានពីគ្រប់ប្រភពសម្រាប់អនុវត្តវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល ជាពិសេស ការពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់គម្រោងវិនិយោគសាធារណៈនានា ដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រនិងថវិកាសម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់។

ជាលទ្ធផល តាមរយៈកិច្ចខិតខំប្រឹងប្រែងឥតរាថយរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ នៅក្នុងដំណាក់នៃផែនការនេះ សេដ្ឋកិច្ចកម្ពុជាមានកំណើនមធ្យមប្រចាំឆ្នាំប្រមាណ ៧%។ ផលិតផលក្នុងស្រុកសរុប សម្រាប់ប្រជាជនម្នាក់ៗមានកម្រិតលើសពី ១ ០០០ដុល្លារអាមេរិក ហើយអត្រាភាពក្រីក្រត្រូវបានកាត់បន្ថយឱ្យមកត្រឹមប្រមាណ ១៩% ក្នុងឆ្នាំ២០១១។ ជាពិសេស កម្ពុជាបានសម្រេចជោគជ័យគួរជាទីមោទនៈ ក្នុងការអនុវត្តប្រកបដោយជោគជ័យនូវចំណុចគោលដៅភាគច្រើននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ហើយកម្ពុជាត្រូវបានអង្គការសហប្រជាជាតិជ្រើសជាប្រទេសគំរូសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

ដោយផ្អែកលើបទពិសោធន៍ លទ្ធផលដែលសម្រេចបានក្នុងនីតិកាលទី៤ នៃរដ្ឋសភា សម្រាប់នីតិកាលទី៥នេះ រាជរដ្ឋាភិបាលយល់ឃើញថា យុទ្ធសាស្ត្រចតុកោណ ពិសេសគោលដៅសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅតែចាំបាច់និងសមស្របសម្រាប់កម្ពុជា ក្នុងការបន្តអនុវត្តដោយរក្សាទុកនូវចតុកោណទាំងបួនឱ្យនៅដដែល និងពង្រីកវិសាលភាព សម្រិតសម្រាំង ធ្វើអាទិភាវូបនីយកម្មមុំ ព្រមទាំងកែលម្អគោលនយោបាយ និងយន្តការមួយចំនួនឱ្យកាន់តែសុក្រឹតឡើងថែមទៀត ឱ្យទៅជាយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ដែលជានាចីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន និងបរិការណ៍ថ្មីៗ ទាំងកម្រិតជាតិ ទាំងកម្រិតអន្តរជាតិ។

ផ.យ.អ.ជ. ២០១៤-២០១៨ គឺត្រូវបានបន្តរៀបចំឡើងសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ដោយមានកំណត់នូវអាទិភាពនានា សូចនាករ ពេលវេលាច្បាស់លាស់សម្រាប់អនុវត្ត និងយន្តការសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃផ្អែកលើក្របខ័ណ្ឌលទ្ធផល ព្រមទាំងមានកំណត់អំពីការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នទៅតាមមុំនីមួយៗ ដើម្បីទទួលបានផលចំណេញខ្ពស់ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងឈានឡើងពីប្រទេសដែលមានចំណូលទាប ឆ្ពោះទៅក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ក្នុងការរៀបចំ ផ.យ.អ.ជ. ២០១៤-២០១៨ រាជរដ្ឋាភិបាលបានប្រើប្រាស់នីតិវិធី និងយន្តការដែលមានស្រាប់ ដូចការរៀបចំ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ និងបានប្រើប្រាស់ពេលវេលាវែងជាងមុនក្នុងការសម្រួចខ្លឹមសារផែនការជាតិនេះ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ទាំងឡាយដែលបានជួយគាំទ្រទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ សម្រាប់រួមចំណែកធ្វើឱ្យកម្ពុជាមានវឌ្ឍនភាពគួរជាទីមោទនៈ។ ពិតណាស់ថា បច្ចុប្បន្នយើងកំពុងបន្តស្ថិតក្នុងយុគសម័យថ្មីដែលរាជរដ្ឋាភិបាល ក៏ដូចជាក្រសួង-ស្ថាប័នទាំងអស់

ត្រូវតែធ្វើជាម្ចាស់លើដំណើរការអភិវឌ្ឍន៍នានា និងទទួលខុសត្រូវលើវិសនារបស់ខ្លួនឯង។ ក្នុងខណៈដែលយើងកំពុងបន្តបោះជំហានឆ្ពោះទៅមុខ រាជរដ្ឋាភិបាលនឹងទទួលខុសត្រូវពេញលេញក្នុងដំណើរការអភិវឌ្ឍន៍ទាំងមូល ដើម្បីធានាថាធនធានទាំងអស់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នឹងត្រូវបានផ្តល់ដោយមានទិសដៅច្បាស់លាស់ទៅដល់អាទិភាព និងវិស័យនានាដែលត្រូវបានជ្រើសរើស។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ខ្ពស់ក្នុងការសម្រេចឱ្យបានការផ្ទេរពិតនៃធនធានអភិវឌ្ឍន៍ ដើម្បីឱ្យបានទៅដល់អ្នកត្រូវទទួលផលប្រយោជន៍ទាំងឡាយ ជាពិសេសនៅតំបន់ជនបទ។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា ដើម្បីភាពជោគជ័យនៃការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដូចបានកំណត់នៅក្នុងយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ខ្ញុំសង្ឃឹមជឿជាក់យ៉ាងមុតមាំថា គ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នឹងប្រកាន់ខ្ជាប់នូវបណ្តាអាទិភាពនានាដែលបានកំណត់នៅក្នុង ផ.យ.អ.ជ. ២០១៤-២០១៨ ដែលជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ២០១៤

ហ៊ុន សែន

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា





# កម្ពុជា: សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ

| ព័ត៌មានទូទៅ | |
|---|---|
| ផ្ទៃដីសរុប: គម² | ១៨១ ០៣៥ |
| ចំនួនរាជធានី | ១ |
| ចំនួនខេត្ត | ២៤ |
| ចំនួនក្រុង | ២៦ |
| ចំនួនខណ្ឌ | ១២ |
| ចំនួនស្រុក | ១៥៩ |
| ចំនួនសង្កាត់ | ២២៧ |
| ចំនួនឃុំ | ១ ៤០៦ |
| ចំនួនភូមិ | ១៤ ១១៩ |
| ឆ្នាំសារពើពន្ធ | មករា-ធ្នូ |
| រូបិយវត្ថុ | រៀល (៛) |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| ១.០០ | **កម្រិតនៃភាពក្រីក្រ** | | | | | | | |
| ១.០១ | សរុបទូទាំងប្រទេស | %នៃប្រជាជន | ១៧,៩ | ១៦,៩ | ១៥,៩ | ១៤,៩ | ១៣,៩ | ១២,៩ |
| ១.០២ | ភ្នំពេញ | %នៃប្រជាជន | ១៥,៣ | ១៤,៣ | ១៣,៣ | ១២,៣ | ១១,៣ | ១០,៣ |
| ១.០៣ | ទីប្រជុំជនផ្សេងទៀត | %នៃប្រជាជន | ១៣,៥ | ១២,៥ | ១១,៥ | ១០,៥ | ៩,៥ | ៨,៥ |
| ១.០៤ | ជនបទ | %នៃប្រជាជន | ១៩,០ | ១៨,០ | ១៧,០ | ១៦,០ | ១៥,០ | ១៤,០ |
| ១.០៥ | ប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ | %នៃប្រជាជន | <៥ | <៥ | <៥ | <៥ | <៥ | <៥ |
| | | | | | | | | |
| ២.០០ | **បញ្ហាយេនឌ័រ** | | | | | | | |
| ២.០១ | ស្ត្រីក្នុងកម្លាំងពលកម្ម (ក.ព.) វិស័យកសិកម្ម | %នៃ ក.ព. សរុប | ៥២ | ៥១ | ៥០ | ៥០ | ៥០ | ៥០ |
| ២.០២ | វិស័យឧស្សាហកម្ម | %នៃ ក.ព. សរុប | ៦០ | ៥៥ | ៥០ | ៥០ | ៥០ | ៥០ |
| ២.០៣ | វិស័យសេវា | %នៃ ក.ព. សរុប | ៣០ | ៣៥ | ៤០ | ៤០ | ៤០ | ៤០ |
| | | | | | | | | |
| ៣.០០ | **ប្រជាជន** | | | | | | | |
| ៣.០១ | សរុប: អង្កេតចន្លោះជំរឿន ខែមីនាឆ្នាំ២០១៣ | លាននាក់ | ១៤,៧ | | | | | |
| ៣.០២ | ដង់ស៊ីតេប្រជាជន | ក្នុងមួយគម² | ៨២ | ៨៥ | ៨៧ | ៨៨ | ៨៩ | ៩០ |
| ៣.០៣ | បុរសធៀបនឹងស្ត្រី | ស្ត្រី១០០នាក់ | ៩៤,៣ | ៩៦ | ៩៦,២ | ៩៦,៣ | ៩៦,៥ | ៩៦,៧ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ៣.០៤ | អាយុ០-១៤ | % នៃប្រជាជន | ២៩,៤ | ២៩,៦ | ២៩,២ | ២៨,៩ | ២៨,៧ | ២៨,៥ |
| ៣.០៥ | អាយុ១៥-៦៤ | % នៃប្រជាជន | ៦២,៦ | ៦៥,៩ | ៦៦,២ | ៦៦,៤ | ៦៦,៥ | ៦៦,៥ |
| ៣.០៦ | អាយុ៦៥ឆ្នាំឡើង | % នៃប្រជាជន | ៥,០ | ៤,៥ | ៤,៦ | ៤,៧ | ៤,៨ | ៥,០ |
| ៣.០៧ | ជនបទ | % នៃប្រជាជន | ៧៨,៦ | ៧៨,៥ | ៧៨,៤ | ៧៨,៣ | ៧៨,២ | ៧៨,១ |
| ៣.០៨ | ទីប្រជុំជន | % នៃប្រជាជន | ២១,៤ | ២១,៥ | ២១,៦ | ២១,៧ | ២១,៨ | ២១,៩ |
| ៣.០៩ | អត្រាកំណើនប្រចាំឆ្នាំ | % | ១,៤៦ | ១,៤៤ | ១,៤២ | ១,៤១ | ១,៣៩ | ១,៣៦ |
| ៣.១០ | អត្រាផ្តល់កំណើតសរុប (ក្នុងស្ត្រីម្នាក់) | កំណើតរស់ | ២,៨ | ២,៧ | ២,៦ | ២,៥ | ២,៤ | ២,៣ |
| ៣.១១ | អាយុកាលមធ្យមសង្ឃឹមរស់ពីកំណើត ប្រុស | ឆ្នាំ | ៦៧,១ | ៦៧,៣ | ៦៧,៥ | ៦៧,៧ | ៦៧,៩ | ៦៨,១ |
| | ស្ត្រី | ឆ្នាំ | ៧១,០ | ៧១,២ | ៧១,៤ | ៧១,៦ | ៧១,៨ | ៧១,៩ |
| | | | | | | | | |
| ៤.០០ | **ម៉ាក្រូសេដ្ឋកិច្ច** | | | | | | | |
| ៤.០១ | ផ.ស.ស. ថ្លៃថេរឆ្នាំ២០០០ | ពាន់លានរៀល | ៦១ ៥២៥ | ៦៨ ៦១៨ | ៧៥ ៦៣៦ | ៨៣ ៤២២ | ៩២ ១៤៣ | ១០១ ៥៤៨ |
| ៤.០២ | ផ.ស.ស. ថ្លៃថេរឆ្នាំ២០០០ | លានដុល្លារ | ១៥ ១៩១ | ១៦ ៩៤៣ | ១៨ ៦៧៦ | ២០ ៥៩៨ | ២២ ៤៧៤ | ២៤ ៧៦៨ |
| ៤.០៣ | អត្រាកំណើន ផ.ស.ស. ពិត | % | ៧,៦ | ៧,០ | ៧,០ | ៧,០ | ៧,០ | ៧,០ |
| ៤.០៤ | កសិកម្ម | % | ៤,២ | ៤,២ | ៤,០ | ៤,០ | ៤,០ | ៤,០ |
| ៤.០៥ | ឧស្សាហកម្ម | % | ៩,៨ | ៩,៩ | ៩,៣ | ៩,១ | ៨,៨ | ៨,៨ |
| ៤.០៦ | សេវា | % | ៨,៨ | ៦,៨ | ៧,១ | ៧,១ | ៧,២ | ៧,២ |
| ៤.០៧ | ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ៗ | ពាន់រៀល | ៤ ២៤៨ | ៤ ៦៧០ | ៥ ០៧២ | ៥ ៥២៣ | ៥ ៩៤៩ | ៦ ៤៧២ |
| ៤.០៨ | ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ៗ | ដុល្លារ | ១ ០៣៦ | ១ ១៣៩ | ១ ២៣៧ | ១ ៣៤៧ | ១ ៤៥១ | ១ ៥៧៩ |
| ៤.០៩ | អតិផរណា (ការប្រែប្រួលមធ្យមប្រចាំឆ្នាំ) | % | ៣,០ | ៣,៥ | ៣,៥ | ៣,៥ | ៣,៥ | ៣,៥ |
| ៤.១០ | ប្រាក់រៀលធៀបនឹងដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល/ ដុល្លារ | ៤ ១០០ | ៤ ១០០ | ៤ ១០០ | ៤ ១០០ | ៤ ១០០ | ៤ ១០០ |
| ៤.១១ | ទុនបម្រុងបរទេសដុល | ចំនួនខែនាំចូល | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ |
| ៤.១២ | ទុនបម្រុងបរទេសដុល | លានដុល្លារ | ៣ ៩៣២ | ៤ ៤៧៧ | ៥ ០៨៦ | ៥ ៧០៨ | ៦ ៣៦៥ | ៧ ០៦៥ |
| ៤.១៣ | ការវិនិយោគផ្ទាល់បរទេស | លានដុល្លារ | ១ ២១៦ | ១ ២១១ | ១ ៣៦១ | ១ ៥២៩ | ១ ៦៩៦ | ១ ៩០៤ |
| | | | | | | | | |
| ៥.០០ | **សារពើពន្ធ** | | | | | | | |
| ៥.០១ | ចំណូលថវិកាសរុប | %នៃ ផ.ស.ស. | ១៤,៣ | ១៥,១ | ១៥,៦ | ១៦,១ | ១៦,៥ | ១៦,៩ |
| ៥.០២ | ចំណាយថវិកាសរុប | %នៃ ផ.ស.ស. | ១៩,៥ | ១៩,៩ | ១៩,៨ | ១៩,៩ | ១៩,៩ | ១៩,៩ |
| ៥.០៣ | អតិរេកចរន្ត | %នៃ ផ.ស.ស. | ២,៣ | ២,៦ | ៣,៤ | ៣,៩ | ៤,៤ | ៤,៨ |
| | | | | | | | | |
| ៦.០០ | **វិស័យហិរញ្ញវត្ថុ** | | | | | | | |
| ៦.០១ | ធនាគារពាណិជ្ជកម្មនិងធនាគារឯកទេស | ចំនួន | ៤៤ | | | | | |
| ៦.០២ | ឥណទានមិនទាន់ទូទាត់សង | ពាន់លានរៀល | ៣០ ២០៤ | ៣៩ ២៦៥ | ៥១ ០៤៥ | ៦៦ ៣៥៨ | ៨៦ ២៦៦ | ១១២ ១៤៥ |
| ៦.០៣ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ចំនួន | ៣៨ | | | | | |
| ៦.០៤ | ឥណទានមិនទាន់ទូទាត់សង | ពាន់លានរៀល | ៥ ២៦២ | ៧ ៥២៤ | ១០ ៧៦០ | ១៥ ៣៨៦ | ២២ ០០៣ | ៣១ ៤៦៤ |
| | | | | | | | | |
| ៧.០០ | **ជំនួយអភិវឌ្ឍន៍ផ្លូវការ (រួមទាំងអង្គការក្រៅរដ្ឋាភិបាល)** | | | ប៉ាន់ស្មាន | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ |
| ៧.០១ | សរុប | លានដុល្លារ | ១ ៥៦៦,៤ | ១ ២៤២,២ | ១ ០០០,៨ | | | |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ៧.០២ | ជំនួយបច្ចេកទេស | លានដុល្លារ | ២៦៣,៧ | ២៥១,១ | ២១៤,៧ | | | |
| ៧.០៣ | ជំនួយវិនិយោគ | លានដុល្លារ | ១២៣៨,៣ | ៨៩៧ | ៦៩៧,៨ | | | |
| ៧.០៤ | ជំនួយផ្សេងៗទៀត | លានដុល្លារ | ៦៤,៤ | ៩៤,១ | ៨៩,៣ | | | |
| | | | | | | | | |
| **៨.០០** | **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | | | |
| ៨.០១ | ទិន្នផលស្រូវក្នុងមួយហិកតា | តោន | | ៣,១៥ | ៣,១៨ | ៣,២១ | ៣,២៣ | ៣,២៥ |
| ៨.០២ | ផ្ទៃដីដាំដុះដំណាំស្រូវ | លានហ.ត. | | ៣,១ | ៣,១ | ៣,២ | ៣,២ | ៣,៣ |
| ៨.០៣ | បរិមាណផលស្រូវ | លានតោន | | ៩,៧ | ១០,០ | ១០,២ | ១០,៥ | ១០,៨ |
| ៨.០៤ | ផលិតផលស្រូវផលិតលើស | លានតោន | | ៥,២៤ | ៥,៤១ | ៥,៦០ | ៥,៧៩ | ៦,០០ |
| ៨.០៥ | ផ្ទៃដីសម្រាប់ដំណាំគ្រប់មុខ (រួមមានដំណាំអចិន្ត្រៃយ៍និងដំណាំចម្ការ) | ហ.ត. | | ៤ ៨១៤ ៥៣៤ | ៥ ០២៤ ៥៣៤ | ៥ ២៣៤ ៥៣៤ | ៥ ៤៤៤ ៥៣៤ | ៥ ៦៥៤ ៥៣៤ |
| ៨.០៦ | សហគមន៍កសិកម្ម | ចំនួន | | ៤៧៥ | ៥៧៥ | ៦៧៥ | ៧៧៥ | ៨៧៥ |
| ៨.០៧ | ផលិតកម្មសត្វគ្រប់ប្រភេទក្នុងកំណើន៣% | លានក្បាល | | ៣៥,៨ | ៣៦,៩ | ៣៨,០ | ៣៩,១ | ៤០,៣ |
| ៨.០៨ | សត្វដែលទទួលបានវ៉ាក់សាំង | % | | ១០ | ១២ | ១៥ | ១៧ | ២០ |
| ៨.០៩ | ចំនួនសត្តឃាតដ្ឋានដែលអនុវត្តអនាម័យល្អតាមស្តង់ដាបច្ចេកទេស | ចំនួនកន្លែង | | ២៥ | ៥០ | ៧៥ | ១០០ | ១២៥ |
| ៨.១០ | ផ្ទៃដីដាំដុះកៅស៊ូ | ហ.ត. | | ៣០៦ ៥០០ | ៣៣៤ ៥០០ | ៣៦២ ៥០០ | ៣៨៤ ៥០០ | ៤០៤ ៥០០ |
| ៨.១១ | ទិន្នផលជ័រកៅស៊ូ | គ.ក្រ/ហ.ត/ឆ្នាំ | | ១ ២៥៧ | ១ ២៨២ | ១ ៣១១ | ១ ៣៧៣ | ១ ៣៦៨ |
| ៨.១២ | បរិមាណផលជ័រកៅស៊ូ | តោន | | ១៣៧ ៥២០ | ១៨១ ៥៦០ | ២៤០ ៨០០ | ៣០០ ៨០០ | ៣៨០ ៩៣០ |
| ៨.១៣ | ផលិតកម្មវារីវប្បកម្មកើន ១៥% | តោន | | ៩៧ ៨០០ | ១១២ ៥០០ | ១២៩ ៤០០ | ១៤៨ ៨០០ | ១៧១ ១៧០ |
| ៨.១៤ | បរិមាណផលិតកម្មនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | ពាន់តោន | | ៧៥២ | ៧៩០ | ៨២៩ | ៨៧០ | ៩១០ |
| ៨.១៥ | ចំនួនសហគមន៍នេសាទ | សហគមន៍ | | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ |
| ៨.១៦ | ការបោះបង្គោលព្រំព្រៃឈើ (គ.ម) | ហ.ត. | | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ |
| ៨.១៧ | ផ្ទៃដីដាំព្រៃឡើងវិញ | ហ.ត. | | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ |
| ៨.១៨ | ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើត | ចំនួន | | ៣២ | ៣២ | ៣២ | ៣២ | ៣២ |
| | | | | | | | | |
| **៩.០០** | **ការអភិវឌ្ឍជនបទ** | | | | | | | |
| ៩.០១ | ការស្តារនិងសាងសង់ផ្លូវជនបទ (លើប្រវែងសរុប ៤០ ០០០ គ.ម) | គ.ម. | ២៧ ៩០០ | ២៨ ៦០០ | ២៩ ៤៥០ | ៣០ ៣០០ | ៣១ ១៥០ | ៣២ ០០០ |
| ៩.០២ | ប្រវែងផ្លូវជនបទដែលបានក្រាលកៅស៊ូពីរជាន់ (DBST ) ឬបេតុង | គ.ម. | ១២៥ | ៥៥០ | ៩៨០ | ១ ៤៣០ | ១ ៨៨០ | ២ ៣៣០ |
| ៩.០៣ | ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | ៤៤,២ | ៤៦,៧ | ៥០ | ៥៣ | ៥៦ | ៦០ |
| ៩.០៤ | ភាគរយប្រជាជនជនបទទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | ៣៧,៥ | ៤២ | ៤៦ | ៥០ | ៥៥ | ៦០ |
| ៩.០៥ | ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ | ក្រុម | ១០០ | ១៣០ | ១៦០ | ១៩០ | ១២០ | ២៥០ |
| ៩.០៦ | ចំនួនភូមិដែលបានបណ្តុះបណ្តាល គ.អ.ភ. ស្តីពីផែនការអភិវឌ្ឍន៍ភូមិ | ភូមិ | ១ ៦១០ | ១ ៨០០ | ២ ០០០ | ២ ២០០ | ២ ៤០០ | ២ ៦០០ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ៩.០៧ | សិក្សានិងសាងសង់សាកល្បងផ្លូវជនបទក្រាលកៅស៊ូ៤៥០គ.ម.ដែលអាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុ១០០% | គ.ម. | ០ | ៦៧,៥ | ៩០ | ១១២,៥ | ៩០ | ៩០ |
| ៩.០៨ | កសាងសមត្ថភាព គ.អ.ភ. ស្ដីពីជម្រើសនៃបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្រប មួយដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន | គ.អ.ភ. | ០ | ១៨៥៤ | ២៤៧២ | ៣០៩១ | ២៤៧២ | ២៤៧២ |
| | | | | | | | | |
| **១០.០០** | **ឧស្សាហកម្ម** | | | | | | | |
| ១០.០១ | ផលិតផលកម្មន្តសាល | ពាន់លានរៀល | ២៥ ៣៣៥ | ២៦ ០៩៥ | ២៦ ៨៥៥ | ២៧ ៦១៥ | ២៨ ៣៧៥ | ២៩ ១៣៥ |
| ១០.០២ | ក្នុងនោះ - ឧស្សាហកម្មសម្លៀកបំពាក់ : ផលិតផល | ពាន់លានរៀល | ២០ ៨៤០ | ២១ ៤៦៥ | ២២ ០៩០ | ២២ ៧១៥ | ២៣ ៣៤០ | ២៣ ៩៦៥ |
| ១០.០៣ | កម្លាំងពលកម្ម | នាក់ | ៦៨៦ ១៤៦ | ៦៩៩ ៨៦៩ | ៧១៣ ៥៩២ | ៧២៧ ៣១៥ | ៧៤១ ០៣៨ | ៧៥៤ ៧៦១ |
| ១០.០៤ | ឧស្សាហកម្មធុនតូចនិងមធ្យម | មូលដ្ឋាន | ៣៨ ១០៨ | ៣៨ ២៧៩ | ៣៨ ៥៤០ | ៣៨ ៨០១ | ៣៩ ០៦២ | ៣៩ ៣២៣ |
| | | | | | | | | |
| **១១.០០** | **ថាមពល** | | | | | | | |
| ១១.០១ | អគ្គិសនីដែលមាន | លាន គ.វ៉.ម. | ៤៣៤៩,៥ | ៥ ២១៩ | ៦ ២៦៣ | ៧ ៥១៦ | ៩ ០១៩ | ១០ ៨២៣ |
| ១១.០២ | ចំនួនគ្រួសារប្រើប្រាស់ថាមពល | គ្រួសារ | ១ ១២៥ ៦៧៩ | ១ ៣២៨ ៣០១ | ១ ៥២៧ ៥៤៦ | ១ ៦៦៥ ០២៦ | ១ ៧៦៤ ៩២៧ | ១ ៨៣៥ ៥២៤ |
| ១១.០៣ | ការប្រើប្រាស់ថាមពលរបស់ប្រជាជនម្នាក់ក្នុង១ឆ្នាំ | គ.វ៉.ម. | ២៦៨ | ២៩៥ | ៣៤៤ | ៤០០ | ៤៦៧ | ៥៤៤ |
| ១១.០៤ | ប្រវែងបណ្ដាញខ្សែបញ្ជូនថាមពល (២២KV) | គ.ម. | ១១ ១៨២ | ១៣ ៤៤០ | ១៧ ១៨២ | ២០ ៤៨២ | ២២ ១៣២ | ២២ ៦៦២ |
| ១១.០៥ | ប្រវែងបណ្ដាញខ្សែបញ្ជូនថាមពល (១១៥KV) | គ.ម. | ៤២២ | ៥២០,៥ | ៦៧៥,៥ | ៨៧៥,៥ | ៨៧៥,៥ | ៨៧៥,៥ |
| ១១.០៦ | ប្រវែងបណ្ដាញខ្សែបញ្ជូនថាមពល (២៣០ KV) | គ.ម. | ៨៥៣ | ៩៤៤,៣ | ១ ០៥៤,៣ | ១ ៤៥៦,៣ | ១ ៦៦៩,៣ | ១ ៧៣៤,៣ |
| | | | | | | | | |
| **១២.០០** | **ដឹកជញ្ជូន** | | | | | | | |
| ១២.០១ | ផ្លូវជាតិនិងផ្លូវខេត្ត : សរុប | គ.ម. | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ |
| ១២.០២ | ក្នុងនោះ -- ផ្លូវកៅស៊ូ | គ.ម. | ៥០០ | ៦០០ | ៥០០ | ៥០០ | ៥០០ | ៥០០ |
| ១២.០៣ | ផ្លូវដែក | គ.ម. | ២៦៦ | ៣៨៦ | ២៥៧ | ៣១៩ | ២៤៨ | ២៤៨ |
| ១២.០៤ | កំពង់ផែអន្តរជាតិ | ចំនួន | ២ | ២ | ២ | ២ | ២ | ២ |
| ១២.០៥ | អាកាសយានដ្ឋាន : | | | | | | | |
| | ក- អាកាសយានដ្ឋានអន្តរជាតិ | ចំនួន | | ៣ | ៣ | ៤ | ៤ | ៥ |
| | ខ- អាកាសយានដ្ឋានក្នុងស្រុក | ចំនួន | | ៨ | ៨ | ៨ | ៨ | ៧ |
| | | | | | | | | |
| **១៣.០០** | **ទូរគមនាគមន៍** | | | | | | | |
| | **ការពង្រីកសេវាកម្មប្រៃសណីយ៍** | | | | | | | |
| ១៣.០១ | អត្រាអ្នកប្រើសេវា | ១នាក់/១ឆ្នាំ | ០,១២៧៩ | ០,១២៩៨ | ០,១៣១៦ | ០,១៣៣៥ | ០,១៣៥៤ | ០,១៣៧៣ |
| ១៣.០២ | អត្រាបម្រើសេវា | គ.ម$^{2}$ ក្នុង១ការិយាល័យ | ៣ ៣៥២,៥ | ៣ ៣៥២,៥ | ៣ ៣៥២,៥ | ៣ ៣៥២,៥ | ៣ ៣៥២,៥ | ៣ ៣៥២,៥ |
| | **ការពង្រីកសេវាទូរគមនាគមន៍** | | | | | | | |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ១៣.០៣ | សរុបទូរស័ព្ទ (ចល័ត-អចល័ត) | លានគ្រឿង | ២៣,៨ | ២៨,៨ | ៣៤,៨ | ៤២,២ | ៥១,០ | ៦១,៧ |
| ១៣.០៤ | អត្រាអ្នកប្រើប្រាស់ទូរស័ព្ទ | ១០០នាក់ | ១៥៩,១ | ១៨៩,៨ | ២២៦,៤ | ២៧០,០ | ៣២២,២ | ៣៨៤,៥ |
| ១៣.០៥ | អ្នកប្រើប្រាស់អ៊ិនធឺណិត | លាននាក់ | ៤,៣ | ៦,៩ | ១១,០ | ១៣,៤ | ១៦,២ | ១៩,៦ |
| | | | | | | | | |
| ១៤.០០ | **ទេសចរណ៍** | | | | | | | |
| ១៤.០១ | ទេសចរអន្តរជាតិ | លាននាក់ | | ៤,៧ | ៥,១ | ៥,៦ | ៦,១ | ៦,៥ |
| ១៤.០២ | ទេសចរជាតិ | លាននាក់ | | ៨,៧ | ៩,០ | ៩,៣ | ៩,៥ | ៩,៨ |
| ១៤.០៣ | សេវាស្នាក់នៅ | បន្ទប់ | | ៥០ ៣២៨ | ៥៣ ៨៥១ | ៥៧ ៦២១ | ៦១ ០៧៨ | ៦៤ ១៣២ |
| ១៤.០៤ | កម្លាំងពលកម្មបម្រើឱ្យវិស័យទេសចរណ៍ | ពាន់នាក់ | | ៤២៥ | ៤៥៥ | ៥០០ | ៥៥០ | ៦០០ |
| ១៤.០៥ | ចំណូលទេសចរណ៍ | លានដុល្លារ | | ២ ៨០២ | ៣ ០៥៤ | ៣ ៣៥៩ | ៣ ៧២៩ | ៤ ១៣៩ |
| | | | | | | | | |
| ១៥.០០ | **ព័ត៌មានសាធារណៈ** | | | | | | | |
| | **ក/. ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ** | | | | | | | |
| | ១-ស្ថានីយទូរទស្សន៍រដ្ឋ (ទ.ទ.ក.) | | | | | | | |
| ១៥.០១ | -ស្ថានីយកណ្តាល | ចំនួន | ០១ | ០១ | ០១ | ០២ | ០២ | ០២ |
| ១៥.០២ | -ស្ថានីយខេត្ត | ចំនួន | ០៧ | ០៨ | ០៨ | ១០ | ១០ | ១២ |
| | ២-ស្ថានីយវិទ្យុរដ្ឋ (វិទ្យុជាតិកម្ពុជា) | | | | | | | |
| ១៥.០៣ | -ស្ថានីយកណ្តាល | ចំនួន | ០៣ | ០៣ | ០៣ | ០៣ | ០៣ | ០៤ |
| ១៥.០៤ | -ស្ថានីយខេត្ត | ចំនួន | ១៨ | ២០ | ២០ | ២២ | ២៣ | ២៤ |
| ១៥.០៥ | ៣-ទីភ្នាក់ងារសារព័ត៌មានរដ្ឋ | អង្គភាព | ០១ | ០១ | ០១ | ០១ | ០១ | ០១ |
| | **ខ/. ប្រព័ន្ធផ្សព្វផ្សាយឯកជន** | | | | | | | |
| ១៥.០៦ | ១-ស្ថានីយទូរទស្សន៍ឯកជន | ចំនួន | ១២ | ១៣ | ១៤ | ១៤ | ១៥ | ១៥ |
| ១៥.០៧ | ២-ស្ថានីយទូរទស្សន៍ខ្សែកាប (ភ.ព.ខេត្ត) | ចំនួន | ៩៦ | ៩៨ | ១០០ | ១០០ | ១០២ | ១០៥ |
| ១៥.០៨ | ៣-ស្ថានីយវិទ្យុឯកជន | ចំនួន | ៥១ | ៥៣ | ៥៥ | ៥៧ | ៥៩ | ៦០ |
| ១៥.០៩ | ៤-សារព័ត៌មានបោះពុម្ព (កាសែត ព្រឹត្តិបត្រ ទស្សនាវដ្តី ភាសាខ្មែរនិងបរទេស ) | អង្គភាព | ៥៧៤ | ៥៨០ | ៥៨០ | ៦០០ | ៦០០ | ៦០០ |
| ១៥.១០ | ៥-រោងពុម្ព | អង្គភាព | ១៣៦ | ១៣៨ | ១៤០ | ១៤២ | ១៤៤ | ១៤៥ |
| | | | | | | | | |
| ១៦.០០ | **សុខាភិបាល** | | | | | | | |
| | **១- កម្មវិធីសុខភាពផ្លូវភេទ សុខភាពបន្តពូជ មាតា ទារក និងកុមារ និងអាហារូបត្ថម្ភ** | | | | | | | |
| ១៦.០១ | អត្រាមរណភាពមាតា | ក្នុង១០០ ០០០ កំណើតរស់ | ២០៦ | | ១៤០ | | | ១៣០ |
| ១៦.០២ | អត្រាមរណភាពទារក | ក្នុង១០០០ កំណើតរស់ | ២៧ | | ២២ | | | ២០ |
| ១៦.០៣ | អត្រាមរណភាពកុមារក្រោម១ឆ្នាំ | ក្នុង១០០០ កំណើតរស់ | ៤៥ | | ៣៥ | | | ៣២ |
| ១៦.០៤ | អត្រាមរណភាពកុមារក្រោម៥ឆ្នាំ | ក្នុង១០០០ កំណើតរស់ | ៥៤ | | ៤៥ | | | ៤២ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ១៦.០៥ | ស្ត្រីមិនចង់មានគភ៌ដែលពុំបានទទួលសេវាពន្យារកំណើត | % | ១៦,៦ | | ១០ | | | ៨ |
| ១៦.០៦ | អត្រារំលូតកូន/ការរំលូតកូនផ្ទួនៗ | % | ៥ [២៦%] | | ៥[២២%] | | | ៥[២០%] |
| ១៦.០៧ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | % | ៣៤ | ៣៧ | ៤០ | ៤២ | ៤៤ | ៤៦ |
| ១៦.០៨ | ស្ត្រីមានគភ៌ទទួលការពិនិត្យផ្ទៃពោះយ៉ាងតិច២លើកដោយបុគ្គលិកសុខាភិបាល | % | ៨១,២ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ |
| ១៦.០៩ | ស្ត្រីមានគភ៌បានទទួលជីវជាតិដែក-ហ្វូលីកអាស៊ីត៩០គ្រាប់ | % | ៨៤ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ |
| ១៦.១០ | ស្ត្រីមានគភ៌ផ្ទុកមេរោគអេដស៍ដែលបានទទួលថ្នាំប្រឆាំងជំងឺអេដស៍សម្រាប់បង្ការការចម្លងពីម្តាយទៅទារក | % | ៧៨ | ៨០ | ៨២ | ៨៤ | ៨៦ | ៨៨ |
| ១៦.១១ | ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ | % | ៨០ | ៨៣ | ៨៥ | ៨៧ | ៨៩ | ៩១ |
| ១៦.១២ | ការសម្រាលដោយវះកាត់ | % | ៣,២ | ៣,៥ | ៤ | ៤,២ | ៤,៤ | ៤,៦ |
| ១៦.១៣ | មាតាដែលបានចាប់ផ្តើមបំបៅដោះទារកក្នុងម៉ោងទី១ក្រោយសម្រាល | % | ៧៤ | ៧៥ | ៧៦ | ៧៧ | ៧៨ | ៧៩ |
| ១៦.១៤ | កុមារក្រោម១ឆ្នាំបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល | % | ៩០,១ | ៩៥ | ៩៥ | ៩៥ | ៩៥ | ៩៥ |
| ១៦.១៥ | កុមារក្រោម៥ឆ្នាំមានជំងឺរលាកសួតបានទទួលការព្យាបាលដោយថ្នាំផ្សះត្រឹមត្រូវនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ | % | ៦៥ | ៦៦ | ៦៧ | ៦៨ | ៦៩ | ៧០ |
| ១៦.១៦ | កុមារក្រោម៥ឆ្នាំ មានជំងឺរាគរូសបានទទួលការព្យាបាលដោយ ORS + Zinc តាមមូលដ្ឋានសុខាភិបាលសាធារណៈ | % | ៩៥ | ៩៦ | ៩៧ | ៩៨ | ៩៨ | ១០០ |
| ១៦.១៧ | កុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់ដែលមានផលវិបាកបានទទួលការព្យាបាល | % | ២៥ | ៣៥ | ៥០ | ៦៥ | ៨០ | ៩០ |
| | **២- ជំងឺឆ្លង** | | | | | | | |
| ១៦.១៨ | ប្រេវ៉ាឡង់ជំងឺអេដស៍ | % | ០,៧ | ០,៧ | ០,៦ | ០,៣ | ០,២ | <០,១ |
| ១៦.១៩ | អ្នកផ្ទុកមេរោគអេដស៍ដែលប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ នៅរស់ក្រោយការព្យាបាលរយៈពេល១២ខែ | % | ៩០ | ៩០ | ៩០ | ៩០ | ៩០ | ៩០ |
| ១៦.២០ | ប្រេវ៉ាឡង់នៃជំងឺរបេងគ្រប់សណ្ឋានលើប្រជាជន | ១០០ ០០០ នាក់ | ៧២៥ | ៦៩៤ | ៦៥៣ | ៦១២ | ៥៧១ | ៥៣០ |
| ១៦.២១ | អត្រាស្លាប់ដោយជំងឺរបេងក្នុងចំណោមប្រជាជន | ១០០ ០០០ នាក់ | ៦៣ | ៦០ | ៥៧ | ៥៤ | ៥១ | ៤៨ |
| ១៦.២២ | អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង | % | ៩១ | ៩១ | ៩១ | ៩១ | ៩១ | ៩១ |
| ១៦.២៣ | អត្រាស្លាប់នៃជំងឺគ្រុនចាញ់រាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈលើប្រជាជន ១០០ ០០០នាក់ | ១០០ ០០០ នាក់ | ០,០៨ | ០,០៨ | ០,០៨ | ០,០៨ | ០,០៨ | ០,០៨ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ១៦.២៤ | ចំនួនករណីគ្រុនចាញ់ ព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ (អាំងស៊ីដង់) | ១ ០០០នាក់ | ១,៥ | ២,៩ | ២ | ១,៨៥ | ១,៦៥ | ១,៤៥ |
| ១៦.២៥ | អត្រាស្លាប់ដោយជំងឺគ្រុនឈាមបានរាយការណ៍ ដោយសុខាភិបាលសាធារណៈ (អ្នកជំងឺ១០០នាក់) | % | ០,៣ | ០,៧ | ០,៥ | ០,៥ | ០,៥ | ០,៣ |
| | **៣- ជំងឺមិនឆ្លង** | | | | | | | |
| ១៦.២៦ | ប្រេវ៉ាឡង់ជំងឺលើសឈាមក្នុងចំណោមអាយុ២៥ ទៅ៦៤ឆ្នាំ | % | ១១,២ | ១១,២ | | | | |
| ១៦.២៧ | ប្រេវ៉ាឡង់ជំងឺទឹកនោមផ្អែមក្នុងចំណោមអាយុ ២៥ទៅ៦៤ឆ្នាំ | % | ២,៩ | ២,៩ | | | | |
| ១៦.២៨ | ស្ត្រីអាយុ៣០ទៅ៤៩ឆ្នាំ បានទទួលតេស្តរកមហារីកមាត់ស្បូនយ៉ាងតិចមួយដង | នាក់ | | ៣៨ ៦០០ | ៤២ ២៦០ | ៤៦ ៧១០ | ៥១ ៣៨០ | ៥៦ ៥២០ |
| ១៦.២៩ | ចំនួនករណីជំងឺមហារីកមាត់ស្បូន ធ្វើរោគវិនិច្ឆ័យថ្មីក្នុងចំណោមស្ត្រីអាយុ២៥ឆ្នាំ ចំនួន ១០០ ០០០នាក់ | ចាប់ពីអាយុ ២៥ឆ្នាំឡើង | | ៣០,៦ | ៣១,២ | ៣១,៨ | ៣២,៥ | ៣៣,១ |
| ១៦.៣០ | អត្រាប្រេវ៉ាឡង់នៃភាពពិការភ្នែក | % | ០,៣៨ | ០,៣៥ | ០,៣២ | ០,២៩ | ០,២៧ | ០,២៥ |
| ១៦.៣១ | អត្រាវះកាត់ជំងឺភ្នែកឡើងបាយ | ១០០ ០០០ នាក់ | ១ ២០០ | ១ ៣០០ | ១ ៥០០ | ១ ៧០០ | ១ ៩០០ | ២ ០០០ |
| ១៦.៣២ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ក្នុងចំណោមបុរសនិងស្ត្រី | % | ប្រ:៤២ ស្រ:១៧ | ប្រ:៤១ ស្រ:១៦ | ប្រ:៤០ ស្រ:១៥ | ប្រ:៣៩ ស្រ:១៤ | ប្រ:៣៨ ស្រ:១៣ | ប្រ:៣៧ ស្រ:១២ |
| ១៦.៣៣ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ជាតិអាល់កុលក្នុងចំណោមបុរសនិងស្ត្រី | % | ៥៣ | ៥២ | ៥២ | ៥១ | ៥០ | ៤៩ |
| ១៦.៣៤ | ចំនួនករណីមនុស្សពេញវ័យមានជំងឺផ្លូវចិត្តបានទទួលការព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | ១០ ០០០ នាក់ | ២៥ | ៣០ | ៣៥ | ៤០ | ៤៥ | ៥០ |
| ១៦.៣៥ | អ្នកញៀនសារជាតិ Opioid បានទទួលការព្យាបាល បន្សាប | % | ៣០ | ៥០ | ៦០ | >៦០ | >៦០ | >៦០ |
| ១៦.៣៦ | អត្រាស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ (ប្រជាជន ១០០ ០០០ នាក់) | ១០០ ០០០ នាក់ | <១១,៦០ | <១១,៦០ | <១១,៦០ | <១១,៦០ | <១១,៦០ | <១១,៦០ |
| | **៤- ពង្រឹងប្រព័ន្ធសុខាភិបាល** | | | | | | | |
| ១៦.៣៧ | មណ្ឌលសុខាភាព ដែលដាច់ស្តុកឱសថសារវន្ត ១៤មុខ | % | <៥ | <៥ | <៥ | <៥ | <៥ | <៥ |
| ១៦.៣៨ | ការផ្តល់ឈាមដោយអ្នកស្ម័គ្រចិត្តមិនទទួលផលកម្រៃ | % | ៥០ | ៥៥ | ៦០ | ៦៥ | ៧០ | ៧៥ |
| ១៦.៣៩ | ការពិគ្រោះជំងឺ(ករណីថ្មី) លើប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ប្រជាជនម្នាក់ ក្នុងមួយឆ្នាំ | ០,៦១ | ០,៦៥ | ០,៧០ | ០,៧៥ | ០,៨០ | ០,៨៥ |
| ១៦.៤០ | សន្ទស្សន៍នៃភាពពេញចិត្តរបស់អតិថិជនចំពោះសេវាសុខាភិបាល | % | ៨៦ | ៨៧ | ៨៧ | ៨៨ | ៨៨ | ៨៩ |
| ១៦.៤១ | ប្រជាជនរស់ក្រោមបន្ទាត់នៃភាពក្រីក្រត្រូវបានការពារដោយមូលនិធិសមធម៌ | % | ៨០ | ៩០ | ១០០ | ១០០ | ១០០ | ១០០ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ១៦.៤២ | មណ្ឌលសុខភាពដែលឆ្មបមធ្យមយ៉ាងតិចមួយនាក់ | % | ៧៥ | ៨៥ | ១០០ | ១០០ | ១០០ | ១០០ |
| ១៦.៤៣ | សន្ទស្សន៍នៃគុណភាពព័ត៌មានសុខាភិបាល | % | ៨៧ | ៩០ | ៩៣ | ៩៦ | ៩៨ | ១០០ |
| ១៦.៤៤ | គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដែលដំណើរការ | % | ៨០ | >៨៥ | >៨៥ | >៨៥ | >៨៥ | >៨៥ |
| | | | | | | | | |
| **១៧.០០** | **អប់រំ** | | **២០១២-១៣** | **២០១៣-១៤** | **២០១៤-១៥** | **២០១៥-១៦** | **២០១៦-១៧** | **២០១៧-១៨** |
| ១៧.០១ | ភាគរយកុមារអាយុ៥ឆ្នាំ ក្នុងការអប់រំកុមារតូចនៅគ្រប់រូបភាព | % | ៥៦,៥ | ៦២,០ | ៦៦,០ | ៧១,០ | ៧៥,០ | ៨០,០ |
| ១៧.០២ | សាលាបឋមសិក្សា (១-៦) | ចំនួន | ៦ ៩១០ | ៦ ៩១៥ | ៦ ៩៥១ | ៧ ០៧៣ | ៧ ៣០២ | ៧ ៦០៦ |
| | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| ១៧.០៣ | សរុប | % | ៩៧,០ | ៩៧,៣ | ៩៧,៩ | ៩៨,៦ | ៩៩,៣ | ១០០ |
| ១៧.០៤ | ប្រុស | % | ៩៧,០ | ៩៧,៥ | ៩៨,១ | ៩៩,៧ | ៩៩,៤ | ១០០ |
| ១៧.០៥ | ស្រី | % | ៩៧,០ | ៩៧,១ | ៩៧,៨ | ៩៨,០ | ៩៩,២ | ១០០ |
| ១៧.០៦ | ទីប្រជុំជន | % | ៨៩,៨ | ៩១,៨ | ៩៣,៩ | ៩៥,២ | ៩៧,៩ | ១០០ |
| ១៧.០៧ | ជនបទ | % | ៩៨,៦ | ៩៨,៩ | ៩៩,២ | ៩៩,៤ | ៩៩,៧ | ១០០ |
| | អត្រាសរុបនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| ១៧.០៨ | សរុប | % | ១២១,១ | ១១៩,២ | ១១៧,២ | ១១៥,៨ | ១១៥,២ | ១១៥,៥ |
| ១៧.០៩ | ប្រុស | % | ១២៣,១ | ១២១,៦ | ១១៨,២ | ១១៦,៤ | ១១៥,៥ | ១១៥,៤ |
| ១៧.១០ | ស្រី | % | ១១៩,០ | ១១៧,៧ | ១១៦,១ | ១១៥,២ | ១១៥,០ | ១១៥,៦ |
| | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | | |
| ១៧.១១ | សរុប | % | ៩១,៥ | ៩៨,៣ | ១០០ | ១០០ | ១០០ | ១០០ |
| ១៧.១២ | ប្រុស | % | ៩១,៩ | ៩៨,៧ | ១០០ | ១០០ | ១០០ | ១០០ |
| ១៧.១៣ | ស្រី | % | ៩១,០ | ៩៨,០ | ១០០ | ១០០ | ១០០ | ១០០ |
| ១៧.១៤ | ចំនួនសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ១ ៦២២ | ១ ៦៣២ | ១ ៦៤២ | ១ ៦៥២ | ១ ៦៦២ | ១ ៦៧២ |
| | អត្រាសរុបនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | |
| ១៧.១៥ | សរុប | % | ៥៦,៥ | ៦០,៤ | ៦៦,៩ | ៧៣,៧ | ៨១,៣ | ៨៧,៤ |
| ១៧.១៦ | ប្រុស | % | ៥៦,២ | ៦០,៤ | ៦៧,២ | ៧៤,៤ | ៨២,២ | ៨៨,៩ |
| ១៧.១៧ | ស្រី | % | ៥៦,៧ | ៦០,៣ | ៦៦,៥ | ៧៣,១ | ៨០,៤ | ៨៥,៩ |
| ១៧.១៨ | ទីប្រជុំជន | % | ៧៨,៤ | ៨០,៧ | ៨៤,៤ | ៨៨,២ | ៩២,៣ | ៩៤,៣ |
| ១៧.១៩ | ជនបទ | % | ៥២,៦ | ៥៦,៧ | ៦៣,៦ | ៧១,២ | ៧៩,២ | ៨៦,១ |
| | អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ | | | | | | | |
| ១៧.២០ | សរុប | % | ៤២,២ | ៤៤,៤ | ៦១,៦ | ៥៧,២ | ៦៧,៣ | ៧៦,៤ |
| ១៧.២១ | ប្រុស | % | ៤២,០ | ៤៤,០ | ៥១,៧ | ៥៧,៦ | ៦៧,៧ | ៧៧,២ |
| ១៧.២២ | ស្រី | % | ២៥,៥ | ២៧,៣ | ៣១,៦ | ៣៥,១ | ៤១,៦ | ៤៧,០ |
| ១៧.២៣ | ចំនួនសាលាមធ្យមសិក្សាទុតិយភូមិ | ចំនួន | ៤៣៣ | ៤៤៣ | ៤៥១ | ៤៩៨ | ៥៦៦ | ៦៦៨ |
| | អត្រាសរុបនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | |
| ១៧.២៤ | សរុប | % | ២៩,៨ | ២៩,៤ | ៣០,៨ | ៣៣,៩ | ៣៨,៤ | ៤៥,៣ |
| ១៧.២៥ | ប្រុស | % | ៣១,៩ | ៣១,៦ | ៣៣,១ | ៣៦,១ | ៤១,១ | ៤៨,៥ |
| ១៧.២៦ | ស្រី | % | ២៧,៦ | ២៧,២ | ២៨,៤ | ៣១,៥ | ៣៥,៦ | ៤១,៩ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ១៧.២៧ | ចំនួនវិទ្យាល័យបច្ចេកទេស | ចំនួន | ៤ | ៤ | ៥ | ៥ | ៦ | ៧ |
| ១៧.២៨ | ចំនួនសិស្សនៅមធ្យមសិក្សាបច្ចេកទេស | ចំនួន | ៧៣០ | ៩៨៤ | ១ ២៣៨ | ១ ៤៩២ | ១ ៧៤៦ | ២ ០០០ |
| ១៧.២៩ | អត្រាអក្ខរជន(១៥-២៤ ឆ្នាំ) | % | ៩១,៥ | ៩២,៥ | ៩៣,៥ | ៩៤,៥ | ៩៥,៥ | ៩៦,៥ |
| ១៧.៣០ | អត្រាអក្ខរជន(១៥-៤៥ឆ្នាំ) | % | | ៨៧,៧ | ៨៨,៤ | ៨៩,១ | ៨៩,៨ | ៩០,៥ |
| | | | | | | | | |
| ១៨.០០ | **កម្មវិធីសម្អាតមីន** | | | | | | | |
| ១៨.០១ | ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ(ស្លាប់/របួស) | នាក់ | ១៦៧ | ១៥១ | ១៣៦ | ១២២ | ១១០ | ៩៩ |
| ១៨.០២ | ចំនួនជនរងគ្រោះដោយសារការលេងនិងថ្មៃគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ (ស្លាប់/របួស) | នាក់ | ១១២ | ៩៩ | ៨៦ | ៧៣ | ៦០ | ៤៨ |
| ១៨.០៣ | ផ្ទៃដីសរុបបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម(ផ្អែកលើលទ្ធផលពីការស្រាវជ្រាវមូលដ្ឋាន) | ហ.ត. | ៨ ៧០៨ | ៩ ១៤៣ | ៩ ៦០០ | ១០ ០៨០ | ១០ ៥៨៤ | ១១ ១១៣ |
| | | | | | | | | |

# មាតិកា

ទំព័រ

**អារម្ភកថា** ........ i

**សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា** ........ vi

**ព័ត៌មានសង្ខេបសំខាន់ៗស្ដីពីព្រះរាជាណាចក្រកម្ពុជា** ........ vii

**មាតិកា** ........ xvi

**បញ្ជីនៃតារាង រូបភាព ប្រអប់ និងឧបសម្ព័ន្ធ** ........ xx

**ជំពូកទី១ សេចក្ដីផ្ដើម** ........ ១

១- ប្រវត្តិដើម ........ ១

២- ការពិនិត្យឡើងវិញពីផែនការអភិវឌ្ឍន៍នៅកម្ពុជា ........ ១

៣- យុទ្ធសាស្ត្រចតុកោណ ........ ៣

៤- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៤-២០១៨ ........ ៦

៥- ទម្រង់នៃផ.យ.អ.ជ. ២០១៤-២០១៨ ........ ៨

**ជំពូកទី២ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្តផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣** ........ ៩

ការកាត់បន្ថយភាពក្រីក្រ ........ ៩

អត្រាភាពក្រីក្រនៅថ្នាក់ក្រោមជាតិ ........ ១០

**១- អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ** ........ **១២**

១.១- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ........ ១២

១.២- កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ........ ១៤

១.៣- កំណែទម្រង់រដ្ឋបាលសាធារណៈ ........ ១៩

១.៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ........ ២៥

**២- បរិស្ថានគ្របដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល** ........ **២៧**

២.១- សុខសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គម ........ ២៧

២.២- សមាហរណកម្មប្រទេសកម្ពុជាក្នុងតំបន់និងពិភពលោក ........ ៣២

២.៣- បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ ........ ៣៤

២.៤- ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ ........ ៤០

**៣- ការលើកស្ទួយវិស័យកសិកម្ម ............ ៤២**

៣.១- ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម............ ៤២

៣.២- កំណែទម្រង់ដីធ្លីនិងការបោសសម្អាតមីន............ ៤៩

៣.៣- កំណែទម្រង់ជលផល............ ៥៥

៣.៤- កំណែទម្រង់ព្រៃឈើ............ ៥៧

**៤- ការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត............ ៦៩**

៤.១- ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍............ ៧០

៤.២- ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ............ ៧៦

៤.៣- ការអភិវឌ្ឍវិស័យថាមពល និងបណ្តាញអគ្គិសនី............ ៨០

៤.៤- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍............ ៨២

**៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ............ ៨៥**

៥.១- ការពង្រឹងវិស័យឯកជននិងការទាក់ទាញវិនិយោគ............ ៨៥

៥.២- ការបង្កើតការងារនិងធានាលក្ខខណ្ឌការងារល្អប្រសើរ............ ៩៥

៥.៣- ការលើកស្ទួយសហគ្រាសធនតូចនិងមធ្យម............ ១០០

៥.៤- ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម............ ១០៥

**៦- ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស............ ១១៥**

៦.១- ការពង្រឹងគុណភាពវិស័យអប់រំ............ ១១៥

៦.២- ការលើកកម្ពស់វិស័យសុខាភិបាល............ ១១៩

៦.៣- ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ............ ១២៨

៦.៤- ការអនុវត្តគោលនយោបាយជាតិប្រជាជន............ ១៣៣

**ជំពូកទី៣ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ............ ១៣៧**

១- សេចក្តីផ្តើម............ ១៣៧

២- ការសម្រេចបាន ក្នុងអំឡុងពេល ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៣............ ១៣៧

៣- ចំណុចដៅនិងគោលនយោបាយសម្រាប់ឆ្នាំ២០១៤-២០១៨............ ១៤៨

បញ្ហានានាដែលត្រូវបន្តដោះស្រាយ............ ១៤៨

ទិសដៅទូទៅនៃគោលនយោបាយ ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣............ ១៥០

ក្របខ័ណ្ឌលទ្ធផល............ ១៥២

គោលនយោបាយសារពើពន្ធ............ ១៥៤

គោលនយោបាយ និងការវាស់វែងពីការអនុវត្ត............ ១៥៥

គោលនយោបាយរូបិយវត្ថុ និងយុទ្ធសាស្ត្រវិស័យហិរញ្ញវត្ថុ............ ១៥៨

ការអភិវឌ្ឍវិស័យអាជីវកម្ម ............ ១៦២

វិមជ្ឈការនិងវិសហមជ្ឈការ............ ១៦៥

ទស្សនវិស័យសេដ្ឋកិច្ច ២០១៤-២០១៨............ ១៦៧

ចំណូលនិងចំណាយថវិកាឆ្នាំ២០១៤-២០១៨............ ១៧២

**ជំពូកទី៤ គោលនយោបាយនិងសកម្មភាពអាទិភាព ២០១៤-២០១៨**............ **១៧៦**

**១- អភិបាលកិច្ចល្អ៖ ស្នូលនៃយុទ្ធសាស្ត្រចតុកោណ**............ **១៧៩**

១.១- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ............ ១៧៩

១.២- កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌............ ១៨៤

១.៣- កំណែទម្រង់រដ្ឋបាលសាធារណៈ............ ១៨៦

១.៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ............ ១៩១

**២- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល**............ **១៩៣**

២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ............ ១៩៣

២.២- បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និងចីរភាពបរិស្ថាន............ ១៩៩

២.៣- ភាពជាដៃគូក្នុងការអភិវឌ្ឍ............ ២០៦

២.៤- សមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅនៅក្នុងតំបន់ និងពិភពលោក............ ២០៨

**៣- ការលើកស្ទួយវិស័យកសិកម្ម**............ **២១០**

៣.១- ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្ម............ ២១០

៣.២- ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម............ ២១៧

៣.៣- កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម............ ២២២

៣.៤- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព............ ២២៨

**៤- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**............ **២៤៩**

៤.១- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង............ ២៤៩

៤.២- ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ........ ២៥៧

៤.៣- ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី........ ២៦៨

៤.៤- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍........ ២៧១

**៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ........ ២៨១**

៥.១- ការពង្រឹងវិស័យឯកជន និងការជំរុញការវិនិយោគ និងធុរកិច្ច........ ២៨១

៥.២- ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម........ ២៨៩

៥.៣- ការអភិវឌ្ឍទីផ្សារការងារ........ ២៩៤

៥.៤- ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ........ ៣០២

**៦- ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស........ ៣០៥**

៦.១- ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស........ ៣០៦

៦.២- ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ........ ៣១៥

៦.៣ - ការអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពសង្គម........ ៣៣៨

៦.៤- ពង្រឹងការអនុវត្តគោលនយោបាយប្រជាជន និងសមភាពយេនឌ័រ........ ៣៤៨

**ជំពូកទី៥ តម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ**........ ៣៥៧

១-តម្រូវការវិនិយោគសាធារណៈសរុប........ ៣៥៧

២-ប្រភពហិរញ្ញប្បទានសក្តានុពលសម្រាប់ចំណាយវិនិយោគសាធារណៈ........ ៣៦២

៣-កម្មវិធីចំណាយ ចំណាយវិនិយោគសាធារណៈ និងហិរញ្ញប្បទានសហប្រតិបត្តិការ........ ៣៦៤

**ជំពូកទី៦ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**........ ៣៦៨

១-សេចក្តីផ្តើម........ ៣៦៨

២- ក្របខ័ណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ក្នុងវដ្តផែនការ ២០១៤-២០១៨........ ៣៦៨

៣- ភាពប្រឈមទាក់ទងនឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ........ ៣៨០

៤- ការរៀបចំនិងពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ........ ៣៨១

**ជំពូកទី៧ សេចក្តីសន្និដ្ឋាន**........ ៤០៥

# បញ្ជីនៃតារាង រូបភាព ប្រអប់ និងឧបសម្ព័ន្ធ

## តារាង


| | | |
|---|---|---|
| តារាងទី២.១ | កំណើនផលិតកម្មដំណាំស្រូវពីឆ្នាំ២០០៩-២០១២.................................................... | ៤៣ |
| តារាងទី២.២ | ផ្ទៃដីដាំដុះដំណាំដូរសំខាន់ៗ៤មុខ................................................................... | ៤៣ |
| តារាងទី២.៣ | ស្ថិតិទាក់ទងនឹងការរំដោះផ្ទៃដីមានមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម............................ | ៥៥ |
| តារាងទី២.៤ | ស្ថិតិផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្មពីឆ្នាំ២០០៩-២០១២.......................... | ៥៦ |
| តារាងទី២.៥ | សូចនាករសំខាន់ៗអំពីការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ.................................. | ៦០ |
| តារាងទី២.៦ | វឌ្ឍនភាពនៃការអភិវឌ្ឍជនបទ........................................................................... | ៦៩ |
| តារាងទី២.៧ | សូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឆ្នាំ២០០៩-២០១៣......................................... | ៩២ |
| តារាងទី២.៨ | អត្រាការសិក្សានិងអត្រាបញ្ចប់ការសិក្សា.............................................................. | ១១៩ |
| តារាងទី២.៩ | និន្នាការនៃសូចនាករកម្មវិធីសុខភាពបន្តពូជ មាតា ទារក កុមារ រវាងឆ្នាំ២០០៨និង២០១៣ | ១២០ |
| តារាងទី២.១០ | និន្នាការនៃការវិភាជន៍ថវិកាជាតិសម្រាប់វិស័យសុខាភិបាលពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២.. | ១២៦ |
| តារាងទី២.១១ | ភាគរយស្ត្រីធ្វើការងារមានប្រាក់កម្រៃតាមវិស័យ...................................................... | ១២៩ |
| តារាងទី៣.១ | ការព្យាករសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០១៣-២០១៨............................... | ១៦៩ |
| តារាងទី៣.២ | ផលិតផលក្នុងស្រុកសរុបពិត (ថ្លៃថេរឆ្នាំ២០០០) អត្រាកំណើនតាមសកម្មភាពសេដ្ឋកិច្ច ឆ្នាំ២០១៤-២០១៨...................................................................................... | ១៧០ |
| តារាងទី៣.៣ | វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយ ដើម្បីសម្រេចបាននូវកំណើនផ.ស.ស..... | ១៧១ |
| តារាងទី៣.៤ | ចំណាយថវិកាចរន្តដែលបានស្នើឡើងសម្រាប់ក្រសួង ស្ថាប័នមួយចំនួន ឆ្នាំ២០១៤-២០១៨...................................................................................... | ១៧៤ |
| តារាងទី៤.១ | ផ្ទៃដីកៅស៊ូពីឆ្នាំ២០១២-២០១៨.......................................................................... | ២២០ |
| តារាងទី៤.២ | ផ្ទៃដីចៀរជ័រ ថែទាំ និងទិន្នផលកៅស៊ូឆ្នាំ២០១២-២០១៨............................................ | ២២០ |
| តារាងទី៤.៣ | សូចនាករសំខាន់ៗរបស់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ.................................. | ២២១ |
| តារាងទី៤.៤ | សូចនាករស្តីពីមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម...................................................... | ២២៨ |
| តារាងទី៤.៥ | សូចនាករសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទ...................................................... | ២៤៨ |
| តារាងទី៤.៦ | ចំណុចដៅនៃការពង្រីកសេវាកម្មប្រៃសណីយ៍........................................................... | ២៧៦ |
| តារាងទី៤.៧ | ចំណុចដៅនៃការពង្រីកសេវាកម្មទូរគមនាគមន៍........................................................ | ២៧៧ |
| តារាងទី៤.៨ | សូចនាករសំខាន់ៗរបស់ក្រសួងព័ត៌មាន................................................................. | ២៧៩ |
| តារាងទី៤.៩ | សូចនាករសំខាន់ៗរបស់វិស័យពាណិជ្ជកម្ម.............................................................. | ២៨៤ |
| តារាងទី៤.១០ | សូចនាករវិស័យទេសចរណ៍សំខាន់ៗ..................................................................... | ២៨៧ |

| | | |
|---|---|---|
| តារាងទី៤.១១ | សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និងកីឡា............... | ៣១៤ |
| តារាងទី៤.១២ | សូចនាករសំខាន់ៗនិងចំណុចដៅរបស់វិស័យសុខាភិបាល......................................... | ៣៣១ |
| តារាងទី៤.១៣ | សូចនាករស្នូលសម្រាប់ការបញ្ជ្រាបយេនឌ័រ ឆ្នាំ២០១៤-២០១៨................................. | ៣៥៦ |
| តារាងទី៥.១ | វិនិយោគមូលធនដែលត្រូវការចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស.ដែលបានគ្រោងទុក និងធនធានដែលអាចមានសម្រាប់ហិរញ្ញប្បទានដល់ឆ្នាំ២០១៤-២០១៨........ | ៣៥៩ |
| តារាងទី៥.២ | ចំណុចដៅនៃការកៀរគរធនធានសម្រាប់វិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៤-២០១៨............................................................................................ | ៣៦១ |
| តារាងទី៥.៣ | វិភាជន៍តាមវិស័យនិងអនុវិស័យនៃវិនិយោគវិស័យសាធារណៈក្នុងផ.យ.អ.ជ. ២០១៤-២០១៨.................................................................................... | ៣៦៧ |
| តារាងទី៦.១ | រចនាសម្ព័ន្ធសូចនាករសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ............................ | ៣៧៥ |
| តារាងទី៦.២ | សូចនាករស្នូលសម្រាប់ការតាមដានត្រួតពិនិត្យនៃផ.យ.អ.ជ. ២០១៤-២០១៨ | ៣៨៣ |
| តារាងទី៦.៣ | សូចនាករបន្ថែម................................. ........................................................ | ៣៩៣ |
| តារាងទី៦.៤ | បញ្ជីការសិក្សាសម្រាប់វិស័យអាទិភាពចំនួនបី........................................................ | ៤០២ |
| តារាងទី៦.៥ | សូចនាករជ្រើសរើសនៅថ្នាក់ក្រោមជាតិ...... ..................................................... | ៤០៣ |


## រូបភាព


| | | |
|---|---|---|
| រូបភាពទី១.១ | គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣................................................ | ៥ |
| រូបភាពទី២.១ | និន្នាការអត្រាភាពក្រីក្រនៅកម្ពុជា ពីឆ្នាំ២០០៧ដល់ឆ្នាំ២០១១.................................... | ១០ |
| រូបភាពទី២.២ | អត្រាភាពក្រីក្រតាមខេត្ត ឆ្នាំ២០១១.......................................................................... | ១១ |
| រូបភាពទី៣.១ | អត្រាកំណើននៃផលិតផលក្នុងស្រុកសរុប ឆ្នាំធៀបនឹងឆ្នាំ (២០០៦-២០១២)................. | ១៣៩ |
| រូបភាពទី៣.២ | និន្នាការចំណូលនិងចំណាយ គិតជាភាគរយនៃផ.ស.ស. ឆ្នាំ២០០៥-២០១២.................. | ១៤០ |
| រូបភាពទី៣.៣ | អត្រាអតិផរណានៅកម្ពុជា គិតតាមត្រីមាស ឆ្នាំ២០០៦-២០១២................................ | ១៤២ |
| រូបភាពទី៣.៤ | តុល្យភាពពាណិជ្ជកម្ម និងគណនេយ្យចរន្ត.............................................................. | ១៤៣ |
| រូបភាពទី៣.៥ | ពាណិជ្ជកម្មនាំចូល-នាំចេញ ធៀបនឹងផ.ស.ស........................................................... | ១៤៤ |
| រូបភាពទី៣.៦ | និន្នាកាភាពក្រីក្រនៅកម្ពុជា តាមតំបន់ ឆ្នាំ២០០៧-២០១១........................................ | ១៤៧ |
| រូបភាពទី៣.៧ | រចនាសម្ព័ន្ធនៃកម្លាំងពលកម្ម (១៥-៦៤ឆ្នាំ) តាមវិធីសាស្ត្ររំលឹក (Usual Status) ឆ្នាំ២០០៩-២០១១.............................................................................................. | ១៤៨ |
| រូបភាពទី៦.១ | សង្វាក់លទ្ធផលៈ ធាតុចូល ធាតុចេញ លទ្ធផល ឥទ្ធិពល............................................ | ៣៧០ |
| រូបភាពទី៦.២ | រចនាសម្ព័ន្ធកម្មវិធី និងគោលបំណង កម្រិតក្រសួង ស្ថាប័ន......................................... | ៣៧១ |


## ប្រអប់


| | | |
|---|---|---|
| ប្រអប់ទី២.១ | ខ្សែបន្ទាត់ភាពក្រីក្រ.............................................................................................. | ៩ |

ប្រអប់ទី២.២ ការគណនាអត្រាភាពក្រីក្រជំនួសនៅថ្នាក់រាជធានី ខេត្ត................................................ ១១
ប្រអប់ទី ៣.១ ក្របខ័ណ្ឌលទ្ធផលៈ បរិយាប័ន្ននិងចីរភាពកំណើន ដើម្បីកាត់បន្ថយភាពក្រីក្រ................... ១៥២

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ពាក្យបំប្រួញ......... ........................................................................................ ៤០៩
ឧបសម្ព័ន្ធទី២ គេហទំព័រ ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល...................................................... ៤១១

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១- ប្រវត្តិដើម

១.១- ក្នុងរយៈពេល២ទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការអភិវឌ្ឍប្រទេសជាតិឡើងវិញ ពីប្រទេសជាតិដែលត្រូវបានបំផ្លិចបំផ្លាញដោយសារសង្គ្រាមស៊ីវិល សេដ្ឋកិច្ចឯកោនិងការហ៊ុមព័ទ្ធ ក្នុងចន្លោះពីទសវត្សរ៍ឆ្នាំ១៩៧០ដល់ឆ្នាំ១៩៩៣។ បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ***គោលនយោបាយឈ្នះៈឈ្នះ*** សន្តិភាពពេញលេញត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៨ ដោយបានបញ្ចប់រាល់នូវអង្គការចាត់តាំងរបស់ខ្មែរក្រហម។ នៅក្នុងគ្រានោះ ដោយផ្អែកលើការផ្សះផ្សាជាតិក្នុងចំណោមភាគីជម្លោះ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩១ ហើយបន្ទាប់មក ការបោះឆ្នោតសកលលើកទី១ត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ១៩៩៣។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសនិងជំនួយអភិវឌ្ឍន៍ផ្លូវការ បានចាប់ផ្តើមពីឆ្នាំ១៩៩៣។ នៅក្នុងអំឡុងឆ្នាំ១៩៩០ ដល់ឆ្នាំ២០០០ អាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការកសាងសង្គម សេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសឡើងវិញ។ នៅក្នុងអំឡុងឆ្នាំ២០០០ ប្រទេសជាតិបានចាប់ផ្តើមរៀបចំផែនការអភិវឌ្ឍន៍ជាតិក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ។

១.២- កម្ពុជាត្រូវបានអង្គការសហប្រជាជាតិចាត់ចំណាត់ថ្នាក់ជាប្រទេសដែលមានការអភិវឌ្ឍតិចតួច។ ចាប់ផ្តើមពីឆ្នាំ២០១២ ចំណូលផ.ស.ស. ជាមធ្យមរបស់ប្រជាជនម្នាក់ៗមានកម្រិតលើស១ ០០០ដុល្លារអាមេរិក។ ចំណូលនេះបានកើនឡើងជិត៥ដងនៃចំណូលផ.ស.ស. របស់ប្រជាជនម្នាក់ៗកាលពីមួយទសវត្សរ៍កន្លងទៅ ដែលជាភស្តុតាងបង្ហាញពីភាពជោគជ័យនៃការអភិវឌ្ឍក្រោមកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជា។ តាមរយៈនិន្នាការកើនឡើងនេះ កម្ពុជាអាចចាកចេញពីបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួចក្នុងរយៈពេលដ៏ខ្លីខាងមុខ។

## ២- ការពិនិត្យឡើងវិញពីផែនការអភិវឌ្ឍន៍នៅកម្ពុជា

១.៣- ក្នុងឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវទស្សនវិស័យរយៈពេលវែងមួយគឺ *កម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* សម្រាប់ការផ្តួចផ្តើមដំណើរការស្តារនិងការអភិវឌ្ឍ

ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គម និងស្ថាប័ន។ ផ្អែកលើទស្សនវិស័យនេះ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច(ផ.អ.ស.ស.) ៥ឆ្នាំលើកទី១ ១៩៩៦-២០០០* ត្រូវបានរៀបចំឡើងដោយបានកំណត់គោលដៅយ៉ាងច្បាស់លាស់និងត្រូវសម្រេចឲ្យបាននៅឆ្នាំ២០០០។ ផែនការនេះបានផ្តោតជាសំខាន់លើកំណើនម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ក្នុងពេលជាមួយគ្នានោះដែរ *កម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.)បីឆ្នាំរំកិល* ត្រូវបានរៀបចំឡើងសម្រាប់ឆ្នាំ១៩៩៦-១៩៩៨ ដើម្បីឲ្យធនធានក្នុងស្រុកនិងធនធានបានមកពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្រៅប្រទេស អាចត្រូវបានយកទៅប្រើប្រាស់ទៅតាមវិស័យអាទិភាពនានាដើម្បីសម្រេចឲ្យបាននូវគោលដៅដែលបានកំណត់នៅក្នុងផែនការ។ ចាប់តាំងពីពេលនោះមក *ក.វ.ស.* ត្រូវបានធ្វើបច្ចុប្បន្នកម្ម(រំកិល)ជារៀងរាល់ឆ្នាំ។

**១.៤-** *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច(ផ.អ.ស.ស.) ៥ឆ្នាំលើកទី២ ២០០១-២០០៥* ត្រូវបានរៀបចំឡើងដោយផ្តោតលើកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ។ សម្រាប់រាជរដ្ឋាភិបាលកម្ពុជា បញ្ហាប្រឈមធំបំផុតនៅក្នុងការអភិវឌ្ឍនោះគឺការអភិវឌ្ឍវិស័យឯកជនដែលជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច៖ ការកែប្រែសេដ្ឋកិច្ចនិងការសម្រេចឲ្យបានការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការធ្វើឲ្យប្រសើរឡើងសុខុមាលភាពរបស់ប្រជាជន។ បន្ទាប់ពីការរៀបចំ *ផ.អ.ស.ស. លើកទី២* ឯកសារអភិវឌ្ឍន៍សំខាន់ចំនួនពីរ ត្រូវបានរៀបចំឡើងគឺ *ទី១* បន្ទាប់ពីមហាសន្និបាតរបស់អង្គការសហប្រជាជាតិឆ្នាំ២០០០ ដែលបានប្រកាសពី *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(គ.អ.ស.)* កម្ពុជាបានរៀបចំនិងអនុម័ត *គ.អ.ស.* ផ្ទាល់ខ្លួនមានឈ្មោះថា *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(គ.អ.ស.ក.)* ដោយបានផ្តោតលើការលុបបំបាត់ភាពក្រីក្រនិងការអភិវឌ្ឍមនុស្ស *ទី២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* ដែលបានអនុម័តនៅក្នុងខែធ្នូ ឆ្នាំ២០០២។ ចាប់ពីពេលនោះមក ការសម្រេច *គ.អ.ស.ក.* និងការកាត់បន្ថយភាពក្រីក្រ ត្រូវបានចាត់ទុកថាជាចំណុចស្នូលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់កម្ពុជា។

**១.៥-** ឯកសារផែនការអភិវឌ្ឍន៍ប្រាំឆ្នាំលើកទី៣សម្រាប់ឆ្នាំ២០០៦-២០១០ ត្រូវបានរៀបចំឡើងដោយបានរួមបញ្ចូលគ្នានូវឯកសារគោលនយោបាយជាតិនានា ដើម្បីសម្រេចឲ្យបានគោលដៅអាទិភាព ចំណុចដៅ និងសកម្មភាព សម្រាប់រយៈពេលប្រាំឆ្នាំបន្ទាប់។ ផែនការថ្មីត្រូវបានប្តូរឈ្មោះជា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០០៦*-២០១០និងជាផែនការជាតិតែមួយគត់ដែលគ្របដណ្តប់គ្រប់វិស័យសម្រាប់អនុវត្តរបៀបវារៈ *គោលនយោបាយរបស់រាជរដ្ឋាភិបាល* និង *យុទ្ធសាស្ត្រចតុកោណដែលជាយុទ្ធសាស្ត្របន្តពីយុទ្ធសាស្ត្រត្រីកោណ*។ រាជរដ្ឋាភិបាលកម្ពុជា

សម្រាប់នីតិកាលទី៣នៃរដ្ឋសភា បានបង្កើតឡើងនូវបរិស្ថានអនុគ្រោះនិងលក្ខខណ្ឌចាំបាច់ នានាដើម្បីឲ្យកម្ពុជាមានលទ្ធភាពបោះជំហានទៅមុខលើមាគ៌ាដែលអាចបន្តការកែទម្រង់និងវឌ្ឍនភាព។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវគោលការណ៍ឯកភាពជាតិប្រមូលផ្តុំនូវប្រជារាស្ត្រពីគ្រប់មជ្ឈដ្ឋានទាំងអស់នៅក្រោមបាវចនា *"ជាតិ សាសនា ព្រះមហាក្សត្រ"*ដើម្បីកសាងជាតិ និងធានានូវឯករាជ្យភាពជាតិ បូរណភាព អធិបតេយ្យភាព សន្តិភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាព។

**១.៦-** បន្ទាប់ពីការបោះឆ្នោតសកលឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីកម្មវិធីគោលនយោបាយសង្គម សេដ្ឋកិច្ចរបស់ខ្លួន សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ឆ្នាំ២០០៨-២០១៣។ ជាមួយនឹងកម្មវិធីនយោបាយនេះ ផែនការជាតិថ្មីមួយត្រូវបានរៀបចំឡើងដើម្បីជំនួស*ផ.យ.អ.ជ. ២០០៦-២០១០* និងដើម្បីបន្ស៊ីដំណើរការនៃការរៀបចំផែនការជាមួយនឹងអាណត្តិកាលរបស់រាជរដ្ឋាភិបាល។ ផែនការថ្មីនេះមានឈ្មោះថា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) បច្ចុប្បន្នកម្ម ២០០៩-២០១៣* និងជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបានប្រកាសផ្សព្វផ្សាយចំពេលដែលកើតមានវិបត្តិហិរញ្ញវត្ថុសកលលោក និងនៅពេលដែលសេដ្ឋកិច្ចនៃបណ្តាប្រទេសជឿនលឿនមានការធ្លាក់ចុះ(ចាប់ផ្តើមពីឆ្នាំ២០០៨ដល់ឆ្នាំ២០០៩ ដែលធ្វើឲ្យតម្រូវការផលិតផលសម្រាប់នាំចេញពីកម្ពុជាមានការថយចុះ ម៉្យាងទៀត ក៏បានធ្វើឲ្យហានិភ័យក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានការកើនឡើងផងដែរ។ បញ្ហានេះក៏បានបង្កើតឲ្យមានផងដែរនូវបញ្ហាមួយចំនួនដែលមិនរំពឹងទុកសម្រាប់កម្ពុជា ដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការថយចុះនៃសេដ្ឋកិច្ចពិភពលោក។ វិធីសាស្ត្ររៀបចំផែនការបង្ហាញនៅក្នុង*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបានរៀបចំកំណត់ច្បាស់ ដើម្បីធ្វើការអភិវឌ្ឍប្រទេសជាតិបញ្ចៀសពីការប្រឈមនឹងវិបត្តិនិងមិនទាន់មានការអភិវឌ្ឍ។

## ៣- យុទ្ធសាស្ត្រចតុកោណ

**១.៧-** រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើងនូវ*"យុទ្ធសាស្ត្រចតុកោណ"* ដែលជាការកំណត់ពីការអភិវឌ្ឍតាំងពីឆ្នាំ២០០៤មក។ *ផ.យ.អ.ជ. ២០០៦-២០១០* ត្រូវបានរៀបចំដើម្បីអនុវត្តរបៀបវារៈគោលនយោបាយដែលបានកំណត់នៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១* ហើយ*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម* ដើម្បីអនុវត្តរបៀបវារៈគោលនយោបាយដែលបានកំណត់នៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២*។ ដូចគ្នានេះដែរ*ផ.យ.អ.ជ. ២០១៤-២០១៨* នេះ ត្រូវ

បានរៀបចំឡើងដើម្បីអនុវត្តរបៀបវារៈគោលនយោបាយដែលបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* ដែលត្រូវបានផ្សព្វផ្សាយនៅក្នុងខែកញ្ញា ឆ្នាំ២០១៣។ យុទ្ធសាស្ត្រចតុកោណបានផ្តល់នូវក្របខ័ណ្ឌនៃការអភិវឌ្ឍ ដែលនឹងត្រូវបានអនុវត្តនៅក្នុងរយៈពេល៥ឆ្នាំបន្ទាប់។

១.៨- *យុទ្ធសាស្ត្រចតុកោណ* គឺជាឯកសារជរភាព ដែលបានបង្ហាញនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច នៅក្នុងរយៈពេល៥ឆ្នាំខាងមុខ។ យុទ្ធសាស្ត្រចតុកោណ ត្រូវបានធ្វើបច្ចុប្បន្នកម្មចំនួនបីលើកនៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះដើម្បីអនុវត្តតាមតម្រូវការជាក់ស្តែង។ រូបភាពទី១.១ បង្ហាញពីគំនូសបំប្រួញនៃ ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣***។ រូបភាពនេះបង្ហាញពីយុទ្ធសាស្ត្រចតុកោណ បានដាក់បញ្ចូលនូវចំណុចគន្លឹះសំខាន់ៗ ដូចជា អភិបាលកិច្ចល្អវិធានការច្បាប់និងការពង្រឹងសមត្ថភាពស្ថាប័នដោយអនុវត្តតាមគំរូប្រទេសជឿនលឿនដែលមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ធនធានមនុស្ស និងការគ្រប់គ្រងប្រកបដោយចីរភាពនូវធនធានធម្មជាតិ ដែលចំណុចទាំងអស់នេះមានដាក់បញ្ចូលក្នុងចង្កោមមុំនៃចតុកោណ។

**រូបភាពទី១.១ : គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**




**១.៩-** នៅក្នុងរូបបំព្រួញនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ បានបង្ហាញពីការដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ៤យ៉ាង ដែលស្តែងចេញតាមរយៈបាវចនា *កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព*និងសម្រាប់បន្តជំរុញដំណើរការអភិវឌ្ឍន៍៖

*ទី១* ធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឲ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណា

មានកម្រិតទាបអាចគ្រប់គ្រងបាន អត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ។

*ទី២* បង្កើតការងារឲ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ជាពិសេស សម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អនិងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការទាក់ទាញ និងការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគទាំងវិនិយោគក្នុងប្រទេសទាំងវិនិយោគមកពីក្រៅប្រទេស។

*ទី៣* សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

*ទី៤* បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង។

**១.១០-** ភាគច្រើននៃសមាសភាគរបស់*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* មានភាពប្រទាក់ក្រឡាជាមួយគ្នា សម្រាប់ធ្វើឲ្យសម្រេចបានកំណើនប្រកបដោយចីរភាពនិងការសម្រេចបាន*គ.អ.ស.ក.* និងគោលដៅផ្សេងទៀត។

## ៤- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៤-២០១៨

**១.១១-** *ផ.យ.អ.ជ. ២០១៤-២០១៨* ដែលអ្នករៀបចំផែនការនិងអ្នកដែលមានចំណែកពាក់ព័ន្ធនានា បានរៀបចំឡើងនេះ គឺបានពិនិត្យលើភាពប្រឈមមួយចំនួន ដូចខាងក្រោម៖

១- កំណើនសេដ្ឋកិច្ចកម្ពុជាដែលធ្វើឲ្យសម្រេចបានផ.ស.ស. សម្រាប់មនុស្សម្នាក់មានកម្រិតលើស១ ០០០ដុល្លារអាមេរិកបាន និងកំពុងនាំឲ្យកម្ពុជាចាកចេញពីប្រទេសមានការអភិវឌ្ឍតិចតួចទៅជាប្រទេសចំណូលមធ្យមកម្រិតទាបនៅពេលឆាប់ៗនេះ។ ប៉ុន្តែទន្ទឹមនឹងវឌ្ឍនភាពដ៏ត្រចះត្រចង់នេះ កម្ពុជានឹងទទួលបានបរិមាណជំនួយឥតសំណងតិចជាងមុន និងទាមទារកម្ពុជាខិតខំរកកម្ចីឥណទានមកបំពេញតម្រូវការអភិវឌ្ឍ។ លើសពីនេះ កម្ពុជានឹងខិតខំបន្ថែមទៀតសម្រាប់រកប្រភពចំណូលផ្សេងៗទៀតទាំងក្នុងប្រទេសទាំងក្រៅប្រទេស ដើម្បីផ្តល់ហិរញ្ញប្បទានដល់ផែនការវិនិយោគក្នុងវិស័យសាធារណៈ។ ក្នុងពេលជាមួយគ្នា កម្ពុជាត្រូវការពង្រឹងនូវការគ្រប់គ្រងចំណាយនិងការប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធភាព។ បញ្ហាសំខាន់ទាំងនេះ ទាមទារឲ្យមានការសម្រេចឲ្យបានឆាប់

ដោយសារពេលវេលាខ្លី សម្រាប់កម្ពុជាឈានទៅសម្រេចគោលដៅជាក្រុមប្រទេសដែល "**មានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលកម្រិតខ្ពស់ ក្នុងឆ្នាំ២០៥០**"។

២- បច្ចុប្បន្ននេះ សេដ្ឋកិច្ចពិភពលោកនៅមិនទាន់មានភាពច្បាស់លាស់និងចាកចេញផុតពីវិបត្តិហិរញ្ញវត្ថុសកលលោកនៅឡើយ ដែលបន្តជះឥទ្ធិពលមកលើដំណើរការធ្វើសមាហរណកម្មរបស់កម្ពុជាទៅក្នុងតំបន់និងពិភពលោក។ ចំណុចសំខាន់មួយទៀតវិបត្តិដែលបានកើតឡើងនៅក្នុងឆ្នាំ២០០៩និងត្រូវបានស្តារឡើងវិញយ៉ាងឆាប់រហ័សក៏ដោយក៏នៅបន្តទាមទារឲ្យកម្ពុជាធ្វើការកំណត់យុទ្ធសាស្ត្រច្បាស់លាស់រួមទាំងការធ្វើពិពិធកម្មទីផ្សារទាំងការនាំចេញ និងការវិនិយោគដើម្បីរក្សាកំណើនប្រកបដោយចីរភាព។ ដៃគូជាដៃគូថ្មីក៏ត្រូវទាមទារឲ្យមានការអនុវត្តតាមទម្រង់ថ្មីរួមទាំងការគ្រប់គ្រងស្ថាប័នប្រកបដោយភាពច្បាស់លាស់បំផុត។

៣- កម្ពុជានឹងធ្វើសមាហរណកម្មពេញលេញទៅក្នុងសមាគមអាស៊ាននៅឆ្នាំ២០១៥ ក្នុងពេលនោះ របាំងជាច្រើនរវាងប្រទេសជាសមាជិកនានានឹងត្រូវលុបបំបាត់។ រាជរដ្ឋាភិបាលពិនិត្យនិងត្រៀមជាស្រេចលំហូរចេញនិងចូលនៃពលករដែលមានជំនាញ មូលធន និងកម្រិតអត្រាពន្ធស្មើគ្នា។ ដូច្នេះ បញ្ហាទាំងអស់នេះត្រូវបានលើកឡើងច្បាស់ៗនៅក្នុង *ផ.យ.អ.ជ. ២០១៤-២០១៨* ដូចជា ទីផ្សារពលកម្ម ការប្រើប្រាស់ដីធ្លី ចំណូលថវិកាជាដើម។

៤- អភិបាលកិច្ចល្អនៅតែបន្តជាចំណុចស្នូលនៃ ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣*** ។ ទោះជាដូចនេះក្តី ដំណាក់កាលបន្ទាប់នៃអភិបាលកិច្ចល្អនឹងទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងយ៉ាងជាក់លាក់ ដើម្បីនាំយកមកនូវការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិកមកអនុវត្ត និងដើម្បីឲ្យការងារអភិបាលកិច្ចមានប្រសិទ្ធភាពខ្ពស់ជាងមុន។ ដើម្បីសម្រេចបានតាមគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តការតភ្ជាប់ប្រព័ន្ធអេឡិចត្រូនិកនៅទូទាំងប្រទេស អភិវឌ្ឍមូលដ្ឋានទិន្នន័យ ផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈប្រព័ន្ធអ៊ិនធឺណិតនៅគ្រប់កម្រិតទាំងអស់និងបន្តវិនិយោគក្នុងការលើកកម្ពស់សមត្ថភាពមនុស្សនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល និងតម្រូវការវិនិយោគលើផ្នែករូបវន្ត សម្រាប់ការធ្វើទំនើបកម្មអភិបាលកិច្ច។

៥- ដើម្បីសម្រេចបាននូវការធ្វើសមាហរណកម្មទៅក្នុងសមាគមអាស៊ានកាន់តែមានទំហំធំឡើងជាលំដាប់គឺចាំបាច់សម្រាប់កម្ពុជា ក្នុងការធ្វើឧស្សាហូបនីយកម្ម និងការទទួលបានទីផ្សារពលកម្មកម្រិតអន្តរជាតិ។ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាផែនទីបង្ហាញផ្លូវដ៏សំខាន់សម្រាប់ការងារទាំងនេះ។ បច្ចុប្បន្ននេះ សមាមាត្រនៃទុនវិនិយោគសាធារណៈដែលវិនិយោគលើមូលធនមនុស្សមានកម្រិតនៅ

ឡើយដែលប្រទេសមួយចំនួនដូចជាម៉ាឡេស៊ីនិងកូរ៉េខាត្បូង បានចំណាយប្រមាណ៥% នៃផ.ស.ស.។ ដូច្នេះរាជរដ្ឋាភិបាលនឹងបន្តបង្កើនធនធាននិងវិនិយោគច្រើនថែមទៀត ក្នុងការអភិវឌ្ឍវិស័យមូលធនមនុស្សឲ្យស្របតាមតម្រូវការចាំបាច់។

៦- សម្រាប់កម្ពុជា ដើម្បីឲ្យមានការគ្រប់គ្រងសេដ្ឋកិច្ចកាន់តែប្រសើរជាងមុន(ជាពិសេសគោលនយោបាយរូបបិយវត្ថុ)នោះចាំបាច់ត្រូវឲ្យមានជំនឿទុកចិត្តលើរូបិយវត្ថុជាតិពីសំណាក់ប្រជាជននិងបណ្ដាប្រទេសនៅក្នុងតំបន់។ ដូចនេះការធ្វើបដិដុល្លារូបនីយកម្ម គឺជាជំហានដំបូងដែលត្រូវអនុវត្ត។

៧- ការងារបរិស្ថាន ក៏ត្រូវបានកំណត់ជាបញ្ហាស្នូលផងដែរ។ បច្ចុប្បន្ននេះ បញ្ហាបរិស្ថានមិនត្រូវបានចាត់ទុកជាអាទិភាពខ្ពស់ទេ ដូច្នេះយើងត្រូវខិតខំរួមគ្នាដើម្បីថែរក្សា ជាពិសេស បឹងទន្លេសាប(និងប្រព័ន្ធទឹកផ្សេងទៀត) និងធនធានព្រៃឈើសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ស្ថិរភាពនៃជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ និងស្ថិរភាពវិស័យកសិកម្ម។

១.១២- **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** មានការឆ្លើយតបចំពោះគ្រប់ចំណុចសំខាន់ៗទាំងអស់ខាងលើ ដូចនេះ *ផ.យ.អ.ជ. ២០១៤-២០១៨* ខិតខំប្រឹងប្រែងដាក់ចេញនូវសំណើសកម្មភាពនានា ដើម្បីឈានទៅសម្រេចឲ្យបាននូវគោលដៅទាំងនោះ ដែលបានចែងនៅក្នុង ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣***។

## ៥- ទម្រង់នៃផ.យ.អ.ជ. ២០១៤-២០១៨

១.១៣- ឯកសារ *ផ.យ.អ.ជ. ២០១៤-២០១៨* ត្រូវបានរៀបចំឡើងជា៧ជំពូក។ បន្ទាប់ពីសេចក្ដីផ្ដើម នៅក្នុងជំពូកនេះ ផែនការនេះនឹងបង្ហាញដោយសង្ខេបពីសមិទ្ធផលសំខាន់ៗនិងបញ្ហាប្រឈម នៅក្នុងអំឡុងពេលនៃការអនុវត្ត *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* នៅក្នុងជំពូកទី២។ ជំពូកទី៣ គ្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ *ផ.យ.អ.ជ. ២០១៤-២០១៨*។ ជំពូកទី៤ បង្ហាញពីគោលនយោបាយនិងសកម្មភាពអាទិភាព *២០១៤-២០១៨* ដែលក្រសួង ស្ថាប័នពាក់ព័ន្ធ(ដោយមានកិច្ចសហការពីរដ្ឋបាលមូលដ្ឋាននៅថ្នាក់ក្រោមជាតិ)ត្រូវអនុវត្ត។ ជំពូកទី៥ បង្ហាញតម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ។ មូលដ្ឋាននៃក្របខ័ណ្ឌលទ្ធផលនៃការវិភាគពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់ដំណាក់កាលពីឆ្នាំ ២០១៤-២០១៨ នឹងមានបង្ហាញនៅក្នុងជំពូកទី៦។ នៅចុងបញ្ចប់ គឺជំពូកទី៧ ដែលបង្ហាញពីសេចក្ដីសន្និដ្ឋានយ៉ាងទូលំទូលាយ។

# ជំពូកទី២

# សមិទ្ធផលនិងបញ្ហាប្រឈម ចម្បងៗក្នុងការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣

# ជំពូកទី២

# សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣

## ការកាត់បន្ថយភាពក្រីក្រ

**២.១-** រវាងឆ្នាំ១៩៩៣និង១៩៩៤ អត្រាភាពក្រីក្រមានប្រមាណ៣៩% ដោយយោងតាមខ្សែបន្ទាត់ភាពក្រីក្រ កំណត់ក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០។ ក្នុងន័យនេះ អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយមកត្រឹម១៤,៦% ដែលមានន័យថា *ព្រះរាជាណាចក្រកម្ពុជា* សម្រេចបាននូវ*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(គ.អ.ស.ក.)* ក្នុងការកាត់បន្ថយសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រ។ ប៉ុន្តែនៅឆ្នាំ២០១១ *រាជរដ្ឋាភិបាល*បានកំណត់ខ្សែបន្ទាត់ភាពក្រីក្រថ្មីមួយឡើងវិញ។ ទោះបីមានការកែសម្រួលខ្សែបន្ទាត់ភាពក្រីក្រក៏ដោយ ក៏ចំណុចដៅសម្រាប់ការកាត់បន្ថយភាពក្រីក្រមកនៅត្រឹម១៩,៥% នឹងឈានទៅសម្រេចបានក្នុងឆ្នាំ២០១៥។

**ប្រអប់ទី២.១ : ខ្សែបន្ទាត់ភាពក្រីក្រ**

១- ខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ ត្រូវបានកំណត់និយមន័យថាជា ចំណាយលើម្ហូបអាហារ ស្មើនឹង២២០០គីឡូកាឡូរី នៅក្នុងកញ្ចប់ម្ហូបអាហារ។ លទ្ធភាពចំណាយលើម្ហូបអាហារ ត្រូវបានធ្វើការបែងចែក ដើម្បីឆ្លុះបញ្ចាំងពីលទ្ធភាពចំណាយលើម្ហូបអាហាររបស់ប្រជាជនក្រុមទី៥ ដល់ក្រុមទី៣០។ ដូច្នេះគំរូអាហារូបត្ថម្ភដែលស្មើនឹង២២០០គីឡូកាឡូរី ត្រូវបានយកមកប្រើប្រាស់សម្រាប់ការគណនាបន្ទាត់ភាពក្រីក្រម្ហូបអាហារនៅទូទាំងប្រទេសកម្ពុជា។

២- ចំណាយលើទំនិញមិនមែនម្ហូបអាហារ គឺជាតម្លៃមធ្យមនៃទំនិញមិនមែនម្ហូបអាហារដែលមានប្រមាណជា២០-៣០% នៃចំណាយសរុបសម្រាប់មនុស្សម្នាក់ៗត្រូវបានគណនាដាច់ដោយឡែកសម្រាប់តំបន់ជនបទ ទីប្រជុំជននិងរាជធានីភ្នំពេញ។

៣- ចំណាយលើទឹកស្អាតត្រូវបានរាប់បញ្ចូលជាលើកដំបូងក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។

*សម្គាល់ : រាល់ការគណនាទាំងអស់ត្រូវបានធ្វើឡើងដោយប្រើទិន្នន័យ* អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា *ដែលរៀបចំឡើងប្រចាំឆ្នាំចាប់តាំងពីឆ្នាំ២០០៧មក។*

**២.២-** និន្នាការថ្មីក្នុងអត្រាភាពក្រីក្រដោយផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រថ្មី មានក្នុងរូបភាព ២.១។ រវាងឆ្នាំ១៩៩០និងឆ្នាំ២០១៥ ចំណុចដៅសម្រាប់កាត់បន្ថយសមាមាត្រប្រជាជនដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឲ្យបានពាក់កណ្តាលនៅត្រឹម១៩% ឬតិចជាង សម្រេចបានរួចហើយទោះបីមានការកែសម្រួលខ្សែបន្ទាត់ភាពក្រីក្រក៏ដោយ។ ទាំងនេះគឺជាសមិទ្ធផលសំខាន់មួយ ដោយមានការចូលរួមពីកំណើនពីរខ្ទង់នៅក្នុង*ផលិតផលក្នុងស្រុក*

*សរុប(ផ.ស.ស.)* សម្រាប់រយៈពេល៣ទៅ៤ឆ្នាំ នគរូបនីយកម្ម ការស្រូបកម្លាំងពលកម្មក្នុងវិស័យមិនមែនកសិកម្មនិងការកាត់បន្ថយវិសមភាព។

**រូបភាពទី២.១ : និន្នាការអត្រាភាពក្រីក្រនៅកម្ពុជា ពីឆ្នាំ២០០៧ដល់ឆ្នាំ២០១១**




| | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|
| Cambodia | 47.8 | 29.9 | 22.9 | 21.1 | 19.8 |
| Phnom Penh | 19.1 | 13.6 | 12.8 | 12.4 | 10.9 |
| Other Urban Areas | 41 | 30.5 | 19.2 | 17 | 22.5 |
| Rural Areas | 53.2 | 31.9 | 24.6 | 22.7 | 20.7 |

*ប្រភព : អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

## អត្រាភាពក្រីក្រនៅថ្នាក់ក្រោមជាតិ

**២.៣-** អត្រាភាពក្រីក្រនៅតំបន់ជនបទបានធ្លាក់ចុះពី៥៣%(ឆ្នាំ២០០៧)មកប្រហែលជា២១% (ឆ្នាំ២០១១) នៅពេលដែលសមាមាត្រចំនួនប្រជាជនរស់នៅជនបទមានជិត៨០% នៃប្រជាជនសរុប។ ទន្ទឹមនឹងនេះអត្រាភាពក្រីក្រក៏បានធ្លាក់ចុះផងដែរនៅតាមទីប្រជុំជននិង រាជធានីភ្នំពេញ។ ការថយចុះ នៃភាពក្រីក្រឆ្លុះបញ្ចាំងឲ្យឃើញពីការធ្លាក់ចុះនូវភាពក្រីក្រគួរឲ្យកត់សម្គាល់នៅតាមតំបន់ជនបទនានា។

**២.៤-** អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា គឺជាប្រភពទិន្នន័យមួយដែលប្រមូលទិន្នន័យស្តីពីលទ្ធភាពចំណាយលើការប្រើប្រាស់និងជីវភាពរស់នៅរបស់ប្រជាជននៅកម្ពុជា ប៉ុន្តែទំហំគំរូនិងការរៀបចំមិនអនុញ្ញាតសម្រាប់ការវិភាគទៅដល់តាមកម្រិតខេត្ត។ ប៉ុន្តែការប្រើប្រាស់ទិន្នន័យ ឃុំសង្កាត់[១] អាចបង្កើតសូចនាករជំនួសនៃភាពក្រីក្រ ដើម្បីបានសន្ទស្សន៍ភាពក្រីក្រនិងអត្រាភាពក្រីក្រ (*សូមមើលប្រអប់ ២.២*)។

[១] ទិន្នន័យឃុំ សង្កាត់ គឺជាមូលដ្ឋានទិន្នន័យរដ្ឋបាល ដែលប្រមូលទិន្នន័យពីបណ្តាភូមិនិងឃុំ។

## រូបភាពទី២.២ : អត្រាភាពក្រីក្រតាមខេត្ត ឆ្នាំ២០១១




ប្រភព : *ទិន្នន័យឃុំ សង្កាត់ និងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

**ប្រអប់ទី២.២ : ការគណនាអត្រាភាពក្រីក្រជំនួសនៅថ្នាក់រាជធានី ខេត្ត**

សន្ទស្សន៍ភាពក្រីក្រត្រូវបានគណនាដោយមានអញ្ញាត៥ក្រុម៖

១- ទ្រព្យសម្បត្តិ (ម៉ូតូ កង់ ផ្ទះនៅក្នុងភូមិ)

២- បរិក្ខារផ្សេងៗ (អគ្គិសនី ទឹកស្អាត អនាម័យនៅក្នុងភូមិ)

៣- ធនធានមនុស្ស (អក្ខរភាព ការចូលរៀននៅក្នុងភូមិ)

៤- ការងារ/ផលិតភាព (ការងារមិនមែនកសិកម្ម ផលិតកម្មស្រូវ កសិករមានដីតិចជាង១ហិកតា ផលធៀបភាពពឹងផ្អែកនៅក្នុងភូមិ) និង

៥- ចម្ងាយ (ចម្ងាយរបស់ភូមិទាំងអស់ពីទីប្រជុំជន)

អត្រាភាពក្រីក្រតាមខេត្ត ត្រូវបានគណនាដោយមានបីដំណាក់កាល ដោយប្រើវិធីសម្រាប់បង្កើតសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស។

<u>ដំណាក់កាលទី១:</u> គណនា Individual Variable Index (EVI) (for $X_i$) = [(Actual ($X_i$) – Min ($X_i$)]/[(Max ($X_i$)– Min_($X_i$)]

<u>ដំណាក់កាលទី២:</u> គណនា Composite Poverty Index = SUM (EVI)/k (ដែល k ជាចំនួនអញ្ញាត ដែលមានចំនួន១៣អញ្ញាត)

<u>ដំណាក់កាលទី៣:</u> គណនា Composite Poverty Index ជាមួយអត្រាភាពក្រីក្រជាតិ នឹងទទួលបានអត្រាភាពក្រីក្រតាមខេត្ត អាស្រ័យលើបម្រែបម្រួលនៅក្នុង Composite Poverty Indices តាមខេត្តអញ្ញាតទាំងអស់ត្រូវបានវាស់វែងជាផលធៀបទៅនឹងចំនួនប្រជាជនសរុប ដើម្បីជៀសបញ្ហានៃការប្រៀបធៀបខេត្តនៅពេលមានចំនួនប្រជាជន និងដង់ស៊ីតេប្រជាជនមិនស្មើនៅតាមខេត្ត។

២.៥- ទិន្នន័យនៃអត្រាភាពក្រីក្រជំនួស ត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្ត ដូចក្នុង(*រូបភាពទី២.២*) ខាងលើ។ ខេត្តទាំងអស់នៅភាគខាងត្បូងនិងខាងត្បូងឆៀងខាងកើតនៃប្រទេស ដែលមានប្រជាជនច្រើននិងការប្រកបរបរកសិកម្មបែបប្រពៃណី មានអត្រាភាពក្រីក្រទាបជាងប្រជាជន ក្នុងខេត្តភាគខាងជើងនិងខាងជើងឆៀងខាងលិច។ ខេត្តទាំងនេះភាគច្រើនជាជនបទនិងមិនទាន់បានធ្វើសមាហរណកម្មពេញលេញជាមួយប្រព័ន្ធជាតិ។ អត្រាភាពក្រីក្រខ្ពស់មាននៅខេត្តសៀមរាបនិងបាត់ដំបង ទោះបីខេត្តទាំងពីរនេះមានប្រពៃណីធ្វើកសិកម្មក៏ដោយ។ ខេត្តសៀមរាប គឺជាតំបន់ទេសចរណ៍របស់កម្ពុជា ចំណែកខេត្តបាត់ដំបងគឺជាខេត្តជង្រុកស្រូវ។ បញ្ហាទាំងនេះ តម្រូវឲ្យមានការវិភាគលម្អិតបន្ថែមនិងស្រាវជ្រាវច្បាស់លាស់ និងដែលជារបៀបវារៈស្រាវជ្រាវអភិវឌ្ឍន៍នៅពេលអនាគត។

### ១- អភិបាលកិច្ចល្អ ៖ ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

២.៦- អភិបាលកិច្ចល្អនៅតែជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ។ កំណែទម្រង់ធំៗទាំងបួន ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ នៅតែបន្តជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនសំដៅធ្វើឲ្យសម្រេចបាននូវការអភិវឌ្ឍសង្គម សេដ្ឋកិច្ចមួយប្រកបដោយចីរភាព ស្ថិរភាព និងសមធម៌ កាលានុវត្តភាពដូចគ្នា ស្មើភាពគ្នាចំពោះមុខច្បាប់ និងយុត្តិធម៌សង្គម។ កំណែទម្រង់ទាំងនេះ រួមមាន ៖ *(ក)ការប្រយុទ្ធប្រឆាំងអំពើពុករលួយ (ខ)កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (គ)កំណែទម្រង់រដ្ឋបាលសាធារណៈ(រួមបញ្ចូលទាំងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ)* និង *(ឃ)កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ*។ វឌ្ឍនភាពសំខាន់ៗដែលសម្រេចបាននៅក្នុងវិស័យទាំងនេះ នឹងត្រូវលើកយកមកបង្ហាញដោយសង្ខេបដូចខាងក្រោម៖

#### ១.១- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ

២.៧- *រាជរដ្ឋាភិបាលកម្ពុជា*បានផ្តល់អាទិភាពខ្ពស់ចំពោះការងារអភិបាលកិច្ច និងបានកំណត់ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ និងកំពុងបន្តជាស្នូលយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣។

២.៨- *រាជរដ្ឋាភិបាលកម្ពុជា*នីតិកាលទី៤បានអនុវត្តវិធានការប្រទាក់ក្រឡាគ្នា ដើម្បីទប់ស្កាត់អំពើពុករលួយ។ ជាក់ស្តែង*រាជរដ្ឋាភិបាលកម្ពុជា*បានបង្កើត*ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ*និង*អង្គភាពប្រឆាំងអំពើពុករលួយ* និងយន្តការប្រឆាំងអំពើពុករលួយផ្សេងៗទៀត រួមមានបទប្បញ្ញត្តិនិងបទដ្ឋានគតិយុត្តនានា។ *រាជរដ្ឋាភិបាល*ក៏បានអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ហើយច្បាប់នេះត្រូវបានផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយ ពិសេស នៅតាមក្រសួងនិងស្ថាប័នរដ្ឋនានា។ ក្នុងន័យនេះដែរ ក្រុមជនបង្គោលត្រូវបានបង្កើតឡើងនៅតាមក្រសួង

និងស្ថាប័នរដ្ឋនានា សម្រាប់សម្របសម្រួលការងារជាមួយ*អង្គភាពប្រឆាំងអំពើពុករលួយ*។ រីឯការប្រកាសទ្រព្យសម្បត្តិនិងបំណុលក៏បានដំណើរការចំនួនពីរដងរួចមកហើយដែរ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានកំណត់តារាងតម្លៃសេវាសាធារណៈនិងរយៈពេលសម្រាប់ការផ្តល់សេវាដែលក្រសួងនិងស្ថាប័នរដ្ឋត្រូវអនុវត្ត សំដៅលុបបំបាត់ការខាតបង់បណ្តាលមកពីការបង់ប្រាក់ក្រៅផ្លូវការនិងភាពអសកម្មរបស់ស្ថាប័នរដ្ឋ។

**២.៩-** រយៈពេល៥ឆ្នាំ(២០០៩-២០១៣)កន្លងមកនេះ *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច* បានឆ្លើយតបទៅនឹងគោលនយោបាយពង្រឹងអភិបាលកិច្ចល្អរបស់*រាជរដ្ឋាភិបាលកម្ពុជា* ដើម្បីជំរុញកំណើន បង្កើតការងារ ធានាបានសមធម៌ និងប្រសិទ្ធភាពដោយជោគជ័យ។ សមិទ្ធផលដែលសម្រេចបានកន្លងមកបានឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈយុទ្ធសាស្ត្រចម្បងៗចំនួន៣ ដូចមានរៀបរាប់ខាងក្រោម៖

- *យុទ្ធសាស្ត្រពង្រឹងវិស័យទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា :* ក្រសួងបានផ្សព្វផ្សាយច្បាប់អាទិភាពចំនួន៩ ក្នុង*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) បច្ចុប្បន្នកម្ម ២០០៩-២០១៣* ក្នុងស្រុកចំនួន១៩៧នៅទូទាំងប្រទេស ដោយមានអ្នកចូលរួមចំនួន ៨៣ ៣៣៨នាក់ ព្រមទាំងបានទទួលនិងឆ្លើយសំណួរបានចំនួន៩ ៥១៧សំណួរ។

- *យុទ្ធសាស្ត្រពង្រឹងវិស័យអធិការកិច្ច :* ក្រសួងបានចាត់ប្រតិភូចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមិនប្រក្រតីនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិបានជាច្រើនលើក។ ក្រសួងក៏បានតាមដានការអនុវត្តដោយផ្ទាល់ទៅលើលិខិតបទដ្ឋានគតិយុត្តនានា ដូចជា *ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ភូមិបាល ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ និងច្បាប់ស្តីពីបរិស្ថាននិងការការពារធនធានធម្មជាតិ*។ ចំពោះយន្តការទទួលនិងដោះ ស្រាយពាក្យបណ្តឹងវិញ ក្រសួងទទួលបានពាក្យបណ្តឹងសរុបចំនួន២០៣ ហើយបណ្តឹងចំនួន ៥៥% ត្រូវបានអង្កេតស្រាវជ្រាវ។ ហើយបណ្តឹងដែលនៅសេសសល់ គឺជាសមត្ថកិច្ចរបស់ក្រសួងរដ្ឋពាក់ព័ន្ធផ្សេងៗទៀត។

- *យុទ្ធសាស្ត្រពង្រឹងស្ថាប័ននិងអភិវឌ្ឍន៍ធនធានមនុស្ស :* សិក្ខាកាមទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិចូលរួមចំនួន៥០១នាក់ ត្រូវបានក្រសួងចាត់បញ្ជូនឲ្យចូលរួមបណ្តុះបណ្តាលនៅក្នុងប្រទេសនិងក្រៅប្រទេស លើមុខជំនាញរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ អធិការកិច្ច ការទទួលនិងដោះស្រាយបណ្តឹងនិងអង្កេតស្រាវជ្រាវ។

២.១០- ទន្ទឹមនឹងសមិទ្ធផលខាងលើ ក្រសួងក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដូចជា លទ្ធផលការងារមិនទាន់ឆ្លើយតបតាមផែនការដែលបានកំណត់ទុក ដោយមូលហេតុសមត្ថភាពជំនាញរបស់មន្ត្រីរាជការនៅមានកម្រិត ហើយកញ្ចប់ថវិកាសម្រាប់បំពេញការងារក៏នៅមានកម្រិត ពុំទាន់ឆ្លើយតបឲ្យបានគ្រប់គ្រាន់តាមតម្រូវការការងារជាក់ស្តែងនៅឡើយ។ *ច្បាប់ស្តីពីអធិការកិច្ច អនុក្រឹត្យស្តីពីនីតិវិធីធ្វើអធិការកិច្ច នីតិវិធីតាមដានការអនុវត្តច្បាប់ នីតិវិធីអង្កេតស្រាវជ្រាវពាក្យបណ្តឹង នីតិវិធីផ្សព្វផ្សាយច្បាប់ វិធីសាស្ត្រសិក្សាស្រាវជ្រាវ និងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស* ក៏មិនទាន់ត្រូវបានរៀបចំបង្កើតឡើងផងដែរ។ ភាពខ្វះចន្លោះនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តខាងលើនេះបានធ្វើឲ្យក្រសួងពុំមានមូលដ្ឋានគ្រឹះសម្រាប់ចង្អុលបង្ហាញផ្លូវក្នុងការបំពេញការងារឲ្យមានប្រសិទ្ធភាពឡើយ។

### ១.២- កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

២.១១- *រាជរដ្ឋាភិបាលកម្ពុជា* នីតិកាលទី៤ បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពន្លឿនដំណើរការ*កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* ដើម្បីសម្រេចឲ្យបាននូវប្រព័ន្ធច្បាប់និងប្រព័ន្ធយុត្តិធម៌មួយដែលអាចជឿទុកចិត្តបាននិងមានស្ថិរភាព សម្រាប់ការលើកស្ទួយការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការពង្រឹងគោលការណ៍នីតិរដ្ឋនៅក្នុងលទ្ធិប្រជាធិបតេយ្យសេរី ការធានាយុត្តិធម៌សង្គម ព្រមទាំងការបង្កើតបរិយាកាសជឿទុកចិត្តសម្រាប់ការទាក់ទាញការវិនិយោគដោយបានដាក់ចេញនូវការងារអាទិភាព ដូចខាងក្រោម៖

- បន្តអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីឈានទៅសម្រេចឲ្យបាននូវទិសដៅយុទ្ធសាស្ត្រទាំង៧ គឺ
  - ➢ ពង្រឹងការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋាន។
  - ➢ ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់។
  - ➢ ផ្តល់លទ្ធភាពទទួលព័ត៌មានអំពីច្បាប់និងតុលាការឲ្យប្រសើរឡើង។
  - ➢ ធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃដំណើរការរឿងក្តីនិងសេវាពាក់ព័ន្ធ។
  - ➢ ពង្រឹងសេវាយុត្តិធម៌ រួមមានអំណាចតុលាការនិងសេវាផ្នែកអយ្យការ។
  - ➢ បង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
  - ➢ ពង្រឹងសមត្ថភាពស្ថាប័នច្បាប់និងតុលាការឲ្យអាចបំពេញអាណត្តិរបស់ខ្លួនបានជោគជ័យ។
- បន្តជំរុញការអនុម័តច្បាប់គោលសំខាន់ៗ ដូចជា៖
  - ➢ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា។
  - ➢ ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃអង្គការតុលាការ។
  - ➢ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

- បន្តរៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋនិងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ ក្នុងគោលដៅបង្កើនការយល់ដឹងនិងការអនុវត្តឲ្យបានត្រឹមត្រូវ។
- ការពង្រឹងសមត្ថភាពរបស់ចៅក្រមនិងព្រះរាជអាជ្ញា។
- ការកសាងនូវយន្តការផ្សេងៗ ដែលចូលរួមបម្រើឲ្យមានៈ
  - ➢ លក្ខន្តិកៈក្រឡាបញ្ជី
  - ➢ លក្ខន្តិកៈសារការី
  - ➢ លក្ខន្តិកៈអាជ្ញាសាលា
- ការផ្តល់ជំនួយផ្នែកច្បាប់
- ការបន្តជំរុញលើកកម្ពស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជូនប្រជាពលរដ្ឋ។

២.១២- សម្រាប់កំណែទម្រង់រចនាសម្ព័ន្ធលើប្រព័ន្ធយុត្តិធម៌ *ក្រសួងយុត្តិធម៌* បានរៀបចំបង្កើតឲ្យមានសាលាដំបូងចំនួន២បន្ថែមទៀតគឺ សាលាដំបូងខេត្តប៉ៃលិន(ពីមុនជាមន្ទីរយុត្តិធម៌ខេត្តប៉ៃលិន) និងបានបង្កើតថ្មីនូវសាលាដំបូងខេត្តឧត្តរមានជ័យ ហើយត្រូវបានប្រកាសសុពលភាពដាក់ឲ្យដំណើរការនៅក្នុងខែមករា ឆ្នាំ២០១១។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានសាងសង់អាគារចំនួន៧ និងបានជួសជុលអាគារសាលាដំបូងចំនួន៣សម្រាប់រយៈពេល៥ឆ្នាំកន្លងមកនេះ។

២.១៣- ច្បាប់ដែលត្រូវបានអនុម័តរវាងឆ្នាំ២០០៩ និងឆ្នាំ២០១១ រួមមានៈ

- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីត្រូវបានចូលជាធរមាននៅក្នុងខែធ្នូ ឆ្នាំ២០១១។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីមិនមែនជាបណ្តឹងត្រូវបានចូលជាធរមាននៅក្នុងខែកក្កដា ឆ្នាំ២០១០។
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងឋានៈបុគ្គលត្រូវបានចូលជាធរមាននៅក្នុងខែឧសភា ឆ្នាំ២០១០។
- ក្រមព្រហ្មទណ្ឌត្រូវបានចូលជាធរមាននៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៩។

២.១៤- *ក្រសួងយុត្តិធម៌* បានបញ្ចប់និងបញ្ជូនសេចក្តីព្រាងច្បាប់មួយចំនួនទៅ*គណៈរដ្ឋមន្ត្រី* ដើម្បីសុំការពិនិត្យពិភាក្សានិងការអនុម័ត ក្នុងនោះរួមមានៈ

- សេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងនិងការប្រព្រឹត្តទៅនៃអង្គការតុលាការ។
- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា។
- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលា។

- សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

**២.១៥-** សម្រាប់ការកសាងលិខិតបទដ្ឋានគតិយុត្តនានា *ក្រសួងយុត្តិធម៌* បានរៀបចំសេចក្តីព្រាងច្បាប់ ដែលប្រកាសអន្តរក្រសួងចំនួន២ ប្រកាសចំនួន៧ សេចក្តីណែនាំចំនួន៤ ព្រះរាជក្រឹត្យចំនួន១ និងកំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**២.១៦-** សម្រាប់ការអប់រំនិងការផ្សព្វផ្សាយច្បាប់រវាងឆ្នាំ២០០៩និងឆ្នាំ២០១២ *ក្រសួងយុត្តិធម៌* បានផ្សព្វផ្សាយច្បាប់មូលដ្ឋាន និងច្បាប់ពាក់ព័ន្ធនឹងស្ត្រីនិងកុមារ យ៉ាងទូលំទូលាយដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីនគរបាលយុត្តិធម៌ សរុបចំនួន៩ ២០០នាក់ នៅតាមរាជធានី ខេត្តនានា។

**២.១៧** *ក្រសួងយុត្តិធម៌* បានផ្សព្វផ្សាយច្បាប់នានាតាមរយៈវិទ្យុនិងទូរទស្សន៍។ ក្រសួងក៏បានផលិតនិងចាក់ផ្សាយស្គេតរឿងខ្លីៗទាក់ទងនឹងការប្រព្រឹត្តបទល្មើសនឹងច្បាប់ ដើម្បីឲ្យប្រជាពលរដ្ឋងាយស្រួលយល់និងស្រួលចងចាំ។ វេទិកាពិភាក្សាដេញដោលអំពីក្រមនីតិវិធីព្រហ្មទណ្ឌនិងក្រមព្រហ្មទណ្ឌ ក៏ដូចជាស្គេតរឿងខ្លីៗទាក់ទងនឹងក្រមព្រហ្មទណ្ឌ ត្រូវបានធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍និងវិទ្យុចំនួន៥ ២០០លើក រវាងឆ្នាំ២០០៩និងឆ្នាំ២០១២។

**២.១៨-** *ក្រសួង* ក៏បានធ្វើការផ្សព្វផ្សាយចែកជូនសៀវភៅឯកសារច្បាប់ចំនួន១៥៦ ១៦៤ក្បាល ដល់គ្រប់ស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ព្រមទាំងមន្ត្រីនគរបាលយុត្តិធម៌ មាននគរបាលជាតិ កងរាជអាវុធហត្ថ ថ្នាក់ខេត្ត ក្រុង ស្រុក និងសាលាខេត្ត រាជធានី ទូទាំងប្រទេស គណៈមេធាវី និងគ្រប់សាកលវិទ្យាល័យ វិទ្យាស្ថានរដ្ឋ និងឯកជន ដើម្បីបានឯកសារច្បាប់គោលនេះទុកជាមូលដ្ឋានសម្រាប់អនុវត្តការងារ និងសម្រាប់ជាឯកសារសិក្សាស្រាវជ្រាវផ្សេងៗ។

**២.១៩-** សម្រាប់ការអភិវឌ្ឍ ការពង្រឹង និងការបណ្តុះបណ្តាលធនធានមនុស្ស *ក្រសួងយុត្តិធម៌* បានយកចិត្តទុកដាក់ធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវាច្បាប់និងតុលាការ តាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាលអំពីច្បាប់មូលដ្ឋាន និងច្បាប់ពាក់ព័ន្ធនឹងស្ត្រីនិងកុមារ និងជំនាញផ្សេងៗជូនដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មន្ត្រីនគរបាល យុត្តិធម៌ និងមន្ត្រីរាជការ សរុបចំនួន៣៩ វគ្គ នៅតាមរាជធានី ខេត្តទូទាំងប្រទេស។

**២.២០-** ផ្អែកតាមគោលនយោបាយកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាល *ក្រសួងយុត្តិធម៌* បានបង្កើតក្រុមការងារតុលាការគំរូ។ ផែនការយុទ្ធសាស្ត្ររបស់តុលាការគំរូសំដៅគ្រប់គ្រងការចុះបញ្ជីសំណុំរឿងក្តី ក្នុងគោលបំណងគ្រប់គ្រងស្ថិតិ តាមដាន ប្រមូលនិងផ្តល់ព័ត៌មាន ឲ្យបានឆាប់រហ័ស និងមានលក្ខណៈតាមស្តង់ដាតែមួយ ដែលជាមូលដ្ឋានគ្រឹះងាយ

ស្រួលក្នុងការអនុវត្តការងាររបស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីពាក់ព័ន្ធ ចាប់ពីដំណាក់កាលដំបូងនៃនីតិវិធី រហូតដល់ដំណាក់កាលបញ្ចប់នៃនីតិវិធីនិងធានាឲ្យបានកាន់តែប្រសើរក្នុងការគ្រប់គ្រងដំណើររឿងក្តីនីមួយៗឲ្យបានសុក្រឹតនិងមានតម្លាភាព។ ក្រុមការងារតុលាការគំរូមានសៀវភៅចុះបញ្ជីសំណុំរឿងក្តីរដ្ឋប្បវេណី និងសៀវភៅចុះបញ្ជីសំណុំរឿងក្តីព្រហ្មទណ្ឌចំនួន២៧ ហើយបានបណ្តុះបណ្តាលវគ្គចុះបញ្ជីសំណុំរឿងក្តី ដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីពាក់ព័ន្ធ នៅតាមរាជធានី ខេត្តទូទាំងប្រទេស។ ការងារចុះបញ្ជីសំណុំរឿងក្តីនៅគ្រប់សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ត្រូវបានត្រួតពិនិត្យ តាមដាននិងវាយតម្លៃជាប់ជាប្រចាំ។

**២.២១-** ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ *ក្រសួងយុត្តិធម៌* បានសហការជាមួយ *ក្រសួងមហាផ្ទៃ* បង្កើតឲ្យមានមណ្ឌលសេវាយុត្តិធម៌ថ្នាក់ស្រុកចំនួន២០មណ្ឌល នៅឆ្នាំ២០០៧ ប៉ុន្តែកិច្ចសហប្រតិបត្តិការនេះត្រូវបានបញ្ចប់នៅឆ្នាំ២០១០។ ដោយមើលឃើញពីជោគជ័យនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ *គណៈមេធាវី* ក្រោមការជួយឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលនៅតែបន្តនិរន្តរភាពមណ្ឌលសេវាយុត្តិធម៌ទាំង២០ និងបានបង្កើតបន្ថែមរហូតដល់៣១ មណ្ឌលសេវាយុត្តិធម៌នៅតាមបណ្តាក្រុង ស្រុក ខណ្ឌ រួមទាំងមានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ចំនួន៥៦ ដើម្បីជួយដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅរាជធានី ខេត្ត។

**២.២២-** កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យច្បាប់និងយុត្តិធម៌ ជាពិសេសការជួយគ្នាទៅវិញទៅមកតាមផ្លូវតុលាការក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាននិងអាស៊ី ត្រូវបានពង្រឹងនិងពង្រីកឲ្យបានទូលំទូលាយ។

- សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (ប្រទេសសមាជិកអាស៊ាន) ត្រូវបានប្រកាសឲ្យប្រើក្នុងខែមករា ឆ្នាំ២០១០។
- កិច្ចព្រមព្រៀងស្តីពីការបញ្ជូនទណ្ឌិត និងស្តីពីកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តការផ្តន្ទាទោសព្រហ្មទណ្ឌ រវាង *ព្រះរាជាណាចក្រកម្ពុជា* និង *ព្រះរាជាណាចក្រថៃ* បានចុះហត្ថលេខា ខែសីហា ឆ្នាំ ២០០៩។
- អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ និងយុត្តិធម៌រវាង *ក្រសួងយុត្តិធម៌* នៃ *ព្រះរាជាណាចក្រកម្ពុជា* និង *សាធារណរដ្ឋសង្គមនិយមវៀតណាម* បានចុះហត្ថលេខា ខែធ្នូ ឆ្នាំ២០០៩។
- កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាង *ព្រះរាជាណាចក្រកម្ពុជា* និង *សាធារណរដ្ឋកូរ៉េ* ត្រូវបានប្រកាសឲ្យប្រើក្នុងខែមករា ឆ្នាំ២០១១។

**២.២៣-** ទោះបីកិច្ចខិតខំប្រឹងប្រែងក្នុងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ មានការរីកចម្រើនគួរឲ្យកត់សម្គាល់ តាមរយៈ ការអនុវត្តផែនការសកម្មភាពក៏ដោយ ក៏ការងារកំណែទម្រង់នេះបានជួបប្រទះនឹងបញ្ហាជាច្រើនផងដែរ។ ការរៀបចំសេចក្តីព្រាងច្បាប់មួយចំនួន ដូចជា *ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សា ច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ច្បាប់ស្តីពីលក្ខន្តិកៈសារការី* និង *ច្បាប់ស្តីពីការតម្កល់* មិនទាន់បានសម្រេចតាមផែនការកំណត់ មូលហេតុដោយសារច្បាប់ទាំងនេះមានភាពស្មុគស្មាញ មានទំនាក់ទំនងគ្នាយ៉ាងខ្លាំង និងទាមទារឲ្យមានការកែសម្រួលនិងពិនិត្យឲ្យបានល្អិតល្អន់ជាច្រើនលើកច្រើនសា (ក្នុងកម្រិតក្រសួងនិងអន្តរក្រសួង)។ បញ្ហាប្រឈមផ្សេងៗទៀតដែលរាំងស្ទះដល់កំណែទម្រង់កន្លងមក រួមមាន៖

- *ធនធានមនុស្ស*
  - ➢ កង្វះចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល សម្រាប់បម្រើការនៅក្រសួងនិងនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងគ្រប់ជាន់ថ្នាក់ដោយសារការផ្តល់ចំនួនក្របខ័ណ្ឌមន្ត្រីនៅមានកម្រិត មិនទាន់មានតុល្យភាពរវាងចំនួនមន្ត្រីនិងសំណុំរឿង។
  - ➢ កង្វះចៅក្រមឯកទេសលើផ្នែកតុលាការការងារ តុលាការអនីតិជន តុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាល ដោយសារចំនួននៃការបណ្តុះបណ្តាលចៅក្រមឯកទេសនៅមានកម្រិត។
  - ➢ កង្វះមន្ត្រីចុះបញ្ជីសំណុំរឿងក្តីតាមប្រព័ន្ធចុះបញ្ជីថ្មី (គម្រោងតុលាការគំរូ) មិនទាន់ឆ្លើយតបទៅនឹងការងារគ្រប់គ្រងរឿងក្តីឲ្យបានល្អប្រសើរ។
- *សមត្ថភាពគ្រប់គ្រងស្ថាប័ន*
  - ➢ កង្វះអគារធ្វើការរបស់ក្រសួងនិងសាលាដំបូងរាជធានី ខេត្ត ដោយអាគារមានលក្ខណៈចង្អៀត បន្ទប់ធ្វើការពុំគ្រប់គ្រាន់ទៅនឹងចំនួនមន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ជាពិសេសខ្វះបន្ទប់សម្រាប់មន្ត្រីចុះបញ្ជីសំណុំរឿងក្តីនិងតម្កល់ទុកឯកសាររឿងក្តី ព្រមទាំងបន្ទប់សវនាការសម្រាប់ដំណើរការកាត់ក្តីឲ្យបានទាន់ពេលវេលាជូនប្រជាពលរដ្ឋ។
  - ➢ កង្វះអាគារធ្វើការនិងថវិកាសម្រាប់ឧបត្ថម្ភមន្ត្រីបម្រើការងារក្នុងមណ្ឌលសេវាកម្មយុត្តិធម៌ទាំង៣១មណ្ឌល។
  - ➢ កង្វះថវិកាប្រចាំឆ្នាំសម្រាប់បម្រើការងារនៅក្រសួងនិងនៅតាមសាលាជម្រះក្តី។
  - ➢ កង្វះថវិកាសម្រាប់ចំណាយក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដែលការចំណាយជាបន្ទុករបស់រដ្ឋទាំងស្រុង ដូចជា មធ្យោបាយធ្វើដំណើរសម្រាប់ការស៊ើបអង្កេតរឿងក្តីដល់ទីកន្លែងកើតហេតុ សម្រាប់ដឹកពិរុទ្ធជនមកកាន់សាលាជម្រះក្តី ការបញ្ជូនដីកាកោះ អ្នកបកប្រែភាសាក្នុងដំណើរការរឿងក្តី និងបញ្ហាកោសលវិច័យ។ល។

- កង្វះមេធាវីដែលតម្រូវដោយច្បាប់ សម្រាប់ការពាររឿងក្តីបទឧក្រិដ្ឋនិងសម្រាប់ការពារជនជាប់ចោទជាអនីតិជន(យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣០១)។
- ខ្វះរថយន្តសម្រាប់មន្ត្រីក្រសួង ចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្ត។

### ១.៣- កំណែទម្រង់រដ្ឋបាលសាធារណៈ

២.២៤- អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ មានសារៈសំខាន់នៅក្នុងការឈានទៅសម្រេចបាននូវការងារអាទិភាពនានារបស់រាជរដ្ឋាភិបាល។ រដ្ឋបាលសាធារណៈគឺជាឧបករណ៍យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រដទៃទៀត នៅក្នុងការអនុវត្តការងារកំណែទម្រង់របស់រាជរដ្ឋាភិបាល។ *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល* បានអនុវត្តជាបន្តបន្ទាប់នូវកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលដើម្បីបម្រើប្រជាពលរដ្ឋឲ្យបានកាន់តែល្អប្រសើរឡើង។

២.២៥- *ផែនការសកម្មភាពអភិបាលកិច្ច* សំដៅជួយសម្រួលឲ្យមានកិច្ចសហការគ្នានៅក្នុងចំណោមការងារកំណែទម្រង់ថ្នាក់ជាតិនិងកំណែទម្រង់តាមវិស័យ។ ផែនការសកម្មភាពនេះបានគ្របដណ្តប់យ៉ាងទូលំទូលាយលើការងារកំណែទម្រង់នានា រួមមាន *កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* និងកំណែទម្រង់នានាដែលពាក់ព័ន្ធនឹងការវិនិយោគ និងពាណិជ្ជកម្ម ការអភិវឌ្ឍសង្គមកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិ។

២.២៦- សម្រាប់ការងារកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាល*នីតិកាលទី៤* នៃ*រដ្ឋសភា* សម្រេចបាននូវសមិទ្ធផលសំខាន់ៗ គួរឲ្យកត់សម្គាល់ ដូចជា៖

- ការគ្រប់គ្រងទំហំមន្ត្រីរាជការស៊ីវិលឲ្យបានសមស្រប និងការបង្កើនបៀវត្សមធ្យមប្រចាំខែរបស់មន្ត្រីរាជការជិតទ្វេដង។
- ការដាក់ឲ្យដំណើរការនូវទីភ្នាក់ងារប្រតិបត្តិការពិសេស ដោយដាក់ឲ្យអនុវត្តនូវកម្រងព័ត៌មានស្តីពីសេវាសាធារណៈនិងការពង្រីកវិសាលភាពនូវយន្តការ *ច្រកចេញចូលតែមួយ* នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ចំនួន២៤។
- ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ការរៀបចំនិងដាក់ឲ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**២.២៧-** ទន្ទឹមនឹងនេះ លទ្ធផលដូចខាងក្រោមបង្ហាញពីសមិទ្ធផលនានា ដែលបានរួមចំណែកក្នុងការកសាងសមត្ថភាពធនធានមនុស្សនិងសមត្ថភាពស្ថាប័ន នៅក្នុង*កំណែទម្រង់រដ្ឋបាលសាធារណៈ* និង *មន្ត្រីរាជការស៊ីវិល*៖

- ការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងប្រព័ន្ធតែមួយ បានផ្តល់លក្ខណៈអំណោយផលក្នុងការលើកទឹកចិត្តនិងការវិវត្តអាជីព។
- ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិនានា ដែលត្រូវបានប្រើប្រាស់នៅក្នុងមុខងារសាធារណៈ រួមមាន *ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល* និង *លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលទាំងអស់។*
- ប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យ ដែលមានលក្ខណៈប្រតិបត្តិការនិងមានប្រសិទ្ធភាព(ដូចជាការជ្រើសរើសការតែងតាំងនិងការចូលនិវត្តន៍ជាដើម)។
- ការដាក់ឲ្យប្រើប្រាស់តារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា។
- ប្រព័ន្ធលាភការថ្មីត្រូវបានបង្កើតឡើងនិងដាក់ឲ្យអនុវត្ត ហើយបានបង្កើនប្រាក់បៀវត្សមធ្យមរបស់មន្ត្រីរាជការស៊ីវិល។
- ដាក់ឲ្យអនុវត្តយន្តការផ្តល់សេវាសាធារណៈ សំដៅពង្រឹងតម្លាភាព គុណភាព ប្រសិទ្ធភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ (ទីភ្នាក់ងារប្រតិបត្តិការពិសេស)។
- ដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារនិងគណនេយ្យភាព ដើម្បីកៀរគរធនធានមនុស្សឲ្យបានល្អប្រសើរនិងកំណត់អំពីតម្រូវការអាទិភាពនៅក្នុងការអភិវឌ្ឍសមត្ថភាព។
- គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ត្រូវបានអនុម័តនិងកំពុងជំរុញការអនុវត្ត។
- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងធនធានមនុស្ស ត្រូវបានដាក់ឲ្យដំណើរការ ហើយយន្តការគ្រប់គ្រងបុគ្គលិក ត្រូវបានពង្រឹងជាបន្តបន្ទាប់។
- ឧបករណ៍ទំនាក់ទំនងព័ត៌មាន (ព្រឹត្តិបត្រព័ត៌មាន គេហទំព័រ និងសិក្ខាសាលា) ត្រូវបានបង្កើតឡើងនិងដាក់ឲ្យដំណើរការ ដើម្បីផ្តល់ព័ត៌មានអំពីការងារកំណែទម្រង់រដ្ឋបាល។
- ដាក់ឲ្យអនុវត្តប្រព័ន្ធប្រាក់បំណាច់មុខងារសម្រាប់ថ្នាក់ដឹកនាំគ្រប់គ្រងនិងមន្ត្រីជំនាញ។

### ក្របខ័ណ្ឌគ្រប់គ្រងការងារមន្ត្រីរាជការស៊ីវិល

**២.២៨-** សមិទ្ធផលនានា ដែលក្រសួង ស្ថាប័នសម្រេចបានក្នុងរយៈពេល៥ឆ្នាំ (២០០៨-២០១២) កន្លងមកនេះ មានដូចតទៅ៖

- ជ្រើសរើសមន្ត្រីរាជការស៊ីវិលចូលក្របខ័ណ្ឌបានចំនួន៣៧ ៨០២នាក់។
- ដាក់ឲ្យចូលនិវត្តន៍មន្ត្រីរាជការស៊ីវិលបានចំនួន១១ ៩៩៣នាក់។

- ផ្តល់សលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិល និងរៀបចំបែបបទបញ្ចូលទិន្នន័យមន្ត្រីក្របខ័ណ្ឌថ្មីបានចំនួន៤១ ៧១១នាក់។
- រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យតាំងស៊ប់ក្នុងក្របខ័ណ្ឌបានចំនួន១៩ ២៦៩នាក់។
- រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍បានចំនួន៤៧៧នាក់។
- រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យដំឡើងឋានន្តរសក្តិនិងថ្នាក់បានចំនួន៦ ៣៦៥នាក់។
- ដោយឡែកមន្ត្រីរាជការស៊ីវិលនៅទូទាំងប្រទេសក្នុងតារាងទូទាត់បៀវត្ស តាមប្រព័ន្ធព័ត៌មានវិទ្យា គិតមកដល់ខែធ្នូ ឆ្នាំ២០១២ មានចំនួនសរុប១៨១ ៩៣០នាក់។

### កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

**២.២៩-** ដើម្បីបន្តជំរុញអនុវត្ត*កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* ឲ្យបានទូលំទូលាយ និងមានប្រសិទ្ធិភាព *រាជរដ្ឋាភិបាលកម្ពុជា*នីតិកាលទី៤ បានរៀបចំ អនុម័ត និងដាក់ឲ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ខែឧសភា ឆ្នាំ២០០៨) ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ខែឧសភា ឆ្នាំ២០០៩) ការដាក់ចេញនូវ*កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* (ខែមិថុនា ឆ្នាំ២០១០) និងបានអនុម័តដាក់ឲ្យអនុវត្តនូវ*ផែនការអនុវត្តបីឆ្នាំដំបូង*(ផ.អ.៣)នៃកម្មវិធីជាតិ (ខែមិថុនា ឆ្នាំ២០១១)។ សមិទ្ធផលទាំងអស់នេះបង្ហាញឲ្យឃើញនូវឆន្ទៈដ៏ច្បាស់លាស់របស់*រាជរដ្ឋាភិបាលកម្ពុជា* ចំពោះកិច្ចដំណើរការកំណែទម្រង់ទាំងផ្នែកនយោបាយ ផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**២.៣០-** ការអនុវត្ត*ផ.អ.៣* ត្រូវបានដាក់ឲ្យមានកិច្ចដំណើរការនៅពាក់កណ្តាលឆ្នាំ២០១១ ដោយមានការផ្តោតការយកចិត្តទុកដាក់ក្នុងការបញ្ជ្រាបយេនឌ័រនិងបង្កើតឡើងនូវបែបផែននៃការគាំទ្រហិរញ្ញប្បទានក្នុងលក្ខណៈជាកញ្ចប់ថវិការួម។ ក្នុងអំឡុងពេលនៃការអនុវត្តផ.អ.៣ (ឆ្នាំ២០១១- ឆ្នាំ២០១៣) សមិទ្ធផលសំខាន់ៗជាច្រើន រួមមាន៖

- បានរៀបចំបង្កើតរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមជាមួយគ្នានោះ មន្ត្រីរាជការស៊ីវិលប្រមាណជាង១០ ០០០នាក់ ក៏ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលបានកែសម្រួលនេះផងដែរ។
- បានរៀបចំនិងដាក់ឲ្យអនុវត្តនីតិវិធីអនុវត្តការងារនិងសេចក្តីណែនាំនានារបស់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុក។ នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធនានាមួយចំនួនធំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានរៀបចំបញ្ចប់ បានកំពុងបន្តអនុវត្តការផ្តល់សេវាសម្របសម្រួល និងអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិព្រមជាមួយនឹងកិច្ចដំណើរការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ក្រៅពី

នេះ វគ្គបណ្តុះបណ្តាលយ៉ាងច្រើនក៏ត្រូវបានរៀបចំឡើងក្រោមក្របខ័ណ្ឌនៃកិច្ចដំណើរការកំណែទម្រង់។

- ក្រសួង ស្ថាប័នអាទិភាពចំនួន៥ បានរៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីបញ្ជីវិភាគមុខងារ និងកំពុងធ្វើការពិនិត្យមើលឡើងវិញនូវមុខងារ ដើម្បីឈានទៅកំណត់នូវមុខងារ និងធនធាននានាដែលត្រូវផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាលក្ខណៈអចិន្ត្រៃយ៍ ឬជាលក្ខណៈសាកល្បង។ កិច្ចដំណើរការនេះបានផ្តល់មេរៀននិងបទពិសោធជាច្រើន ហើយបច្ចុប្បន្ននេះ កម្មវិធីសាកល្បងស្តីពីការផ្ទេរមុខងារចំនួនពីរកំពុងត្រូវបានរៀបចំ។ ជាមួយគ្នានេះដែរ ការសិក្សាជាច្រើនក៏ត្រូវបានរៀបចំឡើងក្នុងន័យស្វែងយល់ និងបកស្រាយឲ្យបានច្បាស់លាស់អំពីមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំលិខិតបទដ្ឋាន សម្រាប់លើកកម្ពស់តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។
- បានរៀបចំ និងដាក់ឲ្យអនុវត្តលិខិតបទដ្ឋានពាក់ព័ន្ធនឹងប្រព័ន្ធមូលនិធិក្រុង ស្រុក និងការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ដោយទទួលបាននូវការផ្ទេរធនធានថវិកាជាតិ ប្រមាណ ០,៨% នៃចំណូលចរន្តសរុបរបស់រដ្ឋ សម្រាប់ជាចំណូលរបស់មូលនិធិក្រុង ស្រុក។ មូលនិធិនេះសំដៅគាំទ្រកម្មវិធីអភិវឌ្ឍសមត្ថភាពស្ថាប័ន ការបណ្តុះបណ្តាល និងការសម្របសម្រួលដើម្បីពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាក្រុង ស្រុក។ ព្រមជាមួយគ្នានេះ គម្រោងអភិវឌ្ឍន៍ក្រុង ស្រុក ក៏ត្រូវបានកំណត់និងរៀបចំផងដែរ។ មូលនិធិក្រុង ស្រុក នឹងត្រូវបានអនុវត្តយ៉ាងពេញលេញចាប់ពីឆ្នាំ២០១៤តទៅ។ ធនធនប្រមាណ២,៨% នៃចំណូលចរន្តសរុបរបស់រដ្ឋក៏ត្រូវបានបន្តផ្ទេរទៅឲ្យមូលនិធិឃុំ សង្កាត់ ដើម្បីបង្កលក្ខណៈឲ្យឃុំ សង្កាត់មានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការ ជាអាទិភាពនៃកិច្ចអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។
- ដើម្បីពង្រឹងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន លិខិតបទដ្ឋានគតិយុត្តសំខាន់ៗចំនួនពីរ ត្រូវបានរៀបចំនិងដាក់ឲ្យអនុវត្ត ដែលក្នុងនោះ រួមមានច្បាប់ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ*គណៈរដ្ឋមន្ត្រី* និងអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ឈប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ លិខិតបទដ្ឋានគតិយុត្តទាំងនេះបានផ្តល់នូវក្របខ័ណ្ឌគតិយុត្តឲ្យ*រាជរដ្ឋាភិបាល* ក្នុងការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ឈប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

- ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម ក៏ត្រូវបានរៀបចំតាក់តែងឡើងដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអង្គការសង្គមស៊ីវិល ហើយក៏ត្រូវបានអនុម័តដោយគ.ជ.អ.ប. នាខែសីហា ឆ្នាំ២០១៣។ ផែនការយុទ្ធសាស្ត្រនេះ នឹងត្រូវអនុវត្តរួមគ្នាដោយរាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល។ ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការអនុវត្តការងារនិងប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំបង្កើតនូវកិច្ចដំណើរការតាមដាន ត្រួតពិនិត្យរបស់ប្រជាពលរដ្ឋទៅលើការចំណាយនិងការផ្តល់សេវាសាធារណៈ ព្រមទាំងបង្កើតនូវយន្តការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលមូលដ្ឋាននិងសហគមន៍ប្រជាពលរដ្ឋក្នុងការកំណត់និងឯកភាពទៅលើវិធានការនានាសម្រាប់ការកែលម្អការផ្តល់សេវាសាធារណៈនានា។ ផែនការយុទ្ធសាស្ត្រនេះផ្តោតជាសំខាន់ទៅលើការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលមូលដ្ឋាននឹងប្រជាពលរដ្ឋ សហគមន៍ និងអង្គការសង្គមស៊ីវិលប្រកបដោយភាពស្ថាបនា។
- ប្រព័ន្ធនិងនីតិវិធីកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានរៀបចំធ្វើបច្ចុប្បន្នកម្ម។ ផ្អែកលើមូលដ្ឋាននេះ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់បានរៀបចំនិងអនុម័តនូវផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលរបស់ខ្លួន។ ជាមួយគ្នានេះដែរសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកក៏ត្រូវបានបន្តរៀបចំដើម្បីសម្របសម្រួលកិច្ចដំណើរការរៀបចំផែនការឃុំ សង្កាត់។
- វឌ្ឍនភាពគួរឲ្យកត់សម្គាល់ផងដែរ គឺការបង្កើតនូវសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិចំនួនពីរ ពោលគឺ សមាគមក្រុមប្រឹក្សារាជធានី ខេត្ត និងសមាគមក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌ និងឃុំ សង្កាត់ដែលតំណាងឲ្យផលប្រយោជន៍របស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។
- ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព តម្លាភាព សាមញ្ញ ភាពឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការនិងបង្កលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់សេវា រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីសម្រេចស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ ផ្អែកតាមសេចក្តីសម្រេចនេះ ចាប់ពីឆ្នាំ២០០៥ រហូតដល់ឆ្នាំ២០១៣ ក្រសួងមហាផ្ទៃបានបង្កើតនិងបានដាក់ឲ្យដំណើរការនូវ **"ការិយាល័យច្រកចេញចូលតែមួយ"** ចំនួន២៤ក្រុង ស្រុក នៅទូទាំង២៣ខេត្ត ដើម្បីផ្តល់សេវារដ្ឋបាលចំនួន១៨៦ប្រភេទ ដែលបានទទួលប្រតិភូកម្មមុខងារពីក្រសួង ស្ថាប័នចំនួន១០ នឹងត្រៀមដាក់ឲ្យដំណើរការនូវការិយាល័យទាំងនេះនៅក្រុង និងខណ្ឌនៃរាជធានីភ្នំពេញចំនួន១៣កន្លែងទៀត ក្នុងដើមឆ្នាំ២០១៤។ ទន្ទឹមនឹងនោះ ដើម្បីធានាបាននូវការអនុវត្តស្របតាមគោលការណ៍អភិបាលកិច្ចល្អនិងគោលការណ៍នានានៃការផ្តល់សេវាសាធារណៈ *ក្រសួងមហា*

*ផ្ទៃ* ក៏បានបង្កើតឡើងនូវការិយាល័យប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យច្រកចេញចូលតែមួយ។ ការិយាល័យប្រជាពលរដ្ឋ គឺជាស្ថាប័នឯករាជ្យ អព្យាក្រឹតមួយ និងមានភារកិច្ចទទួលនិងសម្រុះសម្រួលដោះស្រាយពាក្យបណ្ដឹងត៉ានានារបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្ដល់សេវារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

២.៣១- ទោះបីមានវឌ្ឍនភាពគួរកត់សម្គាល់ក្នុងការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលមានការពាក់ព័ន្ធទៅនឹងក្រសួង ស្ថាប័នទូទាំងរាជរដ្ឋាភិបាលទាំងមូលក៏ដោយ ក៏ការងារនេះនៅមានភាពសាំញ៉ាំនិងតម្រូវឲ្យមានការបន្តពិភាក្សាពិគ្រោះយោបល់ ដើម្បីស្វែងរកការឯកភាពគ្នាក្នុងចំណោមអ្នកធ្វើការសម្រេចចិត្តផ្នែកគោលនយោបាយ។ បញ្ហាប្រឈមសំខាន់ៗមានដូច ខាងក្រោម៖

- ការផ្ទេរមុខងារនិងធនធានពីក្រសួង ស្ថាប័ននៅថ្នាក់ជាតិឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏មានសារៈសំខាន់នៃកិច្ចដំណើរការកំណែទម្រង់ ដើម្បីកែលម្អការផ្ដល់សេវាសាធារណៈ និងគណនេយ្យភាពនៅមូលដ្ឋាន។ ទោះបីមានវឌ្ឍនភាពគួរកត់សម្គាល់ក្នុងកិច្ចដំណើរការរៀបចំបញ្ជីវិភាគមុខងារនិងការពិនិត្យមើលមុខងារឡើងវិញក៏ដោយ ក៏មកទល់បច្ចុប្បន្ននេះ ពុំទាន់មានមុខងារជាក់លាក់ណាមួយត្រូវបានផ្ទេរឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ បញ្ហាប្រឈមជាគន្លឹះក្នុងកិច្ចការនេះ គឺការស្វែងរកការឯកភាពគ្នាអំពីមុខងារនានា ដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនិងការរៀបចំបង្កើតយន្តការសម្រាប់គាំទ្រ សម្របសម្រួល និងតាមដានត្រួតពិនិត្យវាយតម្លៃដំណើរការផ្ទេរមុខងារទាំងនោះដើម្បីធានាថាកិច្ចដំណើរការនេះពុំមានការរំខានដល់កិច្ចអភិវឌ្ឍនិងការផ្ដល់សេវានានានៅមូលដ្ឋាន។
- កម្មវិធីជាតិនិង*ផ.អ.៣* បានកំណត់អំពីយន្តការនានាសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុពីថ្នាក់ជាតិទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រភពចំណូលមូលដ្ឋាននានា។ ទោះបីជាមូលនិធិក្រុង ស្រុកត្រូវបានបង្កើតឡើង ប៉ុន្តែយន្តការផ្សេងៗទៀតរួមមាន យន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ យន្តការផ្ទេរហិរញ្ញប្បទានវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងយន្តការចំណូលផ្ទាល់នៅមូលដ្ឋាន កំពុងស្ថិតនៅក្នុងដំណាក់កាលនៃការសិក្សាដើម្បីរៀបចំបង្កើតនៅឡើយ។
- បុគ្គលិកបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវមានគណនេយ្យភាពជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ននេះបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់ត្រូវបានផ្ទេរឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ អាស្រ័យហេតុនេះរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវការចាំបាច់នូវការផ្ដល់អំណាចឲ្យកាន់តែច្រើនឡើងក្នុងការគ្រប់គ្រង ការចាត់ចែង ការជ្រើសរើស ការតែងតាំង ការផ្លាស់ប្ដូរ ការបញ្ចប់

ភារកិច្ច ការដាក់វិន័យ ការផ្តល់រង្វាន់លើកទឹកចិត្ត និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់ខ្លួន។ បញ្ហាប្រឈមចំពោះកិច្ចការនេះ គឺការផ្តល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវស្វ័យភាពដែលបច្ចុប្បន្ននេះស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រងមន្ត្រីមុខងារសាធារណៈរបស់ថ្នាក់ជាតិ។

- ការពង្រឹងគណនេយ្យភាពខ្សែទទឹងនិងខ្សែបណ្តោយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាគោលបំណងដ៏សំខាន់មួយនៃ *ផ.អ.៣*។ ពាក់ព័ន្ធនឹងបញ្ហានេះ ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលចាំបាច់ត្រូវបានពិនិត្យមើលឡើងវិញ ហើយជាមួយគ្នានេះដែរតួនាទីរបស់ក្រុមប្រឹក្សាក្នុងការតាមដានត្រួតពិនិត្យលើការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិក៏តម្រូវឲ្យមានការពង្រឹងបន្ថែមទៀតផងដែរ។ លើសពីនេះ ថ្នាក់ជាតិចាំបាច់ត្រូវពង្រឹងការរៀបចំគោលនយោបាយស្តីពីអធិការកិច្ចនិងស្តង់ដាសេវាសាធារណៈផងដែរ។
- យន្តការនានា ក៏តម្រូវឲ្យមានការរៀបចំបន្ថែមទៀតដើម្បីជំរុញលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើតនូវគំនិតផ្តួចផ្តើមនានា ក្នុងវិសាលភាពនៃអាណត្តិទូទៅរបស់ខ្លួនពាក់ព័ន្ធទៅនឹងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

## ១.៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

២.៣២- កំណែទម្រង់កងយោធពលខេមរភូមិន្ទ ដែលជាមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ទាមទារនូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពខ្ពស់នូវអធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមនៃព្រះរាជាណាចក្រកម្ពុជា។ ដោយផ្អែកលើ *យុទ្ធសាស្ត្រការពារជាតិ* ដូចបានចែងនៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* និង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣* របស់ *រាជរដ្ឋាភិបាលកម្ពុជា*។ កំណែទម្រង់កងយោធពលខេមរភូមិន្ទសម្រេចបាននូវកិច្ចការដូចខាងក្រោម៖

- *កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ* : *កងយោធពលខេមរភូមិន្ទ* បានធ្វើការកែទម្រង់រចនាសម្ព័ន្ធចាត់តាំងតាមបណ្តាអង្គភាពបានយ៉ាងសមស្រប ព្រមទាំងបានធ្វើការហ្វឹកហាត់ពង្រឹងសមត្ថភាពដល់យោធិន ទាំងផ្នែកបច្ចេកទេសនិងយុទ្ធវិធី។ *កងយោធពលខេមរភូមិន្ទ* ថែមទាំងបានរៀបចំគោលនយោបាយសម្រាប់យោធិនទាំងប្រភេទទី២ និងយោធិនចូលនិវត្តន៍បានយ៉ាងប្រសើរទៀតផង។
- *ការការពារព្រំដែន* : *កងយោធពលខេមរភូមិន្ទ* បានខិតខំការពារជាតិនិងពង្រឹងការងារការទូតជាមួយបណ្តាប្រទេសផ្សេងៗ។
- *ការកសាងសមត្ថភាពកងកម្លាំងប្រដាប់អាវុធ* : ដើម្បីបង្កើនសមត្ថភាពកងកម្លាំងប្រដាប់អាវុធកងយោធពលខេមរភូមិន្ទ បានបន្តបណ្តុះបណ្តាលដល់យោធិនទាំងយុទ្ធវិធីនិងការងារការទូតក្នុងវិស័យការពារជាតិ របៀបប្រើប្រាស់បច្ចេកវិទ្យាទំនើប ចំណេះដឹង និងជំនាញ

ថ្មីៗ ការធ្វើឲ្យទំនើបកម្មអាវុធយុទ្ធភណ្ឌ និងការចូលរួមបេសកកម្មថែរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ។

- *ការអភិវឌ្ឍសហគមន៍ :* សង្គ្រាមបានបន្សល់ទុកនូវគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅតាមទីជនបទជាច្រើន ដែលតម្រូវឲ្យកងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ ដោយសហការជាមួយ *អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន* និង អង្គភាពកំចាត់មីនជាច្រើនក្រុមត្រូវដើរតួនាទីយ៉ាងសំខាន់សម្រាប់បោសសម្អាតគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះទាំងអស់នោះ។ ផ្ទៃដីដែលទទួលបានការបោសសម្អាតមីនរួចបានក្លាយជាដីសម្បទានសង្គមកិច្ចពីរដ្ឋាភិបាលសម្រាប់បង្កបង្កើនផលកសិកម្ម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានបង្កើតមជ្ឈមណ្ឌលកម្ចាត់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះមួយចំណុះឲ្យក្រសួងការពារជាតិផងដែរ។
- *ការអភិវឌ្ឍការងារធុរកិច្ច : កងយោធពលខេមរភូមិន្ទ*ទទួលបានសិទ្ធិឲ្យធ្វើអាជីកម្មនានាចាប់តាំងពីឆ្នាំ២០១២។ ក្នុងន័យនេះ *កងយោធពលខេមរភូមិន្ទ* បានបង្កើតនាយកដ្ឋានអភិវឌ្ឍន៍ក្រោមចំណុះ*ក្រសួងការពារជាតិ* ដើម្បីស្វែងរកប្រភពចំណូលពង្រីកកិត្យានុភាពកងទ័ពនិងបង្កើនកម្រិតជីវភាពរស់នៅរបស់សហគមន៍កងទ័ព។
- *ការលើកកម្ពស់យេនឌ័រ :* ឆ្លើយតបទៅនឹងទិសដៅលើកកម្ពស់សមភាពយេនឌ័រ *កងយោធពលខេមរភូមិន្ទ* បាននឹងបន្តខិតខំជំរុញយោធិនស្ត្រីឲ្យទទួលបានមុខតំណែងដឹកនាំសមស្របមួយចំនួនក្នុងអង្គភាព ថ្វីត្បិតតែចំនួនយោធិនស្ត្រីនៅមានកម្រិតទាបនៅឡើយ។ ការយល់ដឹងពីសមភាពយេនឌ័រក្នុងសហគមន៍កងទ័ពមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ប៉ុន្តែចាំបាច់ទាមទារនូវកិច្ចពង្រឹងបន្ថែមទៀត។

**២.៣៣-** ទោះបីមានវឌ្ឍនភាពគួរជាទីមោទនៈក្នុងដំណើរការនៃកំណែទម្រង់របស់ខ្លួនក៏ដោយក៏កងយោធពលខេមរភូមិន្ទនៅមានបញ្ហាប្រឈមមួយចំនួន ដែលត្រូវបំពេញនិងបន្តអនុវត្តៈ

- *ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស និងវិជ្ជាជីវៈ៖ កងយោធពលខេមរភូមិន្ទ* នៅប្រឈមនឹងការងារពង្រឹងនិងពង្រីកសកម្មភាពការពារ ឧស្សាហកម្មការពារជាតិ ការអភិវឌ្ឍការងារធុរកិច្ច ចំណេះដឹងអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស និងវិជ្ជាជីវៈ ដែលបញ្ហាទាំងអស់នេះ តម្រូវឲ្យមានការស្វែងរកប្រភពជំនួយផ្សេងៗ។
- *ធនធានរូបវន្ត :* ធនធានរូបវន្តរបស់*កងយោធពលខេមរភូមិន្ទ* ដូចជាដីធ្លី សម្ភារៈបរិក្ខារ រោងចក្រ គ្រឿងចក្រ សហគ្រាសនានា ពុំទាន់ត្រូវបានប្រើប្រាស់ឲ្យមានប្រសិទ្ធភាពខ្ពស់ឲ្យអស់លទ្ធភាព និងសក្តានុពលនៅឡើយ ដើម្បីទាញយកប្រយោជន៍ឲ្យបានជាអតិបរមា។ ទាំងអស់នេះ ជាមូលហេតុធ្វើឲ្យកម្រិតជីវភាពរស់នៅរបស់សហគមន៍កងទ័ពស្ថិតក្នុងភាពលំបាក។

- *ការងារអភិវឌ្ឍន៍សហគមន៍កងទ័ព* : មិនទាន់មានដៃគូអភិវឌ្ឍជាយុទ្ធសាស្ត្រ ដើម្បីធ្វើកិច្ចសហប្រតិបត្តិការវិនិយោគធុរកិច្ចយូរអង្វែង។

## ២- បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

២.៣៤- ទិដ្ឋភាពសំខាន់ៗចំនួនបួន គឺ (១)សុខសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម (២)សមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងពិភពលោក (៣)បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និង (៤)ភាពជាដៃគូនៅក្នុងការអភិវឌ្ឍដែលត្រូវបានអនុវត្តដោយ*រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៤នៃរដ្ឋសភា*។

### ២.១- សុខសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម

២.៣៥- បច្ចុប្បន្ននេះ ប្រពៃណីនៃការរៀបចំបោះឆ្នោតដោយសេរីនិងយុត្តិធម៌ត្រូវបានបង្កើតឡើងឲ្យមានសភាពរឹងមាំល្អ។ រហូតមកទល់នឹងពេលនេះ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវបានរៀបចំធ្វើឡើងចំនួន៥ដងរួចមកហើយ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយបង្អស់ត្រូវបានរៀបចំធ្វើឡើងកាលពីខែកក្កដា ឆ្នាំ២០១៣។ ការបោះឆ្នោតជ្រើសតាំង*ក្រុមប្រឹក្សាឃុំ សង្កាត់* ទូទាំងប្រទេស ត្រូវបានរៀបចំធ្វើឡើងចំនួន៣ដងរួចមកហើយ លើកទី១ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០២ លើកទី២ នៅក្នុងខែមេសា ឆ្នាំ២០០៧ និងលើកទី៣ នៅក្នុងខែមិថុនា ឆ្នាំ២០១២។ *ព្រឹទ្ធសភា* ត្រូវបានបង្កើតឡើង ជាសភាជាន់ខ្ពស់ តាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៅខែមីនា ឆ្នាំ១៩៩៩។ ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភាលើកទី១ និងលើកទី២ ត្រូវបានធ្វើឡើងនៅក្នុង ខែមករា ឆ្នាំ២០០៦ និងឆ្នាំ២០១២។ បច្ចុប្បន្ននេះ យុគសម័យនៃស្ថិរភាពដ៏រឹងមាំមួយត្រូវបានបង្កើតឡើង ដោយមានការគិតគូរជាចម្បងលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនៅក្នុងបរិស្ថានមួយ ដែលមានការទទួលខុសត្រូវចំពោះអ្វីទាំងឡាយដែលបុគ្គលម្នាក់ៗបានសម្តែងចេញមក ទាំងនៅក្នុងរង្វង់រាជរដ្ឋាភិបាលទាំងនៅក្នុងរង្វង់សាធារណជន។ *រាជរដ្ឋាភិបាល*ខិតខំយ៉ាងខ្លាំងដើម្បីធានាថា សមិទ្ធផលដែលសម្រេចបានដោយលំបាកនេះបន្តរីកចម្រើននិងជ្រួតជ្រាបយ៉ាងពេញលេញនៅក្នុងសង្គមជាតិកម្ពុជា និងផ្នត់គំនិតរបស់ប្រជាជនកម្ពុជា។

២.៣៦- *ក្រសួងមហាផ្ទៃ* មានតួនាទីចម្បងបី ៖ (១)គ្រប់គ្រងស្ថាប័នរដ្ឋបាលសាធារណៈ នៅថ្នាក់ក្រោមជាតិ (២)ធានានូវសន្តិសុខផ្ទៃក្នុងរបស់សង្គមជាតិ តាមរយៈកងកម្លាំងនគរបាលជាតិ និង (៣)ដឹកនាំនិងសម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងឋានៈជាប្រធានរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)។ រហូតមកទល់ពេលនេះ *ក្រសួង*

*មហាផ្ទៃ* បានធ្វើឲ្យមានវឌ្ឍនភាពជាច្រើននៅក្នុងការពង្រឹងស្ថាប័នរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ ការធានានូវសន្តិសុខផ្ទៃក្នុងរបស់សង្គមជាតិ និងការដាក់ឲ្យដំណើរការនូវយន្តការជាច្រើន ដើម្បីដឹកនាំដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការសំដៅធ្វើឲ្យសម្រេចបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**២.៣៧-** តាមរយៈកងកម្លាំងនគរបាលជាតិ *ក្រសួងមហាផ្ទៃ* បានចូលរួមយ៉ាងសកម្មនៅក្នុងការបញ្ចៀសនូវសកម្មភាពភេរវកម្មទាំងឡាយ ការរក្សាបាននូវសេចក្តីសុខក្សេមក្សាន្តជូនប្រជាពលរដ្ឋ ការទប់ស្កាត់នូវរាល់ឧបាយកលទាំងឡាយដែលប៉ុនប៉ងបំបែកបំបាក់សាមគ្គីភាពជាតិ និងបង្កអស្ថិរភាពនយោបាយនិងភាពចលាចលវឹកវរក្នុងសង្គម ព្រមទាំងការរារាំងប្រកបដោយប្រសិទ្ធភាពនូវមហិច្ឆតាប៉ុនប៉ងប្រើប្រាស់ទឹកដីកម្ពុជាដើម្បីបំផ្លិចបំផ្លាញប្រទេសជិតខាង។ សមិទ្ធផលដ៏គួរឲ្យកត់សម្គាល់ គឺការការពារបានទាំងស្រុងនូវសុវត្ថិភាពនិងសន្តិសុខសម្រាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ ឆ្នាំ២០១២ ការរៀបចំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ កាលពីខែកក្កដា ឆ្នាំ២០១៣ កន្លងទៅ ព្រមទាំងការការពារបាននូវសុវត្ថិភាពនៃដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា។

**២.៣៨-** *ក្រសួងមហាផ្ទៃ* បានអនុវត្តកិច្ចការបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទប្រកបដោយជោគជ័យក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនប្រជាជនពិសេស តាមរយៈការអនុវត្តគោលនយោបាយ *ភូមិ ឃុំ មានសុវត្ថិភាព*។

**២.៣៩-** ទោះបីមានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និងសមិទ្ធផលដ៏គួរឲ្យកត់សម្គាល់ជាច្រើន ក៏ដោយ ក៏ការអនុវត្តភារកិច្ចខាងលើនេះ នៅតែបានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ដែលរួមមាន កម្រិតសមត្ថភាពផ្នែកស្ថាប័ន ក្នុងនោះ ធនធានមនុស្សនិងសម្ភារៈ និងភាពមានកម្រិតនៃក្របខ័ណ្ឌច្បាប់ សម្រាប់តម្រង់ទិសដល់ការអនុវត្តភារកិច្ច។ ភាពខ្វះចន្លោះដែលនៅមាននៅក្នុងប្រព័ន្ធការងាររបស់យើង ងាយនឹងអនុញ្ញាតឲ្យពួកឧក្រិដ្ឋជនឆ្លងដែនដែលមានអង្គការចាត់តាំងឆ្លៀតឱកាសប្រើប្រាស់គ្រប់រូបភាពដើម្បីឆ្លងកាត់និងលាក់ខ្លួននៅកម្ពុជា ដើម្បីគេចពីសំណាញ់ច្បាប់និងបន្តធ្វើសកម្មភាពឧក្រិដ្ឋនានា។ ការងារគ្រប់គ្រងត្រួតពិនិត្យជនបរទេសនៅមិនទាន់ត្រូវបានអនុវត្តស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានឲ្យបានដល់កម្រិតមួយដែលការងារគ្រប់គ្រងត្រួតពិនិត្យនេះត្រូវតែមាន ដើម្បីរួមចំណែកដល់ការរក្សាសន្តិសុខជាតិ និងការទាញយកអត្ថប្រយោជន៍ពីវត្តមានជនបរទេសនៅក្នុងប្រទេស សម្រាប់ការរីកចម្រើនផ្នែកសង្គម សេដ្ឋកិច្ចរបស់កម្ពុជានៅឡើយ។ ទោះបីបទល្មើសព្រហ្មទណ្ឌ បានថយចុះជាលំដាប់ក៏ដោយក៏សកម្មភាពប្លន់ប្រដាប់អាវុធ អំពើឃាតកម្ម ចរាចរណ៍ជួញដូរគ្រឿងញៀនខុសច្បាប់ ការរំលោភសេពសន្ថវៈ ការជួញដូរស្ត្រីនិងកុមារ ព្រមទាំងបទល្មើសប្រភេទផ្សេងៗទៀត ដូចជា បទល្មើសផ្នែកបច្ចេក

វិទ្យា និងការសម្អាតប្រាក់ ជាដើម នៅតែកើតមានឡើងជាញឹកញាប់នៅឡើយ។ គ្រោះថ្នាក់ចរាចរណ៍នៅតែបានបន្តកើតឡើងជាញឹកញាប់គួរឲ្យព្រួយបារម្ភ។ ការងារគ្រប់គ្រងរដ្ឋបាលមានលក្ខណៈប្រឈមខ្លាំងនៅតាមទីប្រជុំជនធំៗ ដោយសារបាតុភាពបាត់សណ្តាប់ធ្នាប់បង្កឡើងដោយក្រុមក្មេងទំនើងនៅតាមទីសាធារណៈ អាហារដ្ឋាន និងក្លឹបកម្សាន្តរាត្រី។ ប្រការនេះបានជះឥទ្ធិពលអាក្រក់ដល់ស្រទាប់យុវជន ដោយធ្វើឲ្យមានការកើនឡើងនូវសកម្មភាពខុសឆ្គងជាច្រើន និងបានធ្វើឲ្យយុវជនទាំងនោះបោះបង់ចោលការសិក្សារៀនសូត្ររបស់ខ្លួន ហើយឈានទៅដល់ការប្រព្រឹត្តនូវបទល្មើសផ្សេងៗ។

## ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

២.៤០- *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* ដោយមានកិច្ចសហការជាជាមួយក្រសួង ស្ថាប័ន អន្តរវិស័យជាតិ អន្តរជាតិ និងកម្លាំងសរុបរបស់សង្គម សម្រេចបាននូវសមិទ្ធផលមួយចំនួនគួរឲ្យកត់សម្គាល់៖

- *ការពង្រឹងស្ថាប័ន* : *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* គឺជាការទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយការត្រួតពិនិត្យគ្រឿងញៀន។ អាជ្ញាធរបានបង្កើតច្បាប់ស្តីពីការត្រួតពិនិត្យនៃការភ្ជាប់ជាមួយនឹងថ្នាំអនុសញ្ញាទាំងបីនៃការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិឆ្នាំ១៩៦១ ឆ្នាំ១៩៧១ និងឆ្នាំ១៩៨៨ ព្រមទាំងពិធីសារឆ្នាំ១៩៧២ ដែលជាច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀនដែលត្រូវបានអនុម័តនិងប្រកាសឱ្យប្រើនៅក្នុងខែមករា ឆ្នាំ២០១២។
- *ការកាត់បន្ថយគ្រឿងញៀន* : អាជ្ញាធរជាតិ បានបង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួង ខេត្ត និងបណ្តាដៃគូអភិវឌ្ឍដទៃទៀត។ អាជ្ញាធរគ្រឿងញៀនក៏បានផ្សព្វផ្សាយជាសាធារណៈ អំពីផលអវិជ្ជមានបណ្តាលពីការប្រើប្រាស់គ្រឿងញៀន។ សកម្មភាពពាក់ព័ន្ធនឹងការកាត់បន្ថយតម្រូវការគ្រឿងញៀន មានដូចខាងក្រោម៖
  - ការបញ្ជ្រាបការយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងកម្មវិធីសិក្សាជាតិ។
  - ការអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ឲ្យបដិសេធគ្រឿងញៀន។
  - ការអប់រំផ្សព្វផ្សាយនៅតាមបណ្តាញសារព័ត៌មាន។
  - ការអប់រំផ្សព្វផ្សាយនៅក្នុងឱកាសនៃ ថ្ងៃឈប់សម្រាកជាតិ និងអន្តរជាតិ។
  - ការអប់រំផ្សព្វផ្សាយលើគម្របនៃផលិតផល អំពីសារអប់រំគ្រឿងញៀននៅលើវិក្កយបត្រ ដបទឹក ធុង ប្រអប់ និងរថយន្តក្រុង។
  - ការអប់រំផ្សព្វផ្សាយតាមសេវាកម្មកម្សាន្ត នៅក្នុងសណ្ឋាគារ សមាគមន៍ដឹកជញ្ជូនទេសចរណ៍ កន្លែងកម្សាន្ត ផ្ទះសំណាក់ ដើម្បីចែកចាយព័ត៌មានស្តីពីការត្រួតពិនិត្យគ្រឿង

ញៀន ហានិភ័យដែលបង្កឡើងដោយការញៀនថ្នាំ និងគ្រឿងញៀន និងបញ្ហាមេរោគអេដស៍/ជំងឺអេដស៍ នៅក្នុងតំបន់មួយចំនួនមានហានិភ័យខ្ពស់។

- ➢ ការអប់រំផ្សព្វផ្សាយតាមរយៈដាក់សារនៅក្នុងស៊ីឌី វីស៊ីឌី ខារ៉ាអូខេ នេះ មានចំនួន១៣៤ ចំណងជើង និងលើកទឹកចិត្តអង្គការ ដើម្បីបង្ហាញជាសាធារណៈដល់ប្រជាជនអំពីទម្រង់នៃសិល្បៈនិងទស្សនីយភាព ដែលទាក់ទងនឹងការអប់រំគ្រឿងញៀន។
- ➢ ការអប់រំផ្សព្វផ្សាយតាមរយៈការប្រឡងកំណាព្យ ចម្រៀង គំនូរ និងកម្មវិធី ប្រគុំតន្ត្រី ដោយផ្សាយតាមវិទ្យុ ទូរទស្សន៍ ជាពិសេសជាមួយនឹងការចូលរួមពីតារាសម្តែងនិងតារាកំប្លែង។

- *ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន* : *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*បានសម្របសម្រួលបង្កើនកិច្ចសហប្រតិបត្តិការជាមួយ ក្រសួង ស្ថាប័ន ជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងស្ថាប័នអនុវត្តច្បាប់នានា បានចាត់វិធានការបង្ក្រាបបទល្មើសបានទាន់ពេលវេលាទាំងករណីប៉ុនប៉ងផលិត ចរាចរឆ្លងកាត់ ការជួញដូរចែកចាយ ករណីបង្វែរសារធាតុគីមីផ្សំ ជាទ្រង់ទ្រាយធំ មធ្យម និងតូច។ អាជ្ញាធរក៏បានបង្ក្រាបការទាញយកសារធាតុគីមីខុសច្បាប់ពីរុក្ខជាតិម្រះព្រៅ។
- *ការពង្រឹងប្រសិទ្ធភាពនៃការព្យាបាលស្តារនីតិសម្បទានិងសមាហរណកម្ម* : អាជ្ញាធរជាតិបានខិតខំពុះពារសម្រេចឱ្យបាននូវកិច្ចការមួយចំនួនគួរជាទីមោទនៈដូចជា៖

- ➢ បានរៀបចំបង្កើតសៀវភៅគោលការណ៍ណែនាំស្តីពីការបន្សាបនិងព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមន្ទីរពេទ្យបង្អែកនិងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមបណ្តារាជធានី ខេត្ត។
- ➢ រាជរដ្ឋាភិបាលសម្រេចផ្តល់នូវរបបជីវភាព ជូនដល់ជនរងគ្រោះដែលកំពុងសម្រាកព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្ន អប់រំ ព្យាបាលអ្នកញៀនគ្រឿងញៀន និង មណ្ឌលស្តារនីតិសម្បទាដែលគ្រប់គ្រងដោយ*ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*។
- ➢ បានជំរុញកម្មវិធីបន្សាប ព្យាបាលអ្នកញៀនគៀងញៀនតាមនិយាមវេជ្ជសាស្ត្រនៅតាមមណ្ឌលបណ្តោះអាសន្ន អប់រំ និងព្យាបាលអ្នកញៀនគ្រឿងញៀន។
- ➢ បានអនុម័តយកការអនុវត្តកម្មវិធី ព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហ-គមន៍ ដែលកម្មវិធីនេះអនុវត្តដោយសេវាសុខភាពផ្លូវចិត្តនិងគ្រឿងញៀននៃ*ក្រសួងសុខាភិបាល*។
- ➢ ការអនុវត្តកម្មវិធីព្យាបាលអ្នកប្រើគ្រឿងញៀនប្រភេទអាភៀន ដោយឱសថមេតាដូន ក៏បានដំណើរការនៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត។

- ការរៀបចំយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀនឆ្នាំ២០០៨-២០១០ សម្រាប់ធ្វើជាឯកសារគោលអនុវត្តន៍កម្មវិធីកាត់បន្ថយគ្រោះថ្នាក់នៅកម្ពុជា។
- បានរៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីម្ទុល/សឺរ៉ាំងនៅកម្ពុជា ដើម្បីជួយទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន។
- ការវាយតម្លៃអំពីលទ្ធផលនិងអនុសាសន៍សម្រាប់ការពង្រីកសេវា និងលើកកម្ពស់គុណភាពសេវាកម្មវិធីម្ទុលសឺរ៉ាំងនៅកម្ពុជា។

• *ការពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់*

- សហការជាមួយអាជ្ញាធរដែនដី មន្ទីរទេសចរណ៍រាជធានី ខេត្ត ដើម្បីធ្វើកិច្ចសន្យាជាមួយម្ចាស់មូលដ្ឋានអាជីវកម្ម សេវាទេសចរណ៍នានា ទីកន្លែងកម្សាន្តសប្បាយ សំដៅទប់ស្កាត់ការជួញដូរ ការចែកចាយ ការប្រើបំពានគ្រឿងញៀនខុសច្បាប់។
- ការិយាល័យទំនាក់ទំនងព្រំដែនចំនួន១៤កន្លែងត្រូវបានបង្កើតឡើងនៅតាមបណ្តោយព្រំដែនប្រទេស និងតាមដងទន្លេមេគង្គដើម្បីត្រួតពិនិត្យ និងទប់ស្កាត់ការជួញដូរគ្រឿងញៀន និងសារធាតុគីមីផ្សំឆ្លងកាត់ព្រំដែន។
- មន្ត្រីអនុវត្តច្បាប់គ្រឿងញៀននៅតាមរាជធានី ខេត្តចំនួន១១ ត្រូវបានបណ្តុះបណ្តាលលើជំនាញការងារត្រួតពិនិត្យគ្រឿងញៀននិងការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន។
- ឯកសារបណ្តុះបណ្តាលស្តីពីការងារត្រួតពិនិត្យសារធាតុគីមីផ្សំ ត្រូវបានផលិតឡើងជា DVD សម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់និងមន្ត្រីត្រួតពិនិត្យ ដែលបម្រើការនៅតាមស្រុក ក្រុង ជាប់ព្រំដែនជិតនឹងការិយាល័យទំនាក់ទំនងព្រំដែន នៅទូទាំងប្រទេស។
- ការផ្លាស់ប្តូរបទពិសោធ និងការបណ្តុះបណ្តាលជំនាញនៅបរទេស។

• *ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ : អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* បានបន្តពង្រឹងនិងពង្រីកឥតឈប់ឈរនូវកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិតាមច្រើនរូបភាព៖

- កិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសជិតខាង។
- កិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ។
- កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ។

២.៤១- រយៈពេលនៃការអនុវត្ត*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន មានចំណុចប្រឈមមួយចំនួន ដែលធ្វើឲ្យមានការលំបាកដល់ការអនុវត្តដូចជាៈ

- ប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមបណ្ដាប្រទេសនៅក្នុងតំបន់រងផលប៉ះពាល់គ្រប់ទម្រង់ពីការរំលោភបំពានគ្រឿងញៀន ទាំងថ្នាំធម្មជាតិទាំងថ្នាំសំយោគ តាមរយៈតំបន់ត្រីកោណមាសដែលជាប្រភពនៃការផលិតពូជថ្នាំ និងមានទីតាំងភូមិសាស្ត្រមួយអំណោយផលដល់ឧក្រិដ្ឋជនសម្រាប់ការជួញដូរគ្រឿងញៀន។ ឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិបានធ្វើការប៉ុនប៉ងប្រើទីតាំងភូមិសាស្ត្រកម្ពុជាផលិតថ្នាំញៀននិងឆ្លងកាត់ តាមរយៈបណ្ដាញអង្គការរៀបចំនិងយុទ្ធវិធីស្មុគស្មាញ។
- និន្នាការនៃការផលិតគ្រឿងញៀនសំយោគមានការកើនឡើង ស្របពេលនឹងតម្រូវការនៃសារធាតុគីមីផ្សំដ៏ច្រើនលើសលប់សម្រាប់បម្រើឲ្យវិស័យឧស្សាហកម្ម គួបផ្សំនឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ក្នុងការត្រួតពិនិត្យនិងគ្រប់គ្រងសារធាតុគីមីផ្សំទាំងនោះ នៅមានកម្រិត ជាឱកាសឲ្យពួកឈ្មួញគ្រឿងញៀន លួចបង្វែរសារធាតុទាំងនេះ ទៅផលិតគ្រឿងញៀនខុសច្បាប់។
- កត្តាប្រឈមជាច្រើន ដូចជា សមត្ថភាពមន្ត្រីអនុវត្តច្បាប់ ធនធានហិរញ្ញវត្ថុ សម្ភារៈ និងសីលធម៌វិជ្ជាជីវៈ បណ្ដាលឲ្យការប្រយុទ្ធប្រឆាំងនឹងអ្នកចរាចរគ្រឿងញៀនពីបណ្ដាប្រទេសទាំងអស់នៅក្នុងតំបន់ឲ្យបានអនុវត្តក្នុងពេលដំណាលគ្នាមានភាពពិបាក។
- ប្រទេសក្នុងតំបន់និងលើសកលលោកពុំទាន់រកឃើញរូបមន្ត ដែលអនុវត្តបានជាសកលក្នុងការព្យាបាល ស្ដារនីតិសម្បទា សមាហរណកម្ម ចាកចេញពីគ្រឿងញៀន និងការលាប់ឡើងវិញ។
- វិបត្តិហិរញ្ញវត្ថុពិភពលោកធ្វើឲ្យកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅមានកម្រិត។

## ២.២- សមាហរណកម្មប្រទេសកម្ពុជាក្នុងតំបន់និងពិភពលោក

២.៤២- សមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍អន្តរជាតិ ជាពិសេស អនុតំបន់ តំបន់ និងពិភពលោក បានរួមចំណែកយ៉ាងសំខាន់ដល់ការលើកស្ទួយកិត្យានុភាព*ព្រះរាជាណាចក្រកម្ពុជា*។ ប្រទេសកម្ពុជាបានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវក្របខ័ណ្ឌគោលនយោបាយការបរទេស សន្តិភាព អព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ បានខិតខំកសាងពង្រឹងទំនាក់ទំនងមិត្តភាពអន្តរជាតិ និងកិច្ចសហប្រតិបត្តិការទ្វេភាគី ព្រមទាំងពង្រឹងសមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោកនិងសហគមន៍អាស៊ាន តាមរយៈការអនុវត្តតួនាទីស្មើភាពនិងស្មើសិទ្ធិរបស់ខ្លួន សំដៅធានាបានផលប្រយោជន៍ទៅវិញទៅមក។

**២.៤៣** បច្ចុប្បន្នកម្ពុជាមានទំនាក់ទំនងការទូតជាមួយប្រទេសជាមិត្តចំនួន១៦៥ (រួមបញ្ចូលទំនាក់ទំនងការទូតជាមួយប្រទេសទួកគី និងបេឡារ៉ូស) មានស្ថានឯកអគ្គរាជទូត ស្ថានបេសកកម្មអចិន្ត្រៃយ៍ និងស្ថានអគ្គកុងស៊ុលប្រចាំនៅបរទេសសរុបចំនួន៣៤។ រីឯស្ថានទូតបរទេសនៅភ្នំពេញ សរុបទាំងអស់មានចំនួន២៦។

**២.៤៤-** កម្ពុជាបានចូលរួមយ៉ាងសកម្ម ក្នុងសហគមន៍អន្តរជាតិនិងតំបន់។ ជាលទ្ធផលសកម្មភាពកិច្ចសហប្រតិបត្តិការ រួមមានលើវិស័យ នយោបាយ សន្តិសុខ សេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គមកិច្ច និងបរិស្ថាន។ល។ ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០១២ កម្ពុជាបានដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា កិច្ចសន្ទនាអាស៊ានជាសកល ដែលជាលើកទី១ក្នុងប្រវត្តិអាស៊ាន និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ពាក់ព័ន្ធផ្សេងៗទៀត ដូចជា ក្នុងក្របខ័ណ្ឌតំបន់ និងអនុតំបន់ ដែលរួមមានកិច្ចប្រជុំអាស៊ី អឺរ៉ុប កិច្ចប្រជុំកំពូលអាស៊ីបូព៌ា វេទិកាតំបន់អាស៊ាន កិច្ចសន្ទនាស្តីពីសហប្រតិបត្តិការអាស៊ី សន្និសីទស្តីពីអន្តរសកម្មភាព និងវិធានការកសាងទំនុកចិត្តនៅអាស៊ី សហប្រតិបត្តិការត្រីកោណ កម្ពុជា ឡាវ វៀតណាម សហប្រតិបត្តិការ កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម សហប្រតិបត្តិការ កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម(ACMECS) មហាអនុតំបន់មេគង្គ កិច្ចសហប្រតិបត្តិការមេគង្គ គង្គា និងមេគង្គ ជប៉ុន មេគង្គ សាធារណរដ្ឋកូរ៉េ និងគំនិតផ្តួចផ្តើមមេគង្គខាងក្រោមជាមួយសហរដ្ឋអាមេរិក។ល។

**២.៤៥-** សមិទ្ធផលសំខាន់ៗផ្សេងៗ ដែលរាជរដ្ឋាភិបាលសម្រេចបាន មានជាអាទិ៍៖

- កម្ពុជាបានជាប់ឆ្នោតជាសមាជិកនៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ២០០៩ ហើយក្នុងឆ្នាំ២០១៣ ក្នុងឋានៈជាប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក កម្ពុជាត្រូវបានជ្រើសរើសធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មាធិការលើកទី៣៧ ផងដែរ។
- ក្នុងក្របខ័ណ្ឌអន្តរជាតិ កម្ពុជាបានចូលរួមបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅប្រទេសស៊ូដង់ និងស៊ូដង់ខាងត្បូង ឆាដ លីបង់ និងស៊ីរី អាហ្វ្រិកកណ្តាល ម៉ាលី ព្រមទាំងបានបញ្ជូនកម្លាំងចូលរួមសមយុទ្ធពហុសាសន៍និងក៏បានធ្វើជាម្ចាស់ផ្ទះសមយុទ្ធពហុសាសន៍។
- កម្ពុជាបានចូលជាភាគីអនុសញ្ញាអន្តរជាតិជាច្រើនដែលមានជាអាទិ៍ អនុសញ្ញានិងពិធីសារស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មចំនួន១២ អនុសញ្ញានានាពាក់ព័ន្ធនឹងការគាំពារសិទ្ធិពលករ និងសិទ្ធិមនុស្ស ការអភិរក្ស និងការពារបរិស្ថាន ការកាត់បន្ថយនិងការត្រួតពិនិត្យសព្វាវុធធុនស្រាល ការមិនសាយភាយអាវុធនុយក្លេអ៊ែរនិងអាវុធគីមី។ ល។

## ២.៣- បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ

### ក- ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០០៩-២០១៣

២.៤៦- កំណើនសេដ្ឋកិច្ចជាមធ្យមសម្រេចបាន៥,៦% ក្នុងមួយឆ្នាំ។ ប៉ុន្តែប្រសិនបើកំណើននៅក្នុងឆ្នាំ២០០៩(វិបត្តិសេដ្ឋកិច្ច)ត្រូវបានដកចេញ នោះកំណើនសេដ្ឋកិច្ចកន្លងមក ជាមធ្យម គឺ ៧%។ រីឯផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) សម្រាប់មនុស្សម្នាក់បានកើនឡើងដល់១ ០៣៦ ដុល្លារអាមេរិកនៅឆ្នាំ២០១៣ (តាមការប៉ាន់ប្រមាណ)។ អតិផរណាស្ថិតនៅក្រោមការគ្រប់គ្រង និងអត្រាប្តូរប្រាក់ត្រូវបានរក្សាឲ្យមានស្ថិរភាព។ ឱនភាពពាណិជ្ជកម្មបានថយចុះគួរឲ្យកត់សម្គាល់ ពោលគឺ-១៥,៣% នៃផ.ស.ស. នៅឆ្នាំ២០០៨ មក-១៣,៩% នៃផ.ស.ស.ក្នុងឆ្នាំ២០១២។ កម្ពុជាបានទទួលទំហំហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ពីដៃគូអភិវឌ្ឍប្រមាណ ៥ ៤៣០លានដុល្លារអាមេរិក នៅចន្លោះពីឆ្នាំ២០០៨-២០១២ ដែលក្នុងនោះ៣ ៥៨០លានដុល្លារអាមេរិក គឺជាជំនួយឥតសំណងនិង១ ៨៥០លានដុល្លារអាមេរិក ជាឥណទាន។ តាមការព្យាករ ប្រទេសកម្ពុជាអាចនឹងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍចំនួន ១ ២០០លានដុល្លារអាមេរិក (៦០០លានដុល្លារអាមេរិក ដែលជាជំនួយឥតសំណងនិង៦០០លានដុល្លារអាមេរិក ដែលជាប្រាក់កម្ចី) នៅក្នុងរយៈពេល២-៣ឆ្នាំខាងមុខនេះ។ អំឡុងពេលមានវិបត្តិសេដ្ឋកិច្ចឆ្នាំ២០០៩-២០១០ អ្នកបាត់បង់ការងារនិងកម្មករគ្មានការងារធ្វើប្រមាណ៤០ ០០០នាក់ ទទួលបាននូវការបណ្តុះបណ្តាលរយៈពេលខ្លីលើជំនាញផ្នែកកសិកម្ម សិប្បកម្ម ឧស្សាហកម្ម បច្ចេកវិទ្យា និងសេវាពី"**មូលនិធិរបស់នាយករដ្ឋមន្ត្រី**" និង"**ការបង្កើតមូលនិធិថ្មីដោយខ្លួនផ្ទាល់**"។

### ខ- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ស្ថានភាពហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៩-២០១៣

២.៤៧ ប្រាក់ចំណូលជាមធ្យមរវាងឆ្នាំ២០០៩ និងឆ្នាំ២០១៣ (ប៉ាន់ស្មាន) មាន១៣,៥៦% នៃផ.ស.ស. ក្នុងនោះចំណូលមកពីពន្ធបាននាំមុខគេ។ សម្រាប់វិស័យពន្ធដារ *អគ្គនាយកដ្ឋានពន្ធដារ* បានរៀបចំនិងដាក់ឲ្យអនុវត្តនូវលិខិតបទដ្ឋានជាច្រើន ជាពិសេសបទប្បញ្ញត្តិស្តីពីពន្ធលើអចលនទ្រព្យ។ *អគ្គនាយកដ្ឋានពន្ធដារ*បានពង្រីកការគ្រប់គ្រងប្រមូលពន្ធដារ តាមរយៈរបបស្វ័យប្រកាសរបស់ខ្លួននៅទីគ្រប់ខេត្ត ក្រុង និងបានជ្រើសរើស និងបណ្តុះបណ្តាលមន្ត្រីថ្មីចំនួនជាង៣០០នាក់។ សម្រាប់វិស័យគយនិងរដ្ឋាករ *អគ្គនាយកដ្ឋានគយនិងរដ្ឋាករ* បានរៀបចំនិងដាក់ឲ្យអនុវត្តច្បាប់និងបទប្បញ្ញត្តិគយ ទាំងការងារបច្ចេកទេសនិងការរៀបចំអង្គការគយដែលមានសង្គតិភាពជាមួយបែបបទអន្តរជាតិ។ ជាមួយគ្នានេះ ពាក់ព័ន្ធនឹងការងារសម្រួលពាណិជ្ជកម្ម បានដាក់ឲ្យដំណើរការពេញលេញនូវយន្តការភាពជាដៃគូគយ ផ្នែកឯកជន និងបានដាក់ឲ្យប្រើ

ប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយតាមមាត់ច្រកអន្តរជាតិចំនួន២០កន្លែង ដែលគ្របដណ្តប់ស្ទើរទាំងស្រុងនូវប្រតិបត្តិការគយ។ ព្រមទាំងបានកសាងនិងដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យហានិភ័យគយ និងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជនបានពេញលេញ។ គោលនយោបាយនិងការគ្រប់គ្រងចំណាយថវិកាជាតិ ត្រូវបានកែលម្អនិងពង្រឹងបន្ថែម ដែលបានធ្វើឲ្យគម្រោងតម្រូវការចំណាយកាន់តែមានភាពសុក្រឹត និងផ្សារភ្ជាប់ទៅនឹងគោលនយោបាយអាទិភាព ព្រមទាំងការប្រើប្រាស់ថវិកាជាតិកាន់តែមានភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព។ ចំណាយអាទិភាពរួមមានលើវិស័យអប់រំ សុខភាព កសិកម្ម អភិវឌ្ឍន៍ជនបទ និងការកែលម្អ ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ និងប្រព័ន្ធធារាសាស្ត្រ។ ចំណាយថវិកាជាតិកើនឡើងជាមធ្យម១៧%ក្នុងមួយឆ្នាំ ក្នុងនោះចំណាយថវិកាចរន្ត១៧,៦% និងចំណាយមូលធន១៦,៨ %។

**២.៤៨-** ថវិកាសម្រាប់ចំណាយលើបៀវត្សមន្ត្រីបានបង្កើនឡើងជាបន្តបន្ទាប់ ជាក់ស្តែងចំណាយបានកើនឡើងជិត២ដង ពោលគឺពី១ ៤៣៧ពាន់លានរៀលនៅក្នុងឆ្នាំ២០០៨ ឡើងដល់ ២ ៦៧២ពាន់លានរៀលនៅក្នុងឆ្នាំ២០១២។ កំណើននេះឆ្លុះបញ្ចាំងពីការអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សមូលដ្ឋានជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ ប្រមាណ២០%ក្នុងមួយឆ្នាំ។ ការចំណាយលើវិស័យអប់រំបានកើនឡើងពី៦០៧ពាន់លានរៀលក្នុងឆ្នាំ២០០៨ទៅ ៩០៧ពាន់លានរៀលក្នុងឆ្នាំ២០១២។ ការចំណាយលើកម្លាំងពលកម្មនិងការបណ្តុះបណ្តាលវិជ្ជាជីវៈបានកើនឡើងពី៣៩ពាន់លានរៀលនៅឆ្នាំ២០០៨ទៅ៩៩ពាន់លានរៀលនៅក្នុងឆ្នាំ២០១២។ រវាងឆ្នាំ២០០៨និងឆ្នាំ២០១២ ការវិនិយោគសរុបលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺ៩ ៨៥២ពាន់លានរៀល នៅលើការដឹកជញ្ជូន៦ ៨២១ពាន់លានរៀល ប្រព័ន្ធធារាសាស្ត្រ២ ២៥១ពាន់លានរៀល និងអគ្គិសនី៧៨០ពាន់លានរៀល។

**២.៤៩-** ការចំណាយវិនិយោគសាធារណៈ តាមរយៈការផ្តល់ហិរញ្ញប្បទានក្នុងស្រុកបានកើនឡើងពី៧១១ពាន់លានរៀលក្នុងឆ្នាំ២០០៨ទៅ១ ៣២៧ពាន់លានរៀល នៅក្នុងឆ្នាំ២០១២ ដូចគ្នានេះដែរ ការផ្តល់ហិរញ្ញប្បទានពីបរទេសបានកើនឡើងពី១ ៩២៦ពាន់លានរៀលដល់ ២ ៨៦០ពាន់លានរៀល។ ទន្ទឹមនឹងនេះ ស្ថានភាពបំណុលត្រូវបានធ្វើឲ្យប្រសើរឡើង ដូចមានបង្ហាញក្នុងជំពូកទី៣។

## គ- ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុ

### ស្ថានភាពវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៩-២០១៣

២.៥០- នៅក្នុងដំណាក់កាលឆ្នាំ២០០៩-២០១៣ វឌ្ឍនភាពដ៏គួរឲ្យកត់សម្គាល់ ក៏មាននៅក្នុងវិស័យហិរញ្ញវត្ថុ។ រូបិយវត្ថុទូទៅ(M2) បានកើនឡើងជាមធ្យម ប្រមាណជា២១%ក្នុងមួយឆ្នាំ រវាងឆ្នាំ២០០៨និងឆ្នាំ២០១២។ វិស័យហិរញ្ញវត្ថុរបស់កម្ពុជាក៏កំពុងឈានចូលដំណាក់កាលវិវត្ត។ ជាក់ស្តែង ទីផ្សារហិរញ្ញវត្ថុ ជាពិសេស ទីផ្សារមូលបត្រតាមរយៈពិពិធកម្មស្ថាប័ននិងឧបករណ៍ហិរញ្ញវត្ថុកំពុងបន្តអភិវឌ្ឍ។ ទីផ្សារអន្តរធនាគារទំនងនឹងរីកចម្រើននៅពេលដែលទីផ្សារមូលបត្របំណុលត្រូវបានបង្កើតឡើង។ ទន្ទឹមនឹងនេះ វិស័យធានារ៉ាប់រងកំពុងមានវឌ្ឍនភាពល្អ។

### ១- ការអភិវឌ្ឍវិស័យធនាគារ

២.៥១- វិស័យធនាគារនៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សគួរឲ្យកត់សម្គាល់ទាំងចំនួនប្រតិបត្តិករ ទំហំប្រតិបត្តិការ និងវិសាលភាព។ ធនាគារពាណិជ្ជខ្នាតអន្តរជាតិដែលមានបទពិសោធច្រើនឆ្នាំបានមកវិនិយោគនៅកម្ពុជាជាបន្តបន្ទាប់។ គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០១៣ ប្រព័ន្ធធនាគារក្នុងប្រទេសកម្ពុជារួមមានសាខាធនាគារជាតិនៃកម្ពុជាចំនួន២១ធនាគារពាណិជ្ជចំនួន៣៣(ក្នុងនោះធនាគារចំនួន២៣ជាធនាគារក្នុងស្រុក និងធនាគារចំនួន១០ជាសាខាបរទេស ហើយធនាគារពាណិជ្ជទាំងនោះមានសាខាខេត្ត ក្រុងចំនួន១៧១) ធនាគារឯកទេសចំនួន៧ និងការិយាល័យតំណាងធនាគារបរទេសចំនួន៥។

២.៥២- ទ្រព្យសកម្មសរុបរបស់ធនាគារទទួលប្រាក់បញ្ញើធៀបនឹងផ.ស.ស. បានកើនពី៤១% នៅឆ្នាំ២០០៨ដល់៨១% នៅចុងឆមាសទី១ ឆ្នាំ២០១៣។ ក្នុងនោះទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ប្រព័ន្ធធនាគារមានការកើនឡើងយ៉ាងឆាប់រហ័ស ពោលគឺពី១ ៥១៣ពាន់លានរៀលដល់១១ ២៨៩ពាន់លានរៀល(កើនឡើងប្រមាណ៧,៤ដង) ហើយទ្រព្យសកម្មបរទេសសុទ្ធ បានកើនឡើងពី១០ ៣៤៦ពាន់លានរៀល(កើនឡើងជាប្រមាណ២ដង) ដល់១៩ ៨៧៤ពាន់លានរៀល។ ឥណទានសរុបធៀបនឹងផ.ស.ស. បានកើនពី២៤%ដល់៤៣% ហើយប្រាក់បញ្ញើសរុបធៀបនឹងផ.ស.ស. បានកើនពី២៣%ដល់៤៦%។ កម្រិតស៊ីជម្រៅផ្នែកហិរញ្ញវត្ថុដែលវាស់ដោយអនុបាតរូបិយវត្ថុទូទៅ(M2) ធៀបនឹងផ.ស.ស. បានកើនពី២៨%ដល់៥៣% ដែលឆ្លុះបញ្ចាំងនូវតួនាទីកាន់តែសកម្មរបស់ប្រព័ន្ធធនាគារក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ច។ គិតត្រឹមចុងខែមិថុនា ឆ្នាំ២០១៣ សេវាធនាគារបានបម្រើអតិថិជនមានការកើនឡើងពី២ ០០២ពាន់នាក់នៅចុងឆ្នាំ២០១៣ បើធៀបទៅនឹងឆ្នាំ២០០៨ មានតែ៩៣០ពាន់នាក់។

២.៥៣ គ្រឹះស្ថានធនាគារមានសុខភាពរឹងមាំ ហើយដើមទុនរបស់បណ្តាធនាគារមានការកើនឡើងជាលំដាប់ពី៣ ៧៨៣ពាន់លានរៀល នៅឆ្នាំ២០០៨ ដល់១០ ៨៦១ពាន់លានរៀល នៅចុងខែមិថុនា ឆ្នាំ២០១៣ ពោលគឺកើន២,៩ដង។ អនុបាតឥណទានមិនដំណើរការធៀប នឹងឥណទានសរុបមាននិន្នាការថយចុះ ហើយស្ថិតក្នុងកម្រិតដ៏ទាបប្រមាណ២,៥% នៅចុងខែមិថុនា ឆ្នាំ២០១៣ ពី៣,៧% នៅឆ្នាំ២០០៨។ អនុបាតសន្ទនីយភាពនិងអនុបាតសាធនភាពស្ថិតក្នុងកម្រិតខ្ពស់គឺ៨២%និង២៦%រៀងគ្នា លើសពីកម្រិតតម្រូវការអប្បរមាដែលកំណត់ដោយបទប្បញ្ញត្តិ។

## *២- វិស័យមីក្រូហិរញ្ញវត្ថុ*

២.៥៤- ការពង្រីកនិងបង្កើនប្រសិទ្ធភាពសេវា និងផលិតផលហិរញ្ញវត្ថុ ជាពិសេសលទ្ធភាពគ្របដណ្តប់បានទូលំទូលាយ ជាទិសដៅសំខាន់មួយក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការរីកចម្រើនគួរឲ្យកត់សម្គាល់ និងបានបំពេញតួនាទីកាន់តែសកម្មផងដែរក្នុងការផ្តល់ឥណទានដល់អាជីវកម្មខ្នាតតូច ជាពិសេសដល់ប្រជាជននៅតាមជនបទ។ ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណបានកើនពី១៨ នៅឆ្នាំ២០០៨ ដល់៣៧ នៅចុងខែមិថុនា ឆ្នាំ២០១៣ ដែលក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ត្រូវបានអនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីសាធារណជនចាប់តាំងពីឆ្នាំ២០០៩។ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនពី១ ៣៦២ពាន់លានរៀលដល់៥ ២៧៧ពាន់លានរៀល(កើនប្រមាណ៤ដង) ខណៈឥណទានសរុបបានកើនពី៩៥៦ពាន់លានរៀល ដល់៤ ៤៧៩ពាន់លានរៀល(កើនប្រមាណ៥ដង)។ ប្រាក់បញ្ញើបានកើនពី២៧ពាន់លានរៀល នៅឆ្នាំ២០០៨ ដល់១ ៥៥៤ពាន់លានរៀល នៅខែមិថុនា ឆ្នាំ២០១៣ ដែលការកើនឡើងនេះបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុកំពុងពឹងផ្អែកលើប្រភពហិរញ្ញវត្ថុក្នុងស្រុកជាលំដាប់។ រីឯចំនួនប្រជាពលរដ្ឋដែលបានទទួលសេវាមីក្រូហិរញ្ញវត្ថុបានកើនពី១ ០០៧ពាន់នាក់ ដល់ប្រមាណ២ ៤៥៦ពាន់នាក់។ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាមានសុខភាពល្អនិងបានគោរពខ្ជាប់ខ្ជួនតាមបទប្បញ្ញត្តិ ដែលកំណត់ដោយ*ធនាគារជាតិនៃកម្ពុជា*។ ជាក់ស្តែងអនុបាតឥណទានមិនដំណើរការធៀបនឹងឥណទានសរុប មានកម្រិតតែប្រមាណ ០,៤% ប៉ុណ្ណោះ នៅខែមិថុនា ឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ អនុបាតសន្ទនីយភាព និងអនុបាតសាធនភាព ស្ថិតក្នុងកម្រិតខ្ពស់គឺ១៨០% និង២១%។

## *៣- វិស័យហិរញ្ញវត្ថុមិនមែនធនាគារ*

- *វិស័យធានារ៉ាប់រង*
  - ➢ បុព្វលាភធានារ៉ាប់រងបានកើនឡើងជិតដល់៣០លានដុល្លារអាមេរិកដោយមានអត្រាកំណើនប្រមាណ២០% ក្នុងមួយឆ្នាំ។

- បានពង្រឹងសមត្ថភាពបញ្ញត្តិករជានាវ៉ាប់រង តាមរយៈ ការដាក់ឲ្យអនុវត្តបទប្បញ្ញត្តិ ប្រុងប្រយ័ត្នគ្រប់ជ្រុងជ្រោយ ដើម្បីធានាចីរភាពនៃការអភិវឌ្ឍវិស័យធានារ៉ាប់រង ស្របតាមលក្ខខណ្ឌរបស់សមាគមបញ្ញត្តិករធានារ៉ាប់រងអន្តរជាតិ។
- បានដាក់បង្ហាញព័ត៌មានជាសាធារណៈទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ទីផ្សារធានារ៉ាប់រងនៅកម្ពុជាសំដៅបង្កើនទំនុកចិត្តសាធារណជន។

- *វិស័យសោធន*

- បានបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន មូលនិធិជនពិការ និងបេឡាជាតិរបបសន្តិសុខសង្គម ក្នុងគោលដៅគាំពារសង្គម និងបង្កើតវប្បធម៌សន្សំប្រាក់សម្រាប់ការបង្កើនចំណូលលការវិនិយោគ និងរួមចំណែកពង្រឹងសំណាញ់សុវត្ថិភាពសង្គម។
- បាននិងកំពុងរៀបចំច្បាប់បង្កើតឲ្យមានសោធនស្ម័គ្រចិត្តពីផ្នែកឯកជន។

- *វិស័យមូលបត្រ*

- បានរៀបចំនិងអភិវឌ្ឍក្របខ័ណ្ឌនិយតកម្មនិងត្រួតពិនិត្យ ដែលក្នុងនោះរួមមាន៖ ច្បាប់ស្តីពីមូលបត្ររដ្ឋ ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងច្បាប់ស្តីពីក្ស័យធន ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធ។
- បានរៀបចំបង្កើតនិងដាក់ឲ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងនិងសម្រាប់ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា ដែលក្នុងនោះរួមមាន៖ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ការផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនចំនួន១៦ឲ្យធ្វើជាក្រុមហ៊ុនមូលបត្រ ការផ្តល់ការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ភ្នាក់ងារទូទាត់ ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃនៅក្នុងវិស័យមូលបត្រ។
- បានប្រកាសបើកជាផ្លូវការដាក់ឲ្យជួញដូរមូលបត្រកម្មសិទ្ធិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាប្រវត្តិសាស្ត្រលើកទី១ក្នុងព្រះរាជាណាចក្រកម្ពុជា។

- *វិស័យហិរញ្ញវត្ថុមិនមែនធនាគារផ្សេងៗទៀត*

- បាននិងកំពុងរៀបចំអភិវឌ្ឍបរបាលធនកិច្ចហិរញ្ញវត្ថុ។

- បានផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈនិងអាជ្ញាបណ្ណផ្នែកសេវាវាយតម្លៃ និងសេវាអចលនវត្ថុដល់ក្រុមហ៊ុនចំនួន៨៧។
- បានផ្តល់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍអចលនវត្ថុដល់ក្រុមហ៊ុនចំនួន២០ ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍលំហូរមូលធនក្នុងវិស័យនេះ។
- បានបង្កើតសមាគមអ្នកវាយតម្លៃនិងភ្នាក់ងារសេវាកម្មអចលនវត្ថុកម្ពុជា ហើយសមាគមនេះបានចូលជាសមាជិកពេញសិទ្ធិទី៨នៃសមាគមអ្នកវាយតម្លៃអាស៊ាន។
- បានបង្កើតក្របខ័ណ្ឌបញ្ញត្តិកម្ម ការត្រួតពិនិត្យ និងយន្តការគ្រប់គ្រង ដើម្បីអភិវឌ្ឍវិស័យទទួលបញ្ចាំឲ្យមានលក្ខណៈផ្លូវការនិងជំរុញឲ្យមានចលនាទុនឲ្យបានទូលំទូលាយ។
- បាននិងកំពុងលើកកម្ពស់វិជ្ជាជីវៈក្នុងប្រតិបត្តិការទទួលបញ្ចាំ តាមរយៈការដាក់ឲ្យអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់បញ្ញត្តិករ ប្រតិបត្តិករ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

### ៤- *ការអភិវឌ្ឍក្រមបទប្បញ្ញត្តិនិងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ*

**២.៥៥-** ធនាគារជាតិនៃកម្ពុជាបានពង្រឹងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យធនាគារ តាមរយៈការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិសំខាន់ៗ ការរៀបចំអភិវឌ្ឍប្រព័ន្ធទូទាត់និងការបង្កើតការិយាល័យព័ត៌មានឥណទាន។ ការិយាល័យព័ត៌មានឥណទានត្រូវបានបង្កើតឡើងក្រោមទម្រង់ជាកម្មសិទ្ធិរួមរវាងសមាគមធនាគារិកកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងអ្នកផ្តល់សេវាឯកជន ដើម្បីរួមចំណែកកាត់បន្ថយហានិភ័យឥណទាននិងបញ្ចៀសការខ្ចីហួសសមត្ថភាព រួមទាំងចែករំលែកព័ត៌មានឥណទានដែលមានតម្លាភាពផងដែរ។ ឧបករណ៍ ទូទាត់នៅក្នុងវិស័យធនាគារក៏មានលក្ខណៈកាន់តែទំនើបផងដែរ ដូចជាសេវាដកប្រាក់តាមម៉ាស៊ីនស្វ័យប្រវត្តិ (ATM) ដោយប្រើប័ណ្ណឥណពន្ធនិងឥណទាន សេវាទូទាត់ដោយប្រើម៉ាស៊ីនឆូតកាត(POS) និងសេវាធនាគារតាមទូរស័ព្ទចល័តជាដើម។ គិតត្រឹមចុងខែមិថុនា ឆ្នាំ២០១៣ ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ(ATM) មានចំនួន៧១៨គ្រឿងនៅទូទាំងប្រទេស។ ទន្ទឹមនឹងនេះ *ធនាគារជាតិនៃកម្ពុជា*បាននិងកំពុងបន្តសហការយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានធនាគារ ណែនាំឲ្យមានវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបាន។ *ធនាគារជាតិនៃកម្ពុជា* ក៏បាននិងកំពុងជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ សំដៅបង្កើនប្រសិទ្ធភាព ក្នុងការគ្រប់គ្រងសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារនិងអភិវឌ្ឍការប្រើប្រាស់ឧបករណ៍អាចជួញដូរបាន។

**២.៥៦-** ទោះបីជាវិស័យធនាគារនិងហិរញ្ញវត្ថុមានតួនាទីសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចក៏ដោយ ក៏វិស័យហិរញ្ញវត្ថុកម្ពុជាស្ថិតក្នុងដំណាក់កាលបឋមនៅឡើយ ដែលប្រឈមនឹងបញ្ហា

មួយចំនួនអំឡុងពេលអនុវត្ត *ផែនការជាតិអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៩-២០១៣* និង *យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០* ដូចជា៖

- កម្រិតដុល្លារូបនីយកម្មខ្ពស់ ដែលរឹតត្បិតការប្រើប្រាស់ឲ្យបានទូលំទូលាយនូវឧបករណ៍គោលនយោបាយរូបិយវត្ថុ។
- ហេដ្ឋារចនាសម្ព័ន្ធស្ថាប័នសម្រាប់វិស័យហិរញ្ញវត្ថុតម្រូវឲ្យមានការអភិវឌ្ឍបន្ថែមជាបន្តទៀត ក្នុងនោះរួមមាន ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ដំណើរដោយប្រសិទ្ធភាពនៃប្រតិបត្តិការធនាគារ ក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រព័ន្ធទូទាត់ប្រកបដោយប្រសិទ្ធភាព និងមានការប្រើប្រាស់ទូលំទូលាយ។
- ក្របខ័ណ្ឌត្រួតពិនិត្យនៅមិនទាន់ស៊ីជម្រៅ ហើយយន្តការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុនៅមិនទាន់មានភាពគ្រប់គ្រាន់ស្របតាមការអនុវត្តជាអន្តរជាតិ។
- ទីផ្សាររូបិយវត្ថុនិងទីផ្សារអន្តរធនាគារនៅមិនទាន់ដំណើរការ។
- កង្វះឧបករណ៍អាចជួញដូរបាន ជាពិសេសមូលបត្ររដ្ឋសម្រាប់ដំណើរការទីផ្សាររូបិយវត្ថុ និងទីផ្សារអន្តរធនាគារ។
- ការយល់ដឹងពីអត្ថប្រយោជន៍និងការប្រើប្រាស់សេវាហិរញ្ញវត្ថុនៅពុំទាន់ទូលំទូលាយ ជាពិសេសនៅតាមជនបទនិងសមត្ថភាពធនធានមនុស្សនៅមានកម្រិត។

## ២.៤- ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ

**២.៥៧-** សមិទ្ធផលដែលសម្រេចបានក្នុងបណ្តាឆ្នាំចុងក្រោយនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់បន្តពង្រឹងវឌ្ឍនភាពបន្ថែមទៀត និងក្តាប់ឲ្យជាប់នូវកាលានុវត្តភាព ទន្ទឹមនឹងនេះបន្តដោះស្រាយបញ្ហាប្រឈមសម្រាប់បង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ។ បណ្តាសមិទ្ធផលសំខាន់ៗដែល*រាជរដ្ឋាភិបាលកម្ពុជា*សម្រេចបាន គឺការកៀរគរធនធានហិរញ្ញប្បទានសហប្រតិ-បត្តិការប្រមាណជាង១ ០០០លានដុល្លាអាមេរិក ក្នុងមួយឆ្នាំចាប់ពីឆ្នាំ២០០៨មក សម្រាប់អភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ ហិរញ្ញប្បទានសហប្រតិបត្តិការនេះ មានទំហំប្រមាណ១០%នៃផ.ស.ស. បានរួមចំណែកក្នុងការសម្រេចបានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងចន្លោះ៦-៧% ក្នុងមួយឆ្នាំ។ ជាលទ្ធផលចំណូលរបស់ប្រជាជនម្នាក់ៗ បានកើនឡើងពី៧៦០ដុល្លារអាមេរិកក្នុងឆ្នាំ២០០៨ និងលើស១ ០០០ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ (ការប៉ាន់ស្មាន)។ រីឯអត្រាភាពក្រីក្រ បានធ្លាក់ចុះពី៤៧,៨%ក្នុងឆ្នាំ២០០៧ មកនៅត្រឹម១៩,៨%ក្នុងឆ្នាំ២០១១។ កំណើនហិរញ្ញប្បទានសហប្រតិបត្តិការ បានឆ្លុះបញ្ចាំងអំពីទំនុកចិត្តរបស់សហគមន៍ដៃគូអភិវឌ្ឍមកលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ និងកម្មវិធីកំណែទម្រង់ ព្រមទាំងបានចូល

រួមបង្កើតបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគវិស័យសាធារណៈនិងឯកជន ជាពិសេស ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ កាត់ដេរ កសិកម្ម សំណង់ និងទេសចរណ៍។

២.៥៨- រាជរដ្ឋាភិបាលបានទទួលជោគជ័យគួរកត់សម្គាល់ក្នុងការដឹកនាំ "**វេទិកានៃកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍកម្ពុជា**"ចាប់ពីឆ្នាំ២០០៧ ជំនួសឲ្យយន្តការ "**កិច្ចប្រជុំពិគ្រោះយោបល់**"។ លើសពីនេះកម្ពុជាត្រូវបានទទួលស្គាល់ថាជាប្រទេសគំរូនិងឈានមុខក្នុងការអនុវត្ត "**សេចក្តីប្រកាសទីក្រុងប៉ារីស**" និង"**ផែនការសកម្មភាពទីក្រុងអាក្រា**" ស្តីពីការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។

២.៥៩- ប៉ុន្តែទោះជាយ៉ាងណាក្តី រាជរដ្ឋាភិបាលក៏កំពុងជួបនឹងបញ្ហាប្រឈមមួយចំនួនក្នុងការបន្តកិច្ចប្រឹងប្រែងដើម្បីឈានទៅសម្រេចបាននូវប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ការងារប្រឈមដែលជាការប្តេជ្ញាទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍទាំងអស់ រួមមាន៖

- ការធានាឲ្យមានការបន្សុីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយបណ្តាអាទិភាពជាតិ។
- ការធ្វើសុខដុមនីយកម្មដំណើរការរៀបចំក្នុងការគ្រប់គ្រងហិរញ្ញប្បទានរបស់បណ្តាដៃគូអភិវឌ្ឍ។
- ការអភិវឌ្ឍសមត្ថភាពសម្រាប់កែលម្អការគ្រប់គ្រងវិស័យសាធារណៈ។

២.៦០- ការប្តេជ្ញាចិត្តទាំងអស់នេះពិតជាមានសារៈសំខាន់ដើម្បីបន្តអនុវត្តឲ្យបានចប់សព្វគ្រប់នូវរបៀបវារៈដែលនៅសេសសល់ ក្នុងគោលដៅឆ្ពោះទៅរកការប្រើប្រាស់ធនធានអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពជាងមុន។ ទន្ទឹមនឹងនេះការសម្រេចបានលទ្ធផលក្នុងកិច្ចអភិវឌ្ឍចាំបាច់ត្រូវកសាងនិងពង្រឹងភាពជាដៃគូទូលំទូលាយជាមួយតួអង្គអភិវឌ្ឍទាំងអស់ និងពង្រឹងប្រព័ន្ធជាតិស្របតាមការប្តេជ្ញានានាដែលបានឯកភាពគ្នាក្នុងវេទិកាកំពូលនៅទីក្រុងប៊ូសាននៃសាធារណរដ្ឋកូរ៉េចុងឆ្នាំ២០១១។

២.៦១- គួរកត់សម្គាល់ថា ប្រភពហិរញ្ញប្បទានពីខាងក្រៅនឹងមានការធ្លាក់ចុះដោយសារនិន្នាការថយចុះនៃហិរញ្ញប្បទានឥតសំណងលើសកលលោក។ ក្នុងបរិការណ៍នេះ ប្រទេសកម្ពុជាចាំបាច់ត្រូវស្វែងរកធនធានពីប្រភពដទៃទៀតព្រមទាំងប្រឹងប្រែងឲ្យអស់លទ្ធភាព ក្នុងការប្រមូលចំណូលក្នុងស្រុកសម្រាប់បន្តអភិវឌ្ឍប្រទេស។ ទន្ទឹមនឹងនេះ សមាហរណកម្មក្នុងតំបន់រួមទាំងសហគមន៍សេដ្ឋកិច្ចអាស៊ាននាឆ្នាំ២០១៥ នឹងបង្កើតបញ្ហាប្រឈមផងនិងផ្តល់កាលានុវត្តភាពថ្មីៗផងសម្រាប់កម្ពុជាដែលតម្រូវឲ្យតួអង្គអភិវឌ្ឍទាំងអស់បន្តសហការគ្នាបន្ថែមទៀត។

## ៣- ការលើកស្ទួយវិស័យកសិកម្ម

**២.៦២-** ការលើកស្ទួយវិស័យកសិកម្មដែលជាចតុកោណទីមួយនៃ *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា*សម្រាប់នីតិកាលទី៥នៃរដ្ឋសភា គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិនិងសេដ្ឋកិច្ចជនបទនិងការធានាបាននូវសមធម៌ និងសន្តិសុខស្បៀង។ មានទិដ្ឋភាពសំខាន់ៗចំនួនបួននៃការលើកស្ទួយវិស័យកសិកម្ម រួមមាន៖ (១)ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មកសិកម្ម (២)ការកែទម្រង់ដីធ្លីនិងបោសសម្អាតមីន (៣)ការកែទម្រង់វិស័យជលផល និង (៤)ការកែទម្រង់វិស័យព្រៃឈើ។

### ៣.១- ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម

**២.៦៣-** *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានបំពេញយ៉ាងសកម្មក្នុងការដឹកនាំគ្រប់គ្រងនិងអនុវត្តសកម្មភាព សំដៅជំរុញការរីកលូតលាស់កសិកម្ម ដោយ (១)ធានាបាននូវសន្តិសុខស្បៀង (២)ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម (៣)កាត់បន្ថយភាពក្រីក្រ ដោយបង្កើនចំណូលប្រជាកសិករ តាមរយៈតម្លៃបន្ថែមទៅក្នុងផលិតផលកសិកម្ម និង (៤)ធានាបាននូវទីផ្សារសម្រាប់ផលិតផលកសិកម្ម។

#### ផលិតផលដំណាំស្រូវ

**២.៦៤-** គិតមកដល់ត្រឹមឆ្នាំ២០១៣ ផ្ទៃដីផលិតកម្មដំណាំស្រូវសរុបបានកើនឡើងដល់ជាង ៣លានហិកតា។ ដោយឡែកទិន្នផលស្រូវមធ្យមទូទាំងប្រទេសនាឆ្នាំ២០១២ សម្រេចបាន ៣,១១តោន/ហ.ត. កើនលើសឆ្នាំ២០០៨ ដែលមានត្រឹមតែ២,៨៣តោន/ហ.ត. (កើនប្រមាណជា ១៤%) និងបរិមាណផលស្រូវសរុបប្រមាណ៩,២៩លានតោន (កើនលើសឆ្នាំ២០០៨ចំនួន២៩% ដែលមាន៧,៥៨លានតោន)។ និន្នាការនេះ បានធ្វើឲ្យកម្ពុជាសល់ស្បៀង គិតជាអង្ករសរុបចំនួនជាង៣,០៣លានតោន ឬស្មើនឹងប្រមាណជា៤,៧លានតោនស្រូវ គឺខ្ពស់ជាងឆ្នាំ២០១១។ សមិទ្ធផលនេះជាសក្ខីកម្មឆ្លុះបញ្ចាំងនូវជោគជ័យមួយដ៏ធំធេង សម្រាប់កម្ពុជាក្នុងការសម្រេចបាននូវសកម្មភាពផែនការ"*គោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ*" ក្នុងវិស័យផលិតកម្មដំណាំស្រូវ។

**តារាងទី២.១ : កំណើនផលិតកម្មដំណាំស្រូវ ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២**

| បរិយាយ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ប្រៀបធៀបកំណើន ២០០៩-២០១២ |
|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហ.ត.) | ២ ៧១៩ ០៨០ | ២ ៧៩៥ ៨៩២ | ២ ៩៦៨ ៥២៩ | ៣ ០០៧ ៥៤៥ | ១០,៦% |
| ផ្ទៃដីប្រមូលផល (ហ.ត.) | ២ ៦៧៤ ៦០៣ | ២ ៧៧៧ ៣២៣ | ២ ៧៦៦ ៦១៧ | ២ ៩៨០ ២៩៧ | ១១,៤% |
| ទិន្នផលស្រូវ (ត/ហ.ត.) | ២,៨៣៦ | ២,៩៧ | ៣,១៧៣ | ៣,១១៧ | ៩,៩% |
| បរិមាណផលិតផល (ត) | ៧ ៥៨៥ ៨៧០ | ៨ ២៤៩ ៤៥២ | ៨ ៧៧៩ | ៩ ២៩០ ៩៤០ | ២២,៤% |
| ស្បៀងសល់ (អង្ករ) | ២ ២៤៤ ៥៩៨ | ២ ៥១៦ ៧៥២ | ២ ៧៨០ | ៣ ០៣១ ០១៧ | ៣៥% |
| ស្បៀងសល់ (ស្រូវ) | ៣ ៥០៧ ១៨៥ | ៣ ៩៣២ ៤២៥ | ៤ ៣៤៤ | ៤.៧៣៥ ៩៦៤ | ៣៥% |

*ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

**២.៦៥-** *ផលិតកម្មដំណាំសាកវប្បកម្មនិងដំណាំឧស្សាហកម្ម៖* ផ្ទៃដីដាំដុះដំណាំសំខាន់ៗ រួមមាន៖ ពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង មាននិន្នាការកើនឡើងគួរឲ្យកត់សម្គាល់ គឺកើនឡើងបានពី៧០៤ ៦៦០ហ.ត.(ឆ្នាំ២០១១)ដល់៧១៦ ៣៧០ហ.ត.(ឆ្នាំ២០១២)។ ផ្ទៃដីដាំដុះដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម សរុបទូទាំងប្រទេសសម្រាប់ឆ្នាំ២០១២ សម្រេចបាន៩១២ ៨៨០ហ.ត.(ឆ្នាំ២០១១ សម្រេចបាន៨៥៦ ៧៧៧ហ.ត.)។ បរិមាណផលសរុបនៃដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មប្រចាំឆ្នាំក៏មានការកើនឡើងដែរ គឺបានកើនពី៩,៩៣លានតោនឆ្នាំ២០១១ដល់១០,៨៥លានតោនឆ្នាំ២០១២។ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ អនុវត្តបានសរុបចំនួន១៩៣ ៧៥១ហ.ត. កើនលើសឆ្នាំមុន១៧,៥%(ឆ្នាំ២០១១ មានតែ១៦៤ ៨៤០ហ.ត.ប៉ុណ្ណោះ)។

**តារាងទី២.២ : ផ្ទៃដីដាំដុះដំណាំរួមសំខាន់ៗ៤មុខ (ឯកតាគិតជាហ.ត.)**

| មុខដំណាំ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|
| ពោត | ២០៦ ០៥៨ | ២១៣ ៦២២ | ១៧៤ ២៥៧ | ២១៦ ៣៣០ |
| ដំឡូងមី | ១៦០ ៣២៦ | ២០៦ ២២៦ | ៣៩១ ៧១៤ | ៣៦១ ៨៥៤ |
| សណ្តែកបាយ | ៤៩ ៥៩៩ | ៦៩ ២០៦ | ៦៨ ១១១ | ៦៦ ៨៥០ |
| សណ្តែកសៀង | ៩៦ ៣៨៨ | ១០៣ ១៩៨ | ៧០ ៥៨៤ | ៧១ ៣៣៧ |
| សរុប | ៥១២ ៣៧១ | ៥៩២ ២៥២ | ៧០៤ ៦៦៦ | ៧១៦ ៣៧០ |

*ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

**២.៦៦-** *ការអភិវឌ្ឍសហគមន៍កសិកម្ម៖* ជាក់ស្តែងគិតមកទល់ឆ្នាំ២០១២នេះ សហគមន៍កសិកម្មសរុបមានចំនួន៣៧៥ ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេស។ សហគមន៍ទាំងអស់នេះមានសកម្មភាពពាក់ព័ន្ធនឹងមុខរបរមួយចំនួនដូចជា ផលិតកម្មកសិកម្ម សេវាលក់ទិញកសិផល និងធាតុចូលកសិកម្ម និងសេវាឥណទានសម្រាប់ប្រព័ន្ធផលិតកម្មកសិកម្ម។

**២.៦៧-** *ការជំរុញការនាំចេញផលិតផលកសិកម្ម៖* ក្នុងឆ្នាំ២០១២ ផលិតផលកសិកម្មចំនួន

២៥មុខទំនិញមានបរិមាណសរុបចំនួន០,៦៨លានតោន ត្រូវបានស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យដើម្បីនាំចេញ។ ក្នុងឆ្នាំ២០១២ដដែល វិស័យឯកជនចំនួន៦៨ក្រុមហ៊ុនបាននាំចេញអង្ករមានបរិមាណសរុប២០៥ ៧១៧តោនទៅកាន់៥៧ប្រទេស។ ការនាំចេញនេះបានកើនលើសឆ្នាំ២០១១ចំនួន១,៩%។ ទោះបីជាកំណើននៃការនាំចេញអង្ករមានចំនួនតិចតួច ប៉ុន្តែអង្ករនាំចេញពីប្រទេសកម្ពុជាកំពុងត្រូវបានទីផ្សារបរទេស(ប្រទេសនាំចូល) ទទួលស្គាល់កាន់តែច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។ ក្នុងឆ្នាំ២០១២ដដែល ការនាំចេញផលិតផលដំឡូងមី សម្រេចបានសរុប០,២២លានតោន ក្នុងនោះម្សៅដំឡូងមីចំនួន៤៨ ៨៧៤តោន ចំណិតដំឡូងមីចំនួន១២៦ ២៧៦តោន និងដំឡូងមីស្រស់ចំនួន៥០ ៥៤០តោន ត្រូវបាននាំចេញ។

២.៦៨- *ការអភិវឌ្ឍនិងការស្រាវជ្រាវកសិកម្ម៖* តាមរយៈការងារស្រាវជ្រាវ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យាកសិកម្មអស់រយៈពេល៥កន្លងមក រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចតទៅ៖

- ធ្វើការប្រមែប្រមូល អភិរក្ស និងប្រើប្រាស់ពូជដំណាំផ្សេងៗ។
- ធ្វើឲ្យប្រសើរឡើងនូវលក្ខណសម្បត្តិរបស់ពូជស្រូវទាំងឡាយដែលបានបញ្ចេញរួចហើយ និងដែលកំពុងពេញនិយម។
- ធ្វើឲ្យប្រសើរឡើងនូវទិន្នផលនិងគុណភាពដំណាំស្រូវ ដំណាំធញ្ញជាតិ ដំណាំបន្លែ។
- ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍។
- អភិវឌ្ឍឧបករណ៍កសិកម្មដោយបានបង្កើតឧបករណ៍ផ្សេងៗ។
- អភិវឌ្ឍបរិក្ខារសម្រាប់រក្សាទុកឬវេចខ្ចប់ផលិតផលកសិកម្ម។
- អភិវឌ្ឍបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ។
- សិក្សាអំពីនិន្នាការរយៈពេលវែងនៃជីជាតិដីសម្រាប់ផលិតកម្មដំណាំស្រូវ។
- តាមដានដំណើរបម្លែងអាសូតក្នុងស្រទាប់ដីនិងទឹក។
- ឥទ្ធិពលនៃការប្រើប្រាស់ជីអាសូតទៅលើទិន្នផលស្រូវក្នុងរដូវវស្សា។
- ធ្វើសមូហាកម្មសត្វល្អិត។
- តាមដានរកពូជស្រូវធន់ទៅនឹងការបំផ្លាញរបស់មមាចត្នោត។
- ទទួលយកពូជស្រូវបញ្ចេញដោយវិទ្យាស្ថាននិងផលចំណេញបន្ថែម។
- បច្ចេកទេសដាំសណ្តែកបាយបន្ទាប់ពីប្រមូលផលស្រូវរដូវវស្សា។
- ធ្វើការងារបណ្តុះបណ្តាលនិងផ្សព្វផ្សាយ។
- ដោយឡែកចំពោះការងារផ្សព្វផ្សាយបានធ្វើទិវាស្រែបង្ហាញមួយចំនួន។
- ធ្វើការងារបោះពុម្ពនិងផ្សព្វផ្សាយ។

២.៦៩- ទោះបីជាសម្រេចបាននូវសមិទ្ធផលគួរជាទីកត់សម្គាល់ក៏ដោយ ក៏ការងារស្រាវជ្រាវផលិតកម្មស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម បាននិងកំពុងជួបប្រទះបញ្ហាប្រឈមមួយចំនួន រួមមាន៖

- ពុំទាន់មានកញ្ចប់ថវិកាជាតិដោយឡែកសម្រាប់ការងារស្រាវជ្រាវ ហើយថវិកាជាតិសម្រាប់អនុវត្តការងារស្រាវជ្រាវក៏នៅមានកម្រិតផងដែរ។
- ពុំទាន់មានគោលនយោបាយលើកទឹកចិត្តដល់អ្នកវិទ្យាសាស្ត្រអ្នកស្រាវជ្រាវមន្ត្រីនិងនិយោជិតដែលបាននិងកំពុងបម្រើការងារក្នុងអង្គភាពស្រាវជ្រាវកសិកម្ម។
- ការដាច់ចរន្តអគ្គិសនីជាញឹកញាប់ បណ្តាលឲ្យខូចខាតនូវឧបករណ៍និងសារធាតុវិភាគ ក្នុងមន្ទីរពិសោធន៍ព្រមទាំងសម្ភារៈអេឡិចត្រូនិច។
- ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការងារស្រាវជ្រាវនៅមានកម្រិតជាពិសេសមន្ទីរពិសោធន៍ដែលមានសមត្ថភាពស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រ។

២.៧០- ក្រៅពីស្ថាប័នអភិវឌ្ឍវិស័យកសិកម្ម ប្រជាកសិករកម្ពុជាបានបន្តជួបនូវផលវិបាកមួយចំនួន ដែលទាមទារនូវដំណោះស្រាយ៖

- កង្វះខាតនូវធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងថវិការសម្រាប់ស្រាវជ្រាវ និងអភិវឌ្ឍ។
- គោលនយោបាយគាំទ្រសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម នៅមានការខ្វះខាត។
- កង្វះខាតឧបករណ៍ផ្នែកច្បាប់និងបទប្បញ្ញត្តិ។
- កង្វះខាតការវិនិយោគឯកជនមកលើវិស័យកសិកម្ម។
- ការប្រែប្រួលអាកាសធាតុ ដែលធ្វើឲ្យមានគ្រោះធម្មជាតិ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ ការរាតត្បាតពីពពួកសត្វល្អិត ជាដើម។
- ចំណេះដឹងកសិករនៅមានកម្រិត ដែលជាកត្តាប្រឈមក្នុងការទទួលបច្ចេកវិទ្យាថ្មីៗក៏ដូចជាការធ្វើជាដៃគូពាណិជ្ជកម្មជាមួយវិស័យឯកជន។

### ផលិតកម្មនិងបសុពេទ្យសាល

២.៧១- ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ(២០០៩-២០១២) ស្ថានភាពនៃការចិញ្ចឹមសត្វពាហនៈនៅកម្ពុជាមានការប្រែប្រួលគួរឲ្យកត់សម្គាល់ ជាពិសេសចំនួនគោមានការថយចុះពី៣,៥៨លានក្បាលមក៣,៣៨លានក្បាល ដោយឡែកចំនួនសត្វក្របីក៏មានការធ្លាក់ចុះ។ ដោយឡែក ជ្រូកនិងបក្សីមានការកើនឡើងពី២,១២លានក្បាលទៅ២៣,៣៣លានក្បាលរវាងឆ្នាំ២០០៩ និងឆ្នាំ២០១២។ បើពិនិត្យនិងវិភាគជារួមលើសូចនាករលទ្ធផល អត្រាផលិតកម្មសត្វគ្រប់ប្រភេទបានកើនឡើង៣% ក្នុង១ឆ្នាំ។ កំណើននេះដោយសារបណ្តាលមកពីតម្រូវការសាច់សត្វខ្ពស់។

ផលិតកម្មសត្វគ្រប់ប្រភេទ រួមចំណែកដល់ផ.ស.ស. របស់កម្ពុជាប្រមាណជា៣,៩% ក្នុងឆ្នាំ២០១២។ ទន្ទឹមនឹងនេះ ការរីកចម្រើននៃផលិតកម្មសត្វរបស់ផ្នែកឯកជនក៏កាន់តែមានទំហំធំឡើងៗ ដោយមានការយល់ដឹងពីបច្ចេកទេសចិញ្ចឹម ការជ្រើសរើសពូជ និងការបង្កាត់ពូជ ជាពិសេស ការបង្កាត់ពូជដោយសិប្បនិម្មិត មានការរីកចម្រើននៃបច្ចេកវិទ្យាថ្មីៗមានរោងចក្រចំណីសត្វគ្រប់ប្រភេទ ការកាត់បន្ថយការផ្ទុះជំងឺនិងការឆ្លងរាលដាលជំងឺសត្វ តាមរយៈការបង្ការនិងទប់ស្កាត់ជំងឺមានប្រសិទ្ធភាពខ្ពស់ ជាពិសេស ការជំរុញការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលក្នុងអនុវិស័យចិញ្ចឹមសត្វ។

២.៧២- ទោះបី*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានបញ្ចប់ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាទាក់ទងនឹងវិស័យផលិតកម្មនិងបសុព្យាបាល ជាពិសេសសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វប្រកបដោយផ្លែផ្កាក៏ដោយ ក៏វិស័យផលិតកម្មនិងបសុព្យាបាលបាននិងកំពុងជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការផ្តល់សេវាបសុព្យាបាលនៅតាមមូលដ្ឋាននៃរាជធានីខេត្ត នៅមានកម្រិតអន់ថយនៅឡើយ។
- សមត្ថភាពនៃការយល់ដឹងនិងបទពិសោធរបស់ការិយាល័យជំនាញនៅតាមរាជធានី ខេត្ត ស្រុក ក្រុង នៅមានកម្រិតទាំងផ្នែកបច្ចេកទេស និងផ្នែកច្បាប់ លិខិតបទដ្ឋាន។
- មិនទាន់មានការធានារ៉ាប់រងសុខភាព សម្រាប់បុគ្គលិកបំពេញតួនាទី នៅកន្លែងមានគ្រោះថ្នាក់។
- ការត្រួតពិនិត្យចលនាសត្វនិងផលិតផលមានដើមកំណើតពីសត្វ នៅមិនទាន់បំពេញបានគ្រប់ជ្រុងជ្រោយនិងខ្វះចន្លោះទាំងផ្នែកបច្ចេកទស និងផ្នែកច្បាប់ លិខិតបទដ្ឋាន។
- ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅតាមសត្តឃាតដ្ឋាននិងទីផ្សារ អនុវត្តមិនទាន់សមស្របតាមស្តង់ដាបច្ចេកទេសនៅឡើយ។
- ការត្រួតពិនិត្យគុណភាពចំណីសត្វនៅមានកម្រិត។
- ការវិនិយោគនិងផលិតកម្មចំណីសត្វនៅមានកម្រិតនៅឡើយ។
- អត្រានៃការបង្កាត់ពូជសត្វតាមបែបវិទ្យាសាស្ត្រ នៅមិនទាន់ឆ្លើយតបឲ្យបានទូលំទូលាយទូទាំងប្រទេសនៅឡើយ។
- ទីផ្សារសត្វនៅមិនទាន់មានការអភិវឌ្ឍ។
- ជំងឺផ្តាសាយបក្សី (H5N1) នៅតែមិនទាន់បានលុបបំបាត់បានទាំងស្រុង។

### វិស័យកសិឧស្សាហកម្ម

២.៧៣- ផ្អែកតាមគោលនយោបាយជាយុទ្ធសាស្ត្ររបស់*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង*

*នេសាទ* ឆ្នាំ២០០៩-២០១៣ វិស័យកសិឧស្សាហកម្ម បានចូលរួមបំពេញសកម្មភាពស្របតាមគោលនយោបាយអនុវិស័យទី២ ស្តីពី*ការពង្រីកទីផ្សារសម្រាប់ផលិតផលកសិកម្ម* និងទី៣ ស្តីពី*ក្របខ័ណ្ឌនៃការអភិវឌ្ឍស្ថាប័ននិងបទប្បញ្ញត្តិច្បាប់* ដោយទទួលបានសមិទ្ធផលមួយចំនួនដូចខាងក្រោម៖

**២.៧៤-** *ការគាំទ្រសេវាបច្ចេកទេសតាមរយៈការងារអនុវត្តកម្មវិធីសកម្មភាព:* កន្លងមកផ្នែកកសិឧស្សាហកម្ម *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានអនុវត្តគម្រោងចំនួន២ តាមកម្មវិធីទី២ "ជំរុញការចូលទីផ្សារនៃផលិតផលកសិកម្ម"។ នៅក្នុងន័យនេះប្រជាកសិករចំនួន ៣ ៩៦០នាក់ បានទទួលវគ្គបណ្តុះបណ្តាលពីអនុកម្មវិធីផ្សេងៗ រួមមាន ការបណ្តុះបណ្តាលកសិករ ស្តីពីការកែច្នៃនិងផ្សំចំណីសត្វ ការលើកកម្ពស់ស្តង់ដាគុណភាពសុវត្ថិភាពផលិតផលកសិកម្ម និងការបណ្តុះបណ្តាលកសិករអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងឆ្នាំ២០០៩ និងឆ្នាំ២០១៣។

**២.៧៥-** *រាជរដ្ឋាភិបាលកម្ពុជា*មានការចាប់អារម្មណ៍និងជំរុញយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យានេះយ៉ាងខ្លាំង ព្រោះជាយន្តការគន្លឹះក្នុងការចូលរួមដោះស្រាយគោលនយោបាយបង្កើនផលិតកម្មនិងទីផ្សារកសិកម្មក៏ដូចជាគោលនយោបាយជំរុញការនាំចេញអង្ករ។ *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានរៀបចំអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្នាំ២០១១ និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម ព្រមទាំងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតដូចជាសារាចរណែនាំស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា និងប្រកាសស្តីពីការគ្រប់គ្រងស្ថិតិសហគ្រាសកសិកម្ម និងកសិឧស្សាហកម្ម។

**២.៧៦-** ទោះបីមានវឌ្ឍនភាពដូចបានរៀបរាប់ខាងលើក៏ដោយ ក៏នៅមានការងារលំបាកមួយចំនួនដូចជា៖

- ព័ត៌មានអំពីសហគ្រាសអ្នកផលិត និងកែច្នៃផលិតផលកសិកម្មសម្រាប់ប្រជាកសិករនៅមិនទាន់សុក្រឹត។
- ទាំងភាគីអ្នកផលិត ទាំងភាគីអ្នកទិញនៅមានការយល់ដឹងតិចតួចស្តីពីយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា។
- ការរៀបចំច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មនៅមិនទាន់មានកិច្ចសហប្រតិបត្តិការល្អ។
- ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស ឧបករណ៍សម្ភារៈ និងរចនាសម្ព័ន្ធគ្រប់គ្រងនៅមានកម្រិត។

- ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍលើបច្ចេកវិទ្យាក្រោយពេលប្រមូលផលការកែច្នៃ និងការគ្រប់គ្រងគុណភាព និងសុវត្ថិភាពនៅមិនទាន់មានសកម្មភាពនៅឡើយ។

**ផលិតកម្មកៅស៊ូ**

**២.៧៧-** គិតមកដល់ឆ្នាំ២០១២នេះ ផ្ទៃដីដាំដុះកៅស៊ូសរុបមានចំនួនជាង២៨០ ៣៥៥ហិកតា ដែលក្នុងនោះផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម មានចំនួន៥៤ ២០៩ហ.ត.(ស្មើនឹង១៩,៣៤% នៃផ្ទៃដីសរុប) ចម្ការកៅស៊ូសម្បទានសេដ្ឋកិច្ចមានចំនួន១១៨ ៤៣៩ហ.ត.(ស្មើ នឹង៤២,២៥% នៃផ្ទៃដីសរុប) និងចម្ការកៅស៊ូគ្រួសារឯកជនចំនួន១០៧ ៦៩៦ហ.ត.(ស្មើនឹង៣៨,៤១%នៃផ្ទៃដីសរុប)។ នៅក្នុងទំហំផ្ទៃដីដាំដុះសរុបចំនួន២៨០ ៣៥៥ហ.ត. មានផ្ទៃដីចៀរជ័រចំនួន៥៥ ៣៦១ ហ.ត. ដោយបានផ្តល់ជាជ័រកៅស៊ូស្ងួតបានចំនួនជាង៦៥ ០០០តោន សម្រាប់នាំចេញទៅបរទេស។

**២.៧៨-** តាមការគ្រោងទុក នៅក្នុង*យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា ២០១១-២០២០* គឺដល់ឆ្នាំ២០២០ ផ្ទៃដីកៅស៊ូនឹងកើនដល់៣០ម៉ឺនហ.ត. ប៉ុន្តែជាក់ស្តែង ត្រឹមឆ្នាំ២០១៣ នេះ ផ្ទៃដីកៅស៊ូ បានកើនដល់ជាង៣០ម៉ឺនហ.ត. រួចស្រេចហើយ។

**២.៧៩-** ការអនុវត្ត***ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣*** វិស័យកៅស៊ូសម្រេចបាននូវសមិទ្ធផលការងារជាច្រើន។ ប៉ុន្តែទន្ទឹមនោះក្រសួងក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

- ខ្វះខាតថវិកា សម្ភារៈ និងមធ្យោបាយ សម្រាប់ដំណើរការការងារ និងការចុះបំពេញបេសកកម្មនៅតាមខេត្ត។
- ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ខ្វះការសហការជាមួយ*អគ្គនាយកដ្ឋានកៅស៊ូ*។
- ទីតាំងចម្ការកៅស៊ូគ្រួសារនិងសិប្បកម្មកែច្នៃផលិតផលកៅស៊ូស្ថិតនៅរាយប៉ាយឆ្ងាយៗ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធមិនអំណោយផល ដែលបណ្តាលឲ្យមានការពិបាកក្នុងការចុះស្រង់ស្ថិតិ សាកសួរព័ត៌មានពាក់ពន្ធ័នឹងការងារដាំដុះកៅស៊ូ និងផ្តល់ការណែនាំពីបច្ចេកទេសកៅស៊ូ។
- ចម្ការកៅស៊ូកសិឧស្សហកម្មមួយចំនួនមិនទាន់បានចូលរួមអនុវត្តតាមស្មារតីអនុក្រឹត្យលេខ៥៥ អ.ន.ក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់ពីគុណភាពកៅស៊ូ។
- វិទ្យាស្ថានមិនទាន់មានផ្ទៃដីសម្រាប់ធ្វើអនុស្ថានីយពិសោធន៍ និងត្រួតពិនិត្យគុណភាពនៅតាមតំបន់។

## ៣.២- កំណែទម្រង់ដីធ្លីនិងការបោសសម្អាតមីន

២.៨០- កំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាល បានផ្ដោតជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្របដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់និងមិនផលិត។ ការងារកែទម្រង់ដីធ្លីក៏មានសារៈសំខាន់ផងដែរក្នុងការពង្រីកនិងការបែងចែកដីធ្លីកសិកម្ម ក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ចសំដៅលើកកម្ពស់បង្កើនផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម និងការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទរបស់ប្រជាកសិករ។

២.៨១- ដោយអនុវត្តគោលដៅខាងលើមានក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* សម្រេចបាននូវសមិទ្ធផលមានដូចខាងក្រោម៖

- *រដ្ឋបាលដីធ្លី*
  - ➢ បន្ទុំច្បាប់ភូមិបាល ជាមួយនឹងក្រមរដ្ឋប្បវេណីថ្មីដែលបានចូលជាធរមានរួចហើយ។
  - ➢ ច្បាប់ស្ដីពីការផ្ដល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស។
  - ➢ អនុក្រឹត្យស្ដីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច។
  - ➢ អនុក្រឹត្យស្ដីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ។
  - ➢ អនុក្រឹត្យស្ដីពីការគ្រប់គ្រងបុរី។
  - ➢ សិក្សាបញ្ចូលបន្ថែមអំពីប្រភេទសិទ្ធិនៃការកាន់កាប់ដីធ្លីដែលលិចទឹកក្នុងរដូវវស្សា និងបានបង្កបង្កើនផលជាក់ស្ដែងរៀងរាល់រដូវទឹកសម្រកក្នុងតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ដីទំនាបដែលទទួលរបបទឹកទន្លេមេគង្គ។
  - ➢ ការងារបច្ចេកទេស មានជាអាទិ៍ ការចុះបញ្ជីដីធ្លី ដោយបញ្ចូលបច្ចេកទេសវាស់វែងទំនើបៗ និងការផលិតមធ្យោបាយបច្ចេកទេសបង្អែកសម្រាប់ការងារដីធ្លី។

២.៨២- ទន្ទឹមការរៀបចំច្បាប់ និងអនុក្រឹត្យ សមិទ្ធផលធំៗផ្សេងទៀត ត្រូវបានបង្កើតឡើងនៅក្នុងការចុះបញ្ជីដីធ្លី ជាពិសេសគឺបានបន្តអនុវត្ត ***គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី***។

- ចុះបញ្ជីដីផ្ដល់ប័ណ្ណកម្មសិទ្ធិបានចំនួន៣៨០ ៥៥២ប័ណ្ណ។
- ចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ : ចេញបណ្ណកម្មសិទ្ធិ បានចំនួន២ ២៥៧ ១៥១បណ្ណ។
- ចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ (ភោគៈ) បានចំនួន៦០៣ ៣០២បណ្ណ។

- ចុះបញ្ជីដីរដ្ឋទំហំធំៗ បាន៥១៥បណ្ណ ស្មើនឹង២៥៧ ៨៨៦ហ.ត.។
- ចុះបញ្ជីសិទ្ធសម្បទានដីសេដ្ឋកិច្ច ១៣០បណ្ណ ស្មើនឹង១០១ ១៧៩ហ.ត.។
- ចុះបញ្ជីសិទ្ធិជួលរយៈពេលវែង៣០៣បណ្ណ ស្មើនឹង៦៥ ៨២៩ហ.ត.។
- ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចបានចំនួន៨សហគមន៍ ក្នុងនោះស្ថិតនៅខេត្តមណ្ឌលគិរីចំនួន៦សហគមន៍(ជនជាតិព្នង) និងស្ថិតនៅខេត្តរតនគិរីចំនួន២សហគមន៍ (ជនជាតិទំពួន)។
- បានបណ្តុះបណ្តាលអំពីខ្លឹមសារច្បាប់និងនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដល់គណៈកម្មការរដ្ឋបាលនៅទូទាំងប្រទេស បានចំនួនជាង១សែននាក់។ លើសពីនេះមាននិស្សិតថ្នាក់បរិញ្ញាបត្រអំពីជំនាញការងាររៀបចំដែនដីនិងរដ្ឋបាលដីធ្លីចំនួន២៦៩នាក់ និងនិស្សិតត្រៀមបរិញ្ញាបត្រចំនួន២៩៦នាក់ ដែលបាននិងកំពុងទទួលការបណ្តុះបណ្តាលនៅមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី។

២.៨៣- *ការដោះស្រាយវិវាទដីធ្លី* : ជាលទ្ធផល ចាប់ពីដំណើរការយន្តការនេះគណៈកម្មការសុរិយាដីគ្រប់ថ្នាក់ គិតត្រឹមឆ្នាំ២០១២ លើចំនួនវិវាទដែលបានទទួលសរុបមាន៥ ៦០៨ករណី បានដោះស្រាយបញ្ចប់បានចំនួន២ ៣២៥ករណី គិតជាគ្រួសារមានចំនួន១០ ៩៨២គ្រួសារ និងជាផ្ទៃដីចំនួន៣ ៦១១,៩ហិកតា។ លើចំនួនវិវាទដែលបានទទួល៥ ៦០៨ករណី បានច្រានចោលដោយខុសយុត្តាធិការចំនួន១ ៨០៧ករណី និងបានសុំដកពាក្យវិញចំនួន៥២៤ករណី។

២.៨៤- *ការរៀបចំដែនដីនិងនគរូបនីយកម្ម* : ក្រសួងបានអនុវត្តការងាររៀបចំដែនដី និងនគរូបនីយកម្ម និងសម្រេចបានលទ្ធផលដូចខាងក្រោម៖

- *ផែនការកម្រិតថ្នាក់តំបន់* : បានរៀបចំយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរនៃខេត្តចំនួន៤ រួមមាន៖ ខេត្តកែប កំពត ព្រះសីហនុ និងកោះកុង។
- *ផែនការកម្រិតថ្នាក់រាជធានីខេត្ត* : បានរៀបចំប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តបាត់ដំបង និងខេត្តកែប។
- *ផែនការកម្រិតថ្នាក់ក្រុង ស្រុក ខណ្ឌ*
  - ➢ បានរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីទីក្រុងចំនួន១០ និងទីប្រជុំជនចំនួន៤ គឺ៖ ក្រុងក្រចេះ ក្រុងបាត់ដំបង ក្រុងស្ទឹងត្រែង ក្រុងបាវិត ក្រុងប៉ោយប៉ែត ក្រុងកំពង់ចាម ក្រុងសួង ក្រុងសៀមរាប ក្រុងច្បារមន ក្រុងខេមរភូមិន្ទ ទីប្រជុំជនកំពង់ត្រាច ទីប្រជុំជនអ្នកលឿង ទីប្រជុំជនស្ទឹងហាវ និងទីប្រជុំជនអន្លង់វែង។
  - ➢ កំពុងរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីក្រុងកែប និងក្រុងព្រះសីហនុ។

- ➢ បានរៀបចំប្លង់គោលប្រើប្រាស់ដីចំនួន១៧ស្រុក ១ខណ្ឌ និង៣ក្រុង គឺ ស្រុកស្ទោង ស្រុកកំរៀង ស្រុកភ្នំព្រឹក្ស ស្រុកពញាក្រែក ស្រុកស្អូល ទីប្រជុំជនស្រុកឆ្លូង ស្រុកពាមរណ៍ ស្រុកជាំក្សាន្ត ស្រុកកោះធំ ស្រុកគិរីវង់ ស្រុកអូរជ្រៅ ស្រុកកែវសីមា ស្រុកសែនមនោរម្យ ស្រុកបន្ទាយស្រី ស្រុកត្បូងឃ្មុំ ស្រុកសាលាក្រៅ ស្រុកចន្ទ្រា ខណ្ឌមានជ័យ ក្រុងព្រះវិហារ ក្រុងសេរីសោភ័ណ និងក្រុងកំពង់ឆ្នាំង។
- ➢ កំពុងរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីស្រុកតាវែង អណ្តូងមាស និងអូរយ៉ាដាវ ខេត្តរតនគិរី។

- *ផែនការកម្រិតថ្នាក់ឃុំ សង្កាត់៖*

- ➢ បានរៀបចំផែនការប្រើប្រាស់ដីចំនួន១២០ ឃុំ សង្កាត់ ក្នុងខេត្តគោលដៅចំនួន១១។
- ➢ បានផលិតផែនទីប្រើប្រាស់ដីផ្តល់ជូនក្រុមប្រឹក្សាឃុំសង្កាត់ទាំង១ ៦៣៣ឃុំ សង្កាត់
- ➢ បានជួយគាំទ្របច្ចេកទេសក្នុងការសម្របសម្រួលការកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ចំនួន ១៤៨ ឃុំ សង្កាត់។

### ២.៨៥- *ការរៀបចំលិខិតបទដ្ឋាននានាដើម្បីធានាការអនុវត្តឲ្យមានភាពរលូននិងប្រសិទ្ធភាព*

- ក្រសួងបានសម្រេចដាក់ចេញអនុវត្ត៖
  - ➢ អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
  - ➢ សេចក្តីណែនាំអនុវត្តការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
  - ➢ សារាចរណែនាំស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។
  - ➢ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។
  - ➢ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
  - ➢ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។
- កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម។

### ២.៨៦- *ការបណ្តុះបណ្តាលសមត្ថភាពជំនាញ*

- បានបណ្តុះបណ្តាលមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់និងអាជ្ញាធរដែនដីថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ សហគមន៍មូលដ្ឋាន និងមន្ត្រីអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ស្តីពីនីតិវិធី

នៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ការអាន និងការប្រើប្រាស់ផែនទី និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងសរុបចំនួន៣ ៥៣៣នាក់។

## ២.៨៧- *ការបែងចែកសម្បទានដីសង្គមកិច្ចនិងប្រទានកម្មដី*

- បានចាត់ចែងអនុវត្តសម្រេចបានលទ្ធផលលើសពីផែនការ គឺសរុបបានប្រមាណ ៣១ ០០០គ្រួសារ នៅដំណាច់ឆ្នាំ២០១៣។
- សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ សម្រេចបានប្រមាណជាង៤ ០០០គ្រួសារ។
- សម្បទានដីសង្គមកិច្ចជូនយោធិននិងគ្រួសារដែលកំពុងឈរជើងការពារតំបន់ព្រំដែនទិសខាងលិចនិងខាងជើង សម្រេចបានប្រមាណ៧ ០០០គ្រួសារ។
- សម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ តាមគ្រប់រូបភាព(ទម្រង់ជាប្រទានកម្មនិងនិយ័តកម្ម) សម្រេចបានប្រមាណ១៥ ០០០គ្រួសារ។
- គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច ដោយសហការជាមួយដៃគូអភិវឌ្ឍនិងអង្គការជាតិនិងអន្តរជាតិ សម្រេចបានប្រមាណជិត៥ ០០០គ្រួសារ។

**២.៨៨-** *ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យសំណង់៖* វិស័យសំណង់ត្រូវបានចាត់ថាជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំង៤នៃការជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា។ សមិទ្ធផលធំៗដែលសម្រេចបានក្នុងវិស័យនេះ រួមមាន៖

- ឆ្នាំ២០០៨ មាន២ ១៥៦គម្រោង ផ្ទៃក្រឡាសំណង់សរុប១០ ៣៣៩ ៦៤២ម² មានតម្លៃប៉ាន់ស្មាន៣ ១៩១ ៥៦៩ ១៤៤ដុល្លារអាមេរិក។
- ឆ្នាំ២០០៩ មាន២ ២៣០គម្រោង ផ្ទៃក្រឡាសំណង់សរុប៦ ៦១៤ ៧៤៧ម² មានតម្លៃប៉ាន់ស្មាន១ ៩៨៨ ៨៥១ ៩៥១ដុល្លារអាមេរិក។
- ឆ្នាំ២០១០ មាន២ ១៤៩គម្រោង ផ្ទៃក្រឡាសំណង់សរុប៣ ២៨៧ ៤៦៨ម² មានតម្លៃប៉ាន់ស្មាន៨៤០ ៤៥៩ ៥២៩ដុល្លារអាមេរិក។
- ឆ្នាំ២០១១ មាន២ ១២៩គម្រោង ផ្ទៃក្រឡាសំណង់សរុប៥ ២៥៧ ៥៨៧ម² មានតម្លៃប៉ាន់ស្មាន១ ៧៣៤ ៥៩៨ ៥៨៤ដុល្លារអាមេរិក។
- ឆ្នាំ២០១២ មាន១ ៦៩៤គម្រោង ផ្ទៃក្រឡាសំណង់សរុប៦ ៥២៨ ៤៥២ម² មានតម្លៃប៉ាន់ស្មាន២ ១០៩ ៦០៧ ២៤២ដុល្លារអាមេរិក។
- បានធ្វើប្រតិភូកម្មការងារឲ្យទៅសាលាក្រុង ស្រុក ខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់និងសេវាពាក់ព័ន្ធនឹងការសាងសង់សំណង់ ដែលមានទំហំតូចជាងឬស្មើ៥០០ម² នៅការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌគោលដៅចំនួន២៣។

- បានចេញប្រកាសកំណត់នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដើម្បីងាយស្រួលគ្រប់គ្រងសហគ្រាសនិងក្រុមហ៊ុនទាំងនោះ។ គិតត្រឹមឆ្នាំ ២០១២ សហគ្រាសនិងក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ ទាំងក្នុងស្រុកនិងបរទេស បានចុះបញ្ជីចំនួន១ ២០៥ក្រុមហ៊ុន។
- បានបង្កើតគណៈស្ថាបត្យករកម្ពុជាក្នុងគោលបំណងប្រមូលផ្តុំនិងគ្រប់គ្រងវិស្វករ និងស្ថាបត្យករដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកកម្ពស់វិជ្ជាជីវៈគុណភាព ស្នាដៃស្ថាបត្យករ និងកិត្យានុភាពនៃស្ថាបត្យកម្មជាតិ។ បច្ចុប្បន្នគណៈស្ថាបត្យករកម្ពុជាបានចូលជាសមាជិកក្រុមប្រឹក្សាវិស្វករនិងក្រុមប្រឹក្សាស្ថាបត្យករអាស៊ាន។
- បានបង្កើតសមាគមអ្នកសាងសង់កម្ពុជាដើម្បីឆ្លើយតបទៅនឹងភាពរីកចម្រើននៃយុគសម័យថ្មីនេះ និងដើម្បីរួមចំណែកអភិវឌ្ឍវិស័យសំណង់។ បច្ចុប្បន្នសមាគមអ្នកសាងសង់កម្ពុជាបានចូលជាសមាជិករបស់សហព័ន្ធអ្នកសាងសង់អាស៊ាន។

**២.៨៩-** ពាក់ព័ន្ធនឹងការប្រើប្រាស់និងគ្រប់គ្រងដីកសិកម្ម *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានពិនិត្យនិងវិភាគឡើងវិញពីការប្រើប្រាស់ដីកសិកម្មដែលកំពុងត្រូវបានប្រើប្រាស់សំដៅបង្កើតរៀបចំផែនការនិងតំបន់ប្រើប្រាស់ដីកសិកម្មឲ្យបានរៀបរយ។ ក្នុងន័យនេះក្រសួងក៏បានរៀបចំសេចក្តីព្រាងក្របខ័ណ្ឌនីតិប្បញ្ញត្តិដីកសិកម្ម ដូចជា សេចក្តីព្រាងច្បាប់ដីកសិកម្ម និងការណែនាំគ្រប់គ្រងដីកសិកម្ម ដើម្បីធានាដល់ការរៀបចំផែនការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពនិងការគ្រប់គ្រងប្រើប្រាស់ដីប្រកបដោយចីរភាព។

**២.៩០-** ដោយផ្តើមចេញពីកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្ត នូវបណ្តាគោលដៅខាងលើ រាជរដ្ឋាភិបាល សម្រេចបាន៖

- បានរៀបចំសេចក្តីព្រាងស្តីពីការរៀបចំផែនការនិងបង្កើតតំបន់ប្រើប្រាស់ដីកសិកម្ម។
- បានរៀបចំសេចក្តីព្រាងស្តីពីផែនការសកម្មភាពជាតិ ស្តីពីការគ្រប់គ្រងការប្រើប្រាស់ដីប្រកបដោយចីរភាព។
- បានរៀបចំសេចក្តីព្រាងស្តីពីការគ្រប់គ្រងនិងអភិរក្សដីជាតិដី។
- បានពង្រឹងសមត្ថភាពពិសោធន៍ រួមមានបន្ទប់ពិសោធន៍ដី ទឹក និងដើមឈើ ក៏ដូចជាសមត្ថភាពនៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម។
- បានរៀបចំសេចក្តីព្រាងស្តីពីច្បាប់កសិកម្ម។

**២.៩១-** យ៉ាងណាក៏ដោយក៏កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ប្រជាពលរដ្ឋនៅគ្រប់ទីកន្លែងចង់បានបណ្ណកម្មសិទ្ធិ ដើម្បីធានាសុវត្ថិភាពកាន់កាប់ដីធ្លី កាត់បន្ថយជម្លោះ លើកកម្ពស់ជីវភាព និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

- ចំណូលរដ្ឋតាមរយៈការផ្ទេរសិទ្ធិលើដីធ្លី នៅមិនទាន់ប្រមូលឲ្យបានអស់លទ្ធភាព ហើយព័ត៌មានដីធ្លីត្រូវបានធ្វើបច្ចុប្បន្នកម្មមិនទាន់ពេញលេញដែលអាចនាំឲ្យប្រព័ន្ធព័ត៌មានសុរិយោដីមិនសូវមានសុក្រឹតភាព។
- ការចូលរួមនិងការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងមន្ត្រីជំនាញ នៅមានកម្រិត ទាំងលើការងាររៀបចំដែនដីនិងនគរូបនីយកម្ម និងការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត សាងសង់ខុសពីលិខិតអនុញ្ញាត និងសាងសង់ខុសលក្ខណៈបច្ចេកទេស។
- ទំនាស់លើការប្រើប្រាស់ដីពីភាគីពាក់ព័ន្ធនៅពេលបិទផ្សាយប្លង់គោលជាសាធារណៈនៅមូលដ្ឋាន បង្កការលំបាកនិងនាំឲ្យយឺតយ៉ាវពេលវេលាក្នុងការអនុម័ត។
- ការស្វែងរកដីនិងគ្រប់គ្រងដីនិងការចូលរួមពីក្រុមការងារថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច មិនទាន់បានពេញលេញ។

### ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម

**២.៩២-** ប្រជាជនកម្ពុជាជាង៦៤ ០០០នាក់ ទាំងបុរស ស្ត្រី និងកុមារ ត្រូវបានស្លាប់និងរងរបួសដោយសារមីនប្រឆាំងមនុស្ស និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ក្នុងនោះ១៨៦នាក់ ទទួលរងគ្រោះថ្នាក់ក្នុងឆ្នាំ២០១២។ មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតែបន្តជាឧបសគ្គរាំងស្ទះដល់ដំណើរការស្តារឡើងវិញនិងការអភិវឌ្ឍប្រទេសជាតិ។

**២.៩៣-** ជាមួយនឹងការគាំទ្រពីសហគមន៍អន្តរជាតិ *រាជរដ្ឋាភិបាលកម្ពុជា* បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ សំដៅបោសសម្អាតផ្ទៃដីមីនប្រឆាំងមនុស្ស និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ រវាងឆ្នាំ២០០៩-២០១២ *អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន* បានអនុវត្តការស្រាវជ្រាវទិន្នន័យមូលដ្ឋានលើស្រុកគោលដៅចំនួន១២៤ ដែលមានការគំរាមដោយមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

**២.៩៤-** ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២ ប្រតិបត្តិករបោសសម្អាតមីន បានរំដោះផ្ទៃដីមានមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន៤០ ៥២៩ហ.ត. សម្រាប់សហគមន៍ ដែលរងផលប៉ះពាល់ប្រើប្រាស់។ ផ្ទៃដីបានរំដោះទាំងនោះភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ធ្វើកសិកម្ម សាងសង់លំនៅឋាន និងបម្រើឲ្យគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន៖ ការសាងសង់សាលារៀន មណ្ឌលសុខភាព ផ្លូវថ្នល់ និងប្រព័ន្ធស្រោចស្រព ដែលបានបម្រើប្រយោជន៍ឲ្យប្រជាជនច្រើនជាង១០ ០០០គ្រួសារ។ កម្ពុជាមិនត្រឹមតែបានធ្វើការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅក្នុងប្រទេសតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានបញ្ជូនកងកម្លាំងបោសសម្អាតមីនចំនួន២៧៨នាក់ ចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិនៅប្រទេសស៊ូដង់

និងនៅប្រទេសលីបង់ក្នុងឆ្នាំ២០១០ដល់ឆ្នាំ២០១២ ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ។ លើសពីនេះកម្ពុជាបានចែករំលែកបទពិសោធវិស័យសកម្មភាពមីនដល់ប្រទេសជាច្រើនដែលរងផលប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

២.៩៥- តារាងទី២.៣ ខាងក្រោមបង្ហាញពីសមិទ្ធផលដែលសម្រេចបាន ក្នុងវិស័យសកម្មភាពមីន ក្នុងការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងការរំដោះផ្ទៃដីមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២។

**តារាងទី២.៣ : ស្ថិតិទាក់ទងនឹងការរំដោះផ្ទៃដីមានមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម**

| សូចនាករ | ឯកតា | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ(ស្លាប់/របួស) | នាក់ (ចំណុចដៅ) | ២៤៤* | ២៤០* | ២២០* | ២០០* |
| | នាក់ (សម្រេចបាន) | ២៤៤ | ២៨៦ | ២១១ | ១៨៦ |
| ផ្ទៃដីសរុបបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | ហ.ត. (ចំណុចដៅ) | ៥ ២៦៨* | ៥ ៣៧៤* | ៥ ៤៨១* | ៥ ៥៩១* |
| | ហ.ត. (សម្រេចបាន) | ៦ ១៣៦ | ១១ ៩៥០ | ១៤ ១៥០ | ៨ ២៩៣ |

*សំគាល់ : លទ្ធផលរំដោះផ្ទៃដីពីឆ្នាំ២០០៩ដល់ឆ្នាំ២០១១ ជាផ្ទៃដីបានរំដោះនៅក្រៅពហុកោណនៃការស្រាវជ្រាវទិន្នន័យមូលដ្ឋាន និងលទ្ធផលរំដោះផ្ទៃដីនៅក្នុងឆ្នាំ២០១២ ជាផ្ទៃដីក្នុងពហុកោណនៃការស្រាវជ្រាវទិន្នន័យមូលដ្ឋាន។*

២.៩៦- នៅចុងឆ្នាំ២០១២ ការស្រាវជ្រាវទិន្នន័យជាមូលដ្ឋានត្រូវបានបញ្ចប់នៅក្នុងខេត្តភាគច្រើនជាតំបន់សង្ស័យមានមីនតាមការស្រាវជ្រាវមុនៗ ដែលជាលទ្ធផលបានរកឃើញថា ផ្ទៃដីនៅមានមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន១៩១ ៤៨២ហ.ត. ដែលត្រូវធ្វើការបោសសម្អាត។ បន្ថែមពីនេះនៅមានផ្ទៃដីច្រើនកន្លែងទៀតដែលសង្ស័យមានសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលចាំបាច់ត្រូវការធ្វើការស្រាវជ្រាវជាលក្ខណៈប្រព័ន្ធនៅក្នុងឆ្នាំខាងមុខ។

២.៩៧- សកម្មភាពមីននៅកម្ពុជាពឹងផ្អែកទាំងស្រុងលើការផ្តល់ថវិកាគាំទ្រពី រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។ *រាជរដ្ឋាភិបាលកម្ពុជា*មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការធ្លាក់ចុះនូវជំនួយថវិកាចាប់តាំងពីឆ្នាំ២០១១។ នៅក្នុងស្ថានភាពនេះតម្រូវឲ្យមានការខិតខំប្រឹងប្រែងកៀរគរជំនួយ និងបង្កើនការផ្តល់ថវិកាជាតិបន្ថែម ដើម្បីធានាចីរភាពនិងប្រសិទ្ធភាពនៃសកម្មភាពបោសសម្អាតមីន។

## ៣.៣- កំណែទម្រង់ជលផល

២.៩៨- រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់ស៊ីជម្រៅ សំដៅជំរុញការនេសាទជាលក្ខណៈគ្រួសារនិងការធ្វើអាជីវកម្ម ប្រកបដោយចីរភាពផងនិងធានាផលស្តុកក្នុងធម្មជាតិផង។ ជាក់ស្តែងបរិមាណផលនេសាទទឹកសាបឆ្នាំ២០១៣នេះអនុវត្តបានចំនួន៥៥០ ០០០តោន និងផលនេសាទសមុទ្រអនុវត្តបានប្រមាណ១០០ ០០០តោន។

**តារាងទី២.៤ : ស្ថិតិផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្មពីឆ្នាំ២០០៩-២០១២ (ឯកតា : តោន)**

| បរិយាយ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| ផលនេសាទទឹកសាប | ៣៩០ ០០០ | ៤០៥ ០០០ | ៤៤៥ ០០០ | ៥០៩ ០០០ | ៥៥០ ០០០ |
| ផលនេសាទសមុទ្រ | ៧៥ ០០០ | ៨៥ ០០០ | ៩១ ០០០ | ៩៩ ០០០ | ១០០ ០០០ |
| ផលវារីវប្បកម្ម | ៥០ ០០០ | ៦០ ០០០ | ៧២ ០០០ | ៧៤ ០០០ | ៨០ ០០០ |
| សរុប | ៥១៥ ០០០ | ៥៥៥ ០០០ | ៦០៨ ០០០ | ៦៨២ ០០០ | ៧៣០ ០០០ |

*ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

**២.៩៩-** ការអភិវឌ្ឍវារីវប្បកម្ម គឺជាគោលនយោបាយដ៏ចម្បងរបស់រាជរដ្ឋាភិបាលក្នុងការធានាសន្តិសុខស្បៀងជូនប្រជាពលរដ្ឋ និងកាត់បន្ថយការដាក់សម្ពាធលើធនធានជលផលក្នុងដែនទឹកធម្មជាតិ។ ការអភិវឌ្ឍវារីវប្បកម្ម ក៏ត្រូវអនុវត្តតាមគ្រប់រូបភាពនិងគ្រប់ទីកន្លែងរួមទាំងការបង្កើតស្រះជម្រកត្រីសហគមន៍ផងដែរ ដើម្បីធ្វើឲ្យផលិតកម្មវារីវប្បកម្មនេះមានការកើនឡើងប្រមាណ ១៥% ជារៀងរាល់ឆ្នាំ។

**២.១០០-** ការអភិវឌ្ឍវារីវប្បកម្ម រួមមានការចិញ្ចឹមត្រីនិងបង្គា។ ក្នុងឆ្នាំ២០១៣ ទិន្នផលសរុបពីការចិញ្ចឹមត្រីនិងបង្គាបានចំនួន៨០ ០០០តោនកើនលើសឆ្នាំមុន៨%។ ការភ្ញាស់កូនត្រីពូជអនុវត្តបាន១៤០លានក្បាលកើនលើសឆ្នាំមុន៨%។ ក្នុងឆ្នាំ២០១២ ការចិញ្ចឹមក្រពើអនុវត្តបាន ២៥០ ០០០ក្បាលកើនលើសឆ្នាំ២០១១ប្រមាណជា២៥% ដោយសារតែស្បែករបស់វាមានតម្លៃខ្ពស់លើទីផ្សារ។

**២.១០១-** *រដ្ឋបាលជលផល* បានបង្កើតសហគមន៍នេសាទសរុបចំនួន៥១៦សហគមន៍នៅតាមបណ្តាខេត្តនានា សម្រាប់ការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋានប្រកបដោយចីរភាព។ សហគមន៍នេះមានសមាជិកសរុប១៥៦ ៦២៨គ្រួសារ(ស្មើនឹង៣៣២ ១៦៨នាក់ ក្នុងនោះ៣៣%ជាស្ត្រី) ដែលមានទីតាំងក្នុងដែននេសាទទឹកសាបចំនួន៤៧៧សហគមន៍ និងតំបន់ឆ្នេរសមុទ្រចំនួន៣៩សហគមន៍។ ក្នុងនោះសហគមន៍នេសាទចំនួន៣២៨ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅ*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*។

**២.១០២-** សម្រាប់សកម្មភាពអភិរក្ស *រដ្ឋបាលជលផល*មានកន្លែងអភិរក្សដែលបានបង្កើតថ្មីចំនួន៥០កន្លែង ក្រោយការរំសាយឡូត៍នេសាទ។ កន្លែងអភិរក្សជលផលបឹងទន្លេសាបចំនួន៨ ដែលមានទំហំ២២ ៥០០ហ.ត. និងមានព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាបដែលមានទំហំប្រមាណ៧២៦ ២២១ហ.ត. ដែលជាជម្រកសំខាន់សម្រាប់រស់នៅរកចំណី ជាកន្លែងបន្តពូជរបស់មច្ឆជាតិច្រើនប្រភេទ។ ក្រៅពីការអភិរក្សនិងការការពារព្រៃលិចទឹក *រដ្ឋបាលជលផល*ក៏បានជំរុញឲ្យមានការចូលរួមពីសហគមន៍ខ្លាំងក្លាផងដែរក្នុងការដាំព្រៃលិចទឹក ប្រមាណ១០០

ហ.ត.ក្នុងមួយឆ្នាំ។ ស្ថានីយល្បាតចំនួន២៧ត្រូវបានបង្កើត និងកន្លែងអភិរក្សសំខាន់ៗផ្សេងទៀតនៅតាមទន្លេមេគង្គ គឺអន្លង់ជ្រៅៗដែលមានប្រមាណ៩៧អន្លង់ក៏ទទួលបានកិច្ចការពារថែរក្សា។

**២.១០៣-** ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានគួរឲ្យកត់សម្គាល់នេះ វិស័យជលផលនៅជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- បទល្មើសនេសាទនៅតែកើតមានជាពិសេសការប្រើឧបករណ៍ឆក់ ស្នែមុង ដាក់សម្រាស់ការកាប់ព្រៃលិចទឹកក្នុងដែននេសាទសហគមន៍ និងដែននេសាទសាធារណៈ។
- សហគមន៍នេសាទពុំមានថវិកាសម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន និងសមាជិកសហគមន៍នេសាទភាគច្រើនជាអ្នកក្រីក្រ។
- កង្វះខាតទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធ សំដៅធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយកាត់បន្ថយការនាំចេញ និងនាំចូលត្រីមិនស្របច្បាប់។
- កង្វះខាតកិច្ចសហប្រតិបត្តិការរវាងមន្ត្រីនៅតាមបណ្តាព្រំដែន។
- ចំនួនក្រុមសហគមន៍នេសាទមិនមានការកើនឡើងហើយការគ្រប់គ្រងនៅខ្សោយ។
- ការអនុវត្តច្បាប់និងការយល់ដឹងពីសារៈសំខាន់នៃធនធានជលផលរបស់ប្រជានេសាទ និងអ្នកពាក់ព័ន្ធនៅមានកម្រិត។
- កង្វះខាតមន្ត្រីបច្ចេកទេសជលផលបំពេញការងារដើម្បីជំនួសមន្ត្រីចូលនិវត្តន៍។
- កង្វះខាតធនធានមនុស្សផ្នែកស្រាវជ្រាវនៅថ្នាក់ជាតិនិងក្រោមជាតិ។
- កង្វះខាតសម្ភារៈ ថវិកាសម្រាប់ដំណើរការគ្រប់គ្រង ការសិក្សាស្រាវជ្រាវ ការផ្សព្វផ្សាយការអភិរក្ស និងការការពារប្រភពធនធានជលផល។
- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។
- ផលប៉ះពាល់ពីការសាងសង់ទំនប់នៅតំបន់មេគង្គលើ នឹងអាចជាឧបសគ្គដល់ការអភិវឌ្ឍវិស័យជលផល។
- ផលប៉ះពាល់ពីជាតិពុលគីមីមកលើត្រីគ្រប់ប្រភេទ។

### ៣.៤- កំណែទម្រង់ព្រៃឈើ

**២.១០៤-** ការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទប្បញ្ញត្តិនានា ដោយមានកិច្ចសហការល្អ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធធនធានព្រៃឈើ ត្រូវបានគ្រប់គ្រងនិងការពារដោយហ្មត់ចត់និងទប់ស្កាត់បានការទន្ទ្រាន កាន់កាប់ដីព្រៃដោយខុសច្បាប់។ ក្នុងន័យនេះដែរ *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានរៀបចំផែនការរយៈពេល២០ឆ្នាំសម្រាប់វិស័យព្រៃឈើ( *កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩*)។ របាយការណ៍វឌ្ឍនភាពស្តីពីកម្មវិធីព្រៃឈើជាតិទាំង៦កម្មវិធីធំៗ មានដូចតទៅ៖

- *ការកំណត់ព្រំប្រទល់ព្រៃឈើ ការចាត់ថ្នាក់និងការចុះបញ្ជិកា :* គម្របព្រៃឈើកម្ពុជានៅឆ្នាំ ២០១០ មានទំហំសរុប១០ ៣៦៣ ៧៨៩ហិកតាស្មើនឹង៥៧,០៧%នៃផ្ទៃដីទូទាំងប្រទេស។ បានបោះបង្គោលព្រំដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍បានប្រវែងសរុបចំនួន២ ៥១៣គីឡូម៉ែត្រ។
- *កម្មវិធីអភិរក្សនិងអភិវឌ្ឍធនធានព្រៃឈើនិងជីវៈចម្រុះ* បានរៀបចំព្រៃការពារនិងតំបន់អភិរក្សចំនួន៣កន្លែង មានផ្ទៃដីសរុប៣៩៤ ២៥៥ហ.ត. ក្នុងនោះ៖

  - ➢ ១០១ ៣៤៨ហ.ត.ជាព្រៃការពារអូយ៉ាដាក្នុងខេត្តរតនគិរី។
  - ➢ ២៩២ ៦៩០ហ.ត.ជាព្រៃការពារសីមាក្នុងខេត្តមណ្ឌលគិរី។
  - ➢ ២១៧ហ.ត.ជាតំបន់អភិរក្សសត្វក្រៀល-អន្លង់ព្រីងក្នុងខេត្តកំពត។ ក្រសួងក៏បានអនុវត្តនូវគម្រោងអភិរក្សសត្វស្លាបនិងសត្វព្រៃនៅ (១)តំបន់បឹងព្រែកល្ពៅ ខេត្តតាកែវ (២) អន្លង់ព្រីង ខេត្តកំពត (៣)តំបន់អាងត្រពាំងថ្ម ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ (៤) កំពង់ធំ (៥)ក្រពើ ខេត្តសៀមរាប (៦)ដំរី តំបន់ព្រៃការពារជួរភ្នំក្រវាញកណ្ដាល និង (៧)ជីវៈចម្រុះ តំបន់ត្រីកោណមរតក កម្ពុជា-ឡាវ-ថៃ។ ទន្ទឹមនឹងបណ្ដាគម្រោងអភិរក្សតំបន់ទាំងនេះ វិស័យឯកជនក៏បានដាំដើមឈើចំនួន៨០ ៦៩២ហ.ត.។

- *ពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើនិងអភិបាលកិច្ច* *រដ្ឋបាលព្រៃឈើ*បានរៀបចំសេចក្ដីព្រាងច្បាប់ចំនួន៨ និងដាក់ឲ្យប្រើប្រាស់ប្រកាសចំនួន៤៣ពាក់ព័ន្ធនឹងការអភិរក្សព្រៃឈើ សត្វព្រៃ ជីវៈចម្រុះ និងនេសាទ។
- *ការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ* *រដ្ឋបាលព្រៃឈើ*បានស្រង់ស្ថិតិ ការកាប់រានដីព្រៃធ្វើជាកម្មសិទ្ធិបានចំនួន២៣៥ ០៤២ហ.ត. និងបានដកហូតដោយការបង្ក្រាបបានចំនួន១៣ ០៦២ហ.ត.។ ទន្ទឹមនោះក៏បានស្រង់ស្ថិតិរណារយន្តបានចំនួន៣ ៤៨០គ្រឿង និង ដកហូតបានចំនួន៣ ២៦២គ្រឿង។
- *ការងារស្ម័គ្រចិត្តសម្រាប់អភិវឌ្ឍន៍សហគមន៍* *រដ្ឋបាលព្រៃឈើ* បានចាត់វិធានការបន្ទាន់ដោយបានបញ្ជូនមន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សរុបចំនួន១៩៨នាក់ចូលរួមជាមួយក្រុមការងារថ្នាក់ជាតិ ថ្នាក់ខេត្ត និងយុវជនស្ម័គ្រចិត្ត ដើម្បីចុះជួយសម្របសម្រួលសកម្មភាពក្នុងយុទ្ធនាការវាស់វែងដីជូនប្រជាពលរដ្ឋ។
- *សហគមន៍ព្រៃឈើ* សហគមន៍ព្រៃឈើបានទទួលផ្ទៃដីពីក្រសួងប្រមាណ២២៩ ៥៦៣ ហ.ត. ដែលមានចំនួន២៥១កន្លែង នៅក្នុងខេត្តចំនួន១៩។ *រដ្ឋបាលព្រៃឈើ* ក៏បានចុះកិច្ចព្រមព្រៀងប្រគល់ជូនគណៈកម្មាធិការគ្រប់គ្រងព្រៃសហគមន៍បានចំនួន២០០កន្លែង លើផ្ទៃដី១៦៨ ៩២៣ហ.ត. ក្នុងខេត្តចំនួន១៦។

- *ការអភិវឌ្ឍសមត្ថភាពនិងស្រាវជ្រាវ* ចាប់ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ *រដ្ឋបាលព្រៃឈើ* បានបញ្ជូនមន្ត្រីទៅចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលខ្លីនិងវែង នៅក្នុងនិងក្រៅប្រទេសបានចំនួន៦ ៣៣៨នាក់។

**២.១០៥-** ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានកន្លងមក *រដ្ឋបាលព្រៃឈើ* នៅមានបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- កង្វះខាតច្បាប់និងបទដ្ឋានគតិយុត្ត ទន្ទឹមនឹងនេះការពង្រឹងច្បាប់នៅមានចំណុចខ្វះខាត។
- ការយល់ដឹងពីសារៈសំខាន់ធនធានព្រៃឈើក្នុងចំណោមប្រជាជនមូលដ្ឋានពឹងអាស្រ័យអនុផលព្រៃឈើនៅមានកម្រិត។
- កង្វះខាតធនធានមនុស្ស សម្ភារៈ និងការលើកទឹកចិត្តដល់មន្ត្រីបម្រើការនៅតំបន់ដាច់ស្រយាល។
- ការងារបង្ក្រាបបទល្មើសនិងការកាប់រានដីព្រៃឈើយកដីធ្វើជាកម្មសិទ្ធិល្មើសច្បាប់ មានការលំបាក ពីព្រោះជនប្រព្រឹត្តបទល្មើសតែងតែផ្លាស់ប្តូរវិធីសាស្ត្រក្នុងការដឹកជញ្ជូននិងបំផ្លាញព្រៃឈើក្រោមរូបភាពផ្សេងៗ។
- កង្វះខាតកិច្ចសហប្រតិបត្តិការនិងការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ។
- ការតាំងទីលំនៅរបស់ជនចំណាកស្រុកក្នុងតំបន់ព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃ។

### កិច្ចការពារ ការអភិរក្ស បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

## ការអភិវឌ្ឍបៃតងនិងការអភិវឌ្ឍកាបូនទាប

**២.១០៦-** *ក្រសួងបរិស្ថាន គណៈកម្មាធិការជាតិបម្រែបម្រួលអាកាសធាតុ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង* បានរៀបចំ *ផែនការយុទ្ធសាស្ត្រជាតិបម្រែបម្រួលអាកាសធាតុ(២០១៤-២០២៨)* និងបានបង្កើត *គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងនិង ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០*។

**២.១០៧-** *ការគ្រប់គ្រងតំបន់ការពារធម្មជាតិ : ក្រសួងបរិស្ថាន* បានតែងតាំងអ្នកឧទ្យានុរក្សក្នុងការល្បាត អង្កេត តាមដាន កត់ត្រាទិន្នន័យ និងទប់ស្កាត់បទល្មើសធនធានធម្មជាតិ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិទាំង២៣កន្លែងនិងតំបន់រ៉ាមសារ។ រចនាសម្ព័ន្ធគ្រប់គ្រងរាប់បញ្ចូលអាជ្ញាធរទាំងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ជាលទ្ធផលផ្ទៃដីតំបន់ការពារធម្មជាតិទាំង២៣កន្លែង បានកើនឡើងពី៣ ១០០ ១៩៩ហ.ត. ក្នុងឆ្នាំ២០០៩ មក៣ ១១១ ០៤១ហ.ត. ក្នុងឆ្នាំ២០១២។ ទន្ទឹមនឹងនេះ សហគមន៍តំបន់ការពារធម្មជាតិបានកើនពីចំនួន៨៤មក១១៥នាឆ្នាំ

ដដែល។

**តារាងទី២.៥ : សូចនាករសំខាន់ៗ អំពីការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ**

| សូចនាករ | ឯកតា | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ផ្ទៃដីតំបន់ការពារធម្មជាតិ ទាំង ២៣កន្លែង | ហិកតា | ៣ ១០០ ១៩៩ | ៣ ១១១ ០៤១ | ៣ ១១១ ០៤១ | ៣ ១១១ ០៤១ |
| សហគមន៍តំបន់ការពារធម្មជាតិ | ចំនួន | ៨៤ | ៩៨ | ១០២ | ១១៥ |

*ប្រភព : ក្រសួងបរិស្ថាន*

**២.១០៨-** ក្រសួងបរិស្ថានបានរៀបចំរបងបៃតង សម្រាប់ការទប់ស្កាត់ការរុករុលចូលទៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស តាមរយៈការបង្កើតជាគម្រោងវិនិយោគកសិឧស្សាហកម្មនិងគម្រោងទេសចរណ៍ធម្មជាតិ។ តំបន់របងបៃតងផ្សេងទៀត ត្រូវបានរៀងចំតាមរយៈការបង្កើតជាសហគមន៍តំបន់ការពារធម្មជាតិ ដែលជាវិធីសាស្ត្រមួយក្នុងការផ្តល់ដីព្រៃឈើក្នុងតំបន់ការពារធម្មជាតិជូនប្រជាសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច ក្នុងការគ្រប់គ្រងនិងប្រើប្រាស់អនុផលព្រៃឈើប្រកបដោយចីរភាព។ ការវិនិយោគឥណទានកាបូនក្នុងតំបន់ការពារធម្មជាតិ ក៏បានចូលរួមចំណែកក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ។

**២.១០៩-** បានរៀបចំផែនទីតំបន់ការពារធម្មជាតិចំនួន២១កន្លែង ព្រមទាំងបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិចំនួន១ ២០៤បង្គោល និងបោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិចំនួន៥៨១បង្គោល។ បានបង្កើតសហគមន៍តំបន់ការពារធម្មជាតិចំនួន១១៥សហគមន៍ ក្នុងភូមិចំនួន២១១ លើទំហំផ្ទៃដីសរុបចំនួន១៥៨ ៩៩៤ហ.ត.។

**២.១១០-** *ការអភិរក្សជីវៈចម្រុះ ក្រសួងបរិស្ថាន*បានរៀបចំរបាយការណ៍ជាតិលើកទី៥ ស្តីពីជីវៈចម្រុះនិងការចុះសច្ចាប័នជាមួយមជ្ឈមណ្ឌលជីវៈចម្រុះអាស៊ាន និងសច្ចាប័នលើ*ពិធីសារណាហ្គូយ៉ា* ស្តីពីការបែងចែកផលប្រយោជន៍ការប្រើប្រាស់ធនធានសេនេទិច។

**២.១១១-** *ការលើកកម្ពស់សមត្ថភាពស្ត្រី* ក្រសួងបានរៀបចំដំណើរការស្ទង់មតិមន្ត្រីរាជការ*ក្រសួងបរិស្ថាន* ដើម្បីស្វែងយល់ពីតម្រូវការនិងការយល់ឃើញរបស់មន្ត្រីរាជការក្នុងការពង្រឹងការបញ្ជ្រាបយេនឌ័រក្នុងក្រសួង។ ក្រសួងក៏បានចូលរួមជាមួយស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងការងារប្រែប្រួលអាកាសធាតុ និងបានរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រដំណាក់កាលទី២ ឆ្នាំ២០១៣-២០១៨។

**២.១១២-** *ការគ្រប់គ្រងគុណភាពបរិស្ថាន* ក្រសួងបានអនុវត្តយ៉ាងសកម្មនូវវិធានការសំខាន់ៗសំដៅពង្រឹងការគ្រប់គ្រងសំណល់ដល់ប្រភពដើម ក៏ដូចជាទីតាំងបោះបង់ចោលចុងក្រោយសម្រាប់ត្រួតពិនិត្យ និងទប់ស្កាត់ការបំពុលបរិស្ថាន។ ក្រសួងបរិស្ថានក៏បានជំរុញនិងលើកទឹក

ចិត្តដល់សកម្មភាពកែច្នៃសំណល់សំរាមទីក្រុងនិងខិតខំសម្របសម្រួលឲ្យមានការវិនិយោគខ្នាតធំលើផ្នែកសំណល់ជាសេដ្ឋកិច្ច។ លើសពីនោះក្រសួងក៏បានខិតខំពង្រឹងការគ្រប់គ្រងសំណល់ទឹកលូខេត្ត ក្រុង ដោយបានរៀបចំឲ្យមានអាងសម្អាតទឹកលូនៅខេត្តសំខាន់ៗ ដូចជាខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តសៀមរាប និងឈានបន្តនៅបណ្តាខេត្តតំបន់ឆ្នេរនិងខេត្តជុំវិញបឹងទន្លេសាប។

២.១១៣- ទន្ទឹមនឹងនេះក្រសួងក៏បានបង្កើនការត្រួតពិនិត្យលើប្រភពបំពុលសំខាន់ ដូចជា តាមរោងចក្រ និងសហគ្រាសធំៗ ដោយជំរុញឲ្យមានការកសាងអាងសម្អាតសំណល់រាវនៅនឹងប្រភពផ្ទាល់ ការបំពាក់ឧបករណ៍សម្អាតផ្សែងពុលមុនការបញ្ចេញ និងការកាត់បន្ថយសំឡេងទៅមជ្ឈដ្ឋានខាងក្រៅ។ កត្តាសម្រេចបានការទប់ស្កាត់ការបំពុលបរិស្ថាននេះ សំខាន់គឺការចូលរួមបំពេញកាតព្វកិច្ចរបស់ម្ចាស់ប្រភពបំពុលទាំងនោះ និងការអនុវត្តច្បាប់មឺុងម៉ាត់ ដូចជា ការព្រមាន ការពិន័យជាប្រាក់ រួមនឹងការធ្វើបណ្តឹងទៅតុលាការចំពោះបទល្មើសបង្កការបំពុលបរិស្ថានជាដើម។ ទន្ទឹមនោះ គុណភាពខ្យល់សាធារណៈនៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ គឺបានបង្ហាញថា គុណភាពខ្យល់សាធារណៈនៅតាមតំបន់ទាំងនេះមានភាពល្អប្រសើរនៅឡើយ។

២.១១៤- ក្នុងនាមជាលេខាធិការដ្ឋាននៃ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ *ក្រសួងបរិស្ថាន* បានសម្រេចនូវសមិទ្ធផលជាច្រើនក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដូចជាការពង្រឹងស្ថាប័នប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពនិងបណ្តាញការងារ ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និង តាមបណ្តាវិស័យពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នចំនួន៩ ការកៀរគរធនធានសម្រាប់អនុវត្តគម្រោងអាទិភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការអប់រំនិងលើកកម្ពស់ការយល់ដឹង និងការរៀបចំជំហររបស់កម្ពុជាសម្រាប់ចូលរួមក្នុងកិច្ចចរចាអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ ថវិកាសរុបជាង២៥០លានដុល្លារអាមេរិកត្រូវបានកៀរគរពីប្រភពទ្វេភាគី និង ពហុភាគីផ្សេងៗ សម្រាប់អនុវត្តគម្រោងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតាមបណ្តាវិស័យអាទិភាព ដូចជាធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដែលគ្រប់គ្រងដោយ*ក្រសួងបរិស្ថាន* បានផ្តល់ថវិកាសម្រាប់អនុវត្តគម្រោងចំនួន២១ លើវិស័យសំខាន់ៗ។ លើសពីនេះដើម្បីរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងជាសកលលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ កម្ពុជាបានអនុម័តគម្រោងយន្តការអភិវឌ្ឍន៍ស្អាតចំនួន១០ ដែលមានសក្តានុពលកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ចំនួនប្រហែល២លានតោនក្នុងមួយឆ្នាំ គិតជាសមមូលឧស្ម័នកាបូនិក។ វេទិកាថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដើម្បីអប់រំនិងផ្សព្វផ្សាយពីចំណេះដឹងនិងគោលនយោបាយ។ ទន្ទឹមនឹងនេះ *ក្រសួងអប់រំ យុវជន និងកីឡា* បានរៀបចំបញ្ចូលបញ្ហាការប្រែប្រួលអាកាសធាតុចូលទៅក្នុង

ប្រព័ន្ធអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ។

២.១១៥- *ការងារជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើប : ក្រសួងបរិស្ថាន* បានសម្រេចការងារជាច្រើនទាក់ទងនឹងជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យារួមទាំងការរៀបចំក្របខ័ណ្ឌច្បាប់ក្នុងការកាត់បន្ថយហានិភ័យបណ្ដាលមកពីសារពាង្គកាយកែច្នៃរស់ ក៏ដូចជាការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ក្នុងការចាប់វត្ថុមានសារពាង្គកាយកែច្នៃរស់។ ក្រសួងក៏បានអនុវត្តសកម្មភាពទាក់ទងនឹងការលើកកម្ពស់ការយល់ដឹងនិងការចូលរួមរបស់សាធារណជនលើផ្នែកជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យាទំនើប។

២.១១៦- *ការអប់រំ និងផ្សព្វផ្សាយ ព័ត៌មានបរិស្ថាន : ក្រសួង* បាននិងកំពុងអនុវត្តការងារអប់រំបរិស្ថាន ដោយផ្អែកលើការងារជាសសរស្តម្ភបួន រួមមាន៖

- ការអប់រំបរិស្ថានក្នុងប្រព័ន្ធ។
- ការអប់រំបរិស្ថានក្រៅប្រព័ន្ធ។
- ការកសាងសមត្ថភាព។
- ការធ្វើកិច្ចសហប្រតិបត្តិការ និងកសាងបណ្ដាញការងារអប់រំបរិស្ថាន។

២.១១៧- សមិទ្ធផលដែលសម្រេចបានលើការងារជាសសរស្តម្ភទាំងបួនរួមមាន៖ ការកសាងសមត្ថភាពរបស់គ្រូនៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា ការរៀបចំផលិតឯកសារនិងសម្ភារៈឧបទេសស្ដីពីការថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះ និងគ្រប់គ្រងគុណភាពបរិស្ថានដោយផ្ដោតជាសំខាន់លើខេត្តជាគោលដៅនៅជុំវិញបឹងទន្លេសាប ការរៀបចំកម្មវិធី "វេទិកាយុវជនពិភាក្សាបញ្ហាបរិស្ថាន" ប្រចាំត្រីមាស ការរៀបចំ "ទិវាបរិស្ថានជាតិ និងពិភពលោក" ការរៀបចំ "ទិវាអនាម័យបរិស្ថានជាតិ" ដែលទិវាទាំង២ត្រូវបានរៀបចំឡើងនៅទូទាំងប្រទេសជារៀងរាល់ឆ្នាំ។ ក្រៅពីនេះ ក្រសួងនៅបានរៀបចំ "ការប្រឡងគំនូរបរិស្ថាន" ចំនួន៣លើក ដែលមានគោលបំណងបំផុសការយល់ដឹងពីបញ្ហាបរិស្ថាន។ លើសពីនេះទៀត ក្រសួងក៏បានធ្វើការងារជាមួយបណ្ដាប្រទេសជាសមាជិកអាស៊ានលើការងារអប់រំបរិស្ថាន ការរៀបចំគោលការណ៍ណែនាំ និងការអនុវត្ត "សាលាមេត្រីបរិស្ថាន" ការបញ្ជូនយុវជនកម្ពុជាចូលរួមការងារបរិស្ថាន ជាមួយយុវជននៃបណ្ដាប្រទេសជាសមាជិកអាស៊ាន ការចែករំលែកនិងផ្លាស់ប្ដូរព័ត៌មាននិងបទពិសោធ។

២.១១៨- ទោះជាយ៉ាងណាក្ដី *ក្រសួងបរិស្ថាន* បានជួបបញ្ហាប្រឈមមួយចំនួនទៀត ដូចជា៖

- កង្វះមធ្យោបាយសម្រាប់ប្រតិបត្តិការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ។
- លំហូរចូលនៃជនចំណាកស្រុកទៅក្នុងតំបន់ការពារធម្មជាតិ។

- មាននិន្នាការនយោបាយប្រឆាំងនឹងគោលនយោបាយអភិរក្សនិងអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់ការពារធម្មជាតិ។
- ការប្រើប្រាស់ប្រជាពលរដ្ឋក្រីក្រជាខែលសម្រាប់ធ្វើការកាប់ទន្រ្ទាន រានដីព្រៃយកធ្វើជាកម្មសិទ្ធិ។
- កំណើនប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជានាំឲ្យមានតម្រូវការដីធ្លីសម្រាប់បង្កបង្កើនផលពីដែនអភិរក្សនិងជម្រកសត្វព្រៃ។
- កង្វះខាតព័ត៌មាន និងទិន្នន័យអំពីជីវៈចម្រុះ និងធនធានធម្មជាតិ។
- កង្វះខាតថវិកាសម្រាប់អនុវត្តចុះជួយសម្របសម្រួលសហគមន៍តំបន់ការពារធម្មជាតិនៅមូលដ្ឋាន។
- កង្វះខាតថវិកាសម្រាប់ប្រតិបត្តិការងារជំនាញ មធ្យោបាយធ្វើដំណើរ និងគ្រឿងបរិក្ខារពិសោធ។
- សមត្ថភាពមន្ទីរពិសោធន៍ជីវបច្ចេកវិទ្យានៅមានកម្រិត។
- កង្វះខាតធនធានមនុស្សដែលមានសមត្ថភាពនិងកន្លែងធ្វើការងារ។
- កង្វះសម្ភារៈនិងឧបករណ៍សម្រាប់អនុវត្តកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
- កង្វះខាតទិន្នន័យនិងយន្តការគ្រប់គ្រងទិន្នន័យសម្រាប់ការវិភាគនិងការផ្តល់ព័ត៌មានគាំទ្រដល់ការឆ្លើយតបទៅនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។
- កិច្ចសហប្រតិបត្តិការអន្តរក្រសួង ស្ថាប័ន ដើម្បីសម្របសម្រួល អនុវត្ត ផ្តល់ហិរញ្ញប្បទាន ត្រួតពិនិត្យតាមដាននិងវាយតម្លៃលើសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅមានកម្រិតនៅឡើយ។
- ពុំទាន់មានផែនការសកម្មភាពនិងការសិក្សាលម្អិតនៅក្រោមគោលនយោបាយនិងយុទ្ធសាស្ត្រមួយចំនួនដែលត្រូវបានរៀបចំរួច ដើម្បីគាំទ្រសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

### ការគ្រប់គ្រងគ្រោះមហន្តរាយ

**២.១១៩-** នៅឆ្នាំ២០០៩ ខ្យល់ព្យុះកេតសាណាបានប៉ះទង្គិច*ព្រះរាជាណាចក្រកម្ពុជា* បានធ្វើឲ្យបាត់បង់អាយុជីវិតប្រជាពលរដ្ឋចំនួន៤៣នាក់ បង្កការខូចខាតដ៏ធំធេងដល់ផ្ទះសម្បែង ដំណាំស្រូវ និងហេដ្ឋារចនាសម្ព័ន្ធ ដែលផ្អែកតាមការប៉ាន់ប្រមាណការខូចខាត ជារួម សេដ្ឋកិច្ច សង្គម ប្រមាណជាង១៣២លានដុល្លារអាមេរិក។ បន្ទាប់មកទឹកជំនន់ឆ្នាំ២០១១ ដែលពុំធ្លាប់ជួបប្រទះក្នុងជាងមួយទសវត្សរ៍នេះ បានធ្វើឲ្យមនុស្សស្លាប់ចំនួន២៥០នាក់ ខូចខាតផ្ទះសម្បែង វិស័យកសិកម្ម ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ ដែលសរុបការខូចខាតជារួមប្រមាណ៤៥១លានដុល្លារអាមេរិក។

ទឹកជំនន់ដោយទឹកភ្លៀងនិងទឹកទន្លេមេគង្គក្នុងឆ្នាំ២០១៣ ថ្មីកន្លងមកនេះបានធ្វើឲ្យមនុស្សស្លាប់ចំនួន១៦៨នាក់ និងខូចខាតសន្ទូងប្រមាណជា៦២ ៨៧៨ហ.ត.។ រីឯជំងឺផ្តាសាយបក្សីបានសម្លាប់មនុស្ស១នាក់(ឆ្នាំ២០១០) ៨នាក់(ឆ្នាំ២០១១) ៣នាក់(ឆ្នាំ ២០១២) និង១៤នាក់(២០១៣)។ ហើយក្រៅពីនោះមានមុខសញ្ញាគ្រោះថ្នាក់ ដូចជាគ្រោះ ខ្វះខាតទឹកបង្កបង្កើនផលនៅតំបន់មួយចំនួន ខ្យល់កន្ត្រាក់ រន្ទះបាញ់។ល។ ដែលកើតមានជារៀងរាល់ឆ្នាំ ធ្វើឲ្យបាត់បង់អាយុជីវិតមនុស្សនិងខូចខាតផ្ទះសម្បែង ទ្រព្យសម្បត្តិប្រជាពលរដ្ឋនិងបណ្តាញហេដ្ឋារចនាសម្ព័ន្ធទៀតផង។

**២.១២០-** ដើម្បីកាត់បន្ថយគ្រោះមហន្តរាយ ដែលបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ដូចមានខាងលើ *រាជរដ្ឋាភិបាលកម្ពុជា* បានរៀបចំដាក់ចេញនូវផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយឆ្នាំ២០០៨-២០១៣ តាមរយៈការពង្រឹងយន្តការមួយដែលមានការចូលរួម និងសម្របសម្រួលដ៏មានប្រសិទ្ធភាពពីគ្រប់អ្នកមានចំណែកពាក់ព័ន្ធ ជាមួយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិល។ សមិទ្ធផលសំខាន់ៗ ដែលមានដូចជាច្បាប់ នីតិប្បញ្ញត្តិ និងផែនការ រួមមាន៖

- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ខែកុម្ភៈ ឆ្នាំ២០០៩ បានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានឆ្លងកិច្ចប្រជុំតាមលំដាប់រហូតដល់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ដោយសម្រេចឲ្យលើកយកទៅធ្វើការកែសម្រួលឡើងវិញ ឲ្យសមស្របតាមស្ថានភាពជាក់ស្តែង និងមានសុក្រឹតភាព។
- អនុក្រឹត្យលេខ១៤៥ អនក្របក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា ក្នុងគោលបំណងដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានាឲ្យទាន់ពេលវេលា។
- បង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ភូមិដែលមានឈ្មោះថា ក្រុមគ្រប់គ្រងគ្រោះមហន្តរាយភូមិ ដើម្បីពង្រឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍។
- បានកសាងផែនការជាតិត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយ ក្នុងគោលបំណងកាត់បន្ថយឥទ្ធិពលនៃគ្រោះមហន្តរាយផ្សេងៗស្ថិតក្នុងកម្រិតអប្បរមា។
- បានកសាងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិនៃការប្រែប្រួលអាកាសធាតុរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។
- ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការតំបន់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

បានអនុវត្តកិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលសម្របសម្រួលអាស៊ាន សម្រាប់ជំនួយមនុស្សធម៌ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ដោយបង់មូលនិធិ៣០ ០០០ដុល្លារអាមេរិក ប្រចាំឆ្នាំចាប់ពីឆ្នាំ២០១២។

- កសាងបានផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយថ្នាក់ខេត្ត បានចំនួន១១ខេត្ត ដែលតែងជួបប្រទះទឹកជំនន់ដោយសហការជាមួយអង្គការដៃគូ ហើយផែនការនេះត្រូវបានធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ដោយមានប្រយោជន៍ដល់ការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយ។
- បានបង្កើតទីទួលសុវត្ថិភាព ទីទួលធម្មជាតិ និងទីទួលដែលជាសំណង់បំពាក់ដោយឧបករណ៍ដូចជា បន្ទប់ទឹក បង្គន់អនាម័យ ជម្រកមនុស្ស សត្វ សរុបចំនួន៩៥៨កន្លែង នៅស្រុកចំនួន១១២នៃខេត្តចំនួន១៧ ដោយសហការជាមួយអង្គការដៃគូ។
- បានធ្វើការចែកចាយស្បៀង ពូជស្រូវ និងជី ដល់ប្រជាពលរដ្ឋក្រីក្រនៅខេត្តចំនួន៧ជុំវិញបឹងទន្លេសាប ដែលប្រជាពលរដ្ឋទទួលផលចំនួន៣៤២ ៨៥៣គ្រួសារ នៅឃុំគោលដៅចំនួន២០០។
- អនុវត្តការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងវិស័យអប់រំ ជាមួយ *ក្រសួងអប់រំ យុវជន និងកីឡា* ដោយបានរៀបរៀងជាសៀវភៅនិងបញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ទី៤និងថ្នាក់ទី៨។ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក៏ត្រូវបានបញ្ជ្រាបនៅក្នុងផែនការនៃកម្មវិធីរបស់*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* និង*ក្រសួងធនធានទឹក និងឧតុនិយម* ជាមួយនេះការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានដាក់បញ្ចូលនៅក្នុងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពផងដែរ។
- វេទិកាជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ បានបង្កើតឡើងក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ តាមរយៈការចែកចាយព័ត៌មាន ពង្រឹងការសម្របសម្រួល រៀបចំការអនុវត្តសកម្មភាពរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**២.១២១-** ការមិនសម្រេចបានតាមចំណុចដៅនិងផែនការសកម្មភាព និងបញ្ហាប្រឈមនានាក្នុងកិច្ចការគ្រោះមហន្តរាយ៖

- ការកែទម្រង់ប្រព័ន្ធយន្តការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅគ្រប់កម្រិតមិនទាន់ធ្វើបាននៅឡើយ។
- ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយនៅតាមក្រសួង ស្ថាប័ន និងការកែសម្រួលរចនាសម្ព័ន្ធការងារនៅតាមក្រសួង ស្ថាប័ន ស្ថិតក្នុងស្ថានភាពដដែលមិនទាន់មានការរៀបចំនៅឡើយ។
- មិនទាន់សម្រេចបានច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ ក្របខ័ណ្ឌការងារ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីប្រតិបត្តិការស្តង់ដា គោលការណ៍ណែនាំ និងគោលនយោបាយ សម្រាប់ការ

គ្រប់គ្រងគ្រោះមហន្តរាយ។

- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ខ្វះខាតធនធាននិងសមត្ថភាពសម្រាប់ការអនុវត្តឲ្យស្របតាមតួនាទីរបស់ខ្លួននិងសេចក្តីត្រូវការរបស់សហគមន៍។
- មិនទាន់មាននីតិវិធីនិងបទដ្ឋានដែលទាក់ទងនឹងការអនុវត្តការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍នៅឡើយ ហើយគោលការណ៍ណែនាំ ការដាក់បញ្ចូលការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ចូលទៅក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់មិនទាន់បានប្រកាសផ្សាយ។
- រចនាសម្ព័ន្ធដំណើរការមិនទាន់បានប្រសើរនៅឡើយ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មួយចំនួន រីឯធនធានមនុស្សនៅមានកម្រិត។

### ការអភិវឌ្ឍជនបទ

២.១២២- អភិវឌ្ឍន៍ជនបទ គឺជាការងារអន្តរវិស័យដ៏ធំមួយដែលគ្របដណ្តប់លើវិស័យហេដ្ឋារចនាសម្ព័ន្ធជនបទ សុខាភិបាល អប់រំ កសិកម្ម ការផ្គត់ផ្គង់ទឹកនិងអនាម័យ និងវិស័យដទៃទៀតនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច នៅតំបន់ជនបទ។ ការងារអន្តរវិស័យនេះ មានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយហេតុថា អត្រាភាពក្រីក្រមានកម្រិតខ្ពស់នៅក្នុងចំណោមប្រជាជនដែលកំពុងរស់នៅតំបន់ជនបទ។ *រាជរដ្ឋាភិបាលកម្ពុជា* បានសម្រេចយកវិធីសាស្ត្រពហុមុខ ដើម្បីជំរុញការអភិវឌ្ឍជនបទនិងការបង្កើនលទ្ធភាពនិងសមត្ថភាពដល់សហគមន៍មូលដ្ឋាន ជាពិសេស គណៈកម្មាធិការអភិវឌ្ឍន៍ភូមិក្នុងការរៀបចំផែនការនិងការគ្រប់គ្រងលើការអភិវឌ្ឍមូលដ្ឋានផ្ទាល់របស់ខ្លួន។ ការធ្វើវិមជ្ឈការនិងវិសហមជ្ឈការលើការផ្តល់សេវាសាធារណៈ ការគាំទ្រដល់កម្មវិធីទាំងឡាយ ដែលមានការចូលរួមជាលក្ខណៈវិមជ្ឈការ និងដែលផ្តោតទៅតាមវិស័យ និងការផ្តល់ឥណទានដល់គ្រួសារ និងអាជីវកម្មធុនតូចៗ គឺជាឧទាហរណ៍មួយចំនួន ដែលបង្ហាញឲ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅក្នុងវិស័យនេះ។

២.១២៣- ចាប់តាំងពីឆ្នាំ២០០៧មក ការអភិវឌ្ឍជនបទត្រូវបានជ្រើសរើសជាវិស័យអាទិភាពនៅក្នុងចំណោមវិស័យអាទិភាពផ្សេងទៀតរបស់*រាជរដ្ឋាភិបាលកម្ពុជា* នៅក្នុងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈសម្រាប់ការវិភាជនិងការបញ្ចេញថវិកាឲ្យទាន់ពេលវេលា។ *រាជរដ្ឋាភិបាលកម្ពុជា* បាននឹងកំពុងអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជំហានទី២។

២.១២៤- ការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យអភិវឌ្ឍន៍ជនបទត្រូវបាននិងកំពុងអនុវត្ត តាមរយៈការរៀបចំឲ្យមានក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត ក្រោមកម្មវិធីគោលនយោបាយមួយចំនួនរួមមាន : (១)គោល

នយោបាយទី១ ធានាលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមទីជនបទឲ្យមានភាពប្រសើរឡើង ក៏ដូចជាការកាត់បន្ថយនូវគម្លាតរវាងជនបទ និងទីប្រជុំជនឲ្យខិតជិតកម្រិតប្រហាក់ប្រហែលគ្នាក្នុងដំណាច់ឆ្នាំ២០២៥។ (២)គោលនយោបាយទី២ ជំរុញកំណើនសេដ្ឋកិច្ចជនបទ តាមរយៈការអភិវឌ្ឍជនបទចម្រុះដោយមានការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ។

**២.១២៥-** សមិទ្ធផលធំៗក្នុងសកម្មភាពអភិវឌ្ឍន៍ជនបទ ពីឆ្នាំ២០០៩-២០១៣ រួមមាន៖

- *បណ្តុះបណ្តាលស្តីពីការធ្វើផែនការនិងជំនាញផ្សេងៗ៖*
  - *ក្រសួងអភិវឌ្ឍន៍ជនបទ* បានបណ្តុះបណ្តាលកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដល់មន្ត្រីចំនួន១ ៥៧៥នាក់(មន្ត្រីថ្នាក់ជាតិ៤៩៥នាក់ និងថ្នាក់ក្រោមជាតិ១ ០៨០ នាក់)។ មន្ត្រី៤៥០នាក់ បានទទួលការបណ្តុះបណ្តាលជំនាញកុំព្យូទ័រផងដែរ។
  - បានអនុវត្តបណ្តុះបណ្តាលវាយតម្លៃតម្រូវការបណ្តុះបណ្តាលថ្នាក់ក្រោមជាតិ។
  - បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានមួយចំនួន មានជំនាញកាត់សក់ អ៊ុតសក់ កែសម្រស់ សិប្បកម្មជួសជុលម៉ាស៊ីនភ្លើង ម៉ាស៊ីនត្រាក់ទ័រ ជួសជុលម៉ូតូនិងរថយន្ត ជួសជុលគ្រឿងអេឡិចត្រូនិក និងបណ្តុះបណ្តាលភាសាអង់គ្លេស កំពុងត្រូវបានអនុវត្តក្នុងខេត្តចំនួន៥។ លទ្ធផលនៃការអនុវត្តផែនការ៥ឆ្នាំ២០០៩ដល់២០១២ មានដូចខាងក្រោម៖
    - បណ្តុះបណ្តាលមន្ត្រីរាជការរបស់ក្រសួង២ ៦៦៦នាក់(ស្ត្រីចំនួន៦១៣នាក់)
    - បណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាពលរដ្ឋ១ ៤៦០នាក់(ស្ត្រីចំនួន៥១២នាក់)។
- *ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ៖*
  - កំពុងរៀបចំបញ្ជីសារពើភណ្ឌផ្លូវជនបទទូទាំងប្រទេស។
  - សាងសង់ផ្លូវក្រាលក្រួសក្រហមបានចំនួន២ ៥៨៧,៨៩គ.ម.។
  - ជួសជុលនិងថែទាំផ្លូវជនបទក្រាលក្រួសក្រហមបានប្រវែង៣ ៩៥៤,៩៥គ.ម.។
  - ផ្លូវជនបទក្រាលកៅស៊ូប្រភេទ(DBST)បានប្រវែង១៩,៩០គ.ម. ផ្លូវក្រាលបេតុងបានប្រវែង២៣,១គ.ម. សាងសង់ស្ពានបេឡេត៍បានប្រវែង១៤១ម. ស្ពានបេតុងបានប្រវែង៧ ៥៩៤ម. និងលូគ្រប់ប្រភេទបានចំនួន២ ៧៦៦កន្លែង។
- *ការអភិវឌ្ឍវិស័យទឹកនៅជនបទ៖*
  - សិក្សារៀបចំផែនទីទឹកក្រោមដី បានចំនួន៨ខេត្ត គឺ ខេត្តស្វាយរៀង ព្រៃវែង កណ្តាល តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម និងជាយរាជធានីភ្នំពេញ។
  - រៀបចំគោលការណ៍ណែនាំបន្សុទ្ធទឹក និងស្តុកទឹកតាមគ្រួសារឲ្យមានសុវត្ថិភាព។

- ➢ សាងសង់អណ្តូងស្នប់បាន១០ ៦៧៨អណ្តូង និងអណ្តូងចម្រុះ១ ៤០៨អណ្តូង។
- ➢ ជួសជុលអណ្តូងគ្រប់ប្រភេទ៦០៣៩អណ្តូង។
- ➢ ស្តារស្រះសហគមន៍បាន២២ស្រះ និងសាងសង់ស្រះសហគមន៍បាន១៩២ស្រះ។
- ➢ សាងសង់អាងត្រងទឹកភ្លៀងបាន៣ ៥៨០អាង។
- ➢ សាងសង់ប្រព័ន្ធចែកចាយទឹកតាមទុយោបាន៦ប្រព័ន្ធ។

- *ការអភិវឌ្ឍវិស័យអនាម័យជនបទ៖*

- ➢ ចុះអប់រំអនាម័យ បណ្តុះបណ្តាល និងចុះយុទ្ធនាការផ្សព្វផ្សាយអនាម័យតាមភូមិ។
- ➢ សាងសង់បង្គន់អនាម័យជាលក្ខណៈគ្រួសារបាន៦៨ ៥០៨ និងសាធារណៈ៤២០។
- ➢ អនុវត្តទីផ្សារអនាម័យនៅតាមបណ្តាខេត្តចំនួន១០ខេត្ត ស្តីពីទីផ្សារអនាម័យសំដៅដល់ការចូលរួមពីវិស័យឯកជន ក្នុងការសាងសង់បង្គន់អនាម័យតាមផ្ទះ មានតម្លៃថោកសមរម្យ និងមានគុណភាព ដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួន។

- *ការអភិវឌ្ឍសហគមន៍ជនបទ៖*

- ➢ បោះឆ្នោតឡើងវិញដល់*គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ* ដែលផុតអាណត្តិបានចំនួន ២៤៦ភូមិ។
- ➢ បណ្តុះបណ្តាលគ្រូបង្គោលបានចំនួន៣០វគ្គ មានសិក្ខាកាមចំនួន៤១០នាក់ នៅថ្នាក់ក្រោមជាតិ។
- ➢ បណ្តុះបណ្តាលចំនួន៤២៣វគ្គសម្រាប់*គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ* ស្តីពីតួនាទីភារកិច្ច និងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិទាំង២៤រាជធានី ខេត្ត ដោយមានសិក្ខាកាមចូលរួមចំនួន១៣ ៣៩៨នាក់។
- ➢ ផ្តល់ស្រូវពូជជូនសហគមន៍បាន៦២៥គ.ក្រ.។
- ➢ ស្តារប្រឡាយតូចៗបាន២ខ្សែប្រវែង២ ៤០០ម៉ែត្រ និងសាងសង់ទ្វារទឹកចំនួន៤កន្លែង។
- ➢ ផ្តល់ជ្រូកចំនួន១០៤ក្បាល មេគោចំនួន៣១ក្បាល និងមាន់ចិញ្ចឹមតាមគ្រួសារចំនួន ៧០៥ក្បាល។
- ➢ ជីកស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារចំនួន៩៤ និងផ្តល់កូនត្រីចំនួន១៧ ៨០០ក្បាល។
- ➢ ផ្តល់ពូជពោតក្រហមចំនួន២០០កាំរ៉ុង កូនក្រូចឆ្លុងផ្អែមចំនួន៦៥៧ដើម និងផ្តល់ដើមឈើហូបផ្លែចំនួន៥ ៦៩៨ដើម។
- ➢ ផ្តល់សម្ភារៈសម្រាប់ធ្វើរោងជីកំប៉ុស្តចំនួន២៤០កន្លែង សម្រាប់២៤០គ្រួសារ។

- ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ៖

- ➢ អត្ថប្រយោជន៍នៃឡជីវឧស្ម័ន និងចង្ក្រាននាងកង្រី អ្នកចូលរួមចំនួន៣៦៧នាក់ និងផ្ទេរបច្ចេកទេសផលិតឡជីវឧស្ម័ន(៣៥គ្រួសារ) និងចង្ក្រាននាងកង្រី(៦០គ្រួសារ)។
- ➢ គំនិតផ្តួចផ្តើមបង្កើតមុខរបរនិងគ្រប់គ្រងអាជីវកម្មបាន៤៦៤នាក់។
- ➢ ព័ត៌មានទីផ្សារផលិតផលកសិកម្មនិងរបៀបគ្រប់គ្រងឥណទានបាន១៧១នាក់។
- ➢ ផ្ទេរបច្ចេកទេសត្បាញក្រមា បាន៤៥គ្រួសារនិងត្បាញហូលបាន៧៥គ្រួសារ។
- ➢ សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល សហគ្រាសមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់ឥណទានជនបទ។

- *ការអភិវឌ្ឍជនជាតិដើមភាគតិច៖*

- ➢ កំណត់អត្តសញ្ញាណវប្បធម៌ប្រពៃណីជនជាតិដើមភាគតិច នៅខេត្តរតនគិរី មណ្ឌលគិរី កំពង់ស្ពឺ ក្រចេះ និងព្រះវិហារ និងបានចេញលិខិតទទួលស្គាល់អត្តសញ្ញាណ បានចំនួន៦៩សហគមន៍។
- ➢ ផ្សព្វផ្សាយគោលនយោបាយជាតិសម្រាប់អភិវឌ្ឍន៍ជាតិជនដើមភាគតិចបានចំនួន៧លើក ដែលក្នុងនោះ ថ្នាក់ជាតិ២លើក និងថ្នាក់ខេត្តបាន៥លើក។

**តារាងទី២.៦ : វឌ្ឍនភាពនៃការអភិវឌ្ឍជនបទ**

| សូចនាករ | ផែនការ/ សម្រេចបាន | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ប្រវែងផ្លូវជនបទដែលបានស្តារធៀបនឹងប្រវែងផ្លូវជនបទសរុបប្រវែង៤០ ០០០គ.ម.) | ផែនការ (គ.ម.) | ២៥ ៦៥៨ | ២៦ ៦៥៨ | ២៧ ៦៥៨ | ២៨ ៦៥៨ |
| | សម្រេចបាន (%) | ២៥ ២៣៧ | ២៥ ៦៨៦ | ២៦ ២៩៤ | ២៦ |
| %នៃប្រជាពលរដ្ឋជនបទ ទទួលបានការផ្គត់ផ្គង់ទឹកជនបទដែលមានការកែលម្អ | ផែនការ | ៤១,៩៩ | ៤៣,៤៩ | ៤៤,៩៩ | ៤៦,៤៩ |
| | សម្រេចបាន | ៤២,២០ | ៤១,១០ | ៤៣,២០ | ៤១,៩០ |
| %ប្រជាជនជនបទទទួលបានការផ្គត់ផ្គង់អនាម័យដែលមានការកែលម្អ | ផែនការ | ២៤,២៤ | ២៥,០០ | ២៧,០០ | ២៩,០០ |
| | អនុវត្តបាន | ២៣,០០ | ២៩,២០ | ៣៣,២០ | ៣៣,៣០ |

*ប្រភព : ក្រសួងអភិវឌ្ឍន៍ជនបទ*

## ៤- ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

**២.១២៦-** ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមានការស្តារនិងកសាង គឺជាគន្លឹះដ៏សំខាន់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងពង្រឹងភាពប្រកួតប្រជែងនិងជំរុញពិពិធកម្មសេដ្ឋកិច្ច។ ក្នុងន័យនេះ *រាជរដ្ឋាភិបាលនីតិកាលទី៤* បានរៀបចំនូវផែនការមេនៃការបន្តការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានចែងក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២៖* (១)ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (២)ការគ្រប់គ្រងធនធាន

ទឹក និងប្រព័ន្ធធារាសាស្ត្រ (៣)ការអភិវឌ្ឍវិស័យថាមពល និង (៤)ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។

## ៤.១- ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

**២.១២៧-** *រាជរដ្ឋាភិបាលកម្ពុជា*សម្រេចបានលទ្ធផលធំៗគួរឲ្យកត់សម្គាល់ ក្នុងការស្តារនិងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា បណ្តាញផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ និងអាកាសយានដ្ឋានសំខាន់ៗ សម្រាប់បណ្តាញដឹកជញ្ជូនយុទ្ធសាស្ត្រមួយតភ្ជាប់គ្នារវាងតំបន់នានានៅទូទាំងប្រទេស ក៏ដូចជា ជាមួយបណ្តាប្រទេសជិតខាង។ ដំណាច់ឆ្នាំ២០១២ *ក្រសួងសាធារណការនិងដឹកជញ្ជូន* និង*ក្រសួងអភិវឌ្ឍន៍ជនបទ*បានធ្វើការវាស់វែងផ្លូវថ្នល់នៅប្រទេសកម្ពុជា ដែលមានផ្លូវថ្នល់សរុបប្រវែង៤៧ ២៦៣គ.ម. ក្នុងនោះ៖

- ផ្លូវជាតិមួយខ្ទង់ប្រវែង២ ២៦២គ.ម.។
- ផ្លូវជាតិពីរខ្ទង់ប្រវែង៣ ៣៦០គ.ម.។
- ផ្លូវខេត្តបីខ្ទង់និងបួនខ្ទង់ប្រវែង៦ ៥៤១គ.ម.។
- ផ្លូវជនបទប្រវែង៣៥ ០០០គ.ម.។

**២.១២៨-** ក្នុងដំណាក់កាលនៃការអនុវត្តផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ *ក្រសួងសាធារណការ និងដឹកជញ្ជូន* សម្រេចបានលទ្ធផលការងារសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

- បានបញ្ចប់គម្រោងស្តារនិងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ប្រវែង១ ៩៧២,៧គ.ម. និងកំពុងដំណើរការគម្រោងចំនួន៣៥ បានប្រវែង២ ៣៦៥,២៧គ.ម. ដែលធ្វើឲ្យការចាក់កៅស៊ូផ្លូវជាតិ និងផ្លូវខេត្តបានកើនឡើងដល់ប្រវែង៥ ៥៩៦,២៨គ.ម. ត្រូវជា៤៥,៧២% នៃប្រវែងផ្លូវថ្នល់សរុប១២ ២៣៩,៩គ.ម.។
- ការងារជួសជុលនិងថែទាំប្រចាំក្រាលកៅស៊ូគ្រប់ប្រភេទបានប្រវែង១៣ ៦៦៦គ.ម. និងផ្លូវក្រាលក្រួសក្រហមបានប្រវែង៥ ១៤៨គ.ម.។ ការជួសជុលនិងថែទាំខួបក្រាលកៅស៊ូគ្រប់ប្រភេទបានប្រវែង១ ២៤៩គ.ម. និងផ្លូវក្រាលក្រួសក្រហម បានប្រវែង២ ១១៦គ.ម.។
- ការអនុវត្តការងារអាជីវកម្មរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ និងភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) មានលទ្ធផលកាន់តែប្រសើរឡើងបើប្រៀបធៀបទៅនឹង៥ឆ្នាំមុន។
- បានរៀបចំច្បាប់ផ្លូវថ្នល់និងច្បាប់ថ្មីស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក។

- គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកបានរៀបចំផែនការសកម្មភាពជាតិទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០២០ និងផែនការសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០១៤។
- គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ក្រោមការដឹកនាំរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់ បានដាក់វិធានការជាច្រើនសម្រាប់ទប់ស្កាត់បទល្មើសយានយន្តដឹកជញ្ជូនលើសទម្ងន់។

**២.១២៩-** *ការពង្រឹងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការងារសុវត្ថិភាពចរាចរណ៍ : គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក* រៀបចំសេចក្តីព្រាងច្បាប់ថ្មី ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក ដូចជា *ផែនការសកម្មភាពជាតិទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០២០* និង *ផែនការសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០១៤* ដោយផ្តោតលើការពាក់មួកសុវត្ថិភាព ពាក់ខ្សែក្រវ៉ាត់បើកបររថយន្ត និងការបើកបរពេលស្រវឹង។

**២.១៣០-** *ការពង្រឹងសុវត្ថិភាពចរាចរណ៍ផ្លូវគោក គ្រោះថ្នាក់ចរាចរណ៍* : រយៈពេល៥ឆ្នាំកន្លងមកនេះ គ្រោះថ្នាក់ចរាចរណ៍មាន៣១ ៩៩២ករណី( ស្លាប់៩ ២៨០នាក់ របួសធ្ងន់២៤ ៤១៧នាក់ និងរបួសស្រាល២៨ ៦០២នាក់) កើនឡើងធៀបនឹងរយៈពេល៥ឆ្នាំមុន។ ចំណែកចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍សម្រាប់៥ឆ្នាំ២០០៩-២០១៣ បានកើនឡើងប្រមាណ៤៤,៥៣% ធៀបនឹងរយៈពេល៥ឆ្នាំមុន ២០០៤-២០០៨ ( ស្លាប់៦ ៤២១នាក់ )។

**២.១៣១-** គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ក្រោមការដឹកនាំរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់ បានដំណើរកិច្ចការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ព្រមទាំងរៀបចំកម្មវិធីអប់រំបណ្តុះបណ្តាល និងបានផ្សព្វផ្សាយអំពីច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការដឹកជញ្ជូនលើសទម្ងន់បានចំនួន៦លើក។

**២.១៣២-** *ការងារសម្បទានផ្លូវដែក :* កិច្ចព្រមព្រៀងសម្បទានរាជាយស្វ័យយានកម្ពុជា សម្រាប់ដំណើរការធ្វើអាជីវកម្មរយៈពេល៣០ឆ្នាំ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន ត្រូវបានចុះហត្ថលេខា នាខែមិថុនា ឆ្នាំ២០០៩។ កិច្ចព្រមព្រៀងនេះ រួមមាន ការទិញក្បាលម៉ាស៊ីនរថភ្លើង ទូរថភ្លើង គ្រឿងចក្រ និងបរិក្ខារថ្មី និងចំណាយសម្រាប់ការថែទាំដើម្បីធានាគុណភាពផ្លូវដែក។ ចំពោះអគារការិយាល័យថ្មីរបស់នាយកដ្ឋានផ្លូវដែក បានចាប់ផ្តើមសាងសង់កាលពីខែធ្នូ ឆ្នាំ២០១២ កន្លងទៅ។

**២.១៣៣-** *ការស្តារឡើងវិញផ្លូវដែកកម្ពុជា* : មានទឹកប្រាក់សរុបចំនួន១៤១,៦លានដុល្លារអាមេរិក ដែលជាហិរញ្ញប្បទានរួមគ្នា រវាងកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី៨៤លានដុល្លារអាមេរិក ជំនួយឥតសំណងរដ្ឋាភិបាលអូស្ត្រាលី២១,៥លានដុល្លារអាមេរិក អង្គការ OFID ១៣លានដុល្លារអាមេរិក រដ្ឋាភិបាលម៉ាឡេស៊ី២,៨លានដុល្លារអាមេរិក (ដោយផ្តល់ជាដែករ៉ែ) និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា២០,៣លានដុល្លារអាមេរិក។

**២.១៣៤-** *ការងារដឹកជញ្ជូនផ្លូវគោក*

- បានចុះបញ្ជីយានយន្តចំនួន១ ៣៦១ ៥៧៥គ្រឿង(ម៉ូតូ១ ១៩៧ ២៩៦គ្រឿង និងរថយន្តគ្រប់ប្រភេទ១៦៤ ២៧៩គ្រឿង មានការកើនឡើង បើធៀបនឹងរយៈពេល៥ឆ្នាំមុន ២០០៤-២០០៨)។ បើគិតពីឆ្នាំ១៩៩០ដល់ឆ្នាំ២០១២ យានយន្តបានចុះបញ្ជីសរុបមានចំនួន ២ ១៧៥ ៤១៨គ្រឿង។
- បានចេញបណ្ណបើកបរចំនួន៤២៨ ៥៧៩បណ្ណ(ម៉ូតូ១៣៦ ០៩៦បណ្ណ និងរថយន្ត ២៩២ ៤៨៣បណ្ណ មានការកើនឡើងបើធៀបនឹងរយៈពេល៥ឆ្នាំមុន ២០០៤-២០០៨)។
- បានកាត់ទ្រុងកែតម្រូវត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសវិញនូវរថយន្តដឹកទំនិញកែច្នៃដំឡើងខុសបទដ្ឋានបច្ចេកទេស សរុបបានចំនួន៤២៦គ្រឿង។

**២.១៣៥-** *ការងារផ្លូវទឹក ការដឹកជញ្ជូនផ្លូវទឹក និងនាវាសមុទ្រ*

- *ការងារផ្លូវទឹក* : ប្រវែងផ្លូវទឹកសរុបនៅកម្ពុជាមានប្រមាណ១ ៧៥០គ.ម. ប៉ុន្តែមានតែ៨៥០ គ.ម. អាចធ្វើនាវាចរណ៍បានតែរដូវប្រាំងប៉ុណ្ណោះ។ ការងារស្តារផ្លូវទឹកត្រូវបានអនុវត្តដោយការចុះពិនិត្យបង្គោលរយៈកម្ពស់ដី នៅទន្លេមេគង្គ (មេគង្គលើ ភ្នំពេញ-ក្រចេះ ប្រវែង២២១ គ.ម. និងមេគង្គក្រោម ភ្នំពេញ-ក្អមសំណ ប្រវែង៩៧គ.ម.) នៅទន្លេសាប (ភ្នំពេញ-ផ្លុកទ្រូ ប្រវែង១៤៦គ.ម) និងទន្លេបាសាក់ (ភ្នំពេញ-ជ្រៃធំ ប្រវែង១០០គ.ម.)។
- *ដឹកជញ្ជូនផ្លូវទឹក* : ផ្ទេរកម្មសិទ្ធិជលយានចំនួន១២៤គ្រឿង ផ្តល់បណ្ណសម្គាល់ជលយានចំនួន៩៧គ្រឿង ប្តូរបណ្ណសម្គាល់ជលយានចំនួន២៣គ្រឿង ផ្តល់បណ្ណបើកបរជលយានចំនួន២០០បណ្ណ ផ្តល់បណ្ណយន្តការីចំនួន១៧បណ្ណ ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានចំនួន៨៧០គ្រឿង និងផ្តល់ច្បាប់អាជីវកម្មដឹកជញ្ជូនចំនួន៩០៥គ្រឿង។
- *ការដឹកជញ្ជូនតាមនាវាសមុទ្រ* : ផ្តល់បណ្ណសម្គាល់នាវា-ផ្ទេរកម្មសិទ្ធិចំនួន៣៦គ្រឿង ត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា(ថ្មី និងពន្យារសុពលភាព) ចំនួន១៤៧គ្រឿង បានផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មចំនួន៦៧ច្បាប់ ផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញចំនួន ១៩៥ច្បាប់ និងផ្តល់សៀវភៅវិជ្ជាជីវៈនាវិក និងពន្យារពេលចំនួន៥៩៦ច្បាប់។

**២.១៣៦-** *ការងារអាជីវកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុ :* បរិមាណទំនិញឆ្លងកាត់មានការកើនឡើងជាលំដាប់ ដោយកើនពី៨ ១១៧ ៦៥៤តោន ទៅ១២ ១៤១ ៤១៤តោន ឬប្រមាណជា៤៩,៥៧% ក្នុងរយៈពេល៥ឆ្នាំ។ បរិមាណកុងតឺន័រ បានកើនឡើង៣,៧៧% ពី១ ១៤៥ ៨៦៨ TEUs មក១ ១៨៩ ១០៨ TEUs។

**២.១៣៧-** *ការងារអាជីវកម្មកំពង់ផែស្វយ័តក្រុងភ្នំពេញ :* បរិមាណសាំង និងឧស្ម័ននាំចូលមានចំនួន៧ ២១៥ ៨៣១តោន ដោយបានកើនឡើង៥៤,៧៥% ធៀបនឹងការនាំចូលសាំងនិងឧស្ម័នរយៈពេល៥ឆ្នាំមុន ដែលមានចំនួន៤ ៦៦២ ៩៦៣តោន។ បរិមាណនាវាសរុបចូលចតនៅកំពង់ផែស្វយ័តក្រុងភ្នំពេញ មានចំនួន៧ ៩៧៩គ្រឿង កើនឡើងបាន២២,៩៤% លើសពី៥ឆ្នាំមុន ដែលមានចំនួន៦ ៤៩០គ្រឿង។ បរិមាណនាវាដឹកអ្នកដំណើរមាន១១ ៤៩៥គ្រឿង កើនឡើង៥៤,១៥% ពី៧ ៤៥៧គ្រឿង។ បរិមាណកុងតឺន័របានកើនឡើង១៥៧,៩៧% ពី១៧១ ៥៤៧ TEUs មក៤៤២ ៥៣២TEUs។ ចំណូលអាជីវកម្មក្នុងឆ្នាំ២០១២ សរុបមានចំនួន៤ ១៤១ ៣៣២ លានដុល្លារអាមេរិក។

**២.១៣៨-** *សេវាភ្នាក់ងារនាវា-ភស្តុភារកម្ម :* បានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍកំពង់ផែអន្តរជាតិ ខេត្តព្រះសីហនុនិងរាជធានីភ្នំពេញ និងបានបម្រើសេវានាវានៅកំពង់ផែឯកជន (ឧកញ៉ាម៉ុង ស្រែអំបិល កោះកុង និងកំពត)។ ការងារភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) សម្រេចបានការងារមួយចំនួន ដូចជា បរិមាណនាវាដែលបានធ្វើសេវាសរុបមាន១៧ ០១៦ គ្រឿង(ស្មើនឹង៤២ ១៩៧.២៤២GRT)។ បរិមាណទំនិញនាំចូលមាន១៧ ៧០៣ ២៥៣តោន និងនាំចេញ៥ ៨០៨ ១៥៦តោន។ ការងារបញ្ជូនទំនិញអនុវត្តបាននាំចូលមាន៩៣៨កុងតឺន័រ និងនាំចេញមាន៥កុងតឺន័រ។ បរិមាណនាវាកត់ត្រា ភ្នំពេញមាន៣ ២២៣គ្រឿង និងខេត្តព្រះសីហនុមាន២ ៧០៨គ្រឿង។ ប៉ាន់ស្មានចំណូលសរុបមាន១៧ ៦០៥ ៦៤៨ដុល្លារអាមេរិក កើនឡើងធៀបនឹង៥ឆ្នាំមុន។

**២.១៣៩-** *កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនមហាអនុតំបន់ទន្លេមេគង្គ :* កិច្ចព្រមព្រៀងនេះ ដោយរាប់បញ្ចូលទាំងឧបសម្ព័ន្ធនិងពិធីសារទាំង២០នៃកិច្ចព្រមព្រៀងនេះផង បានចូលជាធរមាននាពេលបច្ចុប្បន្ននេះ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័ននិងតម្កល់ទុកលិខិតូបករណ៍នៃការផ្តល់សច្ចាប័នលើពិធីសារចំនួន៣ និងឧបសម្ព័ន្ធចំនួន១៧។ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាទ្វេភាគីលើអនុស្សរណៈយោគយល់គ្នាជាមួយប្រទេសថៃនិងវៀតណាម ស្តីពី*ការផ្តួចផ្តើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនមហាអនុតំបន់ទន្លេមេគង្គ*។

**២.១៤០-** កិច្ចសហប្រតិបត្តិការជាមួយឡាវ : ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា ឡាវ (ត្រពាំងក្រៀល-ណងណុលឃៀន)ត្រូវបានបើកកាលពីឆ្នាំ២០០៩។ ក្នុងកូតា រថយន្តដឹកទំនិញចំនួន៤០គ្រឿងអាចដឹកជញ្ជូនឆ្លងកាត់ច្រកនេះបាន។ ប៉ុន្តែរថយន្តដឹកជញ្ជូនទំនិញនិងយានយន្តប្រភេទផ្សេងៗទៀតនៅមិនទាន់មានការអនុញ្ញាតនៅឡើយ។ កម្ពុជា ឡាវក៏បានឯកភាពគ្នាក្នុងការតភ្ជាប់ផ្លូវ ស្ពាននិងជំរុញការដឹកជញ្ជូនឆ្លងកាត់ព្រំដែននៅកំពង់ស្រឡៅរវាងស្រុកឆែប(កម្ពុជា) និងស្រុកម៉ុងឡាប៉ាខេ(ឡាវ)ឆ្ពោះទៅខេត្តកំពង់ធំនិងសៀមរាប។

**២.១៤១-** *កិច្ចសហប្រតិបត្តិការជាមួយវៀតណាម :* ប្រទេសទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចព្រមព្រៀងទ្វេភាគីដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយឯកភាពគ្នាដំឡើងកូតានៃចំនួនយានយន្តពី៤០គ្រឿងរហូតដល់១៥០គ្រឿង កាលពីឆ្នាំ២០០៩ ពី១៥០គ្រឿងទៅ៣០០គ្រឿង កាលពីឆ្នាំ២០១០។ កិច្ចព្រមព្រៀងទ្វេភាគីដឹកជញ្ជូនឆ្លងកាត់ច្រកទ្វារអន្តរជាតិចំនួន៥ រួមមាន បាវិត-ម៉ុកបាយ ព្រែកចាក-ហាទៀង ភ្នំដិន-ទិញបៀន ត្រពាំងផ្លុង-ស្មាច់ និងត្រពាំងស្រែ-វ៉ាលី។ ក្រសួងបានស្នើសុំ*គណៈរដ្ឋមន្ត្រី*ដើម្បីដាក់បញ្ចូលច្រកទ្វារព្រំដែនដាក់ដាំ-ប៊ូប្រាំង ជាច្រកទ្វារព្រំដែនអន្តរជាតិ។

**២.១៤២-** *កិច្ចសហប្រតិបត្តិការជាមួយថៃ :* កម្ពុជា ថៃ បានចុះហត្ថលេខាលើវិសោធនកម្មនៃអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការប្តូរសិទ្ធិគ្នាធ្វើចរាចរណ៍ ដឹកជញ្ជូនឆ្លងកាត់ព្រំដែននៅចំណុចច្រកទ្វារព្រំដែន ប៉ោយប៉ែត-អារញ្ញប្រាថេត កាលពីឆ្នាំ២០០៩។ រហូតដល់ខែកញ្ញា ឆ្នាំ២០១១កន្លងទៅ អាជ្ញាធរថៃបានជួបប្រជុំការងារជាមួយក្រសួង ស្នើជំរុញការអនុវត្តការផ្លាស់ប្តូរសិទ្ធិធ្វើចរាចរណ៍នៅចំណុចច្រកទ្វារ ព្រំដែនប៉ោយប៉ែត-អារញ្ញប្រាថេត និងស្នើសុំពិចារណាបើកខ្សែផ្លូវដឹកជញ្ជូនអ្នកដំណើរ៦ខ្សែ(បាងកក-សៀមរាប បាងកក-ភ្នំពេញ ត្រាត-កោះកុង ស្រះកែវ-ភ្នំពេញ ស្រះកែវ-សៀមរាប និងសុរិន្ទ-សៀមរាប)។ ប្រទេសកម្ពុជា ថៃ ក៏បានធ្វើពិធីបើកជាផ្លូវការឲ្យធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន លើកូតាយានយន្តចំនួន៤០គ្រឿង កាលពីខែមិថុនា ឆ្នាំ២០១២កន្លងទៅ។

**២.១៤៣-** *កិច្ចសហប្រតិបត្តិការរវាងកម្ពុជា ឡាវ និងវៀតណាម :* កិច្ចប្រជុំពិគ្រោះយោបល់ក្រៅផ្លូវការរវាងកម្ពុជា-ឡាវ-វៀតណាម បានប្រព្រឹត្តទៅកាលពីឆ្នាំ២០០៩ និងមានកិច្ចប្រជុំជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១២ ដើម្បីពិនិត្យមើលលើសេចក្តីព្រាងស្តីពីការផ្លាស់ប្តូរសិទ្ធិធ្វើចរាចរណ៍ដឹកជញ្ជូនឆ្លងកាត់ព្រំដែននេះ។ ភាគីទាំងបីកម្ពុជា-ឡាវ-វៀតណាម បានចុះហត្ថលេខាលើការអនុវត្តអនុស្សរណៈនៃការយោគយល់ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ-វៀតណាម កាលពីខែមករា ឆ្នាំ២០១៣កន្លងទៅ។

**២.១៤៤-** ទន្ទឹមនឹងវឌ្ឍនភាពសម្រេចបានគួរឲ្យកត់សម្គាល់ក្តី ក៏*ក្រសួងសាធារណការនិងដឹកជញ្ជូន* នៅមានបញ្ហាប្រឈមមួយចំនួន រួមមាន៖

- កង្វះខាតធនធានមនុស្សក្នុងការបំពេញការងារតាមជំនាញក្នុងវិស័យដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក និងនាវាសមុទ្រ។ មន្ត្រីដែលមានការយល់ដឹងពីផ្នែកច្បាប់ ផ្នែកព័ត៌មានវិទ្យា និងផ្នែកនាវាចរណ៍សមុទ្រនៅមានកម្រិត។
- គុណភាពសេវានៅមានកម្រិត ទីផ្សារកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅមានទំហំតូចធ្វើឲ្យតម្លៃសេវានិងថ្លៃដឹកជញ្ជូនតាមសមុទ្រមានតម្លៃខ្ពស់។
- ការគ្រប់គ្រងនិងការរៀបចំកុងតឺន័រនៅលើទីលានកំពង់ផែពុំទាន់អាចប្រើតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបនៅឡើយ ហើយទីលាននៅកំពង់ផែស្វយ័តភ្នំពេញ នៅមានទំហំតូចចង្អៀត ព្រមទាំងពុំទាន់មានឃ្លាំងត្រជាក់ និងឃ្លាំងទំនិញគ្រោះថ្នាក់សម្រាប់ស្តុកទំនិញ។
- ការបំពេញតួនាទីភារកិច្ចរបស់មន្ត្រី-និយោជិត ពុំទាន់បានពេញលេញ និងជាប់លាប់នៅកំពង់ផែឯកជនមួយចំនួន ហើយការបណ្តុះបណ្តាលធនធានមនុស្សខាងការងារកំពង់ផែមួយចំនួនពុំទាន់បានឆ្លើយតបតាមតម្រូវការរបស់អង្គភាព។

**២.១៤៥-** *សេវាអាកាសចរស៊ីវិល : រាជរដ្ឋាភិបាលកម្ពុជា*បាននិងកំពុងអនុវត្តយុទ្ធសាស្ត្រ **"បើកចំហជើងមេឃ"**។ វឌ្ឍនភាពនៃសេវាអាកាសចរស៊ីវិល បានរួមចំណែកជំរុញឲ្យមានការអភិវឌ្ឍវិស័យទេសចរណ៍ និងកំណើនសេដ្ឋកិច្ច។ ជារួមវឌ្ឍនភាពនិងបញ្ហាប្រឈមទាំងនោះរួមមាន៖

- អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ៖
  - ➢ ផ្នែកដឹកជញ្ជូនតាមផ្លូវអាកាសមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ តាមរយៈការកើនឡើងចំនួនក្រុមហ៊ុនអាកាសចរណ៍បរទេស (១៨ក្រុមហ៊ុន) ដែលធ្វើប្រតិបត្តិការហោះហើរទៀងទាត់មកកាន់ប្រទេសកម្ពុជា។
  - ➢ *ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន :* ស្ថានីយអ្នកដំណើរទៅបរទេស មានទំហំសរុប ១៦ ០០០ម$^{២}$ (កំពុងពង្រីក៨៥០ម$^{២}$ បន្ថែមទៀត)។ ស្ថានីយសម្រាប់អ្នកដំណើរ មានសមត្ថភាពផ្ទុកអ្នកដំណើរបាន២លាននាក់ (២ ០៧៧ ២៨២នាក់ ទាំងក្រៅស្រុក ទាំងក្នុងស្រុក ក្នុងឆ្នាំ២០១២)។ រីឯស្ថានីយអ្នកដំណើរក្នុងស្រុកមានទំហំសរុប៣ ៦៧០ម$^{២}$។
  - ➢ ប្រព័ន្ធត្រួតពិនិត្យចរាចរផ្លូវអាកាស ត្រូវបានធ្វើឲ្យប្រសើរឡើងនិងត្រូវបានពង្រឹងជាលំដាប់។ ជាលទ្ធផល ប្រព័ន្ធនាំផ្លូវអាកាសត្រូវបានដាក់ឲ្យអនុវត្តចាប់ពីខែកក្កដា ឆ្នាំ២០១៣។

- អាកាសយានដ្ឋានអន្តរជាតិសៀមរាប៖

- ផ្នែកដឹកជញ្ជូនតាមផ្លូវអាកាស : ក្រុមហ៊ុនអាកាសចរណ៍បរទេសចំនួន១៨ កំពុងធ្វើប្រតិបត្តិការហោះហើរទៀងទាត់។
- ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន : សម្រេចបាននូវផែនការសកម្មភាពប្រកបដោយភាពជោគជ័យ។ ទាំងស្ថានីយអ្នកដំណើរទៅបរទេស និងក្នុងស្រុកមានទំហំ១៣ ៧០០ម² (អាចពង្រីកបន្ថែម) មានសមត្ថភាពផ្ទុកអ្នកដំណើរបាន១,៥លាននាក់(២ ២២៣ ០២៩ នាក់)។
- ប្រព័ន្ធត្រួតពិនិត្យចរាចរណ៍ផ្លូវអាកាសក៏ត្រូវបានរៀបចំ និងអនុវត្តក្នុងឆ្នាំ២០១៤។

**២.១៤៦-** ទន្ទឹមនឹងសមិទ្ធផលធំៗដែល*រដ្ឋលេខាអាកាសចរស៊ីវិល* សម្រេចបានក៏ដោយ ក៏វិស័យដឹកជញ្ជូនតាមផ្លូវអាកាសបាននិងកំពុងជួបប្រទះនោះ គឺភាពចាំបាច់ក្នុងការបន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យអាកាសចរស៊ីវិល។

## ៤.២- ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ

**២.១៤៧-** *ក្រសួងធនធានទឹកនិងឧតុនិយម* បានធ្វើឲ្យមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ក្នុងអំឡុងពេលពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣ នៅក្នុងផ្នែកនៃការស្តារឡើងវិញនិងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងផ្តល់ការការពារ ពីគ្រោះមហន្តរាយធម្មជាតិ។ *ក្រសួងធនធានទឹកនិងឧតុនិយម* បានអនុវត្តគម្រោងជាច្រើននៅទូទាំងប្រទេស។ សកម្មភាពទាំងនេះ រួមមាន៖

- *ការពង្រីកវិសាលភាពតំបន់ស្រោចស្រព៖*
    - រយៈពេល៥ឆ្នាំនៃការអនុវត្តផែនការសកម្មភាពកន្លងមក លទ្ធភាពប្រព័ន្ធស្រោចស្រពលើផ្ទៃដីដំណាំស្រូវ មានចំនួន៣៨៧ ៥០៧ហ.ត. ក្នុងនោះសម្រាប់ស្រូវរដូវវស្សាចំនួន ២៩៦ ០០០ហ.ត. និងសម្រាប់ស្រូវរដូវប្រាំងចំនួន៩១ ៥០៧ហ.ត.។ នៅចុងឆ្នាំ២០១៣ លទ្ធភាពស្រោចស្រពផ្ទៃដីកសិកម្មរបស់ប្រព័ន្ធធារាសាស្ត្រមានចំនួន១ ៤៨៥ ៦៧០ហ.ត. ក្នុងនោះលទ្ធភាពស្រោចស្រពលើផ្ទៃដីសម្រាប់ស្រូវរដូវវស្សាមាន១ ០៥០ ១៣៥ហ.ត. និងផ្ទៃដីសម្រាប់ស្រូវរដូវប្រាំងមាន៤៣៥ ៥៣៥ហ.ត.។
- *ការកាត់បន្ថយភាពងាយរងគ្រោះដោយសារគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត តាមរយៈ៖*
    - លទ្ធភាពការពារទប់ស្កាត់ទឹកជំនន់លើផ្ទៃដីសរុបចំនួន៥ ០៩៧ហ.ត.បន្ថែមលើលទ្ធភាពការពារដែលមានស្រាប់នៅចុងឆ្នាំ២០០៨ចំនួន១៣៣ ៥៣៣ហ.ត.។ មកដល់ឆ្នាំ២០១៣ លទ្ធភាពការពារទប់ស្កាត់ទឹកជំនន់លើផ្ទៃដីសរុបចំនួន១៣៨ ៦៣០ហ.ត.។

- ➢ លទ្ធភាពការពារទប់ស្កាត់ទឹកប្រៃលើផ្ទៃដីសរុបចំនួន១ ៧៥០ហ.ត. បន្ថែមលើលទ្ធភាពការពារដែលមានស្រាប់នៅចុងឆ្នាំ២០០៨ចំនួន១៧ ៩៩៣៣ហ.ត.។ មកដល់ឆ្នាំ២០១៣ លទ្ធភាពការពារទប់ស្កាត់ទឹកប្រៃលើផ្ទៃដីសរុបចំនួន១៩ ៧៤៣ ហ.ត.។
- ➢ បានដំឡើងស្ថានីយបូមទឹក១ស្ថានីយ ជួសជុលស្ថានីយ៤៩កន្លែង និងជួសជុលម៉ាស៊ីនបូមទឹក២៤០គ្រឿង។

- ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកបានចំនួន១០៩សហគមន៍ មានកសិករចំនួន ១៣ ៨៩៩គ្រួសារ។ សហគមន៍នេះមានលទ្ធភាពស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាចំនួន ៣១ ៩៤៨ហ.ត.និងផ្ទៃដីស្រូវរដូវប្រាំងចំនួន១៧ ៥៨៧ហ.ត.។

- *ការធ្វើឲ្យប្រសើរឡើងផ្នែកជលសាស្ត្រ តាមរយៈ៖*

  - ➢ បានដំឡើងស្ថានីយជលសាស្ត្រចំនួន៥ស្ថានីយ នៅតាមបណ្តោយទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់។
  - ➢ បានជួសជុលស្ថានីយជលសាស្ត្រចំនួន១កន្លែង។
  - ➢ បានដំឡើងក្តារវាស់កម្ពស់ទឹកចំនួន៣១កន្លែង និងជួសជុលបានចំនួន៣កន្លែង នៅតាមចំណុចត្រួតពិនិត្យ តាមបណ្តោយទន្លេនិងស្ទឹង។
  - ➢ បានដំឡើងឧបករណ៍វាស់ធារទឹកបានចំនួន២កន្លែង នៅតាមបណ្តោយស្ទឹងសំខាន់ៗ។

- *ការផ្តល់ព័ត៌មានអំពីអាកាសធាតុឲ្យបានទាន់ពេលវេលា តាមរយៈ៖*

  - ➢ បានដំឡើងស្ថានីយឧតុនិយមចំនួន៣កន្លែង និងបានជួសជុលកែលម្អស្ថានីយឧតុនិយមចំនួន៥កន្លែង នៅតាមបណ្តាខេត្ត។
  - ➢ បានដំឡើងប៉ុស្តិ៍តម្រងទឹកភ្លៀងចំនួន១៨កន្លែង និងបានជួសជុលប៉ុស្តិ៍តម្រងទឹកភ្លៀងចំនួន២៦កន្លែង។
  - ➢ បានបំពាក់ឧបករណ៍ស្វ័យប្រវត្តិតាមស្ថានីយចំនួន៨ស្ថានីយ។

- ការពង្រឹងសមត្ថភាពមន្ត្រីរាជការ (ជំនាញនិងបច្ចេកទេស) នៃ*ក្រសួងធនធានទឹកនិងឧតុនិយម* តាមរយៈវគ្គបណ្តុះបណ្តាល (៣០២នាក់) និងសិក្ខាសាលា (១៨១នាក់) ទាំងនៅក្នុងស្រុក ទាំងនៅក្រៅស្រុក ទាក់ទងនឹងការអភិរក្ស និងការអភិវឌ្ឍវិស័យធនធានទឹក។

**២.១៤៨-** ទោះបីជាមានវឌ្ឍនភាព ដូចបានលើកឡើងនេះក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ការផ្តល់ថវិកាលើការងារជួសជុល ស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ មានការយឺតយ៉ាវ និងពុំចំរដូវសាងសង់ និងនៅមានកម្រិត ដែលពុំអាចឆ្លើយតបតាមតម្រូវការជាក់ស្តែង។
- ការចូលរួមរបស់កសិករលើការងារសាងសង់ ការគ្រប់គ្រង ការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក ទំនប់ការពារទឹកជំនន់ មានកម្រិតនៅឡើយ។
- ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រជាសាស្ត្រ ចាំបាច់ត្រូវតែពង្រឹងបន្ថែមទៀត៖
  - ➢ ការជ្រើសរើសតំបន់អាទិភាពណាដែលមានសក្តានុពលខ្ពស់សម្រាប់បង្កើនចំណូលដល់សហគមន៍ជនបទ សម្រាប់ទទួលបានការសាងសង់ និងការជួសជុល-ស្តារហេដ្ឋារចនាសម្ព័ន្ធប្រជាសាស្ត្រ។
  - ➢ ការលើកទឹកចិត្តក្រុមប្រឹក្សាឃុំ ឲ្យចូលរួមគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រជាសាស្ត្ររបស់បណ្តាឃុំ។
  - ➢ ការលើកទឹកចិត្តប្រជាកសិករក្នុងការគ្រប់គ្រងធនធានទឹកដែលជាកិច្ចការសំខាន់ ក្នុងការរួមចំណែកដល់ការបង្កើនផលិតកម្មកសិកម្ម។
  - ➢ ការបង្កើនការចូលរួមរបស់ប្រជាកសិករនិងសហគមន៍កសិកម្ម ក្នុងការដោះស្រាយបញ្ហានានាដែលទាក់ទងនឹងការប្រើប្រាស់ និងថែរក្សាប្រព័ន្ធស្រោចស្រព។
  - ➢ ការបន្តអនុវត្តការងារថវិការសម្រាប់ការជួសជុលប្រព័ន្ធធារាសាស្ត្រ។

## ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ

**២.១៤៩-** *ព្រះរាជាណាចក្រកម្ពុជា* ក៏ជាម្ចាស់ហត្ថលេខីមួយ(កម្ពុជា ឡាវ វៀតណាម និងថៃ) នៃកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ ឆ្នាំ១៩៩៥។ កិច្ចព្រមព្រៀងនេះ គឺដើម្បីកិច្ចសហប្រតិបត្តិការលើវិស័យអភិវឌ្ឍន៍ប្រកបដោយចីរភាពការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធ នៅក្នុងអាងទន្លេមេគង្គ។

**២.១៥០-** *គណៈកម្មាធិការជាតិទន្លេមេគង្គ* គឺជាគណៈកម្មាធិការអន្តរក្រសួងមួយ ដែលទទួលខុសត្រូវក្នុងការធានានូវប្រសិទ្ធភាពនៃការសម្របសម្រួល ក្នុងចំណោមក្រសួង ស្ថាប័នបច្ចេកទេសពាក់ព័ន្ធជាសមាជិកទាំង១៧ ដើម្បីអនុវត្តការងារក្រោមកម្មវិធីរបស់*គណៈកម្មការទន្លេមេគង្គ* ក្នុងកម្រិតជាតិនិងកម្រិតតំបន់។ ក្នុងរយៈពេលកន្លងមក *ផែនការយុទ្ធសាស្ត្រគណៈកម្មការទន្លេមេគង្គ គោលការគ្រប់គ្រងធនធានទឹកចម្រុះ* និង *យុទ្ធសាស្ត្រអភិវឌ្ឍអាងដោយផ្អែកលើគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ* ត្រូវបានបង្កើត និងធ្វើបច្ចុប្បន្នកម្មសម្រាប់ការអនុវត្ត។ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញពីបណ្តាក្រសួង ស្ថាប័នបច្ចេកទេសពាក់ព័ន្ធ *គណៈកម្មាធិការជាតិទន្លេមេគង្គ* បាននិងកំពុងបន្តអនុវត្ត *យុទ្ធសាស្ត្រអភិវឌ្ឍអាងដោយផ្អែកលើគោល*

*ការណ៍គ្រប់គ្រងធនធានទឹកចម្រុះ* និងកម្មវិធីគម្រោងមួយចំនួន ដូចជា កម្មវិធីកសាងការអភិវឌ្ឍអាងទន្លេ ជលផល កសិកម្ម ស្រោចស្រព វារីអគ្គិសនី ការគ្រប់គ្រង ទឹកជនន់ ការគ្រប់គ្រងភាពរាំងស្ងួត ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានទឹកចម្រុះ ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង និងការកសាងសមត្ថភាពចម្រុះ សម្រាប់បម្រើនូវផលប្រយោជន៍ជាតិនិងតំបន់។

**២.១៥១-** ទោះបីជាសមិទ្ធផលចម្បងៗ ក្នុងការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គក៏នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា៖

- កង្វះខាតនូវធនធានហិរញ្ញវត្ថុ។
- កង្វះខាតនូវធនធានមនុស្ស។
- ការធ្វើឲ្យមានការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយនិរន្តរភាពក្នុងទន្លេមេនៃទន្លេមេគង្គ គឺជាកិច្ចការប្រឈម ដែលនឹងមានការពិភាក្សាពេញលេញរវាងប្រទេសជាសមាជិក និងសង្គមស៊ីវិល និងអ្នកបរិស្ថាន។

### វិស័យផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន

**២.១៥២-** ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជនបានកើនឡើងគួរឲ្យកត់សម្គាល់ ជាពិសេសក្នុងអំឡុងពេល៥ឆ្នាំ ក្នុងអាណត្តិទី៤នៃរាជរដ្ឋាភិបាល។ អត្រាគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាតតាមប្រព័ន្ធបណ្តាញក្នុងតំបន់ទីប្រជុំជន បានកើនឡើងពី៥២%នៅឆ្នាំ២០០៨ ដល់៦៨,៥% នៅឆ្នាំ២០១២ ដែលគិតជាចំនួនគ្រួសារទទួលបានទឹកស្អាតប្រើប្រាស់គឺកើនពី២៦៩ ៧៥៥ ដល់ ៤០០ ១៨១។

**២.១៥៣-** ស្របនឹងកំណើននេះ ដោយឡែកនៅរាជធានីភ្នំពេញ អត្រាសេវាគ្របដណ្តប់ គឺបាន ៨៥% ក្នុងឆ្នាំ២០១២ ដែលក្នុងអំឡុងពេលដូចគ្នា ទីប្រជុំជនផ្សេងក្រៅពីភ្នំពេញ បានប្រមាណជាមធ្យមតែ៥០%ប៉ុណ្ណោះ។ លើសពីនេះ កំណើនប្រជាពលរដ្ឋនៅទីក្រុង ការអភិវឌ្ឍក្រុង គឺទាមទារឲ្យមានការជំរុញកំណើនការអភិវឌ្ឍទឹកស្អាត ដើម្បីឆ្លើយតបនឹងតម្រូវការព្រមទាំងការបម្រែបម្រួលអាកាសធាតុដែលអាចជាឧបសគ្គដល់ការផ្តល់សេវាទឹកស្អាតទៅថ្ងៃអនាគត។

**២.១៥៤-** វិស័យផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន បាននិងកំពុងជួបប្រទះនូវបញ្ហាប្រឈមចម្បងៗ រួមមាន៖

- ពុំទាន់មានច្បាប់និងក្របខ័ណ្ឌបទដ្ឋានគតិយុត្តគ្រប់គ្រាន់។
- ពុំទាន់មានផែនការមេសម្រាប់ថ្នាក់ជាតិនិងផែនការវិនិយោគរយៈពេលវែង។
- អង្គភាពរដ្ឋាករទឹកសាធារណៈទាំងអស់ លើកលែងតែអង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនិងសៀមរាប នៅពុំទាន់ទទួលបានស្វ័យភាពសេដ្ឋកិច្ចនិងដំណើរការនៅឡើយ។

- ពុំមានមន្ត្រីគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យនិងតាមដានការអនុវត្តដំណើរការរបស់អង្គភាពសាធារណៈឲ្យបានពេញលេញ។
- ហេដ្ឋារចនាសម្ព័ន្ធរបស់អង្គភាពចាស់ទ្រុឌទ្រោម ដែលទាមទារឲ្យមានការស្តារ និងកែលម្អ។
- ប្រសិទ្ធភាពដំណើរការនិងគ្រប់គ្រង ព្រមទាំងធនធានមនុស្សនៅមានកម្រិត។
- ថវិកាពីរដ្ឋាភិបាលមានកម្រិតតិចតួចសម្រាប់ការអភិវឌ្ឍនិងពង្រីកទៅតំបន់ដែលពុំទាន់មានទឹកស្អាត។
- វិស័យទាំងមូលនៅពឹងផ្អែកលើជំនួយពីដៃគូអភិវឌ្ឍ។
- តារាងថ្លៃទឹករបស់អង្គភាពសាធារណៈភាគច្រើនមិនអាចធានាបានគ្រប់ចំណាយ ដែលធ្វើឲ្យដំណើរការនិងការថែរក្សាមិនអាចអនុវត្តបានពេញលេញ។
- បរិស្ថានវិនិយោគ គឺពុំទាន់បានរៀបរយល្អគ្រប់គ្រាន់សម្រាប់ការទាក់ទាញវិនិយោគទុនក្នុងស្រុកឲ្យដាក់ទុន ឬការផ្តល់ហិរញ្ញប្បទានឲ្យបានទូលាយដល់វិស័យឯកជន។

### ៤.៣- ការអភិវឌ្ឍវិស័យថាមពល និងបណ្តាញអគ្គិសនី

**២.១៥៥-** គោលដៅជាយុទ្ធសាស្ត្ររបស់*រាជរដ្ឋាភិបាលនីតិកាលទី៤* គឺការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ ការបន្ទូរបន្ថយពន្ធនៃការនាំចូលអគ្គិសនីឲ្យបានសមរម្យនិងការពង្រឹងយន្តការស្ថាប័ននិងសមត្ថភាពគ្រប់គ្រង។ ជាលទ្ធផល វឌ្ឍនភាពគួរឲ្យកត់សម្គាល់ ត្រូវបានធ្វើឲ្យកើតមានឡើងនៅក្នុងការបង្កើតលទ្ធភាពផ្គត់ផ្គង់អគ្គិសនីនិងការពង្រីកបណ្តាញអគ្គិសនី។ ដើម្បីតម្រែតម្រង់ទិសដៅនៃការអភិវឌ្ឍក្នុងវិស័យថាមពល *ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល* បានបន្តអនុវត្ត*ផែនការអភិវឌ្ឍន៍វិស័យថាមពល ២០០៥-២០២៤*។ ផែនការមេអគ្គិសនីភាវូបនីយកម្មជនបទ ដែលផ្តោតលើការប្រើប្រាស់ថាមពលកកើតឡើងវិញក៏កំពុងត្រូវបានអនុវត្ត។ សមិទ្ធផលចម្បងៗ មានដូចខាងក្រោម៖

- បានសាងសង់ កំពុងដំណើរការរោងចក្រវារីអគ្គិសនីមួយចំនួន រួមមាន៖
  - ➢ រោងចក្រវារីអគ្គិសនីកំចាយ អានុភាព១៩៣,២ម៉េហ្គាវ៉ាត់។
  - ➢ រោងចក្រវារីអគ្គិសនីគិរីរម្យទី៣ អានុភាព១៨ម៉េហ្គាវ៉ាត់។
  - ➢ រោងចក្រវារីអគ្គិសនីអាតៃ អានុភាព១២០ម៉េហ្គាវ៉ាត់។
  - ➢ រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម អានុភាព១០៣ម៉េហ្គាវ៉ាត់លើអនុភាពសរុប ៣៣៨ម៉េហ្គាវ៉ាត់។
  - ➢ រោងចក្រអគ្គិសនីដុតធ្យូងថ្មនៅខេត្តព្រះសីហនុ អានុភាព១០០ម៉េហ្គាវ៉ាត់។

- បានពង្រីកបណ្តាញបញ្ជូននិងចែកចាយ និងតភ្ជាប់លើទីតាំងមួយចំនួន និងដាក់ឲ្យដំណើរការ ដូចជា៖

- ➢ ខ្សែបញ្ជូនថាមពលអគ្គិសនីតង់ស្យុង១១៥គីឡូវ៉ុល តភ្ជាប់ពីព្រំដែនថៃមកផ្គត់ផ្គង់នៅក្នុងខេត្តបន្ទាយមានជ័យ សៀមរាប និងបាត់ដំបង។
- ➢ ខ្សែបញ្ជូនថាមពលអគ្គិសនីតង់ស្យុង២៣០គីឡូវ៉ុល ពីព្រំដែនវៀតណាមមករាជធានីភ្នំពេញ។
- ➢ បន្ថែមខ្សែបញ្ជូន១១៥គីឡូវ៉ុលនៅរាជធានីភ្នំពេញ និងបង្កើតអនុស្ថានីយភាគខាងលិចរាជធានីភ្នំពេញ។
- ➢ ខ្សែបញ្ជូនថាមពលអគ្គិសនីតង់ស្យុង២៣០គីឡូវ៉ុល តភ្ជាប់រាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។
- ➢ ខ្សែបញ្ជូនថាមពលអគ្គិសនីតង់ស្យុង២៣០គីឡូវ៉ុល តភ្ជាប់ខេត្តតាកែវ ខេត្តកំពត និងខេត្តព្រះសីហនុ។
- ➢ ខ្សែបញ្ជូនថាមពលអគ្គិសនីតង់ស្យុង២៣០គីឡូវ៉ុល តភ្ជាប់រាជធានីភ្នំពេញនិងខេត្តកំពង់ចាម។

- ដើម្បីបន្តអនុវត្តគោលនយោបាយអគ្គិសនីភាវូបនីយកម្មជនបទ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្ទេរមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ(ម.អ.ជ.)ឲ្យស្ថិតនៅក្រោមការដឹកនាំរបស់អគ្គិសនីកម្ពុជាក្នុងគោលបំណងជំរុញឲ្យមានសមធម៌ក្នុងការទទួលសេវាអគ្គិសនី និងបានលើកទឹកចិត្តផ្នែកឯកជន ឲ្យចូលរួមវិនិយោគក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅជនបទប្រកបដោយចីរភាព ជាពិសេសក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីនិងថាមពលកកើតឡើងវិញ។
- បានពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់នៅក្នុងក្របខ័ណ្ឌ *មហាអនុតំបន់ទន្លេមេគង្គ* ដូចជាការធ្វើពាណិជ្ជកម្មថាមពលទ្វេភាគីជាមួយប្រទេសជិតខាង និងឈានទៅពាណិជ្ជកម្មថាមពលក្នុង *មហាអនុតំបន់ទន្លេមេគង្គ*។
- ក្នុងក្របខ័ណ្ឌអាស៊ាន កម្ពុជាក៏បានចូលរួមនៅក្នុងការអនុវត្តផែនការប្រព័ន្ធបញ្ជូនថាមពលអាស៊ាន។

**២.១៥៦-** ទោះបីជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក៏ដោយ ក៏វិស័យថាមពលនៅតែជួបប្រទះនឹងបញ្ហាប្រឈមចម្បងៗមួយចំនួន ដូចខាងក្រោម៖

- ផលិតកម្មអគ្គិសនីពីប្រភពវារីអគ្គិសនីផលិតបានតែនៅរដូវវស្សា ដោយឡែកនៅរដូវប្រាំងផលិតកម្មថាមពលអគ្គិសនីបានត្រឹមតែ២៥%ប៉ុណ្ណោះ។
- ការពង្រីកបណ្ដាញចែកចាយឲ្យដល់ជនបទនៅមានកម្រិត។
- ថ្លៃលក់អគ្គិសនីរវាងទីក្រុងនិងជនបទនៅមានគម្លាតគ្នាខ្ពស់នៅឡើយ។

## ៤.៤- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍

២.១៥៧- គោលដៅជាយុទ្ធសាស្ត្ររបស់*រាជរដ្ឋាភិបាលនីតិកាលទី៤* គឺជំរុញការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ទំនើប និងប្រកបដោយគុណភាព តាមរយៈការពង្រឹងក្របខ័ណ្ឌគតិយុត្ត ការកសាងសមត្ថភាពស្ថាប័ន ការធ្វើទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស ការលើកស្ទួយការប្រកួតប្រជែង ការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងរដ្ឋបាលអេឡិចត្រូនិក ព្រមទាំងការជំរុញសាងសង់និងបង្កើនប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងសម្រាប់វិស័យបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។

២.១៥៨- វិស័យបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍របស់*ព្រះរាជាណាចក្រកម្ពុជា* រួមមាននូវសេវាប្រៃសណីយ៍ ទូរស័ព្ទនិងប្រព័ន្ធទូរគមនាគមន៍ផ្សេងៗទៀត ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ដូច្នេះរយៈពេល៥ឆ្នាំកន្លងមក រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗនិងបានជួបនឹងបញ្ហាប្រឈមមួយចំនួន រួមមានដូចខាងក្រោម៖

### វិស័យប្រៃសណីយ៍

- សេវាប្រៃសណីយ៍ត្រូវបានធ្វើឲ្យប្រសើរឡើង ដូចជា៖
  - ➢ បានកាត់បន្ថយរយៈពេលចែកចាយបញ្ញើ។
  - ➢ បានដាក់ឲ្យដំណើរការនូវសេវាបញ្ញើឆាប់រហ័ស នៅរាជធានី ខេត្តទាំងអស់។
  - ➢ បានពង្រីកសេវាប្រៃសណីយ៍ទៅដល់តំបន់ទីប្រជុំជនសំខាន់ៗ។
  - ➢ បានបង្កើតប្រព័ន្ធគ្រប់គ្រងសម្រាប់តាមដានត្រួតពិនិត្យបញ្ញើ។
- ក្នុងការអនុវត្តគោលនយោបាយបើកទូលាយវិស័យប្រៃសណីយ៍ *ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍* បានផ្តល់អាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ឲ្យដល់ក្រុមហ៊ុនចំនួន២១និងភ្នាក់ងារប្រៃសណីយ៍ចំនួន៣ ដែលកំពុងផ្តល់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ការបញ្ជូន និងទទួលបញ្ញើក្នុងប្រទេសអនុវត្តបាន២ជើង ក្នុងមួយថ្ងៃជាទៀងទាត់ទៅគ្រប់ទីកន្លែងនៅខេត្តក្រុង ដោយប្រើប្រាស់រថយន្តដឹកជញ្ជូនរបស់ប្រៃសណីយ៍កម្ពុជាដោយផ្ទាល់។ ចំពោះបរិមាណនៃការបញ្ជូនបញ្ញើឆាប់រហ័សក្នុងនិងក្រៅប្រទេសបានកើនឡើងដល់៣៧ ២១៧បញ្ញើ និងជួលជាវប្រអប់សំបុត្របានចំនួន១ ៧២៩ប្រអប់។
- អត្រានៃការប្រើប្រាស់ជាមធ្យមសេវាបញ្ញើប្រៃសណីយ៍(បញ្ជូននិងទទួល) ទូទាំងប្រទេសស្មើ០,១២៧៩ ក្នុងប្រជាជន១នាក់ក្នុង១ឆ្នាំ ក្នុងនោះសេវាបញ្ញើទៅក្រៅប្រទេសស្រូបយកប្រមាណ៩៥%នៃសេវាទូទាំងប្រទេស។

- ទីតាំងនិងសាខាប្រៃសណីយ៍នៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តមានចំនួនសរុប ៥៤កន្លែង ក្នុងនោះនៅរាជធានីភ្នំពេញ៨កន្លែង ខេត្តចំនួន២២កន្លែង និងខណ្ឌ ស្រុកទូទាំងប្រទេសចំនួន២៤កន្លែង។
- បានបណ្តុះបណ្តាលវគ្គជំនាញអាជីវកម្មប្រៃសណីយ៍ : វគ្គគ្រប់គ្រងប្រព័ន្ធប្រៃសណីយ៍អន្តរជាតិ វគ្គគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ និងវគ្គគ្រប់គ្រងចំណូលអាជីវកម្ម។

## វិស័យទូរគមនាគមន៍

- គិតត្រឹមខែធ្នូ ឆ្នាំ២០១២ ចំនួនប្រតិបត្តិករទូរគមនាគមន៍កំពុងធ្វើអាជីវកម្មទូរស័ព្ទចល័តមានចំនួន៨ ទូរស័ព្ទអចល័តមានចំនួន៧ អ៊ិនធឺណិតមានចំនួន២៤ សេវា3G មានចំនួន៥ មាត់ច្រកអន្តរជាតិមានចំនួន៣ សេវាVOIP មានចំនួន២៧ និងសេវាVSAT មានចំនួន១។
- គិតត្រឹមខែធ្នូ ឆ្នាំ២០១២ ចំនួនអតិថិជនប្រើប្រាស់ទូរស័ព្ទចល័ត១៩ ១០៥ ១១៥នាក់ (ចំនួនស៊ីមកាតដែលបានលក់ចេញ) ស្មើអត្រា១២៩,៦០ ក្នុងប្រជាជន១០០នាក់(ឆ្នាំ ២០០៨ មាន៣ ៧៩១ ៨៣៤នាក់ ស្មើអត្រា២៤,៤៣ តែប៉ុណ្ណោះ) និងទូរស័ព្ទអចល័តមានអតិថិជនប្រើប្រាស់ចំនួន៥៨៤ ៤៧៥នាក់ ស្មើអត្រា៣,៩៦ ក្នុងប្រជាជន១០០នាក់(ឆ្នាំ ២០០៨ មានចំនួន៤៣,៤១៧ នាក់ ស្មើអត្រា០,២៨ តែប៉ុណ្ណោះ)។
- ដោយឡែកអតិថិជនជួលជាវអ៊ិនធឺណិតមានចំនួន២ ៧០៦ ៩២២នាក់ ស្មើអត្រា១៨,៦៧ ក្នុងប្រជាជន១០០នាក់(ឆ្នាំ២០០៨ មាន២០ ១០៨នាក់ តែប៉ុណ្ណោះ)។
- គុណភាពបណ្តាញនិងសេវាត្រូវបានពង្រឹងឥតឈប់ឈរ។ ប្រភេទទូរស័ព្ទអចល័ត មានការអភិវឌ្ឍជាបន្តបន្ទាប់ ពិសេសនៅរាជធានីភ្នំពេញនិងតាមបណ្តាខេត្តដែលមានបណ្តាញកាប្លិ៍អុបទិក។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ទូទាំងប្រទេសដោយប្រើប្រាស់ប្រាក់កម្ចី និងការវិនិយោគឯកជន លើវិស័យហេដ្ឋារចនាសម្ព័ន្ធកាប្លិ៍អុបទិកមានប្រវែងសរុប២៣ ០៨០គ.ម. គិតជាទឹកប្រាក់វិនិយោគមានប្រមាណ១ ៧០០លានដុល្លារអាមេរិក។ ក្នុងនោះ (ក)ទូរគមនាគមន៍កម្ពុជាមាន១ ៩០០គ.ម. (ខ)ក្រុមហ៊ុនCFOC មាន៥ ១៨០គ.ម. (គ)ក្រុមហ៊ុន VIETEL មាន១៦ ០០០គ.ម. ហើយបណ្តាញហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងរបស់ក្រុមហ៊ុនទាំង ៣ នេះ គឺត្រូវបានតភ្ជាប់ទៅប្រទេសវៀតណាម ឡាវ និងប្រទេសថៃ។
- កំពុងដំណើការគម្រោងបង្ហោះផ្កាយរណបទូរគមនាគមន៍ចូលទៅក្នុងតារាវិថី ដែលនឹងជួយលើកស្ទួយអធិបតេយ្យជាតិ សន្តិសុខជាតិកិត្តិយសជាតិ ក៏ដូចជាបម្រើផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនិងសង្គម។

### ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

- ប្រជាពលរដ្ឋខ្មែរប្រមាណ៨៥%នៅក្នុងប្រទេស បានទទួលសេវាផ្តល់ព័ត៌មាន ផ្តល់ការអប់រំ និងការកម្សាន្តប្រកបដោយគុណភាព និងសមធម៌ តាមរយៈមធ្យោបាយផ្សេងៗគ្នា ដូចជាទូរទស្សន៍ វិទ្យុ សារព័ត៌មានបោះពុម្ព ប្រព័ន្ធអ៊ិនធឺណិត និងតាមបណ្តាញសង្គម ស្របតាមលទ្ធភាពដែលប្រជាជនមាន។
- យោងតាមស្ថិតិអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១០ បានបង្ហាញថា៦៤% ក្នុងចំណោមគ្រួសារកម្ពុជាសរុប មានទូរទស្សន៍មើល៤១% មានវិទ្យុស្តាប់ ប្រមាណជា២០% បានប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតនិងបណ្តាញសង្គម។
- បណ្តាញផ្សព្វផ្សាយថ្នាក់ក្រោមជាតិ ជាពិសេសស្ថានីយវិទ្យុ ត្រូវបានពង្រីកដល់១៦ខេត្ត/ក្រុង ដែលស្ថានីយទាំងនេះមានតួនាទីផ្សាយបន្តផ្ទាល់ពីព្រឹត្តិការណ៍សំខាន់ៗ ពីថ្នាក់ជាតិ និងមានលទ្ធភាពផលិតកម្មវិធីផ្សាយផ្ទាល់សម្រាប់សហគមន៍ និងមូលដ្ឋានរបស់ខ្លួន ដោយផ្តោតសំខាន់ទៅលើប្រធានបទអប់រំ សង្គម សិទ្ធិ ច្បាប់ សុខភាព សម្រាប់សហគមន៍ ជាពិសេសអំពីយេនឌ័រនិងកុមារ។ ជាសំខាន់ ស្ថានីយវិទ្យុនៅតាមបណ្តាខេត្ត នឹងក្លាយជាស្ពានភ្ជាប់រាជរដ្ឋាភិបាលជាមួយប្រជាជនសម្រាប់ផ្តល់នូវព័ត៌មាន គោលនយោបាយលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាលទៅដល់ប្រជាជន ដើម្បីឲ្យប្រជាជនបានចូលរួមអនុវត្តអភិវឌ្ឍប្រទេស ហើយក៏ជាវេទិកាដ៏ទូលំទូលាយ និងមានប្រសិទ្ធភាពសម្រាប់ប្រជាជនបញ្ចេញមតិយោបល់ និងលើកសំណូមពរពីបំណងប្រាថ្នានិងតម្រូវការរបស់ខ្លួនជូនដល់រាជរដ្ឋាភិបាល។

**២.១៥៩-** ទោះបីយ៉ាងណាក្តី កម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន រួមមានៈ

- ប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យទូរគមនាគមន៍នៅមានកម្រិត អាស្រ័យដោយសារច្បាប់ស្តីពីទូរគមនាគមន៍ពុំទាន់បានអនុម័តពីរដ្ឋសភានៅឡើយ។
- ទោះបី*ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* ខិតខំប្រឹងប្រែងលុបបំបាត់ក៏ដោយ ក៏សេវាមាត់ច្រកអន្តរជាតិខុសច្បាប់នៅតែបន្តកើតមានឡើង ដែលជាហេតុនាំឲ្យប៉ះពាល់ដល់សេវាមាត់ច្រកអន្តរជាតិស្របច្បាប់និងចំណូលរដ្ឋ។
- កិច្ចសហការរវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍និងប្រតិបត្តិករ-ភ្នាក់ងារអភិវឌ្ឍន៍ នៅពុំទាន់មានភាពល្អប្រសើរនៅឡើយ។
- សេវាប្រៃសណីយ៍របស់ក្រុមហ៊ុនឯកជន មានលក្ខណៈប្រកួតប្រជែងជាងរដ្ឋ ហើយសមត្ថភាពធនធានមនុស្សក្នុងវិស័យប្រៃសណីយ៍នៅមានកម្រិតនៅឡើយ។

- សមត្ថភាពជំនាញរបស់មន្ត្រីរាជការ និយោជិកនៅមានកម្រិតពុំទាន់ឆ្លើយតបបានទៅនឹងល្បឿនការអភិវឌ្ឍនៃបច្ចេកវិទ្យាទំនើប។
- បណ្តាអង្គភាពផ្សព្វផ្សាយរបស់រដ្ឋ(វិទ្យុ ទូរទស្សន៍ និងទីភ្នាក់សារព័ត៌មានជាតិ) ពុំមានលទ្ធភាពថវិកាគ្រប់គ្រាន់សម្រាប់ម្ចាស់ការផលិតកម្មវិធីអប់រំឲ្យបានទូលំទូលាយលើគ្រប់វិស័យទៅបាន ជាពិសេសការអប់រំសង្គម។ ការផ្សាយកម្មវិធីអប់រំភាគច្រើនកន្លងមក គឺពឹងផ្អែកលើកិច្ចសហការជាមួយដៃគូជាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។
- មូលដ្ឋានសម្ភារៈបច្ចេកទេសសម្រាប់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ វិទ្យុជាតិ ទូរទស្សន៍ជាតិ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ឈានដល់ដំណាក់កាលត្រូវផ្លាស់ប្តូរនិងធ្វើទំនើបកម្ម ជាពិសេសការត្រៀមលក្ខណៈផ្លាស់ប្តូរពីប្រព័ន្ធអាណាឡូកទៅប្រព័ន្ធបច្ចេកវិទ្យាឌីជីថល។

## ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ

**២.១៦០-** មុំរងទាំងបួននៃចតុកោណនេះ រួមមានៈ (១)ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ (២)ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរ (៣)ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម (៤)ការរៀបចំសុវត្ថិភាពសង្គម។

### ៥.១- ការពង្រឹងវិស័យឯកជននិងការទាក់ទាញវិនិយោគ

**២.១៦១-** វិស័យឯកជន គឺជាក្បាលម៉ាស៊ីនសម្រាប់កំណើននិងកាត់បន្ថយភាពក្រីក្រ។ *រាជរដ្ឋាភិបាល* ទទួលស្គាល់ថា ការធ្វើឲ្យប្រសើរឡើងនូវបរិយាកាសអាជីវកម្មនិងការបង្កើតនូវបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍវិស័យឯកជន គឺជាមូលដ្ឋានគន្លឹះសម្រាប់ជំរុញការអភិវឌ្ឍ បង្កើតការងារ កាត់បន្ថយភាពក្រីក្រ និងសម្រេចបានស្ថិរភាពកំណើនសេដ្ឋកិច្ច។ ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ គឺជាបញ្ហាអន្តរវិស័យ ដែលមានការពាក់ព័ន្ធជាមួយស្ថាប័នមួយចំនួនរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា* អាទិភាពខ្ពស់បំផុតរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការគាំទ្រការបង្កើតនូវបរិយាកាសអំណោយផល ដែលជំរុញឲ្យមានការអភិវឌ្ឍវិស័យឯកជន តាមរយៈការអនុវត្តវិធានការនានាដើម្បីលុបបំបាត់បណ្តាឧបសគ្គទាំងឡាយដែលរារាំងដល់ការអភិវឌ្ឍវិស័យឯកជន។

**២.១៦២-** *គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* បានបង្កើត "*សេវាកម្មច្រកចេញចូលតែមួយ*"សម្រាប់ឲ្យវិនិយោគិនជាច្រើនឆ្នាំមកហើយ ដើម្បីកាត់បន្ថយបន្ទុកផ្នែករដ្ឋបាល នៅក្នុងការសុំការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជាលើគម្រោងវិនិយោគថ្មី។ នៅក្នុងនីតិ

កាលទី៤នៃរដ្ឋសភានេះ យន្តការ "*សេវាកម្មច្រកចេញចូលតែមួយ*" ត្រូវបានបន្តពង្រឹងនិងកែទម្រង់ ហើយយន្តការថ្មី "ការយកចិត្តទុកដាក់ចំពោះវិនិយោគិន" និង "ប្រព័ន្ធតាមដាននិងត្រួតពិនិត្យការវិនិយោគ" បានបង្កើតឡើងនិងបានអនុវត្ត។ *គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* និង*ក្រសួងពាណិជ្ជកម្ម* បានបន្តជំរុញយ៉ាងសកម្មឲ្យមានការវិនិយោគថ្មីៗក្នុងវិស័យសេដ្ឋកិច្ចអាទិភាពនានា ដើម្បីធ្វើពិពិធកម្មនិងពង្រីកមូលដ្ឋានសេដ្ឋកិច្ច រៀបចំនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវព័ត៌មានស្តីពីកាលានុវត្តភាពវិនិយោគនៅក្នុងវិស័យអាទិភាព ដើម្បីផ្តល់សក្តានុពលដល់វិនិយោគិន វិស័យឯកជន និងពង្រឹងការសម្របសម្រួលក្នុងចំណោមស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការទទួលខុសត្រូវរួមគ្នា សម្រាប់លើកកម្ពស់ការប្រកួតប្រជែងរបស់អាជីវកម្មក្នុងវិស័យឯកជន។

**២.១៦៣-** *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* បានបន្តនូវការអនុវត្តតំបន់សេដ្ឋកិច្ចពិសេស ហើយបានធានាថា ទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេសនឹងសមស្របសម្រាប់ធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ឲ្យបានជាអតិបរមា។

**២.១៦៤-** ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៩មក *វេទិការាជរដ្ឋាភិបាលកម្ពុជាវិស័យឯកជន* និងគណៈកម្មាធិការ ដែលស្ថិតនៅក្រោមយន្តការនេះបានចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងដំណើរការនៃកំណែទម្រង់រដ្ឋបាលនិងកំណែទម្រង់ច្បាប់ដើម្បីជំរុញការអភិវឌ្ឍវិស័យឯកជន។ យន្តការសម្របសម្រួលនេះមិនត្រឹមតែមានប្រសិទ្ធភាពក្នុងការកសាងភាពជាដៃគូជាមួយវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងការផ្តល់ធាតុចូលនៅក្នុងការធ្វើអាទិភាវូបនីយកម្ម នូវសកម្មភាពនានានៃកម្មវិធីកំណែទម្រង់។ *រាជរដ្ឋាភិបាលកម្ពុជា*បានបន្តរិះរកវិធីសាស្ត្រថ្មីដើម្បីបន្តពង្រឹងយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជានិងវិស័យឯកជន និងកសាងនូវភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន។

**២.១៦៥-** ប្រទេសកម្ពុជាបាននិងកំពុងធ្វើសមាហរណកម្មយ៉ាងជោគជ័យ ទៅក្នុងសេដ្ឋកិច្ចពិភពលោក តាមរយៈពាណិជ្ជកម្មនិងការវិនិយោគ។ តាមការវាស់វែងការរីកចម្រើន ឬយថាប្រភេទក៏ដោយឃើញថាប្រទេសកម្ពុជាមានវឌ្ឍនភាពរហូតមក។

**២.១៦៦-** ប្រទេសកម្ពុជាទទួលបានការវិនិយោគផ្ទាល់ពីបរទេស ប្រមាណ៤ ៤៧៦លានដុល្លារអាមេរិក ចន្លោះឆ្នាំ២០០៨ និងឆ្នាំ២០១២។ និន្នាការនៃការកើនឡើងនេះ បង្ហាញថាជាកត្តាជោគជ័យមួយក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឯកជន។

**២.១៦៧-** ការនាំចេញទំនិញនិងសេវាតាមការកត់ត្រាទាំងផ្លូវការនិងក្រៅផ្លូវការបានប៉ាន់ប្រមាណថា បានកើនឡើងក្នុងរវាងឆ្នាំ២០០៩និងឆ្នាំ២០១៣ ដែលមានទឹកប្រាក់ពី២ ៩៩៥ពាន់លានដុល្លារអាមេរិក ដល់៦ ៩០៧ពាន់លានដុល្លារអាមេរិក(រំពឹងទុក)។ ទោះជាយ៉ាងនេះក្តី អ្នកប្រកួត

ប្រជែងថ្មីៗកំពុងកើតមានឡើងប្រជែងជាមួយអ្នកនាំចេញកម្ពុជា។ ប្រទេសកម្ពុជាត្រូវតែឆ្លើយតបទៅវិញ តាមរយៈការពង្រឹងការប្រកួតប្រជែងនៃវិស័យនាំចេញដែលមានស្រាប់របស់ខ្លួនស្របពេលនឹងការបង្កើតវិស័យថ្មីៗ។

**២.១៦៨-** ការប្រកួតប្រជែងមានសារៈសំខាន់ណាស់សម្រាប់ការរីកលូតលាស់នៃវិស័យនាំចេញ។ ជាមួយនឹងភាពរីកចម្រើនយ៉ាងរហ័សនៅក្នុងវិស័យកសិកម្មនិងការកើនឡើងនៃការមកដល់នៃទេសចរណ៍ ប្រទេសកម្ពុជាបានបង្កើតនូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់។ ទោះជាយ៉ាងណាក៏ដោយក៏នៅតែមានតម្រូវការកិច្ចអន្តរាគមន៍ជាក់ស្តែងដើម្បីធានាថា ការពង្រីកវិស័យពាណិជ្ជកម្មច្រើនថែមទៀតជួយពន្លឿនបរិយាប័ន្នទិងសមធម៌។

**២.១៦៩-** ការប្រកួតប្រជែងវិស័យពាណិជ្ជកម្ម កើតចេញពីអន្តរកម្មនៃកត្តាមួយចំនួន ដូចជា៖

- *ការកែលម្អលទ្ធភាពចូលទៅកាន់ទីផ្សារ៖*
    - ការផ្លាស់ប្តូរប្រកបដោយភាពអនុគ្រោះក្នុងវិធានស្តីពីប្រភពដើម(ROOs) គ្រប់គ្រងលើកម្មវិធី E.U.'s EBA និងកម្មវិធី Canada's LDCT program រួមជាមួយនឹងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយដៃគូចរចារបស់អាស៊ាន ធ្វើឲ្យមានការកើនឡើងយ៉ាងខ្លាំងនូវការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសទាំងនោះ ជាពិសេស គឺការនាំចេញខាងវិស័យកាត់ដេរ។
    - ដោយហេតុថាលក្ខខណ្ឌសម្រាប់លទ្ធភាពចូលទៅកាន់ទីផ្សារមានភាពអនុគ្រោះតិចតួច (ទីផ្សារសហរដ្ឋអាមេរិក) សម្រាប់ការនាំចេញរបស់ប្រទេសកម្ពុជាបានថយចុះពី៥៥% មក៣៥% ក្នុងអំឡុងឆ្នាំ២០០៧ដល់២០១១ ខណៈដែលសហគមន៍អឺរ៉ុប ដៃគូចរចារបស់អាស៊ាន ប្រទេសថៃ វៀតណាម និងប្រទេសដទៃទៀតបានក្លាយជាទិសដៅកាន់តែសំខាន់សម្រាប់ការនាំចេញរបស់កម្ពុជា។
    - លទ្ធភាពចូលទៅកាន់ទីផ្សារចំពោះផលិតផលកសិកម្មក៏កំពុងតែវិវត្តផងដែរ។ ដោយពឹងផ្អែកទៅលើប្រទេសជិតខាង (សំខាន់បំផុត គឺប្រទេសវៀតណាមនិងថៃ) ដែលជាទីផ្សារកណ្តាលសម្រាប់ការនាំចេញនូវផលិតផលកសិកម្មដែលមិនទាន់កែច្នៃ និងមិនផ្លូវការនោះ កំពុងតែនាំផ្លូវដល់ការនាំចេញផ្ទាល់ និងជាផ្លូវការទៅកាន់ទីផ្សារចុងក្រោយដែលជាទីពេញចិត្តរបស់កម្ពុជាក្នុងការទទួលបាននូវការនាំចូលដោយរួចពន្ធ។
    - ប្រទេសកម្ពុជាចាំបាច់ត្រូវតែសកម្មក្នុងការចរចា ដោយភ្ជាប់នឹងច្បាប់ស្តីពីវិធាននៃប្រភពដើម រួមទាំងបរិបទនៃការចរចា RECP ដែលនឹងមកដល់រវាងអាស៊ាននិងដៃគូចរចា។

- *ការពង្រឹងបរិយាកាសអាជីវកម្មក្នុងស្រុក៖*

- ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលអាចព្យាករបាន និងអាស្រ័យលើបទដ្ឋានអន្តរជាតិ គឺមានសារៈសំខាន់សម្រាប់អាជីវកម្មនិងពាណិជ្ជកម្ម។ ការសម្រួលពាណិជ្ជកម្ម និងភស្តុភារ គឺជាផ្នែកមួយដ៏សំខាន់ផ្សេងទៀតដែលជះឥទ្ធិពលលើការប្រកួតប្រជែង។ ចំណុចពិសេស និងសំខាន់សម្រាប់ការអភិវឌ្ឍការនាំចេញដូចជាផលិតផលសម្លៀកបំពាក់ថ្នាក់ខ្ពស់ ឬ បរិធានសម្រាប់ខ្សែចង្វាក់ផលិតកម្មដែលជា"វង្វិលជុំ-វដ្ត" និងការផ្គត់ផ្គង់តាមពេលគឺជាការសំខាន់។
- ការពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មដែលបានប្រារព្ធនៅទីក្រុងហ្សឺណែវ កាលពីខែវិច្ឆិកា ឆ្នាំ២០១១ ក្រោមការឧបត្ថម្ភរបស់អង្គការពាណិជ្ជកម្មពិភពលោក បានបង្ហាញឲ្យឃើញថា តម្រូវការឲ្យមានកំណែទម្រង់ច្បាប់និងបទប្បញ្ញត្តិមួយចំនួនដែលបានរកឃើញនៅក្នុងកម្មវិធីការងារស្តីពីកាតព្វកិច្ចអង្គការពាណិជ្ជកម្មពិភពលោកឆ្នាំ ២០០៤។ គុណ្យការនៃកំណែទម្រង់និងសកម្មភាពការងារចំនួន៨៤ ត្រូវបានកំណត់នៅក្នុងកម្មវិធីតាមដានសម្រាប់ឆ្នាំ២០១២ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។
- តម្លៃសម្រាប់ការសម្របសម្រួលក្នុងកិច្ចការពាណិជ្ជកម្មក្នុងការនាំចេញ និងនាំចូលតាមមធ្យមភាគអាស៊ាន-៦ មានចំនួន១៣៦%។ រយៈពេលបញ្ចេញទំនិញជាមធ្យម គឺ២៤ ថ្ងៃ ប្រៀបធៀបនឹងមធ្យមភាគនៃប្រទេសអាស៊ាន-៦ គឺមានរយៈពេលតែ១៦ថ្ងៃ។ ប្រទេសកម្ពុជាបានធ្វើផែនការសម្រាប់ការបង្កើត *សេវាកម្មច្រកចេញចូលតែមួយ* ថ្នាក់ជាតិ ដើម្បីកាត់បន្ថយថ្លៃចំណាយនិងរយៈពេលបញ្ចេញទំនិញនៅត្រឹមឆ្នាំ២០១៨។
- ទោះបើមានការកែលម្អដ៏សំខាន់នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ចាប់តាំងពីដើមឆ្នាំ២០០០ក៏ដោយ ក៏នៅមានហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតដែលចាំបាច់ត្រូវការកែលម្អផងដែរ ដើម្បីជំរុញនូវប្រសិទ្ធភាពនៃការដឹកជញ្ជូនក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងអនុតំបន់ទាំងអស់នេះ គឺជាការងារដ៏សំខាន់សំដៅកាត់បន្ថយការចំណាយក្នុងសេវាធុរកិច្ច។

- *បញ្ហានៃការកើនឡើងកត្តាផលិតភាពនិងផលិតភាពការងារ៖* កើនឡើងកត្តាផលិតភាពក៏ជាកត្តាកំណត់ដ៏សំខាន់ផងដែរសម្រាប់ការប្រកួតប្រជែង។ កើនឡើងផលិតភាពជាបឋមតាមរយៈការវិនិយោគលើឧបករណ៍សម្ភារៈដែលមានបច្ចេកវិទ្យាខ្ពស់។ ការប្រើប្រាស់នូវសម្ភារៈទាំងនោះក៏ទាមទារឲ្យមានកម្រិតជំនាញកាន់តែខ្ពស់ផងដែរ។ កម្ពុជាត្រូវតាមដានត្រួតពិនិត្យមើលពីគម្លាតនៃជំនាញ។

- ប្រទេសកម្ពុជាខ្វះនូវប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET) ដ៏រឹងមាំមួយ ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកឯកជន ក្នុងនោះក៏មានវិស័យនាំចេញដើម្បីបំពេញឲ្យបាននូវកង្វះខាតនេះផងដែរ។

- ស្ថាប័នអប់រំថ្នាក់ក្រោយឧត្តមសិក្សានៅកម្ពុជាមានការរីកចម្រើនយ៉ាងរហ័សក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ និងមានអ្នកដែលបញ្ចប់ថ្នាក់មហាវិទ្យាល័យក៏កើនឡើងច្រើន។ ប៉ុន្តែកម្មវិធីសិក្សាថ្នាក់មហាវិទ្យាល័យមិនមានផ្សារភ្ជាប់ជំនាញដែលទីផ្សារក្នុងស្រុកត្រូវការ ទាំងនៅក្នុងវិស័យនាំចេញផងដែរ។
- ប្រទេសកម្ពុជាខ្វះនូវប្រព័ន្ធព័ត៌មានទីផ្សារការងារ ដែលមានតម្លាភាពដើម្បីជួយដល់អ្នកអប់រំបណ្ដុះបណ្ដាល និងអ្នកស្វែងរកទីផ្សារការងារដើម្បីបានដឹងអំពីកន្លែងដែលត្រូវការការងារ និងជំនាញដែលគេត្រូវការ និងក៏អាចជួយដល់និយោជកផងដែរអំពីកន្លែងដែលជ្រើសរើសកម្មករ ដែលមានសក្ដានុពល(ជំនាញ)។

- *ការកើនឡើងតម្លៃបន្ថែមក្នុងស្រុក៖*

- ឧស្សាហកម្មនាំចេញចម្បងរបស់ប្រទេសកម្ពុជា មានឧស្សាហកម្មកាត់ដេរ ស្បែកជើង និងទោចក្រយាន ដោយនាំចូលស្ទើរតែទាំងស្រុងនូវគ្រឿងបន្លាស់និងបរិក្ខារដើម្បីផលិតជាផលិតផលសម្រេចសម្រាប់ការនាំចេញ។ ការនាំចេញផលិតផលកសិកម្មកម្ពុជា ភាគច្រើនក្នុងទម្រង់ជាផលិតផលកសិកម្មមិនទាន់កែច្នៃ។ ក្នុងករណីទាំងពីរនេះហើយ ដែលធ្វើឲ្យតម្លៃបន្ថែមក្នុងប្រទេសកម្ពុជា ទទួលបានតិចតួចពីតម្លៃផលិតផល។ ដើម្បីសម្រេចបានករណីទាំងពីរនេះ ប្រទេសកម្ពុជាត្រូវស្វែងរកលទ្ធភាពដើម្បីបង្កើនតម្លៃបន្ថែមក្នុងប្រទេស។ ក្នុងវិស័យកសិកម្ម ត្រូវធ្វើការកែច្នៃផលិតផលដែលចេញពីកសិដ្ឋាន ដូចជាករណីអង្ករដែលបាននិងកំពុងដំណើរការរួចមកហើយ។ រីឯវិស័យកាត់ដេរស្បែកជើង និងទោចក្រយាន ចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងដំណើរការផលិតកម្មឲ្យបានច្រើនដើម្បីបង្កើតតម្លៃ និងបង្កើនតម្លៃបន្ថែមឲ្យកាន់តែធំនៅក្នុងប្រទេស។
- ការផ្សារភ្ជាប់គ្នារវាងការផ្គត់ផ្គង់សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងក្រុមហ៊ុននាំចេញមានសារៈសំខាន់បំផុត ហើយគប្បីត្រូវលើកកម្ពស់។ ការវិនិយោគផ្ទាល់ពីបរទេសក្នុងផលិតកម្ម ដែលប្រើប្រាស់ធាតុចូលក្នុងស្រុកក៏គប្បីលើកទឹកចិត្តផងដែរ។ ឧស្សាហកម្មនាំចេញគប្បីធ្វើជាស្នូលនៃបណ្ដាញការអភិវឌ្ឍផលិតកម្មក្នុងស្រុក។
- អ្នកនាំចេញកម្ពុជា ត្រូវស្វែងរកគន្លឹះសម្រាប់លើកកម្ពស់បណ្ដាញអភិវឌ្ឍន៍ផលិតកម្មក្នុងស្រុក។ ប្រការនេះគួររិះរកមធ្យោបាយនានា ដើម្បីជាដំណោះស្រាយបញ្ហាកង្វះជំនាញ។ ឧទាហរណ៍ ម្ចាស់ម៉ាស៊ីនកិនស្រូវ ឬអ្នកនាំចេញកំពុងជួបប្រទះការប្រឈមរបស់ខ្លួនក្នុងការធានាឲ្យបាននូវនិរន្តរភាពគុណភាពនៃផលិតផលសម្រាប់នាំចេញរបស់ពួកគេ។ ចំពោះអ្នកផលិតផលិតផលសូត្រ ដែលមានតម្លៃខ្ពស់ត្រូវរៀនអំពីរបៀបត្រួតពិនិត្យគុណភាពសរសៃសូត្រនាំចូលឲ្យបានកាន់តែប្រសើរ។
- នៅក្នុងវិស័យ ស្រូវ ដំឡូងមី ពោត សណ្ដែកសៀង វិស័យបដិសណ្ឋារកិច្ច អាហារកែច្នៃ

និងជលផល អ្នកផលិតចាំបាច់ត្រូវកែលម្អកន្លែងផលិតរបស់ខ្លួនឲ្យដល់កម្រិតស្តង់ដាអន្តរជាតិ។ រដ្ឋាភិបាលក៏មានតួនាទីក្នុងការរៀបចំនូវប្រព័ន្ធតាមដាន និងពង្រឹងការអនុវត្តតាមការកំណត់របស់ប្រទេសនាំចូល ដូចជាការត្រួតពិនិត្យសត្វល្អិតក្នុងទីតាំងផលិត(រោងចក្រ) និងជំងឺសត្វ ត្រួតពិនិត្យការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ឬការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារក្នុងទីផ្សារអ្នកប្រើប្រាស់។

➢ ការគាំទ្រផ្នែកហិរញ្ញវត្ថុនៃអ្នកវិនិយោគសម្រាប់ការនាំចេញ តាមរយៈកម្មវិធីផ្តល់ទុន ឬតាមរយៈស្ថាប័នឯកទេសហិរញ្ញវត្ថុ គឺជាផ្នែកមួយដែលបានទទួលការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ក្នុងនោះមានគោលនយោបាយវិស័យស្រូវអង្ករឆ្នាំ២០១១។ យ៉ាងណាក៏ដោយ ត្រូវមានការយកចិត្តទុកដាក់បន្ថែមទៀតសម្រាប់បណ្តាឆ្នាំខាងមុខៗ។

**២.១៧០-** ក្នុងនីតិកាលទី៤នៃរដ្ឋសភា *ក្រសួងពាណិជ្ជកម្ម* សម្រេចបានសកម្មភាពមួយចំនួនដូចខាងក្រោម ៖

- ពង្រឹងការអនុវត្តកម្មវិធីវិស័យពាណិជ្ជកម្មដែលផ្អែកលើអភិក្រមគ្រប់គ្រងទូទាំងវិស័យ ដែលផ្តោតលើកិច្ចសម្រួលដល់ការធ្វើពាណិជ្ជកម្មនិងការអភិវឌ្ឍវិស័យឯកជន។
- បន្តអនុវត្តនយោបាយកាត់បន្ថយភាពក្រីក្រ តាមរយៈការជំរុញការនាំចេញផលិតផល ជាពិសេសផលិតផលកសិកម្ម សម្លៀកបំពាក់ និងផលិតផលផ្សេងទៀត។
- បន្តធ្វើសមាហរណកម្មដើម្បីសម្រេចគោលដៅបើកច្រកចូលទីផ្សារក្នុងតំបន់ និងអន្តរជាតិ និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។
- រៀបចំពិព័រណ៍កម្រិតជាតិនិងអន្តរជាតិឲ្យបានច្រើនថែមទៀត។
- ពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យទីផ្សារដើម្បីការពារសុខភាព និងសុខុមាលភាពអ្នកប្រើប្រាស់។
- ពង្រឹងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាព។
- ពង្រឹងភាពជាដៃគូជាមួយស្ថាប័នអន្តរជាតិនិងជាមួយបរទេស ដើម្បីធ្វើឲ្យកម្ពុជាក្លាយជាដៃគូអភិវឌ្ឍល្អនិងគួរជាទីទុកចិត្ត។
- រាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីសញ្ញាសម្គាល់ភូមិសាស្ត្រ។

**២.១៧១-** នៅក្នុងនីតិកាលទី៤នៃរដ្ឋសភា *ក្រសួងពាណិជ្ជកម្ម* បានបញ្ជូនសេចក្តីព្រាងច្បាប់មួយចំនួនទៅ*គណៈរដ្ឋមន្ត្រី* ដើម្បីសុំការពិនិត្យពិភាក្សានិងអនុម័ត ដូចខាងក្រោម៖

- ច្បាប់កិច្ចសន្យាពាណិជ្ជកម្ម ច្បាប់ស្តីពីការការពារការសម្គាល់ភូមិសាស្ត្រទំនិញ និងច្បាប់ស្តីពីការបង្កើតតុលាការពាណិជ្ជកម្ម(នៅចុងឆ្នាំ២០០៩)។

- ច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម(នៅឆ្នាំ២០១០)។
- ច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម( នៅចុងឆ្នាំ២០១១)។

**វិស័យទេសចរណ៍**

**២.១៧២-** កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈ បានទទួលរងឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក ការរីករាលដាលនៃជំងឺ A/H1N1 និងវិបត្តិនយោបាយនៃប្រទេសជិតខាងក្នុងតំបន់កន្លងមក។ វិបត្តិទាំងនេះ ជាឧបសគ្គដែលកាត់បន្ថយកំណើនទេសចរណ៍កម្ពុជា ដែលធ្លាប់សម្រេចបានកំណើន ផ.ស.ស. ពីរខ្ទង់ជាច្រើនឆ្នាំ។ នៅឆ្នាំ២០០៩ ចំនួនអ្នកទេសចរណ៍អន្តរជាតិបានធ្លាក់ចុះ ប៉ុន្តែនៅឆ្នាំ២០១២ ចំនួនទេសចរណ៍អន្តរជាតិបានកើនឡើងដល់៣,៥៨លាននាក់ ក្នុងនោះទេសចរមកពីប្រទេសអាស៊ីមានចំនួន២,៧១លាននាក់។ អ្នកទេសចរវៀតណាមឈរក្នុងលំដាប់លេខ១ បន្ទាប់មកអ្នកទេសចរ កូរ៉េ ចិន ជប៉ុន និងឡាវ។ អ្នកទេសចរណ៍មកពីប្រទេសខាងអឺរ៉ុបខាងលិច និងអាមេរិកមានការកើនឡើងពី១២-១៣%ក្នុងឆ្នាំ២០១២ ទោះបីជាសេដ្ឋកិច្ចខាងបស្ចិមប្រទេសនៅបន្តជួបការលំបាកនៅឡើយ។

**២.១៧៣-** ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ជាតិ ២០០៩-២០១៣ បានជួយក្រសួងទេសចរណ៍សម្រេចបានគោលដៅប្រកបដោយប្រសិទ្ធភាព ដោយមានការជួយគាំទ្រពីគំនិតផ្តួចផ្តើមសំខាន់ៗជាអាទិ៍ៈ

- យុទ្ធនាការផ្សព្វផ្សាយកម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ និងចលនាប្រឡងប្រណាំងទីក្រុងស្អាតរមណីយដ្ឋានស្អាតសេវាល្អ។
- គោលនយោបាយបើកចំហជើងមេឃ។
- ធ្វើឲ្យមានភាពងាយស្រួលក្នុងការទទួលទិដ្ឋាការ និងការទស្សនា ដូចជា ការលើកលែងទិដ្ឋាការចំពោះទេសចរវៀតណាមសម្រាប់ដោះស្រាយ ក្នុងដំណាក់កាលមានវិបត្តិ និងមានការអនុញ្ញាតជាគោលការពីរាជរដ្ឋាភិបាល ប្រជាពលរដ្ឋវៀតណាម ឡាវ ដែលនៅជិតព្រំដែនបានប្រើប្រាស់ Border Pass មកទស្សនាកម្ពុជាបាន៣ខេត្តសម្រាប់រយៈពេល១សប្តាហ៍។
- កិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន និងកិច្ចព្រមព្រៀងផ្សេងៗទៀត ជាពិសេសរាជរដ្ឋាភិបាលបានព្រមព្រៀងក្នុងការលើកលែងទិដ្ឋាការចំពោះពលរដ្ឋអាស៊ានទាំងអស់។
- ពង្រឹងសមត្ថភាពនិងយន្តការប្រឆាំងបទល្មើសពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទរាល់រូបភាពនៃអាជីវកម្មលើកុមារ។

- រាជរដ្ឋាភិបាលបានបន្តការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវគោក អាកាសយានដ្ឋាន កំពង់ផែ ប្រព័ន្ធទឹកស្អាត និងអគ្គិសនី)។
- កែលម្អនិងអភិវឌ្ឍបន្ថែមទៀតនូវផលិតផលទេសចរណ៍ ដោយផ្តោតទៅលើតំបន់អាទិភាពទាំងបួន (តំបន់សៀមរាបអង្គរ ភ្នំពេញនិងតំបន់ជុំវិញ តំបន់ឆ្នេរ និងតំបន់ ភូមិភាគឦសានដែលផ្អែកលើទេសចរអេកូធម្មជាតិ)។

**២.១៧៤-** វិស័យទេសចរណ៍បាននាំមកនូវចំណូលដល់ប្រទេសកម្ពុជាប្រមាណជា១ ៩១២លានដុល្លារអាមេរិក សម្រាប់ឆ្នាំ២០១១ និងប្រមាណជា២ ២១០លានដុល្លារអាមេរិក សម្រាប់ឆ្នាំ២០១២ ហើយបានជួយរកចំណូលច្រើនជាង៣ពាន់លានដុល្លារអាមេរិក តាមរយៈទេសចរណ៍ប្រយោល។ ទន្ទឹមនឹងនេះ យើងក៏បានកត់សម្គាល់ផងដែរថា ចំណូលពីទេសចរណ៍បានធ្លាយចេញទៅវិញប្រមាណជា២៥% ដែលភាគច្រើនផ្តោតទៅលើការនាំចូល ដើម្បីផ្គត់ផ្គង់ការរីកលូតលាស់នៃឧស្សាហកម្មទេសចរណ៍ មានដូចជា បន្លែ ផ្លែឈើ ត្រី សាច់ គ្រឿងសង្ហារិម កម្លាំងពលកម្ម។

**២.១៧៥-** ឆ្នាំ២០១២ វិស័យទេសចរណ៍បានចូលរួមបង្កើតការងារដោយផ្ទាល់ ប្រមាណជា ៣០០ ០០០កន្លែង ហើយការងារដោយប្រយោលរាប់ម៉ឺនកន្លែងផ្សេងទៀត។

**តារាងទី២.៧ : សូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឆ្នាំ២០០៩-២០១៣**

| សូចនាករ | ឯកតា | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| ទេសចរអន្តរជាតិ | លាននាក់ | ២,៦ | ២,៥១ | ២,៨៨ | ៣,៥៨ | ៤,២១ |
| ទេសចរជាតិ | លាននាក់ | ៧,០២ | ៧,៥៦ | ៧,៨១ | ៨,២៥ | ៨.៤០ |
| កម្លាំងពលកម្មបម្រើឲវិស័យទេសចរណ៍ | ពាន់នាក់ | ៣០៥ | ៣១៥ | ៣៣០ | ៣៥០ | ៣៨០ |
| ចំណូលទេសចរណ៍ | លានដុល្លារ | ១ ៥៦១ | ១ ៧៨៦ | ១ ៩១២ | ២ ២១០ | ២ ៥៤៧ |
| សេវាស្នាក់នៅ | បន្ទប់ | ៣៧ ៥២២ | ៣៩ ៧១៤ | ៤៣ ២៣៦ | ៤៦ ៤៤៦ | ៤៨ ៧៦៨ |

*ប្រភព : នាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ ក្រសួងទេសចរណ៍*

**២.១៧៦-** នៅក្នុងនីតិកាលទី៤នៃរដ្ឋសភា *ក្រសួងទេសចរណ៍* បានផ្តោតលើសកម្មភាពលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ ដើម្បីទាក់ទាញការទស្សនា ការពន្យារពេលស្នាក់នៅ និងការធ្វើវិនិយោគក្នុងវិស័យទេសចរណ៍។ សកម្មភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់ដោយ *ក្រសួងទេសចរណ៍* ជាសំខាន់ រួមមាន៖

- បន្តអនុវត្តគោលនយោបាយបើកចំហជើងមេឃ និងបន្តជំរុញយុទ្ធនាការឃោសនាផ្សព្វផ្សាយកម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ និងជំរុញចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាល្អ។
- បានពិនិត្យលទ្ធភាពក្នុងការជំរុញការលើកលែងទិដ្ឋាការចំពោះប្រទេសជប៉ុននិងកូរ៉េ។

- បានរៀបចំគេហទំព័រដើម្បីធ្វើការផ្សព្វផ្សាយពីវិស័យទេសចរណ៍កម្ពុជាទៅតាមប្រទេសដែលជាគោលដៅទីផ្សារសំខាន់ៗ។
- បានបន្តផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសផ្នែកឯកជនដើម្បីពង្រឹងការអនុវត្តច្បាប់នេះនិងដើម្បីលើកកម្ពស់គុណភាពនៃផលិតផលនិងសេវាកម្មទេសចរណ៍ប្រកបដោយប្រសិទ្ធភាពខ្ពស់។
- បានសម្រួលការធ្វើដំណើរនិងការដឹកជញ្ជូន និងការកាត់បន្ថយរបាំងមិនចាំបាច់នានាដែលបង្កការលំបាកដល់ភ្ញៀវទេសចរមកទស្សនាកម្ពុជា។
- បានបង្កើតផលិតផលទេសចរណ៍ថ្មី ព្រឹត្តិការណ៍ទេសចរណ៍ និងគោលដៅដែលមានការទាក់ទាញ (ដោយផ្អែកលើទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌និងធម្មជាតិ)។
- បានជំរុញចលនាទេសចរណ៍ក្នុងស្រុកឲ្យកាន់តែខ្លាំងក្លាថែមទៀតដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។
- បានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយបណ្តាប្រទេសនានាក្នុងតំបន់និងបណ្តាប្រទេសផ្សេងទៀតក្នុងពិភពលោក។
- បានពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយ ក្រសួង ស្ថាប័ន ផ្នែកឯកជន អង្គការជាតិនិងអង្គការអន្តរជាតិពាក់ពន្ធ័នានា ក្នុងការជំរុញកិច្ចអភិវឌ្ឍទេសចរណ៍កម្ពុជាឲ្យក្លាយជាគោលដៅទេសចរណ៍ ប្រកបដោយចីរភាព និងការទទួលខុសត្រូវ។
- បានជំរុញការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្សឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងស្របតាមកំណើននិងនិន្នាការទេសចរណ៍បច្ចុប្បន្ន។
- បានជំរុញការបញ្ជ្រាបយេនឌ័រក្នុងវិស័យទេសចរណ៍ ទាំងផ្នែកសាធារណៈ ផ្នែកឯកជននិងសហគមន៍មូលដ្ឋាន។
- បានធ្វើអង្កេតទេសចរណ៍និងរៀបចំបង្កើតស្ថិតិទេសចរណ៍។
- បានបន្តពង្រឹងសន្តិសុខនិងសុវត្ថិភាពសង្គមជូនភ្ញៀវទេសចរដែលបានមកទស្សនាប្រទេសកម្ពុជា ។

**២.១៧៧-** *ក្រសួងទេសចរណ៍* បានបញ្ចប់ការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ ផែនការ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ដែលក្នុងនោះមាន៖

- គោលនយោបាយជាតិលើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ច្បាប់ស្តីពីទេសចរណ៍។
- យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ជាតិ ២០១២-២០២០។
- គោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍អេកូទេសចរណ៍ជាតិ (កំពុងដំណើរការ) និង

- រៀបចំលិខិតបទដ្ឋានគតិយុត្តនានាដែលតម្រូវដោយច្បាប់ស្តីពីទេសចរណ៍ និងសកម្មភាពទេសចរណ៍។

**២.១៧៨-** បញ្ហាប្រឈមនានា ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍនវិស័យទេសចរណ៍ (២០០៩-២០១៣)៖

- ការអភិវឌ្ឍ ការរៀបចំកែច្នៃផលិតផលទេសចរណ៍ពុំទាន់មានស្តង់ដាគុណភាពផលិតផល និងសេវាទេសចរណ៍នៅឡើយ។
- ការផ្គត់ផ្គង់ទឹកស្អាតនិងថាមពលអគ្គិសនីនៅតាមតំបន់ទេសចរណ៍នៅមានកម្រិត។
- ភាពត្រួតស៊ីគ្នារវាងតួនាទីនិងភារកិច្ចនៃបណ្តាស្ថាប័នពាក់ព័ន្ធ។
- ផែនការថវិកានិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ពុំទាន់មានភាពស៊ីចង្វាក់គ្នា។
- មិនទាន់បានបង្កើតឡើងនូវក្រុមប្រឹក្សាភិបាលដើម្បីលើកទឹកចិត្តដល់វិស័យឯកជននិងសាធារណៈ និងឯកជនចូលរួមសហការគ្នាក្នុងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍។
- ការសិក្សាទីផ្សារទេសចរណ៍នៅមានកម្រិត ដោយមិនទាន់អាចវិភាគបានលម្អិតពីចំណែក និងប្រភេទ ឬតម្រូវការទីផ្សារថ្មីៗដែលរះឡើង។
- នៅក្នុងអាស៊ាន កម្ពុជាមិនទាន់មានការតភ្ជាប់តាមផ្លូវអាកាសគ្រប់ប្រទេសនៅឡើយ ជាពិសេសជាមួយឥណ្ឌូនេស៊ីនិងហ្វីលីពីន។
- កង្វះខាតនូវប្រព័ន្ធត្រួតពិនិត្យសម្រាប់ពិនិត្យគុណភាពម្ហូបអាហារតាមស្តង់ដាអន្តរជាតិ។
- ប្រព័ន្ធឬមធ្យោបាយសង្គ្រោះក្នុងករណីទេសចរណ៍ជួបគ្រោះថ្នាក់នៅមានកម្រិត ពិសេសនៅតាមគោលដៅទេសចរណ៍ឆ្ងាយៗក្នុងតំបន់ព្រៃនិងដែនសមុទ្រ។
- ការកំណត់តំបន់ដីសហគមន៍និងតំបន់ទេសចរណ៍នៅមិនទាន់បញ្ចប់នៅឡើយ។
- ការកាន់កាប់ដីឆ្នេរឬតំបន់ទេសចរណ៍ខុសច្បាប់។
- ច្បាប់មានភាពត្រួតស៊ីគ្នាដែលបង្កើតជាបញ្ហាដល់យុត្តាធិការ។

**២.១៧៩-** ការការពារនិងការលើកកម្ពស់មរតកវប្បធម៌ប្រពៃណីខ្មែរដ៏សម្បូរបែបគឺជាការងារអាទិភាពខ្ពស់របស់*រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤នៃរដ្ឋសភា*។ *ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ* បានបន្តការថែរក្សា ប្រាសាទបុរាណនានា សារមន្ទីរវត្ថុបុរាណ និងបានជំរុញលើកកម្ពស់យ៉ាងខ្លាំងក្លានូវសិល្បៈខ្មែរ រួមទាំង របាំប្រពៃណីខ្មែរ ចម្រៀង និងក្បាច់ចម្លាក់។ ក្រសួងក៏បានជំរុញលើកទឹកចិត្តដល់ការធ្វើឲ្យរស់រានឡើងវិញនូវផលិតផលនិងទីផ្សារសិប្បកម្មខ្មែរ។ ការការពារនិងការលើកកម្ពស់មរតកវប្បធម៌ប្រពៃណីខ្មែរដ៏សម្បូរបែបនេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្រដល់កំណើនវិស័យទេសចរណ៍។

២.១៨០- នៅក្នុងនីតិកាលទី៤នៃរដ្ឋសភា *ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ* បានអនុវត្តកម្មវិធីគម្រោងចំនួន២៣ ដែលទាក់ទងនឹង៖

- ការពារប្រាសាទបុរាណ រួមទាំងកែលម្អផ្លូវថ្នល់ និងស្ពាន ដើម្បីងាយស្រួលធ្វើដំណើរទៅប្រាសាទបុរាណទាំងនោះ។
- ថែរក្សាការពារសារមន្ទីរវត្ថុបុរាណ។
- សាងសង់ការិយាល័យអភិរក្សនៅខេត្តនិងមជ្ឈមណ្ឌលកុលសម្ព័ន្ធនៅភូមិភាគឦសាន។
- សាងសង់សាលតាំងពិព័រណ៍ផលិតផលវប្បធម៌និងសាលសម្រាប់ការបង្ហាញពីរបាំប្រពៃណីខ្មែរ។

## ៥.២- ការបង្កើតការងារនិងធានាលក្ខខណ្ឌការងារល្អប្រសើរ

២.១៨១- រាជរដ្ឋាភិបាលកម្ពុជាបន្តគោលដៅរយៈពេលវែង ក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន ការកាត់បន្ថយភាពក្រីក្រ និងការពន្លឿនកំណើនសេដ្ឋកិច្ច។ ទោះជាដូចនេះក្ដី ការបង្កើតកាលានុវត្តភាពការងារថ្មី ក៏អាស្រ័យលើកម្រិតនៃការវិនិយោគរបស់ផ្នែកឯកជន ក្នុងវិស័យផ្លូវការនិងមិនមែនផ្លូវការ នៅតំបន់ទីប្រជុំជននិងតំបន់ជនបទផងដែរ។ ការធានាឲ្យអ្នកចូលបម្រើការងារថ្មីមានជំនាញសមស្របទៅនឹងតម្រូវការរបស់ការងារថ្មី គឺជាបញ្ហាប្រឈមមួយដែលទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងជាច្រើនថែមទៀត ដែលផ្ដោតលើការពង្រីកការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។

២.១៨២- *ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ* បានផ្ដល់សេវារកការងារឲ្យធ្វើដើម្បីជួយដល់អ្នកស្វែងរកការងារធ្វើនៅក្នុងវិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស។

២.១៨៣- ការរីកចម្រើននៃវិស័យការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គឺជាលទ្ធផលប្រកបដោយផ្លែផ្កាក្នុងការអនុវត្តកម្មវិធីនយោបាយការងារនិងសមធម៌ ចាប់ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣ ហើយសមិទ្ធផលដែលសម្រេចបាន មានដូចជា៖

- បានដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងពីចំនួន៥០ដុល្លារអាមេរិកទៅ៨០ដុល្លារអាមេរិក ព្រមទាំងលើកទឹកចិត្តឲ្យនិយោជកផ្ដល់ប្រាក់បំណាច់ផ្សេងៗចំនួន២០ដុល្លារអាមេរិកក្នុង១ខែបន្ថែមទៀត។
- បានរំដោះកុមារចំនួន៤៥ ០០០នាក់ ដែលមិនទាន់គ្រប់អាយុសម្រាប់ចូលរួមក្នុងវិស័យពលកម្មពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២។
- បានបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសថៃ ម៉ាឡេស៊ី និងជប៉ុន ចំនួន៨៨ ៨៤២នាក់ តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងបានបញ្ជូនពលករចំនួន១៦ ៨៩២នាក់ទៅធ្វើ

ការនៅសាធារណរដ្ឋកូរ៉េក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) តាមរយៈគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២។

- បានធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធសុខភាពនិងសុវត្ថិភាពការងារ តាមរយៈការចុះធ្វើអធិការកិច្ចពេទ្យការងារចំនួន១ ៣៣៨លើក នៅក្នុងសហគ្រាសគ្រឹះស្ថានចំនួន៥៨៦ ក្នុងឆ្នាំ២០១២។
- បានផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារដល់កម្មករនិយោជិតចំនួនជាង ៣៧ ០០០នាក់ ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ ហើយរហូតមកដល់ត្រីមាសទី១ ឆ្នាំ២០១៣នេះ ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ ត្រូវបានពង្រីកវិសាលភាពគ្របដណ្តប់ចំនួន២៤ រាជធានី ខេត្តនៅទូទាំងប្រទេស។
- បានបណ្តុះបណ្តាលជំនាញរយៈពេលខ្លីដល់យុវជនយុវនារី និងកម្មករកម្មការិនីដែលបាត់បង់ និងគ្មានការងារធ្វើចំនួន៥៩ ៤៦០នាក់ ស្មើនឹង២ ២៩៣វគ្គ ចាប់ពីឆ្នាំ២០០៩ដល់ជំហានទី១ ឆ្នាំ២០១៣។
- បានអនុញ្ញាតឲ្យបង្កើតបន្ថែមនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈថ្មីចំនួន៧ តាមបណ្តាខេត្ត និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឯកជន និងអង្គការមិនមែនរដ្ឋាភិបាលថ្មីចំនួន៦ទៀត។
- បានធ្វើឲ្យប្រសើរឡើងនូវស្ថានភាពវិស័យព័ត៌មានទីផ្សារការងារនិងសេវាការងារតាមរយៈការប្រមូលអ្នកស្វែងរកការងារធ្វើសរុបចំនួន២៧ ៨៨៩នាក់ និងបានផ្តល់ការណែនាំដល់អ្នកស្វែងរកការងារធ្វើចំនួន៧ ៩៨៤នាក់ ព្រមទាំងបានប្រមូលព័ត៌មានជ្រើសរើសបុគ្គលិកចំនួន៩៥ ១៤២នាក់ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១២។
- បានបង្កើតនូវគណៈកម្មការទទួលបន្ទុកការងារយេនឌ័រនៅក្នុង*ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*។
- បានប្រជុំផ្សព្វផ្សាយនិងបែងចែកភារកិច្ច ដើម្បីអនុវត្តអនុសាសន៍៤២ចំណុចលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)។
- បានចូលរួមសរសេររបាយការណ៍ជាតិលើកទី៤និងទី៥ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីនៅកម្ពុជា។
- បានផ្តល់វគ្គបំពាក់បំប៉នលើជំនាញរដ្ឋបាល បុគ្គលិកហិរញ្ញវត្ថុនិងផែនការ ស្ថិតិ និងនីតិកម្មដល់មន្ត្រីរាជការចំនួន២៣៧នាក់នៅឆ្នាំ២០១១និងឆ្នាំ២០១២។
- បានបង្កើតកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន តាមរយៈការចូលរួមសិក្ខាសិលាអាស៊ានស្តីពីការធានារ៉ាប់រងលើភាពគ្មានការងារធ្វើ វិធានការសន្តិសុខលើប្រាក់ចំណូល និងគោលនយោបាយទីផ្សារសកម្ម។

២.១៨៤- ទន្ទឹមនឹងសមិទ្ធផលជាច្រើនត្រូវបានបង្កើតឡើង ភាពប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែង សំដៅទាក់ទាញបាននូវការវិនិយោគឯកជនថ្មីៗបន្ថែមទៀត។ ភាពប្រឈមទាំងនោះមានដូចជា៖

### ក- ស្ថានភាពប្រឈមក្នុងវិស័យពលកម្ម

- លក្ខខណ្ឌការងារមួយចំនួននៅតាមសហគ្រាសគ្រឹះស្ថានមិនទាន់មានភាពល្អប្រសើរ។ បរិយាកាសនិងបរិស្ថាននៅកន្លែងធ្វើការ និងក្បែរកន្លែងធ្វើការ នៅមិនទាន់បានរៀបចំឲ្យបានល្អប្រសើរនៅឡើយដែលកន្លងមកគ្រោះថ្នាក់ការងារ ក៏ដូចជាការចុះខ្សោយនៃសុខភាព និងការដួលសន្លប់របស់កម្មករនិយោជិតនៅវិស័យវាយនភណ្ឌកាត់ដេរនិងផលិតស្បែកជើងមានការកើតឡើងផងដែរ។
- កង្វះខាតបទប្បញ្ញត្តិគ្រប់គ្រងក្រុមហ៊ុន ឬវិស័យឯកជនដែលផ្តល់សេវារកការងារឲ្យពលករធ្វើការក្នុងស្រុក។
- កង្វះខាតបទប្បញ្ញត្តិមួយចំនួនសម្រាប់គ្រប់គ្រងផ្នែកនីមួយៗនៃវិស័យការងារ ដូចជាច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីតុលាការការងារជាដើម។
- កង្វះខាតអ្នកជំនាញសិក្សាស្រាវជ្រាវនិងចងក្រងឲ្យបានច្បាស់លាស់នូវគោលនយោបាយស្តីពីការងារនិងមុខរបរ។
- កង្វះខាតការគ្រប់គ្រង និងការផ្តល់ឯកសារស្របច្បាប់ជូនពលករខ្មែរដែលឆ្លងដែនធ្វើការងារព្រឹកវិលល្ងាចនិងតាមរដូវ ហើយមិនត្រឹមតែប៉ុណ្ណោះ នីតិវិធីនិងការរៀបចំបែបបទបញ្ជូនពលករទៅបរទេសមានរយៈពេលវែង។
- កង្វះខាតយន្តការគ្រប់គ្រងជនបរទេសដែលចូលមកធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- កង្វះខាតការបណ្តុះបណ្តាលដែលប្រកបដោយប្រសិទ្ធភាពដល់មន្ត្រីអធិការកិច្ចការងារ។
- កង្វះខាតការយល់ដឹងពីសំណាក់និយោជកពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មកុមារ ឲ្យស្របទៅតាមច្បាប់បទប្បញ្ញត្តិនិងអនុសញ្ញាអន្តរជាតិ។
- កង្វះខាតពលករដែលមានជំនាញស្របទៅតាមតម្រូវការទីផ្សារការងារនៅបរទេស។

### ខ- បញ្ហាប្រឈមក្នុងវិស័យរបបសន្តិសុខសង្គម

២.១៨៥- របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបញ្ញត្តិនៃច្បាប់ ស្តីពីការងារ ដែលទើបតែដាក់ឲ្យដំណើរការបានរយៈពេល៤ឆ្នាំប៉ុណ្ណោះ ដូច្នេះមានការលំបាកជាច្រើនអំឡុងពេលអនុវត្តពីព្រោះច្បាប់ នីតិវិធី និងបែបបទនៃការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ ការចុះបញ្ជិកា និងបង់វិភាគទានត្រូវធ្វើតាមប្រព័ន្ធព័ត៌មានវិទ្យា គឺបង្កការលំបាកនិងស្មុគស្មាញដល់អ្នកប្រើប្រាស់ ជាពិសេសសហគ្រាសខ្នាតតូចដែលពុំមានធនធានមនុស្ស

គ្រប់គ្រាន់។

២.១៨៦- ការអនុវត្តរបបធានារ៉ាប់រងសន្តិសុខសង្គមមានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងការអនុវត្តកាតព្វកិច្ច ការចុះបញ្ជិកា ការបង់វិភាគទាន ការរាយការណ៍ពីចំនួនប្រាក់បៀវត្ស និងកម្មករនិយោជិតមិនគ្រប់តាមចំនួនជាក់ស្តែង និងការចុះឯកសារបញ្ជាក់ពីអគ្រានុកូលដ្ឋាន ដែលធ្វើឡើងដោយនិយោជក កម្មករ និយោជិត និងអ្នកផ្តល់សេវាវេជ្ជសាស្ត្រ។ ច្បាប់នានាពាក់ព័ន្ធនឹងការអនុវត្តរបបធានារ៉ាប់រងសន្តិសុខសង្គមក៏មានភាពស្មុគស្មាញ។ ដូច្នេះកត្តាទាំងអស់នេះជាហេតុនាំឲ្យអ្នករស់នៅក្នុងបន្ទុកមិនបានទទួលតាវកាលិកឧត្តរជីវី នៅពេលដែលជនរងគ្រោះទទួលគ្រោះថ្នាក់ការងាររហូតដល់បាត់បង់ជីវិត ទោះបីជាជនរងគ្រោះបានចុះកិច្ចសន្យាជាមួយបេឡាជាតិរបបសន្តិសុខសង្គមក៏ដោយ។

## គ- បញ្ហាប្រឈមក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

២.១៨៧- ប្រជាពលរដ្ឋកម្ពុជាមួយចំនួនធំពុំសូវឲ្យតម្លៃទៅលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ភាគច្រើននៃប្រជាពលរដ្ឋកម្ពុជាមាននិន្នាការនិងជំរុញលើកទឹកចិត្តឲ្យកូនចៅបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ជាហេតុធ្វើឲ្យការចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមានកម្រិតទាប។

២.១៨៨- គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការទីផ្សារការងារ ដោយកន្លងមកយើងមានបញ្ហាប្រឈមមួយចំនួនដូចជាកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍សម្ភារៈ ឯកសារបច្ចេកទេស និងបទដ្ឋានគតិយុត្ត ពាក់ព័ន្ធស្ថិតិការងារ ព័ត៌មានទីផ្សារការងារ បុគ្គលិកមន្ត្រីរាជការគ្រូដែលមានសមត្ថភាពជំនាញ បទពិសោធកម្មវិធីសិក្សាពុំទាន់ឆ្លើយតបទៅនឹងទីផ្សារការងារ។ល។ និងមានកង្វះការចូលរួមសហការនិងឧបត្ថម្ភពីវិស័យឯកជន។

២.១៨៩- វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានជួបប្រទះនឹងបញ្ហាប្រឈម មួយចំនួនដូចជា៖

- កង្វះខាតភាពស៊ីចង្វាក់គ្នាក្នុងយន្តការសម្របសម្រួលដល់ការបណ្តុះបណ្តាល។
- កង្វះខាតការយល់ដឹងពីតម្លៃនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងភាពមាននិន្នាការជំរុញលើកទឹកចិត្តកូនចៅទៅបន្តការសិក្សានៅកម្រិតឧត្តមសិក្សាពី សំណាក់ប្រជាជន។
- កម្មវិធីនិងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការទីផ្សារការងារ។
- កង្វះខាតឧបករណ៍បរិក្ខារបច្ចេកទេសរោងជាងនិងបន្ទប់ពិសោធន៍។

- កង្វះខាតព័ត៌មានទីផ្សារការងារនិងប្រភេទជំនាញ ដែលឆ្លើយតបតាមតម្រូវការទីផ្សារការងារ។
- កង្វះខាតធនធានហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការចូលរួមសហការនិងឧបត្ថម្ភពីវិស័យឯកជន។
- កង្វះខាតពលករដែលមានជំនាញសម្រាប់ឧស្សាហកម្មដែលកំពុងមានសន្ទុះដើបឡើង ជាហេតុធ្វើឲ្យគ្មានភាពស៊ីចង្វាក់គ្នារវាងតម្រូវការនិងការផ្គត់ផ្គង់កម្លាំងពលកម្ម។

## ឃ- បញ្ហាប្រឈមក្នុងវិស័យព័ត៌មានទីផ្សារការងារ

២.១៩០- *ទីភ្នាក់ងារជាតិមុខរបរ និងការងារ* (ទ.ជ.ម.ក.) គឺជាទីភ្នាក់ងារជាតិដែលទើបតែបានដាក់ឲ្យដំណើរការ បានរយៈពេលទើបតែ៣ឆ្នាំប៉ុណ្ណោះ(២០១០-២០១៣)។ កន្លងមកការ អនុវត្តការងារក្នុងវិស័យនេះបានជួបបញ្ហាប្រឈមមួយចំនួន រួមមានៈ

- ប្រជាពលរដ្ឋមិនទទួលបានសេវាការងារនិងព័ត៌មានទីផ្សារការងារគ្រប់តំបន់និងស៊ីជម្រៅ ពីព្រោះហេដ្ឋារចនាសម្ព័ន្ធនៃការផ្តល់សេវា បណ្តុំសេវា និងវិសាលភាពនៃការផ្តល់សេវាគ្របដណ្តប់បានតិចតួចនៅឡើយ ជាពិសេសមិនទាន់គ្របដណ្តប់ដល់តំបន់ជនបទនិងតំបន់ដាច់ស្រយាលដទៃទៀត។
- ការយល់ដឹងជាសាធារណៈអំពីសេវាការងារ និងព័ត៌មានទីផ្សារការងារនៅមានកម្រិតតិចតួច ជាពិសេសអ្នករស់នៅតំបន់ជនបទ ដែលនាំឲ្យអ្នកប្រើប្រាស់មិនបានទាញយកប្រយោជន៍ពីសេវាដែលបានផ្តល់ជូន និងនាំឲ្យការសហការរបស់ភាគីអ្នកស្វែងរកការងារធ្វើ អ្នកផ្តល់ការបណ្តុះបណ្តាល អប់រំ និងអ្នកពាក់ព័ន្ធ សាធារណជនទូទៅ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់មិនទាន់មានភាពប្រសើរនៅឡើយ។
- អ្នកប្រើប្រាស់សេវា ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងនិយោជកមិនបានផ្តល់កិច្ចសហការល្អជាមួយទ.ជ.ម.ក.ទេ មិនមានព័ត៌មានត្រឡប់មកវិញពីលទ្ធផលនៃការប្រើប្រាស់សេវាពិសេសគឺខ្វះលទ្ធភាពក្នុងការពង្រីកសេវាឲ្យបានទូលំទូលាយនិងតាមតម្រូវការ។
- មន្ត្រីដែលបម្រើការការងារនៅទ.ជ.ម.ក. មិនទាន់ទទួលបានការលើកទឹកចិត្តបន្ថែម។
- ប្រភពទិន្នន័យនិងព័ត៌មានដែលមានស្រាប់ពាក់ព័ន្ធនឹងការចងក្រងព័ត៌មានទីផ្សារការងារនៅមានកម្រិត។
- កង្វះការយល់ដឹងពីសំណាក់ប្រជាពលរដ្ឋអំពីសេវាការងារ និងព័ត៌មានទីផ្សារការងាររបស់ ទ.ជ.ម.ក ហើយការសហការរវាងភាគីពាក់ព័ន្ធ ដូចជា អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលសាធារណជនទូទៅ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់មិនទាន់មានភាពប្រសើរនៅឡើយ។

- កង្វះខាតប្រភពទិន្នន័យនិងព័ត៌មានទីផ្សារការងារសម្រាប់ចងក្រង ហើយដំណើរការប្រមូលទិន្នន័យបឋមប្រើប្រាស់ពេលវេលានិងធនធានច្រើន។

### ខ- បញ្ហាប្រឈមក្នុងវិស័យយេនឌ័រ

- កង្វះខាតការយល់ដឹងអំពីយេនឌ័រ អនុសញ្ញាCEDAW និងច្បាប់ពាក់ព័ន្ធនៅក្នុងចំណោមមន្ត្រីបច្ចេកទេស ទាំងថ្នាក់កណ្តាលនិងរាជធានី ខេត្ត។
- កង្វះខាតនូវច្បាប់និងគោលការណ៍ណែនាំក្នុងការជ្រើសរើស ការដំឡើងឋានៈ ការពង្រឹងសមត្ថភាព និងការចូលរួមរបស់មន្ត្រីរាជការ។
- កង្វះខាតការបញ្ជ្រាបយេនឌ័រនៅតាមបណ្តារាជធានី ខេត្ត ចំណុះក្រសួង និងតាមបណ្តាសហគ្រាសគ្រឹះស្ថាន។
- កង្វះខាតថវិកា មធ្យោបាយ និងសម្ភារៈក្នុងការបំពេញការងារផ្សព្វផ្សាយអំពីគោលនយោបាយ និងច្បាប់ទាក់ទងទៅនឹងបញ្ហាសមភាពរវាងស្ត្រីនិងបុរសក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ៥.៣- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម

២.១៩១- ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ចូលរួមចំណែកផ្តល់អត្ថប្រយោជន៍ដល់បណ្តាសហគមន៍ជនបទ ក្នុងដំណើរការកែច្នៃ ការបញ្ចូលតម្លៃបន្ថែមទៅក្នុងផលិតផល ព្រមទាំងការបង្កើតការងារ។ ការអភិវឌ្ឍនេះក៏បានបង្កើតទំនាក់ទំនងល្អជាមួយវិស័យពាណិជ្ជកម្មនិងសហគ្រាសធំៗផ្សេងទៀត។ ដើម្បីសម្រេចបាននូវកិច្ចការទាំងអស់នេះ *រាជរដ្ឋាភិបាលកម្ពុជា* បានកាត់បន្ថយជាអប្បបរមានូវថ្លៃចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ក៏ដូចជា ចំណាយចុះបញ្ជីក្រុមហ៊ុន។ កម្ចីអាជីវកម្មរបស់សហគ្រាសធុនតូចនិងមធ្យម បានកើនឡើងគួរឲ្យកត់សម្គាល់តាមរយៈគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានា។

២.១៩២- *ក្រសួងពាណិជ្ជកម្ម*បានយកចិត្តទុកដាក់អនុវត្តកំណែទម្រង់នីតិវិធីនានានៃការចុះបញ្ជីពាណិជ្ជកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យមទាំងអស់។ វេលាកំណត់ដែលទាមទារសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មត្រូវបានកាត់បន្ថយមកនៅត្រឹម៣-៥ថ្ងៃវិញ។ ដំណើរការបំពេញឯកសារក្នុងការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យមមួយត្រូវបានកាត់បន្ថយ។ ការតម្រូវឲ្យមានរបាយការណ៍ស្តីពីការផ្តន្ទាទោសបទល្មើសឧក្រិដ្ឋ និងដំណោះស្រាយបញ្ជាក់ការយល់ព្រមមិនចាំបាច់ប្រើពេលវេលាយូរ។ តម្រូវការទុនទាំងអស់ក្នុងទម្រង់នៃបញ្ញើធនាគារសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានកាត់បន្ថយពី២០លានរៀលទៅ៤លានរៀល។ ថ្លៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មមានចំនួន១ ៦០០ ០០០លានរៀល។ រីឯថ្លៃរដ្ឋបាលសម្រាប់ក្រុមហ៊ុនឯកកម្មសិទ្ធិមាន

ចំនួន៣០០ ០០០រៀល។ បន្ទាប់ពីកំណែទម្រង់បន្តបន្ទាប់មកចំនួនក្រុមហ៊ុនដែលត្រូវបានចុះបញ្ជីមានការកើនឡើងរៀងរាល់ឆ្នាំ។

**២.១៩៣-** រោងចក្រថ្មីចំនួន៩០៧បានចុះបញ្ជីនៅ*ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* នៅឆ្នាំ ២០១២។ រោងចក្រទាំងនោះបានផ្តល់ការងារឲ្យកម្មករចំនួន៥៥៩ ៥៨៥នាក់ ក្នុងនោះ៤៩២ ៥២០ នាក់ គឺជាកម្មករផ្នែករោងចក្រកាត់ដេរ។

**២.១៩៤-** វឌ្ឍនភាពគួរកត់សម្គាល់ក្នុងការជំរុញសហគ្រាសធុនតូចនិងមធ្យម បានបង្ហាញពីៈ

- *ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចក្នុងការផ្តល់សេវាសាធារណៈ៖*
  - ➢ បានបង្កើតឡើងនូវប្រកាសអន្តរក្រសួងស្តីពីការកំណត់កម្រៃសេវាចំពោះការបង្កើត និងកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម និងការពិន័យលើករណីល្មើសច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងប្រកាសអន្តរក្រសួងស្តីពីកាអនុវត្ត និងការរៀបចំសម្រប សម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ។
  - ➢ បានអនុវត្តនូវកម្មវិធីវិសហមជ្ឈការ។
  - ➢ បានជំរុញការស្រង់ស្ថិតិរោងចក្រ សិប្បកម្ម តាមផ្នែក អនុផ្នែក ឲ្យបានត្រឹមត្រូវតាមលេខកូដ និងបានពង្រឹងការគ្រប់គ្រង និងគុណភាពស្ថិតិរោងចក្រ សិប្បកម្ម តាមប្រព័ន្ធព័ត៌មានវិទ្យា។
  - ➢ ការបង្កើតមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។

- *ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម៖*
  - ➢ ដើម្បីជំរុញតម្លាភាពក្នុងការអនុវត្តច្បាប់លើវិស័យសហគ្រាសធុនតូចនិងមធ្យម ក្រសួងបានបង្កើតយន្តការមួយចំនួនដូចជាយន្តការដោះស្រាយបណ្តឹងតវ៉ានិងការងារអធិការកិច្ចដោយបានចុះធ្វើអធិការកិច្ចរោងចក្រនិងសិប្បកម្ម និងបានរៀបចំវេទិកាផ្សព្វផ្សាយច្បាប់វិស័យឧស្សាហកម្មជូនអាជ្ញាធរមូលដ្ឋាន ឧស្សាហករនិងសិប្បករ នៅតាមបណ្តារាជធានីខេត្ត។ ព្រមទាំងបានចូលរួមអនុវត្តគម្រោងវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលជានីតិវិធីក្នុងការវិភាគវាយតម្លៃលើបន្ទុកចំណាយទាក់ទងនឹងការពង្រឹងនិងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត។
  - ➢ បានរៀបចំប្រកាសស្តីពីនីតិវិធីនិងបែបបទស្នើសុំបង្កើតរោងចក្រនិងសិប្បកម្ម ដើម្បីសម្រួលដល់សិប្បករ ឧស្សាហករ ក្នុងការស្នើសុំប្រកាសបង្កើត និងវិញ្ញាបនបត្រដំណើរការរោងចក្រនិងសិប្បកម្មឲ្យមានភាពងាយស្រួលនិងទាន់ពេលវេលា។

- ➢ បានធ្វើសេចក្តីជូនដំណឹងដល់ម្ចាស់រោងចក្រនិងសិប្បកម្ម ស្តីពីការបំពេញព័ត៌មានក្នុងរបាយការណ៍ផលិតកម្មប្រចាំឆ្នាំនិងផែនការការងារឆ្នាំបន្ទាប់ ដើម្បីក្រសួងមានលទ្ធភាពគ្រប់គ្រងស្ថិតិរោងចក្រ សិប្បកម្ម និងរៀបចំគោលនយោបាយរបស់*រាជរដ្ឋាភិបាល* លើវិស័យសហគ្រាសកម្មន្តសាល។

- *ពង្រឹងភាពជាដៃគូជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍ៖*

- ➢ ដើម្បីដោះស្រាយបញ្ហាធុរកិច្ចជូនសហគ្រាសធុនតូចនិងមធ្យម ក្រសួងបានពង្រឹងការអនុវត្តតួនាទីរបស់អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម និងក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូចនិងមធ្យម។
- ➢ បានយកចិត្តទុកដាក់លើបញ្ហាកង្វះខាតហិរញ្ញវត្ថុ និងការទទួលបានហិរញ្ញប្បទានរបស់សហគ្រាសធុនតូចនិងមធ្យម។ ដោយបានសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និង*ធនាគារជាតិនៃកម្ពុជា* ក្រសួងបានរៀបចំវេទិកាថ្នាក់ជាតិ រវាងសហគ្រាសធុនតូចនិងមធ្យម និងគ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីពិភាក្សារកដំណោះស្រាយធ្វើយ៉ាងណាឲ្យសហគ្រាសធុនតូចនិងមធ្យមមានលទ្ធភាពទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានហិរញ្ញវត្ថុ។
- ➢ បានចូលរួមសហការអនុវត្តកម្មវិធីរបស់ដៃគូអភិវឌ្ឍផ្សេងៗ ក្នុងការជំរុញការអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យម។

- *ការកសាងគោលនយោបាយនានាសម្រាប់គាំទ្រដល់ឧស្សាហកម្មនិងសហគ្រាសធុនតូចនិងមធ្យម៖*

- ➢ បានលើកគម្រោងផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ និងលើកទឹកចិត្តសិប្បករតាមរយៈកិច្ចសហការជាមួយដៃគូអភិវឌ្ឍក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គ និងក្របខ័ណ្ឌការងារអាស៊ាន។
- ➢ បានលើកគម្រោងផែនការអភិវឌ្ឍន៍ឧស្សាហកម្មច្នៃប្រឌិត ដោយមានការស្វែងរកគំនិតនិងប្រភពព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មច្នៃប្រឌិត ដើម្បីជួយដល់សិប្បករ ឧស្សាហករក្នុងស្រុក ដែលផលិតនូវផលិតផលក្នុងស្រុកពិតប្រាកដ។

- *ការជំរុញរៀបចំឲ្យមានផលិតផលជាតិ អនុលោមតាមស្តង់ដាជាតិនិងអន្តរជាតិ* បានបង្កើតឲ្យមានវិទ្យាស្ថានស្តង់ដាជាតិ ដើម្បីធានាគុណភាពផលិតផលអនុលោមតាមស្តង់ដាតំបន់និងអន្តរជាតិ។ ការអនុវត្តវិធានការ រួមមាន៖

- ➢ បានរៀបចំបង្កើតស្តង់ដាផលិតផលចាំបាច់ ដើម្បីជាបង្អែកក្នុងការលើកកម្ពស់គុណភាពផលិតផលជាតិ។

- ស្តង់ដាចំនួន៧៥ ត្រូវបានក្រុមប្រឹក្សាស្តង់ដាជាតិអនុម័តឲ្យរៀបចំជាស្តង់ដាអាទិភាព។
- បានផ្សព្វផ្សាយអំពីសារៈសំខាន់នៃស្តង់ដាជាតិនិងអន្តរជាតិ និងជំរុញឲ្យឧស្សាហករកម្ពុជាទទួលអនុវត្តតាមដើម្បីធានាគុណភាពផលិតផលនិងសេវាកម្មរបស់ខ្លួន។
- បានពង្រឹងរចនាសម្ព័ន្ធវាយតម្លៃគុណភាព ដោយអនុលោមតាមស្តង់ដា។
- បានបង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គភាពស្តង់ដាជាតិ តំបន់ និងអន្តរជាតិ។

• *ការជំរុញលើកកម្ពស់ផលិតភាពនិងសមត្ថភាពឧស្សាហករនិងសិប្បករកម្ពុជា* បានបង្កើតមជ្ឈមណ្ឌលផលិតកម្មជាតិដើម្បីលើកកម្ពស់ផលិតភាពនិងកាត់បន្ថយតម្លៃផលិតកម្ម។

- បង្កើតគោលនយោបាយនិងយុទ្ធសាស្ត្រនានាដើម្បីជំរុញលើកកម្ពស់បច្ចេកទេសនិងបច្ចេកវិទ្យា។
- ផ្សព្វផ្សាយផលិតភាពនិងបច្ចេកទេស។
- ជំរុញការបណ្តុះបណ្តាលស្តីពីផលិតភាពនិងបច្ចេកទេសផ្សេងៗដល់ឧស្សាហករ សិប្បករ។

• *ការបង្កើតនិងការអនុវត្តគោលនយោបាយពង្រឹងការងារកម្មសិទ្ធិឧស្សាហកម្ម៖*

- បានពង្រឹងនិងបានអនុវត្តការផ្តល់សេវាការពារកម្មសិទ្ធិឧស្សាហកម្ម។
- បានជំរុញនិងផ្សព្វផ្សាយការបណ្តុះបណ្តាលចំណេះដឹងស្តីពីកម្មសិទ្ធិឧស្សាហកម្ម។
- បានបង្កើននិងពង្រឹងការអនុវត្តដំណើរការនៃមជ្ឈមណ្ឌលច្នៃប្រឌិតនិងបង្កើតថ្មី។
- បានជំរុញនិងពង្រឹងទំនាក់ទំនងជាមួយភ្នាក់ងារកម្មសិទ្ធិបញ្ញា និងអ្នកដាក់ពាក្យស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការចុះបញ្ជីគំនូរឧស្សាហកម្ម។
- បានបង្កើតនិងផ្តល់សេវាទីប្រឹក្សាយោបល់លើកម្មសិទ្ធិឧស្សាហកម្ម។
- បានជំរុញសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិ ក្នុងការអនុវត្តកម្មសិទ្ធិឧស្សាហកម្ម។

• *ការបង្កើតនិងការអនុវត្តគោលនយោបាយពង្រឹងការងារមាត្រាសាស្ត្រ៖*

- បានបង្កើតលិខិតបទដ្ឋានគតិយុត្ត និងបទបញ្ជាបច្ចេកទេសដើម្បីគ្រប់គ្រងការអនុវត្តដំណើរការងារមាត្រាសាស្ត្រជាតិ។
- បានបង្កើតរចនាសម្ព័ន្ធគ្រប់ផ្នែកមាត្រាសាស្ត្រ រួមមាន មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងមជ្ឈមណ្ឌលត្រួតពិនិត្យផ្ទៀងផ្ទាត់ទាំង៥តំបន់។
- បានផ្សព្វផ្សាយនិងបណ្តុះបណ្តាលការងារមាត្រាសាស្ត្រចំនួន១៥ខេត្ត។

➢ បានធ្វើកិច្ចប្រតិបត្តិការជាមួយអង្គការមាត្រាសាស្ត្រអន្តរជាតិ និងអង្គការមាត្រាសាស្ត្រប្រចាំតំបន់។

២.១៩៥- *ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល* ក៏បានអនុវត្តនូវសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- បានពង្រឹងយន្តការស្តីពីសិទ្ធិការពារឧស្សាហកម្មដើម្បីជំរុញឧស្សាហកម្មនវានុវត្ត។
- បានពង្រឹងភាពជាដៃគូជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍ។
- បានជំរុញផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាទាន់សម័យ។
- បានផ្តល់ការបណ្តុះបណ្តាលនិងជំនាញ។
- ពង្រឹងបទដ្ឋានច្បាប់។
- បានបន្តអនុវត្ត "ភូមិមួយ ផលិតផលមួយ" នៅតាមតំបន់ជនបទ។

២.១៩៦- ដើម្បីស្រូបយកកាលានុវត្តភាព នៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងពិភពលោក ចាំបាច់ត្រូវឈរលើខឿនសេដ្ឋកិច្ចដែលផ្អែកលើវិស័យឧស្សាហកម្ម ដោយជំរុញឲ្យមានពិពិធកម្មនៃមូលដ្ឋានឧស្សាហកម្មនៃសហគ្រាសធុនតូចនិងមធ្យម និងការផ្លាស់ប្តូរឆ្ពោះទៅរកផលិតផលមានតម្លៃបន្ថែមខ្ពស់។ ក្នុងន័យនេះ បញ្ហាចម្បងៗដែលកម្ពុជាជួបប្រទះ មិនមែនស្វែងរកតែទីផ្សារប៉ុណ្ណោះទេ តែថែមទាំងត្រូវផលិតផលិតផលច្រើនប្រភេទដែលមានភាពប្រកួតប្រជែងដើម្បីដណ្តើមទីផ្សារ។ ភាពប្រឈមមួយចំនួនដែលរាំងស្ទះដល់ការបង្កើនផលិតភាពនិងភាពប្រកួតប្រជែងរបស់ឧស្សាហកម្មក្នុងស្រុក មានដូចខាងក្រោម៖

- កង្វះខាតយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីជួយគាំទ្រដល់ផលិតកម្មក្នុងស្រុក៖

  ➢ កង្វះការវិនិយោគក្នុងស្រុកគ្រប់គ្រាន់នៅក្នុងខ្សែចង្វាក់តម្លៃ ជាពិសេសក្នុងផ្នែកកែច្នៃនិងកសិឧស្សាហកម្ម។
  ➢ ការពឹងផ្អែកខ្លាំងលើប្រទេសជិតខាងដើម្បីធ្វើការនាំចេញ។
  ➢ កង្វះការផ្សព្វផ្សាយអំពីព័ត៌មានទីផ្សារនៅកម្រិតតំបន់និងអន្តរជាតិ និងកង្វះខាតការទទួលស្គាល់លើភាពអនុលោមតាមស្តង់ដាអន្តរជាតិ។
  ➢ កង្វះទំនុកចិត្តពីអតិថិជនចំពោះគុណភាពនៃផលិតផលក្នុងស្រុក។
  ➢ កម្លាំងពលកម្មមានជំនាញទាបនិងកម្រិតផលិតភាពទាប។
  ➢ លទ្ធភាពទទួលបានហិរញ្ញប្បទាននៅមានកម្រិតទាបខ្លាំង សម្រាប់សហគ្រាសធុនតូចនិងមធ្យម។

> ➢ បរិយាកាសធុរកិច្ចចំណាយខ្ពស់និងភាពទន់ខ្សោយនៃការពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារដល់ការវិនិយោគនិងធុរកិច្ច។

- តម្រូវការអាទិភាពលើការជំរុញអភិវឌ្ឍបច្ចេកវិទ្យា ការច្នៃប្រឌិតបង្កើតថ្មី និងការលើកកម្ពស់ផលិតភាព ភាពប្រកួតប្រជែងរបស់កម្ពុជានាពេលអនាគត មិនអាចពឹងផ្អែកខ្លាំងលើកម្លាំងពលកម្មថោកទៀតទេ ប៉ុន្តែពឹងផ្អែកខ្លាំងលើសមត្ថភាពផលិតភាព ភាពម្ចាស់ការលើបច្ចេកវិទ្យានិងលទ្ធភាពបង្កើតនូវតម្លៃបន្ថែមលើផលិតផលនិងសេវា។
- ការប្រឈមថ្មីៗនៃតម្រូវការផ្សារភ្ជាប់សេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ក្នុងក្របខ័ណ្ឌជាតិ ការផ្សារភ្ជាប់មានភាពចាំបាច់យ៉ាងខ្លាំងរវាងអន្តរវិស័យដូចជា កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងសេវា ដើម្បីអនុញ្ញាតឲ្យកម្ពុជាអាចស្រូបយកបានផលប្រយោជន៍ពេញលេញពីសក្តានុពលនៃឧត្តមភាពប្រៀបធៀបរបស់ខ្លួន។
- មូលដ្ឋានតូចចង្អៀតនៃវិស័យឧស្សាហកម្មនេះ ពុំអាចជានានិរន្តរភាពឲ្យកំណើនសេដ្ឋកិច្ចជាតិបានឡើយ។ ជាង៧០%នៃចំណែកឧស្សាហកម្មសរុប គឺជាឧស្សាហកម្មកាត់ដេរដែលមានលក្ខណៈងាយរងនូវផលប៉ះពាល់អវិជ្ជមាន។

## ៥.៤- ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម

**២.១៩៧-** វិស័យឯកជនបានចូលរួមក្នុងការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជា ដែលមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងបណ្តាឆ្នាំចុងក្រោយនេះ ដោយបានអនុវត្តតាមផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃបេឡាជាតិសន្តិសុខសង្គម ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ទាំងអស់គ្នា ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។ សហគ្រាសចំនួន៤ ៥៨៣បានចុះឈ្មោះក្នុងបេឡាជាតិសន្តិសុខសង្គម ដែលមាននិយោជិតចំនួន៨៦៨ ១៣៤នាក់ ហើយនិយោជិតប្រមាណជា៣៧ ០០០នាក់ បានទទួលការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ក្នុងការងារពីបេឡាជាតិសន្តិសុខសង្គមនៅចន្លោះឆ្នាំ២០០៨និងឆ្នាំ២០១២។ នៅត្រីមាសទីមួយនៃឆ្នាំ២០១៣ ការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ក្នុងការងារបានពង្រីកវិសាលភាពបាន២៤ទីក្រុងនៃ២៤រាជធានី ខេត្តទូទាំងប្រទេស។

**២.១៩៨-** *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* មានតួនាទីអភិវឌ្ឍនិងរៀបចំគ្រប់គ្រងរបបសន្តិសុខសង្គមនិងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល សម្រេចបាននូវការងារអាទិភាពចំនួន៦៖

- *ការងារអាទិភាពទី១ - ពង្រឹងនិងពង្រីកសេវាសុខុមាលភាពសង្គមសម្រាប់ជនក្រីក្រងាយរងគ្រោះ៖*

- បានផ្សព្វផ្សាយនិងអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ដើម្បីជួយដល់ប្រជាជនរងគ្រោះ ជាពិសេស ប្រជាជនក្រីក្រដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុផ្សេងៗ។
- បានរៀបចំគោលនយោបាយនិងយន្តការសម្រាប់ជួយជនអនាថានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជួយដោះស្រាយបញ្ហាជនអនាថាប្រកបដោយមនុស្សធម៌និងការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ។ ជនអនាថាប្រមាណ១ ០០០គ្រួសារ ក្នុងមួយឆ្នាំៗ ត្រូវបានសង្គ្រោះ ផ្តល់សេវាស្តារនីតិសម្បទា ការថែទាំសុខភាព អប់រំផ្លូវចិត្ត បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសមាហរណកម្មទៅសហគមន៍វិញ។
- បានបង្កើតក្រុមការងារយេនឌ័ររបស់*ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*។ តាមរយៈក្រុមការងារបានផ្សព្វផ្សាយនិងបញ្ជ្រាបការងារយេនឌ័រដល់មន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- បានរៀបចំគោលនយោបាយ បទដ្ឋានអប្បបរមា និងកម្មវិធីសម្រាប់ជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទរាប់រយនាក់ត្រូវបានសង្គ្រោះ ស្តានីតិសម្បទា និងសមាហរណកម្ម។ កម្ពុជាបានទទួលការវាយតម្លៃនៅក្នុងកម្រិតទី២(TIR 2) ជាកម្រិតល្អក្នុងពិភពលោកក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរ។
- បានអនុវត្តកម្មវិធីស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្ត ការកសាងគ្រួសារល្អទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។

- *ការងារអាទិភាពទី២ - ពង្រឹងនិងពង្រីកសេវាសុខុមាលភាពកុមារនិងយុវនីតិសម្បទា៖*

  - បានអនុវត្តយ៉ាងទូលំទូលាយនូវសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារ ដែលមានចែងក្នុងអនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ រួមមាន សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍសិទ្ធិទទួលបានការការពារនិងសិទ្ធិចូលរួម។
  - បានជំរុញដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពាក់ព័ន្ធនឹងវិស័យកុមារ ដូចជា ការកាត់បន្ថយអត្រាមរណភាពមាតានិងទារក អប់រំ ការបង្កើនអត្រាចូលរៀនរបស់សិស្ស និងគុណភាពអប់រំ។
  - បានបង្កើតគោលនយោបាយថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារនៅក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាសម្រាប់ថែទាំកុមារនៅតាមសហគមន៍។ បានធ្វើប្រតិភូកម្មមុខងារលើវិស័យសុខុមាលភាពកុមារតាមប្រព័ន្ធវិសហមជ្ឈការទៅឲ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។
  - បានផ្តល់សច្ចាប័នលើ*អនុសញ្ញាឡាអេ* ស្តីពីសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស និងបានបង្កើតច្បាប់ស្តីពីសុំកូនអន្តរប្រទេសត្រូវបានអនុម័តថ្ងៃទី៣ ខែធ្នូ ឆ្នាំ

២០០៩។

- ➢ បានអនុវត្តការងារយុវនីតិសម្បទា និងអនុវត្តកម្មវិធីយុត្តិធម៌អនីតិជន ផ្តល់នូវសេវាការពារសិទ្ធិកុមារតាមផ្លូវច្បាប់។
- ➢ បានរៀបចំគោលនយោបាយសម្រាប់ស្តារនីតិសម្បទាជួយជនរងគ្រោះ ដែលប្រើប្រាស់បំពានសារធាតុញៀន និងអនីតិជនដែលប្រព្រឹត្តិល្មើសច្បាប់និងលើកទឹកចិត្តការព្យាបាលនិងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀន។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន កំពុងដំណើរការនៅទីស្តីការគណៈរដ្ឋមន្ត្រី។
- ➢ បានរៀបចំរបាយការណ៍ជាតិលើកទី២ លើកទី៣(របាយការណ៍ផ្សេងៗទៀត) ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនិងពិធីសារបន្ថែមស្តីពីអនុសញ្ញាសិទ្ធិកុមារ។ រៀបចំកិច្ចការពារកុមារ និងលិខិតបទដ្ឋានគតិយុត្ត និងធ្វើការស្រាវជ្រាវដើម្បីតាមដាននូវស្ថានភាពកុមារ និងរៀបចំផែនការឆ្លើយតប ដូចជា បង្កើតច្បាប់ការពារកុមារ និងផែនការជាតិសម្រាប់អភិវឌ្ឍកុមារ ដើម្បីលើកកម្ពស់ សិទ្ធិកុមារនៅកម្ពុជា។ បានពង្រឹងពង្រីកយន្តការតាមដាននិងអនុវត្តសិទ្ធិកុមារដែលមកដល់បច្ចុប្បន្ន តាមក្រសួង ស្ថាប័នចំនួន៩ និងរាជធានីខេត្តទាំង២៤ បានបន្សុំទៅតាមគោលនយោបាយ។ បានចងក្រងសូចនាករសិទ្ធិកុមារចំនួន៦២សូចនាករចែកជាបួនផ្នែក៖ (១)ផ្នែកអប់រំចំនួន១០ (២)ផ្នែកសុខភាពនិងអាហារូបត្ថម្ភចំនួន២៤ (៣)ផ្នែកអភិបាលកិច្ចល្អចំនួន១៧ និង(៤)ផ្នែកសង្គមចំនួន១១។

- *ការងារអាទិភាពទី៣ - ពង្រឹងនិងពង្រីកសេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម ៖*

  - ➢ បានបង្កើតច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ស្របតាមគោលនយោបាយជាតិស្តីពីជនពិការ។ តាមរយៈច្បាប់នេះ ការលុបបំបាត់ការរើសអើងចំពោះជនពិការត្រូវបានអនុវត្តយ៉ាងទូលំទូលាយនិងប្រកបដោយផ្លែផ្កា ព្រមទាំងបានបង្កឱកាសឲ្យជនពិការបានចូលរួមគ្រប់សកម្មភាពរបស់សង្គម។
  - ➢ បានបង្កើតមូលនិធិជនពិការ។ មូលនិធិនេះបានបន្តនិរន្តរភាពកម្មវិធីស្តារលទ្ធភាពពលកម្មសម្រាប់ជនពិការប្រមាណជាង២០ ០០០នាក់ក្នុងមួយឆ្នាំ ដោយឥតគិតថ្លៃរួមទាំងការផ្តល់សោហ៊ុយធ្វើដំណើរ ការស្នាក់នៅ និងការហូបចុក។
  - ➢ បានបង្កើតរបបគោលនយោបាយស្តីពីការជួយឧបត្ថម្ភជនពិការក្រីក្រ។
  - ➢ បានអនុវត្តកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍សម្រាប់ជនពិការ។ ផ្តល់សេវាស្តារលទ្ធភាពពលកម្ម ការបង្កើតក្រុមជួយខ្លួនឯង និងការអភិវឌ្ឍជីវភាពរស់នៅ និងមុខរបរខ្នាតតូច។

- បានលើកទឹកចិត្តដល់ការបង្កើតអង្គការរបស់ជនពិការ ដូចជាសមាគមជនពិការភ្នែកកម្ពុជា អង្គការជនពិការកម្ពុជា និងមជ្ឈមណ្ឌលជាតិនៃជនពិការ។
- បានបង្កើតកម្មវិធីផ្តល់សេវាឲ្យកុមារពិការភ្នែក កុមារគថ្លង់ និងកុមារពិការ ខ្សោយសតិបញ្ញា តាមរយៈការបង្កើតឲ្យមានមណ្ឌលផ្តល់នូវសេវាបណ្តុះបណ្តាលពិសេសជូនដល់ប្រភេទកុមារពិការនីមួយៗ។
- បានលើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ ការងារព័ត៌មានជាភាសាសញ្ញា និងការអភិវឌ្ឍសេវាអក្សរស្ទាបនិងភាសាសញ្ញា។
- បានផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីសិទ្ធិជនពិការបន្ថែមលើបទដ្ឋានជាតិដែលមានស្រាប់។
- បានអនុម័តទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក និងផែនការយុទ្ធសាស្ត្រអ៊ីនឈាន់ "*ធ្វើឲ្យសិទ្ធិក្លាយជាការពិត*" ២០១៣-២០២២។

• *ការងារអាទិភាពទី៤ - ពង្រឹង ពង្រីករបបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ មន្ត្រីរាជការស៊ីវិល និងប្រជាជនទូទៅ៖*

- បានបង្កើតនិងអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ និងបង្កើតគណៈកម្មាធិការជាតិ និងយន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគោលនយោបាយចំពោះមនុស្សចាស់។
- បានអនុវត្តនូវកម្មវិធីពីរសំខាន់គឺទី១-កម្មវិធីអភិវឌ្ឍមនុស្សចាស់តាមសហគមន៍ និងទី២-កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ។
- បានផ្សព្វផ្សាយសេចក្តីណែនាំថ្នាក់ជាតិស្តីពីការថែទាំមនុស្សចាស់នៅតាមគ្រួសារ។
- បានបង្កើតសមាគមមនុស្សចាស់នៅតាមឃុំ សង្កាត់បានចំនួនប្រមាណ៥៦៩សមាគម
- បានជំរុញកម្មវិធីថែទាំមនុស្សចាស់នៅតាមគ្រួសារ តាមរយៈការផ្សព្វផ្សាយតាមប្រព័ន្ធផ្សាយព័ត៌មាន និងលើកកម្ពស់ប្រពៃណីទំនៀមទម្លាប់ល្អរបស់គ្រួសារខ្មែរ ក្នុងការគោរពដឹងគុណចំពោះមនុស្សចាស់។
- បានជំរុញកម្មវិធីលើកទឹកចិត្តដល់សហគមន៍ អារាមសាសនា ជាពិសេស ព្រះពុទ្ធសាសនា និងសាសនាដទៃទៀត ក្នុងការជួយដល់សាសនិកដែលជាជនចាស់ជរាបានជ្រកកោននៅតាមទីអារាម។
- មានសប្បុរជនបានបង្កើតនូវកម្មវិធីមនុស្សធម៌ដើម្បីជួយដល់ជនចាស់ជរា។
- បានបង្កើតមូលដ្ឋានទិន្នន័យសម្រាប់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ដើម្បីផ្តល់បៀវត្សតាមរយៈប្រព័ន្ធធនាគារ។ រហូតមកដល់ពេលបច្ចុប្បន្ន អ្នកចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក មាន១៦

រាជធានី ខេត្ត បានចុះឈ្មោះក្នុងមូលដ្ឋានទិន្នន័យ ហើយបានបើកបៀវត្សតាមប្រព័ន្ធធនាគារដល់តារកាលិក នៅរាជធានី ខេត្តចំនួន១៥។

- បានអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលមានតារកាលិក៦មុខ រួមមានការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក។

- *ការងារអាទិភាពទី៥ - ពង្រឹងនិងពង្រីករបបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន៖*

  - បានអនុវត្តគោលនយោបាយជាតិចំពោះអតីតយុទ្ធជន ដោយយកចិត្តទុកដាក់ដោះស្រាយជីវភាពរស់នៅតាមរយៈការផ្តល់សម្ភារៈ ការគាំទ្រថវិកាជាតិ ការជួយសង្គ្រោះបន្ទាន់ ស្តារលទ្ធភាពពលកម្មនិងកាយសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។
  - បង្កើតមូលដ្ឋានទិន្នន័យ អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនដើម្បីបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន តាមប្រព័ន្ធ។ នៅខេត្តចំនួន១៧ បានដំណើរការផ្តល់ប្រាក់ប្រចាំខែតាមប្រព័ន្ធធនាគារ។
  - បានអនុវត្តនូវគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ ព្រមទាំងបានបង្កើតគម្រោងជាច្រើនដើម្បីកែលម្អជីវភាពយោធិននិងអតីតយុទ្ធជន។
  - រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ ដល់សមាគមអតីតយុទ្ធជនកម្ពុជា ក្នុងការកសាងជីវភាពគ្រួសារ ការចូលរួមអភិវឌ្ឍនៅមូលដ្ឋាន ការបង្កើតនូវបេឡាឥណទាន បេឡាមរណសង្គ្រោះ ការសាងសង់ផ្ទះ ការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន។

- *ការងារអាទិភាពទី៦ - ពង្រឹងនិងពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូ គៀរគរប្រភពធនធាន បង្កើនប្រសិទ្ធភាពនៃសេវាសង្គមកិច្ច៖*

  - ការកសាងសមត្ថភាពស្ថាប័ន៖ ការបណ្តុះបណ្តាលមន្ត្រីដែលធ្វើការក្នុងវិស័យសង្គមកិច្ច បង្កើតឡើងនូវប្រភពធនធានមនុស្សប្រកបដោយគុណភាព សេវាសង្គមកិច្ចមូលដ្ឋាន សេវាសង្គមកិច្ចជំនាញ ជំនាញគាំទ្រចិត្តសង្គម ការគ្រប់គ្រងសេវាសង្គម និងជំនាញ ធ្វើការជាមួយជនរងគ្រោះដោយការជួញដូរ និងជំនាញថែទាំកុមារកំព្រា និងកុមាររងាយរងគ្រោះ។ រាជរដ្ឋាភិបាលបានបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច ដើម្បីបណ្តុះបណ្តាលនិងស្រាវជ្រាវផ្នែកការងារសង្គមនិងផ្នែកផលិតឧបករណ៍សិប្បនិម្មិត និងផ្នែកវិស្វកម្ម។
  - បានបង្កើតគេហទំព័ររបស់ក្រសួង http://www.mosvy.gov.kh។
  - ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ

សម្បទា បានបង្កើតបញ្ជីវិភាគមុខងារដែលបានអនុម័តដោយគណៈកម្មការជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

- បានសហប្រតិបត្តិការនិងលើកទឹកចិត្តដល់អង្គការ ដើម្បីអនុវត្តគម្រោងសុខុមាលភាពសង្គម និងការផ្តល់សេវាសង្គមកិច្ច។

**២.១៩៩-** ប្រទេសកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនដែលទាក់ទងនឹងសុខុមាលភាពសង្គម វិបត្តិហិរញ្ញវត្ថុ ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយពីធម្មជាតិនិងពីមនុស្ស។ល។ បញ្ហាទាំងនោះជះឥទ្ធិពលមកលើជនងាយរងគ្រោះ ដូចជាជនចំណាកស្រុក ការជួញដូរ មនុស្ស អ្នកប្រើប្រាស់ថ្នាំញៀន មេរោគអេដស៍/ជំងឺអេដស៍ មនុស្សចាស់ក្រីក្ររស់នៅតែឯងក្រីក្របំផុត អ្នករស់នៅតាមដងផ្លូវ អ្នកជំងឺផ្លូវចិត្ត ក្មេងកំព្រានិងជនរងគ្រោះ និងកុមារងាយរងគ្រោះ។ បញ្ហាប្រឈមផ្សេងទៀតមាន៖

- ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងទៅនឹងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅមានកម្រិត។
- កង្វះខាតមន្ត្រីនិងបុគ្គលិកផ្នែកសង្គមកិច្ចដើម្បីផ្តល់សេវាសុខុមាលភាពសង្គម។

### ក- សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

**២.២០០-** ការពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០០៨-២០១២ ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលអាណត្តិទី៤ កន្លងមកបានបង្ហាញពីលទ្ធផលសម្រេចបានគួរឲ្យកត់សម្គាល់ រួមមាន៖ អតិរេកស្រូវលើសពីតម្រូវការ ការកាត់បន្ថយភាពក្រីក្រ និងស្ថានភាពអាហារូបត្ថម្ភរបស់កុមារនិងស្ត្រី។

**២.២០១-** ទោះបីជាវិស័យសន្តិសុខស្បៀងមានសមិទ្ធផលច្រើនចាប់ពីឆ្នាំ២០០៥យ៉ាងណាក្តី ក៏ស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារអាយុក្រោម៥ឆ្នាំនៅមានការរីកចម្រើនតិចតួច។ ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ អត្រាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ(ក្រិន) បានធ្លាក់ចុះពី៤៣,២% នៅឆ្នាំ២០០៥ មកត្រឹម៣៩,៩% នៅឆ្នាំ២០១០ ហើយអត្រាកង្វះទម្ងន់នៅទ្រឹងក្នុងកម្រិត២៨%។ អត្រាស្គមស្គាំងក្នុងចំណោមកុមារបានកើនឡើងពី៨,៤% នៅឆ្នាំ២០០៥ដល់១០,៩% នៅឆ្នាំ២០១០។ ចំណែកឯអាហារូបត្ថម្ភរបស់មាតាក៏មានការរីកចម្រើនតិចតួចដែរ ដែលក្នុងនោះ ស្ត្រីក្នុងវ័យបន្តពូជប្រមាណ២០%មានទម្ងន់ស្រាល(សន្ទស្សន៍ម៉ាស់រាងកាយ)ក្នុងឆ្នាំ២០០០ ឆ្នាំ២០០៥ និងឆ្នាំ២០១០។ ទន្ទឹមនឹងនេះ អត្រាកង្វះមីក្រូសារជាតិក៏មានកម្រិតខ្ពស់ផងដែរសម្រាប់កុមារអាយុក្រោម៥ឆ្នាំ(៥៥%) រីឯស្ត្រីក្នុងវ័យបន្តពូជចំនួន៤៤% មានភាពស្លេកស្លាំង។ ទន្ទឹមនឹងនេះ កម្រងទិន្នន័យដែលបានមកពីការអង្កេតចុងក្រោយ បានធ្វើការពន្យល់អំពីមូលហេតុដែលបណ្តាលឲ្យមានអត្រា

ខ្ពស់នៃកង្វះអាហារូបត្ថម្ភដូចខាងក្រោម៖

- មួយភាគបីនៃប្រជាពលរដ្ឋ (និងជាងពាក់កណ្តាលនៃគ្រួសារក្រីក្រ) បរិភោគរបបអាហារមិនមានថាមពលគ្រប់គ្រាន់។
- ការអនុវត្តការចិញ្ចឹមទារកនិងកុមារតូចមិនបានត្រឹមត្រូវល្អ ដែលក្នុងនោះកុមារប្រមាណ ៧៥% ទទួលរបបអាហារមិនបានសមស្របក្នុងកម្រិតអប្បរមា។
- លក្ខខណ្ឌអនាម័យមិនល្អ ដែលក្នុងនោះជាងពាក់កណ្តាលនៃប្រជាពលរដ្ឋមិនបន្ទោរបង់នៅក្នុងបង្គន់ (បន្ទោរបង់នៅតាមទីវាល)។ លក្ខខណ្ឌបរិស្ថានរស់នៅមិនល្អបណ្តាលឲ្យកុមារកើតជំងឺរាគរូសច្រើន ហើយដែលជាមូលហេតុចម្បងបណ្តាលឲ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ។

**២.២០២-** វិបត្តិហិរញ្ញវត្ថុសកលលោក រួមមាន វិបត្តិសេដ្ឋកិច្ចនិងតម្លៃម្ហូបអាហារកើនឡើងខ្ពស់ បានជះឥទ្ធិពលអវិជ្ជមានដល់ស្ថានភាពអាហារូបត្ថម្ភកុមារនិងស្ត្រី។ បន្ថែមលើនេះទៀត ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយធម្មជាតិក៏នៅតែជាកត្តាប្រឈមដ៏សំខាន់ដល់ភាពអាចរកបានម្ហូបអាហារនិងអាចមាននៅគ្រួសារ។

### ខ- ការគាំពារសង្គម

**២.២០៣-** អង្គភាពសម្របសម្រួលការគាំពារសង្គម ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីផ្តល់ការទ្រទ្រង់ផ្នែកគោលនយោបាយ ការពិនិត្យតាមដាននិងវាយតម្លៃ ការសម្របសម្រួលលើការពិភាក្សាជាលក្ខណៈអន្តរស្ថាប័ន និងការគ្រប់គ្រងព័ត៌មានលើវិស័យគាំពារសង្គម។ នៅក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម វឌ្ឍនភាពនៃគោលដៅរបស់យុទ្ធសាស្ត្រនេះតម្រូវឲ្យមានការរៀបចំកម្មវិធីជាលក្ខណៈចម្រុះមួយ ដែលអាចគ្របដណ្តប់ ទាំងជនក្រីក្រពុំរ៉ែនិងជនក្រីក្រដែលកំពុងវិវត្តចាកផុតពីភាពក្រីក្រ ក៏ដូចជាការជួយបង្កើនមូលធនមនុស្ស។ ជំហានសំខាន់បំផុតក្នុងការដោះស្រាយបញ្ហាខាងលើ គឺតាមរយៈយន្តការកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលអាចកំណត់គោលដៅជនក្រីក្រ និងជនងាយរងគ្រោះដែលបណ្តាលមកពីហានិភ័យជាលក្ខណៈបុគ្គលឲ្យបានកាន់តែប្រសើរ និងការប្រើប្រាស់យន្តការផ្សេងទៀត ដែលអាចកំណត់អត្តសញ្ញាណជនក្រីក្រនិងជនងាយរងគ្រោះដែលបណ្តាលមកពីហានិភ័យជាលក្ខណៈចម្រុះ ដែលអាចបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុ ឬមហន្តរាយធម្មជាតិ។ យុទ្ធសាស្ត្រជាតិគាំពារសង្គមបានបង្កើតជាក្របខ័ណ្ឌមួយក្នុងការគាំទ្រដល់ការពង្រីកវិសាលភាពកម្មវិធីដែលមានស្រាប់ ដូចជាការផ្តល់អាហារនៅសាលារៀន កម្មវិធីអាហារូបត្ថម្ភ កម្មវិធីអាហារូបករណ៍ ដោយផ្តោតគោលដៅលើសិស្សក្រីក្រនិងមូលនិធិសមធម៌សុខភាព ក៏ដូចជាការរៀបចំបង្កើតកម្មវិធីសំណង់សាធារណៈក្នុងរូបភាពជាការបង្កើតហេដ្ឋារចនា

សម្ព័ន្ធរូបវន្តនិងទ្រទ្រង់ជីវភាព។

២.២០៤- សមិទ្ធផលសំខាន់ៗ ក្នុងការពង្រឹងនិងការលើកកម្ពស់ប្រព័ន្ធគាំពារសង្គមរួមមានៈ

- ការសិក្សាវាយតម្លៃក្នុងកម្រិតនយោបាយចំនួន៤ត្រូវបានរៀបចំឡើងដែលក្នុងនោះ រួមមាន (១)ការពិនិត្យឡើងវិញលើការចំណាយផ្នែកការគាំពារសង្គម(ដែលវាយតម្លៃលើសមត្ថភាពហិរញ្ញប្បទានចំពោះកម្មវិធីគាំពារសង្គម) (២)ការប៉ាន់ប្រមាណលើការចំណាយលើយុទ្ធសាស្ត្រជាតិគាំពារសង្គម(ដែលផ្តល់សេណារីយ៉ូពីរប្រភេទក្នុងការវាយតម្លៃ គឺការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមដែលគ្រប់ដណ្តប់ជាលក្ខណៈសកលលើប្រជាជនទាំងអស់ ឬដោយផ្តោតតែលើជនក្រីក្រនិងជនងាយរងគ្រោះ) (៣)ការសិក្សាលើអត្រាផលចំណេញនៃការវិនិយោគលើការគាំពារសង្គម (ដែលគាំទ្រដល់ការសម្រេចចិត្តផ្នែកគោលនយោបាយលើការជ្រើសរើសអន្តរាគមន៍គាំពារសង្គម) និង(៤)ក្របខ័ណ្ឌពិនិត្យតាមដានលើយុទ្ធសាស្ត្រជាតិគាំពារសង្គម(ដែលបង្កើតឡើងដោយប្រើប្រាស់ប្រភពទិន្នន័យ ដែលមានស្រាប់ដែលប្រមូលពីការអង្កេតថ្នាក់ជាតិ និងប្រមូលផ្តុំជាសូចនាករតាមដានចំនួន៣៣)។
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានធ្វើការវិភាគលើបែបផែននៃការពង្រឹងតួនាទីរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការសម្របសម្រួលលើ ការអនុវត្តអន្តរាគមន៍គាំពារសង្គមនៅថ្នាក់ក្រោមជាតិ។ អភិក្រមចំនួន២ត្រូវបានបង្កើតឡើង រួមមានៈ (១)យន្តការផ្តល់សេវាសង្គម (ជាយន្តការច្រកចេញចូលតែមួយ ក្នុងការផ្តល់សេវាសង្គមនៅតំបន់ជនបទ) និង(២)ការអនុវត្តកម្មវិធីគាំពារសង្គមជាលក្ខណៈចម្រុះ(ជាការធ្វើសុខដុមនីយកម្មនិងការអនុវត្តជាលក្ខណៈចម្រុះនៃអន្តរាគមន៍គាំពារសង្គមផ្សេងៗគ្នា ដោយប្រើប្រាស់គោលការណ៍រួមគ្នាក្នុងការអនុវត្ត)។
- កម្មវិធីសង្គហទានសង្គមត្រូវបានរៀបចំ និងអនុវត្តជាលក្ខណៈសាកល្បងដោយប្រើប្រាស់រចនាសម្ព័ន្ធ ស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់កញ្ចប់លាភការជូនដល់ស្ត្រីមានផ្ទៃពោះនិងកុមារដោយប្រើប្រាស់អភិក្រមនៃការអភិវឌ្ឍកុមារតូច។ ការអនុវត្តជាលក្ខណៈសាកល្បងនឹងត្រូវទទួលការឧបត្ថម្ភដោយដៃគូអភិវឌ្ឍ ហើយក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទ នឹងធ្វើការពិនិត្យតាមដាននិងវាយតម្លៃលើលទ្ធភាពនៃការពង្រីកវិសាលភាពនៅថ្នាក់ជាតិ។
- នៅក្នុងឆ្នាំសិក្សា២០១២-២០១៣ សិស្សានុសិស្សចំនួនប្រមាណ៤៥០ ០០០នាក់ នៅថ្នាក់បឋមសិក្សាបានទទួលកម្មវិធីផ្តល់អាហារនៅសាលារៀន ហើយជាង១០០ ០០០នាក់ទៀតនៅសាលារៀនចំនួន៤ ៧២៥ ក្នុងខេត្តគោលដៅចំនួន១៥ បានទទួលអាហារូបករណ៍ជាស្បៀងឬជាសាច់ប្រាក់។ រាជរដ្ឋាភិបាលកម្ពុជាបានផ្គត់ផ្គង់អង្ករ២០០០តោនដល់អន្តរាគមន៍នេះ។

- កម្មវិធីសំណង់សាធារណៈក្នុងទម្រង់ជាអន្តរាគមន៍សាច់ប្រាក់ពលកម្ម និងស្បៀងពលកម្ម បានបង្កើតការងារជាង៥០០ ០០០ថ្ងៃការងារ ដល់គ្រួសារក្រីក្រ។ កម្មវិធីបង្កើតទ្រព្យធនសកម្ម និងទ្រទ្រង់ជីវភាព ដែលជាបែបផែនថ្មីមួយនៃអន្តរាគមន៍សាច់ប្រាក់ពលកម្មបានអនុវត្តសាកល្បង ដែលបង្កើនភាពជាម្ចាស់ និងសមត្ថភាពស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ក្នុងវិស័យសន្តិសុខសង្គម បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលត្រូវបានបង្កើតនៅឆ្នាំ២០០៨ បេឡាជាតិអតីតយុទ្ធជនត្រូវបានបង្កើតនៅឆ្នាំ២០១០ ហើយបេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានបង្កើតនៅឆ្នាំ២០០២ ដែលជាក្របខ័ណ្ឌនៃការពង្រីកការអនុវត្ត និងការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធគាំពារសង្គមនៅកម្ពុជា។
- គម្រោងហិរញ្ញប្បទានសុខាភិបាលមួយចំនួនត្រូវបានអនុវត្តនៅកម្ពុជា រួមមានការលើកលែងការបង់ប្រាក់និងការបង់ប្រាក់ជំនួស(មូលនិធិសមធម៌សុខភាព បណ្ណសេវាសុខភាពបន្តពូជ និងការធានារ៉ាប់រងសុខភាពនៅសហគមន៍)។ មូលនិធិសមធម៌សុខភាពបានពង្រីកទៅដល់មណ្ឌលសុខភាពចំនួន៣៧០ និងមន្ទីរពេទ្យចំនួន៦៤។ ប្រជាជនប្រមាណ១៦៧ ០០០នាក់ បានចុះឈ្មោះទៅក្នុងគម្រោងធានារ៉ាប់រងសុខភាពនៅសហគមន៍ ដែលអនុវត្តនៅមណ្ឌលសុខភាពចំនួន១៧៩ និងមន្ទីរបង្អែកចំនួន១៣ គិតរួមទាំងនៅរាជធានីភ្នំពេញ។

**២.២០៥-** ការធានាសន្តិសុខស្បៀងនិងកាត់បន្ថយភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប នៅតែជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ *រាជរដ្ឋាភិបាលកម្ពុជា* បានផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការកែលម្អកម្រិតជីវភាពនៃប្រជាជនប្រហែល២០% ដែលកំពុងរស់នៅក្នុងភាពក្រីក្រ លើសពីនេះទៅទៀត *រាជរដ្ឋាភិបាលកម្ពុជា* ក៏បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើក្រុមគ្រួសារដែលកំពុងវិវត្តផុតពីភាពក្រីក្រ ប៉ុន្តែដែលនៅតែប្រឈមនឹងភាពងាយរងគ្រោះដោយសារបញ្ហាសុខភាពនិងវិបត្តិដទៃទៀត ដែលអាចទាញពួកគាត់ឲ្យធ្លាក់មកនៅក្រោមបន្ទាត់នៃភាពក្រីក្រវិញ។ កង្វះអាហាររូបត្ថម្ភសម្រាប់កុមារអាយុក្រោម៥ឆ្នាំ ដែលជាកត្តារាំងពួកគេពីការទទួលបានសមត្ថភាពផ្នែកបញ្ញានិងស្មារតី និងដែលធ្វើឲ្យពួកគេងាយនឹងឆ្លងជំងឺ នៅតែជាបញ្ហាពិសេសដែលរាជរដ្ឋាភិបាលកម្ពុជាបន្តការយកចិត្តទុកដាក់។ ឧបសគ្គលើការអភិវឌ្ឍមូលធនមនុស្សទាំងនេះ ពិសេសលើជនក្រីក្រនឹងរារាំងដល់សក្តានុពលនៃការអភិវឌ្ឍប្រកបដោយសមធម៌ កំណើនសេដ្ឋកិច្ច និងវិបុលភាពសម្រាប់កម្ពុជា។

**២.២០៦-** ជាមួយនឹងផែនការបើកចំហទីផ្សារការងារថ្នាក់តំបន់ តាមរយៈសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ ចលនាការនៃកម្លាំងពលកម្មនឹងមានកំណើនឡើងនៅក្នុងសហគមន៍ ហើយអាចពង្រីកកាលានុវត្តភាពសម្រាប់ការងារ។ ទោះជាយ៉ាងនេះក្តី ក៏ពលករនៃប្រទេសកម្ពុជាដែលជាទូទៅមានកម្រិតជំនាញទាប អាចនឹងត្រូវបានរុញចេញពីការងារបច្ចុប្បន្នរបស់ពួកគាត់ តាមរយៈកំណើននៃការប្រកួតប្រជែងពីពលករអន្តោប្រវេសន៍នៅក្នុង

តំបន់។ ពលករប្រមាណ៦០% នៅតែទទួលបានការងារក្នុងវិស័យក្រៅប្រព័ន្ធ ដែលមានការគាំពារសង្គមតិចតួចឬគ្មាន ក្នុងករណីមានវិបត្តិសុខភាព បញ្ហាគ្រោះអាសន្នក្នុងគ្រួសារ ឬភាពមិនជាក់លាក់ផ្នែកប្រាក់ចំណូល និងកំណើននៃការគំរាមកំហែងដល់និកម្មភាព ដែលនឹងបណ្តាលឲ្យពលករទាំងនេះត្រូវទទួលយកការងារដែលមានប្រាក់កម្រៃទាប។ បញ្ហាប្រឈម ក្នុងពេលអនុវត្តអន្តរាគមន៍ការគាំពារសង្គម សំដៅជានាកំណើនប្រកបដោយសមធម៌ និងបន្សាំទៅនឹងហានិភ័យផ្នែកសង្គម ហើយក្នុងពេលជាមួយគ្នានេះត្រូវកសាងមូលធនមនុស្សនិងកម្លាំងពលកម្មប្រកបដោយផលិតភាពសម្រាប់កម្ពុជា។

### គ - ភូមិមួយ ផលិតផលមួយ

**២.២០៧-** ដើម្បីជំរុញភូមិមួយ ផលិតផលមួយឲ្យកាន់តែមានល្បឿនទៅមុខ *រាជរដ្ឋាភិបាលកម្ពុជា* បានអនុវត្តនូវសកម្មភាពដូចខាងក្រោម៖

- ការរៀបចំសិក្ខាសាលាដើម្បីលើកកម្ពស់ចំណេះដឹងអំពីភាពជោគជ័យនៃទស្សនៈរបស់ភូមិមួយផលិតផលមួយ នៅថ្នាក់ជាតិ និងថ្នាក់ក្រោម។
- ការរៀបចំសិក្ខាសាលាចំនួន៧បន្តបន្ទាប់គ្នា ក្នុងសិក្ខាសាលានីមួយៗមានផលិតផលមួយ ដើម្បីរកវិធីធ្វើឲ្យប្រសើរឡើងនូវគុណភាព បង្កើនបរិមាណ និងពង្រីងទីផ្សារសម្រាប់ផលិតផលក្នុងភូមិមួយផលិតផលមួយ។
- ការសម្របសម្រួលបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍសម្រាប់ដាំដំណាំមន និងការបណ្តុះបណ្តាលចិញ្ចឹមដង្កូវនាង ដើម្បីលើកកម្ពស់ផលិតផលសូត្ររបស់កម្ពុជា។
- ការជ្រើសរើសយកស្រុកគិរីវង្ស ខេត្តតាកែវ ធ្វើជាទីកន្លែងដើម្បីជំរុញផលិតផលសូត្រនៃភូមិមួយផលិតផលមួយ ដែលជាការអភិវឌ្ឍទីផ្សារភូមិមួយផលិតផលមួយ សមាគមន៍អ្នកគាំទ្រភូមិមួយ ផលិតផលមួយ និងដើម្បីលើកទឹកចិត្តប្រជាជនឲ្យដាំដំណាំមន ចិញ្ចឹមដង្កូវនាងនិងផលិតសូត្រ។
- ការផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសនិងកែច្នៃ ដូចជាដាំដំណាំមន ចិញ្ចឹមដង្កូវនាង ផលិតសូត្រ និងជំរុញការបណ្តុះបណ្តាលសិប្បកម្មដល់កសិករនៅតំបន់ជនបទ។
- ការចូលរួមសិក្ខាសាលា សន្និសីទ ទស្សនកិច្ចសិក្សា និងការតាំងពិព័រណ៍នៅបរទេស ដែលជាប្រទេសទទួលបានជោគជ័យក្នុងការលើកកម្ពស់ភូមិមួយផលិតផលមួយ ដូចជាប្រទេសជប៉ុន ចិន ថៃ ឡាវ និងម៉ាឡេស៊ី។ល។

## ៦- ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

**២.២០៨-** ចតុកោណក្រោយគេបង្អស់នៃ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* បានគ្រប់ដណ្តប់លើសលប់ទៅលើការអភិវឌ្ឍវិស័យសង្គមកិច្ច មានដូចជា (១)ការពង្រឹងគុណភាពវិស័យអប់រំ (២)ការលើកកម្ពស់សេវាសុខាភិបាល (៣)ការអនុវត្តគោលនយោបាយសមភាព យេនឌ័រ និង (៤)ការអនុវត្តគោលនយោបាយប្រជាជន។ វឌ្ឍនភាពដែលចាប់អារម្មណ៍ជាខ្លាំងនៅក្នុងវិស័យ៣ គឺវិស័យអប់រំ វិស័យសុខាភិបាល និងយេនឌ័រ។

### ៦.១- ការពង្រឹងគុណភាពវិស័យអប់រំ

**២.២០៩-** ការពង្រឹងគុណភាពសេវាអប់រំ គឺជាអាទិភាពចម្បងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាគន្លឹះចាំបាច់នៃការចូលរួមក្នុងកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍធនធានមនុស្ស។ *ក្រសួងអប់រំ យុវជន និងកីឡា* បានរៀបចំនិងអនុវត្តនូវអភិក្រមគ្រប់គ្រងទូទាំងវិស័យ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣។ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣ បានរួមចំណែកបង្កើនការចូលរៀនរបស់កុមារកម្ពុជា ប្រកបដោយសមធម៌ក្នុងការផ្តល់ឱកាសសិក្សារៀនសូត្រ ជាពិសេស ក្នុងកម្រិតបឋមសិក្សា ដើម្បីឲ្យកុមារក្លាយជាពលរដ្ឋមានចំណេះដឹងនិងសកម្ម ដែលនឹងក្លាយទៅជាកម្លាំងស្នូលដ៏សំខាន់សម្រាប់ការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចកម្ពុជា។

**២.២១០-** រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការបង្កើនថវិការបស់ខ្លួន និងកៀរគរជំនួយកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពីដៃគូអភិវឌ្ឍនានា សម្រាប់អនុវត្តកំណែទម្រង់វិស័យអប់រំ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣ សំដៅសម្រេចបានគោលនយោបាយជាអាទិភាពសំខាន់ៗ ដើម្បីរួមចំណែកដល់ការកសាង និងការអភិវឌ្ឍធនធានមនុស្សរបស់ *ព្រះរាជាណាចក្រកម្ពុជា*។ គោលនយោបាយជាអាទិភាពសំខាន់ៗ រួមមាន៖

- ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ដោយខិតខំកសាងសាលារៀនឲ្យកាន់តែជិតលំនៅឋានរបស់ប្រជាពលរដ្ឋ បង្កើតអន្តេវាសិកដ្ឋានសម្រាប់សិស្ស និស្សិតពិសេស សម្រាប់សិស្ស និស្សិតជានារីភេទ ផ្គត់ផ្គង់ថវិកាដំណើរការគ្រឹះស្ថានសិក្សាផ្តល់គ្រូបង្រៀនប្រកបដោយគុណភាព។
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ តាមរយៈការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សា បណ្ណាល័យ និងបន្ទប់ពិសោធន៍ ការជំរុញកំណែទម្រង់កម្មវិធីសិក្សា និងការបង្កើនម៉ោងសិក្សា ព្រមទាំងខិតខំផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រឲ្យបានច្រើន។

- អភិវឌ្ឍស្ថាប័ននិងអភិវឌ្ឍសមត្ថភាពមន្ត្រីដោយជំរុញការកែលម្អរចនាសម្ព័ន្ធការងារកសាងច្បាប់និងលិខិតបទដ្ឋានឲ្យបានគ្រប់គ្រាន់ ជាមួយនោះ ធ្វើការបណ្តុះបណ្តាលបច្ចេកទេសជំនាញដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

**២.២១១-** ជាក់ស្តែងក្នុងឆ្នាំ២០០៩ដល់ឆ្នាំ២០១៣ អត្រាពិតនៃការសិក្សានៅបឋមសិក្សា(ពីថ្នាក់ទី១ដល់ទី៦) បានកើនឡើងពី៩៤,៤% ក្នុងឆ្នាំសិក្សា២០០៨-២០០៩ដល់៩៧% ក្នុងឆ្នាំសិក្សា២០១២-២០១៣ ជាមួយនឹងអត្រាបញ្ចប់ការសិក្សា៨៧,៣%។ ក្នុងពេលដំណាលគ្នានេះ សាលាបឋមសិក្សាមានចំនួន៦ ៩១០ ដោយកើនឡើងចំនួន៣៤៥សាលា។ ការផ្តល់អាហារពេលព្រឹកនិងអាហារូបករណ៍ សម្រាប់សិស្ស និស្សិតក្រីក្រ ការអនុវត្តគោលនយោបាយស្តីពីសាលាកុមារមេត្រី និងការផ្តល់មធ្យោបាយធ្វើដំណើរដល់ក្រុមបំប៉ន និងពិនិត្យ តាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ គឺជាការផ្តល់ឱកាសដល់កុមារទាំងអស់បានចូលរៀន។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧ដល់ទី៩)នៅឆ្នាំសិក្សា២០១២-២០១៣ មាន៥៣,៦% ជាមួយនឹងអត្រាបញ្ចប់ការសិក្សា៤២,១%។ អំឡុងពេលនេះដែរ អនុវិទ្យាល័យ រដ្ឋមានចំនួន១ ២១៤ ដោយកើនឡើងចំនួន៩២អនុវិទ្យាល័យ ដែលក្នុងនោះ៨៤,២%មានបង្គន់អនាម័យ និង៥១,៦% មានទឹកស្អាតប្រើប្រាស់។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិមាន២៧,៤% ជាមួយនឹងអត្រាបញ្ចប់ការសិក្សា២៧,៨% នៅឆ្នាំសិក្សា២០១២-២០១៣។ វិទ្យាល័យរដ្ឋមានចំនួន៤៣៣ ដោយកើនឡើងចំនួន៨៤វិទ្យាល័យ។ សម្រាប់រាជរដ្ឋាភិបាល អត្រាចូលរៀននិងអត្រាបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សានៅតែមានក្តីបារម្ភ។

**២.២១២-** រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពអប់រំ តាមរយៈការផ្តោតលើបំណិនក្នុងការអាននៅថ្នាក់ដំបូង ការបញ្ចូលកម្មវិធីបណ្តុះបណ្តាលបំណិនជីវិតមូលដ្ឋាន ការអនុញ្ញាតឲ្យជ្រើសរើសមុខវិជ្ជាតាមឧបនិស្ស័យ ការកែលម្អកម្មវិធីសិក្សា និងសៀវភៅសិក្សា ការរៀបចំស្តង់ដាជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការផ្គត់ផ្គង់សម្ភារៈ និងសៀវភៅសិក្សា។ អត្រាអក្ខរកម្មយុវជនអាយុ១៥ដល់២៤ឆ្នាំ បានកើនឡើងដល់ ៩១,៥% នៅឆ្នាំ២០១១ គឺកើន៤% ធៀបនឹងឆ្នាំ២០០៨។ ផ្នែកអប់រំឧត្តមសិក្សាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដោយគ្រឹះស្ថានឧត្តមសិក្សាមានចំនួន១០១ ក្នុងនោះគ្រឹះស្ថានរដ្ឋមានចំនួន៣៩ និងគ្រឹះស្ថានឯកជនមានចំនួន៦២។ និស្សិតដែលបានបញ្ចប់ការសិក្សាចាប់ពីបរិញ្ញាបត្ររងដល់ថ្នាក់បណ្ឌិតមានចំនួន៤៥ ៦៥០នាក់។

**២.២១៣-** ទន្ទឹមនឹងជំហានជោគជ័យមួយចំនួនដូចខាងលើ វិស័យអប់រំក៏កំពុងជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជាគុណភាពសិក្សានៅមានកម្រិត កង្វះខាតបរិក្ខារសិក្សា និងគុណភាពគ្រូបង្រៀន ដែលពាក់ព័ន្ធនឹងការរៀនត្រួតថ្នាក់និងការបោះបង់ការសិក្សារបស់សិស្សានុសិស្សមានកម្រិតខ្ពស់នៅឡើយ និងការអនុវត្តប្រព័ន្ធធានាគុណភាពនៅពុំទាន់បានពេញលេញ ព្រមទាំង

ចំនួនគ្រឹះស្ថាននៅកម្រិតឧត្តមសិក្សាដែលមានគុណភាពនិងភាពឆ្លើយតប នៅមានចំនួនតិចតួចប៉ុណ្ណោះ។

**២.២១៤-** បញ្ហាប្រឈមនិងដំណោះស្រាយ ក្នុងអំឡុងពេលនៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣* ៖

- *បញ្ហាប្រឈមទី១-ការពង្រីកការអប់រំកុមារតូច* ការជំរុញការចូលរៀននៅក្នុងកម្មវិធីអប់រំកុមារតូចឲ្យបានត្រឹមត្រូវតាមអាយុរបស់កុមារអាយុ០ឆ្នាំទៅ៥ឆ្នាំ។ ការលើកកម្ពស់សមត្ថភាពគ្រូមត្តេយ្យសិក្សា តាមរយៈការបណ្តុះបណ្តាលនិងរិក្រឹតការគ្រូមត្តេយ្យសិក្សា និងការផ្សព្វផ្សាយពីគុណតម្លៃនៃការសិក្សាដល់មាតាបិតានិងសហគមន៍។
  - ដំណោះស្រាយៈ ការបង្កើនការចូលរៀនក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះនិងសហគមន៍ ជាមួយគ្នានឹងកម្មវិធីបណ្តុះបណ្តាលក្រុមម្តាយនិងគ្រូមត្តេយ្យសហគមន៍។

- *បញ្ហាប្រឈមទី២-ការពង្រីកការអប់រំដោយសមធម៌នៅបឋមសិក្សា ជាពិសេស តំបន់ជួបការលំបាក និងក្រុមកុមារជួបការលំបាក*
  - ដំណោះស្រាយៈ ការពង្រីកកម្មវិធីអប់រំពីរភាសា កម្មវិធីអាហារូបករណ៍ និងអាហារូបត្ថម្ភ ការពន្លឿនការសិក្សា និងកម្មវិធីចូលរៀនឡើងវិញ តាមរយៈការអប់រំក្រៅប្រព័ន្ធ និងការបង្កើនសមាហរណកម្មការអប់រំបញ្ចូលគ្នាទៅគ្រប់កម្រិតសិក្សា។

- *បញ្ហាប្រឈមទី៣-ការចូលរៀននិងគុណភាពនៅមធ្យមសិក្សា*
  - ដំណោះស្រាយៈ ការបង្កើនការចូលរៀននៅមធ្យមសិក្សាដោយយកចិត្តទុកដាក់លើការកាត់បន្ថយគម្លាតយេនឌ័រ និងយកចិត្តទុកដាក់ជំរុញការបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ។ ការបង្កើនចំនួនអាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេសសិស្សស្រី។ ការបង្កើនចំនួនសាលាមធ្យមសិក្សាបឋមភូមិ តាមរយៈការពង្រីកសាលាបឋមសិក្សាស្របតាមកំណើនសិស្ស។

- *បញ្ហាប្រឈមទី៤-ការប្រមូលកុមារក្រៅសាលានិងការអប់រំក្រៅប្រព័ន្ធ*
  - ដំណោះស្រាយៈ ការរៀបចំវិធានការដើម្បីកាត់បន្ថយចំនួនកុមារនៅក្រៅសាលា ការយកចិត្តទុកដាក់បន្ថែមលើកុមារជនជាតិដើមភាគតិច កុមារពិការ និងកុមារក្នុងគ្រួសារក្រីក្រ តាមរយៈកម្មវិធីដែលបានកំណត់។

- *បញ្ហាប្រឈមទី៥-គុណភាពនិងភាពឆ្លើយតបរបស់ការសិក្សានៅមានកម្រិត*
  - ដំណោះស្រាយៈ ការបង្កើតក្របខ័ណ្ឌធានាគុណភាពនៅថ្នាក់ជាតិ ដែលអាចវាស់វែងបានពីលទ្ធផលនៃការសិក្សារបស់សិស្ស។ ការពង្រឹងការធ្វើតេស្តតាមថ្នាក់រៀនជាប្រចាំ

និងវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ទី៣ ព្រមទាំងពង្រីកទៅដល់ថ្នាក់ទី៦និងទី៨។ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតប តាមរយៈការពិនិត្យឡើងវិញកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។

- *បញ្ហាប្រឈមទី៦-ការបង្កើនការចូលរៀននិងគុណភាពនៅឧត្តមសិក្សា*
  - ដំណោះស្រាយៈ ការរៀបចំចក្ខុវិស័យសម្រាប់ឧត្តមសិក្សា និងការផ្តោតលើកម្មវិធីអាទិភាព(វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា) ស្របជាមួយស្តង់ដាធានាគុណភាពរបស់អាស៊ាន។

- *បញ្ហាប្រឈមទី៧-ការផ្គត់ផ្គង់សៀវភៅសិក្សាគោល*
  - ដំណោះស្រាយៈ ការពិនិត្យឡើងវិញនិងការកែលម្អប្រព័ន្ធបែងចែកនិងគ្រប់គ្រងសៀវភៅសិក្សាគោល។ ការធានាថាការផ្គត់ផ្គង់សៀវភៅសិក្សាគោល កម្មវិធីសិក្សាថ្មី និងការផ្តល់សៀវភៅគ្រូដល់គ្រូបង្រៀននៅតំបន់ជួបការលំបាក។

- *បញ្ហាប្រឈមទី៨-ការផ្គត់ផ្គង់និងការពង្រាយគ្រូមានគុណភាព*
  - ដំណោះស្រាយៈ ការពង្រាយគ្រូបង្រៀននៅតាមវិទ្យាល័យនិងអនុវិទ្យាល័យដែលបង្កើតថ្មី ពិសេសតំបន់ជួបការលំបាក។ ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ តាមរយៈការងារវិក្រឹតការគ្រូបង្រៀននិងការដាក់ឲ្យអនុវត្តប្រព័ន្ធការវាយតម្លៃគុណភាព។

- *បញ្ហាប្រឈមទី៩-ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ និងការត្រៀមអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការ*
  - ដំណោះស្រាយៈ ការអភិវឌ្ឍសមត្ថភាពរបស់នាយកសាលា មន្ត្រីគ្រប់គ្រងនៅថ្នាក់ មន្ទីរនិងការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ ការពង្រឹងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក ក្នុងការពិនិត្យតាមដាននិងគាំទ្រសាលារៀនគ្រប់កម្រិត។

- *បញ្ហាប្រឈមទី១០-ការអភិវឌ្ឍជំនាញបច្ចេកទេសដល់យុវជន*
  - ដំណោះស្រាយ : ការបង្កើនអត្រាចូលរៀន ស្តីពីបច្ចេកទេសអប់រំ បច្ចេកវិទ្យានិងវិទ្យាសាស្ត្រ និងបានរៀបចំខ្លួនជាស្រេចសម្រាប់ធ្វើសមាហរណកម្មក្នុងតំបន់ក្នុងឆ្នាំ២០១៥សម្រាប់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្មនិងកំណើនកាលានុវត្តភាពការងារ។

- *បញ្ហាប្រឈមទី១១-ការពង្រឹងសកម្មភាពយុវជននិងកីឡា*
  - ដំណោះស្រាយ : ការជំរុញសកម្មភាពអប់រំកាយនិងកីឡានៅតាមសាលារៀន និងសកម្មភាពសមាគមកីឡា ក្លឹបកីឡា និងការកសាងហេដ្ឋារចនាសម្ព័ន្ធ។

**តារាងទី២.៨ : អត្រាការសិក្សានិងអត្រាបញ្ចប់ការសិក្សា**

| | ឯកតា | ២០០៨/២០០៩ | ២០០៩/១០ | ២០១០/១១ | ២០១១/១២ | ២០១២/១៣ |
|---|---|---|---|---|---|---|
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | |
| សរុប | % | ៩៤,៤ | ៩៤,៨ | ៩៥,២ | ៩៦,៤ | ៩៧ |
| ប្រុស | % | ៩៤,៨ | ៩៥ | ៩៥,៨ | ៩៦,៧ | ៩៧ |
| ស្រី | % | ៩៤ | ៩៤,៦ | ៩៤,៦ | ៩៦,១ | ៩៧ |
| អត្រាសរុបនៃការសិក្សានៅមធ្យមសិក្សា (ថ្នាក់ទី៩) | | | | | | |
| សរុប | % | ៦១,៦ | ៥៨,១ | ៥៨,៥ | ៥៥ | ៥៣,៦ |
| ប្រុស | % | ៦៤ | ៥៩ | ៥៩ | ៥៥ | ៥៣,៩ |
| ស្រី | % | ៥៩,២ | ៥៧,១ | ៥៧,៨ | ៥៥ | ៥៤,២ |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា (ថ្នាក់ទី៦) | | | | | | |
| សរុប | % | ៨៥,៦ | ៨៣,២ | ៨៥,៣ | ៨៩,៧ | ៨៧,៤ |
| ប្រុស | % | ៨៥,៤ | ៨២,៨ | ៨៥,៦ | ៨៩,៦ | ៨៦,៩ |
| ស្រី | % | ៨៥,៧ | ៨៣,៦ | ៨៥ | ៨៩,៩ | ៨៧,៨ |
| អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៩) | | | | | | |
| សរុប | % | ៤៩,០ | ៤៨,៧ | ៤៦,៨ | ៤២,១ | ៤០,៦ |
| ប្រុស | % | ៥២,១ | ៥០ | ៤៤,៦ | ៤២,៦ | ៤២,២ |
| ស្រី | % | ៤៥,៩ | ៤៧,៣ | ៤៤,៣ | ៤១,៦ | ៤០,៤ |

*ប្រភព : ក្រសួងអប់រំ យុវជន និងកីឡា*

## ៦.២- ការលើកកម្ពស់វិស័យសុខាភិបាល

**២.២១៥-** *ផែនការយុទ្ធសាស្ត្រសុខាភិបាល២០០៨-២០១៥* បានរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តវិស័យសុខាភិបាលរបស់រាជរដ្ឋាភិបាល។ បច្ចុប្បន្ន ប្រទេសកម្ពុជាសម្រេចបានមុនកាលកំណត់នូវ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ២០១៥* លើសូចនាករមួយចំនួន ដូចជា ការកាត់បន្ថយអត្រាមរណភាពមាតា អត្រាមរណភាពកុមារអាយុក្រោមមួយឆ្នាំ អត្រាស្លាប់ដោយជំងឺរបេង និងអត្រាស្លាប់ដោយជំងឺគ្រុនចាញ់។ ចំណែកឯសូចនាករដទៃទៀត សង្ឃឹមថានឹងសម្រេចបានតាមគោលដៅនៅឆ្នាំ២០១៥ រួមមានអត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ អត្រាប្រេវ៉ាឡង់នៃការចម្លងមេរោគអេដស៍។

### ក- កម្មវិធីសុខភាពបន្តពូជ មាតា ទារក និងកុមារ

**២.២១៦-** សូចនាករសំខាន់ៗនៃសុខភាពបន្តពូជ មាតា ទារក និងកុមារ បាននិងកំពុងស្ថិតលើមាគ៌ាវឌ្ឍនភាពរវាងឆ្នាំ២០០៨និង២០១៣(តារាងទី២.៩)។ គម្រោងផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តឆ្មបរបស់រាជរដ្ឋាភិបាលសម្រាប់ការសម្រាលទារកកើតរស់ ត្រូវបានចាត់ទុកថាជាកត្តាគន្លឹះមួយនាំមកនូវកំណើននៃចំនួនសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ រួមគ្នាជា

មួយនឹងការពង្រាយបុគ្គលិកឆ្មបនៅគ្រប់មណ្ឌលសុខភាពទាំងអស់។ ការពង្រឹងសេវាសម្ភព សង្គ្រោះបន្ទាន់និងថែទាំទារកនៅមូលដ្ឋានសុខាភិបាល ការបង្កើនចំនួនបន្ទប់រង់ចាំការសម្រាល និងការពង្រឹងប្រព័ន្ធបញ្ជូនពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែក មាននិន្នាការវិជ្ជមាន។ ការពិនិត្យថែទាំគភ៌មុនសម្រាល និងការថែទាំក្រោយសម្រាល ការផ្តល់ថ្នាំបង្ការជំងឺតេតាណូស លើស្ត្រីមានគភ៌និងលើស្ត្រីវ័យបន្តពូជ ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និង អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបរបស់ស្ត្រីមានគ្រួសារក្នុងវ័យបន្តពូជ ត្រូវបានបង្កើននិងកែលម្អ។

**តារាងទី២.៩ : និន្នាការនៃសូចនាករកម្មវិធីសុខភាពបន្តពូជ មាតា ទារក និងកុមារ រវាងឆ្នាំ២០០៨និង២០១៣**

| សូចនាករ | លទ្ធផលសម្រេចបាន | | | | | លទ្ធផលប៉ាន់ស្មាន | គោលដៅ |
|---|---|---|---|---|---|---|---|
| | ឯកតា | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៣ |
| %នៃស្ត្រីមានគភ៌បានពិនិត្យផ្ទៃពោះមុនសម្រាលលើសពី២ដង ដោយបុគ្គលិកសុខាភិបាល | % | ៨៣ | ៧២ | ៨៤,២៥ | ៨៧ | ៨៧ | ៨៧ |
| %នៃស្ត្រីមានគភ៌បានទទួលឱសថបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន | % | ៨១ | ៥៦,៣០ | ៦១,១០ | ៦០ | ៦៥ | ៦៥ |
| សមាមាត្រនៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាល | % | ៦៣ | ៦៩ | ៧២ | ៧៤,៦៨ | ៧៥ | ៨០ |
| សមាមាត្រនៃការសម្រាលកូននៅមូលដ្ឋានសុខាភិបាល | % | ៤៤ | ៥២ | ៦១,៣៩ | ៦៦,៣៣ | ៦៦ | ៦៦ |
| អត្រានៃការសម្រាលកូនដោយវិធីវះកាត់ | % | ១,៦៩ | ២,០៣ | ២,៤៣ | ២,៨៣ | ៣,២ | ៣,២ |
| %នៃស្ត្រីក្រោយសម្រាលបានពិនិត្យ | % | - | - | - | ៤៣,៣៣ | ៤៤ | ៤៤ |
| អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់វិធីពន្យារកំណើតទំនើប | % | ២២,៣៣ | ២៨,២៧ | ២៩,១៨ | ៣០,៤៨ | ៣៧ | ៣៧ |
| ចំនួនមូលដ្ឋានសុខាភិបាលដែលផ្តល់សេវាសុខភាពបន្តពូជយុវវ័យ | ចំនួន | ៩១ | ២២៦ | ២៦០ | ២៥៥ | ២៧០ | ២៧០ |
| ចំនួនមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាពដែលផ្តល់សេវាសម្ភព សង្គ្រោះបន្ទាន់ និងថែទាំទារកកម្រិតមូលដ្ឋាន | ចំនួន | - | ២៨ | ៤៩ | ៦៧ | ១២២ | ១២២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ចំនួនមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាពដែលផ្តល់សេវាសម្ភពសង្គ្រោះបន្ទាន់ និងថែទាំទារកកម្រិតគ្រប់ជ្រុងជ្រោយ | ចំនួន | - | ២៦ | ៣១ | ៣៤ | ៤៣ | ៤៣ |
| ចំនួនលើកនៃការពិគ្រោះជំងឺករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ | ចំនួន | ១ | ១,៥១ | ១,៥៧ | ១,៧ | ១,៨ | ១,៨ |

*ប្រភព ៖ ក្រសួងសុខាភិបាល*

**២.២១៧-** មរណភាពទារកមានការប្រែប្រួលទៅតាមក្រុមប្រជាជន ដែលមានប្រាក់ចំណូលខុសៗគ្នាទៅតាមទីប្រជុំជននិងតំបន់ជនបទ។ តាមការអង្កេតប្រជាសាស្ត្រសុខភាពឆ្នាំ២០១០ មរណភាពទារកមានចំនួន៣៩ក្នុង១ ០០០កំណើតរស់សម្រាប់ក្រុមប្រជាជនក្រីក្រកម្រិត១ និង ៣៤ក្នុង១ ០០០កំណើតរស់សម្រាប់ក្រុមប្រជាជនក្រីក្រកម្រិត២ ខណៈពេលដែលមរណភាពទារកក្នុងក្រុមប្រជាជនអ្នកមានបំផុតគឺ១៦ក្នុង១ ០០០កើតរស់។ មរណភាពទារកនៅតំបន់ជនបទមានកម្រិតខ្ពស់(៣៥) ធៀបនឹងតំបន់ទីប្រជុំជន(១១)។

**២.២១៨-** វឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងឆ្នាំ២០១២ លើការកាត់បន្ថយប្រេវ៉ាឡង់ជំងឺកញ្ជ្រិល "សូន្យករណី" នៃជំងឺកញ្ជ្រិល។ សមាមាត្រនៃកុមារអាយុក្រោមមួយឆ្នាំបានទទួលវ៉ាក់សាំងបង្ការជំងឺកញ្ជ្រិលមាន៩៣%។ ឯអត្រាគ្របដណ្តប់នៃការផ្តល់វ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស៣លើក និងជំងឺរលាកថ្លើមប្រភេទបេ៣លើកលើកុមារគោលដៅត្រូវបានរក្សាក្នុងអត្រាលើសពី៩០% តាំងពីឆ្នាំ២០០៨។

**២.២១៩-** វិស័យសុខាភិបាលរួមចំណែកយ៉ាងសកម្មក្នុងការកែលម្អស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ ដោយបាននាំមកនូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ តាមរយៈការអនុវត្តសកម្មភាពមួយចំនួន រួមមាន ការផ្តល់មីក្រូសារជាតិដល់កុមារ ស្ត្រីមានគភ៌ និងស្ត្រីក្រោយសម្រាល ការផ្តល់ថ្នាំទម្លាក់ព្រូនដល់កុមារ ការផ្តល់ប្រឹក្សាអំពីការបំបៅដោះទារក និងការចិញ្ចឹមទារកនិងកុមារតូច ការបណ្តុះបណ្តាលគ្រូបង្គោលសហគមន៍ ព្រមទាំងការផ្តល់សេវាគ្រប់គ្រងកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។

## ខ- ប្រយុទ្ធប្រឆាំងជំងឺឆ្លង

**២.២២០-** *មេរោគអេដស៍/ជំងឺអេដស៍* ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពដ៏ធំធេងក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅពី១,៧%នៅឆ្នាំ ១៩៩៨ មក០,៧%នៅឆ្នាំ២០១២ ហើយតាមការប៉ាន់ស្មាន មេរោគអេដស៍នឹងបន្តថយដល់

០,៦% ក្នុងឆ្នាំ២០១៥។ ករណីថ្មីនៃការចម្លងមេរោគអេដស៍បានថយចុះពី១០០នាក់ ក្នុងមួយថ្ងៃ នៅឆ្នាំ២០០៨ មកត្រឹមតែ៣នាក់នៅឆ្នាំ២០១២។ ករណីឆ្លងថ្មី ត្រូវបានប៉ាន់ប្រមាណថាមាន ចំនួន១ ២០២នាក់នៅឆ្នាំ២០១២ និងបន្តធ្លាក់ចុះដល់៩២៤ករណីនៅឆ្នាំ២០១៥។ នៅចុងឆ្នាំ ២០១២នេះ ករណីមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍មានប្រមាណ៧៤ ៥៧២នាក់។ រីឯ អត្រាប្រេវ៉ាឡង់ការឆ្លងមេរោគអេដស៍ក្នុងចំណោមស្ត្រីមានគភ៌បានធ្លាក់ចុះពី១%នៅឆ្នាំ២០០៧ មក០,៣%នៅឆ្នាំ២០១២។ អត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូនបានធ្លាក់ចុះពី២៥%នៅឆ្នាំ ២០០៥ មក៨%នៅឆ្នាំ២០១២។ ខណៈដែលប្រេវ៉ាឡង់ក្រុមបុរសស្រឡាញ់បុរសបានស្ថិតក្នុង កម្រិតទាបគឺ២,១% ប្រេវ៉ាឡង់ស្ត្រីក្នុងសេវាកម្សាន្តសប្បាយ(ដែលមានភ្ញៀវលើសពី៧នាក់ក្នុង មួយអាទិត្យ) មានកម្រិតប្រមាណ១៣,៩% ហើយប្រេវ៉ាឡង់អ្នកចាក់គ្រឿងញៀនមាន២៤,៤%។ ការគ្របដណ្តប់នៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ក៏ត្រូវបានពង្រីក ហើយអត្រារស់ រាននៃអ្នកផ្ទុកមេរោគអេដស៍ក្រោយការព្យាបាលរយៈពេល១២ខែ ដោយឱសថប្រឆាំងមេរោគ អេដស៍មានកម្រិតលើសពី៨៥%។

**២.២២១-** ដើម្បីពង្រឹងនិងផ្តោតគោលដៅការងារបង្ការឲ្យបានកាន់តែប្រសើរឡើង ប្រទេស កម្ពុជាបាននិងកំពុងអនុវត្តស្តង់ដាជំរុញខ្លាំងក្លាក្នុងការបន្តការបង្ការថែទាំនិងព្យាបាល ដើម្បីផ្តល់ សេវាដល់ប្រជាជនប្រឈមមុខខ្ពស់ និងស្តង់ដាជំរុញខ្លាំងក្លាក្នុងការបង្ការការចម្លងមេរោគ អេដស៍ពីម្តាយទៅកូន។

**២.២២២-** ពីឆ្នាំ២០១១ដល់ឆ្នាំ២០១២ *អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍* បានទទួលជោគជ័យ ក្នុងការស្វែងរកការគាំទ្រពីដៃគូសំខាន់មួយចំនួន តាមរយៈការកៀរគរជំនួយហិរញ្ញប្បទាននិង ការចូលរួមពី*ក្រសួងមហាផ្ទៃ* ក្នុងការទទួលយកមុខនាទីសម្របសម្រួលជាមួយស្ថានប័នពាក់ព័ន្ធ សំដៅរៀបចំឲ្យមានបរិយាកាសគាំទ្រកម្មវិធីដៃគូសហគមន៍នគរបាល ដើម្បីគាំទ្រកិច្ចអន្តរាគមន៍ ប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ដែលប្រជាជនប្រឈមមុខខ្ពស់នៅបណ្តាចំណុចក្តៅចំនួន៣២ ប្រ កបដោយប្រសិទ្ធភាពខ្ពស់។ កម្មវិធីដៃគូសហគមន៍និងនគរបាលមានគោលបំណងធ្វើឲ្យប្រសើរ ឡើងនូវសុខដុមនីយកម្ម ការអនុវត្តច្បាប់ និងសេចក្តីណែនាំថ្មីៗដែលអាចនឹងប៉ះពាល់ដល់ក្រុម ប្រជាជនដែលប្រឈមមុខខ្ពស់ពីការផ្តល់សេវាសង្គម និងការបង្ការថែទាំ និងព្យាបាលសុខភាព។

**២.២២៣-** ដោយមានការគាំទ្ររបស់ដៃគូអភិវឌ្ឍ *ក្រសួងកិច្ចការនារី* បានប្រឹងប្រែងជំរុញឲ្យ វិស័យពាក់ព័ន្ធនានា ចូលរួមការងារកាត់បន្ថយអំពើហិង្សាដែលបង្កដោយវិសមភាពយេនឌ័រ។ *ក្រ សួងអប់រំ យុវជន និងកីឡា* បានខិតខំកៀរគរធនធានដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតប នឹងមេរោគអេដស៍ឆ្នាំ២០១២-២០១៣ សម្រាប់អន្តរាគមន៍ ជាពិសេសដល់យុវជននៅក្នុងនិង ក្រៅសាលា។ *ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ* បន្តជំរុញឲ្យនិយោជកនិងនិយោជិតចូល

រួមបញ្ចូលការអប់រំអំពីជំងឺអេដស៍នៅកន្លែងធ្វើការឲ្យបានកាន់តែច្រើនជាងមុន ដើម្បីឆ្លើយតបនឹងអភិក្រមដែលចាត់ទុកថាអេដស៍ជាភារកិច្ចទទួលខុសត្រូវរបស់គ្រប់វិស័យ។

**២.២២៤-** ការឆ្លើយតបនឹងមេរោគអេដស៍កំពុងតែបានជួបប្រទះនឹងភាពប្រឈមមួយចំនួនដែលមានចាប់ពីការងារបច្ចេកទេសកម្មវិធី ការងារស្ថាប័ន ការកៀរគរធនធាន និងប្រើប្រាស់ធនធានកិច្ចសហការភាពជាដៃគូដើម្បីអភិវឌ្ឍន៍ ដូចខាងក្រោមនេះ៖

- ការតាមដានស្ត្រីដែលមានផ្ទុកមេរោគអេដស៍និងទារក (មុន និងក្រោយពេលសម្រាលកូន) ច្រើនជួបការលំបាកពិសេសលើស្ត្រីដែលជាជនចំណាកស្រុក។ ស្ត្រីមួយចំនួនបានសម្រាលកូននៅតាមគ្លីនិកឯកជន ហើយមិនបានចូលរួមក្នុងកម្មវិធីការកាត់បន្ថយការចម្លងពីម្តាយទៅកូនដោយសារគ្មានការបញ្ជូនទៅរកសេវាផ្សេងៗទៀត ដូចជា ការធ្វើតេស្តឈាម និងការព្យាបាលមេរោគអេដស៍ និងការផ្តល់ប្រឹក្សា គ្មានទំនាក់ទំនងជាមួយនឹងកម្មវិធីជាតិ។
- ប្រព័ន្ធតាមដានអ្នកជំងឺអេដស៍ចាប់តាំងពីសេវាធ្វើតេស្តឈាមរហូតដល់សេវាត្រៀមផ្តល់ឱសថប្រឆាំងមេរោគអេដស៍ពុំទាន់មានដំណើរការនៅឡើយ មូលហេតុការតាមដានមិនទាន់ល្អ ជាហេតុធ្វើឲ្យមានការបាត់បង់អ្នកជំងឺដែលកំពុងត្រូវទទួលការព្យាបាល។ ប្រព័ន្ធផ្តល់ការគាំទ្រអ្នកជំងឺអេដស៍មិនឲ្យបោះបង់ការព្យាបាលនៅតាមសហគមន៍ ព្រមទាំងប្រព័ន្ធរាយការណ៍ការទទួលសេវានានា និងគុណភាពនៃសេវារបស់សហគមន៍ ក៏នៅមានកម្រិតផងដែរ។ ការតាមដានករណីអ្នកផ្ទុកមេរោគអេដស៍ដែលស្លាប់ដោយជំងឺរបេង ការតាមដានផលវិបាកនៃការព្យាបាល ការតាមដានភាពស៊ាំនៃឱសថ និងករណីដែលបរាជ័យនៃការព្យាបាលក៏នៅមានការខ្វះខាតផងដែរ។ នៅពេលដែលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានត្រូវពង្រីកកាន់តែធំឡើងៗ នោះការរឹតបន្តឹងការតាមដានករណីបោះបង់ការព្យាបាល និងការតាមដានភាពស៊ាំនៃឱសថ ដែលនាំឲ្យឈានដល់ការប្រើឱសថប្រឆាំងមេរោគអេដស៍ជួរទី២ គឺជាការងារចាំបាច់។
- ការដាក់ចេញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន អាចជាបច្ច័យប៉ះពាល់ដោយអចេតនាដល់ក្រុមប្រឈមមុខខ្ពស់ពីសំណាក់រដ្ឋអំណាចនិងនគរបាល ហើយជាបន្តមកក្រុមដែលប្រឈមមុខខ្ពស់នោះក៏លំបាកស្វែងរកសេវាថែទាំនិងព្យាបាល។
- ទាក់ទងនឹងការកៀរគរធនធាន និងវិនិយោគធនធានមានបញ្ហាសំខាន់មួយចំនួនគួរឲ្យកត់សម្គាល់ ពិសេស នៅថ្នាក់កណ្តាល ដូចជាការចុះថយនូវថវិកាជារួម ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការប្រើប្រាស់ធនធានថវិកា និងការខ្វះខាតព័ត៌មានជាយុទ្ធសាស្ត្រមកធ្វើជាហេតុផលនៃការសម្រេចចិត្តក្នុងការចង្អុលបង្ហាញពីការប្រើប្រាស់ថវិកាជាដើម។

**២.២២៥-** *ជំងឺរបេង* ការកាត់បន្ថយអត្រាប្រេវ៉ាឡង់ដោយសារជំងឺរបេងមានការធ្លាក់ចុះ។ អត្រាប្រេវ៉ាឡង់ជំងឺរបេងស្ងួតមេរោគរបេងបេកាវិជ្ជមាន បានធ្លាក់ចុះពី៣៨% ចន្លោះឆ្នាំ២០០២ និងឆ្នាំ២០១១ ឬ៤,២%ក្នុងមួយឆ្នាំ។ អត្រាស្លាប់ដោយសារជំងឺរបេងត្រូវបានកាត់បន្ថយមកត្រឹម៦៣ ក្នុងចំណោមប្រជាជន១០០ ០០០នាក់នៅឆ្នាំ២០១១។ អត្រានៃការព្យាបាលជំងឺរបេងជាសះស្បើយមានកម្រិតខ្ពស់លើសពី៨៥% ក្នុងរយៈពេល១៤ឆ្នាំជាប់ៗគ្នា។ វិធីសាស្ត្រព្យាបាលជំងឺរបេងដោយត្រួតពិនិត្យផ្ទាល់កម្រិតមូលដ្ឋាន(ដូតស៍) បានគ្របដណ្តប់មណ្ឌលសុខភាពពី៥០៦ នៅឆ្នាំ២០០៨ដល់៧៩៩នៅឆ្នាំ២០១២។ វិធីសាស្ត្រដូតស៍ក៏កំពុងត្រូវបានអនុវត្តនៅពន្ធនាគារចំនួន១៩កន្លែងនិងរោងចក្រសហគ្រាស១៩កន្លែង។ ភាពជាដៃគូរវាងសេវាសាធារណៈនិងឯកជនក្នុងការអនុវត្តយុទ្ធសាស្ត្រដូតស៍កំពុងអនុវត្តនៅ៣៥ស្រុកប្រតិបត្តិក្នុងខេត្តចំនួន១០។ សកម្មភាពសេវារបេង អេដស៍ពង្រីកពី៥៧ស្រុកប្រតិបត្តិនៅឆ្នាំ២០០៨ ទៅគ្រប់៧៩ស្រុកប្រតិបត្តិនៅឆ្នាំ២០១២។

**២.២២៦-** *ជំងឺគ្រុនចាញ់* រវាងឆ្នាំ២០០០និងឆ្នាំ២០១០កន្លងមកនេះ ជំងឺគ្រុនចាញ់ក្នុងសកលលោកបានថយចុះ២៥%(៩៩ប្រទេសមានជំងឺគ្រុនចាញ់) ក្នុងនោះ ជំងឺគ្រុនចាញ់ក្នុងប្រទេសកម្ពុជាបានថយចុះរហូតដល់៥៤%។ ចំនួនករណីជំងឺគ្រុនចាញ់ដែលបានទទួលការព្យាបាលនៅមន្ទីរពេទ្យនិងមណ្ឌលសុខភាពបានថយពី៥ករណីក្នុងប្រជាជន១ ០០០នាក់នៅឆ្នាំ២០០៧ មកនៅ២,៩ករណីនៅឆ្នាំ២០១២។ អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ក្នុងចំណោមប្រជាជន១០០ ០០០នាក់បានថយចុះពី០,៦៧នាក់នៅឆ្នាំ២០១១ និង០,៣២នាក់នៅឆ្នាំ២០១២ ដែលសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក្នុងផ្នែកនេះ។ មុងចំនួនជាង៣លាន៧សែនត្រូវបានចែកចាយដោយឥតគិតថ្លៃដល់ប្រជាជន ក្នុងឆ្នាំ២០១១និងឆ្នាំ២០១២នៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ២០១១-២០២៥*។

### គ- ប្រយុទ្ធប្រឆាំងជំងឺឆ្លង

**២.២២៧-** *ជំងឺគ្រុនឈាម* ចំនួនករណីនៃជំងឺគ្រុនឈាមដែលបានទទួលការព្យាបាលនៅមណ្ឌលសុខភាពសាធារណៈ បានកើនពី៩ ៥៤២ករណីនៅឆ្នាំ២០០៨ដល់៤២ ៣៨២ករណីនៅឆ្នាំ២០១២។ ទោះបីចំនួនករណីសម្រាកព្យាបាលក្នុងឆ្នាំ២០១២ ខ្ពស់ជាងបណ្តាឆ្នាំមុនៗក្តី ក៏អត្រាស្លាប់ដោយជំងឺគ្រុនឈាមនៅទូទាំងប្រទេសក្នុងឆ្នាំ២០១២ មានកម្រិតទាបត្រឹម០,៤០%។

**២.២២៨-** *ជំងឺឆ្លងលេចឡើងថ្មីៗ* ប្រទេសកម្ពុជាបានបន្តពង្រឹងការអនុវត្តនិយ័តកម្មសុខភាពអន្តរជាតិឆ្នាំ២០០៥ ដើម្បីបង្ការ ទប់ស្កាត់ និងគ្រប់គ្រងជំងឺឆ្លងដែលផ្ទុះឡើងនានា។ ប្រព័ន្ធតាមដានជំងឺផ្តាសាយបក្សី និងជំងឺលេចឡើងថ្មីៗ ត្រូវបានពង្រឹងនៅទូទាំងប្រទេស និងតាមច្រកទ្វារព្រំដែនអន្តរជាតិ។

### ឃ- ជំងឺមិនឆ្លងនិងជំងឺរ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈដទៃទៀត

២.២២៩- *ជំងឺមិនឆ្លងនិងជំងឺរ៉ាំរ៉ៃ* ជំងឺមហារីក ទឹកនោមផ្អែម បេះដូង សរសៃឈាម ចក្ខុរោគ សុខភាពមាត់ធ្មេញ និងផ្លូវចិត្តទាក់ទងនឹងការប្រើប្រាស់គ្រឿងញៀនជាដើម បានដាក់បន្ទុកធ្ងន់ធ្ងរលើប្រព័ន្ធសុខាភិបាល ជាពិសេស មន្ទីរពេទ្យ ដោយសារការថែទាំនិងព្យាបាលជំងឺប្រភេទនេះត្រូវប្រើរយៈពេលយូរ និងត្រូវចំណាយថវិកាច្រើនបំផុត។ ដោយឡែកគ្រោះថ្នាក់ចរាចរណ៍ និងរបួសផ្សេងៗនៅតែជាបញ្ហាសុខភាពសាធារណៈដ៏ចម្បង។

២.២៣០- ចំពោះសុខភាពមាត់ធ្មេញពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ ការអប់រំលើកកម្ពស់សុខភាពមាត់ធ្មេញ និងលាងសម្អាតដៃបានអនុវត្តនៅ៦៤៥សាលាបឋមសិក្សា និងផ្តល់ការបណ្តុះបណ្តាលដល់សិស្សានុសិស្សចំនួន១៧ ៥៤៣៣នាក់។

### ង- អន្តរាគមន៍សុខភាពសាធារណៈ

២.២៣១- *សុវត្ថិភាពចំណីអាហារ* ការលើកកម្ពស់សុវត្ថិភាពចំណីអាហារ ត្រូវបានពង្រឹងតាមរយៈសកម្មភាពសំខាន់ៗមួយចំនួន ដូចជា ការបណ្តុះបណ្តាលគ្រូបង្គោលស្តីអំពីសុវត្ថិភាពចំណីអាហារ ការអប់រំពីអនាម័យចំណីអាហារដល់ថៅកែ អ្នកគ្រប់គ្រង និងចុងភៅនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន និងសិប្បកម្មផលិតចំណីអាហារ។ ក្រៅពីនោះមានការចុះត្រួតពិនិត្យអនាម័យចំណីអាហារនៅតាមអាហារដ្ឋាននិងភោជនីយដ្ឋាននានាក្នុងរាជធានី ខេត្ត។

២.២៣២- *ថ្នាំជក់និងសុខភាព* សកម្មភាពសំខាន់ៗដែលបានអនុវត្តរួមមាន រៀបចំទិវាពិភពលោកគ្មានថ្នាំជក់ ពង្រឹងកិច្ចដំណើរការរបស់គណៈកម្មការអន្តរក្រសួង ដើម្បីអប់រំនិងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ និងលេខាធិការដ្ឋានក្របខ័ណ្ឌអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការជក់បារី និងប្រកាសទីកន្លែងធ្វើការគ្មានផ្សែងបារីបានចំនួន១៦៥កន្លែង ក្នុងនោះមន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យបង្អែក ការិយាល័យស្រុកប្រតិបត្តិ មណ្ឌលសុខភាព មន្ទីរអប់រំ យុវជន និងកីឡា សាលាគរុកោសល្យនិងវិក្រឹតការ សាលាគរុកោសល្យភូមិភាគ និងវិទ្យាល័យ អនុវិទ្យាល័យ។

២.២៣៣- *សុខភាពបរិស្ថាន* គណៈកម្មាធិការជាតិបរិស្ថាននិងសុខភាពនិងមន្ត្រីបច្ចេកទេសអន្តរក្រសួង បានពង្រឹងការអនុវត្តតួនាទីរបស់ខ្លួននិងបានផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីបរិស្ថាននិងសុខភាព ផលិតស្ពតវីដេអូនិងផ្ទាំងរូបភាពស្តីពីផលប៉ះពាល់សុខភាព ដែលបណ្តាលមកពីការប្រើប្រាស់សារធាតុគីមីនិងការប្រែប្រួលអាកាសធាតុ ត្រូវបានចាក់ផ្សាយតាមស្ថានីយទូរទស្សន៍នានា។

២.២៣៤- *ការគ្រប់គ្រងគ្រោះមហន្តរាយ* ក្រសួងសុខាភិបាល មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពបានត្រៀមបម្រុងជាប្រចាំក្នុងការឆ្លើយតបទៅគ្រោះមហន្តរាយផ្សេងៗ ពិសេសក្នុងតំបន់ដែលរងផលប៉ះពាល់ដោយទឹកជំនន់ បានចុះធ្វើសកម្មភាពនិងឆ្លើយតបទាន់ពេលវេលាក្នុងការទប់ស្កាត់ការឆ្លងជំងឺនៅពេលមានទឹកជំនន់និងក្រោយពេលទឹកស្រក។

### ច- សុខាភិបាលសាធារណៈ

២.២៣៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសុខាភិបាលសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់ដោយផ្អែកតាមផែនការគ្របដណ្តប់សុខាភិបាលពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ ក្នុងនោះចំនួនមណ្ឌលសុខភាពបានកើនពី៩៦៧ទៅ១ ០២៤ មន្ទីរពេទ្យកើនពី៨៧ទៅ៩១។ មន្ទីរពេទ្យទាំងអស់មានចំនួនគ្រែសរុប១២ ៦៥១ ក្នុងនោះ គ្រែអ្នកជំងឺមាន២ ៧៤១។ គួរកត់សម្គាល់ថាចំនួនគ្រែនៅមន្ទីរពេទ្យសាធារណៈ បានកើនឡើងជារៀងរាល់ឆ្នាំពី៨ ៩៨៦នៅឆ្នាំ២០០៨ដល់១២ ៦៥១នៅឆ្នាំ២០១២។ ឯអត្រាប្រើប្រាស់គ្រែក៏បានកើនពី៦១,៣១%នៅឆ្នាំ២០០៨ទៅ៨៦,១៦%នៅឆ្នាំ២០១២។

### ឆ- ថវិកាជាតិសម្រាប់វិស័យសុខាភិបាល

២.២៣៦- រាជរដ្ឋាភិបាលបានបង្កើនកញ្ចប់ថវិកាជាតិជារៀងរាល់ឆ្នាំ ហើយចំណាយសាធារណៈលើវិស័យសុខាភិបាលមានការកើនឡើងជាលំដាប់។ តារាងទី២.១០ បង្ហាញពីនិន្នាការនៃការវិភាជថវិកាជាតិ និងការចំណាយសម្រាប់វិស័យសុខាភិបាលរវាងឆ្នាំ២០០៨-២០១២។

**តារាងទី២.១០ : និន្នាការនៃការវិភាជថវិកាជាតិ សម្រាប់វិស័យសុខាភិបាលពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២**

| ថវិកាវិភាជន៍ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ផែនការថវិកាអនុម័ត (លានរៀល) | ៤០៤ ៨០៣,៨ | ៥០៣ ៨៤៦,៦ | ៦០០ ០៥៦ | ៦៩៤ ៣៣១,៤ | ៧៩៤ ២១៣,៥ |
| %នៃកំណើនថវិកាវិភាជប្រចាំឆ្នាំ | ២០,១% | ២៤,៥% | ១៩% | ១៥,៧% | ១៤,៣% |
| **ថវិកាចំណាយ** | | | | | |
| ចំណាយចរន្ត (លានរៀល) | ៤២៦ ៧៩០,៣ | ៥២៤ ១៤៦,៣ | ៦១៥ ៣៧៥,៣ | ៦៥៥ ០៩៨,៩ | ៧៥៩ ២០៦,៦ |
| %នៃចំណាយធៀបនឹងផែនការថវិកាអនុម័ត | ១០៥,៤% | ១០៤% | ១០២,៦% | ៩៤,៣% | ៩៦% |

*ប្រភព : ក្រសួងសុខាភិបាល*

២.២៣៧- *ក្រសួងសុខាភិបាល*កំពុងអនុវត្តយន្តការហិរញ្ញប្បទានគាំពារជនក្រីក្រ មានជាអាទិ៍ការលើកលែងការបង់ថ្លៃសេវា មូលនិធិសមធម៌សុខភាព និងបណ្ណសុខភាពបន្តពូជ។ ចំពោះប្រជាពលរដ្ឋមិនសូវមានធនធាន ត្រូវបានគាំពារដោយគម្រោងធានារ៉ាប់រងសុខភាពសហគមន៍។ ប្រជា

ជនប្រហែលជា២,៥លាននាក់បានទទួលមូលនិធិសមធម៌នេះ និងបានពង្រីកពី១០១មណ្ឌលសុខភាពនៅឆ្នាំ២០០៨ទៅ៣៧០មណ្ឌលសុខភាពនៅឆ្នាំ២០១២ និងពី៤៤ទៅ៦៤មន្ទីរពេទ្យនៅក្នុងរយៈពេលដូចគ្នា។ បណ្ណសុខភាពបន្តពូជសម្រាប់ស្ត្រីក្រីក្របានចាប់ផ្តើមអនុវត្ត នៅខែមករា ឆ្នាំ២០១១ ហើយបច្ចុប្បន្នកំពុងត្រូវបានអនុវត្តនៅក្នុងមណ្ឌលសុខភាពចំនួន១១៨ មន្ទីរពេទ្យបង្អែកចំនួន៥ និងគ្លីនិកអង្គការមិនមែនរដ្ឋាភិបាលចំនួន៤ នៅក្នុង៩ស្រុកប្រតិបត្តិ ក្នុងខេត្តចំនួន៣។ ឯគម្រោងធានារ៉ាប់រងសុខភាពកំពុងត្រូវបានអនុវត្តនៅ១៧៩មណ្ឌលសុខភាព និង១៣មន្ទីរពេទ្យបង្អែកក្នុង១១រាជធានី ខេត្ត ដែលមានប្រជាជនចំនួន១៦៦ ៦៣នាក់។ នៅឆ្នាំ២០១២ ការចំណាយលើកម្មវិធីមូលនិធិសមធម៌ដោយថវិកាបដិភាគរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍវិស័យសុខាភិបាលមានទឹកប្រាក់សរុប៩ ៤៥៧ ៩៥៤ដុល្លារអាមេរិក។

**២.២៣៨-** *ក្រសួងសុខាភិបាល* បានដាក់ឲ្យប្រើប្រាស់*ប្រព័ន្ធទិន្នន័យព័ត៌មានសុខាភិបាល* តាមគេហទំព័រនៅឆ្នាំ២០១១។ ប្រព័ន្ធនេះអនុញ្ញាតឲ្យ*ក្រសួងសុខាភិបាល* ទទួលរបាយការណ៍ប្រចាំខែស្តីអំពីលទ្ធផលនៃការផ្តល់សេវាពិនិត្យនិងព្យាបាលជំងឺពី១ ០២៤មណ្ឌលសុខភាព និង៩១មន្ទីរពេទ្យទូទាំងប្រទេស។ ក្រៅពីនេះក្រសួងបានអភិវឌ្ឍនិងប្រើប្រាស់ប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យាមួយចំនួនទៀត ដូចជាសម្រាប់ការគ្រប់គ្រងបុគ្គលិក ការបណ្តុះបណ្តាលធនធានមនុស្ស ការគ្រប់គ្រងឱសថ បរិក្ខារ ផែនការការគ្របដណ្តប់សុខាភិបាល ផែនការប្រតិបត្តិប្រចាំឆ្នាំ។ល។

**២.២៣៩-** *ប្រព័ន្ធអភិបាលកិច្ចសុខាភិបាល* ក្រសួងបានបង្ក្រាបឱសថស្ថានរងគ្មានច្បាប់អនុញ្ញាតឲ្យប្រកបអាជីវកម្មដោយជោគជ័យទាំងស្រុង ពី៤៧,៥%នៅឆ្នាំ២០០៨ដល់០%នៅឆ្នាំ២០១១។ ឯកន្លែងលក់ឱសថអត់ច្បាប់ត្រូវបានលុបបំបាត់ទាំងស្រុងនៅចុងឆ្នាំ២០១១។ ការលុបបំបាត់ទាំងស្រុងកន្លែងលក់ឱសថអត់ច្បាប់បានធ្វើឲ្យចរាចរឱសថក្លែងក្លាយ ឱសថអន់គុណភាព និងឱសថដែលគ្មានប្រភពច្បាស់លាស់ត្រូវបានកាត់បន្ថយដល់កម្រិតទាបបំផុត០,៥០% នៅឆ្នាំ២០១០ មក០,១៨% នៅឆ្នាំ២០១១ និងចុះមកនៅត្រឹម០,១៣%នៅឆ្នាំ២០១២។

**២.២៤០-** *អន្តរវិស័យ-ការងារយេនឌ័រ* ក្រសួងសុខាភិបាលបានផ្តល់ការបណ្តុះបណ្តាដល់សមាជិកក្រុមការងារយេនឌ័រ នៅរាជធានី ខេត្ត ដើម្បីលើកម្ពស់ការយល់ដឹងអំពីបញ្ហាយេនឌ័រ និងអន្តរាគមន៍ពាក់ព័ន្ធ។ ក្រុមការងារយេនឌ័រថ្នាក់ក្រសួងបានចុះអភិបាលដើម្បីពង្រឹងសមត្ថភាពក្រុមការងារយេនឌ័ររាជធានី ខេត្ត។

**២.២៤១-** *អន្តរវិស័យ-ការសម្របសម្រួល* ការសម្របសម្រួលនិងកិច្ចសហការក្នុងវិស័យសុខាភិបាលតាមរយៈកិច្ចដំណើរការនៃក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ក្រសួង និងថ្នាក់រាជធានី ខេត្ត។ ក្រុមការងារបច្ចេកទេសទាំងពីរបានអនុវត្តការប្រជុំប្រចាំខែយ៉ាងទៀតទាត់ ក្រៅពី

នេះ នៅមានយន្តការសំខាន់ៗខ្លះ ដូចជា ការពិនិត្យរួមគ្នាលើសមិទ្ធផលវិស័យសុខាភិបាល និងការពិនិត្យវិនិច្ឆ័យផែនការប្រតិបត្តិប្រចាំឆ្នាំ។

**២.២៤២-** ដោយទទួលស្គាល់ផលប៉ះពាល់ជាអន្តរវិស័យ ក្នុងបញ្ហាប្រឈមនឹងការកែលម្អស្ថានភាពអាហារូបត្ថម្ភ *រាជរដ្ឋាភិបាលកម្ពុជា* បានបង្កើតអង្គភាពផ្សេងៗ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ។ *ក្រសួងសុខាភិបាល* បានចូលរួមក្នុងសកម្មភាពអង្គភាព ដូចជាក្នុងក្រុមប្រឹក្សាជាតិសម្រាប់អាហារូបត្ថម្ភ*នៅក្រសួងផែនការ* និងក្រុមការងារបច្ចេកទេសស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

**២.២៤៣-** ទោះបី*រាជរដ្ឋាភិបាលកម្ពុជា* សម្រេចបានសមិទ្ធផលគួរឲ្យកត់សម្គាល់ ក្នុងការកែលម្អឲ្យកាន់តែល្អប្រសើរឡើងនូវស្ថានភាពសុខភាពរបស់ប្រជាជនកម្ពុជា ពិសេសសុខភាពស្ត្រី កុមារ និងប្រជាជនក្រីក្រក៏ដោយ ក៏បញ្ហាប្រឈមចម្បងៗមួយចំនួនកំពុងស្ថិតនៅចំពោះមុខ៖

- បើប្រៀបធៀបនឹងបណ្តាប្រទេសក្នុងតំបន់ អត្រាមរណភាពរបស់មាតា ទារក និងកុមារ និងកង្វះអាហារូបត្ថម្ភនៅមានកម្រិតខ្ពស់នៅឡើយ។
- ប្រព័ន្ធសុខាភិបាលដើម្បីដោះស្រាយ ជំងឺឆ្លង និងជំងឺមិនឆ្លងរ៉ាំរ៉ៃ ព្រមទាំងបញ្ហាសុខភាពសាធារណៈ ដទៃទៀត មិនទាន់មានប្រសិទ្ធភាព។
- រាជរដ្ឋាភិបាលទទួលស្គាល់ថា ការផ្តល់សេវាសុខាភិបាលបច្ចុប្បន្នទាំងបរិមាណនិងគុណភាពនៅមិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការជាក់ស្តែងផ្នែកសុខភាពរបស់ប្រជាជននៅឡើយ ដោយសារមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកទូទាំងប្រទេសពុំទាន់បានផ្តល់សេវាសុខភាពពេញលេញ ដោយសារកង្វះសម្ភារៈឧបករណ៍ពេទ្យនិងបច្ចេកវិទ្យាវេជ្ជសាស្ត្រទំនើប កង្វះបុគ្គលិក គ្រូពេទ្យ ពិសេស មណ្ឌលសុខភាពសាធារណៈនៅតាមតំបន់ជនបទ គួបផ្សំនឹងការលើកទឹកចិត្តបុគ្គលិកនៅមានកម្រិត ព្រមទាំងការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូពេទ្យបុគ្គលិកនៅមិនទាន់មានសង្គតិភាពនៅគ្រប់មូលដ្ឋានសុខាភិបាល។
- យន្តការនិយ័តកម្មវិស័យឯកជនចាំបាច់ត្រូវពង្រឹងថែមទៀត។
- ទោះបីគម្រោងហិរញ្ញប្បទានគាំពារប្រជាជនក្រីក្រត្រូវបានពង្រីកជាបន្តបន្ទាប់ក៏ដោយ ក៏ការគ្របដណ្តប់នៃការគាំពារសុខភាពសង្គមទាំងនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅមានកម្រិតទាបនៅឡើយ។

## ៦.៣- ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ

**២.២៤៤-** រយៈពេល៥ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ជាអតិបរមាទៅលើការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រីលើគ្រប់វិស័យនិងគ្រប់

កម្រិត។ យេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុង*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣* ដោយបានបញ្ចូលនូវសូចនាករជាក់លាក់មួយចំនួនសម្រាប់តាមដានការអនុវត្ត។

### ក- ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី

**២.២៤៥-** រាជរដ្ឋាភិបាលគិតថា កម្មករស្ត្រីដែលចូលរួមក្នុងកម្លាំងពលកម្មដើម្បីទទួលបានប្រាក់កម្រៃ/ប្រាក់បៀវត្សមានការកើនឡើងគឺជាសញ្ញាវិជ្ជមានមួយ ដែលទាមទារឲ្យមានសមភាពយេនឌ័រ។ ទិន្នន័យស្តីពីបញ្ហាសមភាពយេនឌ័រ ក្នុងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩ ឆ្នាំ២០១០ និងឆ្នាំ២០១១ បានបង្ហាញថា ផលធៀបនេះស្ថិតក្នុងចន្លោះ៤២%ដល់៤៥% តិចជាងចំណុចដៅដែលមាន៥០%។

**២.២៤៦-** សមភាពយេនឌ័រ ក្នុងវិស័យកសិកម្មនិងឧស្សាហកម្ម ត្រូវបានធ្វើឲ្យសម្រេចបានលើសចំណុចដៅ ទោះបីវិស័យសេវានៅតែមានសមាមាត្រទាបនៅឡើយ។ បញ្ហានេះមិនមែនមកពីការរើសអើងក្នុងទីផ្សារពលកម្មនោះទេ ប៉ុន្តែវាជារចនាសម្ព័ន្ធរបស់វិស័យនេះ។ សហគ្រាសជាច្រើន គឺជាសហគ្រាសលក់រាយដោយមានបុគ្គលិក១ឬ២នាក់ និងទំហំប្រាក់បៀវត្សនៅមានកម្រិតទាបនៅឡើយ។

**តារាងទី២.១១ : ភាគរយស្ត្រីធ្វើការងារមានប្រាក់កម្រៃតាមវិស័យ**

| ការចូលរួមរបស់ស្ត្រីក្នុងការងារមានប្រាក់កម្រៃតាមវិស័យ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|
| សមាមាត្រស្ត្រីធ្វើការងារមានប្រាក់កម្រៃក្នុងវិស័យកសិកម្ម | ៥១,៨ | ៥៣,១ | ៥៣,៨ |
| សមាមាត្រស្ត្រីធ្វើការងារមានប្រាក់កម្រៃក្នុងវិស័យឧស្សាហកម្ម | ៧១,២ | ៧៣,៧ | ៧០,៨ |
| សមាមាត្រស្ត្រីធ្វើការងារមានប្រាក់កម្រៃក្នុងវិស័យសេវា | ២៩,៩ | ២៧,៤ | ២៨,៨ |
| %ស្ត្រីធ្វើការងារមានប្រាក់កម្រៃសរុប | ៤៥ | ៤២,២ | ៤៥,៨ |

**២.២៤៧-** រាជរដ្ឋាភិបាលបាននិងកំពុងខិតខំប្រឹងប្រែងក្នុងការផ្តល់កាលានុវត្តភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រីជាបន្តបន្ទាប់ និងជួយឲ្យស្ត្រីអាចបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ក្នុងនោះរួមមានការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅក្នុងខេត្តចំនួន១៣ ដែលមានតួនាទីសំខាន់ក្នុងការផ្តល់ជំនាញវិជ្ជាជីវៈនិងសេវាអភិវឌ្ឍន៍អាជីវកម្មជូនស្ត្រី។ ជាលទ្ធផល ស្ត្រីចំនួន១៣ ១០២នាក់ទទួលបានជំនាញវិជ្ជាជីវៈពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី។ សមាគមសហគ្រិនស្ត្រីកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ២០១២ ដែលមានសមាជិកចំនួន១៥០នាក់ ក្នុងគោលបំណងជួយអភិវឌ្ឍមុខរបររបស់ស្ត្រី ព្រមទាំងពង្រឹងសំឡេងស្ត្រីសហគ្រិននៅក្នុងវិស័យឯកជន។

២.២៤៨- ក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៣ ដែលផ្តោតលើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី ក៏ត្រូវបានរៀបចំឡើងដើម្បីកៀរគរការចូលរួមពីស្ថាប័នរដ្ឋនិងឯកជន ព្រមទាំងដៃគូអភិវឌ្ឍ ក្នុងការសម្រេចបាននូវយុទ្ធសាស្ត្រ៣គឺ៖

- ការពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈដល់ស្ត្រីទៅតាមតម្រូវការទីផ្សារ។
- ការអភិវឌ្ឍសហគ្រាសខ្នាតតូចនិងមធ្យម។
- ការបង្កើនជីវភាពនៅជនបទ។

២.២៤៩- ទោះបីជាមានការប្រឹងប្រែងជាច្រើនក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ៖

- កិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយក្នុងការផ្តល់សេវាបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក៏ដូចជាការផ្តល់អន្តរាគមន៍នានាដើម្បីជំរុញឲ្យស្ត្រីទទួលបានកាលានុវត្តភាពការងារឬការអភិវឌ្ឍសហគ្រិនភាពរបស់ស្ត្រី។
- កិច្ចសហការឬការទុកចិត្តរវាងវិស័យសាធារណៈនិងវិស័យឯកជន នៅមានការខ្វះខាតនៅឡើយ ដើម្បីបង្កើនសេវារបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី។

### ខ- កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី

២.២៥០- រាជរដ្ឋាភិបាលបានចាត់ទុកអំពើហិង្សាជាបទល្មើសត្រូវផ្តន្ទាទោសដោយច្បាប់ និងបានអនុម័តបទប្បញ្ញត្តិនានាដើម្បីការពារស្ត្រីដូចជា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌជាដើម។ ចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព បានរួមចំណែកលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ជាពិសេស គ្មានអំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ។

២.២៥១- *ក្រសួងកិច្ចការនារី* បានពិនិត្យឃើញថាករណីអំពើហិង្សាក្នុងគ្រួសារ មានការថយចុះពី៤១ ៤៧៤ករណីក្នុងឆ្នាំ២០០៦ មកត្រឹម៣៥ ៤០៨ករណីក្នុងឆ្នាំ២០០៩។ យោងតាមទិន្នន័យក៏បានបង្ហាញឲ្យឃើញដែរថាក្នុងចន្លោះឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ មានការកើនឡើងនូវចំនួនប្រជាពលរដ្ឋដែលយល់ថាអំពើហិង្សាលើស្ត្រីជាអំពើល្មើសច្បាប់។

២.២៥២- មាត្រាទី២០នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្នុងដំណើការចេញដីការការពារ គឺជាសមត្ថកិច្ចរបស់តុលាការក្នុងការចេញដីការនៅពេលមានការស្នើសុំពីជនរងគ្រោះ។ ជាក់ស្តែង នៅឆ្នាំ២០១២ ចំនួនដីការការពារដែលបានចេញដោយតុលាការមានចំនួន១៤ដីការ។ ដោយឡែក មាត្រា១៤នៃច្បាប់ដែលពាក់ព័ន្ធនឹងការ

ចេញសេចក្តីសម្រេចរដ្ឋបាលដោយអាជ្ញាធរមូលដ្ឋាននៅឆ្នាំ២០០៩ មាន១៣ ០៥៣ដង និងនៅឆ្នាំ២០១០ មានចំនួន១១ ១៣៦ដង យោងតាមទិន្នន័យថ្នាក់ឃុំ សង្កាត់។ បញ្ហាដែលមិនអាចសម្រេចបានទៅតាមគោលដៅដែលកំណត់លើការចេញដីកាការពារដោយតុលាការ ដោយសារការចុះបញ្ជីរឿងក្តីតាមទម្រង់ថ្មីនៅតាមតុលាការនៅមិនទាន់ចប់សព្វគ្រប់នៅឡើយ។

**២.២៥៣-** ដោយមានកិច្ចសហការរវាង*ក្រសួងកិច្ចការនារី* និងអង្គការដើម្បីជួយស្ត្រីមានវិបត្តិ បានផ្តល់ប្រឹក្សាដល់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារមានចំនួន៧២០នាក់ នៅក្នុងឆ្នាំ២០១២ និង២០១៣ នៅខេត្តសៀមរាប បន្ទាយមានជ័យ និងភ្នំពេញ។ ចំនួននេះមិនទាន់មានការឆ្លើយតបទៅនឹងចំនួនដែលបានកំណត់នៅក្នុង*ផ.យ.អ.ជ បច្ចុប្បន្នកម្ម២០០៩-២០១៣* នៅឡើយទេ។ ក្នុងឆ្នាំ២០១៣មន្ត្រីនៃ*ក្រសួងកិច្ចការនារី*និងរាជធានី ខេត្តមានចំនួន១៤១នាក់ ដែលទទួលបាននីតិសម្បទាជាភ្នាក់ងារនគរបាលយុត្តិធម៌ និងបានបំពេញតួនាទីស្របតាមច្បាប់កំណត់។

**២.២៥៤-** ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស *ក្រសួងកិច្ចការនារី* បានរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តក្នុងឆ្នាំ២០១២-២០១៤ និងធ្វើវិសោធនកម្មលើអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរស្ត្រីនិងកុមារ និងការជួយជនរងគ្រោះដោយការជួញដូរ។ ក្រសួងក៏បានចុះហត្ថលេខាលើវិសោធនកម្មនៃកិច្ចព្រមព្រៀងរវាងកម្ពុជានិងវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរមនុស្សនិងជួយជនរងគ្រោះដោយការជួញដូរ ព្រមទាំងបានរៀបចំសេចក្តីព្រាងផែនការសកម្មភាពសម្រាប់អនុវត្តក្នុងឆ្នាំ១០១៣-២០១៤។

### គ- ការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈនិងនយោបាយ

**២.២៥៥-** *ស្ត្រីក្នុងអង្គនីតិប្បញ្ញត្តិ* ចំនួនស្ត្រីជាសមាជិករដ្ឋសភាបានកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេល៤អាណត្តិកន្លងមក។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ធ្វើការស្វែងរកការគាំទ្រមតិជាមួយគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនឹងគណបក្សនយោបាយនានា ដើម្បីបង្កើនចំនួនសមាជិកសភាជាស្ត្រីក្នុងការបោះឆ្នោតឆ្នាំ២០១៣កន្លងមកនេះ ក៏ដូចជាឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានាឆ្នាំ២០១៥។ សមាមាត្រស្ត្រីដែលជាប់ជាសមាជិករដ្ឋសភាបានធ្លាក់ចុះបន្តិចពី២១% ក្នុងឆ្នាំ២០០៨ មក២០% ក្នុងឆ្នាំ២០១៣។ រីឯសមាជិកព្រឹទ្ធសភាជាស្ត្រីមានអត្រាថេរគឺ១៤,៧៥% ក្នុងឆ្នាំ១៩៩៩ដល់ឆ្នាំ២០១២។

**២.២៥៦-** *ស្ត្រីជាសមាជិករាជរដ្ឋាភិបាល* រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ក្នុងការបង្កើនចំនួនស្ត្រីក្នុងជួរថ្នាក់ដឹកនាំជាបន្តបន្ទាប់ តាមរយៈការលើកទឹកចិត្តនិងតែងតាំងស្ត្រីជាថ្នាក់ដឹកនាំនៅគ្រប់ក្រសួង ស្ថាប័ន។ ជាក់ស្តែងមានស្ត្រី១រូប ជាឧបនាយករដ្ឋមន្ត្រី ស្ត្រីចំនួន៣រូបជា

រដ្ឋមន្ត្រី ៣៨រូបជារដ្ឋលេខាធិការ និង៤៨រូបជាអនុរដ្ឋលេខាធិការ និងអ្នកមានឋានៈស្មើ។ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងនេះ រាជរដ្ឋាភិបាលសង្ឃឹមថាស្ត្រីនឹងបានចូលរួមកាន់តែច្រើនក្នុងតួនាទីធ្វើសេចក្តីសម្រេចនាអាណត្តិខាងមុខ។

២.២៥៧- *ស្ត្រីក្នុងរដ្ឋបាលសាធារណៈ* ក្នុងឆ្នាំ២០០៧ តាមរយៈរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ *រាជរដ្ឋាភិបាលកម្ពុជា* បានចេញសេចក្តីណែនាំដល់ក្រសួងស្ថាប័នរដ្ឋទាំងអស់ក្នុងការកម្រិតចំនួនស្ត្រីពី២០ទៅ៥០% នៅពេលជ្រើសរើសមន្ត្រីថ្មី។ ជាលទ្ធផលចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រីបានកើនឡើងពី៣២% ក្នុងឆ្នាំ២០០៧ដល់៣៥% ក្នុងឆ្នាំ២០១២។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាលក៏បានចេញព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រីដល់អាយុ៦០ឆ្នាំនិងតាមការស្ម័គ្រចិត្ត។

២.២៥៨- *ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិ :* ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានតែងតាំងស្ត្រីជាអភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស។ បច្ចុប្បន្ននេះ សមាមាត្រស្ត្រីជាអភិបាលរង រាជធានី ខេត្ត គឺ ២១% (ឆ្នាំ២០១៣) អភិបាលក្រុង ស្រុក ខណ្ឌ ជាស្ត្រី ចំនួន២រូប និងអភិបាលរងក្រុង ស្រុក ខណ្ឌ១៨៦រូប (២៩%)។ ទោះបីពុំទាន់មានស្ត្រីជាអភិបាលរាជធានី ខេត្ត ក៏ដោយក៏រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ដើម្បីឲ្យមានស្ត្រីក្នុងតំណែងនេះផងដែរនាពេលអនាគត។ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឆ្នាំ២០០៩ មានស្ត្រីចំនួន៣៨រូប(១០%) ដែលបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និង៣៦៣រូប(១៣%) ជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស។ សមាមាត្រស្ត្រីជាក្រុមប្រឹក្សា ឃុំ/សង្កាត់មានការកើនឡើងពី១៥% ក្នុងឆ្នាំ២០០៧ ដល់១៨% ក្នុងឆ្នាំ២០១២។

២.២៥៩- *ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ :* ក្រោមការគាំទ្រផ្នែកបច្ចេកទេសពី *ក្រសួងកិច្ចការនារី* និងដៃគូអភិវឌ្ឍ ក្រសួង ស្ថាប័នពាក់ព័ន្ធបាននិងកំពុងរៀបចំបង្កើតផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យរបស់ខ្លួនជាបន្តបន្ទាប់។ ចាប់ពីឆ្នាំ២០០៩មកទល់បច្ចុប្បន្ននេះ មានក្រសួងចំនួន២៤បានបង្កើតនិងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងក្រសួងស្ថាប័នរបស់ខ្លួនដែលក្នុងនោះក្រសួង ស្ថាប័ន ចំនួន១៦បានទទួលនិងប្រើប្រាស់ថវិកាជាតិ។

២.២៦០- *យេនឌ័រនិងសុខភាព :* ផែនការយុទ្ធសាស្ត្រសុខាភិបាល២០០៨-២០១៥ បានផ្តល់អាទិភាពខ្ពស់លើការផ្តល់សេវាថែទាំសុខភាពសម្រាប់ប្រជាជនទាំងបុរស ទាំងស្ត្រី។ រាជរដ្ឋាភិបាល បាននិងកំពុងដាក់ឲ្យអនុវត្តកម្មវិធីជាច្រើនសំដៅកាត់បន្ថយអត្រាមរណភាពមាតា អត្រាមរណភាពកុមារ និងអត្រាមរណភាពទារក។ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១០ បានបង្ហាញថា អត្រាមរណភាពមាតាបានថយចុះជិត៦០% ក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ

២០០៥ដល់ឆ្នាំ២០១០(៤៧២នាក់មកត្រឹម២០៦នាក់ ក្នុងចំណោម១០០ ០០០កំណើតរស់)។ ទោះជាយ៉ាងនេះក្តី ក៏អត្រាទាំងនេះនៅមានលក្ខណៈខ្ពស់នៅឡើយបើប្រៀបធៀបនឹងប្រទេសនានានៅក្នុងតំបន់ ដែលទាមទារឲ្យរាជរដ្ឋាភិបាលបន្តខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកាត់បន្ថយអត្រាមរណភាពមាតានិងកុមារ ក៏ដូចជាការបង្កើនសេវាថែទាំសុខភាព។

**២.២៦១-** *យេនឌ័រនិងការអប់រំ :* នៅក្នុងវិស័យអប់រំ គម្លាតយេនឌ័រត្រូវបានកាត់បន្ថយនៅគ្រប់កម្រិតដោយបានបង្កើនចំនួនអាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រ ពិសេស នារី បង្កើនចំនួនគ្រឹះស្ថានអប់រំទៅដល់មូលដ្ឋាន បង្កើនចំនួនអន្តេវាសិកដ្ឋានដែលផ្តល់សេវាសមរម្យ និងសុវត្ថិភាពសម្រាប់សិស្សស្រីជាដើម។

## ៦.៤- ការអនុវត្តគោលនយោបាយជាតិប្រជាជន

**២.២៦២-** *រាជរដ្ឋាភិបាលកម្ពុជា* បានរៀបចំ*គោលនយោបាយជាតិប្រជាជន* ដែលមានលក្ខណៈគ្របដណ្តប់ទូលំទូលាយគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបនឹងបញ្ហារបស់ប្រជាជនពាក់ព័ន្ធនឹងសកម្មភាពនានានៅក្នុងវិស័យជាច្រើន ដូចជា សុខាភិបាល អប់រំ បរិស្ថាន យេនឌ័រ ម៉ាក្រូសេដ្ឋកិច្ច បម្លាស់ទីលំនៅ យុវជន ជនចាស់ជរា និងផ្នែកផ្សេងៗទៀត។ *គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍ* និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតបាននិងកំពុងបន្តពង្រឹងសមត្ថភាពធនធានមនុស្ស សម្រាប់ការដាក់បញ្ចូលនូវបញ្ហាប្រជាជនទាំងឡាយទៅក្នុងដំណើរការនៃការធ្វើផែនការអភិវឌ្ឍនៅគ្រប់កម្រិតសម្រាប់អ្នករៀបចំផែនការ និងអ្នករៀបចំគោលនយោបាយ។ គណៈកម្មាធិការជាតិនេះបានរៀបចំឯកសារយោងផ្នែកប្រជាសាស្ត្រជាច្រើន ស្តីពី*គោលនយោបាយជាតិប្រជាជន* តារាងទិន្នន័យប្រជាជន នគរូបនីយកម្ម បម្លាស់ទីលំនៅ យុវជន ចាស់ជរា និងសូចនាករសម្រាប់គោលនយោបាយជាតិប្រជាជន។ ឯកសារយោងទាំងនេះត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយពី*គោលនយោបាយជាតិប្រជាជន* និងពីទំទាក់ទំនង រវាងប្រជាជននិងការអភិវឌ្ឍទៅដល់ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងរដ្ឋបាលមូលដ្ឋាននៅគ្រប់២៣ខេត្តនិងរាជធានីភ្នំពេញ។

**២.២៦៣-** សេដ្ឋកិច្ចកម្ពុជា មានកំណើនយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ២០០០ ដែលបានរួមចំណែកក្នុងការកាត់បន្ថយអត្រាភាពក្រីក្រពី៤៧,៨% ឆ្នាំ២០០៧ មក១៩,៨% ឆ្នាំ២០១១។ អត្រាកំណើននេះ គឺជាយន្តការមួយដ៏មានឥទ្ធិពលទៅលើការផ្លាស់ប្តូរប្រជាជន ដូចជា អត្រាកំណើតនិងអត្រាមរណភាពមានកម្រិតទាប ការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុ បម្លាស់ទីលំនៅនិងនគរូបនីយកម្ម ធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនិងស្ថិរភាពនយោបាយ។

**២.២៦៤-** យោងតាមលទ្ធផលបានបង្ហាញថា ៥៨,៧%នៃប្រជាជនសរុបគឺជាក្រុមអាយុប្រកបដោយផលិតភាពការងារ យ៉ាងណាមិញប្រទេសកម្ពុជាក៏បានឈានចូលនិងកំពុងទទួលបាននូវ *ផលលាភប្រជាសាស្ត្រ* ចាប់តាំងពីឆ្នាំ២០០៨រហូតដល់ឆ្នាំ២០៣៨។ ដោយមើលឃើញនូវសក្តានុពលពីកំណើនប្រជាជនក្រុមយុវវ័យ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយសង្គមកិច្ច សេដ្ឋកិច្ចជាច្រើន ក្នុងនោះ *គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា* សំដៅជំរុញការអភិវឌ្ឍសមត្ថភាព(មូលធនមនុស្ស) ការលើកកម្ពស់សុខាភិបាល និងការលើកទឹកចិត្តចូលរួមលើសេចក្តីសម្រេចចិត្តគ្រប់កម្រិត។

**២.២៦៥-** អត្រាអក្ខរកម្មក្នុងចំណោមប្រជាជនអាយុលើស៧ឆ្នាំ មានការកើនឡើង។ អត្រាចូលរៀនពិតសម្រាប់សិស្សស្រីនៅបឋមសិក្សាសម្រេចបាន៩៧% ឆ្នាំសិក្សា២០១២-២០១៣។ ទោះជាយ៉ាងណាក៏ដោយ ក្នុងវិស័យអប់រំថ្នាក់បឋមសិក្សានៅតែជាតម្រូវការចាំបាច់។ ដូច្នេះ បញ្ហាប្រឈមរបស់ប្រទេសកម្ពុជា គឺការងារចាំបាច់ក្នុងការអភិវឌ្ឍធនធានមនុស្ស។

**២.២៦៦-** យោងតាមលទ្ធផលការអង្កេតពាក់កណ្តាលជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៣ ប្រជាជនកម្ពុជាបានកើនឡើងពី១៣,៤លាននាក់ ឆ្នាំ២០០៨ដល់១៤,៦លាននាក់ ឆ្នាំ២០១៣។

**២.២៦៧-** អត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំ ត្រូវបានរកឃើញថា បានថយចុះជាប្រចាំ ១,៥៤% សម្រាប់ឆ្នាំ១៩៩៨ដល់ឆ្នាំ២០០៨ និងបន្តធ្លាក់ចុះ១,៤៦% សម្រាប់ឆ្នាំ២០០៨ដល់ ២០១៣។ នៅក្នុងកម្រិតថ្នាក់ជាតិ ប្រជាជនស្ថិតនៅក្រោមបន្ទុកក៏មានការថយចុះពី៦១%ក្នុងឆ្នាំ២០០៨ មកត្រឹម៥២%ក្នុងឆ្នាំ២០១៣។ អត្រាធ្លាក់ចុះនេះជាភស្តុតាងដែលបណ្តាលមកពីការធ្លាក់ចុះនូវអត្រាលទ្ធភាពមានកូនពី៣,១ឆ្នាំ២០០៨ដល់២,៨ឆ្នាំ២០១៣។ អត្រាប្រជាជនគ្រប់អាយុធ្វើការងារពីក្រុមអាយុ១៥ឆ្នាំដល់៦៤ឆ្នាំនៃចំនួនប្រជាជនសរុប មានការកើនឡើងពី៦២% ក្នុងឆ្នាំ២០០៨ដល់៦៥,៦%ក្នុងឆ្នាំ២០១៣។ យ៉ាងណាមិញអត្រាប្រជាជនវ័យចាស់មានការកើនឡើងពី៤,៣%ក្នុងឆ្នាំ២០០៨ដល់៥%ក្នុងឆ្នាំ២០១៣។ ទាំងនេះជាសញ្ញាដែលគួរឲ្យយកចិត្តទុកដាក់លើប្រជាជនវ័យចាស់ដែលប្រទេសកម្ពុជានឹងជួបប្រទះក្នុងរយៈពេល៣០ឆ្នាំទៀត។ ប្រជាជនសរុបបានកើនឡើង១,៣លាននាក់ សម្រាប់ឆ្នាំ២០០៨ដល់ឆ្នាំ២០១៣ ចំនួនប្រជាជននៅទីប្រជុំជនមានការកើនឡើង០,៥លាននាក់(ស្មើនឹង៤១,៤%) ខណៈដែលប្រជាជននៅតំបន់ជនបទបានកើនឡើង០,៨លាននាក់(ស្មើនឹង៥៨,៦%)។ អត្រាប្រជាជននៅក្នុងទីប្រជុំជននៃប្រជាជនកម្ពុជាឆ្នាំ ២០០៨ គឺ១៩,៥% និង២១,៤%នៅឆ្នាំ២០១៣។ ទាំងនេះជានិន្នាការនៃការកើនឡើងនគរូបនីយកម្មនៅទូទាំងប្រទេសកម្ពុជាក្នុងអំឡុងប៉ុន្មានឆ្នាំនេះ។ សម្រាប់ឆ្នាំ២០០៨ដល់ឆ្នាំ២០១៣ អត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំសម្រាប់ទីប្រជុំជនបានកើនឡើង៣,៧% ខណៈដែលតំបន់

ជនបទមានត្រឹមតែ១,៣%។ ចលនាបម្លាស់ទីរបស់ប្រជាជនជាកត្តាសំខាន់ដែលជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងអត្រាកំណើនប្រជាជនក្នុងទីប្រជុំជន។

**២.២៦៨-** នៅក្នុងឆ្នាំ១៩៩៨ អត្រាកំណើតដុលមានចំនួន៥១% ហើយអត្រានេះបានធ្លាក់ចុះត្រឹម៤១,៨%ក្នុងឆ្នាំ២០១០។ ការមិនចង់បានវិធីសាស្ត្រពន្យារកំណើតមានការធ្លាក់ចុះពី២៥% ក្នុងឆ្នាំ២០០៥ដល់១៧% ក្នុងឆ្នាំ២០១០។ គោលដៅនេះត្រូវសម្រេចឲ្យបាន១០% នៅក្នុងឆ្នាំ២០១៦។ ទោះបីជាមិនមានច្បាប់ឬការកំណត់អាយុស្តីពីការទទួលបានសេវាសុខភាពបន្តពូជ រួមទាំងការពន្យារកំណើតនិងការរំលូតកូនក៏ដោយ ក៏ការយល់ដឹងពីការប្រើប្រាស់សេវាទាំងអស់នេះក្នុងស្រទាប់យុវវ័យនៅតែមានការខ្វះខាត។ ដូច្នេះ តម្រូវការដ៏ធំនោះ គឺធានាបន្តការផ្គត់ផ្គង់ឧបករណ៍ពន្យារកំណើត។ រហូតដល់ពេលនេះ ដៃគូអភិវឌ្ឍបានផ្គត់ផ្គង់ផលិតផលសុខភាពដែលចាំបាច់។ ជាលទ្ធផលក្នុងចំណោមសូចនាករសុខភាពបន្តពូជ អត្រាផែនការគ្រួសារដើម្បីមានកូនបង្ហាញលទ្ធផលវិជ្ជមាន។ ប៉ុន្តែប្រេវ៉ាឡង់ពន្យារកំណើតតាមបែបទំនើបគឺមានតែ៣៥% ក្នុងឆ្នាំ២០១០ប៉ុណ្ណោះ។

**២.២៦៩** នៅក្នុងទិដ្ឋភាពនៃលក្ខខណ្ឌសង្គម និងនយោបាយតែមួយគត់ដែលប្រទេសកម្ពុជាសម្រេចបានកន្លងមក គឺការកាត់បន្ថយភាពក្រីក្រ តាមរយៈការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* របស់ខ្លួនជាមួយនឹងការផ្តោតសំខាន់ទៅលើការវិនិយោគនៅក្នុងកម្មវិធីប្រជាជន ជាពិសេស សុខភាពបន្តពូជ សុខភាពមាតានិងកុមារ(រួមបញ្ចូលទាំងការធ្វើផែនការគ្រួសារ) និងប្រកាន់ខ្ជាប់ទៅនឹងសិទ្ធិបន្តពូជដែលអនុវត្តតាមបំណងប្រាថ្នា។ លទ្ធផលទាំងអស់នេះ បានបង្ហាញពីភាពរឹងមាំរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងសមភាពបន្តទៀត។ រាជរដ្ឋាភិបាលកម្ពុជាបានបន្តប្តេជ្ញាចិត្តនិងខិតខំបន្ថែមទៀតក្នុងការអនុវត្តរបៀបវារៈនិងអាទិភាពផ្សេងៗ សំដៅឈានទៅសម្រេចបានគោលដៅស្នូលរបស់ *គោលនយោបាយជាតិប្រជាជន* និង *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍* ក្រោយឆ្នាំ២០១៥។

**២.២៧០-** ទោះបីសមិទ្ធផលជាច្រើនត្រូវបានបង្កើតឡើងក្តី ក៏ *គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍ* និងដៃគូដទៃទៀត បានប្រឈមនឹងបញ្ហាមួយចំនួន រួមមាន៖

- ការតស៊ូមតិសម្រាប់កិច្ចការអាទិភាពស្តីពីបញ្ហាប្រជាជននិងការអភិវឌ្ឍ ទាំងក្នុងកម្រិតនយោបាយ ទាំងវិភាជន៍ថវិកា ទាំងការអនុវត្តកម្មវិធីនៅមានកម្រិតនៅឡើយ។
- ការអនុវត្តកម្មវិធីប្រជាជន ធនធានហិរញ្ញវត្ថុ និងបច្ចេកទេស នៅមានកំណត់។
- ការសម្របសម្រួលការអនុវត្តកម្មវិធីប្រជាជនក្នុងចំណោមភាគីពាក់ព័ន្ធនៅមានកម្រិត។
- ការវិភាគស៊ីជម្រៅទាក់ទងនឹងប្រជាជននិងភាគីពាក់ព័ន្ធ ចាំបាច់តម្រូវឲ្យមានការយល់ពីមូលហេតុនិងដំណោះស្រាយនៅមានកម្រិតខ្វះខាត ទន្ទឹមនឹងនេះ ការប្រើប្រាស់ទិន្នន័យ

សម្រាប់ការកសាងផែនការអភិវឌ្ឍ ទាំងនៅថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិនៅមានកម្រិត។

- បញ្ហាប្រជាជនថ្មីៗនិងទិន្នន័យទាន់ពេលវេលា សម្រាប់ធ្វើបច្ចុប្បន្នកម្មសូចនាករគោលនយោបាយប្រជាជននិងឧបករណ៍ចាំបាច់ត្រូវដោះស្រាយឲ្យបានត្រឹមត្រូវនៅមានកម្រិត។
- ការកសាងសមត្ថភាពនិងធនធានសម្រាប់ប្រមូលទិន្នន័យ ការវិភាគ ការបកស្រាយ និងវិភាគបញ្ហាគោលនយោបាយប្រជាជន ចាំបាច់ត្រូវបានពង្រឹងនៅគ្រប់កម្រិតទាំងអស់។

# ជំពូកទី៣

# ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច

# សម្រាប់

# ផ.យ.អ.ជ. ២០១៤-២០១៨

# ជំពូកទី៣

# ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

## ១- សេចក្តីផ្តើម

៣.១- តាមរយៈសមិទ្ធផលដ៏ធំធេងនៃការសម្រេចបាននូវការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.)* បច្ចុប្បន្នកម្ម២០០៩-២០១៣ ដូចបានបង្ហាញនៅជំពូកទី២ គឺសេដ្ឋកិច្ចកម្ពុជាបានបន្តជួបប្រទះបញ្ហាធំៗចំនួនបីគឺ ការរំដោះខ្លួនពីផលប៉ះពាល់ដែលបណ្តាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ការរក្សាការពារនិងការធ្វើឲ្យមានកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ និងការកែទម្រង់សេដ្ឋកិច្ចឆ្ពោះទៅរកហិរញ្ញវត្ថុដែលមានស្ថិរភាពកម្រិតខ្ពស់។ បន្ថែមពីលើបញ្ហាដែលនៅសេសសល់និងត្រូវសម្រេចឲ្យបាននាដំណាក់កាលបន្ទាប់ កម្ពុជាបានប្តេជ្ញាខ្ពស់ក្នុងការឈានទៅសម្រេចបាន *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(គ.អ.ស.ក.)* ដែលបច្ចុប្បន្ននេះត្រូវបានធ្វើឲ្យមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់លើគោលដៅសំខាន់ៗជាច្រើន។ ជំហានបន្ទាប់កម្ពុជានឹងខិតខំយ៉ាងខ្លាំងក្លាបន្ថែមទៀតដើម្បីសម្រេចបានការបន្តពង្រីកកំណើនសេដ្ឋកិច្ច ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការធ្វើឲ្យប្រសើរឡើងមូលដ្ឋានមូលធនមនុស្ស ការបន្តកាត់បន្ថយភាពក្រីក្រនិងវិសមភាព និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសមាគមសេដ្ឋកិច្ចអាស៊ាន។

៣.២- ជំពូកនេះនឹងបង្ហាញពី (១)សមិទ្ធផលដ៏ធំធេងដែលសម្រេចបាន (២)បញ្ហាមួយចំនួនដែលមិនទាន់សម្រេចបាន (៣)បញ្ហាប្រឈមក្នុងដំណាក់កាលនៃការអនុវត្ត *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* និង (៤)លើកនូវសំណើគោលនយោបាយពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ចសម្រាប់ពេលអនាគត។

## ២- ការសម្រេចបានក្នុងអំឡុងពេលពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៣

### ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

### ការធ្វើសមាហរណកម្មអត្រាកំណើនទៅក្នុងផលិតផលក្នុងស្រុកសរុប

៣.៣- ប្រទេសកម្ពុជាបានទទួលជោគជ័យក្នុងការសម្រេចបានកំណើន *ផលិតផលក្នុងស្រុកសរុប(ផ.ស.ស.)*យ៉ាងខ្ពស់ក្នុងអំឡុងពេលពីឆ្នាំ២០០៤ដល់ឆ្នាំ២០០៧ ដែលអត្រាកំណើននៃ *ផ.ស.ស.* (ឆ្នាំធៀបនឹងឆ្នាំ) មានកម្រិតលើស១០%ក្នុងមួយឆ្នាំ(រូបភាពទី៣.១)។ ក្នុងឆ្នាំ២០០៨

អត្រាកំណើនបានថយចុះមកត្រឹម៦,៧%។ ប៉ុន្តែនៅឆ្នាំ២០០៩ នៅពេលដែលសេដ្ឋកិច្ចពិភពលោកជួបប្រទះនឹងវិបត្តិ កំណើននៃផ.ស.ស. របស់កម្ពុជាបានធ្លាក់ចុះជិតដល់សូន្យ។ បើប្រៀបធៀបនឹងអត្រាកំណើន៦-៧%ក្នុងមួយឆ្នាំ ដែលបានកំណត់នៅក្នុង *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* កំណើនមធ្យមប្រចាំឆ្នាំសម្រាប់រយៈពេលបីឆ្នាំ(ឆ្នាំ២០១០ដល់ឆ្នាំ២០១២) (៧%) ត្រូវបានសម្រេចតាមផែនការ ប៉ុន្តែសម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣ កំណើននេះមិនបានសម្រេចតាមផែនការទេ គឺមានត្រឹមកម្រិតតែ៥,៦%ប៉ុណ្ណោះ។ ការប៉ាន់ស្មានកំណើននៃ ផ.ស.ស. សម្រាប់ឆ្នាំ២០១៣ ត្រូវបានព្យាករថាមានកម្រិត៧,៦%។

៣.៤- *ផ.ស.ស.* សម្រាប់ប្រជាជនកម្ពុជាម្នាក់ ត្រូវបានប៉ាន់ស្មានថាមានប្រមាណ១ ០៣៦ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣។ កម្រិតនៃកំណើននេះ គឺបានបញ្ជាក់យ៉ាងច្បាស់ថា សេដ្ឋកិច្ចដែលមាន*ផ.ស.ស.* សម្រាប់មនុស្សម្នាក់លើសពី១ ០០០ដុល្លារអាមេរិក អាចត្រូវបានធ្វើចំណាត់ថ្នាក់ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ប្រសិនបើលក្ខខណ្ឌផ្សេងៗទៀតត្រូវបានបំពេញ។

## កំណើនតាមវិស័យ

៣.៥- ដោយសារតែផលិតភាពនៃកម្លាំងពលកម្មនៅក្នុងវិស័យមិនមែនកសិកម្ម(កម្មន្តសាល ទេសចរណ៍ សំណង់ និងផ្នែកផ្សេងៗទៀត) នៅប្រទេសកម្ពុជា មានអត្រាខ្ពស់ជាងផលិតភាពក្នុងវិស័យកសិកម្ម គឺបានបង្ហាញពីការកើនឡើងនៃការរួមចំណែករបស់វិស័យមិនមែនកសិកម្ម (តម្លៃបន្ថែមពីសកម្មភាពនានា) ក្នុង*ផ.ស.ស.* កាន់តែមានវឌ្ឍនភាពឡើង។ ជាការពិតណាស់ លទ្ធផលខាងលើនេះ មិនមែនមានន័យថាយើងមិនត្រូវការការវិនិយោគបន្ថែមទៀត និងសម្រាប់វិស័យកសិកម្មឲ្យមានការកើនឡើងបន្ថែមទៀតនោះទេ។ ទិន្នន័យ*ផ.ស.ស.*មួយដែលបំបែកតាមវិស័យបង្ហាញថាកំណើនប្រចាំឆ្នាំរបស់វិស័យកសិកម្មមានអត្រា៤,២% វិស័យឧស្សាហកម្មមានអត្រា៧,២% និងវិស័យសេវាមានអត្រា៥,៥% នៅក្នុងអំឡុងពេលពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២។ អត្រាកំណើននេះបានធ្វើឲ្យមានការប្រែប្រួលរចនាសម្ព័ន្ធបន្តិចបន្តួចរបស់*ផ.ស.ស.* ក្នុងវិស័យមិនមែនកសិកម្ម ដែលត្រូវបានប៉ាន់ស្មានថា ការរួមចំណែករបស់វិស័យនេះក្នុង*ផ.ស.ស.* ក្នុងឆ្នាំ២០១២ មានអត្រា២៦% ធៀបនឹងឆ្នាំ២០០៩ មាន២៨%។

**រូបភាពទី៣.១ : អត្រាកំណើននៃផលិតផលក្នុងស្រុកសរុប ឆ្នាំធៀបនឹងឆ្នាំ (២០០៦ ដល់២០១២)**




*ប្រភព : ការគណនាពីទិន្នន័យ ពីក្រសួងផែនការនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## ចំណូលនិងចំណាយរបស់រាជរដ្ឋាភិបាលនិងអតិផរណា

### *កិច្ចខិតខំប្រឹងប្រែងរួម ក្នុងការធ្វើឲ្យមានតុល្យភាពរវាងចំណូលនិងចំណាយ*

៣.៦- ជាក់ស្តែង ថវិកាត្រូវមានតុល្យភាពពេញលេញ*រវាងចំណូលនិងចំណាយ* ហើយប្រសិនបើថវិកាមិនមាន*តុល្យភាព* ក្នុងន័យនេះ ឱនភាពថវិកាគួរតែគ្រប់គ្រងឲ្យបានទាបបំផុតដែលជាធម្មតាមានកម្រិតមិនឲ្យលើសពី៣%។ គិតមកដល់ឆ្នាំ២០០៨ ទាំងចំណូលនិងចំណាយបានកើនឡើងជាបន្តបន្ទាប់ ទោះបីជាចំណាយមានកម្រិតលើសចំណូលប្រមាណពី២ទៅ៣% នៃ *ផ.ស.ស.* ក៏ដោយ។ ទោះជាដូចនេះក្តី នៅឆ្នាំ២០០៩ វិបត្តិហិរញ្ញវត្ថុពិភពលោកបានធ្វើឲ្យមានផលប៉ះពាល់ដល់ប្រទេសកម្ពុជា ជាពិសេស ថវិកាចំណាយ ហើយជាវិធានការបង្ការ រាជរដ្ឋាភិបាលបានបង្កើនចំណាយដែលធ្វើឲ្យគម្លាតរវាងចំណូលនិងចំណាយបានកើនឡើងដល់៨ទៅ៩% នៃ ផ.ស.ស. នៅក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ (រូបភាពទី៣.២)។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តខិតខំកាត់បន្ថយគម្លាតរវាងចំណូលនិងចំណាយ ដែលចាំបាច់ត្រូវខិតខំប្រឹងប្រែងស្វែងរកប្រភពចំណូលថ្មីៗស្របគ្នានឹងការកែសម្រួលការចំណាយផងដែរ។ ទោះជាដូចនេះក្តីក៏កង្វល់មួយចំនួនដែលកម្ពុជានឹងត្រូវប្រឈមនោះគឺ ចំណូលពន្ធគយដែលជាសមាសភាពសំខាន់មួយចំនួននៃចំណូលសរុបនឹងត្រូវធ្លាក់ចុះ ដើម្បីបំពេញទៅតាមលក្ខខណ្ឌចាំបាច់សម្រាប់ការចូលជាសមាជិកពេញលេញរបស់កម្ពុជាក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥។ បញ្ហានេះនឹងធ្វើឲ្យចំណូលសរុបរបស់ប្រទេសមានការថយចុះ។

**រូបភាពទី៣.២ : និន្នាការចំណូលនិងចំណាយ គិតជាភាគរយនៃ ផ.ស.ស. ឆ្នាំ២០០៥ដល់២០១២**




*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

៣.៧- ដោយផ្អែកលើការប៉ាន់ស្មានសម្រាប់ឆ្នាំ២០១២ គម្លាតរវាងចំណូលនិងចំណាយមានកម្រិតប្រមាណជាង៦%នៃ ផ.ស.ស. នៅក្នុងឆ្នាំនោះ ប៉ុន្តែកម្រិតគម្លាតនេះនៅតែទាមទារឲ្យមានការកាត់បន្ថយបន្ថែមទៀតអាចឲ្យខិតនៅជិត០% សម្រាប់ការរក្សាឲ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលកម្ពុជាមានជំនឿជឿជាក់ថា ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អភិវឌ្ឍន៍នឹងបន្តជួយកាត់បន្ថយគម្លាតដែលបានលើកឡើងពីខាងដើម។

## *ការធ្វើសនិទានកម្មក្នុងចំណូលនិងចំណាយ*

៣.៨- នៅក្នុងអំឡុងពេលពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពង្រីកនូវប្រព័ន្ធប្រកាសពន្ធដោយស្វ័យប្រវត្តិទៅដល់គ្រប់ខេត្ត និងបានព្យាយាមកសាងសមត្ថភាពក្នុងចំណោមមន្ត្រីរាជការ ដែលធ្វើការងារពាក់ព័ន្ធនឹងការប្រមូលពន្ធ សវនកម្ម និងជម្រះបំណុល។ ការចុះបញ្ជីពន្ធដែលមានសង្គតិភាពជាមួយការអនុវត្តជាលក្ខណៈអន្តរជាតិ បច្ចុប្បន្នបានដាក់ឲ្យអនុវត្តរួចហើយ។ រាជរដ្ឋាភិបាលក៏បានធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធប្រមូលចំណូលមិនមែនពន្ធផងដែរ។ ការប្រមូលចំណូលពីផលិតផលព្រៃឈើ អាកាសចរណ៍ស៊ីវិល ទូរគមនាគមន៍ ក៏ដូចជាចំណូលពីវិស័យផ្សេងទៀតក៏ត្រូវបានលើកកម្ពស់។ ជាមួយគ្នានេះ ចំណូលពីពន្ធលើការបង់ថ្លៃនិងការយកពន្ធពីអាជីវកម្មរ៉ែនិងប្រេងកាត ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់។ បច្ចុប្បន្ននេះ ការទូទាត់ដោយវិក្ក័យបត្រត្រូវបានប្រើប្រាស់ដើម្បីប្រមូលចំណូលមិនមែនពន្ធនិងថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលកម្ពុជាកំពុងបង្កើតច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនពន្ធនិងច្បាប់ស្តីពីការគ្រប់គ្រងអចលនទ្រព្យរបស់រដ្ឋ។

៣.៩- ជំហានបន្ទាប់គឺ ការគ្រប់គ្រងលើការចំណាយ ត្រូវបានធ្វើឲ្យប្រសើរឡើង ការលើកកម្ពស់ភាពត្រឹមត្រូវនៃការចំណាយតាមតម្រូវការ និងការបន្សុីតម្រូវការនេះជាមួយនឹងវិស័យអាទិភាពនានា(អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ និងធារាសាស្ត្រ)។ ការចំណាយប្រចាំឆ្នាំសម្រាប់វិស័យសុខាភិបាលនិងវិស័យអប់រំក៏មានការកើនឡើងពីជិត២ដងក្នុងអំឡុងពេលពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ គឺវិស័យសុខាភិបាលកើនឡើងដល់៧៩៥ពាន់លានរៀល(១,៥២%នៃផ.ស.ស.) និងវិស័យអប់រំកើនឡើងដល់១ ០០០ពាន់លានរៀល(១,៩២% នៃផ.ស.ស.)។

៣.១០- ចំណាយវិនិយោគសាធារណៈ ដោយប្រើប្រាស់ប្រភពហិរញ្ញវត្ថុក្នុងស្រុក បានកើនឡើងពី៧១១ពាន់លានរៀលក្នុងឆ្នាំ២០០៨ដល់១ ៣២៧ពាន់លានរៀលក្នុងឆ្នាំ២០១២។ ចំណែកចំណាយវិនិយោគសាធារណៈ ដោយប្រើប្រាស់ប្រភពធនធានពីបរទេសបានកើនឡើងពី១ ៩២៦ពាន់លានរៀលក្នុងឆ្នាំ២០០៨ដល់២ ៨៦០ពាន់លានរៀលក្នុងឆ្នាំ២០១២។ ចំណាយចរន្តដែលមិនមែនអាទិភាពត្រូវបានកាត់បន្ថយឲ្យនៅកម្រិតទាបបំផុតនៅក្នុងអំឡុងពេលដូចគ្នានេះ។

៣.១១- ក្នុងអំឡុងពេលពីឆ្នាំ១៩៩៣ដល់ឆ្នាំ២០១២ ស្ថានភាពនៃបំណុលត្រូវបានធ្វើឲ្យមានកម្រិតប្រសើរឡើង។ ជាក់ស្តែងក្នុងឆ្នាំ១៩៩៣ អនុបាតបំណុលរបស់រដ្ឋធៀបនឹងផ.ស.ស. មាន៧៣% អនុបាតបំណុលធៀបនឹងការនាំចេញមាន៦៤៣% ហើយអនុបាតបំណុលធៀបនឹងចំណូលមាន១ ៧៦៦%។ ក៏ប៉ុន្តែនៅឆ្នាំ២០១២ អនុបាតបំណុលរបស់រដ្ឋធៀបនឹងផ.ស.ស. មាន៣១% អនុបាតបំណុលធៀបនឹងការនាំចេញមាន៧២% ហើយអនុបាតបំណុលធៀបនឹងចំណូលមានអត្រា២២៧%។ ដូច្នេះ គោលការណ៍បួនសម្រាប់ធ្វើសនិទានកម្មបំណុលរួមមាន៖

(១) ខ្ចីនូវទឹកប្រាក់ដែលថវិកាជាតិមានសមត្ថភាពផ្គត់ផ្គង់។
(២) ខ្ចីនូវប្រភពដែលមានសម្បទានខ្ពស់(អត្រាការប្រាក់ទាបនិងលក្ខខណ្ឌមិនធ្ងន់ធ្ងរ)។
(៣) ខ្ចីតែសម្រាប់វិស័យអាទិភាពនិងសម្រាប់បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច។
(៤) ប្រើប្រាស់ឥណទានឲ្យមានប្រសិទ្ធភាពនិងតម្លាភាព។

## ការគ្រប់គ្រងអតិផរណា

៣.១២- គោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺរក្សាអតិផរណាឲ្យនៅត្រឹមរង្វង់៥%។ រូបភាពទី៣.៣ បង្ហាញពីទិន្នន័យស្តីពីអតិផរណានៅក្នុងរយៈពេលថ្មីៗនេះ(មធ្យមប្រចាំត្រីមាស)។

## រូបភាពទី៣.៣ : អត្រាអតិផរណានៅកម្ពុជា គិតតាមតាមត្រីមាស ឆ្នាំ២០០៦ដល់២០១២




*ប្រភព : ធនាគារជាតិនៃកម្ពុជា (ការគណនាផ្អែកលើទិន្នន័យ ខែតុលា - ធ្នូ ២០០៦= ១០០)*

៣.១៣- និន្នាការនៃអតិផរណា ស្ថិតិបានបង្ហាញពីនិន្នាការប្រែប្រួលខ្លាំងនៅឆ្នាំ២០០៨។ តម្លៃទំនិញបានចាប់ផ្តើមកើនឡើងនៅឆ្នាំ២០០៧ គឺដោយសារអតិផរណានៃការនាំចូលទំនិញ ដូចជាតម្លៃប្រេងឥន្ធនៈនិងទំនិញ(រួមទាំងម្ហូបអាហារ) នៅលើទីផ្សារពិភពលោកបានកើនឡើងយ៉ាងឆាប់រហ័សដោយសារតែតម្រូវការកើនឡើងលើសនៅប្រទេសចិន និងវិបត្តិនៅតំបន់មជ្ឈិមបូព៌ា។ សមត្ថភាពក្នុងការស្តារស្ថានភាពនៃអតិផរណានៅកម្ពុជាមានការយឺតយ៉ាវ ដែលបណ្តាលឲ្យស្ថានភាពកាន់តែមានការប្រែប្រួលខ្លាំងឡើង។ អតិផរណាបានកើនឡើងបន្តទៀត ដោយការចំណាយរបស់រដ្ឋាភិបាលមានការកើនឡើងខ្លាំង ហើយរូបិយវត្ថុបានចុះតម្លៃធៀបនឹងដុល្លារអាមេរិក។ ទោះជាដូចនេះក្តី តាមរយៈនៃកិច្ចខិតខំបន្ថែមទៀតរបស់រដ្ឋាភិបាល ស្ថានភាពនៃអតិផរណានៅកម្ពុជាត្រូវបានធ្វើឲ្យប្រសើរឡើងវិញនាពេលបន្ទាប់។

៣.១៤- ប្រសិនបើឆ្នាំ២០០៨ មិនត្រូវបានគិតបញ្ចូលទេនោះកម្រិតអតិផរណាមានកម្រិតទាបជាង៦%ដែលនៅតែជាអត្រាខ្ពស់ ប៉ុន្តែស្ថិតនៅក្នុងអត្រាដែលអាចទទួលយកបាន(ប្រមាណ៥%)។

### ជញ្ជីងពាណិជ្ជកម្មនិងជញ្ជីងទូទាត់

៣.១៥- ផលិតផលនាំចេញសំខាន់បំផុតរបស់កម្ពុជាគឺ សម្លៀកបំពាក់ រ៉ែ និងផលិតផលទាក់ទងទៅនឹងកសិកម្ម(ស្រូវ អង្ករ ត្រី និងកៅស៊ូ)។ នៅឆ្នាំ២០០៩ ការនាំចេញរបស់កម្ពុជា គឺបានរងនូវផលប៉ះពាល់ដោយសារការធ្លាក់ចុះនៃតម្រូវការនៅក្នុងទីផ្សារអន្តរជាតិ។ ក្នុងឆ្នាំ២០១៣ ការនាំចេញមានការកើនឡើងវិញតាមការប៉ាន់ស្មានមានប្រមាណ៦,៩ពាន់លានដុល្លារអាមេរិកធៀបនឹងឆ្នាំ២០០៩ មានកម្រិតតែ៣ពាន់លានដុល្លារអាមេរិកប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ ការនាំចូល

ត្រូវបានប៉ាន់ស្មានថាមានកម្រិតប្រមាណ៩ពាន់លានដុល្លារអាមេរិកនៅឆ្នាំ២០១៣ ធៀបនឹងឆ្នាំ២០០៩មានកម្រិត៤,៥ពាន់លានដុល្លារអាមេរិក។ ការនាំចូលផលិតផលអន្តរការី បង្កើតជាសមាសភាគដ៏ធំនៃការកើនឡើងនូវការនាំចូល។

**៣.១៦-** តុល្យភាពពាណិជ្ជកម្មនិងតុល្យភាពគណនេយ្យចរន្ត(គិតបញ្ចូល ឬមិនគិតបញ្ចូលការផ្ទេរមូលធន) មានតម្លៃអវិជ្ជមានក្នុងរយៈពេលវែងកន្លងមកហើយ(រូបភាពទី៣.៤)។ ឱនភាពពាណិជ្ជកម្មមានអត្រា -១៥,៣%នៃផ.ស.ស.ក្នុងឆ្នាំ២០០៨ ដែលបានថយចុះជាបន្តបន្ទាប់ដល់ -១៣,៦%ក្នុងឆ្នាំ២០១៣។ ឱនភាពគណនេយ្យចរន្ត(ឧ. បន្ទាប់ពីគិតការផ្ទេរមូលធន) មានភាពប្រសើរជាងមុន ប៉ុន្តែនៅតែមានតម្លៃអវិជ្ជមាននៅឡើយ។ ភស្តុតាងមួយចំនួនបង្ហាញថា កម្រិតនៃការនាំចេញផលិតផលរបស់កម្ពុជា ពីវិស័យកសិកម្ម រ៉ែ កម្មន្តសាល និងសេវា រួមបញ្ចូលជាមួយនឹងចំណែកផ្សេងទៀតទៅក្នុងជញ្ជីងគណនេយ្យចរន្ត នៅមិនទាន់មានចំនួនច្រើនគ្រប់គ្រាន់សម្រាប់ទូទាត់ជាមួយនឹងការនាំចូលនៅឡើយ។ ដូចនេះ មានតែការបង្កើនការនាំចេញដោយការធ្វើពិពិធកម្ម និងឲ្យកាន់តែស៊ីជម្រៅនូវសកម្មភាពពីវិស័យនានាសម្រាប់ការនាំចេញប៉ុណ្ណោះដែលអាចជួយធ្វើឲ្យមានតុល្យភាពបាន។

**រូបភាពទី៣.៤ : តុល្យភាពពាណិជ្ជកម្មនិងគណនេយ្យចរន្ត**

(ភាគរយនៃផ.ស.ស.)




*ប្រភព : ក្រសួងផែនការ*

**៣.១៧-** ពាណិជ្ជកម្មនាំចេញនាំចូល មានកម្រិតលើសពី១០០%នៃផ.ស.ស. ក្នុងឆ្នាំ២០០៦ ប៉ុន្តែបានធ្លាក់ចុះជាបន្តបន្ទាប់ហើយនិន្នាការនេះបានចាប់ផ្តើមស្ទាទ្បើងវិញនៅបន្ទាប់ពីឆ្នាំ២០០៩

ប៉ុណ្ណោះ(រូបភាពទី៣.៥)។ កម្រិតនៃការធ្វើពាណិជ្ជកម្មនាំចេញនាំចូលក្នុងឆ្នាំ២០១២ មានកម្រិតជិត១០០% ហើយការប៉ាន់ស្មានថ្មីៗបានបង្ហាញថា ពាណិជ្ជកម្មនាំចេញនាំចូលសម្រាប់ឆ្នាំ២០១៣ ក៏មានកម្រិតជិត១០០% ដែរ ដែលកម្ពុជាចាំបាច់ត្រូវបង្កើនឲ្យបានជាអតិបរមាដើម្បីទទួលបានផលប្រយោជន៍ពីពាណិជ្ជកម្ម ការផ្ទេរបច្ចេកវិទ្យា និងការទទួលបានទីផ្សារនៅក្រៅប្រទេស។

**រូបភាពទី៣.៥ : ពាណិជ្ជកម្មនាំចេញនាំចូល ធៀបនឹង ផ.ស.ស.**

**(គិតជាភាគរយ)**




*ប្រភព : ក្រសួងផែនការ*

## ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

៣.១៨- ការផ្គត់ផ្គង់រូបិយវត្ថុបានកើនឡើង(ឆ្នាំធៀបនឹងឆ្នាំ)២២,១% នៅក្នុងអំឡុងពេលពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៣ ដែលបង្ហាញពីភាពកាន់តែស៊ីជម្រៅរបស់វិស័យហិរញ្ញវត្ថុ។ រូបិយវត្ថុត្រូវបានរក្សាឲ្យមានស្ថិរភាពក្នុងកម្រិតឡើងចុះទាបជាង៥% ធៀបនឹងរូបិយវត្ថុបរទេសសំខាន់ៗ (ដុល្លារអាមេរិក)។ ការអភិវឌ្ឍក្នុងវិស័យហិរញ្ញវត្ថុមួយចំនួនមានដូចខាងក្រោម៖

៣.១៩- វិស័យធនាគារ

- ប្រាក់បញ្ញើក្នុងធនាគារនិងប្រាក់កម្ចីពីធនាគារកាន់តែមានទំនុកចិត្តនិងមានការកើនឡើង។
- ឧបករណ៍នានាសម្រាប់ដំណើរការអន្តរធនាគារ ត្រូវបានដាក់ឲ្យដំណើរការ។
- ប្រព័ន្ធកូប្រា ត្រូវបានដំណើរការសម្រាប់ពិនិត្យមើលឯកសារ។
- មូលធនកាតព្វកិច្ចអប្បបរមាសម្រាប់ធនាគារត្រូវបានបង្កើនពី៥០ពាន់លានរៀលដល់១៥០ពាន់លានរៀល។
- ការិយាល័យព័ត៌មានពីឥណទានត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១២ដើម្បីកាត់បន្ថយហានិភ័យឥណទាន។

- ច្បាប់ស្តីពីកិច្ចសន្យាហិរញ្ញវត្ថុ ការធានារ៉ាប់រង និងក្រុមរដ្ឋប្បវេណីត្រូវបានបង្កើតឡើង និងដាក់ឲ្យអនុវត្ត។
- នៅពាក់កណ្តាលឆ្នាំ២០១២ ប្រាក់បញ្ញើនៅក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុបានកើនឡើងដល់ ៧១៩,២៣ពាន់លានរៀល ហើយប្រាក់កម្ចីពីស្ថាប័ននេះមានចំនួន២ ៩៩២ពាន់លានរៀល។ ចំនួនស្ថាប័នមីក្រូហិរញ្ញវត្ថុបានកើនឡើងពីចំនួន៣០ក្នុងឆ្នាំ២០០២ដល់ចំនួន៥៦នៅក្នុងឆ្នាំ ២០១២។

## ៣.២០- វិស័យធានារ៉ាប់រង

- ការទូទាត់ប្រាក់ធានាហានិភ័យ បានកើនឡើង២០% ក្នុងមួយឆ្នាំ។
- ការអនុវត្តវិធានការប្រយ័ត្នប្រយែងដែលស្របជាមួយនឹងការផ្តល់ប្រឹក្សាលើការធានារ៉ាប់រង ត្រូវបានពង្រឹង។
- របាយការណ៍ប្រចាំឆ្នាំស្តីពីអ្នកផ្តល់សេវាត្រូវបានធ្វើជាសាធារណៈដែលអាចបង្កើនតម្លៃ របស់អ្នកផ្តល់សេវា។
- ប្រព័ន្ធធានារ៉ាប់រងអាយុជីវិតត្រូវបានបង្កើតឡើងដើម្បីធានាសុវត្ថិភាពសង្គម។
- សេចក្តីព្រាងច្បាប់ស្តីពីការធានារ៉ាប់រងត្រូវបានរៀបចំឡើងដើម្បីពង្រឹងវិស័យនេះ។

## ៣.២១- ការចូលនិវត្តន៍

- មូលនិធិជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ មូលនិធិជាតិសម្រាប់អតីតយុទ្ធជន មូលនិធិសម្រាប់ជនពិការ និងមូលនិធិជាតិសម្រាប់សន្តិសុខសង្គមសម្រាប់កម្មករ ត្រូវបានបង្កើតឡើង ការបង្កើតការគាំពារសង្គមនិងការបណ្តុះគំនិតថែរក្សាវប្បធម៌។
- ច្បាប់មួយស្តីពីការចូលនិវត្តន៍ដោយស្ម័គ្រចិត្តក្នុងវិស័យឯកជនត្រូវបានបង្កើតឡើង។

## ៣.២២- វិស័យមូលបត្រ

- ហេដ្ឋារចនាសម្ព័ន្ធបទដ្ឋានគតិយុត្តសម្រាប់វិស័យមូលបត្រ ត្រូវរៀបចំ និងដាក់ឲ្យអនុវត្ត។
- ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសម្រាប់ទីផ្សារមូលបត្រត្រូវបានបង្កើតឡើង ដែលក្នុងនោះមាន គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- ក្រុមហ៊ុនចំនួន១៥បានទទួលអាជ្ញាបណ្ណធ្វើជាក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងក្រុមហ៊ុនចំនួន៥ត្រូវបានទទួលស្គាល់ជាក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យផ្តល់សេវានៅក្នុងវិស័យមូលបត្រ ហើយក្រុមហ៊ុនចំនួន១ទៀតត្រូវបានទទួលស្គាល់ជាក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រ។ ធនាគារពាណិជ្ជចំនួន៣ត្រូវបានទទួលស្គាល់ធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។ មានក្រុមហ៊ុននិងធនាគារចំនួន៣ផ្សេងទៀតត្រូវបានទទួលស្គាល់ធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

និងភ្នាក់ងារទូទាត់។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលការអនុញ្ញាតឲ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

- មូលបត្រកម្មសិទ្ធិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញត្រូវបានដាក់ឲ្យជួញដូរជាផ្លូវការនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងក្រុមហ៊ុនមួយចំនួនទៀតកំពុងស្ថិតក្នុងដំណើរការរៀបចំការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។

៣.២៣- វិស័យហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀត

- អាជ្ញាបណ្ណសម្រាប់សេវាវាយតម្លៃនិងសេវាកម្មសិទ្ធិត្រូវបានផ្តល់ជូនដល់ក្រុមហ៊ុនចំនួន៨៧ ហើយអាជ្ញាបណ្ណសម្រាប់ការអភិវឌ្ឍកម្មសិទ្ធិក៏ត្រូវបានផ្តល់ដល់ក្រុមហ៊ុនចំនួន២០។
- សមាគមអ្នកវាយតម្លៃនិងភ្នាក់ងារផ្តល់សេវាកម្មសិទ្ធិនៅកម្ពុជាត្រូវបានបង្កើតឡើង។ សមាគមនេះបានក្លាយជាសមាជិកទី៨នៃសមាគមន៍អ្នកវាយតម្លៃរបស់អាស៊ាន។
- វិធានការច្បាប់ ក្របខ័ណ្ឌយន្តការនៃការគ្រប់គ្រងនិងការតាមដានត្រូវបានបង្កើតឡើងដើម្បីអភិវឌ្ឍសេវាបញ្ចាំនិងជំរុញលំហូរមូលធន។
- ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់អ្នកចុះឈ្មោះ អ្នកដំណើរការ និងអាជ្ញាធរនានាត្រូវបានជំរុញ។

## ភាពក្រីក្រនិងកម្លាំងពលកម្ម

### ការកាត់បន្ថយភាពក្រីក្រ

៣.២៤- ក្នុងឆ្នាំ១៩៩៣ដល់១៩៩៤ ដោយផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រកំណត់ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ អត្រាភាពក្រីក្រត្រូវបានប៉ាន់ស្មានថា មានអត្រា៣៩%។ ដោយផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រនេះ អត្រានៃភាពក្រីក្រមានអត្រា១៤,៦%ក្នុងឆ្នាំ២០០៩ ដូចនេះ គោលដៅទី១នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គឺរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានរួចហើយ។ ដោយសារប្រទេសជាតិមានការអភិវឌ្ឍច្រើន រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការកំណត់ខ្សែបន្ទាត់ភាពក្រីក្រឡើងវិញនៅឆ្នាំ២០១១ ដោយបានបង្កើនតម្លៃនៃខ្សែបន្ទាត់ភាពក្រីក្រ។ ជាមួយគ្នានេះ ទោះបីខ្សែបន្ទាត់ភាពក្រីក្រថ្មីត្រូវបានកំណត់ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាក៏នៅបន្តរក្សាចំណុចដៅដែលបានកំណត់រួចហើយនៃការកាត់បន្ថយភាពក្រីក្រនៅអត្រា១៩,៥%ត្រឹមឆ្នាំ២០១៥។

៣.២៥- និន្នាការនៃអត្រាភាពក្រីក្រនាពេលបច្ចុប្បន្ន គឺផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រថ្មី(រូបភាពទី៣.៦) បានបង្ហាញថាចំណុចដៅនៃការកាត់បន្ថយឲ្យបានពាក់កណ្តាលនៃសមាមាត្រប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ពីចន្លោះពីឆ្នាំ១៩៩០និងឆ្នាំ២០១៥ គឺសម្រេចបានហើយ ទោះបីជាខ្សែបន្ទាត់ភាពក្រីក្រមានកម្រិតខ្ពស់ជាងមុននិងចំណុចដៅមិនបានកែសម្រួលក្តី។ ហេតុផលចម្បងៗដែលនាំឲ្យកម្ពុជាទទួលជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រនេះគឺកិច្ចខិតខំយ៉ាងសកម្មដើម្បីឲ្យមានកំណើនផ.ស.ស. មានអត្រាពីរខ្ទង់ក្នុងរយៈពេល៣ទៅ៤ឆ្នាំ (២០០៤ដល់២០០៧) កំណើនប្រកបដោយចីរភាពក្នុងវិស័យកសិកម្ម ការពង្រីកផ្ទៃដីដាំដុះ ការ

ទាក់ទាញកម្លាំងពលកម្មយ៉ាងឆាប់រហ័សឲ្យទៅធ្វើការក្នុងវិស័យមិនមែនកសិកម្ម និងការកាត់បន្ថយវិសមភាពក្នុងការប្រើប្រាស់។

### រូបភាពទី៣.៦ : និន្នាការភាពក្រីក្រនៅកម្ពុជា តាមតំបន់ ឆ្នាំ២០០៧-២០១១




| | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|
| កម្ពុជា | 47.8 | 29.9 | 22.9 | 21.1 | 19.8 |
| ភ្នំពេញ | 19.1 | 13.6 | 12.8 | 12.4 | 10.9 |
| ទីប្រជុំជនផ្សេងៗ | 41 | 30.5 | 19.2 | 17 | 22.5 |
| ជនបទ | 53.2 | 31.9 | 24.6 | 22.7 | 20.7 |

*ប្រភព : គណនាពីទិន្នន័យ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

### អត្រាភាពក្រីក្រនៅថ្នាក់ក្រោមជាតិ

៣.២៦- ស្ថានភាពនៃអត្រាភាពក្រីក្រ (គណនាជំនួស) ដែលបានគណនានៅកម្រិតរាជធានី ខេត្ត ដោយផ្អែកលើទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងអង្កេតប្រជាសាស្ត្រនិងសុខភាព លទ្ធផលបានបង្ហាញថា បណ្តាខេត្តនៅភាគខាងជើងនិងភាគអាគ្នេយ៍នៃប្រទេស មានដង់ស៊ីតេប្រជាជនខ្ពស់ និងបន្តប្រកបមុខរបរប្រពៃណីធ្វើស្រែចម្ការ និងមានអត្រាភាពក្រីក្រទាបជាងបណ្តាខេត្តដែលស្ថិតនៅភាគខាងជើង ភាគឦសាន និងភាគពាយព្យ។ បញ្ហាដែលគួរឲ្យយកចិត្តទុកដាក់ខ្ពស់នោះគឺ នៅបណ្តាខេត្តភាគឦសាន ដែលមានសហគមន៍ជនជាតិច្រើនរស់នៅ។ នៅបណ្តាខេត្តទាំងនេះ ភាគច្រើនគឺជាតំបន់ជនបទ និងមិនទាន់បានធ្វើសមាហរណកម្មក្នុងប្រព័ន្ធជាតិពេញលេញ។ ជាមួយគ្នានេះ អត្រាភាពក្រីក្រមានកម្រិតខ្ពស់ នៅខេត្តសៀមរាបនិងខេត្តបាត់ដំបង ទោះបីជាខេត្តទាំងពីរនេះប្រកបមុខរបរស្រែចម្ការជាយូរណាស់មកហើយក្តី។ ខេត្តសៀមរាបគឺជាតំបន់មួយដ៏សំខាន់ដែលទាក់ទាញភ្ញៀវទេសចររបស់ប្រទេសកម្ពុជា ហើយបាត់ដំបងគឺជាខេត្តដ៏សំខាន់សម្រាប់ដាំដុះស្រូវ។ មូលហេតុដែលនាំឲ្យមានអត្រាភាពក្រីក្រខ្ពស់នៅក្នុងខេត្តទាំងពីរនេះ ទាមទារឲ្យមានការវិភាគស៊ីជម្រៅនិងត្រូវរៀបចំកម្មវិធីសិក្សាស្រាវជ្រាវឲ្យបានច្បាស់លាស់នាពេលអនាគត។

### វចនាសម្ព័ន្ធរបស់កម្លាំងពលកម្ម

៣.២៧- ចំពោះមូលហេតុដែលបានបកស្រាយពីខាងដើម នៅក្នុងបណ្តាប្រទេសដែលមានចំណូលទាប ការកាត់បន្ថយសមាមាត្រពលករដែលធ្វើការក្នុងវិស័យកសិកម្ម ត្រូវបានបង្ហាញថាមានភាពរីកចម្រើន។ ផ្អែកលើវិធីសាស្ត្ររំលឹក (Usual Status) ទិន្នន័យស្តីពីការមានការងារធ្វើរបស់ពលករដែលទទួលបានពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ច អត្រាពលករដែលធ្វើការក្នុងវិស័យកសិកម្ម ធៀបនឹងកម្លាំងពលកម្មសរុប មានការថយចុះយ៉ាងឆាប់រហ័ស ហើយមានការកើនឡើង

ក្នុងវិស័យមិនមែនកសិកម្ម។ និន្នាការនេះបញ្ជាក់ថា ការងារនានាត្រូវបានបង្កើតឡើងនៅក្រៅវិស័យមិនមែនកសិកម្ម ដើម្បីផ្គត់ផ្គង់ដល់ពលករដែលមានចំនួនលើស ហើយធ្វើការចាកចេញពីវិស័យកសិកម្ម។

**រូបភាពទី៣.៧ : រចនាសម្ព័ន្ធនៃកម្លាំងពលកម្ម (១៥ដល់៦៤ឆ្នាំ)**
តាមវិធីសាស្ត្ររំលឹក (Usual Status) ឆ្នាំ២០០៩ដល់២០១១




*ប្រភព: អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

៣.២៨- ជារួម យើងអាចធ្វើការសន្និដ្ឋានបានថា សេដ្ឋកិច្ចកម្ពុជាបានកើនឡើងក្នុងកម្រិតមួយល្អប្រសើរ ហើយការងារជាច្រើនត្រូវបានបង្កើតឡើងនៅក្នុងវិស័យមិនមែនកសិកម្ម។ ទោះជាសេដ្ឋកិច្ចមានការកើនឡើងក៏ដោយ ក៏ទំហំសេដ្ឋកិច្ចនៅតូច ដោយសារមួយចំណែកធំពឹងផ្អែកតែលើវិស័យកាត់ដេរសម្លៀកបំពាក់ សំណង់ ទេសចរណ៍ និងកសិកម្ម។ ហើយនៅក្នុងវិស័យទាំងប៉ុន្មានខាងលើនេះ ការប្រើប្រាស់បច្ចេកវិទ្យាក៏នៅមានកម្រិតនៅឡើយ ហើយតម្លៃរួមនៃចង្វាក់ផលិតកម្មមានកម្រិតទាប។ លទ្ធផលទាំងអស់នេះបានបង្ហាញថាផលិតភាពនៅមានកម្រិតទាប និងចំណូលក៏មានកំណត់។

## ៣- ចំណុចដៅនិងគោលនយោបាយសម្រាប់ឆ្នាំ២០១៤ដល់២០១៨

### បញ្ហានានាដែលត្រូវបន្តដោះស្រាយ

៣.២៩- ទស្សនវិស័យនៃការអភិវឌ្ឍរបស់កម្ពុជា គឺធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងសង្គម ទៅក្នុងតំបន់និងពិភពលោក និងទទួលបានទីផ្សារការងារសម្រាប់ប្រជាជន។ ហេតុនេះការកសាងមូលដ្ឋានរឹងមាំមួយសម្រាប់ប្រទេសជាតិឲ្យមានសន្តិភាពពេញលេញ សេដ្ឋកិច្ចមានស្ថានភាពល្អប្រសើរ(វិស័យកសិកម្មនិងមិនមែនចម្ការ និងវិស័យសេវាដែលមានផលិតភាព) និងការឈានទៅសម្រេចបានសង្គមមួយដែលមានសមធម៌ និងមានរបៀបរៀបរយគឺជាភាពចាំបាច់បំផុត។ បច្ចុប្បន្ននេះ ប្រទេសជាតិកំពុងស្ថិតនៅក្នុងកាលៈទេសៈដែលប្រឈមនឹងបញ្ហាមួយចំនួនពាក់ព័ន្ធនឹងកិច្ចខិតខំធ្វើឲ្យប្រទេសចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួចនិងដើម្បីសម្រេចបាន

ការធ្វើសមាហរណកម្មទៅក្នុងសមាគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥និងទទួលបានផលប្រយោជន៍ពេញលេញពីសមាហរណកម្មនេះ ដើម្បីជម្នះបាននូវភាពប្រឈមទាំងអស់នេះ គឺទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងសម្រាប់ការអនុវត្តការងារសំខាន់ៗជាច្រើនបន្ថែមទៀត។

៣.៣០- ជាដំបូង កម្ពុជាចាំបាច់ត្រូវដោះស្រាយនូវបញ្ហាមួយចំនួនដែលកំពុងជួបប្រទះ គឺៈ

១-ដូចបានបញ្ជាក់ពីខាងដើម សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើមូលដ្ឋានសេដ្ឋកិច្ចតូច គឺលើវិស័យ ៤ គឺ កសិកម្ម ឧស្សាហកម្មកាត់ដេរ ទេសចរណ៍ និងសំណង់។ ហើយនៅក្នុងវិស័យទាំងនេះ សកម្មភាពស៊ីជម្រៅពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យា ការធ្វើសមាហរណកម្មពីវិស័យមួយទៅមួយ និងតម្លៃបន្ថែម នៅមានកម្រិតទាបធ្វើឲ្យចំណូលរកបានដោយពលករក៏នៅមានកម្រិតទាប។ បន្ថែមលើនេះទៀត ដំណើរការនៃការគណនាកំណើនផ.ស.ស. ត្រូវបានធ្វើតែចំពោះខេត្តមួយចំនួន ដែលជាមូលហេតុធ្វើឲ្យមានគម្លាតរវាងខេត្តនិងខេត្ត។ តម្រូវការសម្រាប់បរិយាប័ន្នកំណើននៅក្នុងគ្រប់រូបភាពត្រូវបានបង្ហាញទីនេះ។

២-ការខ្វះខាតមូលធនមនុស្សនៅតែជាឧបសគ្គដ៏ចម្បង ក្នុងការធ្វើឧស្សាហូបនីយកម្ម និងការអភិវឌ្ឍនៅក្នុងប្រទេស។ នៅក្នុងវិស័យអប់រំ ការផ្តល់ការសិក្សាមូលដ្ឋាន៩ឆ្នាំ និងការពង្រីកការអប់រំបច្ចេកវិទ្យាកន្លងមកមិនទាន់បានទូលំទូលាយ។ បន្ថែមលើនេះទៀត ការធ្វើឲ្យប្រសើរឡើងនូវគុណភាពអប់រំនៅគ្រប់កម្រិត មូលដ្ឋាន និងបច្ចេកទេស នៅតែមិនទាន់អាចសម្រេចបានតាមចំណុចដៅ។ជាមួយនឹងការសម្រេចតាមតម្រូវការទាំងអស់នេះប្រទេសជាតិអាចទទួលបាននូវផលប្រយោជន៍ពីផលលាភប្រជាសាស្ត្រដែលបច្ចុប្បន្ននេះ ប្រទេសជាតិបានចាប់ផ្តើមឈានចូលក្នុងដំណាក់កាលនេះហើយ។

៣- ការពង្រីកវិសាលភាពហេដ្ឋារចនាសម្ព័ន្ធមានកម្រិតទាបនិងចំណាយនៅខ្ពស់ៈ

ក. ប្រព័ន្ធដឹកជញ្ជូន(ទាំងផ្លូវថ្នល់និងសេវាកម្មដឹកជញ្ជូន)នៅមានកម្រិត ហើយនៅមិនទាន់មានផ្លូវដែកនៅឡើយ។ ចំណាយនៃការដឹកជញ្ជូននៅតែមានកម្រិតខ្ពស់នៅឡើយបើប្រៀបធៀបនឹងបណ្តាប្រទេសជិតខាង។

ខ. ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅមានកំណត់ តំបន់មួយចំនួននៅមិនទាន់បានតភ្ជាប់បណ្តាញនៅឡើយ ហើយតម្លៃប្រើប្រាស់ក៏មានកម្រិតខ្ពស់ធៀបនឹងបណ្តាប្រទេសជិតខាង។

គ. ប្រព័ន្ធធារាសាស្ត្រមិនទាន់អាចបំពេញតាមតម្រូវការនៅឡើយ ជាពិសេស សម្រាប់ដំណាំចម្រុះ។

ឃ. ចំនួនប្រជាជនដែលទទួលបានទឹកស្អាតបរិភោគនិងអនាម័យមិនលើសពី៥០% ឡើយ។

៤-វិបត្តិហិរញ្ញវត្ថុសកលលោកនៅតែបន្តបង្កឲ្យមានភាពមិនច្បាស់លាស់សម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា ដោយសារតែសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើទីផ្សារក្រៅប្រទេស។

៥-ការងារអភិបាលកិច្ចនៅមិនទាន់មានភាពទូលំទូលាយគ្រប់គ្រាន់នៅឡើយ។ ចំណេះដឹងពីលិខិតបទដ្ឋានគតិយុត្តនិងសមត្ថភាពអនុវត្តច្បាប់ នៅមិនទាន់បំពេញបានតាមត្រូវការ ហើយរចនាសម្ព័ន្ធនិងតួនាទីរបស់ស្ថាប័នមិនទាន់មានការទទួលខុសត្រូវខ្ពស់។ បន្ថែមលើនេះទៀត កិច្ចសម្របសម្រួលរវាងក្រសួង/នាយកដ្ឋាន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នៅមានកម្រិត ធ្វើឲ្យសេវាសាធារណៈដែលត្រូវផ្ដល់ឲ្យប្រជាជនមានកម្រិតនៅឡើយ។

៦-ការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ ទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ សម្រាប់ការងារអភិវឌ្ឍប្រកបដោយចីរភាព។ បន្ថែមលើនេះទៀត ការប្រែប្រួលអាកាសធាតុនៅក្នុងពិភពលោកមានផលប៉ះពាល់យ៉ាងខ្លាំងមកលើប្រព័ន្ធអេកូឡូស៊ីរបស់កម្ពុជា ហើយបន្ទាប់ពីនេះគឺប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ដែលកម្ពុជាត្រូវតែប្រុងប្រៀបខ្លួនដោយខ្លួនឯង។

៧-ទោះបីជាអត្រានៃភាពក្រីក្រនៅកម្ពុជាមានកម្រិតទាបក៏ដោយ ក៏កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅតែមានកម្រិតទាប ហើយការបែងចែកចំណូលនិងការបែងចែកផលប្រយោជន៍ដែលទទួលបានពីកំណើន នៅតែជាកង្វល់ដែលត្រូវដោះស្រាយ។

៨-ទិន្នន័យមូលដ្ឋាននៃសេដ្ឋកិច្ច សង្គមកិច្ចរបស់កម្ពុជានៅមានកម្រិតទាបនិងនៅងាយរងនូវផលប៉ះពាល់នៅឡើយ។ ហេតុនេះទាមទារនូវការធ្វើសេចក្ដីសម្រេចចិត្តត្រឹមត្រូវដើម្បីពង្រឹងនូវទិន្នន័យមូលដ្ឋាន។

## ទិសដៅទូទៅនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

៣.៣១- **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣** បានលើកឡើងនូវរាល់បញ្ហាដែលបានលើកឡើងខាងលើ និងបានរកឃើញនូវកាលានុវត្តភាពដែលប្រទេសជាតិអាចទទួលបានពីការធ្វើសមាហរណកម្មទៅក្នុងទីផ្សារដែលធំទូលាយជាងមុន(អាស៊ាន និងដំណាក់កាលបន្ទាប់ទៀត) ផលលាភប្រជាសាស្ត្រ កាលានុវត្តភាពកំណើនដែលទទួលបានពីធនធានធម្មជាតិ(រួមទាំងកសិកម្ម)។ ដូចនេះវិស័យស្នូលសំខាន់ៗអាចរួមបញ្ចូលដោយសង្ខេបក្នុងទិសដៅសម្រេចបានគោលដៅជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៤គឺ៖

១-ធានាអត្រាកំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំ៧%ក្នុងមួយឆ្នាំ។ កំណើននេះត្រូវមានចីរភាព បរិយាប័ន្ន និងសមធម៌ និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចឲ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាប អាចគ្រប់គ្រងបានអត្រាប្ដូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ។

២-បង្កើតការងារឲ្យបានកាន់តែច្រើនឡើងជូនប្រជាជន ជាពិសេស សម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អនិងភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការទាក់ទាញ និងជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគទាំងវិនិយោគក្នុងស្រុកនិងវិនិយោគពីក្រៅប្រទេស។

៣-សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុងគ.អ.ស.ក. ទន្ទឹមនឹងការផ្តល់អាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានជាតិប្រកបដោយចីរភាព។

៤-បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង។

**៣.៣២-** អាទិភាពសំខាន់ៗដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ អាចបង្ហាញនៅក្នុងមុំទាំង៤៖

១-បរិស្ថានគ្របដណ្តប់យុទ្ធសាស្ត្រចតុកោណ

ក. សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

ខ. បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ(រួមទាំងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិស័យហិរញ្ញវត្ថុ)។

គ. ស្ថិរភាពបរិស្ថាន។

ឃ. ភាពជាដៃគូក្នុងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពនិងការធ្វើសមាហរណកម្មក្នុងតំបន់និងពិភពលោក។

២-អភិបាលកិច្ចល្អ

ក. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

ខ. កំណែទម្រង់ច្បាប់នឹងប្រព័ន្ធយុត្តិធម៌។

គ. កំណែទម្រង់រដ្ឋបាលសាធារណៈ។

ឃ. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

៣-វិស័យអាទិភាពចំនួន៤

ក. ការអភិវឌ្ឍវិស័យកសិកម្ម(ពិពិធកម្ម តម្លៃបន្ថែម និងផលិតភាព)។

ខ. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

គ. ការអភិវឌ្ឍវិស័យឯកជននិងការងារធ្វើ។

ឃ. ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស។

**៣.៣៣-** នៅក្នុងជំពូកទី៤ ចំណុចនីមួយៗត្រូវបានបង្ហាញយ៉ាងលម្អិត រួមជាមួយនឹងកម្មវិធីដែលពាក់ព័ន្ធសម្រាប់ការអនុវត្ត។ ជំពូកទី៤ បានលើកឡើងយ៉ាងច្បាស់លាស់នូវគោលនយោបាយ

ស្នូលពីររបស់រាជរដ្ឋាភិបាលកម្ពុជា គឺ (១)គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំអង្ករចេញ និង (២)គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដែលគោលនយោបាយនីមួយៗបានបង្ហាញយ៉ាងលម្អិត។

## ក្របខ័ណ្ឌលទ្ធផល

៣.៣៤- យុទ្ធសាស្ត្រចតុកោណ ចាំបាច់ត្រូវរៀបចំជាផែនការសកម្មភាពច្បាស់លាស់សម្រាប់អនុវត្ត។ ជាក់ស្តែង ក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាននៅថ្នាក់ក្រោមជាតិ ត្រូវមានផែនការសកម្មភាពរបស់ខ្លួន ដែលផែនការសកម្មភាពទាំងនោះអាចជាផែនការតាមវិស័យនិងគិតគូរពីហានិភ័យដែលអាចកើតមាន ប៉ុន្តែប្រសិនបើក្របខ័ណ្ឌអន្តរវិស័យមិនត្រូវបានគិតគូរនិងអនុវត្តនោះនឹងបណ្តាលឲ្យមានហានិភ័យកាន់តែខ្ពស់។ ដូចនេះ អ្នករៀបចំនិងអនុវត្តផែនការនៅក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ ត្រូវសហការនិងធ្វើការរួមគ្នាជិតស្និទ្ធដើម្បីទទួលបានលទ្ធផលល្អប្រសើរ។ ក្របខ័ណ្ឌលទ្ធផល គឺអាចត្រូវបានរៀបចំដោយការពិនិត្យមើលគ្រប់ជ្រុងជ្រោយនិងភាពទាក់ទងគ្នា រួមគ្នាដើម្បីឲ្យទទួលបានលទ្ធផលល្អប្រសើរក្រោមកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា និងជាចុងក្រោយដើម្បីកំណត់នូវបញ្ហារាំងស្ទះនានាដែលអាចកើតមានឡើងនៅក្នុងដំណើរការនៃការអនុវត្ត។ ក្របខ័ណ្ឌលទ្ធផលនេះនឹងបង្កើតឡើងនូវទម្រង់តាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់ផែនការនេះ។ ប្រអប់៣.១ បង្ហាញពីក្របខ័ណ្ឌលទ្ធផលដែលអាចសម្រេចបានសម្រាប់ផែនការនេះ។

| ប្រអប់៣.១ : ក្របខ័ណ្ឌលទ្ធផល: បរិយាប័ន្ន និងចីរភាពកំណើនដើម្បីកាត់បន្ថយភាពក្រីក្រ | | | | |
|---|---|---|---|---|
| | **កំណើន** | **ភាពក្រីក្រ** | **ស្ថិរភាព** | **ការអភិវឌ្ឍមនុស្ស** |
| **គោលដៅ** | ស្ថិរភាព បរិយាប័ន្ន និងភាពធននៃសេដ្ឋកិច្ចជាមួយនឹងកំណើន ផ.ស.ស. ខ្ពស់ជាង ៧% ពិពិធកម្មសេដ្ឋកិច្ច | កាត់បន្ថយអត្រាភាពក្រីក្រ (លើសពី១% ក្នុងមួយឆ្នាំ) និងវិសមភាពចំណូល បង្កើតច្រើនថែមទៀតនិងប្រកបដោយប្រសិទ្ធភាពនូវការងារមិនមែនកសិកម្ម | សន្តិភាព អភិបាលកិច្ចល្អប្រសើរជាងមុន កាត់បន្ថយអំពើពុករលួយ វិធានការច្បាប់ ស្ថិរភាពសេដ្ឋកិច្ច | លើកកម្ពស់/ប្រកួតប្រជែងមូលធនមនុស្ស គុណភាពនៃការអប់រំនិងសេវាអប់រំ សមធម៌យេនឌ័រ ឧត្តមភាពគុណភាពការងារនិងជំនាញ |
| **លទ្ធផល** | ១. មូលដ្ឋានម៉ាក្រូសេដ្ឋកិច្ចរឹងមាំ បរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគក្នុងស្រុកនិងមកពីក្រៅប្រទេស សេដ្ឋកិច្ចបើកទូលាយ ការនាំចេញកើនឡើង ការប្រមូលពន្ធមានភាពល្អប្រសើរជាងមុនហើយចំណូលមិនមែនពន្ធមានការកើនឡើង ចំណាយលើវិស័យអាទិភាព។<br>២. ឧស្សាហកម្មដែលប្រើប្រាស់ពលកម្មច្រើនមានការកើនឡើង ចំនួនភ្ញៀវទេសចរមានការកើនឡើងយ៉ាឆាប់រហ័ស ការអភិវឌ្ឍវិស័យកសិកម្ម និងការអភិវឌ្ឍការចិញ្ចឹមសត្វនិងត្រី ការបន្តសកម្មភាពបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។<br>៣. គ្រប់គ្រងធនធានធម្មជាតិ ដោយឲ្យព្រៃឈើគ្របដណ្តប់លើផ្ទៃដី៦០%។<br>៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (រួមទាំងនៅតំបន់ដាច់ស្រយាលនៅជនបទ) ផ្តោតការយកចិត្តទុកដាក់លើ ថាមពល និងផ្លូវ ទឹកស្អាតនិងអនាម័យ ផ្តល់ដីសម្បទានសង្គមកិច្ចច្រើនបន្ថែមទៀត។<br>៥. ស្ថានភាពអភិបាលកិច្ចដែលអាចព្យាករបានកិច្ចដំណើរការរបស់តុលាការ ជាមួយនឹងការអាចទទួលបាននូវសេវាយុត្តិធម៌គ្រប់ៗគ្នា ច្បាប់មានតម្លាភាព អនុវត្តច្បាប់ស្តីពីដែនដី បង្កើនការផ្តល់បណ្ណកម្មសិទ្ធិដី បង្កើនការឆ្លើយតបរបស់រដ្ឋបាលស៊ីវិល កែទម្រង់ក្នុងមន្ត្រីរាជការ បង្កើនប្រាក់បៀវត្សរដល់មន្ត្រីរាជការ តាមដានពិនិត្យមើលនិងវាស់វែងពីការចំណាយ(សម្រាប់ការងាររបស់រាជរដ្ឋាភិបាល) ការឆ្លើយតបទាន់ពេល គណនេយ្យភាព និងតម្លាភាពនៃសេវា | | | | |

| | |
|---|---|
| | វិមជ្ឈការ។<br>៦. រៀបចំមូលធនមនុស្ស នៅតាមកម្រិតខុសៗគ្នាបង្កើនការសិក្សានៅកម្រិតក្រោយបឋមសិក្សា ផ្តល់ជំនាញដល់ស្ថាប័នទីផ្សារពលកម្មដែលមានការប្រែប្រួល ដើម្បីធានាការទទួលបានផលប្រយោជន៍ពីជំនាញ(ធានាតម្រូវការសម្រាប់ជំនាញ និងបង្កើតការងារច្រើន/ព័ត៌មានពីទីផ្សារពលកម្មបន្ថែមទៀត យុត្តភាពយេនឌ័រនៅគ្រប់កម្រិត មណ្ឌលសុខភាពត្រូវបានពង្រីកយ៉ាងទូលំទូលាយ មានស្ថានភាពអាហារូបត្ថម្ភល្អ និង(ស្មើរតែ) សកលកម្មទឹកស្អាតនិងអនាម័យ ប្រព័ន្ធសុវត្ថិភាពសង្គមត្រូវបានដាក់ឲ្យអនុវត្ត។ |
| **គោលនយោបាយ (ធាតុចេញ)** | ១. បង្កើនចំណូលថវិកា(ប្រមាណ១៨%នៃផ.ស.ស. ត្រឹមឆ្នាំ២០១៨) ពង្រឹងរដ្ឋបាលពន្ធដារ ជំរុញការចំណាយនៅក្នុងវិស័យអាទិភាព ជំរុញការអនុវត្តការរៀបចំថវិកាដោយផ្អែកលើលទ្ធផល(និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) ពង្រឹងគោលនយោបាយហិរញ្ញវត្ថុនិងសារពើពន្ធ(រួមទាំងឧបករណ៍នានាដែលអាចទូទាត់បាន)។<br>២. បង្កើត និងអនុវត្តច្បាប់និងវិធានការច្បាប់នានា ពាក់ព័ន្ធនឹងពាណិជ្ជកម្មនិងហិរញ្ញវត្ថុ ធ្វើឲ្យប្រសើរឡើងអភិបាលកិច្ចសេដ្ឋកិច្ច(ឱនភាពពាណិជ្ជកម្ម ទាបជាងឬស្មើ៣% គ្រប់គ្រងអតិផរណាឲ្យស្ថិតនៅក្រោមឬស្មើ៥% និងជំរុញឲ្យមានការអនុវត្ត)។<br>៣. អនុវត្តគោលនយោបាយប្រពលវប្បកម្មស្រូវ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ពង្រឹងក្នុងវិស័យការដាំដុះ ចិញ្ចឹមសត្វ និងត្រី។ វិនិយោគច្រើនបន្ថែមទៀត លើហេដ្ឋារចនាសម្ព័ន្ធ(ធារាសាស្ត្រ ដឹកជញ្ជូន អគ្គិសនី ទឹកអនាម័យ សេវាសាធារណៈនិងផ្នែកផ្សេងទៀត)។<br>៤. ពង្រឹងច្បាប់ពាណិជ្ជកម្ម និងការអនុវត្តគោលនយោបាយលើកកម្ពស់កំណើន/មជ្ឈមណ្ឌលកំណើន គោលនយោបាយនគរូបនីយកម្ម។<br>៥. បង្កើនការងារសុរិយោដីដើម្បីស្វែងយល់ថាតើផ្ទៃដីលើសដែលអាចដាំដុះ(និងធនធានផ្សេងទៀត) ធានាពីកម្មសិទ្ធិដីដោះមីនលើផ្ទៃដីច្រើនថែមទៀត អនុវត្តគោលនយោបាយប្រើប្រាស់ដីលើសដែលអាចដាំដុះបានប្រកបដោយសមធម៌ ផ្តល់លទ្ធភាពសម្រាប់ការធ្វើទំនើបកម្មមុខរបរកសិកម្មនៅក្នុងតំបន់ដែលបានដោះសម្អាតមីន ប្រព័ន្ធសុវត្ថិភាពសង្គម។<br>៦. គ្រប់គ្រង/អនុវត្តឲ្យបានល្អប្រសើរជាងមុន : តំបន់ការពារព្រៃឈើ២៣កន្លែង ធនធានធម្មជាតិ/ធនធានរ៉ែ ទឹក ត្រី។<br>៧. ជំរុញវិមជ្ឈការ តួនាទី ថវិកា និងមន្ត្រីក្នុងវិស័យសំខាន់ៗ ពិនិត្យមើលមន្ត្រីរាជការ បង្កើនប្រាក់បៀវត្សដល់មន្ត្រីរាជរដ្ឋាភិបាល ធ្វើឲ្យប្រសើរឡើងវិន័យរបស់មន្ត្រីរាជការ បែងចែកធនធានសម្រាប់អង្កេតនិងវាស់វែង ដើម្បីឲ្យការអនុវត្តតួនាទីរបស់មន្ត្រីរាជការប្រកបដោយប្រសិទ្ធភាព។<br>៨. បង្កើនថវិកាសម្រាប់វិស័យអភិវឌ្ឍធនធានមនុស្ស (ការអប់រំលើសពី៣%នៃផ.ស.ស. សុខាភិបាលលើសពី២%នៃផ.ស.ស.) បង្កើតនូវគោលនយោបាយច្បាស់លាស់មួយសម្រាប់រៀបចំមូលធនមនុស្សក្នុងផ្នែកពាក់ព័ន្ធនឹងការបង្កើតជំនាញប្រកួតប្រជែងក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកទេស។<br>៩. បង្កើនគណនេយ្យភាព : តាមរយៈការធ្វើឲ្យមានការពាក់ព័ន្ធជាមួយប្រជាជន និងប្រព័ន្ធគណនេយ្យភាពផ្លូវការ ធ្វើឲ្យប្រសើរឡើងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ |
| **យុទ្ធសាស្ត្រ (ធាតុចូល)** | *យុទ្ធសាស្ត្ររូបិយវត្ថុនិងសារពើពន្ធ*<br>១. អនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីធ្វើឲ្យមានប្រសិទ្ធភាពបន្ថែមទៀត (ជាពិសេសបដិដុល្លារូបនីយកម្ម) ជំរុញការធ្វើហិរញ្ញប្បទានទៅក្នុងសេដ្ឋកិច្ច (ជំរុញការធ្វើអាជីវកម្មស្ថាប័នហិរញ្ញវត្ថុ បង្កើតឲ្យបានច្រើនថែមទៀតនូវស្ថាប័ន/ឧបករណ៍ហិរញ្ញវត្ថុ)។<br>២. លើកឡើងនូវឧបករណ៍សារពើពន្ធនានា ដើម្បីសម្រេចឲ្យបាននូវជម្រើសគោលនយោបាយផ្សេងៗ ដែលបានលើកឡើងនៅក្នុង "ផ្នែកគោលនយោបាយ" និងកសាងសមត្ថភាពពីការគ្រប់គ្រងម៉ាក្រូហិរញ្ញវត្ថុនៅក្នុងរាជរដ្ឋាភិបាល។<br>*យុទ្ធសាស្ត្រម៉ាក្រូសេដ្ឋកិច្ច និងយុទ្ធសាស្ត្រតាមវិស័យ*<br>១ ការធ្វើសមាហរណកម្ម ក្នុងសមាគមអាស៊ាន ធ្វើឲ្យប្រសើរឡើងការបន្ស៊ីជំនួយ កិច្ចសហប្រតិបត្តិការត្បូង-ត្បូងៈ ក្នុងផ្នែកពាណិជ្ជកម្ម (រួមទាំងសេវា) ការវិនិយោគផ្ទាល់ពីបរទេស ការផ្ទេរបច្ចេកវិទ្យា និងផ្នែកផ្សេងទៀត។<br>២ សម្របសម្រួលនិងជំរុញការវិនិយោគឯកជន និងពាណិជ្ជកម្ម។<br>៣ ពង្រីកប្រព័ន្ធអគ្គិសនី ប្រៃសណីយ៍និងទូរគមនាគមន៍ ផ្លូវថ្នល់ ផ្លូវជនបទ ផ្លូវដែក កំពង់ផែ (ទន្លេនិងសមុទ្រ) ធារាសាស្ត្រ។<br>៤ លើកទឹកចិត្តឲ្យមានភាពជាសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម។<br>៥ អនុវត្តគ្រប់វិធានការ និងជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនិងគោលនយោបាយនាំចេញស្រូវ។<br>៦ ពង្រឹងសេវាផ្សព្វផ្សាយក្នុងវិស័យ កសិកម្ម ការចិញ្ចឹមសត្វ និងត្រី។ |

| | |
|---|---|
| | ៧ ដាក់ឲ្យអនុវត្តគោលនយោបាយនាំចេញកៅស៊ូ។<br>៨ បន្តអនុវត្តគោលនយោបាយទេសចរណ៍។<br>៩ ពង្រឹងមូលដ្ឋានទិន្នន័យឧស្សាហកម្មនិងកសិកម្ម។<br>១០ ជំរុញការស្រាវជ្រាវផ្នែកឧស្សាហកម្មនិងកសិកម្មដោយភ្ជាប់ជាមួយឧស្សាហកម្ម (និងអ្នកដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត)។<br><br>*គោលនយោបាយកែទម្រង់រដ្ឋបាលសាធារណៈ*<br>១ រៀបចំជំរឿនពីសេវាស៊ីវិលមួយផ្សេងទៀត ។<br>២ អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។<br>៣ ពង្រឹងសមត្ថភាពនៅថ្នាក់ក្រោមជាតិ រៀបចំកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីនៅថ្នាក់ក្រោមជាតិ។<br>៤ ជំរុញការងារតាមតួនាទី/ការធ្វើប្រតិភូកម្មអំណាចទៅស្ថាប័នអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ រួមទាំងការវិសហមជ្ឈការហិរញ្ញវត្ថុ។<br>៥ បង្កើតរតនាគារ ធនាគារ/មិនមែនធនាគារ នៅកម្រិតក្រុង ស្រុក ខណ្ឌ។<br>៦ បង្កើតកិច្ចសម្របសម្រួលនិងទំនាក់ទំនងល្អជាងមុន រវាងរដ្ឋបាលថ្នាក់ជាតិនិងអាជ្ញាធរថ្នាក់ក្រោមជាតិ កំណត់តួនាទីឲ្យបានច្បាស់លាស់បន្ថែមទៀត។<br>៧ ពង្រឹងយន្តការអាជ្ញាកណ្តាល ជាពិសេសសម្រាប់ការដោះស្រាយទំនាស់ដីធ្លី។<br><br>*យុទ្ធសាស្ត្រ សង្គម មូលធនមនុស្ស និងកាត់បន្ថយភាពក្រីក្រ*<br>១ រៀបចំយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ/ភាពងាយរងគ្រោះ ទៅតាមបរិការណ៍នៃភូមិសាស្ត្រ និងដែនដីនីមួយៗ។<br>២ ផ្តល់សេវាកម្មទឹកស្អាតនិងអនាម័យឲ្យបានទូទាំងប្រទេស។<br>៣ ពង្រឹងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។<br>៤ ពង្រីកបណ្តាញសុវត្ថិភាពសង្គមតាមរយៈកម្មវិធីផ្ទេរប្រាក់ជូនកម្មវិធីអាហារពលកម្ម សោធននិវត្តន៍ និងកម្មវិធីផ្សេងទៀត។<br>៥ ពន្លឿនការផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាជន។<br>៦ ពង្រីកការផ្តល់ដីសម្បទានសង្គមកិច្ចសម្រាប់ការធ្វើអាជីវកម្មកសិកម្ម។<br>៧ ពង្រីកការទទួលបានការផ្គត់ផ្គង់ កម្ចី និងទីផ្សារ សម្រាប់ប្រជាជននៅជនបទ។<br>៨ ពង្រីកសាលាមធ្យសិក្សា ឧត្តមសិក្សា និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>៩ ផ្តួចផ្តើមកម្មវិធីក្រុមគោលដៅសម្រាប់រៀបចំប្រមូលផ្តុំជំនាញ។<br>១០ នាំចូលបច្ចេកវិទ្យាទំនើប។<br>១១ បង្កើតសកលវិទ្យាល័យបច្ចេកវិទ្យា។<br>១២ បង្កើតនិងដំណើរការពេញលេញមណ្ឌលសុខភាព ឃុំមួយមណ្ឌលសុខភាពមួយ។<br>១៣ ជំរុញឲ្យមានការតាមដានសុខភាព។<br>១៤ ពង្រឹងការតាមដានត្រួតពិនិត្យនិងវាយតម្លៃនៅគ្រប់កម្រិត (ថ្នាក់ជាតិ/ថ្នាក់ក្រោមជាតិ) ជាពិសេស មូលដ្ឋានទិន្នន័យ។ |

## គោលនយោបាយសារពើពន្ធ

៣.៣៥- រាជរដ្ឋាភិបាលកម្ពុជាមានទិសដៅ ក្នុងការបន្តការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដើម្បីលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាឲ្យដល់កម្រិតស្តង់ដាអន្តរជាតិ។ ជាក់ស្តែងគោលដៅនៃការពង្រីកប្រព័ន្ធនេះឲ្យក្លាយជាឧបករណ៍មួយមានប្រសិទ្ធភាព គឺសម្រាប់ពង្រីកកំណើនសេដ្ឋកិច្ច ធានាសមធម៌និងយុត្តិធម៌សង្គម ថែរក្សាស្ថិរភាពនៃប្រតិបត្តិការរបស់រដ្ឋ (និងការផ្តល់សេវាសាធារណៈ) និងរួមចំណែកធ្វើឲ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

៣.៣៦- ចំណុចដៅនៃការប្រមូលចំណូលថវិកាជាតិ ត្រូវបានកំណត់ឲ្យមានកំណើនចំណូល និងជាមធ្យមកើនឡើង០,៥%នៃផ.ស.ស.ជារៀងរាល់ឆ្នាំ ឧ. នៅឆ្នាំ២០១១មានកម្រិត១៣,២% ដែលនឹងអាចកើនឡើងដល់យ៉ាងហោចណាស់១៤,៩%ក្នុងឆ្នាំ២០១៣ និងដល់១៥,៤%ក្នុងឆ្នាំ ២០១៤។ នៅចុងបញ្ចប់នៃអាណត្តិកាលរបស់ផែនការ ចំណុចដៅអប្បបរមាដែលរំពឹងទុកនៃ ចំណូលថវិកាមានកម្រិត១៦,៩% នៃផ.ស.ស. ដូចនេះកម្រិតដែលប្រសើរបំផុតនោះគឺ១៨% ដូច បានលើកឡើងក្នុងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ នៅក្នុងផ្នែកចំណាយ រាជរដ្ឋាភិបាល កម្ពុជានឹងបន្តកំណត់អាទិភាពខ្ពស់ចំពោះវិស័យសង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើឲ្យ ប្រសើរឡើងនូវសមត្ថភាពនិងកម្រិតជីវភាពរស់នៅរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ វិស័យទាំងនេះ ត្រូវបានកំណត់អាទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ ហេតុ នេះការវិភាជថវិការដ្ឋសម្រាប់វិស័យអប់រំ គួរតែមិនត្រូវទាបជាង៣% នៃផ.ស.ស. ត្រឹមឆ្នាំ២០១៨ និងមិនត្រូវទាបជាង២% សម្រាប់វិស័យសុខាភិបាលត្រឹមឆ្នាំ២០១៨។ ការផ្តោតការយកចិត្តទុក ដាក់អាចត្រូវបានធ្វើឡើងដើម្បីធានានូវភាពស័ក្តិសិទ្ធ តម្លាភាព និងគណនេយ្យភាព នៅក្នុងការ គ្រប់គ្រងការប្រមូលចំណូលនិងការវិភាជសម្រាប់ចំណាយ។

៣.៣៧- ចំពោះបំណុល ដើម្បីកុំឲ្យមានបញ្ហាក្នុងការគ្រប់គ្រងបំណុលសាធារណៈ សំណើក្នុង ផែនការថ្មីបានលើកឡើងថា គួរតែបន្តរក្សាបំណុលនេះកុំឲ្យលើសពីកម្រិតអប្បបរមា។ បច្ចុប្បន្ន នេះ បំណុលមានអត្រា៣១% នៃផ.ស.ស. ដែលអត្រានេះមិនខ្ពស់ឡើយបើយើងពិនិត្យមើលក្នុង បរិការណ៍ក្នុងបណ្តាប្រទេសនានាក្នុងសមាគមអាស៊ាននិងបណ្តាប្រទេសផ្សេងទៀត។ កិច្ចខិតខំ ប្រឹងប្រែងបន្ថែមទៀតនឹងត្រូវបានធ្វើឡើងដើម្បីបង្កើនអតិរេកថវិកាដើម្បីធានាថា នឹងមិនមានការ ខកខានសម្រាប់វិភាជន៍ថវិកាសម្រាប់វិនិយោគសាធារណៈនិងសេវាបំណុល និងដើម្បីការពារទុន បម្រុងរបស់ប្រទេស។ រាជរដ្ឋាភិបាលក៏មានផែនការ ដើម្បីកាត់បន្ថយឱនភាពថវិកាឲ្យនៅត្រឹម អត្រា៣% នៃផ.ស.ស.ត្រឹមឆ្នាំ២០១៨។

## គោលនយោបាយនិងការវាស់វែងពីការអនុវត្ត

៣.៣៨- រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុ សាធារណៈដំណាក់កាលទី១។ រាជរដ្ឋាភិបាលក៏បានបង្កើនល្បឿនការអនុវត្តកម្មវិធីនេះនៅដំណាក់ កាលទី២ "**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**" ផងដែរ ហើយបច្ចុប្បន្ននេះកំពុងមានគោលដៅ អនុវត្តនៅដំណាក់កាលទី៣ "**បង្កើនការភ្ជាប់ទំនាក់ទំនងរវាងថវិកាជាមួយនឹងគោលនយោបាយ**" និង ដំណាក់កាលទី៤ "**បង្កើនការផ្តល់សេវាកម្មប្រកបដោយគណនេយ្យភាព**" នៃកម្មវិធីកំណែទម្រង់។

*សម្រាប់ចំណូល រាជរដ្ឋាភិបាលនឹង៖*

- ពិនិត្យមើលឡើងវិញនូវ**គោលនយោបាយប្រមូលចំណូល**ដើម្បីរៀបចំនិងអនុវត្ត**យុទ្ធសាស្ត្រប្រមូលចំណូលរយៈពេលមធ្យម២០១៣-២០១៨** និងដូចបានលើកឡើងពីខាងដើមមានគោលបំណងសម្រេចឲ្យបាននូវកំណើនចំណូលជាមធ្យម០,៥%នៃផ.ស.ស.ក្នុងមួយឆ្នាំ។
- បន្តរៀបចំនិងធ្វើឲ្យប្រសើរឡើងប្រព័ន្ធសារពើពន្ធ ដើម្បីធ្វើឲ្យប្រព័ន្ធនេះក្លាយជាកត្តាគន្លឹះសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច។ ហេតុដូចនេះរាជរដ្ឋាភិបាលមានគោលបំណងបង្កើតនូវមូលដ្ឋានដ៏រឹងមាំមួយសម្រាប់បង្កើនចំណូលជាតិ(ដូចបានលើកឡើងពីខាងដើម) បង្កើនភាពស័ក្តិសិទ្ធ កាត់បន្ថយការគេចពន្ធ និងធ្វើជាយន្តការមួយសម្រាប់ធានានូវសមធម៌ល្អប្រសើរថែមទៀតក្នុងសង្គម។
- មិនមានគោលបំណងក្នុងការប្រមូលពន្ធលើដីកសិកម្ម ដូចនេះការមិនយកពន្ធនេះ គឺជាជំនួយដ៏មានប្រសិទ្ធភាពសម្រាប់កសិករអាចវិនិយោគច្រើនបន្ថែមទៀតលើដីទាំងនោះ និងជាធាតុចូលយ៉ាងសំខាន់សម្រាប់បង្កើនផលិតកម្មនិងផលិតភាពដំណាំនិងមិនមែនដំណាំ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ខ្លួន។
- បន្តកសាងនិងកែលម្អច្បាប់និងលិខិតបទដ្ឋានស្តីពីពន្ធដារ ពិសេសផ្តោតលើការរៀបចំបទប្បញ្ញត្តិ ពង្រឹងការដាក់ឲ្យអនុវត្តពន្ធអចលនទ្រព្យទូទាំងប្រទេស បន្ថយកម្រិតផលរបរប្រចាំឆ្នាំដើម្បីពង្រីករបបស្វ័យប្រកាសរៀបចំពន្ធលើរូបវន្តបុគ្គល រៀបចំសន្ធិសញ្ញាពន្ធអន្តរជាតិ និងកែសម្រួលអាករ ពិសេសនឹងពិនិត្យមើលលិខិតបទដ្ឋានពន្ធដារស្តីពីផលិតផលប្រេងកាតនិងផលិតផលរ៉ែផ្សេងទៀត។
- រាជរដ្ឋាភិបាលនឹងពង្រឹងនិងកែលម្អយន្តការរដ្ឋបាលពន្ធដារ ដោយបង្កើនសមត្ថភាពមន្ត្រីពន្ធដារ និងបង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធ ពង្រឹងការធ្វើសវនកម្មពន្ធ រឹតបន្តឹងវិធានការប្រមូលបំណុលពន្ធដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ ព្រមទាំងលើកកម្ពស់អភិបាលកិច្ច និងសុចរិតភាពរបស់មន្ត្រីពន្ធដារ។
- ពង្រឹងនិងធ្វើឲ្យប្រសើរឡើងរដ្ឋបាលគយ តាមរយៈការជំរុញប្រព័ន្ធស្វ័យប្រវត្តិសម្រាប់ទិន្នន័យគយ*(អាស៊ីគូដា)*ជាមូលដ្ឋានគ្រឹះនិងជំរុញអនុវត្តពេញលេញនូវ*គោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម* និង *ប្រព័ន្ធបញ្ចរតែមួយ*។
- បន្តជំរុញលើកកម្ពស់អភិបាលកិច្ច និងសុចរិតភាពរបស់មន្ត្រីគយ ព្រមទាំងរឹតបន្តឹងការអនុវត្តវិធានការបង្ក្រាបអំពើរត់ពន្ធគ្រប់រូបភាពទាំងអស់។
- បញ្ចប់ការរៀបចំនិងដាក់ឲ្យអនុវត្ត **ច្បាប់ស្តីពីការប្រមូលចំណូលមិនមែនពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ស្របតាមគោលដៅរួមនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ។

- បន្តរៀបចំនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការកៀរគរចំណូលមិនមែនសារពើពន្ធរួមទាំងការអនុវត្តកិច្ចសន្យាឬកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជាពិសេសកិច្ចសន្យាស្តីពីសម្បទានដីសេដ្ឋកិច្ច ការជួលទ្រព្យសម្បត្តិសាធារណៈ ការផ្តល់សម្បទានរ៉ែនិងប្រេងកាតព្រមទាំងសម្បទានផ្សេងៗទៀត។
- ពង្រឹងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបញ្ចូលទាំងបរិមាណនិងតម្លៃទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលមាននៅក្នុងបញ្ជីសារពើភណ្ឌរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ពង្រឹងសវនកម្មលើការប្រមូលចំណូលគ្រប់ប្រភេទរួមទាំងចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ ។
- ជំរុញឲ្យមានការស្រាវជ្រាវប្រភពចំណូលថ្មីៗ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីបង្កើនចំណូលបង់ចូលថវិការដ្ឋ។

*សម្រាប់ចំណាយ*

៣.៣៩- រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណងជំរុញការចំណាយនៅក្នុងវិស័យអាទិភាពនានា និងធ្វើឲ្យការចំណាយនេះស្ថិតក្នុងភាពប្រយ័ត្នប្រយែង និងគណនេយ្យភាព។ វិស័យអាទិភាពនៃការចំណាយរួមមាន វិស័យអប់រំ សុខាភិបាល សុវត្ថិភាពសង្គម កសិកម្ម ដី និងអភិវឌ្ឍន៍ជនបទ និងការធ្វើឲ្យប្រសើរឡើងនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ធារាសាស្ត្រ ថាមពល ការផ្គត់ផ្គង់ទឹកស្អាត សាលារៀន មន្ទីរពេទ្យជាដើម។ អាទិភាពផ្សេងទៀតរួមមាន បន្តអនុវត្តការបង្កើនប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដោយផ្អែកលើកំណើនសេដ្ឋកិច្ច និងផ្អែកលើសមត្ថភាពផ្គត់ផ្គង់របស់ថវិការដ្ឋ។ បន្ថែមលើនេះទៀត ការចំណាយអាទិភាពចាំបាច់ចំនួន៤ រួមមាន ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ឧស្សាហកម្ម ការជំរុញកម្មន្តសាលនិងការអភិវឌ្ឍកសិឧស្សាហកម្ម ការអភិវឌ្ឍវិស័យទេសចរណ៍ និងការការពារអធិបតេយ្យភាពនិងបូរណភាពដែនដី។

៣.៤០- ការងារអាទិភាពមួយចំនួនដែលរាជរដ្ឋាភិបាលបាននិងកំពុងរៀបចំនិងគ្រប់គ្រងការចំណាយគឺ៖

- បន្តលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការគ្រប់គ្រងនិងការចាត់ចែងចំណាយ ចាប់ពីដំណាក់កាលនៃការរៀបចំ ការអនុវត្ត ការតាមដាន ការត្រួតពិនិត្យ និងសវនកម្មលើលទ្ធផលនៃការអនុវត្តថវិកា។
- ពង្រឹងការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ព្រមជាមួយនឹងការពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដើម្បីជាមូលដ្ឋាននៃការបង្កើនគុណភាពនិងប្រសិទ្ធភាពនៃការរៀបចំថវិកាប្រចាំឆ្នាំ។

- ពង្រឹងនិងពង្រីកការដាក់អនុវត្តថវិកាកម្មវិធីពេញលេញជាជំហានៗតាមទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកា២០១៣-២០២០ ដើម្បីធានាប្រសិទ្ធភាពនៃការរៀបចំថវិកាឲ្យផ្សារភ្ជាប់ទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលជាគោលដៅជំហានទី៣នៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ លើសពីនេះ ការអនុវត្តថវិកាកម្មវិធីនឹងជួយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល កំណត់បានច្បាស់លាស់នូវគោលបំណងគោលនយោបាយរបស់ស្ថាប័ននីមួយៗ ក្នុងការរួមចំណែកសម្រេចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងសូចនាករលទ្ធផលថ្នាក់ជាតិសំខាន់ៗ។
- ធ្វើឲ្យប្រសើរឡើងនីតិវិធីនៃការអនុវត្តថវិកា តាមរយៈការកាត់បន្ថយនីតិវិធីការិយាធិបតេយ្យមិនចាំបាច់។
- ពង្រឹងការអនុវត្តឲ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្ត។
- ពង្រឹងសវនកម្មទាំងផ្ទៃក្នុងនិងក្រៅលើចំណាយ។
- ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឲ្យបានជាអតិបរមា ដើម្បីឆ្លើយតបនឹងកំណើននៃតម្រូវការហិរញ្ញប្បទានសម្រាប់វិនិយោគសាធារណៈ លើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។
- បន្តអនុវត្តតាមគោលនយោបាយនិងគោលការណ៍គន្លឹះពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ សំដៅរក្សាចីរភាពនៃបំណុលសាធារណៈ ជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែង និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- រៀបចំនិងអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល ព្រមទាំងពង្រឹងបន្ថែមសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។

## គោលនយោបាយរូបិយវត្ថុនិងយុទ្ធសាស្ត្រវិស័យហិរញ្ញវត្ថុ

៣.៤១- ក្នុងផ្នែកនេះ បានលើកឡើងពីកម្រិតខ្ពស់នៃការធ្វើដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា ធ្វើឲ្យឧបករណ៍គោលនយោបាយរូបិយវត្ថុមួយចំនួនមិនអាចត្រូវបានអនុវត្ត។ ជម្រើសមួយចំនួនត្រូវបានបង្ហាញដូចខាងក្រោម។

៣.៤២- អត្រាសន្សំប្រចាំឆ្នាំបានបង្ហាញថា មានអត្រាពី២៤ទៅ២៥% ហើយអត្រាវិនិយោគប្រចាំឆ្នាំក៏មានអត្រាប្រមាណពី២៤ទៅ២៥%ដែរ។ ក្នុងចំណោមការវិនិយោគទាំងអស់មានប្រមាណពាក់កណ្តាលជាទម្រង់នៃការវិនិយោគពីបរទេស។ក្នុងអាណត្តិកាល**ផ.យ.អ.ជ. ២០១៤-២០១៨** រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណងបង្កើនអត្រាសន្សំឲ្យដល់ប្រមាណ៣០% នៅត្រឹមឆ្នាំ២០១៨។ ផែនការនេះនឹងនាំយកសមាសភាគសំខាន់មួយនៃការសន្សំឯកជនទៅក្នុងក្របខ័ណ្ឌស្ថាប័នជាតិដែលបច្ចុប្បន្ននេះពឹងផ្អែកលើមាស សាច់ប្រាក់ឬដីដែលមិនធ្វើចរាចរណ៍(សម្រាប់ការ

ប៉ាន់ស្មានពីការសន្សំ)។ គួរកត់សម្គាល់ថាសន្ទស្សន៍ធាតុចេញមូលធនទំនងជាកើនឡើងជាបន្តទៅទៀតពីអត្រាបច្ចុប្បន្ន២,៥% ដោយសារតែចំនួនដ៏ច្រើននៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្ម អាចនឹងកើតមានឡើងនៅក្នុងអាណត្តិកាលនៃ**ផ.យ.អ.ជ. ២០១៤-២០១៨** ដែលទាមទារឲ្យមានការកែប្រែមួយចំនួន។ ចំណុចដៅនៃអត្រាសន្សំដែលបានកំណត់ឲ្យកើនឡើងដល់អត្រា៣០%អាចនឹងសម្រេចបាននៅក្នុងអាណត្តិកាលនៃផែនការនេះ។

៣.៤៣- រាជរដ្ឋាភិបាលកម្ពុជាមានគោលដៅកសាងនូវមូលដ្ឋានហិរញ្ញវត្ថុដ៏រឹងមាំមួយដោយផ្អែកលើគោលការណ៍ទីផ្សារ ការសន្សំសំចៃធនធាននិងវិភាជន៍ដើម្បីរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងធ្វើឲ្យមានស្ថិរភាពកំណើនសេដ្ឋកិច្ច។

៣.៤៤- រាជរដ្ឋាភិបាលកម្ពុជានឹងបន្តស្វែងរកការធ្វើឲ្យប្រសើរឡើងក្នុងការគ្រប់គ្រង និងតាមដានត្រួតពិនិត្យសេដ្ឋកិច្ច ដែលជាភាពប្រកួតប្រជែង សមាហរណកម្ម តម្លាភាព និងប្រសិទ្ធភាព។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបាននិងកំពុងបន្តលើកទឹកចិត្តឲ្យអនុវត្ត**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០** ដើម្បីគាំទ្រការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនិងការប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា។ ការអនុវត្តនេះអាចត្រូវបានយកចិត្តទុកដាក់ក្នុងវិស័យកសិឧស្សាហកម្ម និងសិប្បកម្ម ដូចបានលើកឡើងពីខាងដើម ដើម្បីទទួលបានសេវាហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលប្រជាជនជាចំណុចស្នូលនៃការងារនេះ។ បន្ថែមលើនេះទៀត កិច្ចខិតខំប្រឹងប្រែងនឹងត្រូវបានធ្វើឡើង ដើម្បីភ្ជាប់នូវការអភិវឌ្ឍហិរញ្ញវត្ថុក្នុងប្រទេសទៅនឹងការធ្វើសមាហរណកម្មហិរញ្ញវត្ថុទៅក្នុងសមាគមន៍អាស៊ាន។

៣.៤៥- ដើម្បីសម្រេចបាននូវការអនុវត្តយុទ្ធសាស្ត្រនានាខាងលើ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញអនុវត្តការងារជាអាទិភាពតាមរយៈវិស័យធនាគារ និងមិនមែនធនាគារៈ

### ក. វិស័យធនាគារ

- អនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាស្ថិរភាពតម្លៃ និងរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ។
- ជំរុញការប្រើប្រាស់ប្រាក់រៀលនិងកាត់បន្ថយដុល្លារូបនីយកម្ម។
- ជំរុញការប្រើប្រាស់ឧបករណ៍វិនិយោគជាប្រាក់រៀល ដូចជា បណ្ណរតនាគារ និងបណ្ណបំណុលផ្សេងទៀត។
- សម្របសម្រួលក្នុងចំណោមបញ្ញត្តិករវិស័យហិរញ្ញវត្ថុ ដើម្បីពង្រឹងការត្រួតពិនិត្យធនាគារ។
- ដាក់ឲ្យអនុវត្តយន្តការគ្រប់គ្រងទូទាំងវិស័យសម្រាប់ស្ថិរភាពរូបិយវត្ថុនិងការគ្រប់គ្រងបំណុល។

- ត្រៀមអនុវត្ត "**យន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ**" ដើម្បីបង្ការវិបត្តិហិរញ្ញវត្ថុ និងបំណុល។
- ពិនិត្យលទ្ធភាពបង្កើតគ្រឹះស្ថានជានាលើប្រាក់បញ្ញើ។
- ដាក់ឲ្យដំណើរការទីផ្សារអន្តរធនាគារនិងអភិវឌ្ឍទីផ្សាររូបិយវត្ថុ។

## ខ. វិស័យមីក្រូហិរញ្ញវត្ថុ

- បន្តពង្រឹងវិស័យមីក្រូហិរញ្ញវត្ថុ ដើម្បីកៀរគរប្រាក់សន្សំពីអ្នកផ្ញើប្រាក់ និងរួមបញ្ចូលប្រាក់សន្សំទាំងនោះទៅក្នុងលំហូរ ធ្វើឲ្យប្រសើរឡើងប្រសិទ្ធភាពនិងចីរភាពហិរញ្ញវត្ថុ ទន្ទឹមនឹងការផ្តល់នូវកម្ចីទៅដល់សហគ្រាសធុនតូច និងអ្នកធ្វើអាជីវកម្មឯកកម្មសិទ្ធិ។
- ពង្រីកវិសាលភាពនៃសេវាមីក្រូហិរញ្ញវត្ថុឲ្យកាន់តែទូលំទូលាយនៅទូទាំងប្រទេស និងផ្សព្វផ្សាយពីផលប្រយោជន៍ឲ្យប្រជាជនបានដឹង។
- រក្សាទិសដៅនៃការផ្តល់ប្រាក់កម្ចីដល់ស្រទាប់ប្រជាពលរដ្ឋក្រីក្រជាមួយនឹងអត្រាការប្រាក់សមស្របអាចទទួលយកបាននិងមានលក្ខខណ្ឌតិចតួច។

## គ. វិស័យមិនមែនធនាគារ

### (i) វិស័យធានារ៉ាប់រង

- បង្កើនល្បឿនអភិវឌ្ឍន៍ឧស្សាហកម្មធានារ៉ាប់រងនៅកម្ពុជា តាមរយៈការពង្រីកវិសាលភាពនៃសេវាធានារ៉ាប់រងឲ្យទូលំទូលាយ រួមទាំងការដាក់ឲ្យមានសេវាធានារ៉ាប់រងអាយុជីវិត។
- លើកទឹកចិត្តឲ្យមានលំហូរមូលធនពីអាជីវកម្មធានារ៉ាប់រងទៅជាប្រភពទុនវិនិយោគដ៏សំខាន់ក្នុងទីផ្សារហិរញ្ញវត្ថុ។
- លើកទឹកចិត្តឲ្យមានការធានារ៉ាប់រងខ្នាតតូច ដើម្បីបំពេញតម្រូវការជូនប្រជាពលរដ្ឋនៅតាមជនបទដែលមានចំណូលទាប។
- បង្កើតយន្តការផ្សះផ្សាវិវាទធានារ៉ាប់រង ដើម្បីដោះស្រាយវិវាទនានាសំដៅធានាយុត្តិធម៌រវាងអ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង។
- ដាក់ឲ្យអនុវត្តប្រព័ន្ធជូនដំណឹងហានិភ័យជាមុន និងទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា។
- បង្កើតវិទ្យាស្ថានធានារ៉ាប់រងដើម្បីបណ្តុះបណ្តាលដល់បញ្ញត្តិករធានារ៉ាប់រង ប្រតិបត្តិករធានារ៉ាប់រង និងសាធារណជន ដើម្បីពង្រឹងគុណភាពនៃការគ្រប់គ្រង ការផ្តល់សេវាធានារ៉ាប់រងប្រកបដោយក្រមវិជ្ជាជីវៈខ្ពស់ និងជំនាញទូទៅក្នុងវិស័យធានារ៉ាប់រង។

### (ii) វិស័យសោធននិវត្តន៍

- លើកទឹកចិត្តក្នុងការកៀរគរប្រាក់សន្សំរយៈពេលវែងដើម្បីប្រើប្រាស់សម្រាប់ការវិនិយោគ (ប្រាក់សោធននិវត្តន៍) និងបង្កើតបណ្ដាញសំណាញ់សុវត្ថិភាពសង្គម ដែលផ្ដល់ផលប្រយោជន៍ដល់អ្នកចូលនិវត្តន៍។
- កសាងក្របខ័ណ្ឌច្បាប់ដើម្បីធ្វើបញ្ញត្តិកម្ម និងត្រួតពិនិត្យប្រព័ន្ធសោធន។
- អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរឹងមាំសម្រាប់បម្រើក្នុងវិស័យហិរញ្ញវត្ថុ រួមទាំងមូលនិធិរបស់សោធននិវត្តន៍។

### (iii) វិស័យមូលបត្រ

- ជំរុញនិងលើកទឹកចិត្តសហគ្រាស ក្រុមហ៊ុនឲ្យធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ព្រមទាំងដាក់ចេញនូវគោលនយោបាយលើកទឹកចិត្តផ្សេងៗ។
- អភិវឌ្ឍទីផ្សារមូលបត្របំណុល ដែលរួមមាន ទីផ្សារសញ្ញាបណ្ណសាជីវកម្មនិងទីផ្សារមូលបត្ររដ្ឋ ព្រមទាំងទីផ្សារមូលបត្រផ្សេងទៀត។
- បង្កើតក្របខ័ណ្ឌគ្រប់គ្រងរួមទាំងបង្កើតភ្នាក់ងារវាយតម្លៃលទ្ធភាពសង (Credit Rating Agency) ដើម្បីគាំទ្រដល់ការបោះផ្សាយលក់មូលបត្របំណុល។
- ជំរុញនិងពង្រឹងនូវការអនុវត្តអភិបាលកិច្ចសាជីវកម្មល្អ។
- រៀបចំនិងដាក់ឲ្យអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការក្ស័យធន និងបរធនបាលកិច្ចហិរញ្ញវត្ថុនៅក្នុងទីផ្សារមូលបត្រ។
- បន្តជំរុញការធ្វើពិពិធកម្មឧបករណ៍ហិរញ្ញវត្ថុ និងយន្តការវិនិយោគ ដើម្បីអភិវឌ្ឍទីផ្សារមូលបត្រឲ្យមានមូលដ្ឋានទូលាយ ដោយជំរុញប្រតិបត្តិការគ្រឹះស្ថានមិនមែនធនាគារឲ្យស្ថិតក្រោមច្បាប់ស្ដីពីបរធនកិច្ចក៏ដូចជាប្រតិបត្តិការគម្រោងវិនិយោគរួមដើម្បីកៀរគរមូលនិធិវិនិយោគ និងទម្រង់ផ្សេងទៀតនៃយន្តការវិនិយោគ។
- ស្វ័យវាយតម្លៃលើប្រព័ន្ធទីផ្សារមូលបត្រ។
- កសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀតនៃទីផ្សារមូលបត្រ។
- បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ ក្នុងគោលបំណងទាក់ទាញលំហូរហិរញ្ញវត្ថុ។
- សិក្សាលទ្ធភាពបង្កើតទីផ្សារខុម៉ូឌីធីនិស្សន្ទ (Commodity Future Exchange) សំដៅជំរុញការអភិវឌ្ឍផលិតផលកសិកម្មនិងឧស្សាហកម្ម។
- បន្តពង្រឹងប្រព័ន្ធព័ត៌មានវិទ្យារបស់និយ័តករ ដើម្បីលើកកម្ពស់ការបង្ហាញព័ត៌មាន និងការតាមដានទីផ្សារមូលបត្រ។
- បន្តអប់រំនិងបណ្ដុះបណ្ដាលសាធារណជន វិនិយោគិននិងអ្នកសារព័ត៌មាន និងពង្រឹងកិច្ចការពារវិនិយោគិន។
- បន្តបណ្ដុះបណ្ដាលកសាងសមត្ថភាពជំនាញរបស់និយ័តករ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ។

## ការអភិវឌ្ឍវិស័យអាជីវកម្ម

### *ក. គោលនយោបាយនិងការវាស់វែងការអនុវត្តសម្រាប់ការអភិវឌ្ឍវិស័យឯកជន*

៣.៤៦- រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ថា វិស័យឯកជនគឺជាក្បាលម៉ាស៊ីនដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ច។ ក្នុងបរិការណ៍នេះ ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ការជំរុញការវិនិយោគក្នុងស្រុក ជាពិសេស សហគ្រាសធុនតូចនិងមធ្យម និងការលើកទឹកចិត្តសហគ្រិនមូលដ្ឋាន គឺជាកត្តាជំរុញយ៉ាងសំខាន់ណាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងបង្កើតការងារ។ លើសពីនេះ វិស័យឯកជនក៏មានតួនាទីសំខាន់ក្នុងការងារសង្គមកិច្ចដែរ ដើម្បីធានាចីរភាពក្នុងការអភិវឌ្ឍ។ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តដើម្បីធានានូវកិច្ចដំណើរការអាជីវកម្មនិងបរិស្ថានសម្រាប់ការវិនិយោគនៃការវិនិយោគឯកជន ដើម្បីធ្វើឲ្យកម្ពុជាក្លាយជាទីកន្លែងសម្រាប់ទាក់ទាញវិនិយោគ។

៣.៤៧- រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតលើការបើកទូលាយ អភិក្រមទូទាំងវិស័យសម្រាប់ការអភិវឌ្ឍវិស័យឯកជននិងទាក់ទាញការវិនិយោគដើម្បីធ្វើសមាហរណកម្មកម្ពុជាទៅក្នុងទីផ្សារតំបន់និងអន្តរជាតិក្នុងគោលដៅកៀរគរទុនវិនិយោគ ការផ្ទេរបច្ចេកវិទ្យា និងពង្រឹងមូលដ្ឋានផលិតកម្ម តាមរយៈការផ្សារភ្ជាប់ទៅនឹងចង្វាក់តម្លៃផលិតកម្មតំបន់និងពិភពលោក។ ខាងក្រោមនេះ គឺជាសំណើចាំបាច់មួយចំនួនៈ

- ផ្តល់នូវរបបផលប្រយោជន៍ដល់វិស័យឯកជន ដើម្បីសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍក្នុងរយៈពេលវែងនៃឧស្សាហូបនីយកម្ម ។
- បន្តលើកទឹកចិត្តនិងជំរុញការចូលរួមរបស់វិស័យឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធតាមរយៈការពិនិត្យឡើងវិញនូវច្បាប់ស្តីពីសម្បទាន ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត។
- បន្តបើកចំហសេដ្ឋកិច្ចនិងធ្វើសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក ដើម្បីផ្តល់កាលានុវត្តភាពដល់ផ្នែកពាណិជ្ជកម្ម និងការវិនិយោគដល់សហគ្រិន។
- បន្តលើកទឹកចិត្តនិងជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស តំបន់កែច្នៃការនាំចេញ តំបន់ពាណិជ្ជកម្មសេរី និងការអភិវឌ្ឍទីផ្សារតាមតំបន់ព្រំដែន។
- បន្តការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងឡាយ ដែលគាំទ្រដល់ការបង្កើតធុរកិច្ច និងលើកកម្ពស់ការវិនិយោគ។
- បង្កបង្កើតបរិយាកាសអំណោយផលសម្រាប់ទទួលការវិនិយោគទាំងក្នុងនិងក្រៅប្រទេស រួមមាន ការសម្រួលការចុះបញ្ជី ការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ជាពិសេស តាមយន្តការច្រកចេញចូលតែមួយ ដើម្បីពន្លឿនរាល់ប្រតិបត្តិការនានាពាក់ព័ន្ធនឹងធុរកិច្ចនិងការវិនិយោគ ព្រមទាំងការកាត់បន្ថយចំណាយក្រៅផ្លូវការ។
- បន្តអនុវត្តនិងដំណើរការយន្តការវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជនដើម្បីដោះស្រាយរាល់កង្វល់ផ្សេងៗរបស់វិស័យឯកជន និងដើម្បីពង្រឹងវិស័យនេះឲ្យកាន់តែមានជីវភាពល្អប្រសើរនិងឲ្យកាន់តែមានភាពជាម្ចាស់។

- ផ្តោតការយកចិត្តទុក្ខដាក់លើការផ្សព្វផ្សាយនិងទាក់ទាញការវិនិយោគផ្ទាល់ ព្រមទាំងលើកកម្ពស់សេវាថៃរក្សាវិនិយោគដែលមានស្រាប់។
- លើកកម្ពស់សហគ្រិនភាព ជាពិសេសក្នុងចំណោមជនជាតិកម្ពុជាឲ្យចេះធ្វើធុរកិច្ច និងវិនិយោគឲ្យបានសស្រាក់សស្រាំ តាមរយៈការលើកទឹកចិត្ត ការផ្តល់ប្រឹក្សា ការផ្តល់ទុន និងបច្ចេកទេស។
- លើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម តាមរយៈការផ្តល់បច្ចេកទេស ការគ្រប់គ្រង ហិរញ្ញប្បទាន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។

### *ខ. គោលនយោបាយនាំអង្ករចេញ*

៣.៤៨- ទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា គឺធ្វើឲ្យប្រសើរឡើងផលិតភាពកសិកម្ម ដែលក្នុងនោះ ការនាំចេញអង្ករគឺជាគោលដៅចម្បង។

៣.៤៩- ទិន្នផលស្រូវបានកើនឡើងពី២,៧៤តោនក្នុងមួយហិកតានៅឆ្នាំ២០០៨ ដល់៣,១៣តោនក្នុងឆ្នាំ២០១២ ហើយផលិតផលសរុប បានឡើងពី៧,១៧លានតោនក្នុងឆ្នាំ២០០៨ ដល់៩,៣១លានតោនក្នុងឆ្នាំ២០១២។ ការនាំចេញស្រូវតាមច្រករបៀងផ្លូវការ បានកើនឡើងដល់២០០ ០០០តោនក្នុងឆ្នាំ២០១២ ធៀបជាមួយនឹងឆ្នាំ២០០៨ ដែលមានតិចតួចប៉ុណ្ណោះ និងគ្មានការព្រមព្រៀងលើសន្តិសុខស្បៀងទេ។ រាជរដ្ឋាភិបាលកម្ពុជានឹងចាប់ផ្តើមអនុវត្ត"**គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ**"ឲ្យបានពេញលេញ នៅក្នុងដំណាក់កាលនៃវដ្តផែនការនេះ។ ទោះជាដូចនេះក្តី ក៏វិស័យនេះនៅជួបប្រទះនឹងបញ្ហាខ្វះខាតជាច្រើនដែលទាមទារត្រូវតែដោះស្រាយ។ បញ្ហាចម្បងមួយចំនួននោះគឺ កំណើនផលស្រូវនៅតែផ្អែកលើប្រព័ន្ធដាំដុះដែលមានលក្ខណៈមិនល្អប្រសើរ ទិន្នផលមានកម្រិតទាប បើប្រៀបធៀបជាមួយនឹងបណ្តាប្រទេសប្រកួតប្រជែងនានា ការធ្វើពាណិជ្ជូបនីយកម្មនៅតែមានកម្រិត ហើយទាំងចំណាយដឹកជញ្ជូននិងចំណាយក្នុងការកែច្នៃនៅមានកម្រិតខ្ពស់នៅឡើយ។

៣.៥០- ដោយផ្តើមចេញពីផលិតភាពនិងតម្លៃបន្ថែមនៅមានកម្រិត ចាំបាច់តម្រូវឲ្យមានការកែលម្អប្រព័ន្ធធារាសាស្ត្រ ការអនុវត្តនូវការផ្តល់ប្រឹក្សាបច្ចេកទេសនៃអាជីវកម្មដាំដុះ រួមទាំងបច្ចេកវិទ្យាទំនើប ជំរុញឲ្យអនុវត្តការដឹកជញ្ជូនដែលមានតម្លៃទាប បង្កើតមធ្យោបាយប្រមូលផល និងស្តុកស្រូវ ពង្រីកសមត្ថភាពកែច្នៃស្រូវ(ដែលអាចប្រកួតប្រជែងចំណាយជាមួយបរទេស) ដោយហេតុថា ការបង្កើតឡើងនូវយន្តការត្រួតពិនិត្យគុណភាពនិងប្រព័ន្ធភស្តុភារសម្រាប់ដំណើរការទាំងមូល។ វិធានការណ៍ចាំបាច់មួយចំនួន មានដូចខាងក្រោមៈ

១ បន្តពង្រឹង ពង្រីក និងធានានូវស្ថិរភាពនៃសេវាផ្សព្វផ្សាយនិងព័ត៌មានទីផ្សារ ពង្រីក ផ្តល់សេវាគាំទ្រទៅដល់កសិករកម្រិតមូលដ្ឋាន និងភ្ជាប់សេវានេះទៅដល់អ្នកដែលមានចំណែកពាក់ព័ន្ធនានា ជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍសម្រាប់ធ្វើឲ្យប្រសើរឡើងនូវផលិតភាព

និងសម្របទៅតាមបម្រែបម្រួលអាកាសធាតុ ជំរុញផលិតកម្មនិងការប្រើប្រាស់ប្រភេទគ្រាប់ពូជដែលមានទិន្នន័យផល/គុណភាពខ្ពស់ បន្តការវិនិយោគក្នុងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រនិងការធ្វើសនិទានកម្មការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ កែលម្អឧបករណ៍ប្រមូលនិងស្តុកផលិតផលស្រូវ និងធ្វើឲ្យប្រសើរឡើងនូវក្របខ័ណ្ឌនិយ័តកម្មសម្រាប់ផលិតពូជ នាំចូលគ្រឿងយន្តកសិកម្ម ការធ្វើកសិកម្មដោយមានកិច្ចសន្យា ការប្រើប្រាស់ដីកសិកម្ម សមាគមប្រើប្រាស់ទឹក និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យនេះ។

២ បន្តជំរុញការធ្វើពាណិជ្ជូបនីយកម្មផលិតផលស្រូវ តាមរយៈការអនុវត្តច្បាប់និងគោលនយោបាយ និងការពង្រឹងការរៀបចំស្ថាប័នដើម្បីជំរុញការធ្វើពាណិជ្ជកម្មនិងការនាំចេញផលិតផលកសិកម្ម អនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីសហគមន៍កសិកម្ម លើកកម្ពស់សមត្ថភាពកែច្នៃ បន្តការជំរុញការសម្របសម្រួលការធ្វើពាណិជ្ជកម្ម រួមទាំង *"សេវាកម្មច្រកចេញចូលតែមួយ"* ពង្រឹងប្រព័ន្ធភស្តុភារលើកកម្ពស់គុណភាពនៃផលិតផលកសិកម្មឲ្យស្របនឹងស្តង់ដាអន្តរជាតិ ការធ្វើឲ្យប្រសើរឡើងសមត្ថភាពក្នុងការផ្តល់ឥណទាន និងការលើកកម្ពស់ភាពជាដៃគូរវាងកសិករ ពាណិជ្ជករ និងឧស្សាហកម្មកែច្នៃអង្ករ។

### *គ. គោលនយោបាយឧស្សាហូបនីយកម្ម*

៣.៥១- ទស្សនាទានរយៈពេលមធ្យមរបស់កម្ពុជាសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម គឺធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានការទាក់ទាញឲ្យចូលមកវិនិយោគបង្កើតរោងចក្រនៅកម្ពុជាពីសំណាក់វិនិយោគិនក្នុងតំបន់និងពិភពលោក។ តាមរយៈនេះ វិនិយោគិនទាំងនោះអាចបង្កើតឡើងនូវមូលដ្ឋានដ៏រឹងមាំមួយសម្រាប់សហគ្រាសធុនតូចនិងមធ្យម។ **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**មានគោលដៅជំរុញកំណើនក្នុងវិស័យឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើ ការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម ការបង្កើតការងារច្រើនថែមទៀតក្នុងវិស័យមិនមែនកសិកម្មដាំដុះ ការធ្វើឲ្យប្រសើរឡើងភាពប្រកួតប្រជែង ការធ្វើឲ្យមានភាពជឿនលឿនក្នុងផ្នែកបច្ចេកវិទ្យា និងការភ្ជាប់ទំនាក់ទំនងវិស័យនេះជាមួយនឹងចរន្តតម្លៃក្នុងតំបន់និងអន្តរជាតិ។

៣.៥២- **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម** មានគោលដៅផ្តល់នូវក្របខ័ណ្ឌរយៈពេលវែងនិងមធ្យម សម្រាប់ធ្វើអន្តរាគមន៍ក្នុង៣ដំណាក់កាលអភិវឌ្ឍន៍ ដើម្បីបង្កើនផលិតកម្ម និងការនាំចេញគឺ *ទី១* រៀបចំស្ថាប័ន តាមរយៈយុទ្ធសាស្ត្រគាំទ្រដើម្បីទាក់ទាញការវិនិយោគ និងពង្រឹងសហគ្រាសធុនតូចនិងមធ្យម *ទី២* បង្កើតឡើងនូវស្ថាប័នទាន់សម័យនានាដើម្បីជួយបង្កើនផលិតភាព និង *ទី៣* ជំរុញការធ្វើឯកទេសកម្ម ផលិតផលនិងដំណើរការផលិត តាមរយៈការលើកទឹកចិត្ត និងនិយ័តកម្ម ផ្អែកលើគោលនយោបាយរយៈពេលវែង។

៣.៥៣- នៅក្នុងដំណាក់កាលនៃការផ្តួចផ្តើម រាជរដ្ឋាភិបាលកម្ពុជាមានគោលដៅបង្កើតឡើងនូវសហគ្រាសឧស្សាហកម្មធុនធំថ្មីឲ្យបានចំនួន៥គម្រោងយ៉ាងតិចក្នុងមួយឆ្នាំ និងក៏មានគោល

ដៅកែលម្អនិងបង្កើតឡើងនូវសហគ្រាសធុនតូចនិងមធ្យមផ្លូវការឲ្យបានចំនួន២០សហគ្រាសក្នុងមួយឆ្នាំ។ គោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាគឺ ដើម្បីសម្រេចឲ្យបាននូវការរួមចំណែករបស់វិស័យឧស្សាហកម្មក្នុងផ.ស.ស. មានអត្រា៣០%នៃផ.ស.ស. ហើយក្នុងវិស័យកម្មន្តសាលត្រូវមានអត្រា២០% នៃផ.ស.ស. ត្រឹមឆ្នាំ២០២០។ រាជរដ្ឋាភិបាលកម្ពុជាក៏មានគោលដៅបង្កើនការនាំចេញផលិតផលកម្មន្តសាល(បន្ថែមពីលើផលិតផលសម្លៀកបំពាក់)ឲ្យលើស១០% នៃតម្លៃនាំចេញសរុប។

៣.៥៤- អាទិភាពសំខាន់ៗរួមមាន ការទាក់ទាញឧស្សាហកម្មថ្មីសម្រាប់បង្កើតមូលដ្ឋានផលិតកម្មសំខាន់ៗ អភិវឌ្ឍជាថ្មីទំនាក់ទំនងជាមួយវិស័យនាំមុខសំខាន់ៗ ដូចជា កសិកម្មនិងទេសចរណ៍ និងឆ្ពោះទៅរកឧស្សាហកម្មមិនមែនប្រពៃណី។ វិស័យអាទិភាពនានារួមមាន ការកែច្នៃផលិតផលកសិកម្មនិងកម្មន្តសាល ការដំឡើងនិងការផលិតសមាសភាគអគ្គិសនីនិងគ្រឿងបន្លាស់ម៉ាស៊ីន វិស័យគាំទ្រដល់ឧស្សាហកម្មសម្លៀកបំពាក់និងសិប្បកម្ម ឧស្សាហកម្មថ្មី ដូចជាផ្លាស្ទីក ឧស្សាហកម្មគីមី និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងការអភិវឌ្ឍផ្នែកទន់។

៣.៥៥- រាជរដ្ឋាភិបាលនឹងបន្តខិតខំប្រមូលផ្តុំនិងបែងចែកធនធានមនុស្ស ហិរញ្ញវត្ថុ និងស្ថាប័ន ដើម្បីគាំទ្រដល់ការបង្កើតឧស្សាហកម្មថ្មី។ នៅក្នុងជំហានដំបូង វិធីសាស្ត្រនេះនឹងបង្កើត និងពង្រឹងច្រករបៀងឧស្សាហកម្មនិងតំបន់សេដ្ឋកិច្ចពិសេស និងធ្វើឲ្យប្រសើរឡើងបរិស្ថានអាជីវកម្មដើម្បីទាក់ទាញការវិនិយោគពីបរទេស លើកទឹកចិត្តឲ្យមានការផ្ទេរបច្ចេកវិទ្យានិងបើកទូលាយទីផ្សារនាំចេញ។ នៅក្នុងជំហានទី២ នឹងត្រូវបានផ្តោតការយកចិត្តទុកដាក់លើការបង្កើតទំនាក់ទំនងនៃតម្លៃក្នុងស្រុកនិងពិភពលោក និងជំរុញការនាំចេញតាមរយៈការបង្កើតបរិស្ថានប្រកួតប្រជែង។ នៅក្នុងជំហានទី៣ វិធីសាស្ត្រនេះមានគោលដៅរក្សាកំណើនក្នុងវិស័យឧស្សាហកម្មក្នុងរយៈពេលវែងតាមរយៈការភ្ជាប់ទំនាក់ទំងដែលបានធ្វើឲ្យប្រសើរឡើងជាមួយសហគ្រាសបរទេស។

៣.៥៦- ការភ្ជាប់ទំនាក់ទំនងរវាងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំអង្ករចេញ ជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម គឺដោយហេតុថា ការនាំចេញអង្ករតម្រូវឲ្យមានការរួមចំណែករបស់កសិឧស្សាហកម្ម ដែលជាវិស័យអាទិភាពនៅក្នុងយុទ្ធសាស្ត្រឧស្សាហូបនីយកម្ម។

### វិមជ្ឈការនិងវិសហមជ្ឈការ

៣.៥៧- ការផ្តោតការយកចិត្តទុកដាក់ជាបឋមនៃកិច្ចខិតខំប្រឹងប្រែងអនុវត្តនូវកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការបង្កើតនិងការអភិវឌ្ឍ

សមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុកឲ្យក្លាយជាស្ថាប័នអភិបាលកិច្ចនិងអភិវឌ្ឍមូលដ្ឋានដ៏មានប្រសិទ្ធភាព។ កិច្ចការដែលត្រូវផ្តោតការយកចិត្តទុកដាក់ រួមមាន (១)ការរៀបចំបង្កើតបរិយាកាសផ្នែកគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលជួយតម្រង់ទិសនិងគាំទ្រដល់ការអនុវត្តកំណែទម្រង់ដូចបានកំណត់ក្នុងច្បាប់រៀបចំអង្គការ (២)ការលើកកម្ពស់ស្វ័យភាពនិងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ(ធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ) និង (៣)ការរៀបចំក្របខ័ណ្ឌនិងប្រព័ន្ធត្រួតពិនិត្យលើការអនុវត្តការងារ ដែលត្រូវអនុវត្តដោយស្ថាប័នថ្នាក់ជាតិនិងជំនួសឲ្យប្រព័ន្ធត្រួតពិនិត្យបែបរដ្ឋបាលនាពេលបច្ចុប្បន្ននេះ ដើម្បីអនុញ្ញាតឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តនូវស្វ័យភាពរបស់ខ្លួន ប៉ុន្តែត្រូវមានគណនេយ្យភាពចំពោះរាល់ការសម្រេចចិត្ត និងការអនុវត្តនូវសេចក្តីសម្រេចចិត្តរបស់ខ្លួនស្របតាមក្របខ័ណ្ឌច្បាប់ជាទូទៅរបស់ជាតិ។ ដើម្បីសម្រេចគោលបំណងនេះ ការប្តេជ្ញាចិត្តផ្នែកនយោបាយនិងគោលដៅជាក់លាក់ត្រូវបានកំណត់យ៉ាងលម្អិតនៅក្នុងជំពូកទី៤។ ជាទូទៅ គោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការមានគោលបំណងដូចខាងក្រោម៖

- លើកកម្ពស់ស្វ័យភាព និងគំនិតផ្តួចផ្តើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងបរិយាកាសស្ថាប័នដែលអាចជួយឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានក្នុងការផ្តួចផ្តើមគំនិតនានាដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍មូលដ្ឋាន។
- លើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (គណនេយ្យភាពខ្សែទទឹង គណនេយ្យភាពខ្សែបណ្តោយ គណនេយ្យភាពផ្នែករដ្ឋបាល និងគណនេយ្យភាពសង្គម) លើកកម្ពស់ការចូលរួមតម្លាភាព ការឆ្លើយតបនិងអភិបាលកិច្ចល្អព្រមទាំងពង្រឹងសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទីជាអ្នកតំណាងឲ្យប្រជាពលរដ្ឋនិងតួនាទីក្នុងការរៀបចំគោលនយោបាយ និងការធ្វើសេចក្តីសម្រេចនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- រៀបចំ និងពង្រឹងការអនុវត្តប្រព័ន្ធត្រួតពិនិត្យមើលដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តការងារនិងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- កែលម្អប្រព័ន្ធនីតិវិធី កិច្ចដំណើរការនិងការអនុវត្តការងារក្នុងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- កែលម្អប្រព័ន្ធគ្រប់គ្រង និងការពិគ្រោះយោបល់របស់រដ្ឋបាលថ្នាកក្រោមជាតិ ព្រមទាំងពង្រឹងប្រព័ន្ធទំនាក់ទំនងផ្ទៃក្នុងរវាងអង្គបញ្ញត្តិ និងអង្គប្រតិបត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្វិតយន្តការនៃការធ្វើសេចក្តីសម្រេចចិត្ត និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈឲ្យទៅកាន់តែកៀកជិតប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរក៏តម្រូវឲ្យមានការរៀបចំរចនា

សម្ព័ន្ធនិងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិឡើងវិញ ព្រមទាំងរៀបចំយន្តការទំនាក់ទំនងនានារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នថ្នាក់ជាតិដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត។

- ធានាឲ្យមានការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពនានា និងកិច្ចដំណើរការរៀបចំគោលនយោបាយជាតិ ដោយត្រូវធានាថាសំឡេងរបស់ស្ត្រីត្រូវបានយកចិត្តទុកដាក់ស្តាប់ និងដើម្បីធានាថា សិទ្ធិនិងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រីត្រូវបានយកចិត្តទុកដាក់ទាំងនៅក្នុងប្រព័ន្ធរដ្ឋបាលមូលដ្ឋាន ទាំងនៅក្នុងការប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលមូលដ្ឋាន។
- ធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់តាមរយៈការផ្ទេរធនធានដោយមានលក្ខខណ្ឌនិងការផ្ទេរធនធានដោយគ្មានលក្ខខណ្ឌ ព្រមទាំងការប្រមូលចំណូលផ្ទាល់នៅមូលដ្ឋាន។ ការផ្តល់ប្រភពចំណូលផ្ទាល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាយន្តការជំរុញស្វ័យភាពនៅមូលដ្ឋាន និងការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋផងដែរ។
- ពង្រឹងប្រព័ន្ធកសាងផែនការ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការបន្សុីគ្នារវាងការកសាងផែនការនិងការរៀបចំគម្រោងថវិកា។

## ទស្សនវិស័យសេដ្ឋកិច្ច ២០១៤-២០១៨

៣.៥៨- នៅចុងឆ្នាំ២០១៣ ទស្សនវិស័យសេដ្ឋកិច្ចបានបង្ហាញចេញនូវភាពមិនច្បាស់លាស់ ដោយសារកត្តាធំៗមួយចំនួន។ ក្នុងឆ្នាំនេះកម្ពុជាបានប្រឈមនឹងគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរដែលបានធ្វើឲ្យខូចខាតទ្រព្យសម្បត្តិជាច្រើន។ បន្ទាប់មកទៀតគឺរយៈពេលនៃការស្តារឡើងវិញឲ្យរួចផុតពីវិបត្តិនៅមិនទាន់ដឹងច្បាស់នៅឡើយ។ ជាចុងក្រោយ ផ.ស.ស. សម្រាប់មនុស្សម្នាក់នៅក្នុងប្រទេសមានកម្រិតលើសពី១ ០០០ដុល្លារអាមេរិកក្នុងឆ្នាំនេះ ដែលធ្វើឲ្យលទ្ធភាពនៃលំហូរជំនួយឥតសំណងពីបណ្តាប្រទេសផ្តល់ជំនួយនៅតែមិនទាន់មានភាពច្បាស់លាស់។ ទន្ទឹមនឹងនេះដែរ កម្ពុជានឹងត្រូវពុះពារទល់នឹងការខូចខាតដែលបណ្តាលមកពីគ្រោះទឹកជំនន់ និងត្រូវប្រុងប្រៀបខ្លួនទប់ទល់នឹងបញ្ហាផ្សេងៗ ដែលកើតមានឡើងដោយសារការប្រែប្រួលអាកាសធាតុ។ ចំពោះកង្វល់នានា ពាក់ព័ន្ធនឹងការធ្វើឲ្យល្អប្រសើរឡើងវិញបន្ទាប់ពីវិបត្តិពិភពលោកប្រហែលនឹងមិនបន្តស្តែងឲ្យឃើញពីឥទ្ធិពលមកលើប្រទេសកម្ពុជា ដោយសារកម្ពុជាជាប្រទេសមានសេដ្ឋកិច្ចបើកទូលាយនិងបានភ្ជាប់ទំនាក់ទំនងជាមួយសេដ្ឋកិច្ចអាស៊ាន និងបណ្តាប្រទេសដទៃទៀតនៅទ្វីបអាសុី ដែលក្នុងដំណាក់កាលអន្តរកាលនេះនឹងត្រូវបានគ្រប់គ្រងដោយភាពច្បាស់លាស់។

បញ្ហាចម្បងនោះគឺប្រសិនបើជំនួយឥតសំណងត្រូវបានបញ្ចប់ក្នុងរយៈពេល៤ឬ៥ឆ្នាំបន្ទាប់ នោះដំណើរនៃការផ្តល់ថវិកានឹងត្រូវពង្រឹងឲ្យបានខ្លាំងក្លាជាងមុនថែមទៀត។

៣.៥៩- ដោយសារការដឹកនាំច្បាស់លាស់ និងសន្តិភាពនិងស្ថិរភាពនយោបាយ បានធ្វើឲ្យវិនិយោគផ្ទាល់ពីបរទេសកំពុងចូលមកកម្ពុជា ហើយការវិនិយោគពីវិនិយោគិនក្នុងស្រុកក៏កំពុងកើនឡើងផងដែរ។ កម្រិតជឿជាក់របស់អតិថិជនក៏កំពុងត្រូវបានធ្វើឲ្យប្រសើរឡើងដែលធ្វើឲ្យកម្ពុជាស្វែងរកលទ្ធភាពផ្គត់ផ្គង់ផលិតផលជាទ្រង់ទ្រាយធំសម្រាប់ទីផ្សារក្រៅប្រទេសឲ្យបានច្រើនជាងទីផ្សារក្នុងស្រុក ហើយបាននិងកំពុងបង្កើនកាលានុវត្តភាពការងារ។ ម្យ៉ាងវិញទៀតដោយសារទំហំទីផ្សារមានភាពតូចចង្អៀត ដូចបានលើកឡើងពីខាងដើម និងការពឹងផ្អែកលើការនាំចេញផលិតផលសម្លៀកបំពាក់ទៅទីផ្សារនៅសហគមន៍អឺរ៉ុប និងអាមេរិកនៅតែជាកត្តាកំណត់សម្រាប់ការផលិតនៅឡើយ។ កំណើនសេដ្ឋកិច្ចកម្រិតខ្ពស់របស់ចិនដែលនៅតែបន្តកើនឡើងនិងទស្សនវិស័យសម្រាប់កំណើនពេលអនាគតបាននិងកំពុងលើកទឹកចិត្តដល់សេដ្ឋកិច្ចដ៏ខ្លាំងរបស់ប្រទេសចិននេះនឹងមានឥទ្ធិពលជាវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជានាពេលអនាគត។

៣.៦០- ក្រៅពីផលប៉ះពាល់របស់វិបត្តិសកលលោកមកលើសេដ្ឋកិច្ចកម្ពុជា គឺកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ(ដែលបានដាក់ឲ្យអនុវត្តតាមរយៈការអនុវត្តវិធានការបន្ទាន់នូវគោលនយោបាយនានានៅទសវត្សរ៍កន្លងទៅ) ប្រទេសជាតិនៅតែប្រឈមក្នុងការជៀសវាងពីវិបត្តិនិងដើម្បីឈានចូលក្នុងដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍសេដ្ឋកិច្ច។ កម្ពុជានឹងរង់ចាំប្រមាណពី៧ទៅ៨ឆ្នាំទៀត សម្រាប់ការអភិវឌ្ឍមូលធនមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា។ ម្យ៉ាងវិញទៀត ទោះបីជាសេដ្ឋកិច្ចកម្ពុជានឹងនៅតែបន្តកើនឡើងក្នុងរយៈពេលយ៉ាងតិច៤ទៅ៥ឆ្នាំទៀតក៏ដោយ ក៏ប៉ុន្តែកំណើននឹងមិនអាចកើនលើសពីនេះបានទេ ប្រសិនបើបញ្ហាដែលកំពុងតែកើតមាននៅតែមិនទាន់បានដោះស្រាយ។

៣.៦១- រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា កំណើនសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសរីកចម្រើនដូចជា សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប មានកម្រិតទាប ហើយការចំណាយរបស់អតិថិជននៅទីនោះ នឹងមិនបន្តផ្តល់កម្រិតដូចគ្នានៃការគាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជាដូចកាលពីអតីតកាលបានទេ។ ទោះជាដូចនេះក្តី កម្ពុជាជឿជាក់ថា ដៃគូថ្មីនៅទ្វីបអាស៊ីនិងមជ្ឈិមបូព៌ានឹងអាចជួយបំពេញឲ្យផ្នែកដែលបានបាត់បង់។ បន្ថែមលើនេះទៀត យើងជឿជាក់ថា ការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កំណើនក្នុងផលិតផលដំណាំឧស្សាហកម្ម និងការទើបស្វែងរកឃើញធនធានរ៉ែថ្មីៗនឹងអាចជួយដោះស្រាយនូវបញ្ហាបន្ទាន់។

៣.៦២- តាមការប៉ាន់ស្មាននិងព្យាករណ៍ថ្មីៗពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសម្រាប់រយៈពេលពីឆ្នាំ២០១៤ដល់២០១៨ មានបង្ហាញនៅក្នុងតារាងទី៣.១។ ការព្យាករតាមវិស័យសម្រាប់រយៈពេលពីឆ្នាំ២០១៤ដល់២០១៨ មានបង្ហាញជូននៅក្នុងតារាងទី៣.២។

### តារាងទី៣.១ : ការព្យាករសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០១៣ដល់២០១៨

| សូចនាករសេដ្ឋកិច្ច | ២០១៣ | ២០១៤ ព្យាករណ៍ | ២០១៥ ព្យាករណ៍ | ២០១៦ ព្យាករណ៍ | ២០១៧ ព្យាករណ៍ | ២០១៨ ព្យាករណ៍ |
|---|---|---|---|---|---|---|
| ផ.ស.ស. (ថ្លៃថេរឆ្នាំ២០០០-គិតជាពាន់លានរៀល) | ៦១ ៥២៥ | ៦៨ ៦១៨ | ៧៥ ៦៣៦ | ៨៣ ៤២២ | ៩២ ១៤៣ | ១០១ ៥៤៨ |
| ផ.ស.ស. (ថ្លៃថេរឆ្នាំ២០០០-គិតជាលានដុល្លារអាមេរិក) | ១៥ ១៩១ | ១៦ ៩៤៣ | ១៨ ៦៧៦ | ២០ ៥៩៨ | ២២ ៤៧៤ | ២៤ ៧៦៨ |
| ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ (ដុល្លារអាមេរិក) | ១ ០៣៦ | ១ ១៣៩ | ១ ២៣៧ | ១ ៣៤៧ | ១ ៤៥១ | ១ ៥៧៩ |
| ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ (ពាន់រៀល) | ៤ ២៤៨ | ៤ ៦៧០ | ៥ ០៧២ | ៥ ៥២៣ | ៥ ៩៤៩ | ៦ ៤៧២ |
| **អត្រាកំណើនពិត នៃ ផសស (%)** | ៧,០% | ៧,០% | ៧,០% | ៧,០% | ៧,០% | ៧,០% |
| សន្ទស្សន៍នៃផ.ស.ស. -ការប្រែប្រួលប្រចាំឆ្នាំ -%) | ០,៨% | ៤,២% | ៣,០% | ៣,០% | ៣,២% | ៣,០% |
| | | | | | | |
| អតិផរណា(ការប្រែប្រួលមធ្យមប្រចាំឆ្នាំ - %) | ៣,០% | ៣,៥% | ៣,៥% | ៣,៥% | ៣,៥% | ៣,៥% |
| អតិផរណា(ការប្រែប្រួលក្នុងត្រីមាសទី៤ - %) | ៤,០% | ៣,៥% | ៣,៥% | ៣,៥% | ៣,៥% | ៣,៥% |
| អតិផរណា(ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ - %) | ៣,១% | ៣,៥% | ៣,៥% | ៣,៥% | ៣,៥% | ៣,៥% |
| អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារ(មធ្យមប្រចាំឆ្នាំ) | ៤ ០៥០ | ៤ ០៥០ | ៤ ០៥០ | ៤ ០៥០ | ៤ ១០០ | ៤ ១០០ |
| អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារ(ចុងឆ្នាំ) | ៤ ០៦៥ | ៤ ០៥០ | ៤ ០៥០ | ៤ ០៥០ | ៤ ១០០ | ៤ ១០០ |
| | | | | | | |
| **ការវិនិយោគសរុប(% ផសស)** | ២៧,២ | ២៥,៨ | ២៦,១ | ២៦,៣ | ២៦,៥ | ២៦,៦ |
| ការវិនិយោគសាធារណៈ(%ផ.ស.ស.) | ៧,៧% | ៧,៥% | ៧,៦% | ៧,៧% | ៧,៧% | ៧,៧% |
| ការវិនិយោគឯកជន(%ផ.ស.ស.) | ១៩,៥% | ១៨,៣% | ១៨,៥% | ១៨,៧% | ១៨,៨% | ១៩,០% |
| សញ្ជ័យជាតិ*(សន្សំ)*(% ផ.ស.ស.) | ២១,៨% | ២០,២% | ២០,៧% | ២១,៤% | ២២,៨% | ២៤,២% |
| សញ្ជ័យក្រៅប្រទេស*(សន្សំ)* (% ផ.ស.ស.) | ៥,៤% | ៥,៦% | ៥,៤% | ៤,៩% | ៣,៧% | ២,៤% |
| | | | | | | |
| **ចំណូលថវិកាសរុប(% ផ.ស.ស.)** | ១៤,៣% | ១៥,១% | ១៥,៦% | ១៦,១% | ១៦,៥% | ១៦,៩% |
| **ចំណាយថវិកាសរុប(% ផ.ស.ស.)** | ១៩,៥% | ១៩,៩% | ១៩,៨% | ១៩,៩% | ១៩,៩% | ១៩,៩% |
| ឱនភាព/អតិរេកថវិកាចរន្ត(% ផ.ស.ស.) | ២,៣% | ២,៦% | ៣,៤% | ៣,៩% | ៤,៤% | ៤,៨% |
| ឱនភាព/អតិរេកថវិកាទូទៅ(% ផ.ស.ស.) | -៥,៣% | -៤,៨% | -៤,២% | -៣,៨% | -៣,៤% | -៣,០% |
| | | | | | | |
| **ការនាំចេញទំនិញ(% ផ.ស.ស.)** | ៤៥/៥ | ៣៧/៦ | ៣៧/៤ | ៣៨/៨ | ៤១/០ | ៤៣/៤ |
| **ការនាំចូលទំនិញ(% ផ.ស.ស.)** | ៦៣/០ | ៥២/៥ | ៥២/៥ | ៥៣/៧ | ៥៥/១ | ៥៦/៦ |
| | | | | | | |
| តុល្យភាពពាណិជ្ជកម្ម(% ផ.ស.ស.) | -១៣,៦% | -១៣,៦% | -១៣,៤% | -១២,៨% | -១១,៤% | -៩,៨% |
| តុល្យភាពគណនីចរន្ត(% ផ.ស.ស.) | -៩,៥% | -៩,៣% | -៨,៨% | -៨,១% | -៦,៧% | -៥,២% |
| | | | | | | |
| សាច់ប្រាក់ងាយស្រួលសរុប(ពាន់លានរៀល) | ៣៤ ៤៦៣ | ៤១ ៣៦១ | ៥០ ៦៤៣ | ៦១ ៨៣៦ | ៧៥ ៤៤៤ | ៩២ ២៤០ |
| សាច់ប្រាក់ងាយស្រួលសរុប(បម្រែបម្រួលជា %) | ២០,៥% | ២០,០% | ២២,៤% | ២២,១% | ២២,០% | ២២,៣% |
| សាច់ប្រាក់ងាយស្រួលសរុប(% ផ.ស.ស.) | ៥៦,០% | ៦០,៣% | ៦៧,០% | ៧៤,១% | ៨១,៩% | ៩០,៨% |
| **ទុនបម្រុងបរទេសដុល(លានដុល្លារអាមេរិក)** | ៣ ៩៣២ | ៤ ៤៧៧ | ៥ ០៨៦ | ៥ ៧០៨ | ៦ ៣៦៥ | ៧.០៦៥ |
| **ទុនបម្រុងបរទេសដុល(ចំនួនខែនាំចូលទំនិញនិងសេវា)** | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ |
| | | | | | | |
| **ចំនួនប្រជាជន(តួលេខកែសម្រួល លាននាក់)** | ១៤,៧ | ១៤,៩ | ១៥,១ | ១៥,៣ | ១៥,៥ | ១៥,៧ |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## តារាងទី៣.២ : ផលិតផលក្នុងស្រុកសរុបពិត(ថ្លៃថេរឆ្នាំ២០០០) អត្រាកំណើនតាមសកម្មភាពសេដ្ឋកិច្ច ឆ្នាំ២០១៤ដល់២០១៨

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** | **៤,២%** | **៤,០%** | **៤,០%** | **៤,០%** | **៤,០%** |
| ដំណាំ | ៣,៨% | ៣,៥% | ៣,៤% | ៣,៣% | ៣,២% |
| បសុសត្វនិងបសុបក្សី | ៦,០% | ៦,១% | ៦,៣% | ៦,៤% | ៦,៥% |
| ជលផល | ៤,៧% | ៤,៧% | ៤,៧% | ៤,៧% | ៤,៧% |
| ផលព្រៃឈើ | ១,១% | ១,១% | ១,១% | ១,១% | ១,១% |
| **ឧស្សាហកម្ម** | **៩,៩%** | **៩,១%** | **៨,៩%** | **៨,៦%** | **៨,៦%** |
| រ៉ែ | ២២,៧% | ១៤,៤% | ១០,១% | ១០,១% | ១០,១% |
| កម្មន្តសាល | ៨,៥% | ៨,៥% | ៨,៤% | ៨,៣% | ៨,៣% |
| អាហារ ភេសជ្ជៈ និង ថ្នាំជក់ | ៦,៥% | ៦,៦% | ៦,៧% | ៦,៧% | ៦,៧% |
| វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង | ៨,៧% | ៨,៧% | ៨,៦% | ៨,៤% | ៨,៣% |
| ឈើ ក្រដាស និងការបោះពុម្ព | ៩,៤% | ៨,៨% | ៨,៧% | ៨,៨% | ៨,៧% |
| កម្មន្តសាលកៅស៊ូ | ៧,៦% | ៦,៩% | ៧,០% | ៧,០% | ៧,០% |
| កម្មន្តសាលផ្សេងៗទៀត | ៨,៨% | ៨,០% | ៨,៣% | ៩,២% | ១០,១% |
| អគ្គិសនី ឧស្ម័ន និងទឹក | ៧,៨% | ៧,០% | ៧,០% | ៧,១% | ៧,០% |
| សំណង់ | ១៣,១% | ១០,៨% | ១០,៨% | ៩,៣% | ៩,២% |
| **សេវា** | **៦,៨%** | **៧,១%** | **៧,៣%** | **៧,៣%** | **៧,៣%** |
| ពាណិជ្ជកម្ម | ៦,២% | ៦,២% | ៦,៣% | ៦,៣% | ៦,៣% |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៩,៣% | ៩,៧% | ១០,០% | ៩,៨% | ១០,០% |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៦,៧% | ៦,៦% | ៦,៧% | ៦,៧% | ៦,៧% |
| ហិរញ្ញវត្ថុ | ១០,០% | ១០,១% | ១០,១% | ១០,២% | ១០,១% |
| រដ្ឋបាលសាធារណៈ | ៤,៧% | ៤,៧% | ៥,៣% | ៥,៤% | ៥,៣% |
| អចលនវត្ថុនិងធុរកិច្ច | ៩,៨% | ៩,៤% | ៩,៥% | ៩,៥% | ៩,៥% |
| សេវាផ្សេងៗទៀត | ៣,៥% | ៤,៥% | ៤,៦% | ៤,៧% | ៤,៦% |
| | | | | | |
| ពន្ធលើផលិតផលដកឧបត្ថម្ភធន | ៧,៣% | ៨,៣% | ៧,៧% | ៨,៤% | ៨,៥% |
| ដក : ឧបត្ថម្ភធន | ៧,៥% | ៧,២% | ៦,៧% | ៧,៣% | ៧,៣ |
| ដក : បន្ទុកលើសេវាហិរញ្ញវត្ថុ | ២១,៥% | ១០,១% | ១០,១% | ១០,២% | ១០,១% |
| **សរុប ផលិតផលក្នុងស្រុកសរុប( សរុប ផ.ស.ស.)** | **៧,០%** | **៧,០%** | **៧,០%** | **៧,០%** | **៧,០%** |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

៣.៦៣- តារាងទី៣.៣ បង្ហាញពីតម្រូវការវិនិយោគបំបែកលម្អិតតាមវិស័យសេដ្ឋកិច្ច ដើម្បីសម្រេចឲ្យបាននូវចំណុចដៅអត្រាកំណើន។ ដើម្បីសម្រេចបានតាមការព្យាករចំណុចដៅអត្រាកំណើនតាមវិស័យ ការវិនិយោគនៅក្នុងវិស័យសំខាន់ៗ មានដូចខាងក្រោម៖

- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវការថវិកាសម្រាប់វិនិយោគប្រមាណ ១៥ ៨០១ពាន់លានរៀល(៣,៩ពាន់លានដុល្លារអាមេរិក) ក្នុងរយៈពេលនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨។
- នៅក្នុងវិស័យឧស្សាហកម្មទាំងមូល(ដែលរួមមាន រ៉ែ កម្មន្តសាល អគ្គិសនី ឧស្ម័ន្ទ ទឹក និងសំណង់) នឹងត្រូវការទុនសម្រាប់វិនិយោគប្រមាណ៥២ ២៧៨ពាន់លានរៀល(១២,៨ ពាន់លានដុល្លារអាមេរិក)ក្នុងរយៈពេល៥ឆ្នាំ។ នៅក្នុងក្រុមឧស្សាហកម្មនេះ វិស័យកម្មន្តសាល(ដែលរួមទាំង អនុវិស័យ វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង) នឹងត្រូវការមួយចំណែកធំនៃទុនវិនិយោគ គឺប្រមាណ២៤ ០១៥ពាន់លានរៀល(៥,៩ពាន់លានដុល្លារអាមេរិក) អនុវិស័យសំណង់នឹងត្រូវការ១៧ ៣៦៧ពាន់លានរៀល(៤,៣ ពាន់លានដុល្លារអាមេរិក) និងអនុវិស័យអគ្គិសនី ឧស្ម័ន និងទឹក នឹងត្រូវការទុនវិនិយោគ៨ ១០៧ពាន់លានរៀល(២ពាន់លានដុល្លារអាមេរិក)។
- វិស័យសេវាទាំងមូល(រួមទាំង ពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន ទេសចរណ៍ ការដឹកជញ្ជូននិងប្រៃសណីយ៍ ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ និងអចលនទ្រព្យ) នឹងត្រូវការការវិនិយោគប្រមាណ៤០ ៩៣៧ពាន់លានរៀល(១០ពាន់លានដុល្លារអាមេរិក)។

**តារាងទី៣.៣ : វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗ ដើម្បីសម្រេចបាននូវកំណើន ផ.ស.ស.**

(គិតជាពាន់លានរៀល)

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** | **២ ៧៣៩,០** | **២ ៩៣៨,៨** | **៣ ១៤៩,០** | **៣ ៣៧០,៤** | **៣ ៦០៤,៧** | **១៥ ៨០១,៩** |
| ដំណាំ | ២ ២៨៧,៤ | ២ ៤៥២,៧ | ២ ៦២៥,១ | ២ ៨០៥,៥ | ២ ៩៩៩,៦ | ១៣ ១៦៨,៨ |
| បសុសត្វនិងបសុបក្សី | ១៣៧,៩ | ១៥១,៤ | ១៦៦,៤ | ១៨២,៩ | ២០១,៤ | ៨៤០,០ |
| ជលផល | ១៨១,០ | ១៩៦,០ | ២១២,២ | ២២៩,៧ | ២៤៨,៧ | ១.០៦៧,៧ |
| ផលព្រៃឈើ | ១៣២,៧ | ១៣៨,៦ | ១៤៤,៨ | ១៥១,៣ | ១៥៨,១ | ៧២៥,៥ |
| **ឧស្សាហកម្ម** | **៨ ១៥៨,៣** | **៩ ១៨៥,០** | **១០ ៣២១,២** | **១១ ៥៩៩,១** | **១៣ ១១៣,៩** | **៥២ ២៧៧,៦** |
| រ៉ែ | ៤១០,៦ | ៤៨៥,៤ | ៥៥១,៧ | ៦២៧,១ | ៧១២,៧ | ២ ៧៨៧,៥ |
| កម្មន្តសាល | ៣ ៧៩៩,៧ | ៤ ២៣២,៤ | ៤ ៧១៦,៥ | ៥ ៣១០,៣ | ៥ ៩៥៦,៧ | ២៤ ០១៥,៥ |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | ៣៨២,៣ | ៤២១,០ | ៤៦៣,៧ | ៥១០,៧ | ៥៦២,៥ | ២ ៣៤០,២ |
| វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង | ១ ៤៦៥,២ | ១ ៦៣៤,៨ | ១ ៨២០,៩ | ២ ០៦៤,០ | ២ ២៩៣,១ | ៩ ២៧៨,០ |
| ឈើ ក្រដាស និងការបោះពុម្ព | ១០២,៣ | ១១៥,០ | ១២៩,៣ | ១៤៥,៣ | ១៦៣,៣ | ៦៥៥,២ |
| កម្មន្តសាលកៅស៊ូ | ១៥២,៧ | ១៦៨,៧ | ១៨៦,៣ | ២០៥,៨ | ២២៧,៣ | ៩៤០,៨ |

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|
| កម្មន្តសាលផ្សេងៗទៀត | ១ ៦៩៧,១ | ១ ៨៩២,៩ | ២១១៦,៣ | ២.៣៨៤,៥ | ២ ៧១០,៤ | ១០ ៨០១,២ |
| អគ្គិសនី ឧស្ម័ន និងទឹក | ១ ៣១៥,២ | ១ ៤៥៣,១ | ១ ៦០៥,៤ | ១ ៧៧៣,៧ | ១ ៩៥៩,៧ | ៨ ១០៧,២ |
| សំណង់ | ២ ៦៣២,៨ | ៣ ០១៤,២ | ៣ ៤៤៧,៥ | ៣ ៨៨៨,០ | ៤ ៣៨៤,៩ | ១៧ ៣៦៧,៤ |
| **សេវា** | **៦ ៦១៤,២** | **៧ ៣១១,១** | **៨ ០៩៦,០** | **៨ ៩៧៣,២** | **៩ ៩៤២,៩** | **៤០ ៩៣៧,៤** |
| ពាណិជ្ជកម្ម | ១ ១១៩,៤ | ១ ២២៨,៣ | ១ ៣៤៧,៧ | ១ ៤៧៨,៨ | ១ ៦២២,៥ | ៦ ៧៩៦,៨ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៩៣៦,៣ | ១ ០៧៣,៦ | ១ ២៣១,២ | ១ ៤១៦,១ | ១៦២១,៦ | ៦ ២៧៨,៧ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ១ ០៨៩,៥ | ១ ២០០,២ | ១ ៣២២,២ | ១.៤៥៦,៦ | ១ ៦០៤,៦ | ៦ ៦៧៣,១ |
| ហិរញ្ញវត្ថុ | ២១៦,៦ | ២៤៦,៤ | ២៨០,១ | ៣១៨,៥ | ៣៦២,២ | ១ ៤២៣,៩ |
| រដ្ឋបាលសាធារណៈ | ១ ៧០០,៦ | ១ ៨៤០,១ | ២ ០០០,៩ | ២ ១៧៥,៨ | ២ ៣៦៥,៩ | ១០ ០៨៣,៣ |
| អចលនវត្ថុនិងធុរកិច្ច | ៩៣៨,៨ | ១ ០៦១,៣ | ១ ០៩៩,៧ | ១ ៣៥៦,១ | ១ ៥៣៣,០ | ៦ ០៨៨,៩ |
| សេវាផ្សេងៗទៀត | ៦១២,៩ | ៦៦១,៣ | ៧១៤,២ | ៧៧១,៣ | ៨៣៣,០ | ៣ ៥៩២,៦ |
| **សរុប** | **១៧ ៥១១,៥** | **១៩ ៤៣៤,៩** | **២១ ៥៦៦,២** | **២៣ ៩៤២,៧** | **២៦ ៥៦១,៥** | **១០៩ ០១៦,៩** |

*ប្រភព: ក្រសួងផែនការ*

## ចំណូលនិងចំណាយថវិកា ឆ្នាំ២០១៤ ដល់ ២០១៨

៣.៦៤- ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតឡើងនូវដំណើរការចំនួនពីរ ដែលផ្តល់នូវធាតុចូលសំខាន់ៗនៅក្នុងការរៀបចំថវិកាជាតិប្រចាំឆ្នាំ។ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមផ្តល់នូវការព្យាករពីចំណាយចរន្តរបស់ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាសម្រាប់រយៈពេលបីឆ្នាំបន្ទាប់។ ការព្យាករនេះនឹងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ។ ការព្យាករត្រូវបានធ្វើឡើងដោយផ្អែកលើការវិភាគពីលើចុះក្រោមនៃម៉ាក្រូសេដ្ឋកិច្ច លើការអនុវត្តសេដ្ឋកិច្ច គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាព័ត៌មានពីក្រោមឡើងលើ ស្តីពីការចំណាយរបស់ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា។ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការវិភាគនេះ។ ដំណាក់កាលទី២ គឺ "**ក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា**" បីឆ្នាំរំកិលដែលអនុវត្តតាមវិធីសាស្ត្រពីក្រោមឡើងលើ និងត្រូវបានរៀបចំឡើងដោយនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ធាតុចូលសំខាន់សម្រាប់ការវិភាគនេះ គឺជាព័ត៌មានដែលបានប្រមូលនៅក្នុងពេលនៃការពិភាក្សារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយនឹងក្រសួង ស្ថាប័ន និងជាធាតុចូលដែលត្រូវបានផ្តល់ឲ្យដោយក្រសួង ស្ថាប័ន ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការចំណាយនិងតម្រូវការចំណាយរបស់ស្ថាប័នទាំងនោះសម្រាប់រយៈពេលពីរឆ្នាំបន្ទាប់។ នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងការផ្សារភ្ជាប់រវាងដំណើរការទាំងពីរនេះ ដើម្បីបន្តកែលម្អនិងតម្រង់ទិសដំណើរការរៀបចំថវិកាប្រចាំឆ្នាំ។

**៣.៦៥-** ផ្នែកមួយនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការពង្រឹងទំនាក់ទំនងរវាងដំណើរការនានា ដែល (១) កំណត់អាទិភាពខ្ពស់នៃតម្រូវការវិនិយោគសាធារណៈ ដែលរួមបញ្ចូលទាំង ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** រយៈពេល៥ឆ្នាំ និង ***កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល*** (២) ការកៀរគរធនធានពីបរទេស ពីដៃគូអភិវឌ្ឍប្រពៃណី និងមិនមែនប្រពៃណី និង (៣) ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ***កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល*** ទាមទារឲ្យមានការកែសម្រួល ដើម្បីធានាថា (ក) តម្រូវការចំណាយចរន្ត ដែលបានអនុវត្តសម្រាប់ថវិកាប្រចាំឆ្នាំ គឺជាផ្នែកទាំងមូលនៃព័ត៌មានដែលបានប្រមូលនៅក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ (ខ) គម្រោងនានាដែលបានបញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈចាំបាច់ត្រូវធ្វើអាទិភាវូបនីយកម្ម។ បញ្ហានេះទាមទារឲ្យក្រសួង ស្ថាប័ននានាធ្វើការកំណត់កម្រិតអាទិភាពលើគម្រោង ដែលបានគ្រោងឡើងសម្រាប់អនុវត្តក្នុងរយៈពេលបីឆ្នាំបន្ទាប់ដោយផ្តោតការយកចិត្តទុកដាក់លើបរិស្ថានម៉ាក្រូសេដ្ឋកិច្ចជារួម និងការយល់ដឹងពីទំហំនៃការកៀរគរធនធានពីបរទេសដោយផ្អែកលើនិន្នាការដែលបានកើតឡើងថ្មីៗ។

**៣.៦៦-** រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ក្នុងការបន្តពង្រឹងដំណើរការរៀបចំ ***កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល*** ។ ដោយហេតុថា កម្មវិធីវិនិយោគសាធារណៈត្រូវបានធ្វើឲ្យប្រសើរឡើង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធានាថា មានតែកម្មវិធីនិងគម្រោងដែលបានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈទេ ដែលត្រូវបានពិចារណាសម្រាប់ផ្តល់ហិរញ្ញប្បទាននៅក្នុងដំណាក់កាលនៃការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា។ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងធានាថា នៅក្នុងសកម្មភាពកៀរគរធនធាន **គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា**នឹងជំរុញសកម្មភាពផ្តល់ហិរញ្ញប្បទានដល់គម្រោងនានារបស់កម្មវិធីវិនិយោគសាធារណៈ និងរៀបចំរបាយការណ៍ជាប្រចាំស្តីពីកម្មវិធីវិនិយោគសាធារណៈដែលត្រូវបានគាំទ្រដោយដៃគូអភិវឌ្ឍពីក្រៅប្រទេស ក៏ដូចជាពីគម្រោងនានាដែលគាំទ្រដោយដៃគូអភិវឌ្ឍក្រៅប្រទេស តែពុំមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ។

**៣.៦៧-** ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់តម្លាភាពនៃដំណើរការរៀបចំថវិកា ក្រសួងផែនការបានរៀបចំព្យាករដំបូងនូវការបែងចែកចំណាយចរន្តសម្រាប់ ក្រសួង ស្ថាប័នសម្រាប់**ផ.យ.អ.ជ. ២០១៤-២០១៨**។ ការព្យាករដំបូងនេះមានបង្ហាញជូននៅក្នុងតារាងទី៣.៤។

## តារាងទី៣.៤ : ចំណាយថវិកាចរន្តដែលបានស្នើឡើង សម្រាប់ក្រសួង ស្ថាប័ន មួយចំនួន ឆ្នាំ២០១៤ដល់២០១៨

(គិតជាលានរៀល)

| ក្រសួង ស្ថាប័ន | ២០១៤ ប៉ាន់ស្មាន | ២០១៥ ព្យាករណ៍ | ២០១៦ ព្យាករណ៍ | ២០១៧ ព្យាករណ៍ | ២០១៨ ព្យាករណ៍ |
|---|---|---|---|---|---|
| **I. រដ្ឋបាលទូទៅ** | **១ ៤៣៥ ៧៣២** | **១ ៥៤៤ ៣៨១** | **១ ៦៥៧ ២៦៥** | **១ ៧៧៨ ៤៧៧** | **១ ៩០០ ៦២១** |
| ០១. ព្រះរាជវាំង | ៧១ ៨៥៦ | ៧៧ ០៧៧ | ៨២ ៤៥៦ | ៨៨ ១៨៧ | ៩៣ ៨៨៨ |
| ០២. រដ្ឋសភា | ១៤១ ៣១៥ | ១៥១ ៥៨២ | ១៦២ ១៦០ | ១៧៣ ៤៣១ | ១៨៤ ៦៤៤ |
| ០៣. ព្រឹទ្ធសភា | ៥៧ ៧៤៤ | ៦១ ៩៤០ | ៦៦ ២៦២ | ៧០ ៨៦៧ | ៧៥ ៤៤៩ |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | ៩ ៧៦៣ | ១០ ៤៧៣ | ១១ ២០៤ | ១១ ៩៨២ | ១២ ៧៥៧ |
| ០៥.១ ទីស្តីការគណៈរដ្ឋមន្ត្រី | ៣០៣ ៤២៥ | ៣២៥ ៤៧១ | ៣៤៨ ១៨៤ | ៣៧២ ៣៨៣ | ៣៩៦ ៤៦០ |
| ០៥.២ ក្រសួងមុខងារសាធារណៈ | ៤ ៨៥៥ | ៥ ២០៨ | ៥ ៥៧១ | ៥ ៩០៨ | ៦ ៣៤៤ |
| ០៥.៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ៧ ៨២៧ | ៨ ៣៩៦ | ៨ ៩៨២ | ៩ ៦០៦ | ១០ ២២៧ |
| ០៧.២ មហាផ្ទៃ - រដ្ឋបាល | ៨៨ ៧៩២ | ៩៥ ២៤៣ | ១០១ ៨៩០ | ១០៨ ៩៧១ | ១១៦ ០១៧ |
| ០៨. ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ២៤ ០៩២ | ២៥ ៨៤២ | ២៧ ៦៤៦ | ២៩ ៥៦៧ | ៣១ ៤៧៩ |
| ០៩. ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១០០ ២៨០ | ១០៧ ៥៦៦ | ១១៥ ០៧២ | ១២៣ ០៧០ | ១៣១ ០២៧ |
| ១០. សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២៩១ ០០១ | ៣១២ ១៤៤ | ៣៣៣ ៩២៧ | ៣៥៧ ១៣៥ | ៣៨០ ២២៦ |
| ១៤.ផែនការ | ៤៦ ២០៧ | ៤៩៥៦៤ | ៥៣ ០២៣ | ៥៦ ៧០៨ | ៦០ ៣៧៥ |
| ២៦. យុត្តិធម៌ | ៥៩ ១១៣ | ៦៧ ៧៤១ | ៧៧ ៥៧៧ | ៨៩ ០០១ | ១០១ ៩០៩ |
| ៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ៥៣ ០១៨ | ៥៦ ៨៧០ | ៦០ ៨៣៩ | ៦៥ ០៦៧ | ៦៩ ២៧៤ |
| ៣១. អាជ្ញាធរសេនវកម្មជាតិ | ១០ ២៥០ | ១០ ៩៩៤ | ១១ ៧៦១ | ១២ ៥៧៩ | ១៣ ៣៩២ |
| ៣២. ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៣២ ៣៣២ | ១៤១ ៩៤៧ | ១៥១ ៨៥៣ | ១៦២ ៤០៦ | ១៧២ ៩០៧ |
| ៣៣. គណៈកម្មាធិការប្រឆាំងអំពើពុករលួយកម្ពុជា | ៣៣ ៨៦២ | ៣៦ ៣២២ | ៣៨ ៨៥៧ | ៤១ ៥៥៨ | ៤៤ ២៤៥ |
| **II. ការពារជាតិនិងសន្តិសុខ** | **១ ៧៦៦ ២២៧** | **១ ៨៩៤ ៥៥៦** | **២ ០២៦ ៧៦៧** | **២ ១៦៧ ៦២៨** | **២ ៣០៧ ៧៨០** |
| ០៦. ការពារជាតិ | ១ ០៣៦ ៥០៦ | ១ ១១១ ៨១៥ | ១ ១៨៩ ៤០៣ | ១ ២៧២ ០៦៧ | ១ ៣៥៤ ៣១៥ |
| ០៧.១ មហាផ្ទៃ -សន្តិសុខ | ៧២៩ ៧២១ | ៧៨២ ៧៤១ | ៨៣៧ ៣៦៤ | ៨៩៥ ៥៦១ | ៩៥៣ ៤៦៥ |
| **III. រដ្ឋបាលសង្គម** | **៣ ១១៤ ៧៧៣** | **៣ ៥២៩ ៣៥៣** | **៣ ៩៩៨ ៣១៩** | **៤ ៥៣៩ ៩០៨** | **៥ ១៤៧ ០១៦** |
| ១១. ព័ត៌មាន | ៩១ ៧៣២ | ៩៨ ៣៩៧ | ១០៥ ២៦៤ | ១១២ ៥៨០ | ១១៩ ៨៥៧ |
| ១២. សុខភាពសាធារណៈ | ១ ០៤៥ ៦៦៥ | ១ ១៩៨ ២៨៦ | ១ ៣៧២ ២៨៩ | ១ ៥៧៤ ៣៦៨ | ១ ៨០២ ៦៩៦ |
| ១៦. អប់រំ យុវជន និងកីឡា | ១ ៣០៩ ៨៣៩ | ១ ៥១៤ ០០៨ | ១ ៧៤៨ ៨៦១ | ២ ០២៣ ៧៥៦ | ២ ៣៣៧ ៣១២ |
| ១៨. វប្បធម៌និងវិចិត្រសិល្បៈ | ៥៣ ១៨៣ | ៥៧ ០៤៧ | ៦១ ០២៨ | ៦៥ ២៦៩ | ៦៩ ៤៨៩ |
| ១៩. បរិស្ថាន | ៣៤ ៥៤៧ | ៣៧ ០៥៧ | ៣៩ ៦៤៣ | ៤២ ៣៩៨ | ៤៥ ១៣៩ |
| ២១. សង្គមកិច្ចនិងអតីតយុទ្ធជន | ៥០៦ ៤១៧ | ៥៤៣ ២១២ | ៥៨១ ១១៩ | ៦២១ ៥០៨ | ៦៦១ ៦៩២ |
| ២៣. ធម្មការនិងសាសនា | ៣៧ ៦០៦ | ៤០ ៣៣៨ | ៤៣ ១៥៣ | ៤៦ ១៥២ | ៤៩ ១៣៦ |

| ក្រសួង ស្ថាប័ន | ២០១៤ ប៉ាន់ស្មាន | ២០១៥ ព្យាករណ៍ | ២០១៦ ព្យាករណ៍ | ២០១៧ ព្យាករណ៍ | ២០១៨ ព្យាករណ៍ |
|---|---|---|---|---|---|
| ២៤. កិច្ចការនារី | ៣៥ ៧៨៥ | ៤១ ០០៨ | ៤៦ ៩៦២ | ៥៣ ៨៧៨ | ៦១ ៦៩២ |
| IV. រដ្ឋបាលសេដ្ឋកិច្ច | ៧០៩ ២៨០ | ៧៨៧ ១៩៩ | ៨៧៣ ២៤៦ | ៩៧០ ៦៦៩ | ១ ០៧៦ ៩៨៧ |
| ០៥.៣ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | ២២ ៥០៧ | ២៤ ១៤២ | ២៥ ៨២៧ | ២៧ ៦២១ | ២៩ ៤០៧ |
| ១៣. ឧស្សាហកម្មនិងសិប្បកម្ម រ៉ែនិងថាមពល | ២៧ ២៦៧ | ២៩ ២៤៨ | ៣១ ២៨៩ | ៣៣ ៤៦៤ | ៣៥ ៦២៨ |
| ១៥. ពាណិជ្ជកម្ម | ៩៤ ០០៤ | ១០០ ៨៣៤ | ១០៧ ៨៧០ | ១១៥ ៣៦៧ | ១២២ ៨២៦ |
| ១៧. កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៤០ ៥៧១ | ១៦១ ០៨៩ | ១៨៤ ៤៨០ | ២១១ ៦៤៦ | ២៤២ ៣៤១ |
| ២០. អភិវឌ្ឍន៍ជនបទ | ១២៦ ៧៥៩ | ១៤៥ ២៦០ | ១៦៦ ៣៥៣ | ១៩០ ៨៥០ | ២១៨ ៥២៨ |
| ២២. ប្រៃសណីយ៍និងទូរគមនាគមន៍ | ២៧ ៣១៦ | ២៩ ៣០០ | ៣១ ៣៤៥ | ៣៣ ៥២៤ | ៣៥ ៦៩១ |
| ២៥. សាធារណការនិងដឹកជញ្ជូន | ៥៩ ០៥៥ | ៦៣ ៣៤៥ | ៦៧ ៧៦៦ | ៧២ ៤៧៦ | ៧៧ ១៦២ |
| ២៧. ទេសចរណ៍ | ៤៧ ៨១០ | ៥១ ២៨៣ | ៥៤ ៨៦២ | ៥៨ ៦៧៥ | ៦២ ៤៦៩ |
| ២៨. នគរូបនីយកម្មនិងសំណង់ | ៩២ ៦២៨ | ១០៦ ១៤៨ | ១២១ ៥៦២ | ១៣៩ ៤៦២ | ១៥៩ ៦៨៩ |
| ២៩. ធនធានទឹកនិងឧតុនិយម | ៧១ ៣៦៥ | ៧៦ ៥៥០ | ៨១ ៨៩២ | ៨៧ ៥៨៣ | ៩៣ ២៤៦ |
| V. ចំណាយផ្សេងៗ | ១ ១៧១ ៤២៦ | ១ ២០០ ៧២៨ | ១ ២៨៤ ៥២១ | ១ ៣៧៣ ៧៩៦ | ១ ៤៦២ ៦២១ |
| សរុប | ៨ ១៩៧ ៤៣៩ | ៨ ៩៥៦ ២១៨ | ៩ ៨៤០ ១១៨ | ១០ ៨៣០ ៤៧៨ | ១១ ៨៩៥ ០២៥ |

# ជំពូកទី៤
# គោលនយោបាយ
# និង
# សកម្មភាពអាទិភាព
# ២០១៤-២០១៨

# ជំពូកទី៤

# គោលនយោបាយនិងសកម្មភាពអាទិភាព ២០១៤-២០១៨

៤.១- ទិសដៅរួមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងនូវសង្គមកម្ពុជាមួយ ដែលរឹងមាំមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមមានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិកាផ្សារភ្ជាប់គ្នានឹងត្រូវបានពង្រឹងដើម្បីធានាថាប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់ និងមានសុខភាពល្អ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងរង្វង់គ្រួសារ និងក្នុងសង្គមជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា នឹងប្តេជ្ញាខិតខំយ៉ាងពេញទំហឹង ដើម្បីថែរក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមសម្រាប់លើកកម្ពស់ការអនុវត្តច្បាប់ និង ការគោរពសិទ្ធមនុស្ស សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ គោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស មានកំណើនសេដ្ឋកិច្ចរយៈពេលវែង និងគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

៤.២- ដោយផ្អែកលើបទពិសោធ និងលទ្ធផលសម្រេចបានក្នុងនីតិកាលទី៤ និង “**កម្មវិធីនយោបាយ**” សម្រាប់នីតិកាលទី៥របស់ខ្លួន រាជរដ្ឋាភិបាលយល់ឃើញថា យុទ្ធសាស្ត្រចតុកោណ ជាពិសេស គោលដៅសម្រាប់ **កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព**នៅតែចាំបាច់ និងសមស្របសម្រាប់កម្ពុជាបន្តអនុវត្តនៅក្នុងនីតិកាលទី៥(២០១៣-២០១៨)ទៀត ដោយរក្សាទុកនូវចតុកោណទាំងបួនឲ្យនៅដដែល ប៉ុន្តែពង្រីកវិសាលភាព សម្រិតសម្រាំង ធ្វើអាទិភាវូបនីយកម្មមុំ ព្រមទាំងកែលម្អគោលនយោបាយ និងយន្តការមួយចំនួនឲ្យកាន់តែសុក្រឹតឡើងថែមទៀត។ “**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**” បានបញ្ជាក់ច្បាស់អំពីបេសកកម្មនិងការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលក្នុងការធានាចីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជននិងបរិការណ៍ថ្មីៗ ទាំងកម្រិតជាតិ ទាំងកម្រិតអន្តរជាតិ។ ក្នុងន័យនេះ “**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា**” និង “**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**” រួមជាមួយគ្នា គឺជាឯកសារក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំ “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**” ដោយកំណត់សូចនាករ និងពេលវេលាច្បាស់លាស់សម្រាប់អនុវត្តដែលមានសង្គតិភាពជាមួយនឹងឯកសារគោលនយោបាយតាមវិស័យដទៃទៀតរបស់រាជរដ្ឋាភិបាល។ ដូច្នេះ “**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**” គឺជាឯកសារមគ្គុទ្ទេសក៍ច្បាស់លាស់សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្តនិងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាព សម្រាប់

រយៈពេលវែងសំដៅ ***ជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផលនៃកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ និងធានាឲ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទ។***

៤.៣- ក្នុងខ្លឹមសារនេះ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** គឺជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា។

៤.៤- ដូចមានចែងនៅក្នុងជំពូកទី១ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** មានទម្រង់ប្រហាក់ប្រហែលនឹង**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** ដែរ និងបានបន្ថែមអាទិភាពជាច្រើន ដូចជាពិពិធភាវូបនីយកម្មកសិកម្មនិងការចិញ្ចឹមសត្វ ការអភិវឌ្ឍទីផ្សារការងារ ឧស្សាហូបនីយកម្ម មូលធនមនុស្ស ការគ្រប់ធនធានធម្មជាតិ ជាដើម។ ទាំងនេះនឹងជំរុញដោយមានភាពប្រុងប្រយ័ត្នខ្ពស់ឲ្យសេដ្ឋកិច្ចកម្ពុជាធ្វើសមាហរណកម្មដោយជោគជ័យទៅក្នុងអាស៊ាន និងធ្វើឲ្យកម្ពុជានឹងមិនពឹងពាក់ជាខ្លាំងលើហិរញ្ញប្បទាន។

៤.៥- បញ្ហាអន្តរវិស័យសំខាន់ៗនៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៤-២០១៨** នេះ គឺ យេនឌ័រ បរិស្ថាន ធនធានធម្មជាតិ និងកំណើនបៃតង គ្រប់គ្រងគ្រោះមហន្តរាយ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **ផ.យ.អ.ជ. ២០១៤-២០១៨** បញ្ជាក់ពីតម្រូវការចាំបាច់ដែលក្រសួង ស្ថាប័ន តាមវិស័យទាំងអស់ ត្រូវពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហការជិតស្និទ្ធរបស់ខ្លួនសម្រាប់ការអនុវត្តទាំងនៅថ្នាក់ជាតិទាំងនៅថ្នាក់ក្រោមជាតិ។

៤.៦- **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** គឺជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ដោយបានសម្រិតសម្រាំង និងសម្រួចនូវគោលនយោបាយអាទិភាព ឲ្យមានភាពមុតស្រួចបន្ថែមទៀត ដើម្បីជម្នះបាននូវលក្ខខណ្ឌនាពេលបច្ចុប្បន្ន។ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនានារបស់រាជរដ្ឋាភិបាលកម្ពុជា **យុទ្ធសាស្ត្រចតុកោណ** បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ៤យ៉ាង ដែលស្តែងចេញតាមរយៈបាវចនា **កំណើន ការងារ សមធម៌** និង**ប្រសិទ្ធភាព** ដូចខាងក្រោម៖

*ទី១* ធានាឲ្យបាននូវកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឲ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបាន អត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ។

*ទី២* បង្កើតការងារឲ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ពិសេស សម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អនិងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការទាក់ទាញ និងការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគ ទាំងការវិនិយោគក្នុងប្រទេស ទាំងការវិនិយោគមកពីក្រៅប្រទេស។

*ទី៣* សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១% ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

*ទី៤* បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង។

៤.៧- បន្ថែមពីលើនេះ នៅមានកត្តាជាក់ស្តែងមួយចំនួនទៀត ដែលកំណត់ពីភាពចាំបាច់ក្នុងការបន្តអនុវត្ត "**យុទ្ធសាស្ត្រចតុកោណ**" ដូចជា៖

ទី១ ភាពចាំបាច់ក្នុងការបន្តពង្រីកនិងពង្រឹងសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន តាមរយៈការអនុវត្ត**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** ក្នុងនីតិកាលទី៤នៃរដ្ឋសភាកន្លងមក។

ទី២ ដូចបានរំលេចខាងលើការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** ក្នុងនីតិកាលទី៤នៃរដ្ឋសភាកន្លងមក បានបង្ហាញឲ្យឃើញនូវបញ្ហាប្រឈមនិងកាលានុវត្តភាពសំខាន់ៗមួយចំនួន ដែលទាមទារឲ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំង សម្រួចឲ្យមុតស្រួចបន្ថែមទៀតនិងពង្រឹងអាទិភាពគោលនយោបាយរបស់ខ្លួន ហើយជំរុញការអនុវត្តនូវរបៀបវារៈគោលនយោបាយនេះនៅក្នុងដំណាក់កាលបន្ទាប់ទៀត។

ទី៣ ការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** គឺជាជំហាននាំឆ្ពោះទៅមុខរបស់កម្ពុជា ដើម្បីឈានឡើងទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ពោលគឺការឆ្លងកាត់ពីឋានៈនៃប្រទេសមានចំណូលទាប ទៅប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយបន្ថែមលើនេះ បន្តរៀបចំកសាងមូលដ្ឋានគ្រឹះ សម្រាប់ការសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ពិសេសគឺមហិច្ឆតាក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ទី៤ ឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជា ដែលជាម្ចាស់ឆ្នោត និងរួមទាំងការប្រែប្រួលនៃពិភពលោក និងក្នុងប្រទេស គឺជាកត្តាកំណត់សំខាន់ថ្មីបន្ថែមទៀត ដែលទាម

ទារឲ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំង សម្រួចឲ្យមុតស្រួចបន្ថែមទៀតនូវ**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** និងជំរុញអនុវត្តនៅក្នុងដំណាក់កាលទី៣ឲ្យខ្លាំងក្លាថែមទៀត។

៤.៨- **ផ.យ.អ.ជ. ២០១៤-២០១៨** បង្ហាញដោយសង្ខេបនូវ គោលនយោបាយ យុទ្ធសាស្ត្រ ជាអាទិភាពសំខាន់ៗ រួមទាំងបញ្ជីសកម្មភាព កម្មវិធី និងគម្រោងនានា ដែលក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តនៅក្នុងនីតិកាលទី៥នៃរដ្ឋសភា។ នៅក្នុងជំពូកទី៤នេះ គោលនយោបាយ យុទ្ធសាស្ត្រ ជាអាទិភាពសំខាន់ៗដែលក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្ត គឺត្រូវបានរៀបចំទៅតាមទម្រង់នៃ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**។ ចំពោះសមាសភាគ និងសមាសភាគរងនីមួយៗរបស់**យុទ្ធសាស្ត្រចតុកោណ** នេះត្រូវបានរៀបចំតាមរយៈការដាក់ចេញនូវ ***ទី១: គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់វិស័យជាក់លាក់នីមួយៗ និង ទី២: សកម្មភាព កម្មវិធី និងគម្រោងនានា ដែលបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលយកដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងអស់នេះ***។

## ១- អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

៤.៩- សម្រាប់នីតិកាលទី៥នៃរដ្ឋសភា អភិបាលកិច្ចល្អនៅតែជាស្នូលនៃយុត្តិធម៌សង្គម និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។ ដើម្បីពង្រឹងអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តកំណែទម្រង់ដោយឥតរាថយ ក្នុងវិស័យសំខាន់ៗ រួមមាន (១) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២)កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (៣)កំណែទម្រង់រដ្ឋបាលសាធារណៈ និង(៤) កំណែទម្រង់ប្រដាប់អាវុធ។ ទិសដៅសំខាន់បំផុតនៃកំណែទម្រង់ទាំងនេះ រួមជាមួយនឹងកំណែទម្រង់ដទៃទៀតដូចជា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ដីធ្លី កំណែទម្រង់ព្រៃឈើ និងកំណែទម្រង់ជលផល គឺដើម្បីពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពការងារ និងពង្រឹងគុណភាពនៃសេវាសាធារណៈឲ្យកាន់តែប្រសើរឡើង ដើម្បីបង្កើនជំនឿទុកចិត្តនិងឆ្លើយតបទៅនឹងសេចក្តីត្រូវការនិងបំណងប្រាថ្នារបស់ប្រជាជននិងសហគមន៍ធុរកិច្ច។

### ១.១- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

#### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៥

៤.១០- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅតែជារបៀបវារៈអាទិភាពខ្ពស់នៃបញ្ជីរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជា នៅតែប្តេជ្ញាចិត្តយ៉ាងមោះមុតឥតរាថយ ដើម្បីរៀបចំនិងជំរុញអនុម័តច្បាប់នេះ ដែលមាន

សង្គតិភាពជាមួយនឹងច្បាប់គោលដទៃទៀតជាមូលដ្ឋាន សំដៅធានាបាននូវភាពរលូន និង សង្គតិភាពក្នុងចំណោមច្បាប់ផ្សេងៗ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយបន្តកិច្ចសហការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធ។ ការជំរុញអនុម័តច្បាប់គោលដទៃទៀតជាមូលដ្ឋាន នឹងនៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា។

៤.១១- ដើម្បីបន្តការងារប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលកម្ពុជានឹងពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃវិធានការស្នូលទាំងបី ដូចខាងក្រោម៖

- **ការពង្រឹងការអប់រំមិនឲ្យប្រព្រឹត្តអំពើពុករលួយ** រាជរដ្ឋាភិបាលបន្តជំរុញការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ តាមគ្រប់រូបភាព ទាំងក្នុងវិស័យសាធារណៈទាំងក្នុងវិស័យឯកជនឲ្យកាន់តែទូលំទូលាយថែមទៀត ដើម្បីឲ្យម្នាក់ៗមិនចង់ប្រព្រឹត្តអំពើពុករលួយ។ ការផ្សព្វផ្សាយនេះធ្វើឡើងតាមគ្រប់មធ្យោបាយ ដូចជាការចុះទៅដល់ទីកន្លែងផ្ទាល់ ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន វិទ្យុ ទូរទស្សន៍ជាដើម។ ជាងនេះទៅទៀត ការប្រារព្ធទិវាជាតិប្រឆាំងអំពើពុករលួយរៀងរាល់ឆ្នាំនៅថ្ងៃទី០៩ ខែធ្នូ ដើម្បីឲ្យប្រជាពលរដ្ឋយល់ដឹងពីផលលំបាកនៃអំពើពុករលួយ។ ការយល់ដឹងជ្រួតជ្រាបអំពីច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយនៅគ្រឹះស្ថានសិក្សាពីកម្រិតវិទ្យាល័យ ដល់ឧត្តមសិក្សា និងការសហការរវាងអង្គភាពប្រឆាំងអំពើពុករលួយនិងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំខ្លឹមសារប្រឆាំងអំពើពុករលួយដាក់ក្នុងកម្មវិធីសិក្សាតាំងពីថ្នាក់តូចៗមក មានគោលបំណងតែមួយគត់ គឺចង់ឲ្យយុវជនដែលជាទំពាំងស្នងឬស្សីប្រកាន់ខ្ជាប់នូវគំនិតមិនចង់ប្រព្រឹត្តនិងស្អប់ខ្ពើមអំពើពុករលួយ។
- **ការបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ** រាជរដ្ឋាភិបាលតែងតែបន្តជំរុញឲ្យក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និងវិស័យឯកជន បង្កើនការរៀបចំវិធានផ្ទៃក្នុងបន្ថែមលើច្បាប់និងបទប្បញ្ញត្តិជាធរមាន ដូចជាការកសាងផែនការយុទ្ធសាស្រ្ត ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិផ្សេងៗទៀត ដើម្បីកសាងអង្គភាពស្អាតស្អំ និងជាគំរូក្នុងការគ្រប់គ្រងការងារឲ្យបានជោគជ័យ និងមានប្រសិទ្ធភាព។ យន្តការនេះជាការរារាំងឱកាសនៃការប្រព្រឹត្តអំពើពុករលួយ តាមរយៈការពង្រឹងក្រមសីលធម៌ គណនេយ្យភាព និងសមត្ថភាពស្ថាប័ន ដោយបញ្ចៀសទំនាស់ផលប្រយោជន៍ ដោយអនុវត្តនូវគោលការណ៍វិសមិតភាពមុខងារ ក្នុងការបំពេញមុខងារ និងតួនាទីរបស់ខ្លួន។ ជាពិសេស រាជរដ្ឋាភិបាលនឹងមានវិធានការចាំបាច់សម្រាប់ពង្រឹងការត្រួតពិនិត្យស្ថាប័ន និងលើកកម្ពស់ការគ្រប់គ្រងចំណូលនិងចំណាយសាធារណៈ និង ការកំណត់តម្លៃសេវានានា។

- **ការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការ** ដើម្បីឲ្យខ្លាចរអែង រាជរដ្ឋាភិបាលនឹងបន្តចាត់វិធានការម៉ឺងម៉ាត់ តឹងរ៉ឹង ចំពោះជនល្មើសនៃអំពើពុករលួយ ដោយពុំមានការលើកលែង។ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត រាជរដ្ឋាភិបាលបន្តពង្រឹងសមត្ថភាពរបស់ ***អង្គភាពប្រឆាំងអំពើពុករលួយ*** បន្ថែមទៀត ជាពិសេស សម្រាប់ការស៊ើបអង្កេតនិងការជំរុញការអនុវត្តច្បាប់របស់ក្រសួង ស្ថាប័ននិងអង្គភាពសាធារណៈឲ្យបានត្រឹមត្រូវល្អប្រសើរ។

## ខ- សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១២- ដើម្បីអនុវត្តបណ្តាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ទិសដៅរបស់ ***អង្គភាពប្រឆាំងអំពើពុករលួយ*** ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមមាន៖

- ពង្រឹងនិងបង្កើនល្បឿនការងារអប់រំនិងការងារផ្សព្វផ្សាយ ពីលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងអំពើពុករលួយ។
- ជំរុញលើកទឹកចិត្តមហាជនឲ្យចូលរួមក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។
- ជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងជនប្រព្រឹត្តអំពើពុករលួយ។

៤.១៣- ដើម្បីសម្រេចបានទិសដៅខាងលើ នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា ***អង្គភាពប្រឆាំងអំពើពុករលួយ*** នឹងអនុវត្តនូវបណ្តាយុទ្ធសាស្ត្ររួមគ្នា ដូចខាងក្រោម៖

- ការបង្ការទប់ស្កាត់ជាមុនៈ
  - ➢ បន្តជំរុញសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីរាល់ទិដ្ឋភាពនៃអំពើពុករលួយ រួមមាន មូលហេតុ ឥទ្ធិពល និងផលវិបាកដ៏គ្រោះថ្នាក់នៃអំពើពុករលួយ ដើម្បីបន្តលើកទឹកចិត្តសាធារណជនឲ្យចូលរួមក្នុងការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។
  - ➢ បន្តចាត់វិធានការជាក់ស្តែង ដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ឲ្យប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ សីលធម៌ស្អាតស្អំ និងអនុវត្តការងារប្រកបដោយមនសិការវិជ្ជាជីវៈ និងមានស្មារតីទទួលខុសត្រូវខ្ពស់។
- ការពង្រឹង គណនេយ្យភាព និងសមត្ថភាពស្ថាប័នៈ
  - ➢ ពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍បញ្ចៀសទំនាស់ផលប្រយោជន៍រវាងឯកជននិងសាធារណៈ។
  - ➢ បន្តកសាងនិងពង្រឹងសមត្ថភាពស្ថាប័ន រួមទាំងការងារអធិការកិច្ច ដើម្បីគ្រប់គ្រងនិងជំរុញការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព។
- ការគាំទ្រនិងការចូលរួមពីសាធារណជនៈ

- ➢ បន្តជំរុញលើកកម្ពស់ថែមទៀត និងការការពារសិទ្ធិសេរីភាពនៃការស្វែងរកការទទួលបាននិងការផ្សព្វផ្សាយក្នុងបណ្តាញព័ត៌មាននូវករណីពាក់ព័ន្ធនឹងអំពើពុករលួយ។ បន្តនិងពង្រីកការរៀបចំសិក្ខាសាលាថ្នាក់ជាតិនិងអន្តរជាតិស្តីពីការងារប្រឆាំងអំពើពុករលួយ ។
- ➢ បន្តកិច្ចសហប្រតិបត្តិការជាលក្ខណៈអន្តរជាតិក្នុងភាពជាដៃគូសំដៅទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

- ការចូលរួមពីវិស័យឯកជនៈ
  - ➢ បន្តរៀបចំនិងជំរុញការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់ការពារភាពសុចរិតនៃវិស័យឯកជន ដើម្បីបញ្ចៀសការឃុបឃិត និងធានាបាននូវការប្រកួតប្រជែងដោយស្មើភាពរវាងក្រុមហ៊ុនសហគ្រាសឯកជននានា ដោយធានាឲ្យបាននូវការប្រព្រឹត្តល្អត្រឹមត្រូវប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ក្នុងសកម្មភាពធុរកិច្ច។
  - ➢ ធានាតុល្យភាពរវាងសិទ្ធិនិងផលប្រយោជន៍ទាំងឡាយ ដែលមានចែងក្នុងកិច្ចសន្យារវាងភាគីរដ្ឋនិងវិស័យឯកជន។
- ការពង្រឹងការអនុវត្តច្បាប់ៈ
  - ➢ បន្តចាត់វិធានការច្បាប់យ៉ាងម៉ឺងម៉ាត់និងតឹងរ៉ឹង ចំពោះជនល្មើសដែលប្រព្រឹត្តអំពើពុករលួយដើម្បីកាត់បន្ថយអំពើពុករលួយនិងបង្កើនជំនឿទុកចិត្តពីសំណាក់សាធារណជន។

៤.១៤- ***ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច*** នឹងផ្តោតការយកចិត្តទុកដាក់លើការរួមចំណែកប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដោយពង្រឹងការងារអធិការកិច្ចរបស់ខ្លួនតាមរយៈកម្មវិធីអាទិភាពគន្លឹះចំនួន៥ គឺ *(១)*ការងារផ្សព្វផ្សាយច្បាប់ *(២)*ការងារអធិការកិច្ច *(៣)*ការងារតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ *(៤)*ការងារទទួលនិងដោះស្រាយពាក្យបណ្តឹង និង *(៥)*ការអភិវឌ្ឍស្ថាប័ន ការកសាងសមត្ថភាពមន្ត្រីរាជការ រួមទាំងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីអាទិភាពគន្លឹះសំខាន់ៗទាំង៥។

៤.១៥- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច*** នឹងផ្តោតលើសកម្មភាព ដូចខាងក្រោម៖

- **ការពង្រឹងវិស័យទំនាក់ទំនងជាមួយរដ្ឋសភានិងព្រឹទ្ធសភា៖** ក្រសួងបានបន្តកំណត់យក (១) *ការងារអប់រំសិក្សាផ្សព្វផ្សាយច្បាប់អាទិភាពទាំង១១ ទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ* រួមមាន ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាស់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រអមវេជ្ជ

សាស្ត្រនិងជំនួយវេជ្ជសាស្ត្រ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ (២)*ការងារទំនាក់ទំនងរាជរដ្ឋាភិបាលនិងរដ្ឋសភា ព្រឹទ្ធសភា* នឹងរៀបចំការងារវិភាគស្ថានភាព និងសិក្សាបឋមទៅលើច្បាប់អាទិភាពទាំង១១ខាងលើ ដើម្បីវាស់ស្ទង់កម្រិតយល់ដឹងនិងតម្រូវការច្បាប់របស់ប្រជាពលរដ្ឋតាមភូមិសាស្ត្រនីមួយៗ មុននឹងបើកយុទ្ធនាការផ្សព្វផ្សាយជាផ្លូវការ។ (៣)*ការងារនីតិកម្ម* បញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច និងសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីអធិការកិច្ច នីតិវិធីតាមដានការអនុវត្តច្បាប់ នីតិវិធីអង្កេតស្រាវជ្រាវពាក្យបណ្តឹង និងនីតិវិធីផ្សព្វផ្សាយច្បាប់។

- **ការពង្រឹងវិស័យអធិការកិច្ចៈ** ក្រសួងបានបន្តកំណត់យក (១)ការងារអធិការកិច្ចលើការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ អធិការកិច្ចលើចំណូល ចំណាយថវិកាជាតិ និងជំនួយអន្តរជាតិ និងអធិការកិច្ចលើការងារដឹកនាំ គ្រប់គ្រងនៅតាមក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈ (២)ការងារតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើវិស័យកសិកម្ម សាធារណការ អប់រំ សុខាភិបាល រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពាណិជ្ជកម្ម ឧស្សាហកម្ម គមនាគមន៍ និងវិស័យសង្គមកិច្ច (៣) ទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវពាក្យបណ្តឹងរបស់ប្រជាជនឲ្យបានទាន់ពេលវេលា និងឲ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន។
- **ការពង្រឹងស្ថាប័ននិងការអភិវឌ្ឍធនធានមនុស្សៈ** ដើម្បីសម្រេចនូវយុទ្ធសាស្ត្រនេះក្នុងរយៈពេល៥ឆ្នាំទៅមុខ ក្រសួងបានបន្តកំណត់យកសកម្មភាពចម្បងៗចំនួន៥ សម្រាប់អនុវត្ត (១)ចង្កោមសកម្មភាពការងាររដ្ឋបាល បុគ្គលិក ដែលរួមមាន ការងាររដ្ឋបាល បុគ្គលិក ពិធីការ ការងារអភិវឌ្ឍន៍ធនធានមនុស្ស និងការងារកំណែទម្រង់រដ្ឋបាល (២) ចង្កោមសកម្មភាពការងារហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ដែលគ្របដណ្តប់ដោយការងារហិរញ្ញកិច្ច ការងារផ្គត់ផ្គង់ ការងារគណនេយ្យ ការងារផែនការ និងការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ (៣)ចង្កោមសកម្មភាពការងារសហប្រតិបត្តិការអន្តរជាតិៈ បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសវៀតណាម ដែលបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរួចហើយ និងបន្តស្វែងរកដៃគូច្រើនថែមទៀត ដើម្បីផ្លាស់ប្តូរបទពិសោធការងារជំនាញនិងសហប្រតិបត្តិការក្នុងភាពជាដៃគូ (៤)ការងារសវនកម្ម បន្តជួយគ្រប់អង្គភាពចំណុះក្រសួងឲ្យបានសម្រេចនូវគោលបំណង និងការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់តាមរយៈការធ្វើសវនកម្មផ្ទៃក្នុង (៥)ការងារយេនឌ័រ បន្តលើកទឹកចិត្តនិងបញ្ជ្រាបសកម្មភាពរបស់ស្ត្រីឲ្យចូលជ្រៅទៅក្នុងគ្រប់សកម្មភាពការងាររបស់អង្គភាពចំណុះក្រសួង។

## ១.២- កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៥

៤.១៦- រាជរដ្ឋាភិបាលកម្ពុជា បានកែលម្អច្បាប់និងប្រព័ន្ធយុត្តិធម៌ ដោយផ្តោតជាសំខាន់លើការរៀបចំក្របខ័ណ្ឌច្បាប់ឲ្យបានរឹងមាំ និងការធ្វើទំនើបនីយកម្មច្បាប់ ព្រមទាំងដាក់ចេញនូវយុទ្ធសាស្ត្រនិងវិធានការចាំបាច់នានា ក្នុងគោលដៅពង្រឹងសមត្ថភាព ឯករាជ្យភាព និងអព្យាក្រឹតភាពនៃស្ថាប័នតុលាការ ដែលជាកត្តាសំខាន់សម្រាប់ការពង្រឹងនីតិរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីឈានទៅសម្រេចឲ្យបាននូវទិសដៅជាយុទ្ធសាស្ត្ររបស់ខ្លួន។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តរៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ និងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ ក្នុងគោលដៅបង្កើនការយល់ដឹងនិងការអនុវត្តឲ្យបានត្រឹមត្រូវ។

៤.១៧- ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តឲ្យកាន់តែសកម្មនិងកាន់តែស៊ីជម្រៅថែមទៀតនូវបណ្តាសកម្មភាពសំខាន់ៗ ស្របតាមកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ ដោយផ្តោតលើកម្មវិធីសកម្មភាព៖

- ទី១ ការបន្តជំរុញអនុម័តច្បាប់គោលសំខាន់ៗពាក់ព័ន្ធនឹងស្ថាប័នតុលាការ ជាអាទិ៍ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គការតុលាការនិងអង្គការតុលាការអយ្យការ ច្បាប់ស្តីពីវិសោធនកម្មស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ព្រមទាំងការកសាងច្បាប់ថ្មីៗតាមតម្រូវការចាំបាច់នៃការងារអភិបាលកិច្ច និងសម្រាប់ជាសមាជិកពេញសិទ្ធិនៃសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ និងកាតព្វកិច្ចរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក។
- ទី២ ការបន្តពង្រឹងសមត្ថភាព និងការទទួលខុសត្រូវក្នុងវិជ្ជាជីវៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា និងពង្រឹងឯករាជ្យភាពនៃអំណាចតុលាការ។
- ទី៣ ការជំរុញបង្កើតឲ្យមានរដ្ឋបាលតុលាការតាមសាលាជម្រះក្តីគ្រប់លំដាប់ថ្នាក់។
- ទី៤ ការបន្តផ្តល់មធ្យោបាយសមស្របដល់សាលាជម្រះក្តីសម្រាប់ ប្រតិបត្តិការអនុវត្តច្បាប់។
- ទី៥ ការបន្តអនុវត្តកម្មវិធីផ្សព្វផ្សាយនិងបណ្តុះបណ្តាលច្បាប់ឲ្យបានទូលំទូលាយថែមទៀត។
- ទី៦ ការបន្តសហការ និងជួយដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍តាមផ្លូវតុលាការ។
- ទី៧ ការបន្តជំរុញលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៨- ដើម្បីឈានទៅសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងយុត្តិធម៌*** មានទិសដៅអនុវត្តបន្តនូវការងារសំខាន់ៗដូចខាងក្រោម៖

- ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីឈានទៅសម្រេចឲ្យបាននូវទិសដៅយុទ្ធសាស្ត្រទាំង៧ គឺ៖
  - ➢ ពង្រឹងការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋាន។
  - ➢ ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់។
  - ➢ ផ្តល់លទ្ធភាពទទួលព័ត៌មានអំពីច្បាប់និងតុលាការឲ្យប្រសើរឡើង។
  - ➢ ធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃដំណើរការរឿងក្តីនិងសេវាពាក់ព័ន្ធ។
  - ➢ ពង្រឹងសេវាយុត្តិធម៌ រួមមានអំណាចតុលាការនិងសេវាផ្នែកអយ្យការ។
  - ➢ បន្តជំរុញលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
  - ➢ ពង្រឹងសមត្ថភាពស្ថាប័នវិស័យច្បាប់និងតុលាការឲ្យអាចបំពេញអាណត្តិរបស់ខ្លួនបានជោគជ័យ។
- ការលើកកម្ពស់ការយល់ដឹងអំពីច្បាប់
  - ➢ កសាងច្បាប់និងជំរុញការអនុម័តច្បាប់និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ
  - ➢ ពង្រឹងនិងពង្រីកការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិច្បាប់ជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងស្ត្រីនិងកុមារ និងការជួញដូរមនុស្សឲ្យបានទូលំទូលាយ។
  - ➢ ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យច្បាប់និងយុត្តិធម៌។
- ការលើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយរឿងក្តី
  - ➢ ពង្រីកការបណ្តុះបណ្តាលច្បាប់មូលដ្ឋាន បទប្បញ្ញត្តិច្បាប់ជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងស្ត្រីនិងកុមារ និងជំនាញផ្សេងៗដល់មន្ត្រីអនុវត្តច្បាប់ មន្ត្រីរាជការ និងអ្នកប្រកបវិជ្ជាជីវៈច្បាប់។
  - ➢ ពង្រឹងនិងពង្រីកសមត្ថភាពរបស់ចៅក្រមនិងព្រះរាជអាជ្ញា។
  - ➢ ពង្រឹងនិងពង្រីកយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
  - ➢ ពង្រឹងនិងពង្រីកការគ្រប់គ្រងបញ្ជីសំណុំរឿងក្តីតាមប្រព័ន្ធថ្មី (គម្រោងរបស់តុលាការគំរូ)។
  - ➢ បង្កើតឲ្យមានទិន្នន័យនៃការចុះបញ្ជីសំណុំរឿងក្តីទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា។
  - ➢ បង្កើនព័ត៌មានស្តីពីសិទ្ធិទទួលបានយុត្តិធម៌ រួមមានសេចក្តីសម្រេចរបស់តុលាការ (ដីកាកោះ ដីកាចាប់ខ្លួន) និងបណ្តឹងឥវ៉ា របាយការណ៍អាណត្តិរដ្ឋបាល និងព័ត៌មានរដ្ឋបាលចំពោះរឿងក្តីដែលកំពុងចាត់ការ រួមទាំងលក្ខន្តិកៈសំខាន់ៗនិងតារាងកម្មវិធី។
  - ➢ ពង្រឹងសមត្ថភាព និងលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យយុត្តិធម៌។

- ➢ ពង្រឹងនិងពង្រីកក្នុងការប្រើប្រាស់ជម្រើសវិធានផ្សេងៗមុនពេលសម្រេច ក្នុងការឃុំខ្លួន ជាពិសេស សម្រាប់កុមារ។
- ➢ ពង្រឹងសេវាកម្មជំនួយផ្នែកច្បាប់សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ជាពិសេសកុមារ។
- ➢ ពង្រឹងការតាមដាននិងត្រួតពិនិត្យការអនុវត្តច្បាប់។
- ➢ ពង្រឹងទំនាក់ទំនងរវាងអាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌កម្ពុជា និងអាជ្ញាធរកណ្តាលបរទេស។
- ➢ បង្កើនប្រសិទ្ធភាពនៃសេចក្តីសម្រេចរបស់យុត្តាធិការតុលាការ(ដែនដីនិងពេលវេលា) រួមទាំងការឃុំខ្លួនបណ្តោះអាសន្ន។

- ការលើកកម្ពស់សមត្ថភាពគ្រប់គ្រងស្ថាប័ន
  - ➢ បង្កើនសមត្ថភាពការងារគ្រប់គ្រងរួម និងពង្រឹងការអនុវត្តការងារគ្រប់គ្រងរួម។
  - ➢ ការលើកកម្ពស់សមត្ថភាពនិងពង្រឹងការងារគ្រប់គ្រងរួមដោយការប្រើប្រាស់ការចុះបញ្ជីតុលាការនិងបញ្ចូលទិន្នន័យរឿងក្តីព្រហ្មទណ្ឌគ្រប់ស្ថាប័នតុលាការ។
  - ➢ ពង្រីក និងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅក្រសួង និងនៅតាមសាលាជម្រះក្តី។
  - ➢ បង្កើនព័ត៌មានសិទ្ធិទទួលបានយុត្តិធម៌ រួមមានសេចក្តីសម្រេចរបស់តុលាការ បណ្តឹងត៉ាវ របាយការណ៍អាណត្តិរដ្ឋបាល និងព័ត៌មានរដ្ឋបាលចំពោះរឿងក្តីដែលកំពុងចាត់ការ រួមទាំងលក្ខខណ្ឌសំខាន់ៗនិងតារាងកម្មវិធី។
  - ➢ បង្កើនសេវាយុត្តិធម៌ ដោយការពង្រីករចនាសម្ព័ន្ធសាលាជម្រះក្តី រួមមាន សាលាឧទ្ធរណ៍តាមតំបន់ តុលាការជំនាញនៅតាមតុលាការជាន់ទាប និងសភាជំនាញនៅតាមតុលាការជាន់ខ្ពស់ និងបង្កើតឲ្យមានសាលាដំបូងនៅគ្រប់រាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។
  - ➢ ពង្រឹងនិងពង្រីកការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

## ១.៣- កំណែទម្រង់រដ្ឋបាលសាធារណៈ

## ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១៩- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងបន្តផ្តោតលើការអនុវត្ត **យុទ្ធសាស្ត្រទាំងបីនៃកម្មវិធីកំណែទម្រង់រដ្ឋបាល** ដូចខាងក្រោម៖

ទី១ ពង្រឹងគុណភាពនិងការផ្តល់សេវាសាធារណៈ តាមរយៈការបន្តអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ និងការអនុវត្តឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ ដើម្បីបង្កើនភាពឆ្លើយតប ជំនឿទុកចិត្តពីអ្នកប្រើប្រាស់សេវា និងប្រសិទ្ធភាពនិងប្រសិទ្ធផល។ ឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ កំណត់នូវសូចនាករគោលចំនួន៥ គឺ

(១)គុណភាពព័ត៌មាន (២)ភាពងាយស្រួលក្នុងការទទួលយកសេវា (៣)ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា (៤)សេវាផ្តល់តាមគោលការណ៍កំណត់និងមានអភិបាលកិច្ចល្អ និង (៥)យន្តការព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា។ ទន្ទឹមនឹងនេះ នឹងមានយន្តការសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តស្តង់ដាសេវាសាធារណៈនិងផ្តល់វិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈដែលសម្រេចតាមសូចនាករគោលរបស់ក្រសួង ស្ថាប័ន។

ទី២ ពង្រឹងការការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ តាមរយៈការអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈដើម្បីលើកកម្ពស់គុណផលរបស់មន្ត្រី និងជំរុញការប្រកាន់ខ្ជាប់នូវវប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការភក្តីភាព និងមនសិការវិជ្ជាជីវៈ។ គោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈផ្តោតលើយុទ្ធសាស្ត្រចំនួន៥ គឺ (១)ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធការងារក្នុងអង្គភាពនិងការគ្រប់គ្រងមន្ត្រី (២)ពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រងធនធានមនុស្ស (៣)អនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល (៤)ប្រើប្រាស់ឲ្យកាន់តែប្រសើរឡើងនូវសមត្ថភាពការងារដែលមានស្រាប់និងអភិវឌ្ឍសមត្ថភាពការងារថ្មី និង (៥)ផ្តល់ការបណ្តុះបណ្តាលនិងលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល។

ទី៣ បន្តការកែទម្រង់ប្រព័ន្ធបៀវត្សនិងប្រាក់បន្ថែមផ្សេងៗរបស់មន្ត្រីរាជការ។ ការកែទម្រង់នេះនឹងត្រូវដាក់ឲ្យអនុវត្តដោយឈរលើគោលការណ៍៖ (១)ការដំឡើងបៀវត្សស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ច និងលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ (២)ការធានាបាននូវសមធម៌ ការបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ និង (៣)ការធានាសង្គតិភាពរវាងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌកងកម្លាំងប្រដាប់អាវុធ។ រាជរដ្ឋាភិបាលបានបង្កើត និងកំពុងដំណើរការនូវក្រុមការងារទទួលបន្ទុកលើការងារកែទម្រង់ប្រព័ន្ធលាភការនិងគម្រោង ការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ។

យុទ្ធសាស្ត្រទាំងបីនេះមានភាពប្រទាក់ក្រឡាគ្នា ហើយនឹងត្រូវបានអនុវត្តដោយមានការសម្របសម្រួលជាមួយនឹងកំណែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល ដូចជា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដើម្បីសម្រេចបានទិសដៅរួម គឺលើកកម្ពស់អភិបាលកិច្ចល្អ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.២០- ដើម្បីសម្រេចនូវគោលនយោបាយអាទិភាពសំខាន់ទាំង៣ខាងលើ ***ក្រសួងមុខងារសាធារណៈ*** បាននិងកំពុងបន្តអនុវត្តសកម្មភាពការងារសំខាន់ៗដូចខាងក្រោម៖

**១- ពង្រឹងគុណភាពនិងការផ្តល់សេវាសាធារណៈ**

- បន្តផ្សព្វផ្សាយគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ។
- ធ្វើបច្ចុប្បន្នកម្ម បន្តផ្សព្វផ្សាយ និងតាមដានការអនុវត្តកម្រងព័ត៌មានសេវាសាធារណៈ។
- ផ្សព្វផ្សាយនិងជំរុញការអនុវត្តឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ។
- សម្របសម្រួលក្នុងការរៀបចំនិងអនុវត្តស្តង់ដាសេវាសាធារណៈដល់ក្រសួង ស្ថាប័ន។
- រៀបចំនិងអនុវត្តគម្រោងបណ្តុះបណ្តាលដល់អ្នកផ្តល់សេវា។
- ផ្តល់ការគាំទ្រដល់ការសម្រួលនីតិវិធីនិងដំណើរការនៃការផ្តល់សេវារបស់ក្រសួង ស្ថាប័ន។
- លើកទឹកចិត្តដល់ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការពង្រឹងការផ្តល់សេវាសាធារណៈ។
- សិក្សាស្រាវជ្រាវនិងបង្កើតយន្តការព័ត៌មានត្រឡប់និងបណ្តឹងត៌វារបស់អ្នកប្រើប្រាស់សេវា។
- សិក្សានិងបង្កើតយន្តការវាយតម្លៃ ទទួលស្គាល់ និងផ្តល់រង្វាន់ដល់ក្រសួង ស្ថាប័នដែលផ្តល់សេវាសាធារណៈបានល្អប្រសើរជាងគេ។
- ជំរុញការពង្រីកការអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេសនៅតាមក្រសួង ស្ថាប័ន។

**២- ពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស**

- ពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស។
- ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធការងារតាមរយៈការកំណត់ឲ្យកាន់តែច្បាស់អំពីតួនាទីនិងភារកិច្ចរបស់អង្គភាព និងតាមរយៈការប្រើប្រាស់ការពណ៌នាមុខតំណែង។
- ជំរុញការកែលម្អការធ្វើផែនការធនធានមនុស្ស ដោយជំរុញឲ្យមានការរៀបចំផែនការធនធានមនុស្សរយៈពេលមធ្យមនិងរយៈពេលវែង ដោយមានកំណត់អំពីចំនួនមន្ត្រីដែលត្រូវជ្រើសរើសថ្មី ការពង្រាយមន្ត្រី ការបណ្តុះបណ្តាល និងតម្រូវការនៃការបន្តវេនការងាររបស់មន្ត្រី។
- សម្រួលនីតិវិធីនៃការគ្រប់គ្រងធនធានមនុស្ស និងលើកកម្ពស់តម្លាភាពនិងផ្អែកលើលក្ខណសម្បត្តិស័ក្តិសមក្នុងដំណើរការគ្រប់គ្រងធនធានមនុស្ស។
- កសាងនិងជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និងភ្ជាប់ការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលជាមួយនឹងការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការពង្រាយមន្ត្រី លាភការរបស់មន្ត្រី ការបណ្តុះបណ្តាលនិងការអភិវឌ្ឍសមត្ថភាពការងាររបស់មន្ត្រី។
- ពង្រឹងការអនុវត្តក្រមសីលធម៌និងវិន័យរបស់មន្ត្រីរាជការស៊ីវិល។
- រៀបចំនិងដាក់ឲ្យអនុវត្តប្រវត្តិសមត្ថភាពការងារសម្រាប់មុខតំណែងសំខាន់ៗមួយចំនួន។

- អនុវត្តការវាយតម្លៃជាទៀងទាត់ដើម្បីកំណត់ពីការវិវឌ្ឍនៃសមត្ថភាពការងារ និងតម្រូវការសមត្ថភាពការងារ ព្រមទាំងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា។
- កសាងនិងអនុវត្តយន្តការជំរុញការបណ្តុះបណ្តាលផ្អែកលើតម្រូវការ។
- កសាងនិងអនុវត្តកម្មវិធីសិក្សាដើម្បីឆ្លើយតបនឹងជំនាញបច្ចេកទេស ជំនាញបុគ្គល និងជំនាញអន្តរបុគ្គលជាអាទិភាពនានា។
- ជំរុញការផ្តល់ការបណ្តុះបណ្តាលរយៈពេលខ្លីដល់មន្ត្រីថ្មីនិងអ្នកគ្រប់គ្រង។
- អភិវឌ្ឍសមត្ថភាពស្ថាប័នបណ្តុះបណ្តាលដើម្បីបន្តអនុវត្តការបណ្តុះបណ្តាលមន្ត្រីរាជការ ដោយរួមមានទាំងការបង្កើតវិទ្យាស្ថានជាតិសម្រាប់ការបណ្តុះបណ្តាលអន្តរវិស័យ ការបង្កើតលទ្ធភាពនៃការសិក្សាពីចម្ងាយសម្រាប់មន្ត្រីរាជការ និងការបង្កើតភាពជាដៃគូរវាងអ្នកបណ្តុះបណ្តាលកម្ពុជានិងអ្នកបណ្តុះបណ្តាលបរទេស។
- ជំរុញការអភិវឌ្ឍសមត្ថភាពរបស់អង្គភាពនិងមន្ត្រីក្នុងអង្គភាពធនធានមនុស្សបន្ថែមទៀត។

### ៣- ការកែទម្រង់ប្រព័ន្ធបៀវត្ស

- ពង្រីកការអនុវត្តការបើកបៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ។
- បង្កើនបៀវត្សមន្ត្រីរាជការជាបន្តបន្ទាប់ ដោយផ្អែកលើលទ្ធភាពថវិកាជាតិនិងរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។
- ពិនិត្យឡើងវិញនិងកែសម្រួលនូវសមាសធាតុបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការ។
- ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធក្របខ័ណ្ឌនិងបៀវត្សរបស់មន្ត្រីរាជការ។
- កាត់បន្ថយគម្លាតបៀវត្សខ្ពស់និងបៀវត្សទាបរបស់មន្ត្រីរាជការ។
- ពិនិត្យនិងរៀបចំប្រព័ន្ធបៀវត្សទូទៅដើម្បីធានានូវសង្គតិភាពនិងសមធម៌រវាងប្រព័ន្ធបៀវត្សរបស់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ។
- ពិនិត្យ និងរៀបចំប្រព័ន្ធបៀវត្សដើម្បីគាំទ្រដល់គុណផលរបស់មន្ត្រី។
- ពង្រឹងការគ្រប់គ្រងនិងអត្ថប្រយោជន៍ផ្សេងៗរបស់មន្ត្រីកិច្ចសន្យានិងពលករអណ្តែត។

## កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

៤.២១- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ តាមរយៈ *កម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩* ដោយផ្តោតការយកចិត្តទុកដាក់លើ៖

ទី១ ការបន្តពង្រឹងវិសាលភាពនៃការអនុវត្តការិយាល័យ ច្រកចេញ-ចូលតែមួយ ឲ្យមាននៅគ្រប់ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស និងការបន្តជំរុញការធ្វើប្រតិភូកម្មមុខងារឲ្យបានកាន់តែទូលំទូលាយថែមទៀត។

ទី២ ការពង្រឹងការអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសគឺការផ្ទេរជាជំហានៗនូវមុខងារនិងធនធានក្នុងវិស័យអាទិភាពនានាពីថ្នាក់ជាតិទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទី៣ ការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹង និងការកែលម្អប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការកំណត់ឲ្យបានច្បាស់លាស់នូវយន្តការតាមដានត្រួតពិនិត្យលទ្ធផល និងវាយតម្លៃនិងការត្រួតពិនិត្យនីត្យានុកូលភាព។

ទី៤ ការពង្រឹងប្រសិទ្ធភាពនៃរដ្ឋបាលឯកភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈការបន្តផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ននានា ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

៤.២២- ដើម្បីធានាដល់ការសម្រេចបាននូវគោលដៅ នៃគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ***គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)*** បានរៀបចំតាក់តែងនិងដាក់ឲ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការអនុវត្តកម្មវិធីជាតិ បានផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចការជាអាទិភាពនិងចំណុចដៅមួយចំនួនដូចខាងក្រោម៖

- មុខងារមួយចំនួនរបស់ក្រសួង ស្ថាប័ននានាដែលស្ថិតនៅក្នុងវិស័យអាទិភាពនឹងត្រូវបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយភ្ជាប់ជាមួយនូវធនធាន សិទ្ធិអំណាច តួនាទី និងសមត្ថភាពសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនោះ។
- ការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងយន្តការថ្មីៗ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបង្កើតឡើងដើម្បីពង្រីកការផ្តល់សេវាសាធារណៈ និងពង្រឹងគណនេយ្យភាពនៅមូលដ្ឋាន។
- រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានផ្តល់អំណាចកាន់តែច្រើនឡើងក្នុងការគ្រប់គ្រង និងការចាត់ចែងបុគ្គលិករបស់ខ្លួន ហើយស្ត្រីនឹងកាន់តែត្រូវបានលើកកម្ពស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- គណនេយ្យភាពខ្សែទទឹង និងខ្សែបណ្តោយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានលើកកម្ពស់ ហើយក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនឹងកាន់តែមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា។
- សមត្ថភាពផ្នែកស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានពង្រឹង។

## ១.៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

៤.២៣- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធសំដៅធ្វើទំនើបកម្ម និងបង្កើនសមត្ថភាពវិជ្ជាជីវៈនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីធានាបាននូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពខ្ពស់នូវអធិបតេយ្យភាព បូរណភាពទឹកដី សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

- ការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិតាមរយៈការបន្តអនុវត្ត***យុទ្ធសាស្ត្រ៣ សកម្មភាពប្រតិបត្តិការ និងការអភិវឌ្ឍ១០*** ព្រមទាំងធ្វើបច្ចុប្បន្នកម្មនិងជំរុញអនុវត្តផែនការយុទ្ធសាស្ត្រនគរបាលជាតិកម្ពុជា ក្នុងទិសដៅលើកកម្ពស់ប្រសិទ្ធិភាពនៃការបំពេញតួនាទីរបស់កម្លាំងប្រដាប់អាវុធពិសេសតាមរយៈការបង្កើតនិងការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា។
- ការអភិវឌ្ឍធនធានមនុស្សនិងការបង្កើនសមត្ថភាពកម្លាំងប្រដាប់អាវុធ តាមរយៈការធ្វើទំនើបកម្មនិងការបំពាក់បច្ចេកវិទ្យាសមស្រប ការបង្កើនគុណភាពហ្វឹកហ្វឺន ពិសេស ការបណ្តុះបណ្តាលយោធិនអាជីព ការកសាងជួរកងកម្លាំងប្រដាប់អាវុធវ័យក្មេងដើម្បីបន្តវេន និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត។
- ការពង្រឹងខ្សែរយៈចាត់តាំងក្នុងកងកម្លាំងប្រដាប់អាវុធ ពិសេសក្នុងជួរកងទ័ពនៅគ្រប់ថ្នាក់ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងកងកម្លាំង។
- ការផ្តល់សម្ភារៈបច្ចេកទេសគ្រប់ប្រភេទ និងការលើកកម្ពស់សុខុមាលភាពរបស់កងកម្លាំងប្រដាប់អាវុធ ពិសេស ការបង្កើនប្រសិទ្ធភាពក្នុងការផ្គត់ផ្គង់និងការគ្រប់គ្រងភស្តុភារ និងហិរញ្ញវត្ថុ ពិសេស សម្រាប់បណ្តាកងឯកភាពដែលឈរជើងនាខ្សែត្រៀមជួរមុខនិងកងការពារដែនកោះ។
- ការបន្តផ្តល់ការយកចិត្តទុកដាក់ដល់អតីតយុទ្ធជន យោធិនពិការ គ្រួសារយោធិនពលីមរណៈ និងគ្រួសារនៃកងកម្លាំងប្រដាប់អាវុធ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេស តាមរយៈការបន្តផ្តល់និងការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសម្បទាន

ដីសង្គមកិច្ច និងគម្រោងអភិវឌ្ឍន៍សម្រាប់សហគមន៍នៃគ្រួសារកងកម្លាំងប្រដាប់អាវុធនៅតាមព្រំដែន។

- ការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងរវាងកងកម្លាំងប្រដាប់អាវុធជាមួយនិងក្រសួង ស្ថាប័ន ព្រមទាំងបន្តពង្រឹងប្រពៃណីនៃទំនាក់ទំនងស្អិតល្មួតរវាងកងកម្លាំងប្រដាប់អាវុធនិងប្រជាជន ជាពិសេស តាមរយៈការធ្វើអន្តរាគមន៍ក្នុងពេលមានគ្រោះធម្មជាតិ ការបំពេញប្រតិបត្តិការមនុស្សធម៌ និងការជួយបង្កបង្កើនផលកសិកម្ម ព្រមទាំងការរួមចំណែកកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ។
- ការពង្រឹងនិងពង្រីកទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ លើគ្រប់ផ្នែករួមទាំងការបន្តចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិផងដែរ។
- ការអភិវឌ្ឍធនធានមនុស្សក្នុងកងយោធពលខេមរភូមិន្ទលើជំនាញអាជីព វិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្មខ្នាតតូចនិងមធ្យម រ៉ែ ព្រមទាំងព័ត៌មានវិទ្យា ដើម្បីឲ្យអង្គភាពទ័ពនិងសហគមន៍កងទ័ពអាចរកចំណូលទ្រទ្រង់ខ្លួនបាន និងលើកកម្ពស់សុខុមាលភាពកងទ័ព។ ក្នុងការងារកសាងសមត្ថភាពយោធិនក្នុងជំនាញខាងលើ កងយោធពលខេមរភូមិន្ទនឹងផ្តោតការយកចិត្តទុកដាក់លើផ្នែកសំខាន់ៗក្នុងវិស័យនីមួយៗដូចជា ការដាំដុះដំណាំកសិកម្ម និងកសិឧស្សាហកម្ម ការចិញ្ចឹមសត្វ ជំនាញអាជីពចិញ្ចឹមជីវិតដែលអាចបង្កើតរបរដោយខ្លួនឯង ការងារកែច្នៃកសិផល និងគ្រឿងបរិក្ខារប្រើប្រាស់ប្រចាំថ្ងៃ ។ល។
- លើកកម្ពស់សមភាពយេនឌ័រក្នុងកងយោធពលខេមរភូមិន្ទ ដោយជំរុញឲ្យមានកំណើនយោធិនស្ត្រីក្នុងថ្នាក់ដឹកនាំអង្គភាព និងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តសមស្របនានាក្នុងកងយោធពលខេមរភូមិន្ទ។
- បង្កើតដៃគូវិនិយោគអភិវឌ្ឍន៍លើវិស័យកសិកម្ម និងឧស្សាហកម្មកែច្នៃលើធនធានរូបវន្តពិសេស ដីធ្លីរបស់សហគមន៍កងទ័ព ដើម្បីបង្កើនប្រសិទ្ធភាពប្រើប្រាស់ធនធានរបស់កងយោធពលខេមរភូមិន្ទ និងលើកកម្ពស់ជីវភាពកងទ័ពតាមរយៈការបង្កើតការងារ និងមុខរបរសម្រាប់សហគមន៍កងទ័ពក្នុងតំបន់អភិវឌ្ឍ។ ការអភិវឌ្ឍគម្រោងវិនិយោគបៃតងពិសេសវិស័យថាមពលតាមសហគមន៍កងទ័ព ដើម្បីជួយសម្រួលដល់ការងារអភិវឌ្ឍនានារបស់សហគមន៍។ គម្រោងវិនិយោគបៃតងទាំងនោះ មានជាអាទិ៍ ថាមពលជីវម៉ាស ថាមពលពន្លឺព្រះអាទិត្យ ដែលនឹងផ្តល់នូវមូលដ្ឋានចាំបាច់សម្រាប់ការងារបង្កបង្កើនផល និងធុរកិច្ចនានារបស់សហគមន៍។

## ២- បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

## ២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៥

៤.២៤- នៅក្នុងនីតិកាលទី៤នៃរដ្ឋសភាកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានជោគជ័យតាមគោលដៅយុទ្ធសាស្ត្ររបស់ខ្លួន តាមរយៈការការពារអធិបតេយ្យភាព និងបូរណភាពទឹកដី ការពង្រឹងស្ថិរភាពនយោបាយ នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សណ្តាប់ធ្នាប់សាធារណៈ រួមជាមួយនឹងវឌ្ឍនភាពល្អ ក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងដើម្បីកសាងព្រំដែនមួយច្បាស់លាស់ សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។ វឌ្ឍនភាពនេះបានក្លាយជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍនិងការកាត់បន្ថយភាពក្រីក្រសម្រាប់រយៈពេលវែង។ លើមូលដ្ឋាននេះ កម្ពុជាបានបង្កើនជំនឿទុកចិត្តពីសំណាក់វិនិយោគគិន និងភ្ញៀវទេសចរ ដែលឆ្លុះបញ្ចាំងឡើងតាមរយៈការកើនឡើងនៃលំហូរទុនវិនិយោគ និងចំនួនភ្ញៀវទេសចរមកកម្ពុជា។

៤.២៥- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងគោលដៅបន្តពង្រឹងថែមទៀតនូវកិច្ចការពារអធិបតេយ្យភាពជាតិ បូរណភាពទឹកដី ឯកភាពជាតិ និងឯកភាពទឹកដី សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងភាពសុខដុមក្នុងសង្គម។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ (១)ការបន្តពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌ សន្តិភាព សីលធម៌សង្គម និងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សព្រមទាំងការបន្តប្រឆាំងដាច់ខាតរាល់សកម្មភាពឬការញុះញង់ណាមួយដែលបង្កអស្ថិរភាពនយោបាយឬចលាចលក្នុងសង្គម (២) ការបន្តដោះស្រាយបញ្ហាព្រំដែនគោក និងសមុទ្រជាមួយប្រទេសជិតខាងដោយឈរលើគោលការណ៍ទាំងឡាយដែលបានគូសបញ្ជាក់ខាងលើ រួមជាមួយនឹងការបន្តរៀបចំនិងជំរុញការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រំដែន ទន្ទឹមនឹងការបន្តមិនអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជាដើម្បីប្រឆាំងនឹងប្រទេសជិតខាង (៣)ការទប់ស្កាត់និងការបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រឆាំងភេរវកម្មនិងហិរញ្ញប្បទានភេរវកម្ម ការប្រឆាំងការសម្អាតប្រាក់ ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងគ្រឿងញៀននិងការជួញដូរមនុស្ស ក៏ដូចជា ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទផ្សេងទៀត ព្រមទាំងការបន្តជំរុញការអនុវត្តគោលនយោបាយ***ភូមិឃុំមានសុវត្ថិភាព*** និង(៤)ការបន្តពង្រឹងសុវត្ថិភាពចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈរួមទាំងការលុបបំបាត់បុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់។

## ខ- សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.២៦- ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងមហាផ្ទៃ***នឹងផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាដែលកំពុងលេចឡើង និងដើម្បីធ្វើឲ្យប្រសើរឡើងនូវការទទួលបានសេវាសាធារណៈ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួនលើការងារស៊ីវិលនិងការងារនគរបាល។ ក្រសួងមហាផ្ទៃនឹងរៀបចំអនុក្រឹត្យថ្មីមួយស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងដើម្បីធានាថាមន្ត្រីស៊ីវិលនិងប៉ូលីសរបស់ខ្លួនបំពេញតួនាទីនិងភារកិច្ច ដោយប្រកាន់ខ្ជាប់នូវវិន័យ អព្យាក្រឹតភាពក្រមសីលធម៌ និងការគោរពតាមបទបញ្ជា។

៤.២៧- ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ក្រសួងមហាផ្ទៃបាននិងកំពុងអនុវត្តកម្មវិធីសាកល្បង “**ការិយាល័យច្រកចេញចូលតែមួយ**” នៅថ្នាក់ក្រុង ស្រុក សម្រាប់២៤ក្រុង ស្រុក។ នៅក្នុងកម្មវិធីនេះ ***ក្រសួងមហាផ្ទៃ*** បានកំណត់ “**តំណាងស្រុក**” ដែលមានភារកិច្ចទទួលលិខិតទិតៀនពីប្រជាជន សហគមន៍ អង្គការសង្គមស៊ីវិល និងមន្ត្រីស្រុក។ ***ក្រសួងមហាផ្ទៃ*** នឹងពង្រីកជាបន្តបន្ទាប់នូវការគ្របដណ្តប់របស់កម្មវិធីនេះឲ្យបានគ្រប់ខេត្តទាំង២៤ និងរាជធានី។

៤.២៨- ***ក្រសួងមហាផ្ទៃ*** នឹងបន្តអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌រវាង***ក្រសួងមហាផ្ទៃ*** និង***ក្រសួងយុត្តិធម៌*** ។ នៅក្នុងគម្រោងនេះ មជ្ឈមណ្ឌលសេវាយុត្តិធម៌ចំនួន២០ នៅថ្នាក់ស្រុកត្រូវបានបង្កើតឡើង។

៤.២៩-***ក្រសួងមហាផ្ទៃ*** នឹងបន្តអភិវឌ្ឍស្ថានភាពពន្ធនាគារឲ្យស្របតាមបទដ្ឋានអន្តរជាតិ ដោយធ្វើការជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារចាស់ ដោយធ្វើការបំពាក់នូវសម្ភារៈបរិក្ខារឲ្យឆ្លើយតបទៅនឹងកំណើនជនជាប់ឃុំ និងធ្វើការសាងសង់ថ្មីចំពោះពន្ធនាគារដែលមានសភាពទ្រុឌទ្រោមនៅខេត្តអាទិភាពមួយចំនួន ដូចជាពន្ធនាគារខេត្ត ក្រចេះ កំពង់ចាម បាត់ដំបង ពោធិសាត់ មណ្ឌលគិរី ស្ទឹងត្រែង កំពង់ធំ ព្រៃវែង រតនគិរី និងអាគារឃុំឃាំង មណ្ឌលអប់រំកែប្រែចំនួន៤។ ក្រសួងមហាផ្ទៃនឹងបន្តជំរុញអនុវត្តការងារអប់រំកែប្រែ និងស្តារនីតិសម្បទាដល់ជនជាប់ឃុំ ស្របតាមក្របខ័ណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ ច្បាប់ស្តីពីពន្ធនាគារ និងនីតិវិធីគ្រប់គ្រងពន្ធនាគារ ក្នុងគោលដៅអប់រំ កែប្រែ ស្តារនីតិសម្បទាដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមវិញ និងទប់ស្កាត់ការប្រព្រឹត្តបទល្មើសសាជាថ្មី។ ក្រសួងមហាផ្ទៃនឹងរៀបចំព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ និងបន្តកិច្ចសហប្រតិ

បត្តិការជាមួយអាជ្ញាធររាជធានី ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពង្រឹងការអនុវត្តច្បាប់ និងការគោរពសិទ្ធិមនុស្សនៅក្នុងពន្ធនាគារ។

៤.៣០- ***ក្រសួងមហាផ្ទៃ*** នឹងបន្តពង្រឹងកងកម្លាំងនគរបាលជាតិ ឲ្យទៅជាកងកម្លាំងមួយដែលមានវិជ្ជាជីវៈជំនាញពិតប្រាកដបំពាក់ដោយបច្ចេកវិទ្យាទំនើប មានអត្តចរិតសុភាពរាបសារ មានសមត្ថភាពបំពេញភារកិច្ច មានស្មារតីទទួលខុសត្រូវ គោរពប្រតិបត្តិច្បាប់ និងមានគោលជំហរគោរពសិទ្ធិមនុស្ស រក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម ការពារអាយុជីវិតទ្រព្យសម្បត្តិរបស់ប្រជាជន និងបម្រើសេវាជូនប្រជាពលរដ្ឋដោយស្មោះត្រង់។ ក្រសួងនឹងបន្តពង្រឹងនគរបាលនៅតាមប៉ុស្តិ៍រដ្ឋបាល ក្រោមប្រធានបទ "**នគរបាលនិងសហគមន៍**" ។ ទន្ទឹមនឹងនេះ ក្រសួងអនុញ្ញាតឲ្យសិស្ស និស្សិតចូលមកសិក្សានៅបណ្ឌិត្យសភានគរបាលកម្ពុជាដើម្បីធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញនគរបាល ហើយអនុញ្ញាតឲ្យពួកគេប្រឡងចូលក្របខ័ណ្ឌមន្ត្រីនគរបាលទៅតាមតម្រូវការប្រចាំឆ្នាំនីមួយៗរបស់ក្រសួង។ ក្រសួងក៏បានប្រគល់ភារកិច្ចជូនបណ្ឌិត្យសភានគរបាលជាតិកម្ពុជាក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់អនុរក្សពន្ធនាគារ និងធ្វើវិក្រឹតការ សុក្រឹតការដល់មន្ត្រីនិងថ្នាក់ដឹកនាំពន្ធនាគារគ្រប់លំដាប់ថ្នាក់។

៤.៣១- ***ក្រសួងមហាផ្ទៃ*** នឹងបន្តជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់និងក្រៅតំបន់ និងអង្គការអន្តរជាតិ ពិសេស លើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ដើម្បីទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិលើដំណើរការលទ្ធិប្រជាធិបតេយ្យ គោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការពង្រឹងស្ថិរភាព ការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់និងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។

## ការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន

៤.៣២- ***អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*** នឹងបន្តដឹកនាំការអនុវត្តឲ្យមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រទាំង៥របស់ផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរួមមាន (១) ការកាត់បន្ថយតម្រូវការគ្រឿងញៀន (២)ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន (៣)ការព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម (៤)ការពង្រឹងសមត្ថភាពអនុវត្តច្បាប់ និង (៥) កិច្ចសហប្រតិបត្តិការអន្តរជាតិ។ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រទាំង៥ខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានដាក់ឲ្យអនុវត្តវិធានការយុទ្ធសាស្ត្រចំនួន៧ ដែលមានដូចខាងក្រោម៖

- ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀនៈ ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀននៅក្នុងសង្គម។ ការលើកទឹកចិត្តឲ្យមានការចូលរួមពីគ្រប់ផ្នែកនៃសង្គមក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំផែនការក្នុងការបង្កើនកម្មវិធីអប់រំអំពីបញ្ហាគ្រឿងញៀន និងការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាជាតិ នៅគ្រប់កម្រិតសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធ។ ការជំរុញរៀបចំយន្តការសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន និងចងក្រងឯកសារស្តីពីបទពិសោធអំពីសកម្មភាពត្រួតពិនិត្យគ្រឿងញៀន ដើម្បីធានាឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់នៅពេលអនាគត។

- ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀនៈ ការព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍តាមរយៈសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀនរបស់ក្រសួងសុខាភិបាល។ ការអនុវត្តកម្មវិធីថែទាំ ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនដោយឱសថមេតាដូន។ ការរៀបចំសេចក្តីព្រាងគោលនយោបាយមួយស្តីពីការព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន។ ការរៀបចំបង្កើតរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន។ ការរៀបចំបង្កើតក្រុមផ្តល់ប្រឹក្សានៅតាមសហគមន៍។ ការលើកកម្ពស់សមត្ថភាពមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។
- ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ៈ ការជំរុញការអនុវត្តការងារនីតិកម្មឲ្យមានប្រសិទ្ធភាព។ ការជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦១ ១៩៧១ ១៩៨៨ ពិធីសារឆ្នាំ១៩៧២ និងអនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនឲ្យមានប្រសិទ្ធភាព។ ការរៀបចំតាក់តែងបទដ្ឋានគតិយុត្តនានានិងការជំរុញការអនុវត្តច្បាប់ទាំងឡាយ ដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឲ្យមានប្រសិទ្ធភាព។ ការបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ការផលិត ការចរាចរ ការចែកចាយគ្រឿងញៀនខុសច្បាប់ និងពង្រឹងប្រសិទ្ធភាពការងារស៊ើបអង្កេតរបស់ស្ថាប័នអនុវត្តច្បាប់។ ការបំផុសឲ្យមានការចូលរួមផ្តល់ព័ត៌មានពីសាធារណជនអំពីការផលិត ការចរាចរ ការជួញដូរគ្រឿងញៀនខុសច្បាប់។ ការពង្រឹងនិងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន។ ការលើកកម្ពស់សមត្ថភាពជំនាញដល់មន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន។ ការបន្តប្រើប្រាស់យន្តការបណ្តុះបណ្តាលតាមកុំព្យូទ័រដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់។ ការពង្រឹងការអនុវត្តច្បាប់ដើម្បីគាំទ្រដល់កម្មវិធីកាត់បន្ថយគ្រោះថ្នាក់។
- ការត្រួតពិនិត្យសារធាតុគីមីផ្សំៈ ការបង្កើនការគ្រប់គ្រងសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុញៀនដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ។ ការជំរុញការរៀបចំបទបញ្ញត្តិនានា និងកសាងផែនការស្តីពីការត្រួតពិនិត្យសារធាតុដែលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ

ដើម្បី ទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅផលិតគ្រឿងញៀនខុសច្បាប់ និងបណ្តុះបណ្តាលជំនាញដល់ស្ថាប័នអនុវត្តច្បាប់។ ការរៀបចំផែនការគ្រប់គ្រង និងត្រួតពិនិត្យការផលិត និងការចរាចរប្រេងរុក្ខជាតិដែលមានផ្ទុកសារធាតុសាហ្វ្រូលខ្ពស់ចម្រាញ់ចេញពីដើមម្រះព្រៅភ្នំនិងរុក្ខជាតិផ្សេងៗទៀត។

- ការបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែនៈ ការជំរុញយន្តការភូមិ-ឃុំបែតងគ្មានគ្រឿងញៀននៅតាមតំបន់ព្រំដែន។ ការពង្រឹងយន្តការទំនាក់ទំនងព្រំដែន។
- ការបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍនានាៈ ការពង្រឹង និងពង្រីកការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញាគ្រឿងញៀនអន្តរជាតិ និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន។
- ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងក្រោមជាតិៈ ការពង្រឹងរចនាសម្ព័ន្ធអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ជំរុញការរៀបចំបង្កើតក្រុមការងារ និងគណៈកម្មការជំនាញដទៃទៀតដែលមានសារៈសំខាន់ដល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន។ ការរៀបចំគោលនយោបាយលើកទឹកចិត្តដល់បុគ្គលនិងអង្គភាពដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៤.៣៣- ដើម្បីពង្រឹងតម្លៃរបស់គ្រួសារនិងសាសនា ដែលជាមូលដ្ឋានគ្រឹះនៃការរៀបចំសង្គមកម្ពុជា ***ក្រសួងធម្មការនិងសាសនា*** នឹងបន្តជំរុញលើកកម្ពស់យ៉ាងសកម្មនូវតួនាទីរបស់គ្រួសារ និងការផ្សារភ្ជាប់ទៅនឹងតម្លៃជាប្រពៃណីនៃសាសនារបស់ព្រះរាជាណាចក្រកម្ពុជា។ ដើម្បីអនុវត្តតាមគំនិតផ្តួចផ្តើមរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ***ក្រសួង*** បានបង្កើតកម្មវិធី “**នាទីព្រះពុទ្ធសាសនា ផ្សារភ្ជាប់នឹងសង្គម**” ដោយនិមន្ត**ព្រះឧទ្ទេសាចារ្យ** ដែលមានទេពកោសល្យ ឈ្លាសវៃប៉ិនប្រសប់មកសំដែងព្រះធម៌ទេសនារៀងរាល់ថ្ងៃសីល(៤ដងក្នុង១ខែ) សំដៅបញ្ជ្រាបការអប់រំវិស័យព្រះពុទ្ធសាសនាទៅក្នុងស្រទាប់សិស្ស និស្សិត និងមហាជនទូទៅដើម្បីបង្កើនការយល់ដឹងពីតម្លៃសីលធម៌រស់នៅក្នុងសង្គម បញ្ចៀសពីការប្រើប្រាស់គ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ អំពើអានាចារ ការកេងប្រវ័ញ្ចផ្លូវភេទ និងក្មេងទំនើងក្នុងស្រទាប់យុវវ័យ។ ការរៀបចំកម្មវិធីនេះបានផលិតជាវីស៊ីឌី និងឌីវីឌី ហើយត្រូវបានចាក់ផ្សាយតាមវិទ្យុនិងទូរទស្សន៍រដ្ឋ ឯកជន ចំនួន២២ស្ថានីយជារៀងរាល់ថ្ងៃ។ ទន្ទឹមនឹងនេះ ក្រសួងក៏បានជំរុញលើកទឹកចិត្តឲ្យសាសនាដទៃទៀតជួយអប់រំសីលធម៌តាមវិស័យសាសនារបស់ខ្លួនយ៉ាងសកម្មរួមចំណែកដល់ការអភិវឌ្ឍជាតិ។

៤.៣៤- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ ***ក្រសួងធម្មការនិងសាសនា*** នឹងៈ

- បង្កើនការអប់រំ ពិសេស ការអប់រំក្នុងស្រទាប់យុវជននិងកុមារឲ្យយល់ដឹងច្បាស់ពីតម្លៃដ៏វិសេសវិសាលនៃវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរដែលជាអត្តសញ្ញាណរបស់ជាតិ ហើយចូលរួមថែរក្សា លើកតម្កើង អភិវឌ្ឍវប្បធម៌ជាតិ និងកាត់បន្ថយឥទ្ធិពលវប្បធម៌អវិជ្ជមានពីបរទេស។
- បន្តគោរពសេរីភាពខាងជំនឿនិងសាសនា លើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ជាពិសេស ការបន្តពង្រឹងនិងពង្រីកពុទ្ធិកសិក្សានៅគ្រប់កម្រិត ការបោះពុម្ពផ្សាយគម្ពីរ ដីកា ក្បួនច្បាប់នានា និងកិច្ចប្រតិបត្តិធម៌វិន័យ ទន្ទឹមនឹងនេះគាំទ្រសកម្មភាពនៃសាសនាផ្សេងៗទៀតក្នុងសង្គម។
- ពង្រឹងសុខដុមនីយកម្មរវាងសាសនិកនៃគ្រប់សាសនា ប្រឆាំងការរើសអើងបែងចែកក្នុងចំណោមប្រជាជនដែលបណ្តាលមកពីភាពខុសគ្នាខាងសាសនា សំដៅប្រែក្លាយសក្តានុពលរបស់សាសនាទាំងអស់ទៅជាកម្លាំងជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ច សន្តិភាព សាមគ្គីភាពថែរក្សាប្រពៃណីជាតិ និងលើកកម្ពស់តម្លៃសីលធម៌។ រាំងស្កាត់ការយកសាសនាទៅធ្វើអាជីវកម្មនិងបង្កជាវិបត្តិសាសនា។
- បង្កើតសាខាពុទ្ធិកសាកលវិទ្យាល័យតាមខេត្តនីមួយៗ ស្របតាមលទ្ធភាពនិងស្ថានភាពជាក់ស្តែង បន្តពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សា តាំងពីកម្រិតធម្មវិន័យបឋមសិក្សារហូតដល់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សាតាមរយៈការបណ្តុះបណ្តាលសមណសិស្សនិងនិស្សិតនៅតាមគ្រឹះស្ថានពុទ្ធិកសិក្សានានាដែលមានក្នុងពេលបច្ចុប្បន្ននិងអនាគត។
- ពង្រឹងនិងពង្រីកបណ្ណាល័យនៅតាមមន្ទីរ វត្តអារាម សាលាពុទ្ធិកសិក្សាដោយបំពាក់សៀវភៅ គម្ពីរ ដីកា ក្បួនច្បាប់ និងឯកសារដែលពាក់ព័ន្ធនានា ដើម្បីជំរុញការអាន ការសិក្សាស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់។
- បន្តរៀបចំវគ្គបណ្តុះបណ្តាលតួនាទី ភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរ រៀបចំការគ្រប់គ្រងជាសមាគមអាចារ្យខ្មែរទូទាំងប្រទេសចាប់ពីថ្នាក់កណ្តាលដល់មូលដ្ឋាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយធ្វើសន្និបាតបូកសរុបការងារសមាគមអាចារ្យខ្មែរប្រចាំឆ្នាំ និងលើកទិសដៅបន្ត។
- បន្តរៀបចំបើកវគ្គបណ្តុះបណ្តាលតួនាទី ភារកិច្ច និងវិធីប្រតិបត្តិដូនជី និងបន្តថែរក្សាប្រពៃណីទំនៀមទម្លាប់សាសនានិងពិធីបុណ្យគ្រប់សាសនានានា។
- បន្តជំរុញការលើកកម្ពស់តួនាទីសាសនា ជាពិសេស ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ក្នុងការចូលរួមផ្តល់ការអប់រំផ្នែកគុណធម៌ សីលធម៌ និងចរិយាធម៌ ព្រមទាំងក្នុងការធានាសុខដុមរមនានៅក្នុងសង្គមកម្ពុជា តាមរយៈការផ្សព្វផ្សាយនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គមឲ្យបានទូលំទូលាយនិងជ្រួតជ្រាបគ្រប់ស្រទាប់មហាជន។

## ២.២- បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះនិងចីរភាពបរិស្ថាន

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.៣៥- ក្នុងនីតិកាលកន្លងទៅនេះ ទោះបីកម្ពុជាបានទទួលរងឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងពីវិបត្តិកលិយុគហិរញ្ញវត្ថុនិងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក ដែលរហូតមកដល់បច្ចុប្បន្ននេះនៅមិនទាន់ចប់នៅឡើយក៏ដោយ ក៏រាជរដ្ឋាភិបាលទទួលបានជោគជ័យក្នុងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហើយសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពស់ជាង៧% ឡើងវិញ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ បន្ទាប់ពីការធ្លាក់ចុះនៅឆ្នាំ២០០៩។ ការបន្តអនុវត្ត**កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២** បានពង្រឹងភាពជឿទុកចិត្តនៃថវិកា ហើយគណនេយ្យភាពហិរញ្ញវត្ថុ ក៏ត្រូវបានកែលម្អឲ្យកាន់តែប្រសើរឡើង។

៤.៣៦- ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រផ្នែកម៉ាក្រូសេដ្ឋកិច្ច រាជរដ្ឋាភិបាលនីតិកាលទី៥នឹងផ្តោតអាទិភាពលើ៖

- ទី១ ការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងភាពធន់នៃសេដ្ឋកិច្ចជាតិ តាមរយៈការបន្តអនុវត្តគោលនយោបាយថវិកា ដែលមានលក្ខណៈទន់ភ្លន់ សម្របសម្រួល និងប្រទាក់ក្រឡាគ្នាជាមួយនឹងគោលនយោបាយរូបិយវត្ថុ ការពង្រីកមូលដ្ឋាននាំចេញនៃសេដ្ឋកិច្ចកម្ពុជាឲ្យរីកចម្រើន ស្របជាមួយនឹងសេចក្តីត្រូវការក្នុងតំបន់និងពិភពលោក ការពង្រីក ***លំហថវិកា*** រួមទាំងការរក្សាបំណុលសាធារណៈឲ្យនៅកម្រិតទាប ដែលអាចគ្រប់គ្រងបាន និងការពង្រឹងការសម្របសម្រួលរវាងស្ថាប័ន ក្នុងក្របខ័ណ្ឌយន្តការបង្ការ និងដោះស្រាយវិបត្តិ។
- ទី២ ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបុរេសកម្ម សម្រាប់ទ្រទ្រង់កំណើន តាមរយៈការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន ការជំរុញការអភិវឌ្ឍទីផ្សារការងារ ការជំរុញការវិនិយោគក្នុងវិស័យគន្លឹះនានា ប្រកបដោយសមធម៌ ការបន្តអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា រួមទាំងការបន្តជំរុញអនុវត្ត***យុទ្ធសាស្ត្រអភិវឌ្ឍហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០*** ដើម្បីធានាប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងទាំងក្នុងការទាក់ទាញវិនិយោគ ទាំងក្នុងការជំរុញការនាំចេញ។
- ទី៣ ការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់ និងប្រុងប្រយ័ត្ន រួមទាំងការពង្រឹងអប្បមាទក្នុងការគ្រប់គ្រងលំហូរមូលធន ដើម្បីរួមចំណែកដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើតបរិស្ថានអំណោយផលដល់ការអភិវឌ្ឍ ការធានាបង្កើនទុនបម្រុងអន្តរជាតិ ការបន្តអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដើម្បី

រក្សាស្ថិរភាពប្រាក់រៀល និងពង្រឹងជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគិនមកលើប្រាក់រៀល ព្រមទាំងការជំរុញការប្រើប្រាស់ប្រាក់រៀលសំដៅកាត់បន្ថយដុល្លារូបនីយកម្ម ការពង្រឹងនិងរក្សាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ ពិសេសការពង្រឹងប្រព័ន្ធធនាគារឲ្យកាន់តែមានប្រសិទ្ធភាព សមាហរណកម្ម និងមានភាពប្រកួតប្រជែង តាមរយៈការពង្រឹងការត្រួតពិនិត្យនិងការគ្រប់គ្រងហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន និងហានិភ័យទីផ្សារ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ។

- ទី៤ ការបន្តជំរុញអនុវត្តកម្មវិធី**កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឲ្យស្របតាមបទដ្ឋានអន្តរជាតិ តាមរយៈ (១)ការបន្តបង្កើនភាពជឿទុកចិត្តនៃថវិកា ដោយបន្តពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ពិសេសការអនុម័តនិងការដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ព្រមទាំងការកែលម្អការអនុវត្តថវិកានិងការគ្រប់គ្រងសាច់ប្រាក់ (២)ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដោយរៀបចំនិងដាក់ឲ្យអនុវត្តមាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី និងអង្គភាពថវិកាព្រមទាំងការ**គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបច្ចេកវិទ្យាព័ត៌មាន** (៣)ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម ដោយបន្តពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ព្រមទាំងការកែលម្អការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ដោយដាក់ឲ្យអនុវត្តនូវឯកសារទស្សនាទានស្ដីពីទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកា និង (៤)ការបន្តបង្កើនសមត្ថភាព និងការចូលរួមប្រកបដោយភាពជាម្ចាស់ និងបុរេសកម្មរបស់ក្រសួង ស្ថាប័ន ដើម្បីធានាជោគជ័យនៃការអនុវត្តកម្មវិធីកំណែទម្រង់។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព កំណើនប្រកបដោយចីរភាព

៤.៣៧- រាជរដ្ឋាភិបាលកម្ពុជា បន្តធានារក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពក្នុងបរិការណ៍អតិផរណាមានកម្រិតទាប និងអាចគ្រប់គ្រងបាន ហើយអត្រាប្តូរប្រាក់មានស្ថិរភាពដើម្បីធានាបាននូវបរិស្ថានអនុគ្រោះដល់ការអភិវឌ្ឍ និងការសម្រេចបាននូវគោលដៅធំៗនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ព្រមទាំងការលើកកម្ពស់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជានឹងសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម៧%ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យកម្ពុជាបានចាកចេញផុតពី***ប្រទេសមានការអភិវឌ្ឍតិចតួច*** ហើយឡើងឋានៈជា***ប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៣០*** ។ ជាមួយគ្នានេះបន្តខិតខំដើម្បីសម្រេចឲ្យបានការកាត់បន្ថយ

ភាពក្រីក្រជាង១%ក្នុងមួយឆ្នាំ និងឈានទៅសម្រេចឲ្យបាន***គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ២០១៥***។

៤.៣៨- ដើម្បីសម្រេចឲ្យបាននូវបណ្តាគោលនយោបាយអាទិភាព សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងក្រសួង ស្ថាប័ន*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

- បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុប្រយ័ត្នប្រយែង ដើម្បីធានាបន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងបរិការណ៍នៃអត្រាអតិផរណាទាបនិងអត្រាប្តូរប្រាក់មានស្ថិរភាព។
- ពង្រឹងនិងពង្រីកលំហូររូបិយវត្ថុនិងលំហាថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ និងដើម្បីទប់ទល់វិបត្តិ កលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ។
- បន្តការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយរឹងមាំនិងផ្អែកលើគោលការទីផ្សារ ដែលបម្រើឲ្យការគៀរគរ និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាពសំដៅរួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។
- បន្តអនុវត្តគោលនយោបាយធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ដោយឈរលើមូលដ្ឋានភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅក្នុងបណ្តាញផលិតកម្មក្នុងតំបន់ ក្នុងនោះយកចិត្តទុកដាក់ជាពិសេសដល់ការបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្មន្តសាលនិងកសិឧស្សាហកម្ម ព្រមទាំងការអនុវត្ត**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ឆ្នាំ២០១១-២០២០**។
- សម្របសម្រួលការនាំចេញ ជាពិសេស ការនាំចេញផលិតផលកសិកម្ម តាមរយៈ***ច្រកចេញចូលតែមួយ*** និងកែសម្រួលដំណើរការស្នើសុំការងកភាព។
- បន្តជំរុញនិងលើកកម្ពស់ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាផ្លូវថ្នល់ស្ពាន ទំនប់ ប្រឡាយ ប្រព័ន្ធស្រោចស្រព និងធារាសាស្ត្រ ដើម្បីបង្កលក្ខណៈដល់ការអភិវឌ្ឍវិស័យកសិកម្ម។ ផ្តោតការយកចិត្តទុកដាក់លើការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនក្នុងប្រទេសឲ្យក្លាយជាប្រព័ន្ធសម្រួលការដឹកជញ្ជូន និងការវិនិយោគលើវិស័យអគ្គិសនី ដើម្បីធានាបាននូវតម្លៃសមរម្យនិងភាពទុកចិត្តបាននៃសេវាអគ្គិសនី ទាំងសម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារ ទាំងសម្រាប់ជាលក្ខណៈពាណិជ្ជកម្ម ឧស្សាហកម្ម។

- បង្កើនការវិនិយោគលើការលើកកម្ពស់គុណភាពអប់រំ ជាពិសេស ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជំនាញ ទាំងសម្រាប់គោលដៅបង្កើតមុខរបរ និងទាំងសម្រាប់គាំទ្រដល់វិស័យឧស្សាហកម្ម។
- ពិនិត្យនិងរៀបចំឡើងវិញនូវរបបវិនិយោគឯកជន ដើម្បីធានាបាននូវការទាក់ទាញវិនិយោគតាមគោលដៅជាយុទ្ធសាស្ត្រ ដោយធានាបានកំណើនសេដ្ឋកិច្ចផង និងការបង្កើតការងារផង ព្រមទាំងការពង្រីកមូលដ្ឋាននៃប្រភពចំណូលថវិកាជាតិផងដែរ។ បង្កើនប្រសិទ្ធភាពនៃការអនុវត្តការកែទម្រង់ពាក់ព័ន្ធនឹងការកែលម្អបរិស្ថានវិនិយោគ និងការសម្រួលពាណិជ្ជកម្ម។ ក្នុងការងារនេះ ការយកចិត្តទុកដាក់ជាពិសេស ត្រូវផ្តោតលើការពង្រឹងអភិបាលកិច្ច ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តកម្មវិធី**កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ** និងការពង្រឹងនីតិរដ្ឋ។
- បន្តជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញនិងបង្កើនល្បឿនសមាហរណកម្មទៅក្នុងក្របខ័ណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់និងពិភពលោក ជាពិសេសសហគមន៍សេដ្ឋកិច្ចអាស៊ានដើម្បីយកប្រៀបចំណេញពីការចូលរួមនេះ។
- បន្តការអនុវត្តកំណែទម្រង់ដីធ្លី ជាពិសេស ការបន្តអនុវត្ត"**គោលនយោបាយចាស់សកម្មភាពថ្មីក្នុងវិស័យដីធ្លី**" ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ដីធ្លីក្នុងគោលដៅធានាបាននូវចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។
- ពិនិត្យឡើងវិញនូវគោលនយោបាយប្រមូលចំណូលបច្ចុប្បន្ន ព្រមទាំងរៀបចំនិងអនុវត្ត**យុទ្ធសាស្ត្រកៀរគរចំណូលក្នុងរយៈពេលមធ្យម ២០១៣-២០១៨**។
- បន្តកសាងនិងកែលម្អប្រព័ន្ធសារពើពន្ធ ក្នុងគោលដៅធ្វើឲ្យប្រព័ន្ធនេះក្លាយទៅជាវិចារណកម្មនៃកំណើនសេដ្ឋកិច្ច ជាមូលដ្ឋានដ៏រឹងមាំនៃចំណូលថវិកាជាតិ បង្កើនប្រសិទ្ធភាពកាត់បន្ថយអំពើគេចពន្ធនិងជាយន្តការធានានូវសមធម៌សង្គម។
- បន្តមិនយកពន្ធលើដីធ្លីកសិកម្ម ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិស័យកសិកម្ម ជាពិសេសការកាត់បន្ថយភាពក្រីក្រនិងការលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។
- បន្តកសាងនិងកែលម្អច្បាប់និងលិខិតបទដ្ឋានស្តីពីពន្ធដារ ពិសេស ផ្តោតលើការរៀបចំបទប្បញ្ញត្តិស្តីពីប្រេងកាត រ៉ែ។ បន្តពង្រីកការដាក់ឲ្យអនុវត្តពន្ធអចលនទ្រព្យទូទាំងប្រទេស បន្ថយកម្រិតពន្ធលើផលរបរប្រចាំឆ្នាំ ដើម្បីពង្រីករបបស្វ័យប្រកាសរៀបចំពន្ធលើរូបវន្តបុគ្គល រៀបចំសន្ធិសញ្ញាពន្ធអន្តរជាតិ និងកែសម្រួលអាករពិសេស។
- ពង្រឹងនិងកែលម្អរដ្ឋបាលពន្ធដារ ដោយបង្កើនសមត្ថភាពមន្ត្រីពន្ធដារ បង្កើនការផ្តល់សេវាកម្មដល់អ្នកជាប់ពន្ធ ពង្រឹងការធ្វើសវនកម្មពន្ធ រឹតបន្តឹងវិធានការប្រមូលបំណុល

ពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ ព្រមទាំងបង្កើនអភិបាលកិច្ច និងសុចរិតភាពរបស់មន្ត្រីពន្ធដារ។

- ពង្រឹងនិងកែលម្អរដ្ឋបាលគយ តាមរយៈការជំរុញប្រព័ន្ធអាស៊ីគូដាជាមូលដ្ឋានគ្រឹះ និងជំរុញអនុវត្តពេញលេញនូវគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈយន្តការគ្រប់គ្រងហានិភ័យនិងការដាក់ឲ្យដំណើរការពេញលេញនូវប្រព័ន្ធបញ្ជរតែមួយ។
- បញ្ចប់ការរៀបចំនិងដាក់ឲ្យអនុវត្តច្បាប់ស្តីពីការប្រមូលចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ស្របតាមគោលដៅរួមនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- បញ្ចប់ការរៀបចំ និងដាក់ឲ្យអនុវត្តច្បាប់ស្តីពីការប្រមូលចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ស្របតាមគោលដៅរួមនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ។
- បន្តរៀបចំ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តដោយម៉ឺងម៉ាត់នូវការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការកៀរគរចំណូលមិនមែនសារពើពន្ធ រួមទាំងការអនុវត្តកិច្ចសន្យាកិច្ចព្រមព្រៀងលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ជាពិសេសកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ការជួលទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សម្បទានរ៉ែនិងប្រេងកាត ព្រមទាំងសម្បទានផ្សេងៗទៀត។
- ជំរុញឲ្យមានការស្រាវជ្រាវប្រភពចំណូលថ្មី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីបង្កើនចំណូលបង់ចូលថវិការដ្ឋ។
- ពង្រឹងការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ។
- ពង្រឹងសវនកម្មលើការប្រមូលចំណូលគ្រប់ប្រភេទ។
- បន្តរក្សាអាទិភាពគោលនយោបាយចំណាយដល់វិស័យអប់រំ សុខាភិបាល សុវត្ថិភាពសង្គម កសិកម្ម ដីធ្លី និងអភិវឌ្ឍន៍ជនបទ ព្រមទាំងការពង្រីកការកែលម្អ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន មន្ទីរពេទ្យ។ល។
- បន្តអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធតាមកំណើនសេដ្ឋកិច្ចនិងភាពទ្រទ្រង់បាននៃថវិកា។

- យកចិត្តទុកដាក់ជាពិសេស ដល់ការអនុវត្តគោលនយោបាយជំរុញ**ផលិតកម្មស្រូវនិងការនាំចេញអង្ករ អភិវឌ្ឍន៍វិស័យកសិឧស្សាហកម្ម** និង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ ២០១១-២០២០**។
- បន្តលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការគ្រប់គ្រងនិងការចាត់ចែងចំណាយ ចាប់ពីដំណាក់កាលនៃការរៀបចំ ការអនុវត្ត ការតាមដាន ការត្រួតពិនិត្យ និងសវនកម្មលើលទ្ធផលនៃការអនុវត្តថវិកា។
- ពង្រឹងការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ជាពិសេសក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ព្រមជាមួយនឹងការពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដើម្បីជាមូលដ្ឋាននៃការបង្កើនគុណភាពនិងប្រសិទ្ធភាពនៃការរៀបចំថវិកាប្រចាំឆ្នាំ។
- ពង្រឹងនិងពង្រីកការដាក់អនុវត្តថវិកាកម្មវិធីពេញលេញជាជំហានៗ តាមទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០ ដើម្បីធានាប្រសិទ្ធភាពនៃការរៀបចំថវិកាឲ្យផ្សារភ្ជាប់ទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ពង្រឹងការអនុវត្តឲ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានពាក់ព័ន្ធ។
- ពង្រឹងសវនកម្មទាំងផ្ទៃក្នុង និងផ្ទៃខាងក្រៅលើចំណាយ។
- ពង្រីកការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឲ្យបានជាអតិបរមា ដើម្បីឆ្លើយតបនឹងកំណើននៃតម្រូវការហិរញ្ញប្បទានសម្រាប់វិនិយោគសាធារណៈ លើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។
- បន្តអនុវត្តតាមគោលនយោបាយនិងគោលការណ៍គន្លឹះទាំង៤ ចំណុចពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ សំដៅរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែងនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- រៀបចំនិងអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល ព្រមទាំងពង្រឹងបន្ថែមសមត្ថភាពស្ថាប័ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។
- ពិនិត្យឡើងវិញនូវរបបវិនិយោគឯកជន ដើម្បីផ្តល់ការលើកទឹកចិត្តសមស្របនិងចំគោលដៅ ស្របតាមគោលដៅអភិវឌ្ឍរយៈពេលវែង។
- បន្តលើកទឹកចិត្តនិងជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស តំបន់កែច្នៃការនាំចេញ តំបន់ពាណិជ្ជកម្មសេរី និងការអភិវឌ្ឍទីផ្សារតាមតំបន់ព្រំដែន ដោយមានការចូលរួមពីវិស័យឯកជន។
- បង្កបង្កើតបរិយាកាសអំណោយផល សម្រាប់ទទួលការវិនិយោគទាំងក្នុងនិងក្រៅប្រទេស រួមមានការសម្រួលការចុះបញ្ជី ការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ជា

ពិសេស តាមយន្តការច្រកចេញចូលតែមួយ ដើម្បីបង្កើនល្បឿនរាល់ប្រតិបត្តិការនានាទាក់ទងនឹងធុរកិច្ចនិងវិនិយោគ ព្រមទាំងការកាត់បន្ថយចំណាយក្រៅផ្លូវការ។

- បន្តអនុវត្តនិងដំណើរការ**យន្តការវេទិការាជរដ្ឋាភិបាល-វិស័យឯកជន** ដើម្បីបន្តដោះស្រាយកង្វល់ផ្សេងៗរបស់វិស័យឯកជន និងដើម្បីបន្តពង្រឹងវិស័យឯកជនឲ្យកាន់តែមានជីវភាពនិងឲ្យកាន់តែមានភាពជាម្ចាស់។
- លើកកម្ពស់សហគ្រិនភាព រួមទាំងសហគ្រាសធុនតូចនិងមធ្យម ជាពិសេសក្នុងចំណោមប្រជាជនកម្ពុជាឲ្យចេះធ្វើធុរកិច្ចនិងវិនិយោគ តាមរយៈការផ្តល់ការលើកទឹកចិត្ត ការប្រឹក្សា មូលធន និងបច្ចេកទេស។

### ចីរភាពបរិស្ថាន

៤.៣៩- ការគ្រប់គ្រងបរិស្ថាននិងការប្រែប្រួលអាកាសធាតុ បានក្លាយជាបញ្ហាប្រឈមមួយទៀតសម្រាប់ចីរភាពនៃកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គមកម្ពុជា ដោយសារសម្ពាធពីកំណើនប្រជាជន ចរន្តនគរូបនីយកម្ម វិបុលកម្ម និងប្រពលវប្បកម្មកសិកម្ម ក៏ដូចជាការអភិវឌ្ឍវិស័យដឹកជញ្ជូន ថាមពល និងវិស័យដទៃទៀត។ បញ្ហាប្រឈមផ្នែកបរិស្ថានភាគច្រើនមានលក្ខណៈអន្តរវិស័យ ដែលទាមទារឲ្យមានការសម្របសម្រួលរវាងស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងកិច្ចសហការជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធ។

៤.៤០- ក្នុងនីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងបរិស្ថាន*** នឹងបន្តប្រកាន់យកនូវអភិក្រមគ្រប់ជ្រុងជ្រោយសម្រាប់ការគ្រប់គ្រងបរិស្ថាននៅកម្ពុជា តាមរយៈ៖

ទី១ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

ទី២ ការខិតខំកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងសមត្ថភាពបន្សាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ការអនុវត្ត***ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង*** និង ***ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០***។

ទី៣ ការបន្តពង្រឹងសមត្ថភាពបច្ចេកទេសនិងស្ថាប័ន ដើម្បីជំរុញការបញ្ជ្រាបប្រធានបទស្តីពីការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ ច្បាប់ និងផែនការ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ទី៤ ការបន្តដាក់ចេញនូវវិធានការនានា ដើម្បីគ្រប់គ្រងការបំពុលបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី។

## ២.៣- ភាពជាដៃគូក្នុងការអភិវឌ្ឍ

## ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.៤១- រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចលទ្ធផលជាច្រើន ក្នុងការពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍទាំងអស់ដែលក្នុងនោះ រួមមានសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល ដោយឈរលើគោលការណ៍ជាមូលដ្ឋាន និងការប្តេជ្ញាដែលមានចរិតសាកលនានា ដែលជានាឲ្យមានភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការដឹកនាំកិច្ចអភិវឌ្ឍប្រទេសជាតិ។

៤.៤២- វត្តមានកាន់តែច្រើនឡើងរបស់ដៃគូអភិវឌ្ឍមិនប្រពៃណី ពិសេស ពីតំបន់អាស៊ីនិងប៉ាស៊ីហ្វិក និងទម្រង់ការប្រកបដោយគំនិតច្នៃប្រឌិត ដូចជាកិច្ចសហប្រតិបត្តិការ**ត្បូង-ត្បូង** ពីប្រទេសដែលមានប្រវត្តិធ្លាប់ទទួលហិរញ្ញប្បទានសហប្រតិបត្តិការកន្លងមក ព្រមទាំងទម្រង់ហិរញ្ញប្បទានថ្មីៗដទៃទៀត ដែលត្រូវបានបង្កើតឡើងសម្រាប់ដោះស្រាយបញ្ហាប្រឈមក្នុងកម្រិតតំបន់និងសកលលោក ដូចជាការប្រែប្រួលអាកាសធាតុ និងមូលនិធិសកលជាដើម បានផ្តល់នូវការគិតគូរនិងគំនិតច្នៃប្រឌិតព្រមទាំងប្រភពធនធានថ្មីៗដល់កម្ពុជា។ ជាមួយគ្នានេះ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូសំខាន់ក្នុងកិច្ចអភិវឌ្ឍនឹងបន្តពង្រឹងកិច្ចសហការបន្ថែមទៀតជាមួយរាជរដ្ឋាភិបាលនាពេលអនាគត។ លើមូលដ្ឋាននៃភាពសម្បូរបែបរបស់តួអង្គអភិវឌ្ឍ និងកាលានុវត្តភាពដូចបានរៀបរាប់ខាងលើកិច្ចអភិវឌ្ឍន៍នៅកម្ពុជាត្រូវផ្អែកលើទស្សនៈទូលំទូលាយជាងមុន ពោលគឺមិនមែនផ្អែកលើតែហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍប្រពៃណីនោះឡើយ។

៤.៤៣- ក្នុងស្មារតីនេះ ក្រោមភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព នឹងផ្តោតការយកចិត្តទុកដាក់ដល់ភាពសម្បូរបែបរបស់ភាគីពាក់ព័ន្ធ និងទម្រង់ការកែច្នៃប្រឌិតថ្មីៗ ព្រមទាំងផ្តល់តម្លៃចំពោះការចូលរួមរបស់តួអង្គអភិវឌ្ឍនីមួយៗដើម្បីឈានទៅសម្រេចគោលដៅរួម និងកិច្ចអភិវឌ្ឍក្នុងបរិការណ៍នៃភាពជាដៃគូទូលំទូលាយ។ ដើម្បីប្រើប្រាស់ឲ្យអស់សក្តានុពល និងផ្អែកលើភាពសម្បូរបែបរបស់ដៃគូអភិវឌ្ឍនិងប្រភពធនធាន រាជរដ្ឋាភិបាលនឹងបន្តស្វែងយល់បន្ថែមទៀត និងគ្រប់គ្រងឲ្យបាននូវរបៀបរបបដំណើរការនិងប្រភពធនធានរបស់តួអង្គនីមួយៗ ទាំងវិស័យសាធារណៈទាំងវិស័យឯកជនសម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់គោលដៅ និងតាមដានលទ្ធផលក្នុងបរិការណ៍នៃអភិក្រមស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍ។

៤.៤៤- ការពិនិត្យឡើងវិញអំពីសមិទ្ធផល បញ្ហាប្រឈម និងកាលានុវត្តភាព បានបង្ហាញយ៉ាងច្បាស់ថា បរិការណ៍អភិវឌ្ឍន៍របស់កម្ពុជា ក៏ដូចជាសកលលោក តម្រូវឲ្យរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ឲ្យបានខ្ពស់ទៅលើការសម្រេចឲ្យបានលទ្ធផលក្នុងកិច្ចអភិវឌ្ឍ និងការប្រើប្រាស់អភិក្រមនានាដែលគាំទ្រដល់ផែនការនីយកម្មភាពជាដៃគូ និងការតាមដាន។ ដើម្បីអនុវត្តអភិក្រមស្តីពីភាពស័ក្តិសិទ្ធក្នុងកិច្ចអភិវឌ្ឍ សកម្មភាពទាំងឡាយសម្រាប់ពង្រឹងភាពជាដៃគូ និងសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍ ព្រមទាំងពង្រឹងសមត្ថភាពប្រកបដោយចីរភាពត្រូវតែផ្សារភ្ជាប់នឹងផែនការនីយកម្ម ថវិកាកម្ម និងក្របខ័ណ្ឌតាមដានលទ្ធផលរបស់ប្រទេស។ ទន្ទឹមនឹងនេះ ដៃគូអភិវឌ្ឍក៏ត្រូវប្រើប្រាស់ធនធានរបស់ខ្លួនសម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់នានាក្នុងគោលដៅអភិវឌ្ឍសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាល។ ក្របខ័ណ្ឌលទ្ធផលសម្រាប់តាមដានក៏ត្រូវបង្កើតទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតវិស័យសម្រាប់ជំរុញនិងតម្រែតម្រង់ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៤៥- ក្នុងនីតិកាលទី៥ រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ៖

ទី១ បន្តពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីប្រមូលធនធានហិរញ្ញប្បទានពីគ្រប់ប្រភពសម្រាប់អភិវឌ្ឍប្រទេស ដោយឈរលើគោលការណ៍នៃភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល។

ទី២ រៀបចំនិងអនុវត្ត ***យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ ២០១៤-២០១៨***។ គោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ គឺការពង្រឹង ***ភាពជាដៃគូទូលំទូលាយជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់*** ក្នុងបរិការណ៍ថ្មីដែលកម្ពុជានឹងពង្រឹងដោះស្រាយបញ្ហាប្រឈមធំៗ២ គឺ(១)ភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវតួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការដោយសារនិន្នាការថយចុះ នៃហិរញ្ញប្បទានឥតសំណងលើសកលលោក និងការវិវត្តនៃភាពជាដៃគូជាមួយដៃគូអភិវឌ្ឍនីមួយៗ (២)ការធ្លាក់ចុះនៃប្រភពហិរញ្ញប្បទានសម្បទាននៅពេលដែលកម្ពុជាសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបនាអនាគតដ៏ខ្លីខាងមុខ។ បន្ថែមលើនេះ យុទ្ធសាស្ត្រនេះ ក៏នឹងរំលេចពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តឲ្យបានពេញលេញនូវ គោលការណ៍សកលចម្បងៗដែលត្រូវបានឯកភាពក្នុងវេទិកាកំពូលនានា។

ទី៣ បន្តលើកកម្ពស់ និងបង្កើនប្រសិទ្ធភាពនៃយន្តការ ***វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន*** សំដៅពង្រឹងតួនាទីនៃយន្តការនេះ ក្នុងការផ្តល់ជម្រើសនិងអនុសាសន៍គោលនយោបាយនានាដើម្បីបង្កើនតួនាទីរបស់វិស័យឯកជន ក្នុងកិច្ចការអភិវឌ្ឍន៍ទន្ទឹមនឹងការបន្ត

ពង្រឹងតួនាទីនៃការដោះស្រាយឧបសគ្គ និងកង្វល់នានារបស់វិស័យឯកជនពាក់ព័ន្ធនឹងធុរកិច្ចរបស់ខ្លួននៅកម្ពុជា។

ទី៤ រៀបចំជាទៀងទាត់នូវកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ទន្ទឹមនឹងការបន្តជំរុញបង្កើតច្បាប់ស្តីពីសមាគមន៍និងអង្គការមិនមែនរដ្ឋាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយនឹងបណ្តាភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃកិច្ចប្រតិបត្តិការ។

ទី៥ បន្តពង្រឹងយន្តការ ***វេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍកម្ពុជា វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន កិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល*** និង***កិច្ចពិគ្រោះយោបល់ទ្វេភាគី*** ក្នុងទិសដៅជំរុញឲ្យយន្តការទាំងនេះឈានក្លាយទៅជា***វេទិកាអភិវឌ្ឍន៍កម្ពុជា*** ដែលជាយន្តការសម្រាប់រាជរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍទាំងអស់ មានជាអាទិ៍ដៃគូអភិវឌ្ឍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាបណ្តាភាគីពាក់ព័ន្ធចូលរួមពិភាក្សាលើបញ្ហានានាក្នុងការអភិវឌ្ឍប្រទេស។

## ២.៤- សមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅនៅក្នុងតំបន់និងពិភពលោក

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.៤៦- នៅក្នុងនីតិកាលទី៤នៃរដ្ឋសភាកន្លងមក រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលគួរឲ្យកត់សម្គាល់ក្នុងការតភ្ជាប់ខាងផ្នែករូបវន្តជាមួយនឹងបណ្តាប្រទេសក្នុងតំបន់ និងបានធ្វើឲ្យកាន់តែស៊ីជម្រៅនូវសេរីភាវូបនីយកម្មសេដ្ឋកិច្ចនិងពាណិជ្ជកម្ម តាមរយៈការកែទម្រង់យ៉ាងទូលំទូលាយលើក្របខ័ណ្ឌគតិយុត្ត ដែលបានធ្វើឲ្យកាន់តែប្រសើរនូវបរិយាកាសវិនិយោគនិងកិច្ចសម្រួលពាណិជ្ជកម្ម ព្រមទាំងបានលើកតម្កើងរបបពាណិជ្ជកម្មកម្ពុជាឲ្យមានសង្គតិភាពជាមួយនឹងវិធាននិងបទដ្ឋានអន្តរជាតិ។ លើសពីនេះ រាជរដ្ឋាភិបាលបានចូលរួមយ៉ាងសកម្ម តាមរយៈការអនុវត្តតួនាទីស្មើភាពនិងស្មើសិទ្ធិរបស់ខ្លួននៅលើឆាកអន្តរជាតិ និងក្នុងកិច្ចការសមាហរណកម្មតំបន់ពិសេស ការចូលរួមលើកកម្ពស់តួនាទីមជ្ឈភាពរបស់អាស៊ានក្នុងការរៀបចំនិម្មាបនកម្មតំបន់។

៤.៤៧- ដោយសារតែពាណិជ្ជកម្ម គឺជាប្រភពសំខាន់នៃកំណើនសេដ្ឋកិច្ចនិងសម្រាប់ការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តដំណើរទៅមុខយ៉ាងស្វាហាប់ នៅលើមាគ៌ានៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម សំដៅធានាឲ្យទំនិញនិងសេវាគ្រប់ប្រភេទអាចចរាចរបានដោយសេរីនៅក្នុងទូទាំងប្រទេស និងរវាងប្រទេសកម្ពុជានិងប្រទេសជាដៃគូសំខាន់ៗនៅក្នុងតំបន់និងសកលលោក។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តបើកច្រកឲ្យផលិតផលកម្ពុជាអាចឈានចូលដោយគ្មានរបាំងនិងឧបសគ្គនានាទៅកាន់ទីផ្សារធំៗនៅក្នុងតំបន់និងក្នុងពិភពលោក ដែលនឹងផ្តល់ឲ្យកម្ពុជានូវកាលានុវត្តភាពនៃ“**វិមាត្រសេដ្ឋកិច្ច**”ដ៏ធំធេង និងផ្តល់ផលប្រយោជន៍ដល់

សេដ្ឋកិច្ចកម្ពុជាជាកំណើននៃការវិនិយោគ កំណើននៃការងារ កំណើននៃប្រាក់ចំណូល និងកំណើននៃសេដ្ឋកិច្ចជាតិទាំងមូល ដែលសុទ្ធតែជាកត្តាដ៏សំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

៤.៤៨- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងបន្តបង្កើនការទាក់ទាញវិនិយោគទាំងក្នុងនិងក្រៅប្រទេស ធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម ពង្រីកទីផ្សារពាណិជ្ជកម្ម ជំរុញការតភ្ជាប់បណ្តាញគមនាគមន៍ដឹកជញ្ជូន និងការកែលម្អប្រព័ន្ធឡូជីស្ទិក កែលម្អក្របខ័ណ្ឌគតិយុត្ត ពង្រឹងយន្តការស្ថាប័ន រួមទាំងយន្តការដោះស្រាយវិវាទ ព្រមទាំងបន្តលើកកម្ពស់កិច្ចការកសាងសមត្ថភាព ដើម្បីជានានូវបរិស្ថានអនុគ្រោះសម្រាប់ការអភិវឌ្ឍកម្ពុជា។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៤៩- ដើម្បីអនុវត្តគោលនយោបាយអាទិភាពសម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***រាជរដ្ឋាភិបាលកម្ពុជា*** នឹងបន្តពង្រឹងការសម្របសម្រួលអន្តរក្រសួង អនុម័តច្បាប់ និងលិខិតបទដ្ឋានចាំបាច់នានាដើម្បីបំពេញនូវកាតព្វកិច្ចជាសមាជិកនៃអង្គការអន្តរជាតិនិងក្នុងតំបន់ ថែមទាំងការពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគ្រប់គ្រងនិងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋាននានាឲ្យមានប្រសិទ្ធភាព។

៤.៥០- ដើម្បីសម្រេចបានគោលដៅនេះ ***រាជរដ្ឋាភិបាលកម្ពុជា*** នឹងផ្តោតអាទិភាពលើ៖

- ទី១ ការបន្តចូលរួមបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងរាល់កិច្ចការតំបន់ និងកិច្ចការអន្តរជាតិ។
- ទី២ ការដាក់ចេញនូវគោលនយោបាយចាំបាច់នានា ពិសេស ***គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម*** ដើម្បីឈានឡើងមួយកម្រិតទៀតក្នុងខ្សែចង្វាក់តម្លៃនៃសេដ្ឋកិច្ចតំបន់និងពិភពលោក ពិសេស ក្នុងទីផ្សារអាស៊ីដែលកំពុងមានកំណើនខ្ពស់គួបផ្សំនឹងការយកចិត្តទុកដាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ពលករកម្ពុជាគ្រប់ស្រទាប់។
- ទី៣ ការបន្តកែលម្អក្របខ័ណ្ឌគតិយុត្ត សំដៅធ្វើឲ្យកាន់តែប្រសើរឡើងថែមទៀតនូវបរិស្ថានធុរកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ។
- ទី៤ ការចាត់វិធានការពង្រឹងនិងពង្រីកទីផ្សារនាំចេញរបស់កម្ពុជា ពិសេស តាមរយៈការចរចាបើកទីផ្សារជាមួយប្រទេសក្នុងតំបន់និងក្រៅតំបន់ ការជំរុញកែលម្អហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធឡូជិស្ទិក រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដើម្បីសម្រួលលំហូរទំនិញនិងសេវា រាប់ទាំងសេវាហិរញ្ញវត្ថុផង ព្រមទាំងការកាត់

បន្ថយរបាំងមិនមែនពន្ធនានា មានជាអាទិ៍ ការកែលម្អបទដ្ឋានអនាម័យ និងភូតគាមអនាម័យ។

ទី៥ ការចាត់វិធានការគោលនយោបាយចាំបាច់នានា ដើម្បីចូលរួមក្នុងសហគមន៍អាស៊ាន ឆ្នាំ២០១៥ ពិសេសតាមរយៈការអនុវត្តដោយប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងដែលមានការពាក់ព័ន្ធទាំងឡាយរបស់អាស៊ាន។

ទី៦ ការរៀបចំបង្កើតក្របខ័ណ្ឌចាំបាច់នានា ដើម្បីគ្រប់គ្រងការប្រែប្រួលដែលកើតចេញពីសហគមន៍អាស៊ានឆ្នាំ២០១៥ ក្នុងគោលដៅធានាផលប្រយោជន៍របស់កម្ពុជា ជាពិសេសការគ្រប់គ្រងទីផ្សារពលកម្មនិងលំហូរពលករ។

## ៣- ការលើកស្ទួយវិស័យកសិកម្ម

៤.៥១- វិស័យកសិកម្ម នៅតែបន្តតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ សន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រម និងក្នុងវិសាលភាព និងល្បឿនថ្មី ដើម្បីប្រែក្លាយវិស័យនេះពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម(បើកទូលាយ) ពោលគឺពឹងផ្អែកជាសំខាន់លើធនធានដែលមានស្រាប់(ធនធានដីនិងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណីឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម(ស៊ីជម្រៅ) ពោលគឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី ការស្រាវជ្រាវ និងការអភិវឌ្ឍយន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដោយគិតគូរផងដែរអំពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និងការធានាចីរភាពបរិស្ថាននិងធនធានធម្មជាតិ។ ទន្ទឹមនេះ ការបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្ម និងការអភិវឌ្ឍវិស័យកសិឧស្សាហកម្មនឹងជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្មក៏ដូចជាជួយបង្កើនចំណូលជូនកសិករ។

### ៣.១- ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្ម

### ក. គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.៥២- ក្នុងការអនុវត្តគោលដៅខាងលើនេះ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ រួមមាន (១)កំណើនក្នុងវិស័យដំណាំជាមធ្យមប្រចាំឆ្នាំបានប្រមាណ៥% សម្រាប់រយៈពេលឆ្នាំ២០០៨-២០១២ ដែលក្នុងនោះទិន្នផលស្រូវជាមធ្យមបានកើនឡើងពី២,៧៤តោន នៅឆ្នាំ២០០៨ដល់៣,១៣តោនក្នុងមួយហិកតានៅឆ្នាំ២០១២ ជាមួយនឹងបរិមាណផលិតកម្មសរុប

កើនឡើងពី៧,១៧លានតោននៅឆ្នាំ២០០៨ដល់៩,៣១លានតោននៅឆ្នាំ២០១២ (២)ពិពិធកម្មមុខដំណាំក្រៅពីស្រូវ ដូចជាពោត ដំឡូងមី អំពៅ ស្វាយចន្ទី ម្រេច និងដំណាំផ្សេងទៀត ដោយអនុវត្តបានលើផ្ទៃដីសរុបកើនពី២១០ពាន់ហ.ត.នៅឆ្នាំ២០០៨ ដល់៧៧០ពាន់ហ.ត. នៅឆ្នាំ២០១២ ដោយឡែកការដាំដុះដំណាំកៅស៊ូ សម្រេចបានលើផ្ទៃដីសរុបប្រមាណជាង២៨០,៣៥ពាន់ហ.ត. គឺកើនឡើងជិត២ដងធៀបនឹងឆ្នាំ២០០៨ និង (៣)ទន្ទឹមនឹងការធានាបាននូវសន្តិសុខស្បៀង ការនាំចេញអង្ករជាផ្លូវការសម្រេចបាន២០០ពាន់តោន ក្នុងឆ្នាំ២០១២ ធៀបនឹងឆ្នាំ២០០៨ ដែលមានការនាំចេញតែបន្តិចបន្តួច រីឯការនាំចេញកៅស៊ូមានប្រមាណ៥០ពាន់តោនក្នុងឆ្នាំ២០១២ គឺកើនឡើង៣,៥ដង ធៀបនឹងឆ្នាំ២០០៨ ហើយការនាំចេញផលិត ផលផ្សេងទៀតកើនដល់ជិត ៥០ពាន់តោននៅឆ្នាំ២០១២ ធៀបនឹងជាង៣ពាន់តោននៅឆ្នាំ២០០៨។ ការដាក់ចេញនិងជំរុញការអនុវត្ត***គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ*** និង***យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០*** បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវសមិទ្ធផលទាំងអស់នេះ។

៤.៥៣- ក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងខិតខំរក្សាកំណើនក្នុងវិស័យកសិកម្មនេះឲ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ ដោយបន្តលើកកម្ពស់ផលិតភាព ធ្វើពិពិធភាវូបនីយកម្មនិងធ្វើពាណិជ្ជូបនីយកម្ម។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើះ

- ទី១ ការបន្តបង្កើនផលិតភាពស្រូវ និងដំណាំផ្សេងទៀត តាមរយៈការពង្រឹង ការពង្រីក និងការធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេសនិងព័ត៌មានទីផ្សារកសិកម្ម ដោយជំរុញសេវាទាំងនេះឲ្យមានរចនាសម្ព័ន្ធទៅដល់មូលដ្ឋាន ហើយផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្ត និងដៃគូដែលមានការពាក់ព័ន្ធ ការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍដើម្បីបង្កើនផលិតភាព និងបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ការផលិត និងការប្រើប្រាស់ពូជដែលមានគុណភាព និងឆ្លើយតបនឹងតម្រូវការទីផ្សារ ការបន្តវិនិយោគនិងការធ្វើវិចារណកម្មការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ការបន្តកែលម្អប្រព័ន្ធប្រមូលនិងទុកដាក់កសិផល ការរៀបចំនិងកែសម្រួលក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងការផលិតពូជ ការនាំចូលធាតុចូលកសិកម្ម ប្រព័ន្ធកសិកម្មតាមកិច្ចសន្យាដីកសិកម្ម សហគមន៍កសិកម្ម និងសហគមន៍អ្នកប្រើប្រាស់ទឹកព្រមទាំងការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យកសិកម្ម។
- ទី២ ការបន្តជំរុញពិពិធកម្ម តាមរយៈការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ ការផ្សព្វផ្សាយមុខដំណាំថ្មីៗ ដែលមានសក្តានុពលសម្រាប់ការដាំដុះ និងការនាំចេញ ការពង្រីកបរិស្ថានអនុគ្រោះ សម្រាប់ទាក់ទាញការវិនិយោគឯកជន ពិសេសក្នុងការស្រាវជ្រាវ ការផលិត ការចែកចាយពូជ និងការកែច្នៃកសិកម្ម ការបង្កើនកិច្ចសហប្រតិបត្តិការ

ជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ក្នុងការផ្ទេរចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិទ្យាថ្មីៗ ដល់កសិករនិងការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម។

ទី៣ ការបន្តលើកកម្ពស់ពាណិជ្ជូបនីយកម្ម តាមរយៈការជំរុញការអនុវត្តច្បាប់ និងគោលនយោបាយព្រមទាំងការពង្រឹងយន្តការស្ថាប័ន ដើម្បីជំរុញការធ្វើពាណិជកម្មនិងការនាំចេញកសិផល រួមមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីសហគមន៍កសិកម្ម ការលើកកម្ពស់សមត្ថភាពកែច្នៃ ការសម្រួលថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមមាននូវយន្តការ*ច្រកចេញចូលតែមួយ* ផង ការពង្រឹងប្រព័ន្ធឡូជិស្ទីក ការលើកស្ទួយគុណភាពកសិផលឲ្យស្របតាមបទដ្ឋានអន្តរជាតិ ការបង្កើនសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានតាមថ្លៃសមរម្យ ការលើកស្ទួយភាពជាដៃគូរវាងកសិករនិងពាណិជ្ជករ ក៏ដូចជារវាងកសិឧស្សាហកម្មខ្នាតធំ និងកសិកម្មលក្ខណៈគ្រួសារ។

ទី៤ ការបន្តជំរុញការអនុវត្ត*គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ* និង *យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០* ឲ្យសម្រេចជោគជ័យតាមការគ្រោងទុក។

ទី៥ ការខិតខំជំរុញឲ្យមានតម្លៃបន្ថែមសម្រាប់ដំណាំកើនឡើងពី៩៩៧ដុល្លារអាមេរិក ក្នុងមួយហិកតានៅឆ្នាំ២០០៧ដល់១ ៤៥០ដុល្លារអាមេរិកក្នុងមួយហិកតា នៅឆ្នាំ២០១៨។

ទី៦ ការជំរុញឲ្យអនុវត្តកម្មវិធីពិសេសសម្រាប់លើកកម្ពស់កសិករដែលពឹងផ្អែកលើកសិកម្មឲ្យទទួលបានសេវាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសម្រាប់ការងារកសិកម្ម ផលិតផលមានទីផ្សារនិងកំណត់តម្លៃច្បាស់លាស់។

ទី៧ ជំរុញកម្មវិធីសម្រាប់អភិរក្សដីកសិកម្ម និងការកែលម្អដីកសិកម្ម តាមរយៈ

- ➢ បង្កើតច្បាប់ដីកសិកម្មនិងលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារពីការផ្ទេរដីកសិកម្មទៅប្រើប្រាស់ក្នុងគោលដៅផ្សេង។
- ➢ បង្កើតលេខកូដបច្ចេកទេសលើការប្រើប្រាស់ដីកសិកម្មក្នុងគោលបំណងថែរក្សា និងកែលម្អជីជាតិដី។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៥៤- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* នឹងបន្តការងាររបស់ខ្លួនដើម្បីធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រវិស័យកសិកម្ម និងខិតខំស្វែងរកការគាំទ្រសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររបស់ខ្លួន តាមរយៈកម្មវិធីទូទាំងវិស័យ។ សកម្មភាពសំខាន់ៗរួមមាន៖

- ការលើកកម្ពស់ផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម

- ➢ ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តបម្រើឲ្យការងារស្រាវជ្រាវ ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យាគ្រប់កម្រិត។
- ➢ ពង្រឹងនិងពង្រីកសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកទេសផលិតកម្មនិងប្រព័ន្ធគ្រប់គ្រងដំណាំ។
- ➢ ពង្រឹងនិងពង្រីកការស្រាវជ្រាវ ការអភិវឌ្ឍ និងការបញ្ជ្រាប ការប្រើប្រាស់ពូជដំណាំមានគុណភាពនិងផលិតភាពខ្ពស់ទាំង១០មុខដែលសមស្របជាមួយស្ថានភាពកម្ពុជា។
- ➢ ពង្រឹងការគ្រប់គ្រងកែលម្អដីជាតិដី ដើម្បីទប់ស្កាត់ការបាត់បង់ដីជាតិដី។
- ➢ វាយតម្លៃនិងធ្វើចំណាត់ថ្នាក់ដីសម្រាប់តំបន់ដាំដុះ និងផែនការប្រើប្រាស់ដីធ្លី។
- ➢ ពង្រឹងនិងពង្រីកការយល់ដឹងចំណេះជំនាញស្តីពីការការពារដំណាំនិងការបង្កើនទិន្នផលដំណាំដោយប្រព័ន្ធគ្រប់គ្រងដំណាំចម្រុះ។
- ➢ ជំរុញការស្រាវជ្រាវ អភិវឌ្ឍ និងបញ្ជ្រាបការប្រើប្រាស់ធ្វើឲ្យប្រសើរឡើងនូវបច្ចេកវិទ្យាមុននិងក្រោយពេលប្រមូលផល ដើម្បីលើកកម្ពស់គុណភាពនិងកាត់បន្ថយការបាត់បង់ផលិតផល។
- ➢ ជំរុញការរៀបចំនិងអនុវត្តការអនុវត្តល្អក្នុងផលិតកម្មដំណាំកសិកម្ម ដើម្បីធានាគុណភាពផលិតផលនិងសុវត្ថិភាពចំណីអាហារ។
- ➢ ពង្រឹងសេវាអន្តរាគមន៍កម្ចាត់សមាសភាពចង្រៃនិងសង្គ្រោះផលដំណាំពីផលប៉ះពាល់ពីគ្រោះធម្មជាតិផ្សេងៗ។

- ការពង្រឹងប្រព័ន្ធនិងសេវាវិបុលកម្មកសិកម្ម
  - ➢ ត្រួតពិនិត្យឡើងវិញក្របខ័ណ្ឌនូវប្រព័ន្ធនិងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម។
  - ➢ ពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្មនិងភ្នាក់ងារផ្សព្វផ្សាយនៅមូលដ្ឋានភូមិ ឃុំ។
  - ➢ បង្កើតគោលការណ៍និងសៀវភៅណែនាំពីការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម។
  - ➢ ការសិក្សាវាយតម្លៃប្រព័ន្ធកេ្សត្រ-បរិស្ថាន នៅមូលដ្ឋាន ភូមិ ឃុំ។
  - ➢ បង្កើតមណ្ឌលកសិកម្មឃុំ សង្កាត់។
  - ➢ ការបង្កើតបង្ហុំបច្ចេកវិទ្យាកសិកម្ម។
  - ➢ ការសិក្សាវាយតម្លៃស្ថានភាពសេដ្ឋកិច្ចកសិកម្មរបស់គ្រួសារកសិករ។
  - ➢ សិក្សានិងវាយតម្លៃពីតម្រូវការព័ត៌មាន បច្ចេកវិទ្យាកសិកម្មរបស់កសិករ និងអ្នកប្រើប្រាស់។
  - ➢ ពង្រីកការទទួលបាននូវព័ត៌មានបច្ចេកទេសកសិកម្មតាមរយៈការផលិតចែកចាយឯកសារផ្សព្វផ្សាយកសិកម្មនិងការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសាធារណៈនិងការរៀបចំវេទិកាសាធារណៈផ្សេងៗ។
  - ➢ បង្កើតនិងដំណើរការ Tele Centers តាមឃុំនិងស្រុក។

- ការចងក្រងនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម
  - ➢ សិក្សាវាយតម្លៃតួនាទីរបស់អង្គការកសិករ និងសហគមន៍កសិកម្ម។
  - ➢ រៀបចំគោលការណ៍ណែនាំពីការអភិវឌ្ឍសហគមន៍កសិកម្ម។
  - ➢ បង្កើតបណ្តាញកសិធុរកិច្ចសហគមន៍កសិកម្ម។
  - ➢ រៀបចំសន្និបាតសហគមន៍កសិកម្មប្រចាំឆ្នាំ។
  - ➢ កសាងហេដ្ឋារចនាសម្ព័ន្ធគំរូដល់សហគមន៍កសិកម្ម។
  - ➢ ពង្រឹងសមត្ថភាពដល់មន្ត្រីលើការងារដំណើរការ និងគាំទ្រសហគមន៍។
  - ➢ ជំរុញការរៀបចំពិព័រណ៍ផលិតផលរបស់សហគមន៍កសិកម្មតាមបណ្តាស្រុក ខេត្តនិងថ្នាក់ជាតិ។
- ជំរុញការប្រើប្រាស់និងគ្រប់គ្រងដីកសិកម្ម
  - ➢ កសាងគោលនយោបាយដីកសិកម្ម។
  - ➢ រៀបចំច្បាប់ដីកសិកម្ម និងពិគ្រោះយោបល់។
  - ➢ ផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងភាពការចុះខិនភាពដី។
  - ➢ ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយសម្រាប់អភិរក្សដីកសិកម្ម។
  - ➢ គោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការប្រើប្រាស់ដីកសិកម្មនិងការគ្រប់គ្រងសម្រាប់ដំណាំនិងផលិតកម្មកសិកម្ម។
  - ➢ ស្រាវជ្រាវនិងអនុវត្តពីការគ្រប់គ្រងនិងការប្រើប្រាស់ដី កាត់បន្ថយនិងបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងកាត់បន្ថយគ្រោះមហន្តរាយ។
  - ➢ ធ្វើឲ្យប្រសើរឡើង ការកែលម្អដីនិងគុណភាពដីឡើងវិញសម្រាប់ធានាចីរភាពនៃការគ្រប់គ្រងដី។
  - ➢ ធ្វើការវាយតម្លៃនិងធ្វើចំណាត់ថ្នាក់ដីសម្រាប់ការរៀបចំផែនទី។
  - ➢ រៀបចំផែនការប្រើប្រាស់ដីកសិកម្មនិងកំណត់តំបន់ដាំដុះ។
  - ➢ វាយតម្លៃពីតម្រូវការប្រើប្រាស់ទឹកលើដំណាំពាក់ព័ន្ធនឹងប្រភេទដីផ្សេងៗ។
- ការជំរុញការធ្វើយន្តូបនីយកម្មកសិកម្ម
  - ➢ លើកស្ទួយការធ្វើយន្តូបនីយកម្ម តាមរយៈជម្រើសយន្តូបនីយកម្មកសិកម្មសម្រាប់ប្រទេសកម្ពុជានិងការធ្វើឲ្យប្រសើរឡើងនូវខ្សែចង្វាក់ផ្គត់ផ្គង់គ្រឿងយន្តកសិកម្ម។
  - ➢ ពង្រឹងការអភិវឌ្ឍជំនាញបច្ចេកទេសគ្រឿងយន្តកសិកម្ម និងការប្រើប្រាស់គ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម។
  - ➢ ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាមុននិងក្រោយពេលប្រមូលផលដោយគ្រឿងយន្ត។

- ➢ លើកកម្ពស់ការយល់ដឹងអំពីបច្ចេកទេសការរៀបចំហេដ្ឋារចនាសម្ព័ន្ធដីស្រែ ចម្ការ ដើម្បីចូលរួមចំណែកធ្វើឲ្យកាន់តែប្រសើរផលិតភាពកសិកម្ម។
- ➢ ជំរុញការបង្កើតបណ្ដាញស្ថាប័នស្រាវជ្រាវ ពាណិជ្ជករ ផលិតករ អាជីវករគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម និងសហគមន៍កសិករ។

- ការជំរុញលទ្ធភាពនៃការចូលដល់ទីផ្សារសម្រាប់ផលិតផលកសិកម្ម
  - ➢ ជំរុញការរៀបចំបទដ្ឋានជាតិស្ដីពីដំណាំកសិកម្មសំខាន់ៗ។
  - ➢ ពង្រឹងនិងពង្រីកសមត្ថភាពពិសោធ វិភាគ និងសេវាត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម។
  - ➢ ពង្រឹងការអង្កេតស្រាវជ្រាវ តាមដាននិងត្រួតពិនិត្យគុណភាពកសិផល ចរាចរនៅលើទីផ្សារ។
  - ➢ ជំរុញការផ្សព្វផ្សាយអំពីតម្រូវការនិងលក្ខខណ្ឌទីផ្សារក្នុងស្រុក តំបន់ និងពិភពលោកដល់អ្នកពាក់ព័ន្ធ។
- ការពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់ និងអភិវឌ្ឍធនធានមនុស្ស
  - ➢ ជំរុញការកសាងសេចក្ដីព្រាងច្បាប់ស្ដីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ និងសេចក្ដីព្រាងច្បាប់ស្ដីពីការប្រើប្រាស់និងគ្រប់គ្រងដីកសិកម្ម។
  - ➢ ជំរុញការកសាងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ និងច្បាប់ស្ដីពីសហគមន៍កសិកម្ម។
  - ➢ បន្តលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រក្នុងវិស័យកសិកម្ម។
  - ➢ ពង្រឹងសមត្ថភាពលើការកសាងបទដ្ឋានបច្ចេកទេស និងគតិយុត្តពាក់ព័ន្ធនឹងសេវាពិសោធន៍វិភាគក្នុងមន្ទីរពិសោធន៍។

## ការអភិវឌ្ឍនិងការស្រាវជ្រាវកសិកម្ម

- សមូហកម្មអភិរក្ស វាយតម្លៃ និងប្រើប្រាស់ធនធានពន្ធុរុក្ខជាតិទាំងអស់ដែលមានគុណប្រយោជន៍សម្រាប់ស្បៀងនិងកសិកម្ម។
- អភិវឌ្ឍពូជស្រូវទំនាបរំពឹងទឹកភ្លៀងដែលធន់នឹងកត្តាមិនអំណោយផលផ្នែកជីវៈនិងអជីវៈព្រមទាំងមានទិន្នផលខ្ពស់និងគុណភាពល្អ។
- អភិវឌ្ឍពូជស្រូវស្រាលមានទិន្នផលខ្ពស់គុណភាពអង្ករល្អហើយធន់នឹងមមាចត្នោត និងជំងឺរលាកគែមស្លឹកបណ្ដាលមកពីបាក់តេរី។
- អភិវឌ្ឍពូជដំណាំពពួកសណ្ដែក ពោត ស្វាយ និងបន្លែដែលមានទិន្នផលខ្ពស់ និងគុណភាពល្អ។
- ជំរុញប្រព័ន្ធផលិតកម្មនិងការប្រើប្រាស់គ្រាប់ពូជដំណាំដែលបានបញ្ចេញដោយកាឌី។

- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសគ្រប់គ្រងដីប្រកបដោយចីរភាព និងកំណត់តម្រូវការសារធាតុចិញ្ចឹមរបស់ដំណាំសម្រាប់ប្រព័ន្ធផលិតកម្មដំណាំស្រូវជាមូលដ្ឋាន (១)ស្រូវដើមរដូវនិងស្រូវវស្សា (២)ស្រូវប្រដេញទឹក និងស្រូវមុនទឹកចូល និង (៣)ស្រូវស្រោចស្រពពេញលេញធ្វើ៣ដង និងដំណាំជីវថាមពល ដំឡូងមី។
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យានិងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសប្រើប្រាស់និងគ្រប់គ្រងទឹកស្រោចស្រពដំណាំប្រកបដោយចីរភាពទាំងលក្ខណៈសេដ្ឋកិច្ចនិងបរិស្ថាន។
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍឧបករណ៍កសិកម្ម និងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសមុនប្រមូលផលដំណាំ ដើម្បីឆ្លើយតបនឹងបរិបទនៃការប្រើប្រាស់គ្រឿងយន្តកសិកម្មដើម្បីរួមចំណែកបង្កើនផលិតភាពនិងពិពិធកម្មដំណាំកសិកម្ម។
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យានិងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសគ្រប់គ្រងសមាសភាពចង្រៃ៖ សត្វកណ្តុរ ខ្យងពណ៌មាស សត្វល្អិត ជំងឺ និងស្មៅ លើដំណាំកសិកម្ម ដោយផ្តោតសំខាន់លើវិធានការទប់ស្កាត់ជាមុននិងការកម្ចាត់ ហើយរក្សាបាននូវស្ថិរភាពទិន្នផលដំណាំនិងគុណភាពផលិតផល ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចនិងបរិស្ថាន។
- អភិវឌ្ឍបង្គុំបច្ចេកវិទ្យាប្រព័ន្ធផលិតកម្មដំណាំស្រូវជាមូលដ្ឋានដែលមានលក្ខណៈសេដ្ឋកិច្ចនិងបរិស្ថានសម្រាប់តំបន់ទំនាបរំពឹងទឹកភ្លៀង តំបន់ស្រោចស្រពពេញលេញ និងតំបន់ចម្ការ។
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យា និងវិធានការសមស្របសម្រាប់ផលិតកម្មដំណាំនៅតំបន់ឆ្នេរសមុទ្រ ដែលអាចប្រឈមនឹងការកើនឡើងនៃនីវ៉ូទឹកសមុទ្រ ដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាកសិកម្មដែលជួយកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។ ទន្ទឹមនឹងនេះចូលរួមសិក្សាអំពីប្រសិទ្ធភាពនៃបច្ចេកវិទ្យាថ្មីៗ ដែលកំពុងអនុវត្តដោយផ្តោតលើការតាមដានវាយតម្លៃឥទ្ធិពលរបស់វាលើការប្រែប្រួលអាកាសធាតុ។
- សិក្សា ស្រាវជ្រាវ និងអភិវឌ្ឍចំណេះដឹងមូលដ្ឋាន សម្រាប់ប្រើប្រាស់ក្នុងគោលបំណងធានារ៉ាប់រងដំណាំកសិកម្មក្នុងស្ថានភាពនៃសេដ្ឋកិច្ចកំពុងលូតលាស់។
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាក្នុងប្រព័ន្ធគ្រប់គ្រងទីជម្រាលចម្រុះឲ្យកាន់តែមានផលិតភាពនិងនិរន្តរភាពដើម្បីរួមចំណែកលើកកម្ពស់សកម្មភាពអនុវត្តល្អក្នុងការប្រើប្រាស់ធនធានដីនិងទឹក។
- សិក្សាស្រាវជ្រាវអំពីកសិកម្មអភិរក្សសម្រាប់លក្ខខណ្ឌក្នុងប្រទេសកម្ពុជា។

- សិក្សា ស្រាវជ្រាវក្នុងផលិតកម្មជាក់ស្ដែងលើប្រសិទ្ធភាពសម្ភារៈឧបករណ៍ និងម៉ាស៊ីនសម្រាប់បម្រើឲ្យការប្រមូលផលវេចខ្ចប់ដឹកជញ្ជូនទុកដាក់ប្រកបដោយសុវត្ថិភាពនិងធានាបាននូវការបាត់បង់ទាប។
- សិក្សាពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅលើគុណភាពគ្រាប់ធញ្ញជាតិបន្លែ និងផ្លែឈើក្នុងសកម្មភាពក្រោយប្រមូលផលនិងការកែច្នៃបឋមនូវផលិតផលកសិកម្ម។
- ធ្វើការស្រាវជ្រាវនិងអភិវឌ្ឍឧបករណ៍ប្រើប្រាស់ សម្រាប់បម្រើឲ្យការងារក្រោយប្រមូលផលដំណាំគ្រប់ប្រភេទ។
- សិក្សាវាយតម្លៃសមត្ថភាពជនបទក្នុងការបន្សុំាទៅនឹងបម្រែបម្រួលអាកាសធាតុដូចជាគ្រោះទឹកជំនន់ និងរាំងស្ងួត ក្នុងវិស័យកសិកម្ម។
- សិក្សាវាយតម្លៃឥទ្ធិពលនៃការទទួលយកនិងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗរបស់កាឌីទៅលើសង្គម សេដ្ឋកិច្ចជនបទ។
- ធ្វើឲ្យកាន់តែប្រសើរឡើងនូវទូរគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មាន ការយល់ដឹងជាសាធារណៈ ការបើកវគ្គបណ្តុះបណ្តាលនិងការផ្ទេរចំណេះដឹងបច្ចេកវិទ្យាដើម្បីលើកស្ទួយជីវភាពកសិករ។
- ពង្រឹងសមត្ថភាពនិងទេពកោសល្យរបស់អ្នកស្រាវជ្រាវ និងអ្នកផ្សព្វផ្សាយតាមរយៈការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស។

## ៣.២- ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម

៤.៥៥- រាជរដ្ឋាភិបាលបានអនុវត្តកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យជលផល ដោយលុបចោលឡូត៍នេសាទទាំងស្រុង ហើយផ្តល់ជូនប្រជាជនធ្វើការនេសាទជាលក្ខណៈគ្រួសារ ទន្ទឹមនឹងការពង្រឹងនិងពង្រីកការរៀបចំសហគមន៍នេសាទ និងតំបន់អភិរក្សជលផល ព្រមទាំងបានអនុវត្តយ៉ាងសកម្មនូវវិធានការការពារព្រៃលិចទឹក ជាពិសេស នៅជុំវិញបឹងទន្លេសាប ដែលជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅ និងជាកន្លែងបន្តពូជរបស់មច្ឆជាតិជាច្រើនប្រភេទ។

៤.៥៦- ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលមានគោលដៅជំរុញលើកកម្ពស់ចលនាចិញ្ចឹមសត្វ និងវារីវប្បកម្មឲ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយដោយផ្អែកលើគោលការណ៍ខ្សែចង្វាក់ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍវិស័យទាំងនេះ ដោយគិតគូរផងដែរដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេស អនាម័យ និងភូតគាមអនាម័យ ទន្ទឹមនឹងការបន្តអនុវត្តវិធានការមុតស្រួចនានា សំដៅធានាចីរភាពនៃធនធានជលផលទាំងក្នុងដែនទឹកសាបនិងសមុទ្រ។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១ ការបន្តជំរុញអនុវត្ត **ក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ២០១០-២០១៩** សំដៅបង្កើនផលិតផលត្រី ដើម្បីធានាសេចក្តីត្រូវការរបស់ប្រជាជន និងទីផ្សារនាំចេញ ដោយផ្តោតសំខាន់លើសសរស្តម្ភបី គឺ(១)ជលផលទឹកសាប និងសមុទ្រ (២)វារីវប្បកម្មទឹកសាបនិងសមុទ្រ និង(៣)ការកែច្នៃនិងពាណិជ្ជកម្ម។

ទី២ ការជំរុញរៀបចំនិងដាក់ឲ្យអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការចិញ្ចឹមសត្វ។

ទី៣ ការជំរុញការលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍលើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ ការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋាន ទាំងក្នុងវិស័យបសុសត្វ និងវារីវប្បកម្ម។

ទី៤ ការជំរុញអនុម័តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំស្ថាប័ន និងគ្រប់គ្រងវិស័យនេះ ក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដាអនាម័យលើផលិតផលពីសត្វ ការពង្រឹងនិងជំរុញអនុវត្តវិធានការអនាម័យសត្វ ភូតគាមអនាម័យដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ក៏ដូចជាដើម្បីការពារសុខភាពសាធារណៈ។

ទី៥ ការជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ក្នុងទ្រង់ទ្រាយមធ្យម និងធំ ដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន និងការរកទីផ្សារជូនកសិករ ការលើកកម្ពស់ការវិនិយោគឯកជនក្នុងការកែច្នៃផលិតផលបសុសត្វ និងផលិតផលជលផល ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលពាណិជ្ជកម្មលើបសុសត្វ និងផលិតផលមានដើមកំណើតពីសត្វនិងផលិតផលជលផល។

៤.៥៧- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពខាងលើ ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*** នឹង៖

- ជំរុញការរៀបចំកសាងច្បាប់។
- អភិវឌ្ឍធនធានមនុស្សក្នុងវិស័យផលិតកម្មនិងបសុព្យាបាលឲ្យកាន់តែមានប្រសិទ្ធភាព។
- បង្កើនប្រសិទ្ធភាពការផ្តល់សេវាបសុព្យាបាល និងចាត់វិធានបសុពេទ្យក្នុងគោលបំណងកាត់បន្ថយអត្រាសត្វឈឺនិងងាប់។
- ការធ្វើឲ្យប្រសើរឡើងនូវសុខភាពសាធារណៈពិសេសជំងឺឆ្លងពីសត្វទៅមនុស្ស និងសុវត្ថិភាពម្ហូបអាហារមានប្រភពពីសត្វ។
- ជំរុញធ្វើឲ្យប្រសើរឡើងនូវផលិតកម្មចំណីសត្វ និងធ្វើឲ្យប្រសើរឡើងនូវពូជសត្វ និងការបង្កាត់ពូជសត្វ ដោយប្រើប្រាស់តាមបច្ចេកវិទ្យាទំនើបថ្មី (ការបង្កាត់តាមបែបសិប្បនិម្មិត)។

- ជំរុញការកែច្នៃលាមកសត្វ តាមរយៈការបង្កើតឡជីវឧស្ម័ន។
- ជំរុញការកែទម្លាប់ការចិញ្ចឹមសត្វរបស់កសិករពីលក្ខណៈគ្រួសារទៅជាបែបពាណិជ្ជកម្ម ដោយមានជីវសុវត្ថិភាពនៅកន្លែងមានឡជីវឧស្ម័ន។
- បង្កើននិងពង្រឹងការស្រាវជ្រាវ និងផ្សព្វផ្សាយលើការងារសុខភាពសត្វនិងផលិតកម្មសត្វ។
- ជំរុញឲ្យប្រសើរឡើងនូវឥណទានក្នុងការសាងសង់ឡជីវឧស្ម័ននិងការចិញ្ចឹមសត្វ។
- លើកទឹកចិត្តនិងជំរុញការវិនិយោគលើការចិញ្ចឹមសត្វ សេវាសុខភាពសត្វ និងធ្វើឲ្យប្រសើរឡើងនូវទីផ្សារសត្វសាច់និងផលិតផលមានដើមកំណើតពីសត្វ។
- បង្កើនការស្វែងរកនិងបន្តកិច្ចសហប្រតិបត្តិការទ្វេភាគី អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍនិងផ្នែកឯកជនដទៃផ្សេងៗទៀត ក្នុងការគាំទ្រអនុវិស័យនេះទាំងផ្នែកបច្ចេកទេស និងថវិកា។

### វិស័យកសិឧស្សាហកម្ម

៤.៥៨- ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*** បានលើកឡើងនូវវិធានការយុទ្ធសាស្ត្រនិងសម្មភាពអាទិភាពមួយចំនួន រួមមានដូចខាងក្រោម៖

- បង្កើតប្រព័ន្ធផ្តល់ព័ត៌មានអំពីសហគ្រាសអ្នកផលិតកែច្នៃនិងផលិតផលកសិកម្ម។
- ការផ្តល់សេវាគាំទ្របច្ចេកទេសដល់តំបន់ជនបទ។
- ពង្រឹងការអនុវត្តក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។
- ពង្រឹងការអភិវឌ្ឍភាពជាដៃគូ។
- បង្កើនការរៀបចំក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។
- ការពង្រឹងសមត្ថភាពស្ថាប័ននិងមន្ត្រីជំនាញ។
- កាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការអភិវឌ្ឍកសិឧស្សាហកម្មល្អ។
- ការឆ្លើយតបចំពោះយេនឌ័រក្នុងវិស័យកសិឧស្សាហកម្ម។
- ការពង្រឹងសមត្ថភាពនៃការកែច្នៃនិងវេចខ្ចប់។

### ការអភិវឌ្ឍអនុវិស័យកៅស៊ូ

៤.៥៩- ការអភិវឌ្ឍអនុវិស័យកៅស៊ូ គឺផ្អែកទៅលើក្របខ័ណ្ឌ **យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា ឆ្នាំ២០១១-២០២០** ដែលក្នុងនោះមានស្នូលយុទ្ធសាស្ត្រចំនួន៦ ដែលបានរៀបចំសម្រាប់អនុវត្ត រួមមាន៖

- ការធានាគុណភាពនិងផលិតភាពនៃការដាំដុះកៅស៊ូ។

- ការសិក្សាអំពីលទ្ធភាពប្រើប្រាស់ដោយស្របច្បាប់នូវសក្តានុពលដីទំនេរ ដែលកបទៅនឹងដំណាំកៅស៊ូ។
- ការជំរុញការដាំដុះកៅស៊ូគ្រួសារ និងសហគមន៍អ្នកដាំកៅស៊ូ។
- ការជំរុញចម្ការកៅស៊ូឧស្សាហកម្ម ដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ។
- ការជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឲ្យបានល្អ។
- ការពង្រឹង និងកែលម្អតួនាទីដឹកនាំរបស់***អគ្គនាយកដ្ឋានកៅស៊ូ***។

**តារាងទី៤.១ ផ្ទៃដីកៅស៊ូពីឆ្នាំ២០១២-២០១៨**

| ប្រភេទចម្ការកៅស៊ូ | ឯកតា | តាមឆ្នាំ | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | |
| ចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) | ហ.ត. | ៥៤ ៣៦០ | ១ ០០០ | ១ ០០០ | ១ ០០០ | ១ ០០០ | | | ៥៨ ៣៦០ |
| ចម្ការកៅស៊ូកសិឧស្សាហកម្ម (ដីសម្បទានសេដ្ឋកិច្ច) | ហ.ត. | ១១៨ ៤៤៩ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ២២៣ ៤៤៩ |
| ចម្ការកៅស៊ូគ្រួសារ | ហ.ត. | ១០៧ ៦៩៦ | ៥ ០០០ | ៧ ០០០ | ៧ ០០០ | ៦ ០០០ | ៥ ០០០ | ៣០០០ | ១៤០ ៦៩៦ |
| សរុបរួម | | ២៨០ ៥០៥ | ២៦ ០០០ | ២៨ ០០០ | ២៨ ០០០ | ២២ ០០០ | ២០ ០០០ | ១៨ ០០០ | ៤២២ ៥០៥ |

*ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

**តារាងទី៤.២ ផ្ទៃដីចៀរជ័រ ថែទាំ និងទិន្នផលកៅស៊ូឆ្នាំ២០១២-២០១៨**

| ឆ្នាំ | ផ្ទៃដី (ហត) | | | ផលិតផល | ទិន្នផល |
|---|---|---|---|---|---|
| | ចៀរជ័រ | ថែទាំ | សរុប | (តោន) | គ.ក្រ/ហ.ត/ឆ្នាំ |
| **២០១២** | ៥៥ ៣៦១ | ២២៤ ៩៩៣ | ២៨០ ៣៥៤ | ៦៤ ៥២៥ | ១ ១៦៦ |
| **២០១៣** | ៧៩ ៦៣៦ | ២២៥ ៨៧០ | ៣០៥ ៥០៦ | ១០២ ៩៧៩ | ១ ២៩៣ |
| **២០១៤** | ១០៩ ៣៨១ | ២២៥ ១២៥ | ៣៣៤ ៥០៦ | ១៣៧ ៥២៤ | ១ ២៥៧ |
| **២០១៥** | ១៤១ ៦១៦ | ២២០ ៨៩០ | ៣៦២ ៥០៦ | ១៨១ ៥៥៧ | ១ ២៨២ |
| **២០១៦** | ១៨៣ ៦៣២ | ២០០ ៨៧៤ | ៣៨៤ ៥០៦ | ២៤០ ៨០១ | ១ ៣១១ |
| **២០១៧** | ២១៩ ១៣៧ | ១៨៥ ៣៦៨ | ៤០៤ ៥០៦ | ៣០០ ៧៩៣ | ១ ៣៧៣ |
| **២០១៨** | ២៧៨ ៥០៦ | ១៤៤ ០០០ | ៤២២ ៥០៦ | ៣៨០ ៩៣៤ | ១៣ ៦៨ |

*ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

៤.៦០- សូចនាករសំខាន់ៗ ដែលបង្ហាញពីវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីរបស់ ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*** មានបង្ហាញនៅក្នុងតារាងទី៤.៣ ខាងក្រោម ។

## តារាងទី៤.៣ សូចនាករសំខាន់ៗរបស់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| សូចនាករសំខាន់ៗ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ទិន្នផលស្រូវ | តោន/ ហ.ត. | ៣,១៥ | ៣,១៨ | ៣,២១ | ៣,២៣ | ៣,២៥ |
| ផ្ទៃដីដាំដុះដំណាំស្រូវ | លានហ.ត. | ៣,១០ | ៣,១៥ | ៣,២០ | ៣,២៨ | ៣,៣៤ |
| បរិមាណផលស្រូវ | លានតោន | ៩,៧៦ | ១០,០១ | ១០,២៨ | ១០,៥៦ | ១០,៨៥ |
| ផលិតផលស្រូវផលិតលើស | លានតោន | ៥,២៤ | ៥,៤១ | ៥,៦០ | ៥,៧៩ | ៦,០០ |
| ផ្ទៃដីសម្រាប់ដំណាំគ្រប់ប្រភេទ (រួមទាំង ដំណាំអចិន្ត្រៃយ៍និងចម្ការ) | ពាន់ហ.ត. | ៤ ៨១៤ ៥៣៤ | ៥ ០២៤ ៥៣៤ | ៥ ២៣៤ ៥៣៤ | ៥ ៤៤៤ ៥៣៤ | ៥ ៦៥៤ ៥៣២ |
| សហគមន៍កសិកម្ម | ចំនួន | ៤៧៥ | ៥៧៥ | ៦៧៥ | ៧៧៥ | ៨៧៥ |
| ផលិតកម្មសត្វគ្រប់ប្រភេទក្នុងកំណើន៣% | លានក្បាល | ៣៥,៨៦ | ៣៦,៩៣ | ៣៨,០៣ | ៣៩,១៧ | ៤០,៣៤ |
| សត្វដែលទទួលបានវ៉ាក់សាំង | % | ១០ | ១២ | ១៥ | ១៧ | ២០ |
| ចំនួនសត្តឃាតដ្ឋានដែលអនុវត្តអនាម័យល្អតាមបទដ្ឋានបច្ចេក-ទេស | ចំនួនកន្លែង | ២៥ | ៥០ | ៧៥ | ១០០ | ១២៥ |
| ផ្ទៃដីដាំដុះកៅស៊ូ | លានហ.ត. | ៣០៦ ៥០០ | ៣៣៤ ៥០០ | ៣៦២ ៥០០ | ៣៨៤ ៥០០ | ៤០៤ ៥០០ |
| ទិន្នផលជ័រ | គ.ក្រ/ហ.ត./ឆ្នាំ | ១២៥៧ | ១២៨២ | ១៣១១ | ១៣៧៣ | ១៣៦៨ |
| បរិមាណផលជ័រកៅស៊ូស្ងួត | តោន | ១៣៧ ៥២០ | ១៨១ ៥៦០ | ២៤០ ៨០០ | ៣០០ ៨០០ | ៣៤០ ៩៣០ |
| ផលិតកម្មវារីវប្បកម្មកើន ១៥% | តោន | ៩៧ ៨០០ | ១១២ ៥០០ | ១២៩ ៤០០ | ១៤៨ ៨០០ | ១៧១ ១៧០ |
| បរិមាណផលិតកម្មនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | ពាន់តោន | ៧៥២ | ៧៩០ | ៨២៩ | ៨៧០ | ៩១០ |
| ចំនួនសហគមន៍នេសាទសមត្ថភាព | សហគមន៍ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ |
| ផ្ទៃដីអភិរក្សសត្វព្រៃនិងព្រៃការពារ | ហ.ត. | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ |
| ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើត | ចំនួន | ៣២ | ៣២ | ៣២ | ៣២ | ៣២ |

*ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

## ៣.៣- កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៥

៤.៦១- ក្នុងនីតិកាលកន្លងទៅ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗជាច្រើនគួរឲ្យកត់សម្គាល់ មានជាអាទិ៍ការអនុម័តច្បាប់ស្តីពីអស្សាមិករណ៍ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងវិស័យនគរូបនីយកម្ម សំណង់ និង វិស័យដីធ្លី ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីចំនួនជាង៣លានបណ្ណ តាមរយៈការចុះបញ្ជីក្នុងក្របខ័ណ្ឌផែនការទូទៅ និងការអនុវត្ត "***គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី***" ការបែងចែកដីក្រោមរូបភាពសម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្មដែលមានចំនួនសរុបជាង៥៣ពាន់គ្រួសារ ការចុះបញ្ជីដីរដ្ឋទំហំធំៗ ការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ការចុះបញ្ជីសិទ្ធិជួលរយៈពេលវែង និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ និងកាត់បន្ថយវិវាទដីធ្លី តាមរយៈយន្តការដែលមានស្រាប់ និងក្នុងក្របខ័ណ្ឌ "***គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី***"។ ដោយឡែក លទ្ធផលក្នុងការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីគោលដៅនៃការបង្កើនផ្ទៃដីសម្រាប់ការអភិវឌ្ឍត្រូវបានរំលេចតាមរយៈការកើនឡើងគួរឲ្យកត់សម្គាល់នៃទំហំផ្ទៃដី ដែលត្រូវបានបោសសម្អាតរួចពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។

៤.៦២- ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តកាន់តែសកម្ម និងស៊ីជម្រៅថែមទៀត នូវកំណែទម្រង់ដីធ្លី ដោយផ្តោតលើការពង្រឹងការគ្រប់គ្រង ការរៀបចំ ការប្រើប្រាស់ និងការបែងចែកដីធ្លី ដើម្បីរួមចំណែកធ្វើឲ្យសម្រេចគោលដៅជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាន និងធនធានធម្មជាតិ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ក្នុងបរិការណ៍នៃសេដ្ឋកិច្ចទីផ្សារ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពលើ៖

- ទី១ ការបន្តជំរុញរៀបចំគោលនយោបាយដីធ្លីទូលំទូលាយ ***សៀវភៅសដីធ្លី***។
- ទី២ ការជំរុញរៀបចំច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម និងច្បាប់ស្តីពីដីកសិកម្ម។
- ទី៣ ការបន្តជំរុញល្បឿននៃការចុះបញ្ជី និងការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ ដីឯកជន និងដីសហគមន៍ជនជាតិដើមភាពតិច តាមរយៈការចុះបញ្ជីក្នុងក្របខ័ណ្ឌផែនការទូទៅ និងការបន្តអនុវត្ត***គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី*** ដោយផ្តល់អាទិភាពលើតំបន់ដែលគ្មានវិវាទ ដើម្បីធានាសុវត្ថិភាព និងទំនុកចិត្តក្នុងការកាន់កាប់ដីធ្លី។

ទី៤ ការបន្តជំរុញកសាងទិន្នន័យអំពីការគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីជាមូលដ្ឋានច្បាស់លាស់ក្នុងការរៀបចំផែនការប្រើប្រាស់ និងបែងចែកដីធ្លីឲ្យបានត្រឹមត្រូវ ជាអាទិ៍ ដីសម្រាប់កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ ជនបទ ទីក្រុង លំនៅឋាន និងអភិរក្សសំដៅធ្វើវិចារណកម្មនៃការប្រើប្រាស់ដី ចៀសវាងការប្រើប្រាស់ដី និងការបំប្លែងការប្រើប្រាស់ដីមិនចំសក្តានុពល។ ការយកចិត្តទុកដាក់នឹងត្រូវផ្តោតទៅលើការបន្តជំរុញកិច្ចការស្រាវជ្រាវនិងការរៀបចំចំណាត់ថ្នាក់ដីទៅតាមប្រភេទមានសក្តានុពល អំណោយផលដល់ផលិតកម្មកសិកម្មតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ទី៥ ការបន្តធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព ដើម្បីរក្សាចីរភាពបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច ព្រមទាំងការទប់ស្កាត់រាល់ការទន្ទ្រានដីព្រៃ និងការចាត់វិធានការតឹងរ៉ឹងចំពោះបុគ្គលដែលរំលោភកាន់កាប់ដីគ្រប់ប្រភេទដោយខុសច្បាប់ និងប្រមូលដីទុកមិនផលិត រួមទាំងការបន្តដកហូតមកវិញនូវសម្បទានដីសេដ្ឋកិច្ច ដែលក្រុមហ៊ុនមិនគោរពតាមកិច្ចសន្យានិងបទដ្ឋានគតិយុត្តជាធរមាន ទន្ទឹមនឹងការឈប់ផ្តល់ថែមទៀតនូវសម្បទានសេដ្ឋកិច្ច។

ទី៦ ការបន្តបែងចែក និងប្រើប្រាស់ដីរដ្ឋ ជាពិសេសដីសម្បទានសេដ្ឋកិច្ច ដែលត្រូវបានដកហូតមកវិញ និងផ្ទៃដី ដែលត្រូវបានបោសសម្អាតមីនរួច និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីបម្រើប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយតម្លាភាពនិងសមធម៌ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជនក្រីក្រ យោធិនពិការ គ្រួសារយោធិនពលី និងមរណៈនិងអតីតកងកម្លាំងប្រដាប់អាវុធដែលគ្មាន ឬខ្វះដីពិតប្រាកដ តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្ម។

ទី៧ ការបន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីកសិកម្មជាលក្ខណៈគ្រួសារ និងការបន្តជួយប្រជាកសិករ ក្នុងការលើកកម្ពស់ផលិតភាពនៃការប្រើប្រាស់ដី តាមរយៈការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ធារាសាស្ត្រនិងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងទៀត។

ទី៨ ការបន្តដោះស្រាយវិវាទដីធ្លី ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងយុត្តិធម៌ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន តាមរយៈយន្តការដោះស្រាយវិវាទដីធ្លីទាំងក្នុងនិងក្រៅប្រព័ន្ធតុលាការ។

ទី៩ ការបន្តជំរុញអនុវត្ត ***ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១០-២០១៩*** ជាពិសេសការបន្តបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីបង្កើនផ្ទៃដីដាំដុះធានាសុវត្ថិភាពក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងកាត់បន្ថយបន្ថែមទៀតនូវអគ្រាគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៦៣- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*** មានផែនការសកម្មភាពដូចខាងក្រោម៖

### រដ្ឋបាលដីធ្លី

- វាស់វែងដីធ្លី និងផ្តល់កម្មសិទ្ធិដីជូនប្រជាពលរដ្ឋ ក្នុងក្របខ័ណ្ឌនៃការអនុវត្ត "***គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី***" ដែលទាក់ទងនឹងដីរដ្ឋទាំង៣ប្រភេទ គឺ ដីរដ្ឋក្នុងដីព្រៃសម្បទាន ដីរដ្ឋក្នុងដីសម្បទានសេដ្ឋកិច្ចនិងដីរដ្ឋដែលមានដីការដកហូត។
- ទប់ស្កាត់មិនឲ្យកើតមានសកម្មភាពទន្ទ្រានយកដីរដ្ឋបន្តទៀត នៅក្រោយថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២។
- ជំរុញការចុះបញ្ជីដីគ្រប់ប្រភេទ (ការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជីអាគារសហកម្មសិទ្ធិ ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដោយជំរុញការដោះស្រាយទំនាស់ទន្ទឹមគ្នាសម្រេចឲ្យបានតាមផែនការ (ឆ្នាំ២០១៤ សម្រេចឲ្យបាន៥២% ឆ្នាំ២០១៥ ៥៧% និងឆ្នាំ២០១៨ ៧០%) លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីប៉ាន់ស្មានសរុប៦ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។
- គាក់តែងបញ្ចប់សេចក្តីព្រាងច្បាប់ភូមិបាលថ្មី និងបទប្បញ្ញត្តិពាក់ព័ន្ធដែលចាំបាច់មាន ដូចជាច្បាប់ស្តីពីសិទ្ធិបុព្វក្រ័យ ច្បាប់ស្តីពីអនុប្បយោគ ច្បាប់ស្តីពីពន្ធលើដីធ្លី ការវាស់វែងដីធ្លី ការបំបែកក្បាលដី។ល។
- បញ្ចប់សេចក្តីព្រាងគោលនយោបាយដីធ្លីទូលំទូលាយ និងស្នើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី។
- ការតាក់តែង និងអនុម័តនូវសេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្ត និងការកសាងផែនទីវាយតម្លៃថ្លៃអចលនទ្រព្យឲ្យបានស្របតាមស្ថានភាពជាក់ស្តែងរបស់សង្គមជាតិ។
- ការតាក់តែងនិងអនុម័តនូវសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីប្រព័ន្ធព័ត៌មានដីធ្លី និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្ត។
- ការតាក់តែង និងអនុម័តនូវសេចក្តីព្រាងគោលនយោបាយ និងការបង្កើតប្រព័ន្ធច្រកចេញចូលតែមួយលើការងារសុរិយោដី។

- ការសិក្សាអំពីប្រភេទនៃសិទ្ធិកាន់កាប់ដី ដែលអាចផ្តល់ដល់ប្រជាកសិករកាន់កាប់ស្រប ច្បាប់លើដីដាំដុះតាមរដូវក្នុងតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ទំនាបទទួលរបបទឹកទន្លេ មេគង្គ។
- ការបន្តចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។
- គាំទ្របច្ចេកទេសក្នុងការកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ដែលមិនទាន់ច្បាស់លាស់។
- ការរៀបចំគោលនយោបាយស្តីពីភាពជាដៃគូរវាងវិស័យឯកជននិងវិស័យសាធារណៈ លើ ការងារដីធ្លី។
- ពង្រឹងប្រសិទ្ធភាពលើការងារប្រមូលផ្តុំ ចងក្រង ផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិលើការ ងាររដ្ឋបាលដីធ្លី។

## ការរៀបចំដែនដីនិងនគរូបនីយកម្ម

- ជំរុញការរៀបចំនិងអនុម័តច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម និងលិខិតបទ ដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់អនុវត្តច្បាប់នេះ។
- ជំរុញការអនុម័តនិងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពតាមឋានានុក្រម ដែលបានកំណត់ ដោយគោលនយោបាយស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះរាជក្រឹត្យ និងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម គ្រប់លំដាប់ ថ្នាក់ នូវផែនការរៀបចំដែនដី រាជធានី ខេត្ត ជាពិសេសរាជធានីភ្នំពេញ ខេត្តក្នុងតំបន់ ឆ្នេរ ប្លង់គោល និងផែនការប្រើប្រាស់ដីបណ្តាទីក្រុង ទីប្រជុំជននៃខេត្តក្នុងតំបន់ជាប់ព្រំ ដែនកម្ពុជា វៀតណាម ឡាវ។
- បន្តរៀបចំនិងជំរុញការអនុម័តយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍទីក្រុង ទីប្រជុំជន និង ផែនការយុទ្ធសាស្ត្រសមាហរណកម្មអភិវឌ្ឍន៍តំបន់ឆ្នេរ ព្រមទាំងប្លង់គោលថ្នាក់តំបន់ គឺ តំបន់ត្រីកោណកម្ពុជា វៀតណាម ឡាវ។
- បន្តជំរុញការអនុម័តគោលនយោបាយជាតិស្តីពីលំនៅឋាន ដើម្បីដោះស្រាយលំនៅឋាន ជូនប្រជាពលរដ្ឋក្រីក្រសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។
- បន្តការគាំទ្របច្ចេកទេសដល់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុង ការរៀបចំប្លង់គោល និងផែនការប្រើប្រាស់ដី។
- ពង្រឹងប្រសិទ្ធភាពលើការងារប្រមូលផ្តុំ ចងក្រង ផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិលើ ការងាររៀបចំដែនដីនិងនគរូបនីយកម្ម។

## ការបែងចែកដី

- រៀបចំគោលនយោបាយជាតិស្តីពីការបែងចែកដីធ្លីនៅព្រះរាជាណាចក្រកម្ពុជា។

- ជំរុញរកដីសមស្របសម្រាប់ធ្វើសម្បទានដីសង្គមកិច្ច មានដូចជាដីទំនេរ សម្បទានដីសេដ្ឋកិច្ច ដែលត្រូវបានលុបកិច្ចសន្យាដោយសារមិនដំណើរការផលិតកម្ម ដីបោសសម្អាតមីនរួច ដោយរៀបចំសន្និធិដីរដ្ឋ សម្រាប់បម្រើគោលដៅកម្មវិធីបែងចែកដីរយៈពេលខ្លី មធ្យម និងវែង។
- ជំរុញបង្កើតគោលនយោបាយស្តីពីភាពជាដៃគូរវាងកសិដ្ឋានខ្នាតតូច មធ្យម ធំ និងរវាងសម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច។
- ផ្តល់ឱកាសក្នុងការទទួលបានសេវាឥណទានខ្នាតតូចដល់សម្បទានិកដីសង្គមកិច្ច និងអ្នក ដែលបានទទួលដីប្រទានកម្មពីកម្មវិធីនានារបស់រាជរដ្ឋាភិបាល ដូចជាការអនុវត្តបទបញ្ជាលេខ០១បប ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ដើម្បីអាចប្រើប្រាស់ដីឲ្យក្លាយជាទ្រព្យពិតប្រាកដសម្រាប់ពង្រីកមុខរបររបស់កសិករ ដោយត្រូវចេញបណ្ណសម្បទានដីដើម្បីអាចយកបណ្ណនេះទៅដាក់ហ៊ីប៉ូតែក ឬបញ្ចាំបាន ក្នុងចន្លោះពេលអន្តរកាល ដែលច្បាប់បានកំណត់លក្ខខណ្ឌនៃការកាន់កាប់ដីគ្រប់៥ឆ្នាំ ទើបអាចមានកម្មសិទ្ធិលើដីនោះ។
- ពង្រឹងយន្តការសម្បទានដីសង្គមកិច្ច ជាពិសេសគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់រាជធានី ខេត្ត ដោយជំរុញលើកកម្ពស់ការអនុវត្តនីតិវិធីទាក់ទងនឹងការប្រើប្រាស់ បែងចែកដីរដ្ឋ ទាំងនៅខេត្តដែលមានដីសម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ទាំងនៅខេត្តដែលគ្មានដី តែបានសម្រិតសម្រាំងជ្រើសរើសមុខសញ្ញាអ្នកត្រូវទទួលដីឲ្យបានហ្មត់ចត់។ ទន្ទឹមនេះ បន្តរៀបចំកម្មវិធីបង្កើនល្បឿនផ្តល់សម្បទានដីសង្គមកិច្ចទូទាំងប្រទេស លើមូលដ្ឋាននៃសន្និធិដីរដ្ឋក្នុងការអនុវត្តគោលនយោបាយចាស់-សកម្មភាពថ្មីលើវិស័យដីធ្លីសម្រាប់គោលដៅនេះ ដើម្បីទប់ស្កាត់ការកើតមានទៀតនូវភាពមិនប្រក្រតីនៃការទន្ទ្រានកាន់កាប់ដីរដ្ឋ។

### ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យសំណង់

- សម្របសម្រួល និងជំរុញការវិនិយោគលើវិស័យសំណង់ ដោយយកចិត្តទុកដាក់ពង្រឹងភាពជាដៃគូជាមួយផ្នែកឯកជន សំដៅជំរុញកំណើនសេដ្ឋកិច្ចជាតិ និងបង្កើតការងារជូនប្រជាពលរដ្ឋ។
- ជំរុញការរៀបចំ និងអនុម័តច្បាប់សំណង់ ស្តង់ដាសំណង់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យសំណង់ សម្រាប់ការអនុវត្តឲ្យមានប្រសិទ្ធភាព។ ពង្រឹងយន្តការ និងសមត្ថភាពមន្ត្រីជំនាញ ដើម្បីបម្រើសេវារដ្ឋបាលឲ្យមានប្រសិទ្ធភាព និងបន្តអនុវត្តនយោបាយវិសហមជ្ឈការលើវិស័យសំណង់។
- បន្តការផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងសំណង់ និងនីតិវិធីស្តីអំពីការសុំលិខិតអនុញ្ញាតសាងសង់ឲ្យបានទូលំទូលាយដល់ប្រជាជន។

- បង្កើនសមត្ថភាពរូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ និងលើកស្ទួយឧស្សាហកម្មសំណង់ក្នុងស្រុកឲ្យមានលក្ខណសម្បត្តិកាន់តែប្រសើរ ដែលអាចចូលរួមប្រកួតប្រជែង អនុវត្តការងារសិក្សាគម្រោងប្លង់ និងសាងសង់សំណង់ធំៗដោយខ្លួនឯងនិងផ្តល់សេវាប្រកបដោយគុណភាព ប្រសិទ្ធភាព ទាំងនៅក្នុងប្រទេសនិងក្នុងតំបន់។
- ពង្រឹងប្រសិទ្ធភាពលើការងារប្រមូលផ្តុំ ចងក្រង ផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិសំណង់។

## ការបោសសម្អាតមីន

៤.៦៤- ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានគួរឲ្យកត់សម្គាល់ ក្នុងការបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ក៏នៅមានផ្ទៃដីជាច្រើនហិកតាដែលត្រូវបានសង្ស័យថាមានមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ដែលនឹងបន្តជាឧបសគ្គដល់ការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច និងគ្រោះថ្នាក់ដល់ប្រជាជនជារៀងរាល់ថ្ងៃ។ ប្រទេសកម្ពុជា នៅតែមិនទាន់អាចសម្រេចបាននូវចំណុចដៅដែលបានគ្រោងទុក ដោយសារទំហំនៃការងារបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម មានកម្រិតធំហួសពីសមត្ថភាពរបស់កម្ពុជា។ យោងតាមមាត្រាទី៥នៃអនុសញ្ញានេះ កម្ពុជាបានស្នើសុំពន្យារការបោសសម្អាតមីនរហូតដល់ចុងឆ្នាំ២០១៩ ដើម្បីធ្វើការបោសសម្អាតផ្ទៃដីមានមីន និងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម។ លើសពីនេះទៀត ផ្ទៃដីដែលអាចមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម នឹងត្រូវធ្វើស្ថិតិជាបន្តបន្ទាប់នៅឆ្នាំខាងមុខ។ ដោយមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធនានា ***អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន*** បានរៀបចំយុទ្ធសាស្ត្រជាតិសកម្មភាពកម្ចាត់មីន ដើម្បីគាំទ្រដល់ការងារបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

៤.៦៥- **ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនឆ្នាំ២០១០-២០១៩** ជាយុទ្ធសាស្ត្រមួយត្រូវបានរៀបចំឡើង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម តាមរយៈការបោសសម្អាតមីន ការអប់រំពីគ្រោះថ្នាក់ដោយសារមីន ការជំរុញកំណើនសេដ្ឋកិច្ច និងចូលរួមកាត់បន្ថយភាពក្រីក្រ ដើម្បីធានានិរន្តរភាពសមត្ថភាពជាតិក្នុងការដោះស្រាយបញ្ហាមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅសេសសល់ រួមទាំងការលើកកម្ពស់ស្ថិរភាព និងការរំសាយសព្វាវុធនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ។

៤.៦៦- ការកសាងផែនការ និងការចាត់អាទិភាពប្រកបដោយប្រសិទ្ធភាព មានសារៈសំខាន់ណាស់ ក្នុងការតម្រង់ទិសបោសសម្អាតមីនឆ្ពោះទៅរកសហគមន៍ ដែលរងការគំរាមកំហែងខ្លាំងដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាដែលមានកំណត់ឲ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយគ្រោះថ្នាក់ និងគាំទ្រដល់ការអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន។ ក្នុងន័យនេះ អាជ្ញាធរមីននឹងបន្តធ្វើឲ្យកាន់តែប្រសើរឡើងនូវដំណើរការនៃការក

សាងផែនការនិងការចាត់អាទិភាពចម្ការមីន ដែលបានបញ្ជ្រាបនៅក្នុងដំណើរការកសាងផែនការវិនិយោគឃុំ សង្កាត់ ដោយពង្រឹងសមត្ថភាពការកសាងផែនការសកម្មភាពមីននៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ ដើម្បីសម្រេចការងារនេះ អាជ្ញាធរមីននឹងធានាឲ្យមានការពិភាក្សាផ្តល់យោបល់និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងវិស័យសកម្មភាពមីនជាមួយ នឹងវិស័យពាក់ព័ន្ធសកម្មភាពមីនផ្សេងទៀត។ បន្ថែមពីនេះ អាជ្ញាធរមីន នឹងបន្តរៀបចំកែសម្រួលវិធីសាស្ត្រដើម្បីរំដោះផ្ទៃដីដោយប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធភាពនិងមានប្រសិទ្ធផល។

៤.៦៧- ចីរភាពនៃការគាំទ្រផ្នែកថវិកាពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍនានា នឹងនៅបន្តជាតម្រូវការចាំបាច់ ដើម្បីធ្វើឲ្យសម្រេចបាននូវគោលដៅនៃសកម្មភាពបោសសម្អាតមីន ដែលបានចែងនៅក្នុង ផ.យ.អ.ជ. ហើយការបង្កើនការគាំទ្រ គឺជាប្រការចាំបាច់ ដើម្បីធ្វើឲ្យសម្រេចបាននូវកាតព្វកិច្ចក្នុងការអនុវត្តអនុសញ្ញាខាងលើ។

៤.៦៨- តារាងទី៤.៤ ខាងក្រោម បង្ហាញពីសូចនាករ និងចំណុចដៅសម្រាប់សកម្មភាពមីនពីឆ្នាំ២០១៤-២០១៨។

**តារាងទី៤.៤ សូចនាករស្តីពីមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម**

| សូចនាករ | ឯកតា | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ (ស្លាប់/របួស) | នាក់ | ១៨៦ | ១៦៧ | ១៥១ | ១៣៦ | ១២២ | ១១០ | ៩៩ |
| ចំនួនជនរងគ្រោះដោយសារការលេង និងច្នៃគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ (ស្លាប់/របួស) | នាក់ | ១២៥ | ១១២ | ៩៩ | ៨៦ | ៧៣ | ៦០ | ៤៨ |
| ផ្ទៃដីសរុបបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម (ផ្អែកលើលទ្ធផលពីការស្រាវជ្រាវមូលដ្ឋាន) | ហិកតា | ៨ ២៩៣ | ៨ ៧០៨ | ៩ ១៤៣ | ៩ ៦០០ | ១០ ០៨០ | ១០ ៥៨៤ | ១១ ១១៣ |

*ប្រភព: អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន*

## ៣.៤- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៥

៤.៦៩- ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង និងពង្រីកថែមទៀតនូវការគ្រប់គ្រងធនធានធម្មជាតិសំដៅរក្សា“**តុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្ស**” ពិសេសលើកកម្ពស់វិភាគទាននៃធនធានធម្មជាតិ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈ(១)ការធានាគម្របបៃតង ការអភិរក្សព្រៃឈើ និងសត្វព្រៃ (២)ការធានាចីរភាពនៃធនធានជលផល និង(៣)ការ

រក្សាចីរភាពប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាគុណភាពដី និងចីរភាពនៃប្រភពទឹក ដោយផ្តោតលើការការពារជីវៈចម្រុះ តំបន់ដីសើមនិងតំបន់ឆ្នេរ ។

៤.៧០- រាជរដ្ឋាភិបាលនឹងប្រកាន់យកអភិក្រម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា សំដៅលើកកម្ពស់ប្រសិទ្ធភាព និងសមធម៌ ក្នុងការប្រើប្រាស់ធនធានធម្មជាតិ តាមរយៈ (១)ការកំណត់ច្បាស់លាស់នូវកម្មសិទ្ធិលើធនធានធម្មជាតិ (២)ការពង្រឹងប្រព័ន្ធលើកទឹកចិត្តត្រឹមត្រូវក្នុងការងារអភិរក្សធនធានធម្មជាតិ និងការផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរថ្នាក់ក្រោមជាតិ សហគមន៍ និងប្រជាជនម្នាក់ៗ ក្នុងការចូលរួមអភិរក្សធនធានធម្មជាតិដោយផ្តោតលើការបណ្តុះបណ្តាល ការផ្តល់ព័ត៌មាន ព្រមទាំងការពង្រឹងមូលធនសង្គម គណនេយ្យភាព និងតម្លាភាពនៃស្ថាប័ន និង (៣)ការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយអ្នកមានចំណែកពាក់ព័ន្ធក្នុងក្របខ័ណ្ឌកំណើនបៃតងនិងការប្រែប្រួលអាកាសធាតុ។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

- ទី១ ការបន្តគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ ប្រកបដោយចីរភាពនិងសមធម៌ ស្របតាម“**កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩**” ពិសេសតាមរយៈការពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ការកំណត់ព្រំប្រទល់ ចំណាត់ថ្នាក់ និងការចុះបញ្ជីដែនព្រៃឈើ ការគ្រប់គ្រង និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនូវព្រៃឈើរដ្ឋ និងឯកជន ការអនុវត្តវិធានការលើកកម្ពស់ជីវភាព និងការចូលរួមរបស់សហគមន៍ដែលរស់នៅអាស្រ័យព្រៃឈើ ការលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងការអភិរក្ស ការកាត់បន្ថយនូវការបាត់បង់ និងរេចរឹលព្រៃឈើ ការបង្កើនការដាំ និងស្តារព្រៃឈើឡើងវិញ ការពង្រឹងកិច្ចអភិរក្សសត្វព្រៃ និងជម្រកសត្វព្រៃ ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការជំរុញការងារស្រាវជ្រាវនិងផ្សព្វផ្សាយ។
- ទី២ ការបន្តពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានជលផលប្រកបដោយចីរភាព ស្របតាម “**ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ២០១០-២០១៩**” និង“**សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយវិស័យជលផលជាតិ**” ពិសេសតាមរយៈការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទគ្រប់ប្រភេទ ជាអាទិ៍ការពង្រឹងការគ្រប់គ្រងឧបករណ៍ និងរដូវនេសាទ ការលុបបំបាត់ការនេសាទហួសកម្រិត ការពង្រឹងសមត្ថភាពសហគមន៍នេសាទ ក្នុងការគ្រប់គ្រងប្រើប្រាស់ និងអភិរក្សធនធានជលផល ការការពារជីវៈចម្រុះ និងទីជម្រកវារីសត្វ ការគ្រប់គ្រងគុណភាពទឹកសាប និងសមុទ្រ ដោយកាត់បន្ថយសារធាតុពុលជាអតិបរមា ការថែរក្សា និងជំរុញការដាំព្រៃលិចទឹក និងព្រៃកោងកាង ការកំណត់ព្រំប្រទល់ព្រៃលិចទឹក និងតំបន់អភិរក្សជលផល ព្រមទាំងការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយ។

ទី៣ ការបន្តជំរុញអនុវត្តវិធានការនានា ដើម្បីរក្សាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី សំដៅធានាគុណភាពដី និងទឹក ធម្មជាតិ រួមទាំងទឹកក្រោមដីផង សម្រាប់បម្រើឲ្យវិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការជំរុញការរៀបចំ និងអនុវត្តគោលនយោបាយ និងបទដ្ឋានគតិយុត្ត ព្រមទាំងផែនការសកម្មភាព និងកម្មវិធីនានាឲ្យមានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចជាឧទ្យានជាតិ ជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង "តំបន់រ៉ាមសារ" តំបន់អភិរក្សជីវសាស្ត្រ តំបន់អភិរក្សមរតកធម្មជាតិ តំបន់ឧទ្យានសមុទ្រ ជាពិសេសពង្រឹងការអនុវត្ត "**ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ**" "**ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ**" និង "**សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា**" ។

ទី៤ ការបន្តជំរុញអនុវត្តកិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌ "**គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង**" និង "**ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០**" តាមរយៈការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រាប់ការធ្វើពាណិជ្ជកម្មកាបូន ការពង្រឹងសមត្ថភាព ការរៀបចំនិងអនុវត្តវិធានការសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការសិក្សាពីលទ្ធភាពក្នុងការប្រើប្រាស់យន្តការហិរញ្ញប្បទានផ្នែកបរិស្ថាន ដូចជាការទូទាត់កម្រៃបរិស្ថាន និងមូលនិធិបរិស្ថាន ការពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ រួមទាំងជីវៈចម្រុះ តំបន់ផ្ទៃរងទឹកភ្លៀង និងតំបន់ដីសើម ព្រមទាំងការពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

### កំណែទម្រង់ព្រៃឈើ

៤.៧១- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***រដ្ឋបាលព្រៃឈើ*** បានរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តកម្មវិធីព្រៃឈើជាតិឲ្យមានប្រសិទ្ធភាពខ្ពស់ ដោយរួមបញ្ចូលគោលដៅអាទិភាពជាយុទ្ធសាស្ត្រចំនួន៩ មានដូចខាងក្រោម៖

- បង្កើនជាអតិបរមានូវវិភាគទានរបស់ធនធានព្រៃឈើក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ជីវភាពនិងកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌។
- បន្សាំការប្រែប្រួលអាកាសធាតុ និងការសម្រាលឥទ្ធិពលរបស់វាទៅលើជីវភាពរបស់សហគមន៍មូលដ្ឋាន ដែលពឹងអាស្រ័យលើធនធានព្រៃឈើ។

- ការធ្វើផែនការគ្រប់គ្រងដីធ្លីជាទ្រង់ទ្រាយធំដោយមានការចូលរួមពីវិស័យពាក់ព័ន្ធ មានលក្ខណៈយុត្តាធិការនិងមានព្រំប្រទល់រដ្ឋបាលមូលដ្ឋាន។
- សម្រេចឲ្យបានអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងព្រៃឈើ ការអនុវត្តច្បាប់នៅគ្រប់ស្រទាប់។
- រៀបចំប្រព័ន្ធគ្រប់គ្រងទំនាស់ប្រកបដោយប្រសិទ្ធភាព។
- ផ្សព្វផ្សាយការយល់ដឹង និងកសាងសមត្ថភាពរបស់ស្ថាប័ននិងបង្កើនគុណភាពការអប់រំដើម្បីឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិឲ្យមាននិរន្តរភាព។
- ធានាការការពារបរិស្ថាននិងការអភិរក្សធនធានព្រៃឈើ។
- ប្រកាន់នូវការអនុវត្តគំរូគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាពដោយសម្របតាមស្ថានភាពនៃព្រៃឈើ។
- រៀបចំនិងអនុវត្តប្រព័ន្ធហិរញ្ញប្បទានប្រកបដោយនិរន្តរភាព។

៤.៧២- **កម្មវិធីព្រៃឈើជាតិ**មានកម្មវិធីធំៗចំនួន៦ សម្រាប់ការរៀបចំផែនការការអនុវត្ត និងការតាមដានសម្រាប់វិស័យនេះ នៅក្នុងរយៈពេល២០ឆ្នាំ ដូចខាងក្រោម៖

- ការកំណត់ព្រំប្រទល់ដែនព្រៃឈើ ចុះបញ្ជិកា និងចំណាត់ថ្នាក់។
- ការអភិរក្ស ការអភិវឌ្ឍធនធានព្រៃឈើ និងជីវៈចម្រុះ។
- អនុវត្តច្បាប់ព្រៃឈើនិងអភិបាលកិច្ច។
- សហគមន៍ព្រៃឈើ។
- អភិវឌ្ឍការស្រាវជ្រាវ និងការបង្កើនសមត្ថភាព។
- ហិរញ្ញប្បទានព្រៃឈើប្រកបដោយចីរភាព។

៤.៧៣- ***រដ្ឋបាលព្រៃឈើ*** បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីអនុវត្ត**កម្មវិធីព្រៃឈើជាតិ** ប្រកបដោយប្រសិទ្ធភាព ដែលមានអនុកម្មវិធីចំនួន៨សម្រាប់អនុវត្តប្រចាំឆ្នាំដូចខាងក្រោម៖

- ការគ្រប់គ្រងនិងអភិរក្សព្រៃឈើ និងព្រៃឈើសហគមន៍។
- ការអភិវឌ្ឍការដាំកូនឈើ។
- ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងឧទ្យានសត្វ។
- ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងការធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើ។
- ការស្រាវជ្រាវនិងការអភិវឌ្ឍព្រៃឈើ និងជីវិតសត្វព្រៃ។
- ការអនុវត្តច្បាប់ព្រៃឈើនិងអភិបាលកិច្ច។
- ការគ្រប់គ្រងហិរញ្ញប្បទានព្រៃឈើ ការរៀបចំផែនការ និងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។
- ការសង្គ្រោះសត្វព្រៃ ស្តារនីតិសម្បទា បង្កាត់ពូជ និងអនុវត្តច្បាប់។

## វិស័យជលផល

៤.៧៤- ផ្ដើមចេញពីទស្សនវិស័យជលផល និងការកែទម្រង់ស៊ីជម្រៅវិស័យជលផលរបស់រាជរដ្ឋាភិបាល នៅក្នុងឆ្នាំ២០១២ ដោយបានរំសាយឡូត៍នេសាទបន្ថែមចំនួន៨០ឡូត៍ មានផ្ទៃសរុបចំនួន៤១៥ ២១៨ហ.ត. ដែលក្នុងនោះ ផ្ទៃឡូត៍នេសាទប្រមាណ៣១៧ ១៥ហ.ត.ស្មើ ៧៦,៥០% ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងរៀបចំសហគមន៍នេសាទបន្ថែមថ្មីចំនួន៤៧សហគមន៍នេសាទ ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព។ ក្រៅពីនោះ ផ្ទៃឡូត៍នេសាទប្រមាណ៩៧ ៥០៣ហ.ត. ស្មើ២៣,៥០% ត្រូវបានកំណត់ទុកជាតំបន់អភិរក្សសម្រាប់ការពារថែរក្សាពូជត្រី សំដៅធានាផលស្តុកត្រីសម្រាប់ឆ្នាំក្រោយៗទៀត។ ការកែទម្រង់ស៊ីជម្រៅវិស័យជលផលទាំង២លើក មានទំហំផ្ទៃឡូត៍នេសាទចំនួន៩៥៣ ៧៤០ហ.ត. ត្រូវបានលុបចោលសម្រាប់រៀបចំសហគមន៍នេសាទ និងធ្វើកន្លែងអភិរក្សជលផល។

៤.៧៥- ***រាជរដ្ឋាភិបាលកម្ពុជា*** សម្រាប់នីតិកាលទី៥នៃរដ្ឋសភា នឹងបន្តអាទិភាពក្នុងការជួយ និងការលើកទឹកចិត្តដល់សហគមន៍នេសាទ ក្នុងការចូលរួមរៀបចំផែនការ និងការគ្រប់គ្រងធនធានធម្មជាតិ ដោយផ្តល់នូវការណែនាំ និងការបណ្តុះបណ្តាលបច្ចេកទេស ដើម្បីធានាស្ថិរភាពគ្រប់គ្រងធនធានជលផលដោយផ្អែកលើស្តង់ដាបច្ចេកទេស។ ដើម្បីសម្រេចបានដូចគោលបំណងខាងលើរាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើការកំណត់ព្រំដែនឡូត៍នេសាទច្បាស់លាស់។

៤.៧៦- ដើម្បីធានាថាតម្លៃត្រី បញ្ជាក់ពីតម្លៃពិតនៃសេដ្ឋកិច្ច ***រាជរដ្ឋាភិបាលកម្ពុជា*** នឹងបង្កើតយន្តការទីផ្សារត្រីមួយប្រកបដោយប្រសិទ្ធភាព ដែលត្រីជាប្រភពចំណូល ឬជាការចំណាយរបស់អ្នកក្រសម្រាប់ការរស់នៅ។ យន្តការទីផ្សារត្រីនេះ នឹងរួមបញ្ចូលនូវការរៀបចំដំណើរការដេញថ្លៃឡូត៍នេសាទឲ្យមានតម្លាភាពជាងមុន ហើយនឹងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងឡូត៍នេសាទក៏ដូចជាការបង្កើតចំណូលរបស់រដ្ឋ។

៤.៧៧- ***រាជរដ្ឋាភិបាលកម្ពុជា*** នឹងពង្រឹងបន្ថែមទៀតនូវការអភិរក្សធនធានរបស់ជាតិ ជាពិសេស បង្កើនទំនាក់ទំនងរវាងការអភិរក្សទៅនិងទេសចរណ៍ធម្មជាតិ ។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តនូវសកម្មភាពយ៉ាងម៉ឺងម៉ាត់ ប្រឆាំងនិងទប់ស្កាត់បទល្មើសកាប់បំផ្លាញព្រៃលិចទឹក ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ និងទប់ស្កាត់រាល់សកម្មភាពអនាធិបតេយ្យគ្រប់ប្រភេទដែលប៉ះពាល់ដល់កិច្ចខិតខំអភិរក្ស តាមរយៈការលើកទឹកចិត្តឲ្យមានការចូលរួមពីសមត្ថកិច្ចដែលមានការពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋាន។

៤.៧៨- ការបង្កើនវារីវប្បកម្ម គឺជាភាពចាំបាច់ ដើម្បីការពារធនធានមច្ឆជាតិ ដែល ***រាជរដ្ឋាភិបាលកម្ពុជា*** នឹងផ្តល់នូវការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី រួមទាំងបច្ចេកទេស ពូជត្រី ឥណទាន និងទីផ្សារ។ ការធ្វើឲ្យប្រសើរឡើងនូវការអនុវត្តច្បាប់ តាមរយៈការប្រើប្រាស់បន្តនូវយន្តការដែលមានស្រាប់ គឺជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការការពារធនធានជលផល។

៤.៧៩- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***រដ្ឋបាលជលផល*** នឹងផ្តោតការខិតខំយកចិត្តទុកដាក់លើការពង្រឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយចីរភាព ដែលរួមចំណែកដល់ការធានាសន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីបង្កើនជីវភាពរបស់ប្រជាជន និងភាពថ្កុំថ្កើងរបស់ជាតិ។ ជាមួយគ្នានេះដែរ ដើម្បីរួមចំណែកធានានិរន្តរភាពវិស័យជលផលនិងរក្សាការប្រើប្រាស់ត្រីរបស់ប្រជាជន ***រដ្ឋបាលជលផល*** នឹងនៅតែបន្តជំរុញការអនុវត្ត **ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រឆ្នាំ២០១០-២០១៩** ដែលឈរលើសសរស្តម្ភ៣ គឺ(១)គ្រប់គ្រងប្រកបដោយនិរន្តរភាពនូវការធ្វើនេសាទទឹកសាបនិងសមុទ្រ (២)ជំរុញនិងអភិវឌ្ឍវារីវប្បកម្មទឹកសាប និងទឹកប្រៃ (៣)កែលម្អគុណភាពនិងសុវត្ថិភាពផលិតផលជលផលសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងនាំចេញ។

៤.៨០- ដើម្បីសម្រេចបានតាមគោលដៅជាមួយ ***ផ.យ.អ.ជ. ២០១៤-២០១៨ រដ្ឋបាលជលផល*** បានដាក់ចេញនូវចំណុចដៅ៣សំខាន់ៗ ដូចខាងក្រោម៖

- ត្រូវសម្រេចឲ្យបានតាមទិសដៅ៥ឆ្នាំ (២០១៤-២០១៨) ដូចមាននៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផលរយៈពេល១០ឆ្នាំ។
- បន្តជុំរុញរៀបចំនិងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ សម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ក្នុងការកំណត់បញ្ហាប្រឈមជាលក្ខណៈអន្តរជាតិចំពោះវិស័យជលផលកម្ពុជា រួមមានបម្រែបម្រួលអាកាសធាតុ ការសាងសង់ទំនប់វារីអគ្គិសនី និងភាពរេចរឹលនៃបរិស្ថាន។
- ធានានូវការទទួលទានជលត្រីរបស់ប្រជាជនតាមកម្រិត៥២,៤គ.ក្រ. សម្រាប់មនុស្សម្នាក់ក្នុងរយៈពេលមួយឆ្នាំ។

៤.៨១- ដើម្បីសម្រេចបានតាមទស្សនវិស័យ និងចំណុចដៅខាងលើ ***រដ្ឋបាលជលផល***នឹងខិតខំបន្តជំរុញអនុវត្តនូវគោលដៅចំនួន៧ចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ការរួមចំណែករបស់វិស័យជលផលដល់ការរីកចម្រើនរបស់ជាតិមានកម្រិតខ្ពស់ និងមានចីរភាព។

- ជីវភាពរស់នៅរបស់ប្រជាជនក្នុងវិស័យនេះកំពុងត្រូវបានធ្វើឲ្យប្រសើរឡើង និងមានកម្រិតខ្ពស់ជាងកម្រិតមធ្យមដែលបានកំណត់នៅថ្នាក់ជាតិ។
- ដែននេសាទនិងប្រភពធនធានជលផលផ្សេងទៀតមានលក្ខខណ្ឌល្អនិងមានភាពធន់ ហើយត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព។
- ត្រីគឺជាប្រភពនៃចំណីអាហារដែលមានលក្ខណៈសម្បូរបែប ផ្តល់សុខភាពល្អ និងមានតម្លៃ។
- មុខជំនួញក្នុងរបរនេសាទគឺមានភាពចំណេញ ស្ថិរភាព និងមានភាពទទួលខុសត្រូវ។
- ដែននេសាទត្រូវបានគ្រប់គ្រង អភិវឌ្ឍ និងអភិរក្សដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង។
- បរិយាកាសគោលនយោបាយ ច្បាប់ និងការជួយគាំទ្រចំពោះវិស័យ គឺមានភាពគ្រប់គ្រាន់សមស្របនិងមានសមត្ថភាពអាចអនុវត្តបាន។

៤.៨២- ដើម្បីសម្រេចបានតាមគោលដៅទាំង៧ខាងលើ ***រដ្ឋបាលជលផល*** បានរៀបចំផែនការសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

- បន្តអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់***សម្តេចអគ្គមហាសេនាបតីតេជោ*** “ **ធ្វើឲ្យទីណាមានទឹកទីនោះមានត្រីឡើងវិញ**”។
- ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យជលផល។
- ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលជលផលថ្នាក់កណ្តាលនិងនៅថ្នាក់ខណ្ឌរដ្ឋបាលជលផល។
- ការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទទាំងទឹកសាបនិងសមុទ្រ។
- ការគាំទ្រសហគមន៍នេសាទ និងការនេសាទក្នុងវាលស្រែ។
- ការកាត់បន្ថយការខាតនៅក្នុងសកម្មភាពកែច្នៃជលផលនិងការខ្វះខាតចំពោះអ្នកកែច្នៃខ្នាតតូច។
- ការអភិរក្សនិងការការពារតាមរយៈសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖
  - ➢ ការបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សឲ្យបានច្បាស់លាស់និងរឹងមាំ។
  - ➢ ការធ្វើផែនទីការកំណត់ព្រំប្រទល់បោះបង្គោល និងការការពារព្រៃលិចទឹក។
  - ➢ ការការពារនិងការអភិរក្សអន្លង់ជ្រៅៗនៅតំបន់មេគង្គលើ។
  - ➢ ការគ្រប់គ្រងប្រកបដោយចីរភាពនូវទីជម្រកជលផលសំខាន់ៗ។

### កិច្ចគាំពារបរិស្ថាន និងការអភិរក្សជីវៈចម្រុះ

៤.៨៣- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងបរិស្ថាន*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

- អនុវត្ត**ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣**។
- អភិវឌ្ឍបៃតងនិងអភិវឌ្ឍកាបូនទាប ជាការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងនិរន្តរភាពបរិស្ថាន។
- ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដើម្បីលុបបំបាត់ភាពអនាធិបតេយ្យក្នុងតំបន់ទាំងនោះ លប់បំបាត់ការធ្វើអាជីវកម្មធនធានធម្មជាតិខុសច្បាប់ និងត្រួតពិនិត្យការទន្ទ្រានដីដើម្បីប្រើប្រាស់និងកាន់កាប់ព្រៃឈើខុសច្បាប់។
- វាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើគម្រោងអភិវឌ្ឍន៍នានាដែលបានស្នើឡើង។
- ពង្រឹងការគ្រប់គ្រងគុណភាពបរិស្ថានសល់ពីការកាត់បន្ថយនិងបញ្ឈប់ការប្រើប្រាស់គីមីពុល តាមរយៈសកម្មភាពចុះត្រួតពិនិត្យ ធ្វើអធិការកិច្ចលើប្រភពបំពុលនិងតាមដានគុណភាពបរិស្ថាន( ទឹក ដី ខ្យល់ សំឡេង )។
- បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងវិធានការសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- ពង្រឹងការអនុវត្តការងារជីវសុវត្ថិភាពនិងបច្ចេកវិទ្យាទំនើប។
- ពង្រឹងការអប់រំនិងផ្សព្វផ្សាយព័ត៌មានបរិស្ថាន។

៤.៨៤- ***ក្រសួងបរិស្ថាន*** នឹងរៀបចំលិខិតបទដ្ឋាន និងឯកសារច្បាប់មួយចំនួន ដូចខាងក្រោម៖

- សម្របសម្រួលការរៀបចំក្របខ័ណ្ឌច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ ដោយគ្របដណ្តប់លើការធ្វើបច្ចុប្បន្នកម្មស្ថាប័នរៀបចំហិរញ្ញប្បទាន និងការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងវិស័យពាក់ព័ន្ធ។
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងការបំពុលបរិស្ថាន។
- រៀបចំច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន។
- រៀបចំច្បាប់ស្តីពីការអភិវឌ្ឍបៃតង។
- រៀបចំច្បាប់ស្តីពីជីវៈចម្រុះ។
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងគីមី។
- រៀបចំច្បាប់ស្តីពីការផ្តល់សច្ចាប័ននៃអនុសញ្ញាមីណាម៉ាតាស្តីអំពីបារ៉ត។
- រៀបចំអនុក្រឹត្យស្តីពីការបង្កើតមូលនិធិតំបន់ការពារធម្មជាតិ។
- រៀបចំប្រកាសស្តីពីការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងតំបន់ការពារធម្មជាតិ។
- វិសោធនកម្មអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន។
- រៀបចំអនុក្រឹត្យស្តីពីមូលនិធិនិងសង្គម។
- រៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក។

- រៀបចំសារាចរណែនាំអំពីការគ្រប់គ្រងសំណល់ទឹកលូដល់អាជ្ញាធររាជធានី ខេត្ត។
- រៀបចំសារាចរណែនាំអំពីការប្រមូល ដឹកជញ្ជូន ការកែច្នៃ និងការបោះបង់ចោលសំណល់រឹងសំរាម។

៤.៨៥-នៅក្នុងផ្នែកការវាយតម្លៃផលប៉ះពាល់បរិស្ថាន ***ក្រសួងបរិស្ថាន*** នឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឲ្យមានការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិ និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយចីរភាព ដោយធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានមុននឹងអនុវត្តគម្រោងអភិវឌ្ឍនានា តាមរយៈ៖

- រៀបចំគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថាន លើវិស័យប្រេង និងឧស្ម័ន កសិកម្ម ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធស្តីពីកិច្ចដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន។
- ការពង្រឹងសមត្ថភាពបច្ចេកទេសរបស់មន្ត្រីជំនាញនៅគ្រប់កម្រិត ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន។
- ការពង្រឹងការតាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាននិងលើការអនុវត្តកិច្ចព្រមព្រៀងការការពារបរិស្ថានរបស់ម្ចាស់គម្រោងនៅក្នុងសកម្មភាពអភិវឌ្ឍន៍របស់ខ្លួន។

៤.៨៦- នៅក្នុងផ្នែកការត្រួតពិនិត្យការបំពុលបរិស្ថាន ***ក្រសួងបរិស្ថាន*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- តាមដានត្រួតពិនិត្យគុណភាពទឹកសាធារណៈតាមទន្លេ ស្ទឹង បឹង និងទឹកលូសាធារណៈ
- ពិនិត្យលទ្ធភាព ពង្រីកការតាមដានត្រួតពិនិត្យគុណភាពទឹកសាធារណៈ។
- តាមដានត្រួតពិនិត្យការបំពុលដោយសំណល់រាវពីប្រភពរោងចក្រសហគ្រាស។

៤.៨៧- គោលការណ៍គ្រប់គ្រងបរិស្ថានផ្សេងៗ ***ក្រសួងបរិស្ថាន*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- តាមដានត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងនិងរំញ័រ។
- ពិនិត្យលទ្ធភាពពង្រីកការតាមដានត្រួតពិនិត្យការបំពុលខ្យល់រាជធានី ខេត្ត។
- ត្រួតពិនិត្យការគ្រប់គ្រងសំណល់រឹងសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។
- ពង្រឹងគុណភាព និងសមត្ថភាពមន្ទីរពិសោធន៍។
- ពង្រឹងសមត្ថភាពមន្ត្រីបរិស្ថានរាជធានីខេត្ត អំពីការគ្រប់គ្រងការបំពុលបរិស្ថាន និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការបំពុលបរិស្ថាន និងសុខភាពសាធារណៈ។

៤.៨៨- នៅក្នុងផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ***ក្រសួងបរិស្ថាន*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- រៀបចំផែនទី ការបោះបង្គោលព្រំប្រទល់ ការកំណត់តំបន់គ្រប់គ្រង និងការគ្រប់គ្រងទិន្នន័យនៅតំបន់ការពារធម្មជាតិ។
- រៀបចំបង្កើតរុក្ខឧទ្យានជាតិនិងឧទ្យានជាតិសមុទ្រ។
- កំណត់តំបន់សក្តានុពលសម្រាប់ការចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍នៅតំបន់ការពារធម្មជាតិ។
- ពង្រឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។
- ពង្រឹងការគ្រប់គ្រងនិងការអភិរក្ស តំបន់ដីសើម ទីជម្រាល ឋបនីយជីវមណ្ឌល និងតំបន់ឆ្នេរ។
- បន្តរៀបចំទិវាដីសើម។
- ពង្រឹងសមត្ថភាពលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុក្នុងការសម្របសម្រួលអន្តរក្រសួង និងការគ្រប់គ្រងមូលនិធិអាកាសធាតុជាតិ។
- រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចិត្តអនុវត្ត**ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣** តាមរយៈសកម្មភាព ដូចខាងក្រោម៖
  - ➢ ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។
  - ➢ ពង្រឹងគោលនយោបាយ និងបទប្បញ្ញត្តិនានាស្តីពីការប្រែប្រួលអាកាសធាតុ។
  - ➢ បង្កើតនិងអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃថ្នាក់ជាតិ សម្រាប់គម្រោងប្រែប្រួលអាកាសធាតុ។
  - ➢ បង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹង សម្រាប់ប្រមូល វិភាគ និងផ្សព្វផ្សាយព័ត៌មាននិងចំណេះដឹង រួមទាំងចំណេះដឹងសហគមន៍មូលដ្ឋានអំពីការប្រែប្រួលអាកាសធាតុ។
  - ➢ កែលម្អប្រព័ន្ធសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ រួមទាំងការប្រមូលទិន្នន័យ ការថែរក្សាទុក ការវិភាគ និងធ្វើម៉ូដែល។
  - ➢ បង្កើតនូវប្រព័ន្ធបញ្ជីចុះឈ្មោះថ្នាក់ជាតិ សម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងអស់ ព្រមទាំងជំរុញការអនុវត្តសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់សមស្របថ្នាក់ជាតិ និងសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្រោមយន្តការផ្សេងៗ នៅក្នុងវិស័យអាទិភាពនានា ដែលផ្តល់ពហុប្រយោជន៍ច្រើនយ៉ាង។
  - ➢ កៀរគរថវិកានិងជំនួយបច្ចេកទេស សម្រាប់អនុវត្តសកម្មភាពចម្បងៗ ដែលកំណត់នៅក្នុងផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាស

ធាតុតាមវិស័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដោយរួមទាំងការងារស្រាវជ្រាវ និងគម្រោងសកម្មភាពរៀនសូត្រ ដើម្បីជាជំនួយដល់ការរៀបចំគោលនយោបាយ។

- ➢ សម្របសម្រួលនិងលើកកម្ពស់ការកសាងសមត្ថភាពប្រែប្រួលអាកាសធាតុ និងការយល់ដឹងជាសាធារណៈ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- ➢ សម្របសម្រួលការរៀបចំផែនការបន្សាំជាតិ និងរៀបចំយុទ្ធសាស្ត្រអនុវត្តសម្រាប់តម្រូវការបន្សាំរយៈពេលមធ្យមនិងវែង។

៤.៨៩- រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច តាមគោលការណ៍អភិវឌ្ឍន៍បៃតង ដូចមានចែងក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និង **ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០**។ កម្មវិធីអភិវឌ្ឍន៍បៃតងផ្តោតលើការធ្វើឲ្យមានសុខដុមនីយកម្មរវាងការអភិវឌ្ឍសេដ្ឋកិច្ច ការការពារបរិស្ថាន ការអភិវឌ្ឍសង្គម និងការលើកកម្ពស់វប្បធម៌ជាតិ រួមទាំងការវិនិយោគបៃតង និងការបង្កើតការងារបៃតង ការគ្រប់គ្រងសេដ្ឋកិច្ចបៃតង ជាអាទិ៍ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ចដោយគិតគូរបន្ថែមលើការលើកទឹកចិត្តបៃតងពិសេស ពន្ធបៃតង ហិរញ្ញវត្ថុបៃតង ឥណទានបៃតង និងមីក្រូ ម៉ាក្រូហិរញ្ញវត្ថុបៃតង ការអភិវឌ្ឍសេដ្ឋកិច្ចឲ្យមាននិរន្តរភាព ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ ការបណ្តុះបណ្តាលធនធានមនុស្សនិងការអប់រំបៃតង ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព។

៤.៩០- សកម្មភាពនៅក្នុងកំណើនបៃតង មានដូចខាងក្រោម៖

- បញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍បៃតង សេដ្ឋកិច្ចបៃតង និងការអភិវឌ្ឍកាបូនទាបទៅលើគ្រប់វិស័យ។
- រៀបចំផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍបៃតង។
- អប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព ដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីការអភិវឌ្ឍបៃតង។
- ជំរុញការវិនិយោគបៃតង ដែលប្រើបច្ចេកវិទ្យាបៃតង។

៤.៩១- នៅក្នុងផ្នែកការគ្រប់គ្រងតំបន់ធម្មជាតិ ***ក្រសួងបរិស្ថាន*** នឹងអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ធ្វើការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគក្នុងតំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយអភិវឌ្ឍន៍បៃតង។

- រៀបចំយុទ្ធសាស្ត្របង្កើនគម្របព្រៃឈើឡើងវិញតាមរយៈការដាំឈើឡើងវិញ។
- ពង្រឹងការគ្រប់គ្រងខ្សែក្រវាត់បៃតងតាមរយៈ ការពង្រឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។
- បង្កើនសមត្ថភាពនៃការអភិរក្ស តាមរយៈការរៀបចំជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវជីវៈចម្រុះ រុក្ខឧទ្យានជាតិ ថ្នាលបណ្តុះកូនឈើ និងការធ្វើទំនើបភាវូបនីយកម្មលើបច្ចេកវិទ្យាទំនើប។

៤.៩២- នៅក្នុងផ្នែកការគ្រប់គ្រងនិងអភិរក្សជីវៈចម្រុះ ***ក្រសួងបរិស្ថាន*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- រៀបចំគោលនយោបាយជាតិនិងលិខិតបទដ្ឋានច្បាប់ស្តីពីជីវៈចម្រុះនិងការប្រើប្រាស់និងការបែងចែកផលប្រយោជន៍នៃធនធាននេសេនេទិច។
- រៀបចំធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ។
- អនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ។
- បញ្ជ្រាបបញ្ហាជីវៈចម្រុះទៅក្នុងផែនការអភិវឌ្ឍនិងតាមវិស័យនីមួយៗ។
- រៀបចំនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានជីវៈចម្រុះ។

៤.៩៣- នៅក្នុងផ្នែកការងារជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើប ***ក្រសួងបរិស្ថាន*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- ពង្រឹងការងារជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើបនៅក្រោមក្របខ័ណ្ឌ ពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាពឲ្យមានប្រសិទ្ធភាពរួមចំណែកថែរក្សាបរិស្ថាន សុខភាពមនុស្ស និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- ពង្រឹងការងារវិភាគ Deoxyribonucleic Acid (DNA) របស់សារពាង្គកាយកែច្នៃរស់ដើម្បីចាប់វត្តមានសារពាង្គកាយនោះ នឹងចាត់វិធានការទប់ស្កាត់ហានិភ័យ។
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជន ផ្នែកជីវសុវត្ថិភាព។

៤.៩៤- ដើម្បីផ្តល់ការអប់រំពីបរិស្ថាននិងព័ត៌មានស្តីពីបរិស្ថាន ***ក្រសួងបរិស្ថាន*** នឹង៖

- បញ្ចូលការអប់រំបរិស្ថានទៅគ្រប់កម្រិតសិក្សានៃការអប់រំក្នុងប្រព័ន្ធ។
- លើកកម្ពស់និងធ្វើឲ្យប្រសើរឡើងនូវការអប់រំក្រៅប្រព័ន្ធលើវិស័យអប់រំបរិស្ថាន ដោយធ្វើសមាហរណកម្មចំណេះដឹង វប្បធម៌ ប្រពៃណី និងសម័យទៅក្នុងបញ្ហាគោលដៅបរិស្ថានក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ។
- កសាងនិងពង្រឹងការអភិវឌ្ឍធនធានមនុស្ស សម្រាប់ការងារអប់រំបរិស្ថាន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

- លើកកម្ពស់និងធ្វើឲ្យប្រសើរឡើងនូវរបៀបផ្លាស់ប្តូរព័ត៌មានបរិស្ថាន ជំនាញ និងធនធាន នៅក្នុងតំបន់ និងផ្តល់ការគាំទ្រចំពោះការងារអប់រំបរិស្ថាន និងបណ្តុះបណ្តាលតាមរយៈបណ្តាការងារក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ។

### ការគ្រប់គ្រងគ្រោះមហន្តរាយ

៤.៩៥- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតការយកចិត្តទុកដាក់លើការអនុវត្ត“***ផែនការសកម្មភាពនិងយុទ្ធសាស្ត្រជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៤-២០១៨***” តាមរយៈការពង្រឹងយន្តការមួយដែលមានការចូលរួមនិងការសម្របសម្រួលដ៏មានប្រសិទ្ធភាពពីគ្រប់អ្នកមានចំណែកពាក់ព័ន្ធ ទាំងក្នុងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិល។ ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ***គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ*** នឹងអនុវត្តកម្មវិធីអាទិភាព ដូចតទៅ៖

- បន្តអនុវត្តឲ្យមានប្រសិទ្ធភាពបន្ថែមទៀតនូវការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ ផែនការ កម្មវិធីអភិវឌ្ឍប្រកបដោយចីរភាពនៅគ្រប់ថ្នាក់ ដោយផ្តោតសំខាន់ទៅលើការត្រៀមបង្ការគ្រោះមហន្តរាយ ការកាត់បន្ថយគ្រោះថ្នាក់ការត្រៀមរៀបចំនិងការកាត់បន្ថយភាពងាយរងគ្រោះ ពិសេសស្ត្រីនិងកុមារ។
- រៀបចំពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីប្រតិបត្តិការស្តង់ដា គោលការណ៍ណែនាំ គោលនយោបាយ និងបង្កើតយន្តការស្របតាមសំណូមពរការងារជាក់ស្តែង ដោយភ្ជាប់ជាមួយថ្នាក់ជាតិ តំបន់ និងពិភពលោក។ ពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ពិសេសថ្នាក់សហគមន៍លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយផ្សារភ្ជាប់ជាមួយការបន្សាំការប្រែប្រួលអាកាសធាតុដែលអាចចូលរួមជាប្រព័ន្ធក្នុងការកសាងភាពធន់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់។
- បញ្ចូលការកាត់បន្ថយហានិភ័យទៅក្នុងការរៀបចំនិងការអនុវត្តកម្មវិធីត្រៀមរៀបចំគ្រោះអាសន្ន ការឆ្លើយតបនិងការស្តារឡើងវិញដើម្បីកាត់បន្ថយការបាត់បង់ដោយគ្រោះមហន្តរាយឲ្យបានជាអតិបរមា និងជំរុញលើកទឹកចិត្តការចូលរួមយ៉ាងពេញលេញពីស្ថាប័នរាជរដ្ឋាភិបាល អង្គការ សង្គមស៊ីវិល ផ្នែកឯកជនផងដែរ។

៤.៩៦- រាជរដ្ឋាភិបាល នឹងពង្រឹង តួនាទី របស់***គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ*** ក្នុងការសម្របសម្រួលការអនុវត្ត ***ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៤-២០១៨*** ដែលមានសមាសភាពសំខាន់ចំនួន៥ គឺ៖

- កសាងស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយអោយបានរឹងមាំនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋានសហគមន៍ ដើម្បីធានានូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ៖
  - ➢ រៀបចំនិងកែសម្រួលឡើងវិញឲ្យមានសុក្រឹតភាពច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីសុំការអនុម័ត។
  - ➢ បង្កើត និងពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ កំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានឲ្យស្របតាមស្ថានភាពជាក់ស្តែង។
  - ➢ រៀបចំគោលនយោបាយជាតិលិខិតបទដ្ឋានគតិយុត្ត ក្របខ័ណ្ឌច្បាប់ក្នុងការគាំទ្រដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
  - ➢ បញ្ជ្រាបការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយនៅក្នុងគោលនយោបាយនិងផែនការអភិវឌ្ឍនៅគ្រប់ថ្នាក់។
- លើកកម្ពស់ការប៉ាន់ប្រមាណនិងតាមដានត្រួតពិនិត្យហានិភ័យគ្រោះមហន្តរាយ និងបង្កើនប្រព័ន្ធប្រកាសឲ្យដឹងមុន៖
  - ➢ ធ្វើការប៉ាន់ប្រមាណហានិភ័យនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន។
  - ➢ រៀបចំនិងកសាងផែនទីនិងមុខសញ្ញាគ្រោះថ្នាក់និងភាពងាយរងគ្រោះ។
  - ➢ បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រោះមហន្តរាយ។
  - ➢ ធ្វើការកត់ត្រាវិភាគផ្សព្វផ្សាយព័ត៌មានស្ថិតិស្តីពីការខូចខាត។
  - ➢ រៀបចំប្រព័ន្ធប្រកាសឲ្យដឹងមុនពីមុខសញ្ញាគ្រោះថ្នាក់នៅតាមឃុំសង្កាត់ ពិសេសអ្នកដែលរស់នៅប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់។
  - ➢ រៀបចំមជ្ឈមណ្ឌលប្រតិបត្តិការគ្រោះអាសន្ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
  - ➢ អភិវឌ្ឍសមត្ថភាពបច្ចេកវិទ្យាស្រាវជ្រាវ វិភាគ ធ្វើផែនទីព្យាករពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និងមុខសញ្ញាគ្រោះថ្នាក់ផ្សេងទៀតដែលទាក់ទងភាពងាយរងគ្រោះ និងផលប៉ះពាល់គ្រោះមហន្តរាយដែលកើតមាន។
  - ➢ រៀបចំកែលម្អទិន្នន័យសម្រាប់ធ្វើការប៉ាន់ប្រមាណ តាមដានត្រួតពិនិត្យ និងការប្រកាសឲ្យដឹងជាមុនឲ្យបានស្របគ្នាទៅនឹងថ្នាក់តំបន់និងថ្នាក់អន្តរជាតិ។
  - ➢ រៀបចំនិងពង្រឹងសមត្ថភាពសម្រាប់កត់ត្រា វិភាគ បូកសរុបផ្សព្វផ្សាយនិងផ្លាស់ប្តូរព័ត៌មាន ស្ថិតិ និងវិធីសាស្ត្រទូទៅសម្រាប់ធ្វើការប៉ាន់ប្រមាណហានិភ័យ និងការតាមដានត្រួតពិនិត្យ។
- អភិវឌ្ឍចំណេះដឹងនិងវិធីសាស្ត្រថ្មីៗ ដោយធ្វើការអប់រំបណ្តុះបណ្តាល កសាងវប្បធម៌សុវត្ថិភាព និងភាពធន់ទៅនឹងគ្រោះមហន្តរាយ៖

- ➢ ប្រមូលចងក្រងផ្សព្វផ្សាយចំណេះដឹងនិងព័ត៌មានស្តីពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព ជូនដល់ប្រជាជន ដើម្បីកសាងនូវវប្បធម៌ត្រៀមបង្ការនិងភាពធន់ទៅនឹងគ្រោះមហន្តរាយ។
- ➢ ផ្តល់ព័ត៌មានដែលងាយយល់ស្តីពីហានិភ័យគ្រោះមហន្តរាយ ដែលអាចការពារបានជូនដល់ប្រជាជនដែលប្រឈមនឹងហានិភ័យ។
- ➢ រៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឃុំ សង្កាត់។
- ➢ ពង្រឹងកិច្ចសហប្រតិបត្តិការ និងជំរុញភាពជាដៃគូក្នុងចំណោមអ្នកដែលមានការពាក់ព័ន្ធ រួមមានអ្នកដែលធ្វើការងារសេដ្ឋកិច្ចសង្គមសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- ➢ លើកកម្ពស់ការប្រើប្រាស់ ការអនុវត្ត និងការទទួលយកព័ត៌មានថ្មី ការទំនាក់ទំនងបច្ចេកវិទ្យាពីលំហអាកាស និងសេវានានា រួមទាំងការសង្កេតមើលផែនទី។
- ➢ រៀបចំសៀវភៅណែនាំសម្រាប់ប្រើប្រាស់នៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ អំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- ➢ រៀបចំវាក្យសព្ទស្តង់ដាអន្តរជាតិទាក់ទងហានិភ័យគ្រោះមហន្តរាយ ជាភាសាជាតិសម្រាប់ប្រើប្រាស់ក្នុងស្ថាប័ន ឯកសារបណ្តុះបណ្តាល និងកម្មវិធីព័ត៌មានសាធារណៈ។
- ➢ ដាក់បញ្ចូលទស្សនាទាននៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងកម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសាលានិងគ្រឹះស្ថានឧត្តមសិក្សា។
- ➢ រៀបចំកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីសិក្សាលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅតាមផ្នែកនានា(អ្នករៀបចំផែនការ អ្នកគ្រប់គ្រងគ្រោះអាសន្ន និងមន្ត្រីរដ្ឋបាល) ដោយធានាឱកាសលើកស្ទួយយេនឌ័រ។
- ➢ ពង្រឹងសមត្ថភាពបច្ចេកទេសនិងវិទ្យាសាស្ត្រ ដើម្បីប៉ាន់ប្រមាណភាពងាយរងគ្រោះផលប៉ះពាល់តាមតំបន់ហានិភ័យទាក់ទងការប្រែប្រួលអាកាសធាតុ។
- ➢ បង្កើតវេទិកាជាតិនិងថ្នាក់ក្រោមជាតិ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- ➢ បង្កើនការចូលរួមរបស់សហគមន៍ក្នុងយុទ្ធនាការអប់រំប្រែកបដោយនិរន្តរភាព និងការពិគ្រោះយោបល់ជាសាធារណៈនៅគ្រប់ថ្នាក់។

- កាត់បន្ថយកត្តាដែលបណ្តាលឲ្យកើតមានមហានិភ័យ៖
  - ➢ បញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទាក់ទងការប្រែប្រួលអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។
  - ➢ បញ្ជ្រាបផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងវិស័យសុខាភិបាល អប់រំ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិវឌ្ឍន៍ជនបទ។

- ➢ លើកកម្ពស់ភាពធន់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់របស់សហគមន៍ នៅតាមតំបន់ដែលងាយរងគ្រោះរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ និងមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗដែលធ្វើឲ្យមានឱនភាពនៃជីវភាពរស់នៅ។
- ➢ ពង្រឹងផែនការស្តារឡើងវិញ រួមមានកម្មវិធីបណ្តុះបណ្តាលចិត្តវិទ្យាសង្គម ដើម្បីកាត់បន្ថយការប៉ះពាល់ផ្លូវចិត្តរបស់ប្រជាជនដែលរងគ្រោះ ជាពិសេស ស្ត្រី និងកុមារ ក្រោយពេលគ្រោះមហន្តរាយ។

• ពង្រឹងការត្រៀមរៀបចំសម្រាប់ឆ្លើយតបគ្រោះអាសន្នឲ្យមានប្រសិទ្ធភាព នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋានសហគមន៍៖

- ➢ រៀបចំផែនការត្រៀមរៀបចំសម្រាប់ឆ្លើយតបគ្រោះមហន្តរាយ និងធ្វើបច្ចុប្បន្នកម្មផែនការត្រៀមបម្រុងគ្រោះអាសន្នឲ្យមានប្រសិទ្ធភាពនៅគ្រប់ថ្នាក់។
- ➢ បង្កើតក្រុមការងារសម្របសម្រួលឆ្លើយតបគ្រោះអាសន្ន។
- ➢ បង្កើតក្រុមរុករក សង្គ្រោះបន្ទាន់។
- ➢ បង្កើតក្រុមសម្របសម្រួលប៉ាន់ប្រមាណគ្រោះមហន្តរាយ។
- ➢ រៀបចំនីតិវិធីសម្របសម្រួលឲ្យបានល្អ ជាមួយមជ្ឈមណ្ឌលសម្របសម្រួលអាស៊ានសម្រាប់ជំនួយមនុស្សធម៌ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងអនុវត្តឲ្យបានល្អកិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយនិងការឆ្លើយតបសង្គ្រោះបន្ទាន់។
- ➢ លើកកម្ពស់ការធ្វើលំហាត់សមយុទ្ធត្រៀមរៀបចំគ្រោះមហន្តរាយ ដូចជាការហាត់ជម្លៀស ដើម្បីធានានូវការឆ្លើយតបបានលឿន មានប្រសិទ្ធភាព និងការទទួលបានស្បៀង និងជំនួយសំខាន់ៗទៅតាមសេចក្តីត្រូវការរបស់មូលដ្ឋាន។
- ➢ រៀបចំមូលនិធិឆ្លើយតបគ្រោះអាសន្ន។
- ➢ បង្កើតទីទួលសុវត្ថិភាពដែលជាសំណង់បំពាក់ដោយឧបករណ៍ ដូចជា បន្ទប់ទឹក បង្គន់អនាម័យ ជម្រកមនុស្សសត្វ។

### ការអភិវឌ្ឍជនបទ

## ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៥

៤.៩៧- រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា នៅតែចាត់ទុកថាការកាត់បន្ថយភាពក្រីក្រតាមរបៀបមួយដ៏ឆាប់តាមដែលអាចធ្វើបាន គឺជាអាទិភាពដ៏ចម្បងមួយ។ ការអភិវឌ្ឍជនបទ គឺមានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដោយហេតុថាប្រជាជនក្រីក្រច្រើនជាង៧៥% រស់នៅតំបន់ជនបទ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះ ដែលផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើកត្តាដែលមានផលប៉ះ

ពាល់ជាវិជ្ជមានទៅលើប្រជាពលរដ្ឋក្រីក្រនៅតំបន់ជនបទ ដូចជាការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការអនុវត្តការធ្វើផែនការមូលដ្ឋានចម្រុះ ការកសាងផ្លូវជនបទ ការផ្គត់ផ្គង់ទឹកនៅជនបទ ការថែទាំសុខភាពបឋមនិងការងារអនាម័យជនបទ ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនកម្ពុជាឲ្យមានភាពប្រសើរជាងមុន ជាពិសេស ប្រជាជននៅជនបទ។

៤.៩៨- ការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័នក្នុងវិស័យអភិវឌ្ឍន៍ជនបទកំពុងដំណើរការទៅយ៉ាងល្អតាមរយៈការរៀបចំក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយដែលចាំបាច់សម្រាប់អនុវត្តសកម្មភាពនានាក្នុងវិស័យនេះ រួមមានគោលនយោបាយជាតិ យុទ្ធសាស្ត្រជាតិ និងបទដ្ឋានគតិយុត្តផ្សេងៗទៀត៖

- **គោលនយោបាយទី១** ធានាលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទឲ្យមានគម្លាតខិតជិតទីប្រជុំជននៅឆ្នាំ២០២៥។
- **គោលនយោបាយទី២** ជំរុញកំណើនសេដ្ឋកិច្ចជនបទតាមរយៈការអភិវឌ្ឍជនបទចម្រុះដោយមានការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ។

៤.៩៩- ដើម្បីសម្រេចបាននូវគោលដៅនានានៃការអភិវឌ្ឍជនបទ រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា នឹងបន្តការផ្តោតការយកចិត្តទុកដាក់លើ៖

- ការពង្រឹងសមត្ថភាពស្ថាប័ន ដោយបន្តការពង្រឹងនិងការអភិវឌ្ឍស្ថាប័នថ្នាក់ជាតិ តាមរយៈការអភិវឌ្ឍ ផ្នែករូបវន្ត និងការកសាងក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តឲ្យបានគ្រប់គ្រាន់ព្រមទាំងបន្តការពង្រឹងនិងការអភិវឌ្ឍស្ថាប័នថ្នាក់ក្រោមជាតិ តាមរយៈការពង្រឹងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ។
- ការអភិវឌ្ឍធនធានមនុស្ស ដោយបន្តការអប់រំ បណ្តុះបណ្តាលនូវចំណេះដឹងជំនាញផ្សេងៗ និងបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រក្នុងការអភិវឌ្ឍដល់មន្ត្រីរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងប្រជាពលរដ្ឋទូទៅ ដោយរួមទាំងប្រជាជនជាជនជាតិដើមភាគតិចផងដែរ។
- ការបន្តអនុវត្ត ការធ្វើផែនការមូលដ្ឋានចម្រុះ ដែលជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់ធ្វើការកំណត់ឲ្យបានប្រសើរជាងមុននូវអាទិភាពទាំងឡាយ និងសម្រាប់ការរៀបចំកសាងកម្មវិធីវិនិយោគសាធារណៈលើការផ្តល់សេវាគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធនៅជនបទ។
- ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទ ដើម្បីធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវារបស់ប្រជាជននៅជនបទ និងធ្វើឲ្យមានភាពងាយស្រួលដល់ការដឹកជញ្ជូន

ផលិតផលនៅជនបទទៅកាន់ទីផ្សារ ជាពិសេស ការសាងសង់ជាជំហានៗនូវផ្លូវមានគុណភាពខ្ពស់ ដែលធានាដល់ការប្រើប្រាស់បានរយៈពេលវែង។

- ការបន្តការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទខ្នាតតូចនៅក្នុងមូលដ្ឋានឃុំ សង្កាត់។
- ការធ្វើឲ្យប្រសើរឡើងនូវការទទួលបានទឹកស្អាតសម្រាប់បរិភោគ និងសេវាអនាម័យ ជាពិសេស នៅសហគមន៍ជនបទដែលរស់នៅក្នុងតំបន់ខ្វះខាតទឹកក៏ដូចជាទឹកប្រើប្រាស់ក្នុងគ្រួសារនិងទឹកសម្រាប់ការស្រោចស្រព។
- ការជំរុញដំណើរការនៃ"**ភូមិមួយផលិតផលមួយ**" សំដៅលើកទឹកចិត្តដល់ការបង្កើតផលិតផល ដែលមានតម្លៃខ្ពស់ ដើម្បីទាក់ទាញឲ្យមានការចូលរួមពីផ្នែកឯកជន។
- ការពង្រឹងនិងគាំទ្រយន្តការដែលមានស្រាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដឹកនាំការអភិវឌ្ឍភូមិ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន និងជំរុញការអភិវឌ្ឍភូមិរបស់ប្រជាពលរដ្ឋ ជាពិសេស របស់គ្រួសារយោធិននិងនគរបាលរស់នៅតាមបណ្តោយព្រំដែនទិសខាងលិចនិងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រែក្លាយអតីតតំបន់ប្រយុទ្ធឲ្យក្លាយទៅជាតំបន់ដែលមានការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ដោយផ្សារភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រសម្រាប់ការការពារបូរណភាពទឹកដី។
- ការបង្កើនថវិកាប្រចាំឆ្នាំ១% នៃថវិកាចំណាយរបស់ក្រសួង ស្ថាប័ន នីមួយៗ ដើម្បីយកទៅធ្វើការអភិវឌ្ឍតំបន់ទល់ដែនកម្ពុជា វៀតណាម ឡាវ និង កម្ពុជា ឡាវ ថៃ។
- ការបន្តជំរុញ ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ តាមរយៈការបង្កើនទំហំមីក្រូហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ ឥណទានជនបទប្រកបដោយប្រសិទ្ធភាពក្នុងអត្រាការប្រាក់ទាប។

## ខ- សកម្មភាព កម្មវិធី និងគម្រោងដើម្បីអនុវត្តគោលនយោបាយអាទិភាព

៤.១០០- ដើម្បីអនុវត្តគោលនយោបាយអាទិភាព សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងអភិវឌ្ឍន៍ជនបទ*** នឹងត្រូវបន្តអនុវត្តសកម្មភាព ដូចតទៅ៖

- បន្តចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី២និងទី៣ ដោយជំរុញបង្កើតអង្គភាពថវិកា និងអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដោយពេញលេញ។
- ចាប់ផ្តើមអនុវត្តកម្មវិធីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា។
- បន្តធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រថវិកា ផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល និងផែនការប្រចាំឆ្នាំ។
- បន្តកែសម្រួលនិងដាក់ឲ្យប្រើប្រាស់ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងកម្មវិធីនានារបស់ក្រសួង។

- បន្តបណ្តុះបណ្តាលបំពាក់បំប៉នមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក និងខិតខំកៀរគរជំនួយជួសជុលនិងសាងសង់មន្ទីរការិយាល័យអភិវឌ្ឍន៍ជនបទស្រុកទាំង២៤ រាជធានី ខេត្ត។
- បន្តអនុវត្តគម្រោងផែនការមូលដ្ឋានចម្រុះ។
- ជំរុញកៀរគរអ្នកវិនិយោគទុនមកវិនិយោគនៅតំបន់ជនបទ ដែលមានសក្តានុពលស្រាប់ ដូចជា ទឹក ផ្លូវ និងអគ្គិសនី ដើម្បីកាត់បន្ថយចំណាកស្រុក និងបង្កើតការងារថ្មីៗបន្ថែមទៀតដល់កសិករក្នុងសហគមន៍ជនបទ។
- បន្តសហប្រតិបត្តិការជាអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានាដើម្បីរួមចំណែកអភិវឌ្ឍជនបទ។
- បន្តអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។
- បន្តរៀបចំនិងអនុវត្តកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ។
- បន្តអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។
- បន្តកសាងសមត្ថភាព និងបណ្តុះបណ្តាលមន្ត្រីរាជការគ្រប់កម្រិត។
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមូលដ្ឋានឲ្យបានគ្រប់ខេត្ត។
- ជំរុញឲ្យបង្កើតមជ្ឈមណ្ឌលឬវិទ្យាស្ថានជាតិអភិវឌ្ឍន៍ជនបទ។
- បន្តអនុវត្តសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច។
- បន្តអនុវត្តកម្មវិធីយេនឌ័រ។
- បន្តថែទាំនិងជួសជុលផ្លូវជនបទ និងសំណង់សិល្បការ្យ។
- បន្តកែលម្អកម្រាលផ្លូវជនបទពីក្រួសក្រហមទៅជាកម្រាលកៅស៊ូពីរជាន់ ឬបេតុង។
- បន្តរៀបចំបញ្ជីសារពើភណ្ឌផ្លូវជនបទឲ្យបានចប់សព្វគ្រប់ទូទាំង២៤រាជធានី ខេត្តដោយកំណត់អត្តសញ្ញាណផ្លូវជនបទ ធ្វើផែនទីផ្លូវជនបទ និងដាក់ស្លាកឈ្មោះផ្លូវ និងសញ្ញាចរាចរណ៍។
- ចាប់ផ្តើមសិក្សានិងសាកល្បងផ្លូវជនបទ និងសំណង់សិល្បការ្យមួយចំនួនបន្សាំនៅនឹងការបម្រែបម្រួលអាកាសធាតុ។
- បណ្តុះបណ្តាល គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ស្តីពីជម្រើសនៃបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្របមួយដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន។
- បន្តបណ្តុះបណ្តាល គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ស្តីពីការធ្វើផែនការអភិវឌ្ឍន៍ភូមិ។
- បន្តអប់រំអំពីសុខភាពនិងអនាម័យ ព្រមទាំងសាងសាង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋក្នុងសហគមន៍ជនបទ។

- បន្តផ្គត់ផ្គង់ទឹកស្អាតដល់តំបន់ជនបទ តាមរយៈជួសជុល ថែទាំ និងសាងសង់អណ្តូងទឹកគ្រប់ប្រភេទ ស្រះទឹក ពាងយក្ស ពិសេស ជំរុញកសាងប្រព័ន្ធចែកចាយទឹកតាមទុយោ នៅតំបន់ដែលមានប្រភពទឹកស្រាប់។
- បង្កើតកម្មវិធីជាតិនៃវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ដែលផ្តល់ធនធានថវិកាពីស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ហើយគាំទ្រដោយដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាលនានា។
- បង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃថ្នាក់ជាតិ សម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ និងការរៀបចំកម្មវិធីជាតិស្តីពីការផ្លាស់ប្តូរទម្លាប់។
- រៀបចំយុទ្ធសាស្ត្រថវិកាសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ដែលផ្តោតលើការជួយគាំទ្រគ្រួសារក្រីក្រនិងគ្រួសារងាយរងគ្រោះ។
- រៀបចំតួនាទីថ្នាក់ក្រោមជាតិ ជាពិសេសឃុំ សង្កាត់ ស្រុក ក្រុង ក្នុងការផ្តល់សេវាការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ ស្របគ្នាជាមួយនឹងការអនុវត្តតាមគោលការណ៍ណែនាំ និងកម្មវិធីកសាងសមត្ថភាព។
- បង្កើតកម្មវិធីជាតិផ្លាស់ប្តូរឥរិយាបថ តាមរយៈការប្រាស្រ័យទាក់ទង។
- បង្កើតយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានសម្រាប់ទឹកនិងអនាម័យ ដោយផ្តោតជាពិសេសលើគ្រួសារក្រីក្រ និងងាយរងគ្រោះ។
- បែងចែកតួនាទីដល់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ(ឃុំ និងស្រុក) ផ្នែកខាងការផ្តល់សេវាពាក់ព័ន្ធជាមួយនឹងទឹក និងអនាម័យ ដោយមានផ្តល់ឲ្យពួកគេនូវគោលការណ៍ណែនាំស្តីពីការអនុវត្ត និងកម្មវិធីកសាងសមត្ថភាព។
- បង្កើតកម្មវិធីសម្រាប់គាំទ្រដល់ប្រតិបត្តិការ និងការគ្រប់គ្រងការផ្គត់ផ្គង់ទឹក នៅថ្នាក់ភូមិ
- បន្តជួសជុលសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូចដើម្បីផ្តល់ទឹកសម្រាប់កសិកម្មខ្នាតតូច និងមធ្យម។
- បន្តជួសជុល សាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដើម្បីផ្តល់ទឹកសម្រាប់កសិកម្មខ្នាតតូចនិងមធ្យម។
- បន្តអប់រំអំពីសុខភាពនិងអនាម័យ ព្រមទាំងសាងសាង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋក្នុងសហគមន៍ជនបទ។
- បន្តអភិវឌ្ឍន៍ភូមិតាមតំបន់ព្រំដែនទិសខាងលិចនិងទិសខាងជើង(កម្ពុជា-ថៃ) និងតំបន់ត្រីកោណកម្ពុជា វៀតណាម និងឡាវ ដែលជាតំបន់ប៉ូលសេដ្ឋកិច្ចទី៤។
- បន្តអនុវត្តកម្មវិធីសន្តិសុខស្បៀងជាលក្ខណៈគ្រួសារនៅក្នុងភូមិ។
- សាងសង់មជ្ឈមណ្ឌលអភិវឌ្ឍន៍និងអភិរក្សជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី។
- បន្តរៀបចំសហគមន៍ជនជាតិដើមភាគតិច។

- ចងក្រងគ្រួសារកសិករជាសហគមន៍សម្រាប់ផ្តល់ឥណទានជនបទក្នុងអត្រាការប្រាក់ទាប ដើម្បីបង្កើតការងារនិងពង្រីកមុខរបររបស់កសិករ។
- ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចជនបទ តាមរយៈវិធីសាស្ត្រចលនាភូមិថ្មី។

**តារាងទី៤.៥ សូចនាករសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទ**

| សូចនាករ | ឯកតា | ២០១៣ ប៉ាន់ស្មាន | ២០១៤ ព្យាករណ៍ | ២០១៥ ព្យាករណ៍ | ២០១៦ ព្យាករណ៍ | ២០១៧ ព្យាករណ៍ | ២០១៨ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ការស្តា និងសាងសង់ផ្លូវជនបទ (លើប្រវែងសរុប ៤០០០០ គ.ម.) | គ.ម. | ២៧ ៧៥០ | ២៨ ៦០០ | ២៩ ៤៥០ | ៣០ ៣០០ | ៣១ ១៥០ | ៣២ ០០០ |
| ប្រវែងផ្លូវជនបទដែលបានក្រាលកៅស៊ូពីរជាន់ ឬបេតុង | គ.ម. | ១២៥ | ៥៥០ | ៩៨០ | ១ ៤៣០ | ១ ៨៨០ | ២ ៣៣០ |
| %ប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | ៤៤,២ | ៤៦,៧ | ៥០ | ៥៣ | ៥៦ | ៦០ |
| %ប្រជាជនជនបទទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយចីរភាព | % | ៣៧,៥ | ៤២ | ៤៦ | ៥០ | ៥៥ | ៦០ |
| ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ | សហគមន៍ | ១០០ | ១៣០ | ១៦០ | ១៩០ | ១២០ | ២៥០ |
| ចំនួនភូមិដែលបានបណ្តុះបណ្តាល គ.អ.ភ. ស្តីពីផែនការអភិវឌ្ឍន៍ភូមិ | ភូមិ | ១ ៦១០ | ១ ៨០០ | ២ ០០០ | ២ ២០០ | ២ ៤០០ | ២ ៦០០ |
| សិក្សានិងសាងសង់សាកល្បងផ្លូវជនបទក្រាលកៅស៊ូ៤៥០គ.ម.ដែលអាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ១០០% | គ.ម. | ០ | ៦៧,៥ | ៩០ | ១១២,៥ | ៩០ | ៩០ |
| កសាងសមត្ថភាពគ.អ.ភ.ស្តីពីជម្រើសនៃបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្របមួយដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន | គ.អ.ភ. | ០ | ១ ៨៥៤ | ២ ៤៧២ | ៣ ០៩១ | ២ ៤៧២ | ២ ៤៧២ |

*ប្រភព: ក្រសួងអភិវឌ្ឍន៍ជនបទ*

### ភូមិមួយ ផលិតផលមួយ

៤.១០១- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ស្តីពីភូមិមួយផលិតផលមួយ ***ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ*** នឹង៖

- បន្តពង្រឹង**ចលនាភូមិមួយ ផលិតផលមួយ** រួមបញ្ចូលការកសាងសមត្ថភាពដល់ថ្នាក់ងារ ស្ថាប័ន សហគមន៍ និងស្ថាប័ននានា ព្រមទាំងរៀបចំឯកសារពាក់ពន្ធ័ចាំបាច់សម្រាប់ជំរុញចលនាភូមិមួយ ផលិតផលមួយ។
- រៀបចំផែនទីផលិតផលភូមិមួយ ផលិតផលមួយ។
- បង្កើតភាពជាដៃគូជាមួយអង្គការ និងស្ថាប័នពាក់ព័ន្ធសម្រាប់ជំរុញចលនាភូមិមួយផលិតផលមួយ។
- លើកទឹកចិត្តប្រជាជនតាមសហគមន៍ និងអ្នកពាក់ព័ន្ធឲ្យផលិតនូវផលិតផលប្រកបដោយគុណភាព សោភណភាព និងឧត្តមភាពទីផ្សារ។
- រៀបចំជនបង្គោលនៅថ្នាក់ក្រោមជាតិពីខេត្តគោលដៅចំនួន១៨។
- អភិវឌ្ឍសាកល្បង គម្រោងចលនាភូមិមួយផលិតផលមួយ ក្នុងខេត្តចំនួន១៨(៦គម្រោងសាកល្បងសម្រាប់ឆ្នាំ២០១៤- ២០១៥ នៅខេត្តចំនួន១០)។
- បើកយុទ្ធនាការស្វែងរកការគាំទ្រមតិ តាមគ្រប់រូបភាពតាមប្រព័ន្ធផ្សព្វផ្សាយ និងឧបករណ៍ទំនាក់ទំនង អប់រំ និងព័ត៌មាន ក្នុងការជំរុញចលនាភូមិមួយ ផលិតផលមួយនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅឯបរទេស។
- រៀបចំការប្រកួតប្រជែងដោយមានការផ្តល់រង្វាន់ សម្រាប់ផលិតផលភូមិមួយផលិតផលមួយ សម្រាប់ខេត្តគោលដៅចំនួន១៨។
- លើកកម្ពស់ការចូលរួមរបស់យុវជន សាកលវិទ្យាល័យ សមាគម ឬសហគមន៍ ឬក្រុមការងារពាក់ព័ន្ធនានាក្នុងសកម្មភាពជំរុញចលនាភូមិមួយ ផលិតផលមួយ។
- រៀបចំយន្តការសម្របសម្រួល រៀបចំ អនុវត្ត ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការងារជំរុញចលនាភូមិមួយផលិតផលមួយ។

## ៤- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

៤.១០២- មុំឬសមាសធាតុរងទាំង៤នៃចតុកោណ ការបន្តការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន (១)ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង (២)ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ (៣)ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី និង(៤)ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។

### ៤.១- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១០៣- រាជរដ្ឋាភិបាលនីតិកាលទី៥ ដាក់ចេញនូវគោលដៅបន្តអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ រួមជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធទីក្រុងឲ្យក្លាយទៅជា

ប្រព័ន្ធភស្តុភារកម្មមួយដ៏រស់រវើក មានសុវត្ថិភាព និងមានប្រសិទ្ធភាព សំដៅរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងជួយលើកស្ទួយសុខុមាលភាពរបស់ប្រជាជន។ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពលើ៖

- ទី១ ការបន្តជំរុញកសាងបណ្តាញផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ ពិសេសការខិតខំក្រាលកៅស៊ូនិងចាក់បេតុង ផ្លូវជនបទឲ្យបានពី៣០០ទៅ៤០០គីឡូម៉ែត្រក្នុងមួយឆ្នាំ។
- ទី២ ការបង្កើនការយកចិត្តទុកដាក់លើការជួសជុល និងការថែទាំប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនពិសេសផ្លូវថ្នល់ តាមរយៈការពង្រឹងយន្តការ និងការកែលម្អប្រព័ន្ធជួសជុល និងថែទាំផ្លូវ រួមទាំងការចាត់វិធានការតឹងរ៉ឹងប្រកបដោយប្រសិទ្ធភាព និងភាពម៉ឺងម៉ាត់ចំពោះការដឹកជញ្ជូនលើសទម្ងន់កំណត់។
- ទី៣ ការបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់លើសុវត្ថិភាពចរាចរណ៍ តាមរយៈការកែលម្អ និងការពង្រឹងការអនុវត្ត"**ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក**" រួមបញ្ចូលនូវការអនុវត្តវិធានការតឹងរ៉ឹងបំផុតចំពោះបទល្មើសចរាចរណ៍ ការពង្រឹងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងការផ្តល់ការអនុញ្ញាតឲ្យយានយន្តធ្វើចរាចរណ៍ ការពង្រឹងយន្តការផ្តល់បណ្ណបើកបរ ការដាក់សញ្ញាចរាចរណ៍ផ្លូវគោក ការរៀបចំសម្រួលលំហូរចរាចរណ៍ ការពង្រឹងសមត្ថភាពនិងសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ ក៏ដូចជាការលើកកម្ពស់ការអប់រំនិងការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍ ស្របតាមទិសស្លោក "**ថ្ងៃនេះ ថ្ងៃស្អែកកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍**"។
- ទី៤ ការរៀបចំ និងការអនុវត្ត**ផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូន** ដើម្បីតភ្ជាប់ផ្ទៃក្នុងប្រទេសផង និងជាមួយប្រទេសជិតខាងផង តាមរយៈការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទឲ្យក្លាយជាប្រព័ន្ធភស្តុភារកម្មមួយដ៏រស់រវើក និងមានភាពប្រកួតប្រជែង ទាំងក្នុងទិដ្ឋភាពនៃការតភ្ជាប់ការដឹកជញ្ជូនពហុរូបភាព និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែនក្នុងគោលដៅលើកកម្ពស់ការវិនិយោគ ពាណិជ្ជកម្ម ទេសចរណ៍ និងការអភិវឌ្ឍជនបទ ដោយក្នុងនោះការយកចិត្តទុកដាក់នឹងត្រូវបានផ្តោតទៅលើការបញ្ចប់ទាំងស្រុងនូវការស្តារនិងការអភិវឌ្ឍផ្លូវដែក ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និងកំពង់ផែ ការសិក្សាអំពីសក្តានុពល និងការវិនិយោគលើការដឹកជញ្ជូនតាមផ្លូវទឹក ព្រមទាំងការកែសម្រួលសេវាពាក់ព័ន្ធនឹងការដឹកជញ្ជូនមួយចំនួនដែលមានលក្ខណៈផ្តាច់មុខ និងការបន្តជំរុញអនុវត្តកិច្ចព្រមព្រៀង និងពិធីសារទាំងឡាយពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលកម្ពុជាជាប្រទេសហត្ថលេខី។
- ទី៥ ការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តចាំបាច់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានពាក់ព័ន្ធ រួមបញ្ចូលនូវការកំណត់ស្តង់ដានិងគុណភាពផ្លូវ ច្បាប់ស្តីពីកំពង់ផែ និងច្បាប់ស្តីពីការ

ដឹកជញ្ជូនផ្លូវគោកជាដើម ដើម្បីជួយសម្រួលដល់ការអនុវត្តផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍។

ទី៦ ការរៀបចំផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង ពិសេសប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនអ្នកដំណើរក្នុងទីក្រុង ព្រមទាំងការតភ្ជាប់រវាងតំបន់មូលដ្ឋានផលិតកម្មជុំវិញក្រុងប៉ូលសេដ្ឋកិច្ចសំខាន់ៗ តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស ជាដើម ដែលនឹងជួយកាត់បន្ថយការកកស្ទះចរាចរណ៍ លើកកម្ពស់ប្រសិទ្ធភាព និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងជួយលើកស្ទួយសុខុមាលភាពប្រជាជន និងធានាចីរភាពបរិស្ថាន ដោយធានានូវសង្គតិភាពជាមួយនឹងក្របខ័ណ្ឌនៃការរៀបចំដែនដី និងនគរូបនីយកម្ម រួមមានជាអាទិ៍គោលនយោបាយជាតិស្តីពីលំនៅឋាន ច្បាប់ពាក់ព័ន្ធនឹងការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍតំបន់ទីក្រុងនិងទីប្រជុំជន ការរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រាវនិងសំណល់រឹង ព្រមទាំងប្រព័ន្ធការពារនិងពន្លត់អគ្គិភ័យ។

ទី៧ ការបន្តជំរុញការចូលរួមរបស់វិស័យឯកជន ក្នុងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ តាមរយៈការពង្រឹងនិងការកែលម្អយន្តការ "**ភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន**" ដោយដាក់ចេញនូវឯកសារគោលនយោបាយស្តីពីការលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជននៅកម្ពុជាដើម្បីបង្កើនភាពទាក់ទាញ និងសម្រួលដល់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តល់ហិរញ្ញប្បទានដោយវិស័យឯកជន។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១០៤- ***ក្រសួងសាធារណការនិងដឹកជញ្ជូន*** មានភារកិច្ចដឹកនាំការអនុវត្តគោលនយោបាយជាតិ ទាក់ទងនឹងគ្រប់ការងារសាងសង់សាធារណៈ តាមរយៈ (១)ការបង្កើតក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងការធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននានា ដើម្បីអភិវឌ្ឍប្រទេស (២)ការសាងសង់និងថែរក្សារាល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដូចជាផ្លូវថ្នល់ ស្ពាន កំពង់ផែ ផ្លូវដែក និងផ្លូវទឹក (៣)ការបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក និងផ្លូវទឹក (៤)ការបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់ការដឹកជញ្ជូនតាមផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក និងការត្រួតពិនិត្យ ការដឹកជញ្ជូនតាមផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក (៥)ការចូលរួមរៀបចំនិងសហការក្នុងការបង្កើតច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទាក់ទងនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការងារដឹកជញ្ជូន (៦)ការសម្រេចឲ្យបាននូវការសាងសង់ផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលកម្ពុជាប្រគល់ជូន (៧)ការធ្វើកិច្ចសហប្រតិបត្តិការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលក្នុងការ

ងារសាងសង់ព្រលានយន្តហោះ និង (៨)ជំរុញឲ្យមានការចូលរួមរបស់ស្ត្រីនិងបុរសនៅក្នុងការអនុវត្តគោលនយោបាយទាំងអស់ខាងលើ ព្រមទាំងបង្កើនតួនាទីនិងភាពអង់អាចផ្នែកបច្ចេកទេសគ្រប់គ្រង ដឹកនាំ និងការពារសិទ្ធិទទួលបាននូវផលប្រយោជន៍របស់ស្ត្រីជាមន្ត្រីរាជការនិងប្រជាពលរដ្ឋក្នុងវិស័យសាធារណការនិងដឹកជញ្ជូន។

៤.១០៥- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងសាធារណការនិងដឹកជញ្ជូន*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

១- ការងារផ្លូវថ្នល់៖

- ស្តារនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ឲ្យបានយ៉ាងហោចប្រវែង៣ ៥០០គ.ម សម្រាប់៥ឆ្នាំខាងមុខ។
- ស្តារនិងសាងសង់ផ្លូវជាតិ១ខ្ទង់ ពីប្រភេទផ្លូវ DBST ទៅ AC។
- ពង្រីកផ្លូវជាតិ១ខ្ទង់នៅជុំវិញទីក្រុងសំខាន់ៗពី២គន្លងទៅ៤គន្លង។
- បង្កើនអត្រាក្រាលកៅស៊ូសម្រាប់ផ្លូវជាតិ២ខ្ទង់ ឲ្យបានពី៥០%ទៅ៩០%។
- រៀបចំប្រព័ន្ធបង្ហូរទឹកការងារទឹកជំនន់ សម្រាប់ផ្លូវជាតិ១ខ្ទង់។
- បង្កើនបន្ថែមផ្លាកសញ្ញាសុវត្ថិភាពចរាចរណ៍សម្រាប់តំបន់ទីប្រជុំជន។
- រៀបចំឲ្យមានសេវាដឹកជញ្ជូនសាធារណៈនៅតាមទីក្រុងសំខាន់ៗ។
- រៀបចំដាក់ឲ្យមានកាម៉េរ៉ា សម្រាប់តាមដានការបើករថយន្តលើសល្បឿនកំណត់នៅតាមផ្លូវជាតិ១ខ្ទង់ ដើម្បីសុវត្ថិភាព និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។
- ជំរុញឲ្យមានការសាងសង់ផ្លូវល្បឿនលឿន(អាទិភាពទី១ ផ្លូវពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុ)។

២- ការងារដឹកជញ្ជូនផ្លូវគោក៖

- បន្តពង្រឹង និងរៀបចំការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងយានដ្ឋានជួសជុលនិងយានដ្ឋានកែច្នៃ។
- បន្តពង្រឹងនិងរៀបចំការអនុវត្តអនុក្រឹត្យស្តីពីការធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក។
- បន្តពង្រឹងនិងរៀបចំការអនុវត្តប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីយានយន្ត។
- បន្តពង្រឹងនិងរៀបចំការអនុវត្តសេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាការដឹកជញ្ជូនផ្លូវគោក។
- បន្តរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក។
- កាត់បន្ថយរយៈពេលនៃការចុះបញ្ជីយានយន្ត ការធ្វើផ្លាកលេខយានយន្ត ការផ្តល់ប័ណ្ណបើកបរ និងពង្រឹងសមត្ថភាពមន្ត្រីឲ្យកាន់តែប្រសើរ។
- បន្តពង្រឹងសមត្ថភាពមន្ត្រីដែលមានចំណែកពាក់ព័ន្ធឲ្យមានជំនាញខ្ពស់បន្ថែមទៀត។
- ជំរុញឲ្យអនុវត្តការងារចុះបញ្ជីយានយន្ត និងការត្រួតពិនិត្យយានយន្ត តាមប្រព័ន្ធព័ត៌មាន វិទ្យា។

៣- ការងារផ្លូវទឹក ដឹកជញ្ជូនផ្លូវទឹក និងដឹកជញ្ជូនតាមនាវាសមុទ្រ៖

**ក. ការងារផ្លូវទឹក**

- បន្តរៀបចំបូមស្តារផ្លូវនាវាចរណ៍ ភ្នំពេញ ក្រចេះ។
- ចុះធ្វើការវាស់ស្ទង់ជម្រៅទឹកទន្លេមេគង្គលើនិងទន្លេមេគង្គក្រោម។
- ជំរុញឲ្យមានការវិនិយោគពីផ្នែកសាធារណៈនិងផ្នែកឯកជនលើការងារកំពង់ផែតាមដងទន្លេ។
- បន្តនិងបញ្ចប់ការសិក្សាអង្កេតធារាសាស្ត្រមេគង្គលើ កំពង់ចាម។

**ខ. ដឹកជញ្ជូនផ្លូវទឹក**

- បន្តរៀបចំបូមស្តារផ្លូវនាវាចរណ៍និងដាក់ពោងសញ្ញានាវាចរណ៍។
- បន្តរៀបចំនិងជំរុញច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធមួយចំនួន ដូចជាសេចក្តីព្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក សេចក្តីព្រាងអនុក្រឹត្យស្តីពីទម្រង់និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតបង្កើតយានដ្ឋាន សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការដឹកជញ្ជូនតាមផ្លូវទឹកឡើងវិញ សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ទីតាំង និងលក្ខណៈបច្ចេកទេសនៃភ្លើងនាវាចរណ៍ សញ្ញានាវាចរណ៍ សញ្ញាភ្លើង សញ្ញាសំឡេង និងសញ្ញាប្រកាសអាសន្ន។
- បន្តកែសម្រួល និងធ្វើវិសោធនកម្មអនុក្រឹត្យស្តីពីនាវាចរណ៍ផ្លូវទន្លេ។
- បន្តការរៀបចំផែនការមេស្តីពីវិស័យដឹកជញ្ជូនផ្លូវទឹក និងជំរុញការចូលរួមវិនិយោគពីផ្នែកឯកជនលើការងារដឹកជញ្ជូនតាមនាវា។

**គ. ដឹកជញ្ជូនតាមនាវាសមុទ្រ**

- បន្តរៀបចំនិងជំរុញការរៀបចំសេចក្តីព្រាងក្រមនាវាចរណ៍សមុទ្រ។
- បន្តរៀបចំនិងជំរុញការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការអនុញ្ញាតឲ្យចូលចតរបស់នាវា/បរទេសនៅតាមកំពង់ផែ។
- បន្តរៀបចំនិងជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតប្រព័ន្ធថ្នាក់ជាតិសម្រាប់ការត្រៀមការឆ្លើយតប និងកិច្ចសហប្រតិបត្តិការទល់នឹងការកំពប់ហៀរប្រេងនៅសមុទ្រ។
- បន្តរៀបចំនិងជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យសៀវភៅវិជ្ជាជីវៈនាវិក។
- បន្តរៀបចំនិងជំរុញការរៀបចំសេចក្តីព្រាងវិញ្ញាបនបត្របញ្ជាក់សមត្ថភាពជំនាញ។
- បន្តពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងវិធានការនានានៃកិច្ចព្រមព្រៀង ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវសមុទ្រ។
- បញ្ចប់ការងារអភិវឌ្ឍន៍ចំណតពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុ។
- ជំរុញឲ្យមានការវិនិយោគកាន់តែច្រើននៅតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តខេត្តព្រះសីហនុ។
- បន្តផ្តល់សេវាកំពង់ផែប្រកបដោយប្រសិទ្ធភាព។

៤- វិស័យផ្លូវដែក៖

- ធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់ទាំងក្នុងប្រទេស និងក្រៅប្រទេសជាមួយទីប្រឹក្សាបច្ចេកទេស Canarail។
- បញ្ចប់ការងារសាងសង់ផ្លូវដែកទិសពាយព្យ (ភ្នំពេញ-ប៉ោយប៉ែត)។
- បញ្ចប់ការសាងសង់កន្លែងរក្សាទុកទំនិញនៅស្ថានីយភ្នំពេញ និងនៅកំពង់ផែក្រុងព្រះសីហនុ។
- សម្រេចឲ្យបានតាមកិច្ចសន្យានូវដំណើរការដឹកជញ្ជូនតាមផ្លូវដែក។
- ជំរុញឲ្យមានការសាងសង់ផ្លូវដែកបន្ថែម។

៥- ការងារពង្រឹងសុវត្ថិភាពចរាចរណ៍ផ្លូវគោកៈ

- បន្តរៀបចំផែនការសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោករយៈពេល១០ឆ្នាំ។
- ត្រៀមការពារគោលនយោបាយជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដោយជំរុញបន្ថែមការរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក។
- តាមដានដំណើរការកសាងមជ្ឈមណ្ឌលត្រួតពិនិត្យមួកសុវត្ថិភាព។
- បន្តរៀបចំធ្វើសិក្ខាសាលាស្តីពីការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

៦- ការងារបង្ការនិងទប់ស្កាត់បទល្មើសយានយន្តដឹកជញ្ជូនលើសទម្ងន់ៈ

- បន្តខិតខំស្វះស្វែងរកវិធីសាស្ត្រនិងយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់នូវភាពអសកម្មទាំងឡាយដោយធ្វើកំណែទម្រង់លើប្រព័ន្ធការងារគ្រប់គ្រង និងដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់ឲ្យមានប្រសិទ្ធភាពខ្ពស់។
- បន្តធ្វើផែនទីនិងរបាយការណ៍ស្តីពីការដឹកជញ្ជូន ព្រមទាំងផ្សព្វផ្សាយដល់ក្រុមហ៊ុន និងម្ចាស់យានយន្ត។

៧- ការរៀបចំផែនការដឹកជញ្ជូនៈ

- រៀបចំគោលនយោបាយលើវិស័យដឹកជញ្ជូននិងផែនការតាមវិស័យនីមួយៗ។
- រៀបចំផែនការមេ expressway និងចាប់ផ្តើតអនុវត្តនូវគម្រោងអាទិភាព។
- រៀបចំផែនការមេផ្លូវដែក និងចាប់ផ្តើមអនុវត្តនូវគម្រោងអាទិភាព។
- រៀបចំផែនការមេផែក្នុងស្រុក ដើម្បីវាយតម្លៃពីការផ្តល់ការវិនិយោគដល់ផ្នែកឯកជន។
- អនុវត្តនូវផែនការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពបរិស្ថាន។
- ធ្វើសមាហរណកម្មគោលនយោបាយ និងផែនការលើវិស័យដឹកជញ្ជូន ឲ្យទៅជាគោលនយោបាយ និងផែនការដឹកជញ្ជូនរបស់ជាតិ។

៨- សេវាបញ្ជូនទំនិញ ការដឹកជញ្ជូនពហុរូបភាព ភស្តុភារកម្ម និងសេវាភ្នាក់ងារនាវាៈ

- រៀបចំផែនការមេស្តីពីការផ្គត់ផ្គង់ភស្តុភារ និងការដឹកជញ្ជូនពហុរូបភាព នៅក្នុងប្រទេស និងតំបន់ ដើម្បីបង្កឲ្យមានការសម្រួលពាណិជ្ជកម្ម ដោយមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធដទៃទៀត។

- បង្កើនប្រសិទ្ធភាពនៃសេវាបញ្ជូនទំនិញ ការដឹកជញ្ជូនពហុរូបភាព ភស្តុភារកម្ម និងភ្នាក់ងារកម្ពុជានាវាចរណ៍"**កាំសាប**"។
- គាំទ្រនិងលើកចិត្តដល់សកម្មភាពរបស់**កាំសាប** ដើម្បីបង្កលក្ខណៈឲ្យភ្នាក់ងារនេះបានបំពេញតួនាទីជាអ្នកបញ្ជូនទំនិញ តំណាង និងជាអ្នកផ្តល់សេវា ក្នុងនាមម្ចាស់នាវា ឬអ្នកជួលនាវា ឬម្ចាស់ទំនិញ និងជាអ្នកផ្តល់ភស្តុភារកម្មទៅតាមសេចក្តីត្រូវការក៏ដូចជាដើម្បីធានាបាននូវប្រសិទ្ធភាព សុវត្ថិភាព គុណភាព ការផ្តល់ដល់គោលដៅទាន់ពេលវេលា តម្លៃសមស្រប ប្រកបដោយឧត្តមភាពប្រកួតប្រជែង។
- បង្កើនសមត្ថភាពផ្ទុករបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុនិងកំពង់ផែស្វយ័តភ្នំពេញ។

៩- ការដឹកជញ្ជូនក្នុងក្រុង៖

- ពង្រឹងនិងធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងបរិស្ថាននិងការដឹកជញ្ជូនក្នុងក្រុង។
- ជំរុញការធ្វើផែនការស្តីពីការដឹកជញ្ជូនក្នុងក្រុង និងការដឹកជញ្ជូនសាធារណៈ នៅតាមទីក្រុងសំខាន់ៗ។
- ជំរុញការរៀបចំប្លង់មេថ្មី និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការដឹកជញ្ជូនក្នុងក្រុង រួមមាន គម្រោងសាងសង់រថភ្លើងស្រាលដឹកអ្នកដំណើរក្នុងក្រុង ដើម្បីចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិកដែលបណ្តាលឲ្យមានការបំពុលបរិស្ថាន ការកើនឡើងកំដៅផែនដីនិងការប្រែប្រួលអាកាសធាតុ។
- ជំរុញការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងភាពស័ក្តិសិទ្ធិនូវហេដ្ឋារចនាសម្ព័ន្ធនិងសេវាដឹកជញ្ជូនសាធារណៈនិងដឹកជញ្ជូនក្នុងក្រុង ដែលគ្រប់គ្រងនិងកាន់កាប់ដោយឯកជន។
- ដាក់ចេញនូវវិធានការបន្ថែមសម្រាប់ការគ្រប់គ្រងចរាចរណ៍ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍។
- ពង្រឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងកែលម្អសុវត្ថិភាពចរាចរណ៍លើផ្លូវថ្នល់។

១០- ការពង្រឹងនិងការកែលម្អនូវការគ្រប់គ្រងមូលដ្ឋានទិន្នន័យស្ថិតិ និងការរៀបចំផែនការសម្រាប់វិស័យដឹកជញ្ជូន៖

- ពង្រឹងនិងកែលម្អការរៀបចំផែនការ ការងារស្ថិតិ និងការគ្រប់គ្រងនិងការផ្សព្វផ្សាយទិន្នន័យក្នុងវិស័យដឹកជញ្ជូន។
- ពង្រឹងកសាងសមត្ថភាពមន្ត្រី និងស្ថាប័នក្នុងវិស័យដឹកជញ្ជូន។

១១- ការកសាងក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន និងការជំរុញការអនុវត្តច្បាប់៖

- អនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី។

- បន្តជំរុញការរៀបចំកសាងច្បាប់ អនុក្រឹត្យ ប្រកាស និងបទដ្ឋានគតិយុត្តផ្សេងៗទៀត ពាក់ព័ន្ធនឹងវិស័យសាធារណការនិងដឹកជញ្ជូនដែលក្រសួងកំពុងរៀបចំ។

### អាកាសចរណ៍ស៊ីវិល

៤.១០៦- ***រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល*** មានភារកិច្ច ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍ វិស័យអាកាសចរណ៍ស៊ីវិលរបស់ប្រទេសកម្ពុជា ដើម្បីធានាឲ្យបាននូវការផ្តល់សេវាដឹកជញ្ជូន តាមផ្លូវអាកាស ទាំងក្នុងស្រុកនិងអន្តរជាតិ ប្រកបដោយសុវត្ថិភាព សន្តិសុខ ប្រសិទ្ធភាព គុណភាព ព្រមទាំងប្រសិទ្ធភាពចំណាយ ក្នុងកម្រិតស្តង់ដាអន្តរជាតិនៃប្រតិបត្តិការ និងដើម្បីធ្វើអតិបរមានីយកម្ម ការរួមចំណែកដ៏សំខាន់របស់វិស័យនេះ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ជាពិសេស ឆ្លើយតបនឹងការលេលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស ទេសចរណ៍ និងអភិវឌ្ឍន៍ជនបទ។ ដើម្បីចូលរួមបន្តអនុវត្តគោលនយោបាយបើកចំហជើងមេឃរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ព្រមទាំងដើម្បីពង្រឹងសន្តិសុខនិងសុវត្ថិភាព ហោះហើរនិងចីរភាពបរិស្ថាន ក៏ដូចជាដើម្បីពង្រឹងសេវាអាកាសយានដ្ឋាន ***រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល*** នឹងអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យអាកាសចរណ៍ស៊ីវិល
  - ធ្វើសមាហរណកម្ម និងធ្វើឲ្យមានសុខដុមនីយកម្មបន្តិចម្តងៗជាមួយនឹងគោលនយោបាយបើកចំហជើងមេឃរបស់អាស៊ាន មហាអនុតំបន់ទន្លេមេគង្គ ក្រុមប្រទេស កម្ពុជា ឡាវ ភូមា វៀតណាម និងកិច្ចសហប្រតិបត្តិការអន្តរជាតិផ្សេងៗទៀត ។
  - ជំរុញការកសាងនិងការកែលម្អសមត្ថភាពស្ថាប័ន ជាពិសេស កែសម្រួលរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីប្រែក្លាយជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការទៅជាបែបវិមជ្ឈការនិងវិសហមជ្ឈការ ក៏ដូចជាដើម្បីឲ្យស្របទៅតាមតម្រូវការរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ។
- ការពង្រឹងសន្តិសុខនិងសុវត្ថិភាព
  - ធ្វើវិសោធនកម្ម**ច្បាប់អាកាសចរណ៍ស៊ីវិល** ដែលបានអនុម័តកន្លងមក ដើម្បីឆ្លើយតបនឹងភាពចាំបាច់ ក្នុងការពង្រឹងសន្តិសុខ សុវត្ថិភាព ក្នុងការហោះហើរ និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ដែលត្រូវបានបង្កឡើងដោយសេវាដឹកជញ្ជូនតាមផ្លូវអាកាស។
  - ពង្រឹងតួនាទីរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលក្នុងការធ្វើបច្ចុប្បន្នកម្ម និងការរៀបចំបទប្បញ្ញត្តិនានាសម្រាប់បទដ្ឋានបច្ចេកទេសនិងសេដ្ឋកិច្ច និងចីរភាពបរិស្ថាន ក្នុងវិស័យអាកាសចរណ៍ស៊ីវិល។

- ➢ លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពត្រួតពិនិត្យសន្តិសុខ សុវត្ថិភាព និងការកាត់បន្ថយផលប៉ះពាល់លើបរិស្ថានក្នុងសេវាដឹកជញ្ជូនតាមផ្លូវអាកាស ដោយផ្អែកលើគោលការណ៍ច្បាប់និងបទប្បញ្ញត្តិនានា។
- ➢ បង្កើតកិច្ចព្រមព្រៀងផ្លូវការនានាជាមួយប្រទេសជិតខាង សម្រាប់ការងារសន្តិសុខ សុវត្ថិភាព និងការផ្លាស់ប្តូរទិន្នន័យប្រតិបត្តិការ។

- ការពង្រឹងសេវានាំផ្លូវអាកាសនិងអាកាសយានដ្ឋាន
  - ➢ កែលម្អនិងធ្វើទំនើបកម្មនូវអាកាសយានដ្ឋានដែលបានកំណត់ និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ រួមមានការអនុវត្តនូវប្រព័ន្ធថ្មីមួយ គឺប្រព័ន្ធគមនាគមន៍នាំផ្លូវ ការឃ្លាំមើលការហោះហើរ និងការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស។
  - ➢ ជំរុញការចូលរួមរបស់វិស័យឯកជន និងសាធារណៈនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និងសេវាអាកាសចរណ៍ ជាពិសេសជំរុញឲ្យមានការវិនិយោគពីវិស័យឯកជនលើសកម្មភាព ដែលបម្រើឲ្យវិស័យអាកាសចរណ៍ដោយផ្ទាល់និងដោយប្រយោល។ សកម្មភាពទាំងនោះ រួមមានអគារលក់ដូរ ទីលានវាយកូនហ្គោល ឧទ្យានសម្រាប់កម្សាន្ត គីឡូអាកាសចរណ៍ ជាដើម ដែលមានទីតាំងនៅក្បែរអាកាសយានដ្ឋាន ហើយដែលនឹងត្រូវជំរុញដើម្បីបង្កើនចំណូល ធានាចីរភាពរបស់អាកាសយានដ្ឋាននិងដើម្បីលើកកម្ពស់វិស័យទេសចរណ៍។
  - ➢ លើកកម្ពស់ការចូលរួមក្នុងការត្រួតពិនិត្យ និងសម្របសម្រួលដំណើរនៃការអភិវឌ្ឍធុរកិច្ចទាំងឡាយដែលស្ថិតនៅក្រោមកិច្ចសន្យាសម្បទាន។
  - ➢ បន្តជំរុញការលើកកម្ពស់សមត្ថភាព និងការយល់ដឹងរបស់និយោជិតស្ត្រី ដើម្បីធ្វើឲ្យប្រសើរឡើងនូវតួនាទីនិងស្ថានភាពរបស់ស្ត្រីនៅក្នុងសេវាដឹកជញ្ជូនតាមផ្លូវអាកាស។
  - ➢ អភិវឌ្ឍព័ត៌មានវិទ្យា ប្រព័ន្ធព័ត៌មានឧតុនិយម ប្រព័ន្ធទិន្នន័យស្ថិតិ និងធ្វើការសិក្សាស្រាវជ្រាវ។

## ៤.២- ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១០៧- រាជរដ្ឋាភិបាលកម្ពុជាបានខិតខំស្តារ និងកសាងប្រព័ន្ធធារាសាស្ត្របន្ថែមទៀត ហើយបានដាក់ចេញនូវវិធានការនានា ដើម្បីប្រើឲ្យអស់លទ្ធភាពនូវសក្តានុពលពីប្រព័ន្ធធារាសាស្ត្រនេះ សម្រាប់ដោះស្រាយបញ្ហាទឹកក្នុងវិស័យកសិកម្ម។ ជាលទ្ធផល សមត្ថភាពអាងស្តុកទឹកត្រូវបានពង្រីក ហើយលទ្ធភាពនៃការដោះស្រាយទឹកសម្រាប់ការដាំដុះក៏បានកើនឡើងដែរ។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកដែលមានការចូលរួមកាន់តែច្រើន

ឡើងពីសំណាក់កសិករ។ ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន និងតំបន់ជនបទក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ។

៤.១០៨- រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា នឹងបន្តលើកកម្ពស់ការគ្រប់គ្រងធនធានទឹកនិងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ បង្កើនប្រសិទ្ធភាពនៃការថែទាំនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ជំរុញសមាហរណកម្មប្រព័ន្ធធារាសាស្ត្រជាមួយនឹងការអភិវឌ្ឍវារីអគ្គិសនី និងប្រព័ន្ធដឹកជញ្ជូន ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត ស្ថាប័ន និងធនធានមនុស្ស។ រាជរដ្ឋាភិបាល នឹងផ្តោតអាទិភាពលើ៖

- ទី១ ការជំរុញវិត្តារកម្មប្រព័ន្ធធារាសាស្ត្រ តាមរយៈការកៀរគរធនធានសាធារណៈ និងធនធានពីប្រភពផ្សេងទៀត ដើម្បីសមត្ថភាពស្រោចស្រពប្រកបដោយវិចារណភាព ដោយយកចិត្តទុកដាក់លើការលើកកម្ពស់ស្តង់ដា និងគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ក៏ដូចជាប្រសិទ្ធភាពនៃការវិនិយោគគួបផ្សំនឹងការកសាងអាងស្តុកទឹកបម្រុង និងការបន្តរៀបចំប្រព័ន្ធប្រឡាយស្រោចស្រពឲ្យបានពេញលេញ ដោយយកចិត្តទុកដាក់ផងដែរដល់ភាពចាំបាច់ក្នុងការត្រៀមខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។
- ទី២ ការលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ដោយផ្តោតលើការពង្រឹងក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត និងយន្តការនៃការប្រើប្រាស់ទឹក ការថែទាំ និងហិរញ្ញប្បទាន តាមរយៈការជំរុញរៀបចំនិងអនុវត្តផែនការមេសម្រាប់ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ ការបន្តពង្រឹងយន្តការថែទាំ ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រ ព្រមទាំងការជំរុញរៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគមន៍កសិករអ្នកប្រើប្រាស់ទឹក ការគ្រប់គ្រងអាងទន្លេ ការគ្រប់គ្រងគុណភាពទឹក និងការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស។
- ទី៣ ការជំរុញការសម្របសម្រួលស្ថាប័ន សំដៅធ្វើសមាហរណកម្មការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រជាមួយនឹងការអភិវឌ្ឍវារីអគ្គិសនី និងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិនិយោគនិងការប្រើប្រាស់ធនធានទឹក។
- ទី៤ ការលើកកម្ពស់ចីរភាពនៃការប្រើប្រាស់ធនធានទឹក តាមរយៈការអនុវត្តឲ្យបានម៉ឺងម៉ាត់នូវ ***ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា*** និងច្បាប់ពាក់ព័ន្ធផ្សេងៗ។
- ទី៥ ការលើកកម្ពស់ការគ្រប់គ្រងនិងទប់ទល់នឹងទឹកជំនន់ តាមរយៈការសាងសង់ប្រព័ន្ធដោះទឹក ទំនប់ការពារទឹក អាងស្តុកទឹក និងប្រឡាយបង្វៃរទឹក ដើម្បីកាត់បន្ថយផលប៉ះពាល់ពីគ្រោះធម្មជាតិ។

ទី៦ ការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ និងទីប្រជុំជន តាមរយៈការជំរុញអនុវត្ត ***យុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ២០១១-២០២៥*** ព្រមទាំងការរៀបចំផែនការជាក់លាក់ និងការលើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជន។

ទី៧ ការបន្តខិតខំពង្រឹងនិងពង្រីកយន្តការតាមដាន ព្យាករនិងផ្សព្វផ្សាយព័ត៌មានជលសាស្ត្រ និងឧតុនិយមឲ្យបានទាន់ពេលវេលា និងឲ្យកាន់តែមានសុក្រឹតភាព ពិសេស សំដៅធានាសុវត្ថិភាពនៃការដាំដុះ និងត្រៀមទប់ទល់នឹងបច្ច័យនៃគ្រោះមហន្តរាយជាយថាហេតុ។

ទី៨ ការបន្តចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យទឹក ដើម្បីធានាចីរភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានទឹក ក៏ដូចជាក្នុងការដោះស្រាយបច្ច័យអាក្រក់បណ្តាលមកពីគ្រោះទឹកជំនន់និងភាពរាំងស្ងួត ព្រមទាំងពីការប្រែប្រួលអាកាសធាតុ។

៤.១០៩- រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតការយកចិត្តទុកដាក់លើការធានាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានទឹកស្អាត តាមរយៈការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ជូនប្រជាជនគ្រប់រូបដើម្បីធានាសន្តិសុខស្បៀងក្នុងជីវភាពរស់នៅរបស់ប្រជាជនស្របតាម **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** ហើយនឹងធានាឲ្យបាននូវប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានទឹកពុំមានការបំពុល។ ចក្ខុវិស័យសម្រាប់ពេលអនាគតក្នុងការគ្រប់គ្រងទឹកក្នុងអាងទន្លេមេគង្គ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តចាត់វិធានការធ្វើវិចារណកម្មលើការប្រើប្រាស់ធនធានទឹកនៅគ្រប់ដងស្ទឹង បឹង និងទន្លេរួមទាំងបឹងទន្លេសាបផងដែរ។

៤.១១០- រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រតាមរយៈការពង្រឹងសមត្ថភាពស្ថាប័នរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ តាមរយៈការបង្កើនប្រសិទ្ធភាពនេះ នឹងធ្វើឲ្យមានការកើនឡើងនូវការចូលរួមរបស់ប្រជាជនក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រតាមបែបវិមជ្ឈការ និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ដើម្បីដោះស្រាយទឹកសម្រាប់បង្កបង្កើនផលផង សម្រួលដល់ការធ្វើដំណើររបស់ប្រជាជនផង និងអនុវត្តវារីវប្បកម្មផង ហើយនឹងពង្រឹងសមត្ថភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹកផងដែរ។ ទន្ទឹមនឹងការកៀរគរធនធានពីដៃគូអភិវឌ្ឍ និងប្រើប្រាស់ធនធានផ្ទាល់របស់ខ្លួន ដើម្បីធ្វើការវិនិយោគក្នុងវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញឲ្យវិស័យឯកជនបានចូលរួមចំណែកយ៉ាងសកម្មបន្ថែមទៀតក្នុងការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹកស្អាត។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១១១- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា សកម្មភាពរបស់***ក្រសួងធនធានទឹក និងឧតុនិយម*** នឹងត្រូវផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រ៥ផ្នែក គឺ៖

- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹក និងការអនុវត្តអនុគ្គរភាពប្រព័ន្ធធារាសាស្ត្រ។
- ការគ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួត។
- ការជំរុញការរៀបចំច្បាប់ បទប្បញ្ញត្តិ និងចីរភាពទឹក។
- ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម។
- ការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងរដ្ឋបាលនិងការអភិវឌ្ឍធនធានមនុស្ស។

៤.១១២- នៅក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹក និងការអនុវត្តអនុគ្គរភាពប្រព័ន្ធធារាសាស្ត្រ ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម៖

- ស្តារឡើងវិញនិងសាងសង់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ក្នុងគោលបំណងឆ្លើយតបជាបន្ទាន់នូវតម្រូវការទឹកសម្រាប់កសិកម្ម។
- ផ្តល់អាទិភាពខ្ពស់ដល់ការស្តារឡើងវិញនិងសាងសង់ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹកនៅតាមតំបន់ដែលភាពក្រីក្រមានកម្រិតខ្ពស់ ឬពិនិត្យឃើញថាមានសក្តានុពលសេដ្ឋកិច្ចដែលត្រូវផ្តល់ទឹកដល់ផលិតកម្ម។
- ជំរុញឲ្យមានការថែទាំនិងពង្រីកបន្ថែមនូវអាងតម្កល់ទឹក ស្រះទឹក ប្រឡាយនាំទឹកនិងប្រព័ន្ធដោះទឹកដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកសម្រាប់ផ្ទៃដីបង្កបង្កើនវារីវប្បកម្ម ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនិងសត្វពាហនៈ។
- ជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាគ្រប់គ្រងទឹកសមស្របមួយក្នុងតំបន់កសិកម្ម ដែលពឹងផ្អែកលើទឹកភ្លៀង។
- ប្រមូលផ្តុំឲ្យមានការចូលរួមពីកសិករ ជាពិសេស កសិករស្ត្រីអ្នកពាក់ព័ន្ធ និងផ្នែកឯកជននៅគ្រប់ដំណាក់កាលនៃការរៀបចំគម្រោងការកែលម្អ ព្រមទាំងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹក។
- ជំរុញការសិក្សា និងរៀបចំផែនការអភិវឌ្ឍន៍អាងទន្លេសម្រាប់រយៈពេលខ្លី មធ្យម និងវែង ព្រមទាំងគិតគូរដល់ការប្រែប្រួលធារទឹកទន្លេ ការផ្លាស់ប្តូរចរន្តទឹក និងល្អាងទឹកធម្មជាតិក្រោមដី ដើម្បីធានាដល់ការប្រើប្រាស់ធនធានទឹកនាពេលបច្ចុប្បន្ននិងពេលអនាគត។
- ផ្តោតការយកចិត្តទុកដាក់លើកិច្ចប្រឹងប្រែងលើអាងស្ទឹងអាទិភាព ព្រមទាំងអភិរក្សលទ្ធភាពល្អាងទឹកក្រោមដី។
- អនុវត្តវិធីសាស្ត្រចម្រុះចំពោះការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកដោយគិតគូរឲ្យបានច្បាស់លាស់ពីប្រភពទឹក ការផ្សារភ្ជាប់គ្នារវាងធនធានទឹកជាមួយនឹងផ្នែកផ្សេងទៀតនៃបរិស្ថានការប្រែប្រួលនូវតម្រូវការរបស់មនុស្ស និងបរិស្ថានមកលើធនធានទឹក ព្រមទាំងតម្រូវការនូវវិធីសាស្ត្រនានាក្នុងការអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

- បង្កើនការយល់ដឹង និងជំរុញការរៀបចំការអនុវត្តផែនការគ្រប់គ្រងនិងផែនការអភិវឌ្ឍអាងទន្លេ ដោយមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធ អ្នកពាក់ព័ន្ធ និងអ្នកទទួលផល ជាពិសេស ស្ត្រី។
- ជំរុញឲ្យមានការចូលរួមពីសហគមន៍កសិករប្រើប្រាស់ទឹក អ្នកទទួលផលនិងផ្នែកឯកជន នៅគ្រប់ដំណាក់កាលនៃការអភិវឌ្ឍនិងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនិងប្រព័ន្ធដោះទឹក។
- បង្កើនសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹកស្តីពីរបៀបគ្រប់គ្រង ថែទាំ និងកិច្ចដំណើរការប្រព័ន្ធធារាសាស្ត្រ ដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍន៍។
- បន្តពង្រឹង និងរៀបចំបន្ថែមនូវសហគមន៍កសិករប្រើប្រាស់ទឹកដើម្បីចូលរួមក្នុងការគ្រប់គ្រងទឹក បែងចែកទឹក និងថែរក្សាប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងរក្សាបាននូវនិរន្តរភាព។
- ជំរុញការវិនិយោគពីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ ព្រមទាំងផ្នែកឯកជនដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផលនិងកិច្ចអភិវឌ្ឍន៍។
- បង្កើនប្រាក់ចំណូលតាមរយៈផ្នែកធារាសាស្ត្រកសិកម្ម និងធានាបន្តការវិនិយោគក្នុងវិស័យធនធានទឹកសម្រាប់ការផលិតដំណាំ។

៤.១១៣- នៅក្នុងផ្នែកនៃការគ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត ***ក្រសួងធនធានទឹក និងឧតុនិយម*** នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម៖

- ជំរុញនិងយកចិត្តទុកដាក់លើ ការសិក្សានិងការសាងសង់ ទំនប់ការពារទឹកជំនន់ព្រមទាំងប្រឡាយដោះទឹក ក្នុងគោលបំណងកាត់បន្ថយឲ្យបានជាអតិបរមានូវគ្រោះធម្មជាតិដែលបណ្តាលមកពីទឹក។
- អនុវត្តគ្រប់សកម្មភាពទាំងអស់ ដើម្បីកាត់បន្ថយទឹកជំនន់នៅគ្រប់តំបន់ ដែលផ្តល់នូវសក្តានុពលសេដ្ឋកិច្ចខ្ពស់ តាមរយៈការអប់រំដល់សហគមន៍ និងការផ្តល់ព័ត៌មានជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។
- ឆ្លើយតបជាបន្ទាន់ចំពោះតម្រូវការរបស់ប្រជាជននៅតំបន់ដែលទទួលរងគ្រោះរាំងស្ងួត គ្រោះទឹកជំនន់និងគ្រោះមហន្តរាយផ្សេងទៀតដែលបង្កឡើងដោយសារទឹក។
- បន្តលើកទឹកចិត្តដល់ប្រជាពលរដ្ឋគ្រប់រូប និងគ្រប់ស្ថាប័នឱ្យចូលរួមក្នុងសកម្មភាពកាត់បន្ថយគ្រោះទឹកជំនន់ ដូចជាការរៀបចំទីទួលសុវត្ថិភាព ការផ្គត់ផ្គង់សម្ភារបរិក្ខារ និងគ្រឿងចក្រ ការផ្តល់ការអប់រំ ការបង្ហាញពីបច្ចេកវិទ្យាថ្មីៗដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែងជាដើម។
- ចូលរួមយ៉ាងសកម្មក្នុងកម្មវិធីជាតិ និងអន្តរជាតិនានា ដើម្បីកាត់បន្ថយឥទ្ធិពលនៃគ្រោះមហន្តរាយដែលបង្កឡើងដោយសារទឹក។
- សាងសង់ស្ថានីយបូមទឹក ជួសជុលស្ថានីយបូមទឹក និងជួសជុលម៉ាស៊ីនបូមទឹក។

- ត្រៀមលក្ខណៈចុះធ្វើអន្តរាគមន៍បូមទឹកសង្គ្រោះដំណាំស្រូវប្រាំងនិងស្រូវវស្សា ពេលជួបការខ្វះខាតទឹក និងគ្រោះរាំងស្ងួតជូនប្រជាកសិករគ្រប់ខេត្ត ជាពិសេស តំបន់នៅជិតប្រភពទឹកហើយគ្មានប្រព័ន្ធស្រោចស្រពទៅដល់។
- រៀបចំផែនទីបង្ហាញតំបន់រងគ្រោះដោយសារទឹកជំនន់។

៤.១១៤- នៅក្នុងផ្នែកនៃ *ការជំរុញការរៀបចំច្បាប់ បទប្បញ្ញត្តិ និងនិន្នភាពទឹក* ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម៖

- ក្រោយពីច្បាប់ស្តីពី**ការគ្រប់គ្រងធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា** បានចូលជាធរមានមកក្រសួងធនធានទឹក និងឧតុនិយម បាននឹងកំពុងរៀបចំអនុក្រឹត្យចំនួន៤បន្ថែមទៀត ដូចខាងក្រោម៖
  - ➢ អនុក្រឹត្យស្តីពីសហគមន៍កសិករប្រើប្រាស់ទឹក។
  - ➢ អនុក្រឹត្យស្តីពីអាជ្ញាបណ្ណទឹកនិងការចែកចាយទឹក។
  - ➢ អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ។
  - ➢ អនុក្រឹត្យស្តីពីគុណភាពទឹក។
- ពង្រឹងនិងជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក និងបទប្បញ្ញត្តិ ដែលពាក់ព័ន្ធនានា ដើម្បីតាមដានត្រួតពិនិត្យនិងទប់ស្កាត់នូវរាល់គម្រោងស្ថាបនាឡើងវិញនិងសាងសង់ ដែលអាចមានផលប៉ះពាល់ដល់ធនធានទឹកនិងប្រព័ន្ធអេកូឡូស៊ី។
- រក្សាឲ្យបាននូវជារទឹកនិងកម្រិតកម្ពស់អប្បបរមា ទឹកទន្លេ ស្ទឹង បឹងបួរ ព្រែក ដើម្បីធានានូវចីរភាព ប្រព័ន្ធអេកូឡូស៊ី និងនាវាចរណ៍។
- ហាមឃាត់ និងមានវិធានការជាបន្ទាន់ ចំពោះការចាក់បំពេញ ការជីក ឬរំលោភបំពានដោយខុសច្បាប់លើផ្លូវទឹក ទន្លេ ស្ទឹង ឬដីទំនាបដែលលិចទឹកជាប្រចាំ និងឆ្នេរសមុទ្រដែលបណ្តាលឲ្យមានផលប៉ះពាល់ដល់ធនធានទឹក ប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន។
- ពង្រឹងការងារអភិរក្សអាងទឹកនិងបឹងធម្មជាតិ ដែលមានលទ្ធភាពស្តុកទឹក ដើម្បីជួយដល់ការកាត់បន្ថយទឹកជំនន់ ព្រមទាំងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី។
- រៀបចំអនុក្រឹត្យស្តីពីការកំណត់ទីតាំងភូមិសាស្ត្រនៃប្រព័ន្ធធារាសាស្ត្រ និងអាងស្តុកទឹក ដើម្បីចៀសវាងការរំលោភបំពាននានា ដែលអាចកើតមានឡើងមកលើតំបន់គ្របដណ្តប់របស់ប្រព័ន្ធធារាសាស្ត្រ។

៤.១១៥- នៅក្នុងផ្នែកនៃ *ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម* ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

- បន្តពង្រឹងនិងពង្រីកប្រព័ន្ធឧតុនិយម និងជលសាស្ត្រ រួមទាំងការប្រមូលផ្តុំព័ត៌មាននិងការផ្សព្វផ្សាយ។

- ធ្វើការព្យាករ និងប្រកាសភាពអាសន្នដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រងគ្រោះពីភាពរាំងស្ងួត ទឹកជំនន់ និងព្យុះ សម្រាប់រយៈពេលខ្លី មធ្យម និងវែង។
- កែលម្អនិងសាងសង់ស្ថានីយឧតុនិយមនិងជលសាស្ត្រ ព្រមទាំងប៉ុស្តិ៍តម្រងទឹកភ្លៀង និងក្តារវាស់ កម្ពស់ទឹក នៅតាមទីតាំង និងស្ទឹងសំខាន់ៗ រួមទាំងការប្រមូលព័ត៌មាន និងការផ្សព្វផ្សាយ។
- ដំឡើងប្រព័ន្ធអង្កេតជលសាស្ត្រ ដើម្បីផ្តល់នូវកម្រិតកម្ពស់ទឹកជាក់លាក់ និងទិន្នន័យធារទឹក សម្រាប់ការព្យាករទឹកជំនន់ និងទិន្នន័យជលសាស្ត្រដែលត្រូវយកទៅប្រើប្រាស់សម្រាប់ការរៀបចំគម្រោង និងការគ្រប់គ្រងធនធានទឹក។
- ដំឡើងប្រព័ន្ធអង្កេតឧតុនិយម ដើម្បីទទួលបាននូវទិន្នន័យធាតុអាកាសជាក់លាក់សម្រាប់ព្យាករអាកាសធាតុ ការរៀបចំគម្រោង និងសម្រាប់គោលបំណងផ្សេងៗទៀត។
- ផ្តល់ព័ត៌មានស្តីពីការព្យាករអាកាសធាតុ ការណែនាំ និងការអប់រំ ដល់សាធារណជន ដើម្បីលើកកម្ពស់ចំណេះដឹងពួកគាត់ឲ្យចេះបង្ការទប់ស្កាត់ និងកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់ ដែលបង្កឡើងដោយការប្រែប្រួលធម្មជាតិ និងអាកាសធាតុ ដូចជាខ្យល់ព្យុះ រន្ទះ ស៊ូណាមី ទឹកជំនន់ ជាដើម។
- រៀបចំសារពើភណ្ឌនិងផែនទីភូមិសាស្ត្រសម្រាប់ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធការពារទឹកជំនន់ ទំនប់ការពារ ទឹកប្រៃ អាងទន្លេ ស្ទឹង ផ្ទៃដីលិចទឹក និងការគ្រប់គ្រងធនធានទឹកដោយមានមូលដ្ឋានទិន្នន័យគ្រប់គ្រាន់។

៤.១១៦- នៅក្នុងផ្នែកនៃ*ការធ្វើឲ្យប្រសើរឡើងការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍធនធានមនុស្ស* ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

- ពង្រឹងដំណើរការរដ្ឋបាល និងផ្តល់ការបណ្តុះបណ្តាលក្នុងការងារដល់មន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ដើម្បីឆ្លើយតបទៅនឹងកម្រិតស្តង់ដាជាតិនិងអន្តរជាតិ។
- បន្តពង្រឹងសមត្ថភាពរបស់មន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងសមត្ថភាពរបស់សហគមន៍កសិករ ប្រើប្រាស់ទឹកឲ្យយល់ដឹងពីអត្ថប្រយោជន៍របស់ទឹកចំពោះជីវភាពប្រចាំថ្ងៃនិងការអភិវឌ្ឍសេដ្ឋកិច្ច និងណែនាំពួកគាត់ឲ្យចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការសម្រាប់ការគ្រប់គ្រង ការថែទាំ ការអភិរក្ស និងការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាពនិងចីរភាព ដើម្បីរក្សាបាននូវប្រព័ន្ធអេកូឡូស៊ីល្អ ដោយប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ដូចជាការរៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និងបញ្ចូលបញ្ហាទាំងនេះទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សា និងធ្វើការផ្សព្វផ្សាយព័ត៌មាននេះឲ្យបានទូលំទូលាយតាមរយៈព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត។
- បង្កើតប្រព័ន្ធការងារយេនឌ័រ នៅគ្រប់មន្ទីរធនធានទឹក និងឧតុនិយម រាជធានី ខេត្ត។

- បង្កើនការយល់ដឹងនិងការវិភាគពីយេនឌ័រ នៅគ្រប់រាជធានី ខេត្ត។
- ធានាឲ្យមានការចូលរួមរបស់ក្រុមការងារយេនឌ័រ នៅក្នុងគ្រប់ទិដ្ឋភាពការងាររបស់ក្រសួងធនធានទឹក និងឧតុនិយម។
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងដល់មន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ទាំងបុរសនិងស្ត្រី ដើម្បីអនុវត្តវិធីសាស្ត្រនិងបច្ចេកវិទ្យាស្រោចស្រពនិងដោះទឹក។

៤.១១៧- នៅក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងផ្តោតលើ៖

- ការប្រើប្រាស់ជាអតិបរមានូវសក្តានុពលនៃប្រព័ន្ធធារាសាស្ត្រ ដើម្បីជាផលប្រយោជន៍សម្រាប់ការដោះស្រាយបញ្ហាទឹកដល់វិស័យកសិកម្ម។
- ការធានាឲ្យមានការចូលរួមច្រើនជាងមុនពីកសិករទាំងឡាយនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹក។
- ការពង្រឹងនូវដំណើរការនៃការផ្តល់អាទិភាពដល់ការស្តារឡើងវិញ ការសាងសង់ ការថែទាំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដូចជាអាងស្តុកទឹក ប្រព័ន្ធដោះទឹក ប្រឡាយទឹក ប្រព័ន្ធត្រួតពិនិត្យទឹកជំនន់ ទំនប់ការពារទឹកប្រៃ និងស្ថានីយបូមទឹក ដើម្បីបង្កើនផ្ទៃដីដាំដុះនិងផលិតកម្មកសិកម្ម។
- ការយកចិត្តទុកដាក់លើមតិយោបល់និងសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានទឹកស្អាត និងការធានានូវសុវត្ថិភាពស្បៀងក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដើម្បីធ្វើឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងដើម្បីធានាឲ្យមាននូវប្រព័ន្ធអេកូឡូស៊ីនិងទឹកដែលគ្មានការបំពុលនៅក្នុងអាងទន្លេមេគង្គ និងបន្តសិក្សាពីការប្រើប្រាស់ធនធានទឹកក្នុងទន្លេ បឹងបួរ ស្ទឹង និងទន្លេសាប។
- ការធានាឲ្យមានការចូលរួមរបស់ស្ថាប័ននានា និងភាពជាម្ចាស់របស់ប្រជាជនក្នុងការប្រើប្រាស់និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។
- ការធានាឲ្យមានទឹកស្អាតគ្រប់គ្រាន់ ហើយគុណភាពទឹកឆ្លើយតបទៅនឹងតម្រូវការនៅគ្រប់វិស័យពេញទូទាំងឆ្នាំ និងដើម្បីការពារប្រព័ន្ធអេកូឡូស៊ី។
- ការកាត់បន្ថយនៅកម្រិតតិចបំផុតនូវផលប៉ះពាល់ពីទឹកជំនន់ និងកសាងសមត្ថភាពដើម្បីការពារទល់នឹង ទឹកជំនន់ ដែលបណ្តាលមកពីទឹកភ្លៀងនិងទឹកសមុទ្រ។
- ការបញ្ចៀសការបំពុលធនធានទឹក ដើម្បីការពារប្រព័ន្ធអេកូឡូស៊ី ជាពិសេស ធនធានត្រី។

### ការអភិវឌ្ឍអាងទន្លេមេគង្គប្រកបដោយចីរភាព

៤.១១៨- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តកិច្ចសហប្រតិបត្តិការដោយពេញទំហឹងជាមួយបណ្តាប្រទេសជាសមាជិកទន្លេមេគង្គក្រោមទម្រង់ការគណៈកម្មការទន្លេមេគង្គ ដើម្បីធានាការអភិវឌ្ឍ

ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ។ ជាងនេះទៅទៀត នៅក្នុងកិច្ចប្រជុំកំពូលលើកទី១ របស់គណៈកម្មការទន្លេមេគង្គ ដែលបានប្រារព្ធឡើងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ នៅហួហ៊ីន ប្រមុខរដ្ឋាភិបាលប្រទេសជាសមាជិកមេគង្គ បានប្តេជ្ញាចិត្តនឹងធ្វើស្វ័យាភិបាលហិរញ្ញវត្ថុពេញលេញសម្រាប់គណៈកម្មការទន្លេមេគង្គក្នុងឆ្នាំ២០៣០ខាងមុខ ដែលក្នុងនោះប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គនីមួយៗ ត្រូវបង្កើននូវវិភាគទានហិរញ្ញវត្ថុរបស់ខ្លួនដើម្បីដំណើរការគណៈកម្មការទន្លេមេគង្គ និងត្រៀមខ្លួនដើម្បីទទួលការរ៉ាប់រងជាបណ្តើរៗ ដែលបានចាប់ផ្តើមពីឆ្នាំ២០១២ និងឈានទៅទទួលខុសត្រូវពេញលេញក្នុងឆ្នាំ២០៣០។

៤.១១៩- ដើម្បីអនុវត្តគោលនយោបាយអាទិភាព រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាសមាជិកមេគង្គក្នុងការធ្វើបច្ចុប្បន្នកម្ម **ផែនការយុទ្ធសាស្ត្រយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង** និងអនុវត្តគម្រោងនានាដែលបានគ្រោងទុកក្រោមទម្រង់ការរបស់ ***គណៈកម្មការទន្លេមេគង្គ*** ដែលគម្រោងទាំងនោះរួមមានកម្មវិធីកសាងផែនការអភិវឌ្ឍអាងទន្លេ ជលផល កសិកម្ម ស្រោចស្រព វារីអគ្គិសនី ការគ្រប់គ្រងទឹកជំនន់ ការគ្រប់គ្រងភាពរាំងស្ងួត ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានទឹកចម្រុះ ការគ្រប់គ្រងព័ត៌មាននិងចំណេះដឹង និងការកសាងសមត្ថភាពចម្រុះ។ ទន្ទឹមនឹងនេះ ផែនទីវិថីសម្រាប់ធ្វើវិមជ្ឈការមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេកំពុងត្រូវបានរៀបចំនិងកែសម្រួល សម្រាប់ការអនុវត្តជាបណ្តើរៗចាប់ពីឆ្នាំ២០១២មក ហើយរំពឹងថានឹងមានការអនុវត្តពេញលេញនៅក្នុងឆ្នាំ២០៣០ ដោយប្រទេសជាសមាជិកមេគង្គ ក្រោមការប្តេជ្ញាចិត្តរបស់ប្រមុខរដ្ឋាភិបាលក្នុងកិច្ចប្រជុំកំពូលលើកទី១របស់គណៈកម្មការទន្លេមេគង្គ។

### ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន

៤.១២០- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងឧស្សាហកម្ម និងសិប្បកម្ម*** នឹងត្រូវអនុវត្តទៅតាមសកម្មភាពគោលខាងក្រោម៖

- ការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតតំបន់ទីប្រជុំជន៖
  - ➢ រៀបចំច្បាប់ស្តីពីការគ្រប់គ្រងសេវាទឹកស្អាត។
  - ➢ រៀបចំនីតិវិធីស្តីពីការស្នើសុំវិនិយោគក្នុងវិស័យទឹកស្អាត។
  - ➢ រៀបចំបញ្ញត្តិកម្មសេដ្ឋកិច្ច (ការកំណត់ថ្លៃទឹក)។
  - ➢ រៀបចំបទប្បញ្ញត្តិបច្ចេកទេស។
- ការជំរុញវិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតតំបន់ទីប្រជុំជន៖
  - ➢ ជំរុញការធ្វើប្រតិភូកម្មអំណាចដល់ថ្នាក់ក្រោមជាតិ ក្នុងភារកិច្ចនៃការផ្តល់សេវាទឹកស្អាតដោយរក្សាភារកិច្ចបញ្ញត្តិកម្មទាំងបច្ចេកទេសនិងសេដ្ឋកិច្ចនៅថ្នាក់ជាតិ។

- ការផ្តល់ស្វ័យភាពពេញលេញដល់អង្គភាពសាធារណៈ៖
  - ➢ កសាងសមត្ថភាពរដ្ឋាករទឹកសាធារណៈតាមបណ្តាខេត្ត ដើម្បីមានសមត្ថភាពជាបណ្តើរៗក្នុងការទទួលខុសត្រូវលើក្របខ័ណ្ឌការងាររបស់ខ្លួនទៅតាមច្បាប់ជាធរមាន ព្រមទាំងជំរុញការផ្តល់ស្វ័យភាពជាសហគ្រាសមានលក្ខណៈសេដ្ឋកិច្ចតាមស្ថានភាពជាក់ស្តែង។
  - ➢ ដោយយកតាមគំរូ និងបទពិសោធរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អង្គភាពទាំងអស់នឹងត្រូវផ្តល់ស្វ័យភាពជាអង្គភាពសាធារណៈមានលក្ខណៈសេដ្ឋកិច្ចត្រឹមឆ្នាំ ២០១៨។
- ការបង្កើនហិរញ្ញប្បទានរបស់វិស័យ៖
  - ➢ រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ រួមមានផែនការហិរញ្ញប្បទាននិងវិនិយោគរយៈពេលវែង។
  - ➢ គ្រប់អង្គភាពសាធារណៈទាំងអស់ត្រូវរៀបចំផែនការអាជីវកម្ម៥ឆ្នាំ របស់ខ្លួនត្រឹមឆ្នាំ ២០១៨ រួមទាំងផែនការវិនិយោគ និងការពង្រីក។
  - ➢ បន្តកិច្ចសហប្រតិបត្តិការស្មើភាពល្អជាមួយដៃគូអភិវឌ្ឍនានា ដើម្បីរកហិរញ្ញប្បទានសម្រាប់ការស្តារ និងពង្រីកសមត្ថភាពផ្គត់ផ្គង់ស្របតាមផែនការអភិវឌ្ឍន៍។
  - ➢ សិក្សា និងជំរុញលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់ផ្នែកឯកជនតាមរយៈការសហការជាមួយបណ្តាស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងធនាគារក្នុងស្រុក ដើម្បីជួយគាំទ្រផ្នែកឯកជនក្នុងការទទួលបានប្រាក់កម្ចីដែលមានលក្ខណៈអនុគ្រោះដល់វិស័យឯកជន។
  - ➢ ជំរុញលើកទឹកចិត្តឲ្យមានការចូលរួមវិនិយោគពីវិស័យឯកជន ដោយការបង្កើតនូវគោលនយោបាយក្របខ័ណ្ឌច្បាប់ សម្រួលដល់បរិយាកាសវិនិយោគ ក្នុងការទាក់ទាញភាពជាដៃគូសាធារណៈ ឯកជន ព្រមទាំងការលើកទឹកចិត្តដល់ការវិនិយោគឯកជន។
  - ➢ អនុវត្តកម្មវិធី "**ទឹកស្អាតសម្រាប់ទាំងអស់គ្នា**" ដោយផ្តោតលើការផ្តល់ឧបត្ថម្ភធនថ្លៃភ្ជាប់បណ្តាញដល់គ្រួសារដែលក្រីក្របំផុតនិងគ្រួសារដែលងាយរងគ្រោះបំផុត។
- ការបង្កើនប្រសិទ្ធភាពការផ្តល់សេវា និងលទ្ធភាពទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតដែលមានគុណភាពស្រប មានតម្លៃសមរម្យ និងមានចីរភាព៖
  - ➢ ស្តារឡើងវិញនូវមធ្យោបាយផលិតកម្មនិងបណ្តាញចែកចាយដែលមានស្រាប់ ដោយប្រើប្រាស់ធនធានរបស់រាជរដ្ឋាភិបាល ធនធានរបស់អង្គភាព និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍនានា។

- ➢ សិក្សាស្វែងយល់អំពីមូលហេតុតាមអង្គភាពនីមួយៗអំពី ឫសគល់នៃបញ្ហាដែលបណ្តាលឲ្យរដ្ឋាករទឹកសាធារណៈមិនទាន់មានចំណូលជានាគ្រប់ចំណាយ និងរិះរកវិធានការកែលម្អឲ្យបានឆាប់រហ័ស។
- ➢ កសាងធនធានមនុស្សឲ្យមានបរិមាណនិងគុណភាពឆ្លើយតបទៅនឹងតម្រូវការ។
- ➢ បង្កើត "**សមាគមអ្នកផ្គត់ផ្គង់សេវាទឹកស្អាតកម្ពុជា**" ជាសមាគមជាតិតំណាងឲ្យវិស័យផ្គត់ផ្គង់ទឹកស្អាត ទីប្រជុំជននិងជំរុញការអនុវត្តតួនាទីរបស់សមាគមដើម្បីផ្លាស់ប្តូរបទពិសោធនិងរៀនសូត្រពីគ្នាទៅវិញទៅមក។
- ➢ ប្រើប្រាស់មន្ត្រីបុគ្គលិកនិងធនធានរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ព្រមទាំងការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលទឹកស្អាតក្នុងទិសដៅលើកកម្ពស់វិស័យទាំងមូល។
- ➢ ខិតខំពង្រីកគំរូបទពិសោធរបស់រដ្ឋាករទឹកក្រុងភ្នំពេញ សម្រាប់រដ្ឋាករទឹកទូទាំងប្រទេស ទាំងសាធារណៈនិងឯកជន ដើម្បីឲ្យរដ្ឋាករទឹកទាំងនោះអាចផ្គត់ផ្គង់ទឹកដែលមានគុណភាព ថ្លៃសមរម្យ និងមានចីរភាព ដល់អតិថិជន។
- ➢ បង្កើតបរិយាកាសប្រឡងប្រណាំង ដោយដាក់ចេញនូវសូចនាករគុណភាពសេវាផ្គត់ផ្គង់ទឹកស្អាតសំខាន់ៗ សម្រាប់ធ្វើជាខ្នាតវាស់សមត្ថភាពរបស់អង្គភាពផ្តល់សេវានិងប្រព័ន្ធត្រួតពិនិត្យប្រកបដោយតម្លាភាព ដែលត្រូវបានពិនិត្យនិងធ្វើសវនកម្មដោយក្រសួងជារៀងរាល់ឆ្នាំ។
- ➢ ខិតខំជំរុញឲ្យរដ្ឋាករទឹកសាធារណៈ ផ្តល់សេវាប្រកបទៅដោយគុណភាព តម្លៃសមរម្យ ធានាការទូទាត់សោហ៊ុយចំណាយបានទាំងស្រុង និងមានធនធានសម្រាប់ការវិនិយោគឡើងវិញ។ ខិតខំកាត់បន្ថយជាបណ្តើរៗការពឹងផ្អែកលើហិរញ្ញប្បទានពីក្រៅប្រទេសដើម្បីស្តារនិងអភិវឌ្ឍអង្គភាព។
- ➢ អភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យគុណភាពទឹកឲ្យមានប្រសិទ្ធភាព ដើម្បីធានាថាការផ្គត់ផ្គង់ទឹកស្អាតត្រូវអនុលោមតាមបទដ្ឋានគុណភាពទឹកផឹកជាតិ។
- ➢ បន្ថយផលប៉ះពាល់ពីការអភិវឌ្ឍទឹកស្អាតដល់វិស័យផ្សេងៗទៀត ដោយការសហការស្អិតល្មួតជាមួយស្ថាប័នពាក់ព័ន្ធ។
- ➢ សហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងត្រៀមចំពោះបម្រែបម្រួលអាកាសធាតុ ព្រមទាំងការចូលរួមរាល់សកម្មភាពដើម្បីកាត់បន្ថយផលប៉ះពាល់ដល់វិស័យទឹកស្អាត។

- ការបង្កើនការការពារប្រភពទឹក និងពង្រឹងបញ្ញត្តិកម្មៈ
  - ➢ សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីការពារប្រភពទឹក ទាំងបរិមាណ និងគុណភាព ជៀសវាងការកើនឡើងចំណាយផលិតកម្មដោយមូលហេតុបញ្ហាប្រភពទឹក។

- ការផ្គត់ផ្គង់ទឹកស្អាតគឺការពារសុខភាពសាធារណៈ និងការពារបរិស្ថានល្អ។ ត្រូវកាត់បន្ថយជាបណ្តើរនូវការបង្ហូរកាកសំណល់ពីប្រព្រឹត្តិកម្មទឹកចូលទៅប្រភពធម្មជាតិ ដោយមិនបានធ្វើប្រព្រឹត្តិកម្មជាមុន។
- គម្រោងអភិវឌ្ឍន៍ត្រូវមានការសិក្សាពីផលប៉ះពាល់បរិស្ថានឲ្យបានច្បាស់លាស់ ដើម្បីធានាថាគម្រោងនោះមានផលប៉ះពាល់បរិស្ថានក្នុងកម្រិតដែលច្បាប់អនុញ្ញាត។
- អភិវឌ្ឍត្រូវគោរពតាមបទដ្ឋានបច្ចេកទេស គឺរិះរកបច្ចេកវិទ្យាដែលមានលក្ខណៈសមស្រប ដើម្បីធ្វើឲ្យតម្លៃទឹកមានលក្ខណៈសមរម្យ និងធានាការផ្តល់សេវាយូរ អង្វែង។

## ៤.៣- ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី

### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៥

៤.១២១- នៅក្នុងនីតិកាលទី៤នៃរដ្ឋសភាកន្លងទៅ រាជរដ្ឋាភិបាលបានបង្កើនសមត្ថភាពផ្គត់ផ្គង់ និងធ្វើពិពិធភាវូបនីយកម្មប្រភពថាមពល ដើម្បីងាកចេញពីការពឹងផ្អែកជាសំខាន់លើការប្រើប្រាស់ប្រេងក្នុងការផលិតថាមពលអគ្គិសនី មកជាការសាងសង់ស្ថានីយវារីអគ្គិសនី និងរោងចក្រអគ្គិសនីប្រើធ្យូងថ្មដែលមានសមត្ថភាពផលិតធំ និងតម្លៃដើមផលិតកម្មទាប ទន្ទឹមនឹងការនាំចូលអគ្គិសនីពីប្រទេសជិតខាងក្នុងគោលដៅកាត់បន្ថយតម្លៃអគ្គិសនី។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់លើការពង្រីកបណ្តាញបញ្ជូននិងចែកចាយ ព្រមទាំងកាត់បន្ថយការបាត់បង់ថាមពលតាមប្រព័ន្ធ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការអគ្គិសនីដែលមានកំណើនប្រមាណ២៥% ក្នុងមួយឆ្នាំ។

៤.១២២- រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា នឹងផ្តល់អាទិភាពលើ៖

ទី១ ការបន្តបង្កើនសមត្ថភាពផលិតថាមពលអគ្គិសនីដែលមានតម្លៃដើមថោក និងប្រើប្រាស់បច្ចេកវិទ្យាទំនើប ពិសេស ប្រភពថាមពលថ្មីនិងថាមពលស្អាត ទន្ទឹមនឹងការបន្តអភិវឌ្ឍបណ្តាញបញ្ជូនអគ្គិសនីគ្រប់កម្រិត សំដៅពង្រឹងសន្តិសុខថាមពល ព្រមទាំងធានាប្រសិទ្ធភាព សុវត្ថិភាព គុណភាព ភាពអាចជឿទុកចិត្តបាន និងតម្លៃសមរម្យក្នុងការផ្គត់ផ្គង់ និងចែកចាយថាមពលអគ្គិសនី ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍ។

ទី២ ការបន្តទាក់ទាញឲ្យមានការចូលរួមរបស់វិស័យឯកជន ក្នុងការវិនិយោគលើការផលិត និងលើហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពលអគ្គិសនី ដោយយកចិត្តទុកដាក់លើការប្រសិទ្ធភាពបច្ចេកទេស សេដ្ឋកិច្ចនិងការកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់លើបរិស្ថានធម្មជាតិនិងសង្គម។

ទី៣ ការបន្តអនុវត្តយុទ្ធសាស្ត្រអគ្គិសនីភាវូបនីយកម្ម ដើម្បីឈានទៅសម្រេចគោលដៅ ***នៅឆ្នាំ២០២០ គ្រប់ភូមិទាំងអស់នៃព្រះរាជាណាចក្រកម្ពុជានឹងមានការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិ និងប្រភពផ្សេងៗ***។

ទី៤ ការបន្តគាំទ្រមូលនិធិអគ្គិសនីភាវូនីយកម្មជនបទសំដៅធានាសមធម៌ក្នុងការទទួលបានសេវាអគ្គិសនីក្នុងចំណោមប្រជាជន តាមរយៈការផ្តល់ថវិកាពីរាជរដ្ឋាភិបាល ការផ្តល់ថវិកាសង្គមកិច្ចពីអគ្គិសនីកម្ពុជា និងការកៀរគរហិរញ្ញប្បទាននិងជំនួយពីដៃគូអភិវឌ្ឍនានា និងការជួយស្វែងរកហិរញ្ញប្បទានការប្រាក់សមរម្យជូនអ្នកផ្គត់ផ្គង់អគ្គិសនីនៅជនបទសម្រាប់ពង្រីកបណ្តាញចែកចាយអគ្គិសនី។

ទី៥ ការជំរុញអនុវត្តវិធានការវិចារណកម្មនៃការប្រើប្រាស់ថាមពលអគ្គិសនី តាមរយៈការលក់អគ្គិសនីក្នុងតម្លៃទាបជូនអតិថិជន ដែលប្រើប្រាស់អគ្គិសនីក្នុងរយៈពេលមានសេចក្តីត្រូវការទាបក្នុងគោលដៅបម្រើប្រព័ន្ធផលិតកម្ម និងការស្រោចស្រពសំដៅលើកកម្ពស់ផលិតភាពកសិកម្មនិងជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនិងសិប្បកម្ម។

ទី៦ ការបន្តជំរុញការរុករកនិងធ្វើអាជីវកម្មវិស័យប្រេងនិងឧស្ម័ន ដែលជាសក្តានុពលដ៏សំខាន់មួយសម្រាប់សន្តិសុខថាមពល និងជាប្រភពធនធានដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជារយៈពេលវែង។

ទី៧ ការបន្តពង្រឹងសមត្ថភាពស្ថាប័ន ធនធានមនុស្ស ព្រមទាំងការធ្វើផែនការ និងការគ្រប់គ្រងក្នុងវិស័យថាមពល។

ទី៨ ការបន្តចូលរួមក្នុងកិច្ចសហប្រតិបត្តិការវិស័យថាមពលក្នុងក្របខ័ណ្ឌតំបន់។

៤.១២៣- រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តល់អាទិភាពខ្ពស់លើការទាក់ទាញឲ្យមានការចូលរួមរបស់វិស័យឯកជនក្នុងការវិនិយោគក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពល រួមទាំងការផលិតការបញ្ជូននិងការចែកចាយ ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជា នឹងបន្តការផ្តោតការយកចិត្តទុកដាក់ឲ្យបានជាអតិបរមាលើបរិស្ថានធម្មជាតិនិងសង្គម ក្នុងការអភិវឌ្ឍគម្រោងវិស័យថាមពល ទន្ទឹមនឹងការសង្កត់ធ្ងន់លើប្រសិទ្ធភាពសេដ្ឋកិច្ចរបស់គម្រោងនីមួយៗ។ ការយកចិត្តទុកដាក់ក៏នឹងត្រូវផ្តោតជាសំខាន់ផងដែរ លើការកសាងសមត្ថភាពនិងការកែទម្រង់ស្ថាប័នក្នុងវិស័យថាមពលអគ្គិសនី រួមមាន ***អាជ្ញាធរអគ្គិសនី ក្រុមហ៊ុនអគ្គិសនីកម្ពុជា*** ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងក៏ដូចជាគុណភាពសេវាផ្គត់ផ្គង់អគ្គិសនី។

៤.១២៤- រាជរដ្ឋាភិបាលកម្ពុជា នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តសម្រាប់វិស័យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ធនធានទាំងឡាយ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១២៥- ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ***ក្រសួងរ៉ែនិងថាមពល*** នឹងផ្តោតការយកចិត្តទុកដាក់លើ៖

- ការបង្កើនសមត្ថភាពផ្គត់ផ្គង់អគ្គិសនី និងកាត់បន្ថយតម្លៃឲ្យនៅក្នុងកម្រិតមួយសមស្រប ជាមួយគ្នានឹងការពង្រឹងយន្តការស្ថាប័ន និងសមត្ថភាពផ្គត់ផ្គង់។
- ការធានាភាពជឿជាក់លើការផ្គត់ផ្គង់អគ្គិសនី ដើម្បីសម្រួលនិងទាក់ទាញការវិនិយោគ ក្នុងវិស័យនេះ និងដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។
- ការបង្កើតគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យថាមពល ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។
- ការលើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងមានផលប៉ះពាល់ដល់បរិស្ថានក្នុងកម្រិតទាបបំផុត។

៤.១២៦- ដើម្បីបំពេញតម្រូវការអគ្គិសនីនៅទូទាំងប្រទេស ***ក្រសួងរ៉ែនិងថាមពល*** មានទិសដៅអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- ជំរុញការរុករកប្រភពធនធានថាមពល ដូចជាថាមពលវារីអគ្គិសនី ឧស្ម័នធម្មជាតិ និងធ្យូងថ្មជាដើម សម្រាប់ការផលិតថាមពលអគ្គិសនី។
- ធានាឲ្យមានការទុកចិត្តនិងស្ថិរភាពក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីសម្រួលដល់ការវិនិយោគនិងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច។
- លើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន ដែលបណ្តាលមកពីការប្រើប្រាស់ និងការផ្គត់ផ្គង់ថាមពល។
- បន្តជំរុញឲ្យមានការចូលរួមវិនិយោគពីផ្នែកឯកជន ក្នុងវិស័យថាមពល រួមមានការផលិត ការបញ្ជូននិងការចែកចាយ ជាដើម។
- បន្តជំរុញឲ្យមានការអភិវឌ្ឍលើវិស័យថាមពលកកើតឡើងវិញគ្រប់ប្រភេទ ដូចជា ជីវម៉ាស់ ជីវឧស្ម័ន ជីវឥន្ធនៈ ជាដើម និងបង្កើនប្រសិទ្ធភាពនៃថាមពល តាមរយៈការប្រើប្រាស់ចង្ក្រានប្រសិទ្ធភាពដើម្បីកាត់បន្ថយការប្រើប្រាស់ ប្រេង អុស ធ្យូង ជាដើម។
- ជំរុញការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងតំបន់ តាមរយៈសហប្រតិបត្តិការទ្វេនិងពហុភាគី។

៤.១២៧- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងរ៉ែនិងថាមពល*** នឹងផ្តោតការយកចិត្តទុកដាក់លើ៖

- បន្តរកចំណូលឲ្យបានជាអតិបរមាជូនរាជរដ្ឋាភិបាល តាមរយៈចំណូលជាសួយសារ ការបែងចែកផល ពន្ធលើប្រាក់ចំណេញ និងចំណូលពន្ធផ្សេងៗទៀត ទាក់ទងនឹងអាជីវកម្មធនធានរ៉ែប្រេងកាតនិងឧស្ម័ន ដើម្បីចូលរួមក្នុងការបង្កើនសមត្ថភាពហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា។
- បង្កើតគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានា សម្រាប់វិស័យរ៉ែប្រេងកាត ដើម្បីធានានូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ធនធានរ៉ែប្រេងកាតនិងឧស្ម័នសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
- យកចិត្តទុកដាក់រៀបចំផែនការ សម្រាប់ការប្រើប្រាស់ឧស្ម័ន ដែលស្ថិតនៅលាយឡំជាមួយប្រេងកាតដែលនឹងទទួលបានពីផលិតកម្មប្រេងកាត ដើម្បីការពារកុំឲ្យឧស្ម័នទាំងនោះក្លាយជាសំណល់ ដែលឆេះចោលនៅក្នុងខ្យល់។
- លើកម្ពស់សកម្មភាពឲ្យបានសមស្រប សម្រាប់កែច្នៃធនធានប្រេងកាតប្រកបដោយលក្ខណៈសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីបង្កើតកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម។
- ជំរុញការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពក្នុង ការគ្រប់គ្រងធនធានរ៉ែប្រេងកាតនិងឧស្ម័នសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។
- បង្កើនការគ្រប់គ្រង និងតាមដានត្រួតពិនិត្យ លើកាអនុវត្តកិច្ចព្រមព្រៀងធនធានរ៉ែប្រេងកាតឲ្យមានប្រសិទ្ធភាពជាងមុន។
- ជំរុញការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍដោយផ្តោតលើបញ្ហារ៉ែប្រេងកាតនិងឧស្ម័ន។

## ៤.៤- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១២៨- នៅក្នុងនីតិកាលទី៤នៃរដ្ឋសភាកន្លងមក វិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍សម្រេចបាននូវការរីកចម្រើនគួរឲ្យកត់សម្គាល់ តាមរយៈការពង្រីកវិសាលភាពគ្របដណ្តប់នៃសេវាប្រៃសណីយ៍និងគមនាគមន៍ និងសេវាអ៊ិនធឺណិតផង និងការកើនឡើងនៃចំនួនអ្នកប្រើប្រាស់សេវានេះ។

៤.១២៩- រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា នឹងបន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ឲ្យមានលក្ខណៈទាន់សម័យ មានគុណភាពខ្ពស់ស្របតាមស្តង់ដាអន្តរជាតិ មានតម្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេសដែលប្រជាជនទូទៅអាចប្រើប្រាស់បាននិងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវានេះ និងត្រៀមរៀបចំមូលដ្ឋានសម្រាប់ការឈានឡើងរបស់កម្ពុជាទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ជាពិសេស ការធានា

ភាពប្រកួតប្រជែងរបស់កម្ពុជាក្នុង***សេដ្ឋកិច្ចពុទ្ធិ*** នាពេលអនាគត។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១ ការរៀបចំគោលនយោបាយជាតិ សម្រាប់ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដោយយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម។

ទី២ ការជំរុញអនុម័តច្បាប់ស្តីពីទូរគមនាគមន៍ និងការរៀបចំច្បាប់ពាក់ព័ន្ធផ្សេងទៀត មានជាអាទិ៍ ច្បាប់ស្តីពីការបង្ក្រាបឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ដែលចាំបាច់សម្រាប់ការគ្រប់គ្រងវិស័យបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ប្រកបដោយប្រសិទ្ធភាព។

ទី៣ ការពង្រឹងការអនុវត្ត និងការជំរុញរៀបចំបំពេញបន្ថែមនូវបញ្ញត្តិកម្មលើវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។

ទី៤ ការពង្រឹងតួនាទីស្ថាប័នគ្រប់គ្រងនិងការជំរុញការសម្របសម្រួលស្ថាប័ន ដើម្បីអភិវឌ្ឍនិងគ្រប់គ្រងវិស័យនេះឲ្យមានប្រសិទ្ធភាពនិងតម្លាភាព។

ទី៥ ការរៀបចំនិងការដាក់ឲ្យប្រើប្រាស់ផែនការជាតិ សម្រាប់ប្រព័ន្ធអ៊ីនធឺណិតល្បឿនលឿន ដើម្បីរួមចំណែកដល់ការលើកកម្ពស់នវានុវត្តន៍ ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងភាពប្រកួតប្រជែង និងការបង្កើតផលិតភាពសេដ្ឋកិច្ចក៏ដូចជាដើម្បីបង្កើនការចូលរួមរបស់ប្រជាជនឲ្យកាន់តែទូលំទូលាយឡើងនៅក្នុងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

ទី៦ ការពង្រីកវិសាលភាព និងការពង្រឹងប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង ពិសេសតាមរយៈការជំរុញលើកទឹកចិត្តឲ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងរួម ទន្ទឹមនឹងការបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធនេះឲ្យបានដល់តំបន់ ដែលមានសក្តានុពលខាងសេដ្ឋកិច្ច និងទេសចរណ៍ ក៏ដូចជាតំបន់ជនបទដាច់ស្រយាលដែលគ្មាន ឬមានសេវាទូរគមនាគមន៍មិនគ្រប់គ្រាន់។

ទី៧ ការជំរុញអភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងការរីចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាទំនើប និងការលើកកម្ពស់កម្រិតអក្ខរកម្មបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍សំដៅធានាប្រសិទ្ធភាពនៃការប្រើប្រាស់ និងស្រូបយកឲ្យអស់លទ្ធភាពនូវសក្តានុពលពីវិស័យនេះ តាមរយៈការពង្រីកកម្មវិធីសិក្សានៅគ្រប់កម្រិតក៏ដូចជាការបណ្តុះបណ្តាលមន្ត្រីរាជការ ព្រមជាមួយនឹងការជំរុញលើកទឹកចិត្តដល់វិស័យឯកជនចូលរួមលើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។

ទី៨ ការបន្តអភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច។

ទី៩ ការជំរុញលើកទឹកចិត្តដល់វិស័យឯកជនឲ្យវិនិយោគលើបច្ចេកវិទ្យាទំនើប ទាន់សម័យ ប្រព័ន្ធអ៊ីនធឺណិតល្បឿនលឿន បច្ចេកវិទ្យាពពក និងការអភិវឌ្ឍសូហ្វវែរដើម្បីលើកកម្ពស់

គុណភាពនិងប្រសិទ្ធភាពនៃសេវាបច្ចេកវិទ្យាព័ត៌មាន និងប្រសិទ្ធភាពនៃសេវាបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៣០- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍*** នឹងធ្វើការពង្រីកសេវាប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងបណ្តុះបណ្តាល អភិវឌ្ឍធនធានមនុស្ស និងកាត់បន្ថយតម្លៃ ដោយ៖

- លើកកម្ពស់គុណភាពសេវា ភាពជឿទុកចិត្ត ផ្តល់ចំណេះដឹងខាងបច្ចេកទេស ផ្តល់ការគាំទ្រដល់បណ្តាសេវាដែលមានស្រាប់ និងប្រសិទ្ធភាពនៃបណ្តាញប្រៃសណីយ៍៖
  - ➢ បន្តពង្រីកបន្ថែមប្រព័ន្ធត្រួតពិនិត្យតាមបញ្ញើប្រៃសណីយ៍ឲ្យបានគ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។
  - ➢ បន្តពង្រីកបន្ថែមប្រព័ន្ធតាមដានបញ្ញើប្រៃសណីយ៍ឲ្យបានគ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។
  - ➢ បន្តផ្សព្វផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធសាធារណៈងាយៗដូចជាវិទ្យុ ទូរទស្សន៍ កាសែត ជាដើម។
  - ➢ ពង្រឹងការចែកចាយបញ្ញើប្រៃសណីយ៍ដល់លំនៅឋានរបស់អតិថិជន។
  - ➢ ពង្រឹងការដឹកជញ្ជូនបញ្ញើក្នុងស្រុក។
- បង្កើនសុច្ចរិតភាពនិងសុវត្ថិភាពនៃសេវាប្រៃសណីយ៍៖
  - ➢ សហការជាមួយស្ថាប័នមានសមត្ថកិច្ចក្នុងការទប់ស្កាត់ការចរាចរគ្រឿងញៀនតាមរយៈបញ្ញើប្រៃសណីយ៍។
  - ➢ ទប់ស្កាត់ការបាត់បង់ខូចខាតបញ្ញើឲ្យបានកម្រិតអតិបរិមា។
- ជំរុញការអនុវត្តនិងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍៖
  - ➢ អភិវឌ្ឍ និងគ្រប់គ្រងអាជីវកម្មប្រៃសណីយ៍ស្របតាមស្តង់ដាអន្តរជាតិដោយប្រើប្រាស់ប្រព័ន្ធពត៌មានវិទ្យាឲ្យបានទូលំទូលាយ។
  - ➢ ការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធ IFS របស់សហភាពប្រៃសណីយ៍សកលសម្រាប់សេវាផ្ទេរប្រាក់អន្តរជាតិតាមប្រព័ន្ធអេឡិចត្រូនិក។
  - ➢ បំពាក់ Mobile Scanner ឲ្យគ្រប់កន្លែងចែកចាយសេវា EMS។
  - ➢ ពង្រឹងការគ្រប់គ្រងការងារអាជីវកម្មតាមប្រព័ន្ធព័ត៌មានតាមបណ្តាខេត្ត។
- កសាងស្តង់ដានិងបទប្បញ្ញត្តិនានា៖
  - ➢ ពង្រីកការប្រើប្រាស់ Postal Code ទូទាំងប្រទេស។

- ➢ ចូលរួមចំណែកក្នុងការធ្វើវិសោធនកម្មច្បាប់គយដែលទាក់ទងនឹងបញ្ញើប្រៃសណីយ៍ជាប់ពន្ធ។
- ➢ ចូលរួមទប់ស្កាត់ភាពអាណាធិបតេយ្យនៃការដឹកជញ្ជូនបញ្ញើតាមរថយន្តឈ្នួលដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់មុខចំណូលអាជីវកម្ម។

- ផ្តល់ការស្រាវជ្រាវទីផ្សារដែលទាក់ទងនឹងវិស័យប្រៃសណីយ៍ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជននិងភាគីពាក់ព័ន្ធនានា៖
  - ➢ រៀបចំដាក់ឲ្យដំណើរការសេវាធនាគារប្រៃសណីយ៍ដោយសហការជាមួយធនាគារឯកជន។
  - ➢ ការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធ IFS របស់សហភាពប្រៃសណីយ៍សកលសម្រាប់សេវាផ្ទេរប្រាក់អន្តរជាតិតាមប្រព័ន្ធអេឡិចត្រូនិច។
- ពង្រឹងសមត្ថភាពក្នុងការអនុវត្តនិងការគ្រប់គ្រងសេវាសកល៖
  - ➢ ពង្រីកមុខសញ្ញាអាជីវកម្មថ្មីៗទៅកាន់ទីប្រជុំជន ពិសេស តំបន់ជនបទ។
  - ➢ បន្តបណ្តុះបណ្តាលជំនាញអាជីវកម្មប្រៃសណីយ៍ដល់និយោជិក ជាពិសេស តាមបណ្តាខេត្ត។
  - ➢ បង្កើនសមត្ថភាពយល់ដឹងពីមុខជំនាញប្រៃសណីយ៍ដល់និយោជិកគ្រប់លំដាប់ថ្នាក់។
  - ➢ រៀបចំកែសម្រួលឥរិយាបថរបស់និយោជិកពីមន្ត្រីរាជការទៅជាអ្នកបម្រើអាជីវកម្ម។
- រៀបចំកសាងស្ថិតិនិងវិភាគលើនីតិវិធីគណនាតម្លៃដើម។
- ផ្តល់ព័ត៌មាន និងជំនាញនានាដែលទាក់ទងនឹងវិស័យប្រៃសណីយ៍ដើម្បីសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ។
- ធ្វើទំនើបភាវូបនីយកម្មនិងប្រសិទ្ធកម្មលើផលិតផលនិងសេវាប្រៃសណីយ៍៖
  - ➢ បង្កើនបរិមាណប្រអប់សំបុត្រជួលជាវ និងរៀបចំលក្ខណៈបច្ចេកទេសប្រអប់ឲ្យស្របតាមកម្រិតស្តង់ដាអន្តរជាតិ។
  - ➢ ជំរុញការបម្រើសេវាទទួលនិងបែងចែកវិក្កយបត្ររបស់ស្ថាប័នរដ្ឋ ក្រុមហ៊ុន និងអង្គការនានា។
- ជំរុញកំណើនទីផ្សារតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មី។
- ជួយសម្រួលលើសកម្មភាពពាណិជ្ជកម្មអន្តរជាតិតាមបែបអេឡិចត្រូនិក៖
  - ➢ សិក្សាលើការប្រើប្រាស់សេវាប្រៃសណីយ៍តាមប្រព័ន្ធ E-Commerce។
- ការអភិវឌ្ឍបណ្តាញប្រៃសណីយ៍៖
  - ➢ សាងសង់និងជួសជុលកែលម្អសាខា គ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសឲ្យបានសមរម្យជាទីតាំងបម្រើអាជីវកម្ម។
- កែលម្អប្រព័ន្ធលាភការរវាងប្រតិបត្តិករប្រៃសណីយ៍ដែលបានជ្រើសតាំង។

- ជំរុញឲ្យមានការយល់ដឹងពីបញ្ហាបរិស្ថាននិងភាពមិនរាថយចំពោះគ្រោះមហន្តរាយ។
- ជំរុញសមត្ថភាពយល់ដឹងរបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈពីការប្រើប្រាស់សេវាប្រៃសណីយ៍ឲ្យកាន់តែទូលំទូលាយ។
- បន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងឲ្យបានដល់ទីជនបទដាច់ស្រយាលនិងតំបន់មានសក្តានុពលខាងសេដ្ឋកិច្ចនិងទេសចរណ៍ ដោយៈ
  - ➢ កសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងទូរគមនាគមន៍បណ្តាញខ្សែកាប្លិ៍អុបទិកឲ្យបានដល់គ្រប់ខេត្តនិងស្រុកសំខាន់ៗដែលមានសក្តានុភាពសេដ្ឋកិច្ច និងទេសចរណ៍ និងសំដៅចូលរួមអនុវត្តគម្រោងមេរបស់អាស៊ានឆ្នាំ២០១៥។
  - ➢ រៀបចំបង្កើតប្រព័ន្ធ ASEAN-Cambodia Internet Exchange របស់បណ្តាប្រទេសក្នុងតំបន់អាស៊ាន។
  - ➢ អនុវត្តតាមគោលនយោបាយ Broad Band សម្រាប់អភិវឌ្ឍនិងពង្រីកសេវានៅទូទាំងប្រទេសដោយរួមទាំងការផ្លាស់ប្តូរថ្មីពី Internet Protocol Version 4 ទៅជា Internet Protocol Version 6។
  - ➢ រៀបចំគម្រោងបណ្តាញកាប្លិ៍អុបទិកតាមបាតសមុទ្រ Submarine Cable ភ្ជាប់ទៅនឹងបណ្តាញកាប្លិ៍បាតសមុទ្រអន្តរជាតិ។
  - ➢ រៀបចំឲ្យមានសេវាសកល USO (Universal Service Obligation )សម្រាប់បម្រើសេវានៅតាមទីជនបទនិងសហគមន៍ដែលមិនមានសេវា ICT។
  - ➢ កែសម្រួលយុទ្ធសាស្ត្របញ្ញត្តិកម្មទូរគមនាគមន៍ ដោយផ្អែកលើមូលដ្ឋានការវិវឌ្ឍបច្ចេកវិទ្យាថ្មីទំនើបនិងការកែទម្រង់ថ្មីរបស់បញ្ញត្តិកម្មអន្តរជាតិ។
  - ➢ បណ្តុះបណ្តាលធនធានមនុស្សឲ្យមានសមត្ថភាពដើម្បីបន្តវេនក្នុងវិស័យទូរគមនាគមន៍។
  - ➢ ជំរុញការកសាងលិខិតបទដ្ឋាននៃវិស័យនីមួយៗ តាមដានត្រួតពិនិត្យការអនុវត្តជាក់ស្តែងក៏ដូចចាត់វិធានការចាំបាច់សំដៅធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់លិខិតបទដ្ឋានដោយពុំរើសអើង។
  - ➢ បើកទូលាយនិងលើកទឹកចិត្តចំពោះការចូលរួមវិនិយោគរបស់ផ្នែកឯកជន។
  - ➢ រៀបចំនិងដំណើរការបណ្ណាល័យ ដើម្បីរក្សាទុកនូវរាល់ឯកសារ ជាពិសេស ឯកសារពាក់ព័ន្ធវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ព្រមទាំងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលឡើងវិញ។
  - ➢ បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាស៊ាន និងបណ្តាអង្គការអន្តរជាតិនានា ដូចជា ITU UPU APPU ជាដើម។
  - ➢ ពង្រឹងគុណភាពគ្រប់គ្រងតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា។
  - ➢ ពង្រឹងគោលការណ៍សមភាពយេនឌ័រ។

➢ បង្កើតវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។

- អភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច។
- ពង្រីកនិងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវិដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល។
- អភិវឌ្ឍកម្មវិធីកុំព្យូទ័រនិងមាតិកាព័ត៌មាន។

៤.១៣១- ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ ***ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍*** នឹងរៀបចំកសាងបទប្បញ្ញត្តិគតិយុត្តរួមមាន សេចក្តីណែនាំ សេចក្តីសម្រេច សារាចរណែនាំ ប្រកាស គោលនយោបាយ អនុក្រឹត្យ ច្បាប់ ដែលមានជាអាទិ៍៖

- គោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិវិស័យប្រៃសណីយ៍។
- អនុក្រឹត្យស្តីពីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល។
- វិសោធនកម្មច្បាប់ប្រៃសណីយ៍។
- គោលនយោបាយប្រព័ន្ធបែនជាតិ (National Broadband )។
- គោលនយោបាយកាតព្វកិច្ចសេវាទូរគមនាគមន៍សកល។
- គោលនយោបាយបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។
- ច្បាប់ស្តីពីទូរគមនាគមន៍។
- ច្បាប់ស្តីពីវិទ្យុគមនាគមន៍។

៤.១៣២- ចំណុចដៅនៃកំណើនដែលត្រូវបានកំណត់សម្រាប់ការពង្រីកវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវបានបង្ហាញនៅក្នុងតារាងទី៤.៦ និងតារាងទី៤.៧ ខាងក្រោម៖

**តារាងទី៤.៦-ចំណុចដៅនៃការពង្រីកសេវាកម្មប្រៃសណីយ៍**

| សូចនាករ | ជាក់ស្តែង ២០១២ | ប៉ាន់ស្មាន ២០១៣ | ព្យាករណ៍ ២០១៤ | ព្យាករណ៍ ២០១៥ | ព្យាករណ៍ ២០១៦ | ព្យាករណ៍ ២០១៧ | ព្យាករណ៍ ២០១៨ |
|---|---|---|---|---|---|---|---|
| អត្រាអ្នកប្រើសេវា (១នាក់/១ឆ្នាំ) | 0,១២៦០ | 0,១២៧៩ | 0,១២៩៨ | 0,១៣១៦ | 0,១៣៣៥ | 0,១៣៥៤ | 0,១៣៧៣ |
| អត្រាបម្រើសេវា ជាគ.ម² ក្នុង០១ការិយាល័យ | ៣ ៣៥២,៥០ | ៣ ៣៥២,៥០ | ៣ ៣៥២,៥០ | ៣ ៣៥២,៥០ | ៣ ៣៥២,៥០ | ៣ ៣៥២,៥០ | ៣ ៣៥២,៥០ |

*ប្រភព៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍*

**តារាងទី៤.៧-ចំណុចដៅនៃការពង្រីកសេវាទូរគមនាគមន៍**

| សូចនាករ | ឯកតា | ជាក់ស្តែង ២០១២ | ប៉ាន់ស្មាន ២០១៣ | ព្យាករណ៍ ២០១៤ | ព្យាករណ៍ ២០១៥ | ព្យាករណ៍ ២០១៦ | ព្យាករណ៍ ២០១៧ | ព្យាករណ៍ ២០១៨ |
|---|---|---|---|---|---|---|---|---|
| សរុប ទូរស័ព្ទចល័ត អចល័ត | លានគ្រឿង | ១៩,៦៩ | ២៣,៨២ | ២៨,៨៣ | ៣៤,៨៨ | ៤២,២០ | ៥១,០៧ | ៦១,៧៩ |
| អត្រាអ្នកប្រើប្រាស់ | ១០០ នាក់ | ១៣៣,៥៦ | ១៥៩,១៩ | ១៨៩,៨៦ | ២២៦,៤១ | ២៧០,០៥ | ៣២២,២៣ | ៣៨៤,៥០ |
| អ្នកប្រើប្រាស់អ៊ីនធឺណិត | លាននាក់ | ២,៧០ | ៤,៣៣ | ៦,៩៣ | ១១,០៩ | ១៣,៤១ | ១៦,២៣ | ១៩,៦៤ |

*ប្រភព: ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍*

៤.១៣៣- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងព័ត៌មាន*** ដាក់ចេញគោលនយោបាយអាទិភាពចំនួន៣ ដូចខាងក្រោម៖

- ពង្រីកវិសាលភាពនិងប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយផ្តល់ព័ត៌មាន ការអប់រំ និងការកម្សាន្តប្រកបដោយគុណភាព និងសមធម៌ជូនប្រជាពលរដ្ឋនៅកម្ពុជាឲ្យបាន៨៥%ដល់៩៥%។
- លើកទឹកចិត្តការអនុវត្តសេរីភាពសារព័ត៌មាន និងការបញ្ចេញមតិស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស លើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។
- រួមចំណែកអភិរក្ស និងអភិវឌ្ឍវប្បធម៌ប្រពៃណី ដើម្បីលើកកម្ពស់អត្តសញ្ញាណជាតិនិងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

៤.១៣៤- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងព័ត៌មាន*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- ការបន្តជំរុញប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ និងលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយឯកជនឲ្យខិតខំពង្រីកសក្តានុពលប្រសិទ្ធភាព និងវិសាលភាពនៃការផ្សាយគ្របដណ្តប់ឲ្យបានទូលំទូលាយទាំងក្នុងប្រទេស ក្នុងតំបន់ និងទ្វីបនានា ដើម្បីផ្តល់ព័ត៌មាន ការអប់រំ និងការកម្សាន្តប្រកបដោយគុណភាព និងសមធម៌ជូនប្រជាពលរដ្ឋខ្មែរនៅគ្រប់ច្រកល្ហកនៃមាតុប្រទេស និងឆ្ពោះទៅកាន់ពិភពលោកខាងក្រៅរួមចំណែកលើកតម្កើងអត្តសញ្ញាណ និងមោទនភាពជាតិខ្មែរ និងកិត្យានុភាពរបស់កម្ពុជានៅលើឆាកអន្តរជាតិ។
- ការកសាងផែនការទំនើបនីយកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស សម្រាប់អង្គភាពផ្សព្វផ្សាយថ្នាក់ជាតិ(វិទ្យុជាតិ ទូរទស្សន៍ជាតិ និងទីភ្នាក់ងារសារព័ត៌មានកម្ពុជា) ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់នៃការផ្សព្វផ្សាយជាសំឡេងផ្លូវការរបស់ជាតិ។

- ការបន្តជំរុញការកសាងសង់ស្ថានីយវិទ្យុ និងទូរទស្សន៍ថ្នាក់ក្រោមជាតិនៅតាមបណ្ដាខេត្តបន្តទៀត ដោយផ្ដល់អាទិភាពចំពោះបណ្ដាខេត្តនៅប៉ែកពាយ័ព្យនិងល្បសាននៃមាតុប្រទេស។ ស្ថានីយទាំងនេះ ដើរតួនាទីជាស្ពានចម្លងនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ទៅជូនប្រជាពលរដ្ឋ និងជាវេទិកាសាធារណៈសម្រាប់ប្រជាពលរដ្ឋបញ្ចេញមតិយោបល់ និងសំណូមពររបស់ខ្លួនស្របតាមគោលការណ៍ស្ដីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនិងអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ ដែលកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។
- ជំរុញការបើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេស និងលើកកម្ពស់សមត្ថភាពសម្រាប់មន្ត្រីផលិតកម្មវិធីនិងព័ត៌មានថ្នាក់ក្រោមជាតិ ដើម្បីឲ្យស្ថានីយវិទ្យុ ទូរទស្សន៍ថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការផ្សព្វផ្សាយបន្តផ្ទាល់នូវព្រឹត្តិការណ៍សំខាន់ៗពីថ្នាក់ជាតិ និងមានលទ្ធភាពផលិតកម្មវិធីអប់រំសង្គម និងបញ្ហាទាក់ទងស្ត្រីនិងកុមារ។
- ជំរុញការពង្រឹងសមត្ថភាពស្ថាប័ន ដោយអនុវត្តគោលនយោបាយយុវភាវូបនីយកម្មនិងយេនឌ័រ និងទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេសប្រកបដោយជាសុកភាព ដើម្បីប្រសិទ្ធភាពការងារ។
- ជំរុញការអនុវត្តច្បាប់ស្ដីពីរបបសារព័ត៌មាន និងបន្តខិតខំសិក្សាស្រាវជ្រាវ ដើម្បីកសាងលិខិតបទដ្ឋានគតិយុត្តថ្មីៗ សម្រាប់គ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ឲ្យស្ថិតក្នុងក្របខ័ណ្ឌនីតិរដ្ឋ ដោយធានាបានទាំងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាននិងលទ្ធិប្រជាធិប្បតេយ្យ។
- ការបន្តលើកទឹកចិត្តនិងបើកទូលាយនូវការចូលរួមរបស់វិស័យឯកជនសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងវិស័យព័ត៌មាននិងសោតទស្សន៍។
- ការលើកកម្ពស់គុណភាពនៃកម្មវិធីផ្សាយព័ត៌មានគ្របដណ្ដប់ ដោយព័ត៌មានជាតិដែលឆ្លុះបញ្ចាំងពីគ្រប់ទិដ្ឋភាពនៃជីវភាពសង្គមកម្ពុជា ជាព័ត៌មានពិត ត្រឹមត្រូវតាមទិសស្លោក "**ប្លែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន**" ដោយឈរលើស្មារតីទទួលខុសត្រូវនិងគោរពសីលធម៌វិជ្ជាជីវៈ ដើម្បីធានានូវការលើកស្ទួយនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។
- ការបង្កើតកម្មវិធីផ្សព្វផ្សាយសម្បូរបែប អប់រំសង្គម អប់រំច្បាប់ កម្មវិធីអប់រំអំពីយេនឌ័រ និងកុមារ និងកម្មវិធីយល់ដឹងសម្រាប់គ្រប់មជ្ឈដ្ឋាននិងសហគមន៍ ដោយសហការជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា។
- តាមរយៈមធ្យោបាយផ្សព្វផ្សាយទំនើប របស់ខ្លួនប្រព័ន្ធផ្សព្វផ្សាយជាតិទាំងអស់ក៏មានកាតព្វកិច្ចរួមចំណែកលើកកម្ពស់អត្តសញ្ញាណជាតិ និងកិត្យានុភាពរបស់កម្ពុជានៅលើឆាកអន្តរជាតិ ព្រមទាំងម្ចាស់ការប្រតិកម្មតបទាន់ពេលវេលាចំពោះរាល់ការផ្សាយ និង

ព័ត៌មានទាំងឡាយណាដែលប្រាសចាកការពិត អាចបណ្ដាលឲ្យប៉ះពាល់ដល់កិត្តិយស និងអន្តរាយដល់សន្តិភាពជាតិ ឬបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ ក៏ដូចជាប៉ះពាល់ដល់កិត្តិយសនិងសេចក្ដីថ្លៃថ្នូររបស់មនុស្សទូទៅ។

**តារាងទី៤.៨ សូចនាករសំខាន់ៗរបស់ក្រសួងព័ត៌មាន**

| សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| **ក. ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ:** | | | | | | | |
| ១- ស្ថានីយទូរទស្សន៍រដ្ឋ (ទ.ទ.ក.) | | | | | | | |
| - ស្ថានីយកណ្ដាល | ចំនួន | ០១ | ០១ | ០១ | ០២ | ០២ | ០២ |
| - ស្ថានីយខេត្ត | ចំនួន | ០៧ | ០៨ | ០៨ | ១០ | ១០ | ១២ |
| ២- ស្ថានីយវិទ្យុរដ្ឋ (វិទ្យុជាតិកម្ពុជា) | | | | | | | |
| - ស្ថានីយកណ្ដាល | ចំនួន | ០៣ | ០៣ | ០៣ | ០៣ | ០៣ | ០៤ |
| - ស្ថានីយខេត្ត | ចំនួន | ១៨ | ២០ | ២០ | ២២ | ២៣ | ២៤ |
| ៣- ទីភ្នាក់ងារសារព័ត៌មានរដ្ឋ | អង្គភាព | ០១ | ០១ | ០១ | ០១ | ០១ | ០១ |
| **ខ. ប្រព័ន្ធផ្សព្វផ្សាយឯកជន:** | | | | | | | |
| ១- ស្ថានីយទូរទស្សន៍ឯកជន | ចំនួន | ១២ | ១៣ | ១៤ | ១៤ | ១៥ | ១៥ |
| ២- ស្ថានីយទូរទស្សន៍ខ្សែកាប (រាជធានី ខេត្ត) | ចំនួន | ៩៦ | ៩៨ | ១០០ | ១០០ | ១០២ | ១០៥ |
| ៣- ស្ថានីយវិទ្យុឯកជន | ចំនួន | ៥១ | ៥៣ | ៥៥ | ៥៧ | ៥៩ | ៦០ |
| ៤- សារព័ត៌មានបោះពុម្ព (កាសែត ព្រឹត្តិបត្រ ទស្សនាវដ្ដី ភាសាខ្មែរ និងបរទេស) | អង្គភាព | ៥៧៤ | ៥៨០ | ៥៨០ | ៦០០ | ៦០០ | ៦០០ |
| ៥- រោងពុម្ព | អង្គភាព | ១៣៦ | ១៣៨ | ១៤០ | ១៤២ | ១៤៤ | ១៤៥ |

*ប្រភព: ក្រសួងព័ត៌មាន*

៤.១៣៥- រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ដែលត្រូវបន្តអភិវឌ្ឍលើគ្រប់វិស័យពាក់ព័ន្ធទាំងអស់នឹងធ្វើយ៉ាងណាដើម្បីឲ្យសម្រេចបាននូវទស្សនវិស័យរបស់ ផែនការមេជាតិសម្រាប់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជា គឺ "**ឈានឆ្ពោះជាប្រទេសជាតិដែលមានខឿនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានវានុវត្ត**"។ ក្នុងន័យនេះ គោលដៅ៤ យុទ្ធសាស្ត្រ៤ និងផែនការតាមវិស័យចំនួន១០ ត្រូវបានកំណត់ឡើងដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ។ ជាក់ស្ដែង គោលដៅទាំង៤ គឺ (១)បង្កើតមូលដ្ឋានសម្រាប់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (២)ធានាសមត្ថភាពការស្រាវជ្រាវនិងអភិវឌ្ឍន៍ (៣)បង្កើតបរិយាកាសវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និង (៤)ពង្រឹងសមត្ថភាពឧស្សាហកម្មស្នូល។ ដើម្បីសម្រេចបានគោលដៅទាំង៤ យុទ្ធសាស្ត្រ៤ ត្រូវបានដាក់ចេញ គឺ (១)ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដោយផ្អែកលើធនធានមនុស្ស (២)ការបង្កើត

បណ្តាញសម្រាប់កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដឹកនាំដោយកម្ពុជា (៣)ទទួលស្គាល់ពីភាពជោគជ័យនៃវិទ្យាសាស្ត្រនិងបច្ចេកវិជ្ជានិងការបន្តថែរក្សាលទ្ធផល និង (៤)ប្រើធនធានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិដោយមានជម្រើសនិងផ្តោតលើអាទិភាព។

៤.១៣៦- ដើម្បីសម្រេចបានគោលបំណងនិងយុទ្ធសាស្ត្រខាងលើ ***រាជរដ្ឋាភិបាលកម្ពុជា*** បានរៀបចំផែនការតាមវិស័យចំនួន១០ ដូចខាងក្រោម៖

- បង្កើតជាស្ថាប័នជាតិទទួលបន្ទុកលើការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ បង្កើតលិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធច្បាប់ និងរបៀបវារៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាតិ និងប្រគល់ភារកិច្ចឲ្យស្ថាប័នទទួលបន្ទុក ដើម្បីដឹកនាំការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។
- អភិវឌ្ឍធនធានមនុស្សផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ ធានានូវការពង្រីកផ្នែកបរិមាណនិងពង្រឹងផ្នែកគុណភាពនូវវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាតាមរយៈការធានាដល់អ្នកបច្ចេកទេសនិងជំរុញអ្នកស្រាវជ្រាវ។
- បង្កើតប្រព័ន្ធគាំទ្រហិរញ្ញវត្ថុដល់ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។
- រាជរដ្ឋាភិបាលដឹកនាំការស្រាវជ្រាវនិងការអភិវឌ្ឍ៖ ចាប់យកនូវបច្ចេកវិទ្យាដែលចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេស និងជំរុញដល់ការស្រាវជ្រាវនិងការអភិវឌ្ឍដើម្បីធានាដល់តម្រូវការបច្ចេកវិទ្យា។
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ ជំរុញកិច្ចសហប្រតិបត្តិការបច្ចេកវិទ្យាអន្តរជាតិដោយផ្អែកលើការផ្ទេរបច្ចេកវិទ្យា និងអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារបស់ខ្លួន។
- ជំរុញព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ ប្រមូលនិងប្រើប្រាស់ព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាប្រព័ន្ធ ដើម្បីគាំទ្រការសម្រេចចិត្តសម្រាប់បង្កើតគោលនយោបាយវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ក៏ដូចជាសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍរបស់បណ្តាសហគ្រាស។
- ពង្រឹងការយល់ដឹងជាសាធារណៈអំពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ ផ្តល់សមកម្មភាពទំនាក់ទំនងនិងផ្សព្វផ្សាយជាសាធារណៈឲ្យបានច្រើន និងផ្តល់កាលានុវត្តភាពដើម្បីឲ្យមានការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងជំរុញការចាប់អារម្មណ៍ និងចូលរួមរបស់ពួកគាត់លើផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។
- ពង្រឹងផលិតភាពកសិកម្ម៖ ជំរុញឲ្យមានលទ្ធភាពប្រកួតប្រជែងផ្នែកកសិកម្មកាន់តែខ្ពស់និងនាំទៅរកការអភិវឌ្ឍបៃតងតាមរយៈការពង្រីកផលិតភាពកសិកម្ម និងការធានានូវការប្រើប្រាស់បច្ចេកវិទ្យាចម្រុះ។

- អភិវឌ្ឍជំហរឧស្សាហកម្មផ្ទាល់ខ្លួន៖ ជំរុញការប្រកួតប្រជែងផ្នែកឧស្សាហកម្មតាមរយៈបង្កើតថាមពលដោយផ្ទាល់ខ្លួន ជំរុញឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ លើកកម្ពស់វិស្វករដែលមានជំនាញ និងលើកទឹកចិត្តការស្រាវជ្រាវនិងអភិវឌ្ឍតាមសហគ្រាស។
- ធានាដល់ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍៖ ជំរុញបន្ថែមសមត្ថភាពកម្មវិធីផ្នែកទន់ ដើម្បីផ្លាស់ប្តូរពីបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ដែលផ្អែកលើផ្នែករឹងទៅផ្អែកលើកម្មវិធីផ្នែកទន់វិញ ។

## ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ

## ៥.១- ការពង្រឹងវិស័យឯកជននិងការជំរុញការវិនិយោគ និងធុរកិច្ច

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១៣៧- រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំក្របខ័ណ្ឌគតិយុត្តចាំបាច់ជាច្រើន សម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន និងបានពង្រឹង“***វេទិការាជរដ្ឋាភិបាល វិស័យឯកជន*** ” ឲ្យទៅជាយន្តការដោះស្រាយបញ្ហាដ៏មានប្រសិទ្ធភាព។ ការកាត់បន្ថយនូវការតម្រូវខាងឯកសារបានជួយសម្រួលដល់ធុរកិច្ចនានា ជាពិសេសតាមរយៈការដាក់អនុវត្តនូវប្រព័ន្ធ“***ឯកសាររដ្ឋបាលតែមួយ***” និងសេវា “***ច្រកចេញ ចូលតែមួយ***”។

៤.១៣៨- រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា នឹងបន្តផ្តោតអាទិភាពលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍវិស័យឯកជន តាមរយៈការបង្កើនការវិនិយោគសាធារណៈ នៅក្នុងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រួមមានផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក (រួមទាំងតាមទន្លេនិងសមុទ្រ) និងផ្លូវអាកាស ការជំរុញការផលិត និងពង្រីកបណ្តាញចែកចាយអគ្គិសនីនៅតំបន់ទីប្រជុំជននិងជនបទ ក្នុងតម្លៃថោកសមរម្យ ការពង្រឹងនិងពង្រីកបណ្តាញទូរគមនាគមន៍ដែលមានសេវាទំនើបក្នុងតម្លៃថោកសមរម្យ ការពង្រឹងនិងពង្រីកបណ្តាញផ្គត់ផ្គង់ទឹកស្អាតព្រមទាំងការពង្រឹងនិងពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សម្រាប់វិស័យទេសចរណ៍វប្បធម៌ និងទេសចរណ៍ធម្មជាតិ។

៤.១៣៩- រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា នឹងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវកាតព្វកិច្ចរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក ក្របខ័ណ្ឌអាស៊ាន និងក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់និងអនុតំបន់ដទៃទៀត។ បន្ថែមលើនេះទៀត រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តពង្រឹងបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រវិស័យឯកជន រួមមាន បទប្បញ្ញត្តិច្បាប់និងនីតិវិធីរដ្ឋបាល ការលើកកម្ពស់ផលិតភាព តាមរយៈការបណ្តុះបណ្តាលបុគ្គលិកអ្នកបច្ចេកទេស និងកម្មករជំនាញ ការធានាឲ្យមានការប្រកួតប្រជែងដោយយុត្តិធម៌ ការបន្ត

ជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ការជំរុញការអនុវត្តច្បាប់ស្តីពីការងារ និងការពង្រឹងយន្តការដោះស្រាយវិវាទឲ្យមានប្រសិទ្ធភាព។

៤.១៤០- ***រាជរដ្ឋាភិបាលកម្ពុជា*** ដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ២ គឺ(១)ការបន្តជំរុញការអភិវឌ្ឍវិស័យឯកជនឲ្យកាន់តែមានភាពរស់រវើក និងមានជីវភាពខ្លាំងថែមទៀតក្នុងតួនាទីជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និង(២)ការប្រែក្លាយកម្ពុជាឲ្យទៅជាគោលដៅវិនិយោគប្រកបដោយភាពទាក់ទាញនិងភាពប្រកួតប្រជែងក្នុងតំបន់ ពិសេស ក្នុងក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ***រាជរដ្ឋាភិបាលកម្ពុជា*** នឹងផ្តោតអាទិភាពលើៈ

ទី១ ការជំរុញលើកទឹកចិត្តការវិនិយោគក្នុងវិស័យឧស្សាហកម្មទំនើប ដែលមានតម្លៃបន្ថែមខ្ពស់ក្នុងទិសដៅលើកកម្ពស់ពិពិធកម្មមូលដ្ឋានផលិតកម្ម។

ទី២ ការជំរុញលើកទឹកចិត្តការវិនិយោគនៅទីជនបទ ដែលនឹងចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ការកាត់បន្ថយគម្លាតរវាងទីក្រុងនិងជនបទ ក៏ដូចជាលើកស្ទួយជីវភាពរបស់ប្រជាជន និងកាត់បន្ថយចំណាកស្រុកពីជនបទមកទីប្រជុំជន និងចំណាកស្រុករកការងារធ្វើនៅក្រៅប្រទេស។

ទី៣ ការបន្តធ្វើទំនើបកម្មសហគ្រាសក្នុងស្រុក និងការលើកកម្ពស់គំនិតច្នៃប្រឌិត ព្រមទាំងការផ្សព្វផ្សាយភ្ជាប់គ្នារវាងសហគ្រាស និងឧស្សាហកម្មក្នុងស្រុកជាមួយនឹងគម្រោងវិនិយោគមកពីក្រៅប្រទេស ក្នុងគោលដៅស្រូបយកបច្ចេកវិទ្យា ចំណេះដឹង ចំណេះធ្វើ បង្កើនភាពទាក់ទាញនិងភាពប្រកួតប្រជែងរបស់កម្ពុជា។

ទី៤ ការបន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគនិងធុរកិច្ច តាមរយៈការបន្តកែលម្អក្របខ័ណ្ឌគតិយុត្ត ការធ្វើវិចារណកម្មរបបលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគ ការបន្តពង្រឹងក្របខ័ណ្ឌអភិបាលកិច្ចនិងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ រួមទាំងការបន្តពង្រឹងយន្តការ ***ច្រកចេញ ចូលតែមួយ*** នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ទី៥ ការបន្តកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការកែសម្រួលទម្រង់បែបបទ នីតិវិធី និងយន្តការនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ការកាត់បន្ថយចំណាយធុរកិច្ច ព្រមទាំងការពង្រឹងកិច្ចសម្របសម្រួលអន្តរស្ថាប័ន។

ទី៦ ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងកែលម្អសេវា និងមធ្យោបាយសម្រាប់សម្រួល និងគាំទ្រដល់កិច្ចដំណើរការធុរកិច្ច រួមទាំងការបន្តពង្រឹងនិងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

ទី៧ ការបន្តពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ភាពរឹងមាំ និងភាពធំធាត់របស់វិស័យឯកជន និងសម្រាប់លើកកម្ពស់វប្បធម៌គណនេយ្យភាពចំពោះសង្គម។

ទី៨ ការបន្តពង្រឹងប្រសិទ្ធភាពនៃយន្តការ ***វេទិការាជរដ្ឋាភិបាល ផ្នែកឯកជន***ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលវិស័យឯកជនជួបប្រទះ ហើយបន្ថែមលើនេះលើកកម្ពស់ឲ្យ

ទៅជាយន្តការសម្រាប់ការពិភាក្សាផ្តល់ជម្រើស និងអនុសាសន៍គោលនយោបាយនានា ដើម្បីបង្កើនតួនាទីរបស់វិស័យឯកជនជាតួអង្គក្នុងកិច្ចអភិវឌ្ឍន៍។

ទី៩ ការពង្រឹង**សេវាថៃទាំការវិនិយោគ** ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិនឲ្យទាន់ពេលវេលា។

ទី១០ ការពង្រឹងយន្តការតាមដានត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគ ដើម្បីធានាការអនុវត្តត្រឹមត្រូវតាមគោលការណ៍ និងលក្ខខណ្ឌកំណត់។

៤.១៤១- ជាចំណែកមួយដ៏សំខាន់នៃគោលនយោបាយពិពិធភាវូបនីយកម្ម មូលដ្ឋានសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជា នឹងជំរុញការបង្កើតនូវបរិស្ថានអំណោយផល សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃ និងវិស័យឧស្សាហកម្មគ្រឿងផ្គុំអេឡិចត្រូនិកនិងគ្រឿងម៉ាស៊ីន។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តពង្រឹងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់ ជាពិសេស ការរៀបចំក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់កិច្ចដំណើរការប្រកបដោយប្រសិទ្ធភាពនូវតំបន់សេដ្ឋកិច្ចពិសេស។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៤២- ***រាជរដ្ឋាភិបាកម្ពុជា*** បានកំណត់ថាវិស័យឯកជន គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ វិស័យឯកជនមានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច ជាពិសេស ការធ្វើឲ្យសម្រេចនូវគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម ការបញ្ចូលបច្ចេកវិទ្យាទំនើប និងគំនិតច្នៃប្រឌិតសំដៅបង្កើនប្រសិទ្ធភាព និងពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងការបង្កើតការងារដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរបស់ប្រជាជន។

៤.១៤៣- ***ក្រុមប្រឹក្សាវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** បានបង្កើត "**សេវាកម្មច្រកចេញចូលតែមួយ**" សម្រាប់វិនិយោគិនជាច្រើនឆ្នាំមកហើយ ដើម្បីកាត់បន្ថយបន្ទុកផ្នែករដ្ឋបាលនៅក្នុងការសុំការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជាលើគម្រោងវិនិយោគថ្មី។ នៅក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ យន្តការ "***សេវាកម្មច្រកចេញចូលតែមួយ***" នឹងត្រូវបានបន្តពង្រឹងនិងកែប្រែតម្រង់។ ***ក្រុមប្រឹក្សាវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** និង ***ក្រសួងពាណិជ្ជកម្ម*** នឹងបន្តជំរុញយ៉ាងសកម្មឲ្យមានការវិនិយោគថ្មីៗ ក្នុងវិស័យសេដ្ឋកិច្ចអាទិភាពនានា ដើម្បីធ្វើពិពិធកម្មនិងពង្រីកមូលដ្ឋានសេដ្ឋកិច្ច រៀបចំនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវព័ត៌មានស្តីពីកាលានុវត្តភាពវិនិយោគនៅក្នុងវិស័យអាទិភាព ដើម្បីផ្តល់សក្តានុពលដល់វិនិយោគិន វិស័យឯកជន និងពង្រឹងការសម្របសម្រួលក្នុងចំណោមស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការទទួលខុសត្រូវរួមគ្នា សម្រាប់លើកកម្ពស់ការប្រកួតប្រជែងរបស់អាជីវកម្មក្នុងវិស័យឯកជន។

៤.១៤៤- ***ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** នឹងពង្រឹងបន្តទៀត នូវការអនុវត្តតំបន់សេដ្ឋកិច្ចពិសេស ហើយនឹងធានាថា ទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេស នឹងសមស្របសម្រាប់ធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ឲ្យបានជាអតិបរមា។

**តារាងទី៤.៩ សូចនាករសំខាន់ៗរបស់វិស័យពាណិជ្ជកម្ម**

| សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| តម្លៃនៃការនាំចូល | ពាន់លានរៀល | ៣០ ៧៣២ | ៣៣ ៧១៩ | ៣៦ ៦៩១ | ៣៩ ៦៤៨ | ៤២ ៥៩១ | ៤៥ ៥២០ |
| តម្លៃនៃការនាំចូល | លានដុល្លារ | ៧ ៥៣៩ | ៨ ២៩១ | ៩ ០៤៣ | ៩ ៧៩៦ | ១០ ៥៤៨ | ១១ ៣០១ |
| តម្លៃនៃការនាំចេញ | ពាន់លានរៀល | ៣៤ ៦១៥ | ៣៨ ០៥៨ | ៤១ ៤៨៣ | ៤៤ ៨៩២ | ៤៨ ២៨៣ | ៥១ ៦៥៨ |
| តម្លៃនៃការនាំចេញ | លានដុល្លារ | ៨ ៤៩២ | ៩ ៣៥៨ | ១០ ២២៥ | ១១ ០៩២ | ១១ ៩៥៨ | ១២ ៨២៥ |
| សម្លៀកបំពាក់ | ពាន់លានរៀល | ១៩ ៨៤១ | ២១ ៤៨៩ | ២៣ ៣៥៥ | ២៥ ២១២ | ២៧ ០៦០ | ២៨ ៨៩៨ |
| សម្លៀកបំពាក់ | លានដុល្លារ | ៤ ៨៦៧ | ៥ ២៨៤ | ៥ ៧៥៧ | ៦ ២២៩ | ៦ ៧០២ | ៧ ១៧៤ |
| ចំនួនក្រុមហ៊ុនចុះបញ្ជី | ចំនួន | ៣ ៦០៣ | ៣ ៧៨២ | ៣ ៩៧១ | ៤ ១៦៩ | ៤ ៣៧៧ | ៤ ៥៩៥ |
| – ក្រុមហ៊ុនឯកត្តជន | | ៦០៩ | ៦៣៩ | ៦៧១ | ៧០៥ | ៧៤០ | ៧៧៧ |
| – ក្រុមហ៊ុន | | ២ ៩២៥ | ៣ ០៧០ | ៣ ២២៤ | ៣ ៣៨៥ | ៣ ៥៥៤ | ៣ ៧៣២ |
| – សាខាក្នុងស្រុក | | ៤៣ | ៤៥ | ៤៧ | ៤៩ | ៥១ | ៥៤ |
| – សាខាក្រៅស្រុក | | ២៧ | ២៨ | ២៩ | ៣០ | ៣២ | ៣២ |
| ចំនួនឈ្មោះក្រុមហ៊ុនចុះបញ្ជី | | ៤ ៦៣៦ | ៤ ៧២៨ | ៤ ៨២១ | ៤ ៩១៤ | ៥ ០០៧ | ៥ ០៩៩ |
| ចំនួនរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ចំនួន | ៤៥៩ | ៤១០ | ៤៣៨ | ៤៦៦ | ៤៩៤ | ៥២២ |
| ចំនួនកម្មករ (ប្រុសនិងស្រី) បំពេញការងារក្នុងរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | នាក់ | ៤៤៥ ០១៤ | ៣៩០ ៧៦៦ | ៤០៦ ៥៣៤ | ៤២២ ៣០២ | ៤៣៨ ០៧( | ៤៥៣ ៨៣៨ |
| ប្រាក់បៀវត្សសរុប | លានរៀល | ៥៥ | ៥១ | ៥៦ | ៦០ | ៦៥ | ៧០ |

*ប្រភព: ក្រសួងពាណិជ្ជកម្ម*

៤.១៤៥- ក្នុងនីតិកាលទី៥ នៃរដ្ឋសភា ***ក្រសួងពាណិជ្ជកម្ម*** នឹងអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ពង្រឹងការអនុវត្តកម្មវិធីវិស័យពាណិជ្ជកម្ម ដែលផ្អែកលើអភិក្រមគ្រប់គ្រងទូទាំងវិស័យ ដែលផ្តោតលើកិច្ចសម្រួលដល់ការធ្វើពាណិជ្ជកម្មនិងការអភិវឌ្ឍវិស័យឯកជន។ សូចនាករសំខាន់ៗសម្រាប់វិស័យពាណិជ្ជកម្ម មានបង្ហាញជូនក្នុងតារាងទី៤.៩ ខាងលើ។
- បន្តអនុវត្តនយោបាយកាត់បន្ថយភាពក្រីក្រ តាមរយៈការជំរុញការនាំចេញផលិតផលជាពិសេស ផលិតផលកសិកម្ម សម្លៀកបំពាក់ និងផលិតផលផ្សេងទៀត។

- បន្តធ្វើសមាហរណកម្ម ដើម្បីសម្រេចគោលដៅបើកច្រកចូលទីផ្សារក្នុងតំបន់ និងអន្តរជាតិ និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។
- រៀបចំពិព័រណ៍កម្រិតជាតិ និងអន្តរជាតិឲ្យបានច្រើនថែមទៀត។
- ពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យទីផ្សារ ដើម្បីការពារសុខភាពនិងសុខុមាលភាពអ្នកប្រើប្រាស់។
- ពង្រឹងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាព។
- ពង្រឹងភាពជាដៃគូជាមួយស្ថាប័នអន្តរជាតិ និងជាមួយបរទេស ដើម្បីធ្វើឲ្យកម្ពុជាក្លាយជាដៃគូអភិវឌ្ឍល្អនិងគួរជាទីទុកចិត្ត។

៤.១៤៦- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងពាណិជ្ជកម្ម*** នឹងផ្តោតអាទិភាពលើសកម្មភាពដូចខាងក្រោម៖

- អនុវត្តកំណែទម្រង់ច្បាប់ស្តីពីពាណិជ្ជកម្មរបស់ខ្លួនស្របតាមអង្គការពាណិជ្ជកម្មពិភពលោកនិងអាស៊ាន និងពង្រឹងលទ្ធភាពចូលទៅទីផ្សាររបស់កម្ពុជាតាមរយៈការចរចាពាណិជ្ជកម្ម។
- លើកកម្ពស់តម្លាភាពនៃវិធាន និងច្បាប់ស្តីពីពាណិជ្ជកម្មរបស់កម្ពុជា។
- បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាតាមរយៈការកាត់បន្ថយការចំណាយថ្លៃនាំចេញនាំចូល និងការកែលម្អការដឹកនាំពាណិជ្ជកម្ម។
- ពង្រឹងការផ្តល់ស្តង់ដាបច្ចេកទេសនិងតម្រូវការ SPS។
- បង្កើតបរិយាកាសវិនិយោគសម្រាប់ការនាំចេញ។
- បន្តបង្កើនផលិតកម្មសម្លៀកបំពាក់ច្រើនប្រភេទ សម្រាប់នាំចេញទៅកាន់ទីផ្សារថ្មីៗ បង្កើនធាតុចូលក្នុងស្រុក និងការពង្រីកផលិតផលដែលមានតម្លៃខ្ពស់។
- បន្តបង្កើននិងធ្វើពិពិធកម្មការនាំចេញស្បែកជើងរបស់កម្ពុជា តាមរយៈការឆ្ពោះទៅកាន់ទីផ្សារថ្មីៗនិងអភិវឌ្ឍន៍ទីផ្សារថ្មីៗ។
- បង្កើនភាពប្រកួតប្រជែងរបស់តំបន់សេដ្ឋកិច្ចប្រទេសកម្ពុជា ព្រមទាំងទាក់ទាញនូវការវិនិយោគ ក្នុងវិស័យកម្មន្តសាលបន្ថែមទៀត។
- ការប្រមូលផ្តុំកម្មន្តសាលធុនស្រាល។
- បន្តបង្កើននិងធ្វើពិពិធកម្មវិស័យកែច្នៃចំណីអាហាររបស់ខ្លួន តាមរយៈទីផ្សារនាំចេញថ្មីៗ និងបោះជំហានឆ្ពោះទៅផលិតផលិតផលដែលមានតម្លៃកាន់តែខ្ពស់ និងពង្រីកធាតុចូលក្នុងស្រុក។

- លើកកម្ពស់ការនាំចេញដំឡូងមីដោយផ្ទាល់ទៅកាន់បណ្តាប្រទេសមួយចំនួន ដូចជាប្រទេសចិន និងសាធារណៈរដ្ឋកូរ៉េដោយបន្ថយការពឹងពាក់ការនាំដំឡូងមើម(មិនទាន់កែច្នៃ) ទៅកាន់តែប្រទេសថៃ និងវៀតណាម។
- បង្កើនផលិតកម្មនិងការនាំចេញកៅស៊ូ។
- បង្កើនភាពជាដៃគូរវាងឯកជន និងរដ្ឋ ដើម្បីអភិវឌ្ឍការបណ្តុះបណ្តាលបច្ចេកទេស។
- តាមដានត្រួតពិនិត្យនិងកៀរគរហិរញ្ញប្បទានសម្រាប់ពាណិជ្ជកម្ម។
- លើកកម្ពស់ការចូលរួមរបស់ផ្នែកឯកជនលើវិស័យពាណិជ្ជកម្ម។

៤.១៤៧- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងទេសចរណ៍*** នឹងផ្តោតលើសកម្មភាពលើកកម្ពស់គុណភាពសេវាទេសចរណ៍ ដើម្បីទាក់ទាញការទស្សនា ការពន្យារពេលស្នាក់នៅ និងការធ្វើវិនិយោគក្នុងវិស័យទេសចរណ៍។ សកម្មភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់រួមមាន៖

- កសាងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ពាក់ព័ន្ធ។
- បង្កើតវិទ្យាស្ថានជាតិទេសចរណ៍ជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងវិភាគទេសចរណ៍ ដើម្បីដាក់ចេញគោលនយោបាយផែនការយុទ្ធសាស្ត្រសមស្រប។
- អភិវឌ្ឍផលិតផលទេសចរណ៍និងលើកកម្ពស់គុណភាពផលិតផលទេសចរណ៍។
- រៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់តំបន់។
- ពង្រឹងនិងអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យទេសចរណ៍។
- បង្កើតនិងដំណើរការគ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ជាតិ។
- កសាងផែនការយុទ្ធសាស្ត្រទីផ្សារទេសចរណ៍។
- បង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍រួមគ្នារវាងរដ្ឋនិងឯកជន។
- ពង្រឹងនិងពង្រីកប្រព័ន្ធសន្តិសុខនិងសុវត្ថិភាពទេសចរណ៍នៅតាមគោលដៅទេសចរណ៍។
- សម្របសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនទេសចរណ៍។
- ពង្រឹងអភិបាលកិច្ចល្អក្នុងវិស័យទេសចរណ៍។

**តារាងទី៤.១០ សូចនាករវិស័យទេសចរណ៍សំខាន់ៗ**

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ទេសចរអន្តរជាតិ | លាននាក់ | ៤,៧២ | ៥,១៩ | ៥,៦៥ | ៦,១១ | ៦,៥៣ |
| ទេសចរជាតិ | លាននាក់ | ៨,៧០ | ៩,០០ | ៩,៣០ | ៩,៥០ | ៩,៨០ |
| កម្លាំងពលកម្មបម្រើឲ្យវិស័យទេសចរណ៍ | ពាន់នាក់ | ៤២៥ | ៤៥៥ | ៥០០ | ៥៥០ | ៦០០ |
| ចំណូលទេសចរណ៍ | លានដុល្លារ | ២ ៨០២ | ៣ ០៥៤ | ៣ ៣៩៩ | ៣ ៧២៩ | ៤ ១១៣ |
| សេវាស្នាក់នៅ | បន្ទប់ | ៥០ ៣២៨ | ៥៣ ៨៥១ | ៥៧ ៦២១ | ៦១ ០៧៨ | ៦៤ ១៣២ |

*ប្រភព: ក្រសួងទេសចរណ៍*

៤.១៤៨- ការការពារ និងការលើកកម្ពស់មរតកវប្បធម៌ប្រពៃណីខ្មែរដ៏សម្បូរបែបនឹងនៅតែបន្តជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា។ ***ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ*** នឹងបន្តជានាំឲ្យមានការថែរក្សាការពារ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពចំពោះបេតិកភណ្ឌទាំងរូបីនិងអរូបី ដោយប្តូករួមទាំងក្រុងបុរាណ បេតិកភណ្ឌក្រោមទឹក សិល្បៈទស្សនីយភាពប្រពៃណី សិល្បៈនិងប្រពៃណីនៃជនជាតិដើមភាគតិច សារមន្ទីរ ព្រមទាំងជានាឲ្យមានការប្រយុទ្ធប្រឆាំងនឹងការជួញដូរវត្ថុសិល្បៈខុសច្បាប់នានាផង។ ទន្ទឹមគ្នានេះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនឹងជំរុញឲ្យបានផុសផុលចំពោះគំនិតច្នៃប្រឌិតនិងការបង្កើតថ្មីៗ ក្នុងវិស័យសិល្បៈ ឧស្សាហកម្មវប្បធម៌ និងសហគ្រិនវប្បធម៌នានា។ ការបញ្ចប់ ការអនុម័តនិងការអនុវត្តតាមគោនយោបាយវប្បធម៌ និងការនុវត្តនូវអនុសញ្ញាយូណេស្កូលើវិស័យវប្បធម៌ នឹងជួយក្រសួងក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពការងាររបស់ខ្លួន។

៤.១៤៩- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ ***ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ*** មានផែនការនឹងអនុវត្តនូវកម្មវិធីនិងសកម្មភាព ដូចខាងក្រោម៖

- លើកតម្កើងសិល្បៈទស្សនីយភាព និងការផ្សព្វផ្សាយឲ្យកាន់តែប្រសើរឡើង ដើម្បីធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាក្លាយជាគោលដៅវប្បធម៌៖
  - ➢ រក្សានូវចំណេះដឹងប្រពៃណី និងទម្រង់នៃការច្នៃប្រឌិតបង្កើតថ្មី ដែលជាផ្នែកមួយជួយឲ្យមានការទទួលស្គាល់នូវឧស្សាហកម្មច្នៃប្រឌិត។
  - ➢ ថែរក្សាការពារសិល្បៈទស្សនីយភាពប្រពៃណី ជានាឲ្យមានការចែករំលែកចំណេះដឹងតាមរយៈមរតកមនុស្សរស់និងលើកស្ទួយដល់ការច្នៃប្រឌិតបង្កើតថ្មី ស្នាដៃថ្មីនិងការបង្កើតជាគំនិតថ្មីៗតាមរយៈសិល្បៈនិងឧស្សាហកម្មច្នៃប្រឌិត។
  - ➢ បង្កើតទីផ្សារផលិតផលវប្បធម៌និងសិល្បៈ សម្រួលដល់សិល្បករនិងផលិតករឲ្យងាយចូលរួមនិងងាយទទួលបានពត៌មាននានា។

- ➢ ជំរុញនិងផ្សព្វផ្សាយសិល្បៈទស្សនីយភាព និងការច្នៃប្រឌិតបង្កើតថ្មី ដើម្បីឲ្យត្រូវតាមតម្រូវការនៃអតិថិជន។
- ប្រែក្លាយកម្ពុជាជាដែនដីស្វាគមន៍នៃការថតភាពយន្តបរទេស៖
  - ➢ អភិវឌ្ឍធនធានមនុស្សក្នុងវិស័យភាពយន្ត។
  - ➢ បង្កើនការផ្សព្វផ្សាយគ្រប់រូបភាព ដើម្បីទាក់ទាញក្រុមហ៊ុនបរទេសមកថតភាពយន្តនៅកម្ពុជា។
  - ➢ បង្កើនយន្តការសម្របសម្រួលក្នុងការស្នើសុំថតភាពយន្តតាមច្រកចេញចូលតែមួយ។
  - ➢ ថែរក្សាការពារបេតិកភណ្ឌក្រុងដោយប្រែក្លាយឲ្យទៅជាធនធានដ៏សំខាន់នៃទិដ្ឋភាពវប្បធម៌របស់កម្ពុជា ដែលអាចនឹងជួយជំរុញដល់វិស័យទេសចរណ៍ភាពយន្ត ការបង្កើតសិល្បៈនិងការវិនិយោគ។
- ជំរុញឲ្យកម្ពុជា ជាទីកន្លែងផ្សព្វផ្សាយផលិតផលវប្បធម៌៖
  - ➢ បង្កើតប្រព័ន្ធទិន្នន័យស្តីពីអង្គការ សមាគម និងសហគ្រាសវប្បធម៌។
  - ➢ ធ្វើអត្តសញ្ញាណកម្មវប្បធម៌ និងភូមិមួយផលិតផលមួយ។
  - ➢ អភិវឌ្ឍធនធានមនុស្សក្នុងវិស័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម និងសហប្រតិបត្តិការជាមួយដៃគូឯកជន។
  - ➢ ពង្រឹងការត្រួតពិនិត្យ ការសិក្សា ស្រាវជ្រាវ និងការផ្សព្វផ្សាយផលិតផលវប្បធម៌។
- ថែរក្សា ការពារ អភិវឌ្ឍតំបន់បេតិកភណ្ឌ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ៖
  - ➢ ចុះបញ្ជីតំបន់បេតិកភណ្ឌ រួមទាំងបេតិកភណ្ឌក្រុង ដោយអភិរក្សតំបន់ទាំងអស់នោះហើយយកមកបង្ហាញផ្សព្វផ្សាយដល់សាធារណជន ជាពិសេស តំបន់បេតិកភណ្ឌដែលនៅដាច់ស្រយាលដូចជា ប្រាសាទបន្ទាយឆ្មារ សម្បូរណ៍ព្រៃគុក និងព្រះខ័នកំពុងស្វាយ ជាដើម។
  - ➢ ការពារតំបន់បេតិកភណ្ឌពីការលួចនិងជួញដូរដោយខុសច្បាប់ ពង្រឹងសមត្ថភាពមន្ត្រីបេតិកភណ្ឌ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ ជាពិសេស ជាមួយអាជ្ញាធរជាតិអប្សរានិងអាជ្ញាធរព្រះវិហារ។
  - ➢ លើកទឹកចិត្តឲ្យមានការចូលរួមពីសាធារណជនក្នុងការថែរក្សាការពារបេតិកភណ្ឌវប្បធម៌។
- ពង្រឹងពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូអភិវឌ្ឍ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងសេវា៖
  - ➢ បន្តពង្រឹងបែបបទរដ្ឋបាល បទដ្ឋានគតិយុត្តធានាឲ្យមានប្រសិទ្ធភាពនិងគុណភាពក្នុងការផ្តល់សេវាលើវិស័យវប្បធម៌។

- ➤ បង្កើនការត្រួតពិនិត្យលើបទដ្ឋានគតិយុត្តដែលមាន និងជំរុញការកសាងបទដ្ឋានគតិយុត្តថ្មីបន្ថែម ដើម្បីបម្រើដល់ការផ្តល់សេវាសាធារណៈក្នុងវិស័យវប្បធម៌ និងដើម្បីគាំទ្រផែនការយុទ្ធសាស្ត្រទាំង៥។
- ➤ បន្តជំរុញការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការតាមសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងគោលការណ៍កំណែទម្រង់រដ្ឋបាលសាធារណៈនិងយេនឌ័រ។
- ➤ បង្កើនការត្រួតពិនិត្យ និងណែនាំលើការកសាងផែនការ និងវាយតម្លៃលើការអនុវត្តផែនការសកម្មភាពនិងការសម្តែង។

## ៥.២- ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម

### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៥

៤.១៥០- ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការបន្តធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្ម តាមរយៈការជំរុញលើកទឹកចិត្តវិនិយោគក្នុងវិស័យឧស្សាហកម្មថ្មីៗទំនើបដែលមានតម្លៃបន្ថែមខ្ពស់ មានភាពច្នៃប្រឌិតរស់រវើក និងមានសមត្ថភាពប្រកួតប្រជែង ពិសេស ឧស្សាហកម្មផ្គុំដំឡើង ឧស្សាហកម្មអេឡិចត្រូនិក ឧស្សាហកម្មគ្រឿងបន្លាស់ ឧស្សាហកម្មមាត្រាសាស្ត្រ ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មកម្មន្តសាលផ្សេងទៀតគួបផ្សំនឹងការបន្តជំរុញអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម រួមទាំងសិប្បកម្មផង ព្រមទាំងការជំរុញការអភិវឌ្ឍឧស្សាហកម្មឲ្យទៅដល់ទីជនបទ សំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចក៏ដូចជាបង្កើតការងារនិងបង្កើនចំណូលជូនប្រជាជន។ បន្ថែមលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់បន្ថែមទៅលើការអភិវឌ្ឍ និងការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវខ្ពស់លើវិស័យឧស្សាហកម្មនិស្សារណកម្ម ដើម្បីប្រែក្លាយសក្តានុពលដែលមាននេះឲ្យទៅជាប្រភពមួយទៀតនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១ ការរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដែលនឹងផ្តោតលើអភិក្រមគន្លឹះពីរ គឺ (១)ការពង្រឹងមូលដ្ឋានឧស្សាហកម្ម តាមរយៈការបង្កើនភាពទាក់ទាញ និងការជំរុញលើកទឹកចិត្តការវិនិយោគ ព្រមទាំងការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម និង (២)ការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មក្នុងតំបន់ដើម្បីជ្រៀតចូលនិងអភិវឌ្ឍឈានឡើងក្នុងខ្សែចង្វាក់តម្លៃសកល។

ទី២ ការរៀបចំគោលនយោបាយលើកកម្ពស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឧស្សាហកម្មមាត្រាសាស្ត្រ សំដៅបង្កើនសមត្ថភាពនៃការស្រាវជ្រាវ និងការអភិវឌ្ឍរបស់កម្ពុជា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍប្រទេសក្នុងដំណាក់កាលថ្មី ពិសេសធានា

សង្គតិភាពជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មនៅក្នុងពេលចំពោះមុខ។

ទី៣ ការធ្វើបច្ចុប្បន្នកម្ម ***ក្របខ័ណ្ឌនៃការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម*** ដើម្បីឲ្យមានសង្គតិភាពជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម សំដៅជំរុញលើកកម្ពស់សមត្ថភាពសហគ្រាសធុនតូច និងមធ្យមឲ្យមានលទ្ធភាពតភ្ជាប់ជាមួយសហគ្រាសធំៗជាចង្កោមឧស្សាហកម្ម មានសហគ្រិនភាព ផលិតភាព សមត្ថភាពច្នៃប្រឌិតនវានុវត្តន៍ និងមានឯកទេស តាមរយៈការដាក់ចេញ និងអនុវត្តនូវកញ្ចប់វិធានការគាំទ្រគ្រប់ជ្រុងជ្រោយ រួមមានការចងក្រងគ្នាជាប្រព័ន្ធតួអង្គក្នុងខ្សែចង្វាក់ផលិតកម្ម ការលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា ការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន ការពង្រឹងស្តង់ដាបច្ចេកទេស ការបង្កើត ***មជ្ឈមណ្ឌលផ្តល់ទីប្រឹក្សាស្តីពីការអភិវឌ្ឍធុរកិច្ច*** ការបន្តជំរុញ ***ចលនាភូមិមួយផលិតផលមួយ*** និងការកែលម្អក្របខ័ណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងការសម្របសម្រួលស្ថាប័ន។

ទី៤ ការតម្រង់គោលនយោបាយអភិវឌ្ឍន៍វិស័យឯកជន និងវិនិយោគឲ្យឆ្លើយឆ្លងគ្នាជាមួយគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម ជាពិសេស ការលើកទឹកចិត្តដល់ការវិនិយោគបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការជំរុញបង្កើត **ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស** សំដៅអភិវឌ្ឍតំបន់នេះឲ្យឈានឡើងដល់កម្រិតស្តង់ដាអន្តរជាតិ ទាំងក្នុងទិដ្ឋភាពនៃការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធនិងកិច្ចប្រតិបត្តិការ។

ទី៥ ការជំរុញការអភិវឌ្ឍច្រករបៀងឧស្សាហកម្មនៅតាមផ្លូវជាតិសំខាន់ៗ ដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗនៃកម្ពុជា ក៏ដូចជាតភ្ជាប់សេដ្ឋកិច្ចកម្ពុជាជាមួយនឹងប្រទេសជិតខាងពិសេស ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ និងអាស៊ាន។

ទី៦ ការបន្តពង្រឹងយន្តការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនិស្សារណកម្ម ពិសេសការគ្រប់គ្រងនិងការត្រួតពិនិត្យទាំងផ្នែកបច្ចេកទេស ផ្នែកគ្រប់គ្រងហានិភ័យ ផ្នែកគ្រប់គ្រងផលប៉ះពាល់បរិស្ថាននិងសង្គម តាំងពីដើមទីរហូតដល់ការធ្វើអាជីវកម្ម និងក្រោយការធ្វើអាជីវកម្ម ព្រមទាំងការគ្រប់គ្រងចំណូលសម្រាប់ថវិកាជាតិ តាមរយៈការរៀបចំគោលនយោបាយ ការពង្រឹងក្របខ័ណ្ឌគតិយុត្ត ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួលស្ថាប័ន រួមទាំងការអភិវឌ្ឍធនធានមនុស្ស។

ទី៧ ការអភិវឌ្ឍធនធានមនុស្ស ពិសេស ការបណ្តុះបណ្តាលជំនាញ សម្រាប់វិស័យឧស្សាហកម្ម តាមរយៈការលើកស្ទួយគុណភាពអប់រំគ្រប់ផ្នែក និងគ្រប់កម្រិត ពិសេស កំណែទម្រង់វិស័យឧត្តមសិក្សា និងការអប់រំបណ្តុះបណ្តាលជំនាញសមស្របតាមសេចក្តីត្រូវ

ការនៃទីផ្សារ ផ្អែកលើអភិក្រមបុរេសកម្ម និងភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៥១- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ***ក្រសួងឧស្សាហកម្ម និងសិប្បកម្ម*** នឹងផ្តោតការយកចិត្តទុកដាក់ សម្រេចឲ្យបាននូវសកម្មភាព ដូចខាងក្រោម៖

- ការជំរុញឲ្យកាន់តែប្រសើរនូវបរិស្ថានវិនិយោគ និងជំរុញការបង្កើតឡើងនូវឧស្សាហកម្មកកើតឡើងវិញ បរិស្ថានវិនិយោគសហគ្រាសធុនតូចនិងមធ្យម និងគម្រោងវិនិយោគខ្នាតធំ។
- ការពង្រឹងអភិបាលកិច្ចល្អសម្រាប់វិស័យឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម តាមរយៈការអនុវត្តច្បាប់ឲ្យមានសមធម៌និងតម្លាភាព៖
    - ➢ ការបន្តការអនុវត្តកម្មវិធីជំរុញអភិបាលកិច្ចល្អ ក្នុងការងារពង្រឹងការអនុវត្តច្បាប់ និងប្បញ្ញត្តិកម្ម ការពង្រឹងក្រមសីលធ៌មវិជ្ជាជីវៈ ការទទួលខុសត្រូវសង្គម យន្តការត្រួតពិនិត្យ និងពង្រឹងតម្លាភាពក្នុងសកម្មភាពបម្រើសេវាសាធារណៈរបស់ស្ថាប័នសាធារណៈ និងយន្តការទទួលដោះស្រាយបណ្តឹងត៏វ៉ារបស់វិស័យឯកជន។
    - ➢ ការបន្តអនុវត្តការត្រួតពិនិត្យឡើងវិញនូវបែបបទរដ្ឋបាល បទប្បញ្ញត្តិមានស្រាប់ និងអនុវត្តការវាយតម្លៃផលប៉ះពាល់លើធុរកិច្ចដោយសារប្បញ្ញត្តិកម្មថ្មី សំដៅធានាប្រសិទ្ធភាពប្បញ្ញត្តិកម្ម កាត់បន្ថយការិយាធិបតេយ្យ និងបន្ទុកធុរកិច្ចមិនចាំបាច់ក្នុងការវិនិយោគ និងអាជីវកម្ម ក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យម និងវិស័យសហគ្រាសកម្មន្តសាល។
    - ➢ ការបន្តការជំរុញលើកកម្ពស់ប្រសិទ្ធភាពស្ថាប័នក្នុងការគ្រប់គ្រង និងជួយគាំទ្រឧស្សាហកម្ម តាមរយៈកិច្ចសម្របសម្រួលអន្តរក្រសួង ស្ថាប័ន កាត់បន្ថយការិយាធិបតេយ្យ សមត្ថកិច្ចត្រួតគ្នានិងចំណាយលើសមត្ថកិច្ចស្ថាប័នច្រើនមិនចាំបាច់។
    - ➢ ការបន្តជំរុញនិងអនុវត្តឲ្យកាន់តែប្រសើរនូវយន្តការវេទិកាសាធារណៈ ជាមួយវិស័យឯកជន សំដៅជំរុញឲ្យវេទិកានេះក្លាយជាកម្លាំងចលករដ៏មានប្រសិទ្ធភាពក្នុងកម្មវិធីកំណែទម្រង់ចាំបាច់នានា និងការដោះស្រាយឆ្លើយតបប្រកបដោយប្រសិទ្ធភាពរាល់សំណូមពរ និងបញ្ហានានាដែលរាំងស្ទះ ឬជាឧបសគ្គក្នុងការជំរុញនិងអភិវឌ្ឍវិស័យឯកជន។
    - ➢ ការបន្តបណ្តុះបណ្តាល កសាងសមត្ថភាពស្ថាប័នកិច្ចថ្នាក់ក្រោមជាតិ និងប្រតិភូកម្មមុខងារ និងអំណាចក្នុងផ្នែកសេវាសាធារណៈ ក្នុងគោលដៅខិតឲ្យកាន់តែជិតគ្នារវាងអ្នកផ្តល់សេវានិងអ្នកទទួលសេវា។
    - ➢ ជំរុញកសាងសុខដុមនីយកម្មរវាងយន្តការនិងក្របខ័ណ្ឌបញ្ញត្តិកម្ម ជាមួយនិងទម្លាប់អនុវត្តល្អប្រសើរក្នុងតំបន់និងសកល។

- ការជំរុញលើកកម្ពស់ភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូចនិងមធ្យម តាមរយៈការពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងអាជីវកម្ម បង្កើននូវផលិតភាព សមត្ថភាពជំនាញ និងបច្ចេកវិទ្យា។
  - ➢ ជំរុញកសាងសមត្ថភាពផ្តល់សេវាអភិវឌ្ឍធុរកិច្ច និងស្ថាប័នកិច្ចគាំទ្រសំខាន់ៗ ដូចជាមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា មជ្ឈមណ្ឌលផលិតភាពជាតិ មជ្ឈមណ្ឌលភ្ជាស់បច្ចេកវិទ្យា វិទ្យាស្ថានបណ្តុះបណ្តាលឧស្សាហកម្ម វិទ្យាស្ថានស្តង់ដាកម្ពុជា មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ល។ សំដៅបង្កើតឡើងនូវប្រព័ន្ធចលករ គាំពារមួយរឹងមាំដល់ការជំរុញលទ្ធភាពផ្សារភ្ជាប់ភាពប្រកួតប្រជែង និងភាពអនុលោមតាមការតម្រូវលើទីផ្សារតំបន់និងសកល។
  - ➢ កសាងនិងអនុវត្តយុទ្ធោបករណ៍គោលនយោបាយចាំបាច់នានា ដើម្បីគាំទ្រនិងជំរុញលើកទឹកចិត្តសហគ្រាសធុនតូចនិងមធ្យម ក្នុងការវិនិយោគលើកិច្ចអភិវឌ្ឍបច្ចេកវិទ្យា ការបណ្តុះបណ្តាលនិងការលើកកម្ពស់សមត្ថភាពនិយោជិត កម្មករ។
  - ➢ ចលនា និងជំរុញការចូលរួមរបស់គ្រប់ដៃគូភាគីពាក់ព័ន្ធក្នុងការផ្សព្វផ្សាយ ការកសាងពុទ្ធិ និងពង្រីកការអនុវត្តឲ្យកាន់តែទូលំទូលាយនូវសកម្មភាពនៃចលនាផលិតភាពជាតិ ចលនាសហគ្រិនភាព និងចលនាឧត្តមភាពធុរកិច្ច សំដៅឈានទៅកសាងនូវខឿនឧស្សាហកម្មមួយរឹងមាំ មានការទទួលខុសត្រូវបរិស្ថាន សង្គមខ្ពស់ និងមានសមត្ថភាពខ្ពស់ក្នុងសកម្មភាពសមាហរណកម្មខ្សែចង្វាក់តម្លៃរបស់កម្ពុជាទៅក្នុងតំបន់ និងសកល។
  - ➢ បន្តកសាងសមត្ថភាពស្ថាប័នកិច្ច និងយុទ្ធោបករណ៍គោលនយោបាយចាំបាច់នានា ក្នុងវិស័យកម្មសិទ្ធិបញ្ញា និងកម្មសិទ្ធិឧស្សាហកម្មសំដៅជំរុញការសិក្សាស្រាវជ្រាវ និងច្នៃប្រឌិត និងបង្កើតយន្តការគាំទ្រសម្រាប់ការទាញយកនូវកាលានុវត្តភាពផ្សេងៗនៃប្រព័ន្ធកម្មសិទ្ធិបញ្ញាអន្តរជាតិ។
- ការជំរុញលើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញប្បទាន និងប្រព័ន្ធសេវាហិរញ្ញវត្ថុឲ្យមានភាពរឹងមាំនិងរស់រវើក សម្រាប់វិស័យសហគ្រាសធុនតូចនិងមធ្យម៖
  - ➢ ជំរុញការផ្តល់ហិរញ្ញប្បទានត្រូវបានធ្វើក្នុងលក្ខណៈជាផ្នែកមួយនៃកញ្ចប់ហិរញ្ញប្បទានសរុបរួមមួយ ដែលមានភាពស៊ីចង្វាក់គ្នាជាមួយយុទ្ធសាស្ត្រអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម ក្នុងការជំរុញឲ្យមានសម្ព័ន្ធភាព ការបំពេញគ្នាទៅវិញទៅមករវាងឧស្សាហកម្មធុនធំ និងសហគ្រាសធុនតូចនិងមធ្យម និងការជំរុញឲ្យសហគ្រាសធុនតូចនិងមធ្យម ក្លាយជាផ្នែកមួយនៃខ្សែចង្វាក់ផ្គត់ផ្គង់ប្រកបដោយភាពប្រកួតប្រជែង។

- ➢ បន្តពង្រឹងការអនុវត្ត និងកែលម្អប្រព័ន្ធទូទាត់ជាតិ ក្នុងគោលដៅពង្រីកពិពិធកម្មនៃមធ្យោបាយទូទាត់ ជំរុញការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុកាន់តែសម្បូរបែបនិងមានលក្ខណៈច្នៃប្រឌិតថ្មីសម្រាប់ឆ្លើយតបនឹងស្ថានភាព និងតម្រូវការរបស់សហគ្រាសធុនតូចនិងមធ្យម ។
- ➢ បន្តជំរុញកែលម្អបរិស្ថានហិរញ្ញវត្ថុកាន់តែប្រសើរ សម្រាប់ការស្រូបទាញវិនិយោគឯកជន ការបង្កើតទីផ្សារមូលធនក្នុងស្រុក និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ធ្វើយ៉ាងណាឲ្យមានភាពប្រកួតប្រជែងនៅក្នុងទីផ្សារមូលធន សំដៅកាត់បន្ថយតម្លៃកម្ចីមូលធន។
- ➢ ផ្តល់ជំនួយកសាងសមត្ថភាពដល់សហគ្រាសធុនតូចនិងមធ្យម ក្នុងការរៀបចំផែនការធុរកិច្ចច្បាស់លាស់ ការរៀបចំព័ត៌មានគណនេយ្យត្រឹមត្រូវ និងមានតម្លាភាព ដើម្បីលើកកម្ពស់លក្ខណសម្បត្តិក្នុងការទទួលបានហិរញ្ញប្បទានជាដើម។

- ការជំរុញផលិតផលកម្ពុជាឲ្យមានភាពអនុលោមតាមស្តង់ដាជាតិ តំបន់ និងអន្តរជាតិ ដើម្បីទទួលបាននូវទំនុកចិត្តពីអតិថិជននៅលើទីផ្សារជាតិ តំបន់ និងអន្តរជាតិ តាមរយៈការចូលរួមអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព៖
  - ➢ កសាងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់បម្រើឲ្យការអនុវត្តច្បាប់ស្តីពីស្តង់ដាកម្ពុជាប្រកបដោយប្រសិទ្ធភាព និងជំរុញការងារអធិការកិច្ច និងកិច្ចការពាក់ព័ន្ធទាំងឡាយដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពីស្តង់ដាកម្ពុជានិងមាត្រាសាស្ត្រកម្ពុជា។
  - ➢ អភិវឌ្ឍស្តង់ដាកម្ពុជា សម្រាប់ផលិតផល និងប្រព័ន្ធនានា សំដៅលើកកម្ពស់គុណភាពផលិតផលធានាសុវត្ថិភាពផលិតកម្មតាមការតម្រូវរបស់ទីផ្សារក្នុងប្រទេស តំបន់ និងអន្តរជាតិ និងដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់។
  - ➢ បង្កើនយុទ្ធនាការផ្សព្វផ្សាយព័ត៌មានអំពីស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក។
  - ➢ ជំរុញឲ្យបានខ្លាំងក្លាក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ផលិតផលនិងប្រព័ន្ធ។
  - ➢ ពង្រីកជាលំដាប់នូវវិសាសភាពនៃការវាយតម្លៃទទួលស្គាល់ ពីស្ថាប័នអន្តរជាតិចំពោះអង្គភាពវិញ្ញាបនបត្របញ្ជាក់ផលិតផលនិងប្រព័ន្ធ និងពង្រឹងសមត្ថភាពអង្គភាពវាយតម្លៃទទួលស្គាល់ជាតិរបស់វិទ្យាស្ថានស្តង់ដាកម្ពុជា។
  - ➢ ខិតខំប្រែក្លាយភាពជាសមាជិកនៅក្នុងអង្គការស្តង់ដាអន្តរជាតិពីសមាជិកទំនាក់ទំនងទៅជាសមាជិកពេញសិទ្ធិ និងក្នុងគណៈកម្មាធិការអន្តរជាតិអេឡិកត្រូនិកពីសមាជិកបុត្រសម្ព័ន្ធអេឡិកត្រូនិក ទៅជាសមាជិកពេញសិទ្ធិ។

- ការជំរុញកសាងនូវទំហំសេដ្ឋកិច្ចរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក តាមរយៈការបង្កើតកម្រងសហគ្រាសនិងការផ្សារភ្ជាប់សេដ្ឋកិច្ច ដែលមានលក្ខណៈបំពេញគ្នាទៅ

វិញទៅមករវាងឧស្សាហកម្មឈានមុខ ឧស្សាហកម្មខ្នាតធំ និងសហគ្រាសធុនតូចនិងមធ្យម។

- ជំរុញឲ្យមានប្រសិទ្ធភាពអភិវឌ្ឍវិស័យមាត្រាសាស្ត្រ ដែលជាមូលដ្ឋានគ្រឹះមួយដ៏សំខាន់ក្នុងការគាំទ្រដល់កិច្ចដំណើរការចង្វាក់ផលិតកម្មរបស់ឧស្សាហកម្ម និងសិប្បកម្មឲ្យទទួលបាននូវផលិតផលសម្រេចអនុលោមតាមស្តង់ដាដែលបានកំណត់ និងធានាបានទាំងបរិមាណ គុណភាព សុវត្ថិភាព និងបរិស្ថាន តាមរយៈការអភិវឌ្ឍមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។
  - ➢ គាំទ្រ និងជំរុញសកម្មភាពការងារនីត្យានុកូលមាត្រាសាស្ត្រ វិទ្យាសាស្ត្រមាត្រាសាស្ត្រ តាមរយៈការពង្រឹង គ្រប់គ្រងស្តង់ដាមាត្រាសាស្ត្រ ការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ព្យាសកម្ម អនុម័តគំរូ តេស្តវិភាគ ដើម្បីការពារផលប្រយោជន៍អ្នកផ្គត់ផ្គង់និងអ្នកប្រើប្រាស់ និងធានាបាននូវយុត្តិធម៌ក្នុងសកម្មភាពពាណិជ្ជកម្ម សេវា។
  - ➢ ជំរុញឲ្យមានសកម្មភាពការងារចុះបញ្ជីមាត្រាសាស្ត្រ ការផ្តល់អាជ្ញាបណ្ណប្រើពាណិជ្ជកម្មសញ្ញាមាត្រាសាស្ត្រ ការផ្តល់អាជ្ញាបណ្ណផលិត ជួសជុលឧបករណ៍មាត្រាសាស្ត្រ ជាការចូលរួមពង្រីកទីផ្សារ និងធ្វើឲ្យមានជំនឿទុកចិត្តលើផលិតផលរបស់កម្ពុជា។
  - ➢ គាំទ្រជំរុញបង្កើនការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីមាត្រាសាស្ត្រ និងសារប្រយោជន៍នៃវិស័យមាត្រាសាស្ត្រ ក្នុងការចូលរួមលើកកម្ពស់លើគ្រប់វិស័យឲ្យបានប្រសើរឡើង រួមទាំងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

## ៥.៣- ការអភិវឌ្ឍទីផ្សារការងារ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១៥២- នៅក្នុងនីតិកាលទី៤នៃរដ្ឋសភានៅឆ្នាំ២០១១ ចំនួនសហគ្រាសគ្រប់ប្រភេទ បានកើនឡើងគួរឲ្យកត់សម្គាល់ដល់ចំនួនសរុបជាង៥សែន ហើយស្រូបយកកម្មករ និយោជិតជាង ១លាន៦សែននាក់។ ពលករកម្ពុជាចំនួនជាង១សែននាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស ហើយទទួលបានប្រាក់ចំណូលជាង២០០លានដុល្លារអាមេរិកជាមធ្យមក្នុងមួយឆ្នាំ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានបង្កើត ***ទីភ្នាក់ងារជាតិមុខរបរនិងការងារ*** សម្រាប់ផ្តល់សេវាការងារជូនប្រជាជន ព្រមទាំងបានបង្កើត ***វេទិកាការងារ*** សម្រាប់ផ្លាស់ប្តូរនិងផ្តល់ព័ត៌មានស្តីពីទីផ្សារការងារ។ រាជរដ្ឋាភិបាលបានលើកទឹកចិត្តឲ្យមានយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការផងដែរ គឺយន្តការក្រុមប្រឹក្សាអាជ្ញាកណ្តាលនិងគណៈកម្មាធិការប្រឹក្សាការងារ។

៤.១៥៣- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តកែទម្រង់ឲ្យបានស៊ីជម្រៅថែមទៀតទាំងលើគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត និងយន្តការស្ថាប័ន ដែលបាន

អនុវត្តនាពេលអាពេលកន្លងមក សំដៅធ្វើឲ្យគ្រប់សមាភាគនៃទីផ្សារការងារ ដំណើរការប្រកបដោយភាពស៊ីចង្វាក់គ្នា និងជួយគាំទ្រគ្នាទៅវិញទៅមក ដើម្បីរួមចំណែកលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារ និងលើកស្ទួយជីវភាពប្រជាជន។ រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតអាទិភាពលើ៖

- ទី១ ការរៀបចំ និងអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ដើម្បីអភិវឌ្ឍវិស័យការងារឲ្យស្របតាមការវិវត្តនៃស្ថានភាពសង្គម សេដ្ឋកិច្ច ដោយយកចិត្តទុកដាក់ជាពិសេស លើការអភិវឌ្ឍការងារសម្រាប់យុវជន ការរៀបចំកម្លាំងពលកម្មឲ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ព្រមទាំងការត្រៀមលក្ខណៈក្នុងការគ្រប់គ្រង និងទាញយកផលប្រយោជន៍ឲ្យបានជាអតិបរមាពីការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។
- ទី២ ការពង្រឹងយន្តការ ***វេទិកាការងារ*** ដែលមានការចូលរួមពីសំណាក់អ្នកផ្តល់ការងារ អ្នកស្វែងរកការងារ និងអ្នកផ្តល់ការអប់រំ និងបណ្តុះបណ្តាល ក្រោមការសម្របសម្រួលរបស់រាជរដ្ឋាភិបាល សំដៅផ្លាស់ប្តូរព័ត៌មាន ប្រឹក្សាយោបល់ និងធ្វើសកម្មភាពរួមគ្នាដើម្បីឆ្លើយតបទៅនឹងស្ថានភាពទីផ្សារការងារ។
- ទី៣ ការពង្រីកការផ្តល់សេវារកការងារ និងការផ្សព្វផ្សាយព័ត៌មានអំពីកាលានុវត្តភាពការងារក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋគ្រប់មជ្ឈមណ្ឌលការងារនៃទីភ្នាក់ងារជាតិមុខរបរ និងការងាររបស់**ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល** នៅទូទាំងប្រទេស។
- ទី៤ ការបន្តអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារឲ្យកាន់តែល្អ ជាពិសេសការពង្រឹងការប្រមូល ការវិភាគ និងការផ្សព្វផ្សាយស្ថិតិការងារ ការផ្សព្វផ្សាយព័ត៌មានស្តីពីការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការផ្តល់ព័ត៌មានអំពីប្រាក់ឈ្នួល រួមទាំងអំពីការផ្គត់ផ្គង់ពលកម្មនិងសេចក្តីត្រូវការជំនាញ។
- ទី៥ ការបន្តអភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកទេស ឲ្យឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ជាពិសេស តាមរយៈការជំរុញការបណ្តុះបណ្តាល និងរឹតក្រឹតការជំនាញនិងវិជ្ជាជីវៈ ព្រមទាំងការហ្វឹកហ្វឺនកូនជាង ដោយផ្តល់ការលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនសំដៅលើកកម្ពស់ផលិតភាពការងារ និងបង្កើនចំណូលជូនពលករនិងនិយោជក។
- ទី៦ ការសម្របសម្រួលឲ្យស៊ីចង្វាក់គ្នារវាងវិស័យអប់រំ និងវិស័យបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការផ្តល់ព័ត៌មានអំពីប្រាក់ឈ្នួល រួមទាំងអំពីការផ្គត់ផ្គង់ពលកម្មនិងសេចក្តីត្រូវការជំនាញ។

ទី៧ ការបន្តលើកកម្ពស់លក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ រួមទាំងការបន្តគាំទ្រកម្មវិធី ***រោងចក្រល្អប្រសើរ*** និងការធ្វើឲ្យប្រសើរឡើងនូវបរិយាកាសទីផ្សារការងារ។

ទី៨ ការពង្រីកភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្ម និយោជិត និងនិយោជក តាមរយៈការជំរុញអនុម័តច្បាប់ស្តីពីសហជីព ការធ្វើបច្ចុប្បន្នកម្មច្បាប់ស្តីពីការងារ ការពង្រឹងការគោរពវិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈ ការពង្រឹងនិងសម្រួលសម្រួលស្ថាប័នអនុវត្តយន្តការទប់ស្កាត់និងដោះស្រាយវិវាទការងារ ក៏ដូចជាយន្តការទប់ស្កាត់ និងដោះស្រាយបាតុកម្ម ព្រមទាំងការពង្រឹងសមត្ថភាព និងតួនាទីរបស់ធិការកិច្ចការងារក្នុងការផ្សះផ្សា ដោះស្រាយវិវាទនិងការបង្កើតតុលាការការងារ។

ទី៩ ការបង្កើតយន្តការសម្រាប់ធ្វើការសិក្សាជាទៀងទាត់ និងជាយថាហេតុលើកអនុសាសន៍សម្រាប់ការពិនិត្យ កំណត់ប្រាក់ឈ្នួលអប្បបរមា ស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិតាមវិស័យនិងតាមតំបន់ ព្រមទាំងការបង្កើតយន្តការធានារ៉ាប់រងផលប្រយោជន៍របស់កម្មករ និយោជិត នៅពេលរោងចក្រក្ស័យធន។

ទី១០ ការបន្តពង្រឹងគ្រប់គ្រងការជ្រើសរើស និងការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ព្រមទាំងការលើកកម្ពស់យន្តការការពារសិទ្ធិ សុខភាព និងសុវត្ថិភាពការងាររបស់ពលករកម្ពុជានៅក្រៅប្រទេស។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៥៤- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- ធានាលើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរ៖
  - ➢ ពង្រឹងការអនុវត្តបទប្បញ្ញត្តិ និងច្បាប់ស្តីពីការងារ និងរៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីសុខភាពនិងសុវត្ថិភាពការងារ។
  - ➢ ធ្វើវិសោធនកម្មបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីការងារ និងរៀបចំបទប្បញ្ញត្តិឲ្យបានគ្រប់គ្រាន់ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិច្បាប់ស្តីពីការងារ ដើម្បីលើកកម្ពស់សិទ្ធិនិងសេរីភាពនៃទំនាក់ទំនងវិជ្ជាជីវៈ សុខភាព និងសុវត្ថិភាពការងារ និងលក្ខខណ្ឌការងារល្អប្រសើរ។
  - ➢ ធ្វើសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលដៅធានាឲ្យមានការអនុវត្តច្បាប់កាន់តែប្រសើរ និងចុះធ្វើអធិការកិច្ចតាមសហគ្រាសគ្រឹះស្ថានគ្រប់វិស័យ

ក្នុងគោលបំណងធានាស្តង់ដាលក្ខខណ្ឌការងារអប្បបរមា ទប់ស្កាត់ និងលុបបំបាត់ពលកម្មកុមារ។

- ពង្រីកការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់មូលដ្ឋាន ជាពិសេសដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យមានការយល់ដឹងពីផលវិបាកចំពោះបញ្ហាពលកម្មកុមារ ជាពិសេសការបង្កើនការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ ក៏ដូចជាការលើកកម្ពស់ការបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកអធិការកិច្ចពលកម្មកុមារ។

- បង្កើតបរិយាកាសការងារ និងការបង្កើនកាលានុវត្តភាពការងារៈ
  - ផ្តើមអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ដើម្បីអភិវឌ្ឍវិស័យការងារស្របតាមការវិវត្តនៃស្ថានភាពសង្គម សេដ្ឋកិច្ច ជាពិសេសដោយយកចិត្តទុកដាក់លើការបង្កើតការងារសម្រាប់យុវជន ដែលជាកម្លាំងពលកម្មស្នូលសម្រាប់ត្រៀមលក្ខណៈក្នុងការទប់ទល់លំហូរដោយសេរីនូវពលករជំនាញនាពេលសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥។
  - រៀបចំបង្កើតវិទ្យាស្ថានការងារក្នុងគោលបំណងបណ្តុះបណ្តាលមន្ត្រី សិស្ស និស្សិតសិក្សាស្រាវជ្រាវ និងវិភាគលើស្ថានភាពកម្លាំងពលកម្ម ប្រាក់ឈ្នួលនិងជំនាញដែលពាក់ព័ន្ធនឹងវិស័យការងារ។
  - លើកទឹកចិត្តម្ចាស់សហគ្រាសគ្រឹះស្ថានឯកជននៅតាមតំបន់ដាច់ស្រយាល ឲ្យគោរពលក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង ដើម្បីទាក់ទាញពលរដ្ឋខ្មែរឲ្យជ្រើសរើសការងារក្នុងស្រុក។
  - កែលម្អនីតិវិធីក្នុងការគ្រប់គ្រងពលករខ្មែរដែលទៅធ្វើការនៅបរទេសទាំងស្របច្បាប់ទាំងមិនស្របច្បាប់។
  - រៀបចំគោលការណ៍ស្នើសុំទៅរាជរដ្ឋាភិបាល ដើម្បីបង្កើតឲ្យមានអនុព័ន្ធការងារនៅតាមប្រទេសដែលមានពលករខ្មែរទៅធ្វើការលើសពីចំនួន៣ ០០០នាក់។
  - ចាត់វិធានការជាក់ស្តែងដើម្បីគ្រប់គ្រង និងការពារពលករខ្មែរដែលបានឆ្លងដែន និងរស់នៅដោយខុសច្បាប់នៅបរទេស ពិសេស នៅប្រទេសថៃ ដើម្បីធានាថាពលករទាំងនោះទទួលបានសិទ្ធិស្របច្បាប់ដើម្បីរស់នៅ និងធ្វើការ ឬត្រូវបានធ្វើមាតុភូមិនិវត្តន៍ដោយគោរពទៅតាមបទដ្ឋានអន្តរជាតិ។

- ពង្រឹងភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ
  - ផ្សព្វផ្សាយការយល់ដឹងអំពីសិទ្ធិការងារជាមូលដ្ឋានដល់គ្រប់ភាគីពាក់ព័ន្ធ ដើម្បីឲ្យមានការអនុវត្តបទប្បញ្ញត្តិនិងច្បាប់ស្តីពីការងារឲ្យកាន់តែប្រសើរឡើង។
  - ជំរុញឲ្យមានការចរចាជាសមូហភាពនៅថ្នាក់សហគ្រាសគ្រឹះស្ថាន ដើម្បីឲ្យមានការចុះអនុសញ្ញារួម។

- ➢ ពង្រឹងយន្តការដោះស្រាយវិវាទការងារ ដើម្បីលើកកម្ពស់សិទ្ធិកម្មករ និយោជិត និយោជក និងសហជីព និងកាត់បន្ថយការធ្វើកូដកម្មទាំងស្របតាមនីតិវិធី និងមិនស្របតាមនីតិវិធី។
- ➢ ជំរុញឲ្យមានការដោះស្រាយតាមរយៈយន្តការក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំពោះសំណុំរឿងវិវាទការងាររួមណាដែលត្រូវបានដោះស្រាយអស់លទ្ធភាពតែនៅមិនទាន់សះជា។
- ➢ បន្តស្នើសុំពិនិត្យ និងសម្រេចសេចក្តីព្រាងច្បាប់ស្តីពីសហជីពដើម្បីឈានទៅស្នើសុំសភាអនុម័ត និងប្រកាសឲ្យអនុវត្ត ព្រមទាំងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារ។
- ➢ ពិនិត្យតាមឃ្លាំមើលអំពីស្ថានភាពជីវភាពរស់នៅរបស់កម្មករ និយោជិត ធៀបនឹងកំណើនសេដ្ឋកិច្ច ដើម្បីកែសម្រួលអត្រាបៀវត្សអប្បបរមាឲ្យសមស្របទៅតាមស្ថានភាពសេដ្ឋកិច្ច។

• លើកកម្ពស់ការផ្តល់សេវាការងារនិងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព
  - ➢ ពង្រីកបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធផ្នែកសេវាជួរមុខឲ្យបានយ៉ាងហោចមួយ នៅតាមបណ្តារាជធានី ខេត្ត។
  - ➢ បង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការផ្តល់សេវាដូចជា ការចុះឈ្មោះការស្វែងរកការងារ និងការផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិក ដើម្បីជួយកាត់បន្ថយការចំណាយថវិកានិងពេលវេលា។
  - ➢ អភិវឌ្ឍធនធានមនុស្សក្នុងក្របខ័ណ្ឌទ.ជ.ម.ក. ឲ្យប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈក្នុងការផ្តល់សេវា។
  - ➢ ពង្រឹងការប្រមូលព័ត៌មានពីគ្រប់ប្រភព និងដោយផ្ទាល់ដល់ទីកន្លែងរបស់និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងអាជ្ញាធរមូលដ្ឋាន។
  - ➢ ផ្សព្វផ្សាយពីសេវាការងារ និងព័ត៌មានទីផ្សារការងារតាមរយៈមធ្យោបាយបោះពុម្ព ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងផ្សព្វផ្សាយនៅតាមទីវាល។
  - ➢ បង្កើតនិងចូលរួមពិព័រណ៍ការងារ និងសិក្ខាសាលាផ្សព្វផ្សាយការចងក្រងព័ត៌មានទីផ្សារការងារពីទិន្នន័យដែលមានស្រាប់ពីប្រភពអង្គភាពស្ថិតិ ដែលបានចាត់តាំងនិងការអង្កេតប្រមូលទិន្នន័យ។
  - ➢ ពង្រឹងយន្តការវេទិកាការងារដែលមានការចូលរួមពីសំណាក់អ្នកផ្តល់ការងារ អ្នកស្វែងរកការងារ និងអ្នកផ្តល់ការអប់រំ និងបណ្តុះបណ្តាល ក្រោមការសម្របសម្រួលរបស់រាជរដ្ឋាភិបាល សំដៅផ្លាស់ប្តូរព័ត៌មាន ប្រឹក្សាយោបល់ និងធ្វើសកម្មភាពរួមគ្នាដើម្បីឆ្លើយតបទៅនឹងស្ថានភាពទីផ្សារការងារ។

- ពង្រឹងនិងពង្រីកសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយសមធម៌
  - ពង្រីកប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឲ្យការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈបានដល់ប្រជាពលរដ្ឋគ្រប់រូបនៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេសប្រកបដោយសមធម៌។
  - បង្កើនការចុះឈ្មោះចូលរៀន ពង្រីកកម្មវិធីអប់រំ និងបំពាក់ឧបករណ៍សម្ភារៈមូលដ្ឋាន និងសង់អគារបន្ថែមសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរយៈពេលវែងដល់គ្រឹះស្ថានតាមខេត្តមួយចំនួនទៀត។
  - បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញ តាមរយៈមូលនិធិពិសេសរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី**សម្រាប់ជំហានទី៣បន្ថែមទៀត។
  - ពង្រឹងគុណភាពវិញ្ញាបនបត្រផ្អែកលើសមត្ថភាពជាមូលដ្ឋាននិងវគ្គសិក្សាសញ្ញាបត្រ ដើម្បីបណ្តុះបណ្តាលពលករឲ្យមានសមត្ថភាពជំនាញកម្រិតមធ្យម។
  - បង្កើនគុណភាពនៃកម្មវិធីអប់រំគ្រប់កម្រិត ដើម្បីធានាឲ្យពលករខ្មែរមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រកួតប្រជែងជាមួយនឹងពលករនៃបណ្តាប្រទេសអាស៊ានផ្សេងទៀត ជាពិសេស នាពេលសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥។
  - ដាក់បញ្ចូលជំនាញសហគ្រិនភាពនិងការប្រាស្រ័យទាក់ទង (ភាសាអង់គ្លេស) ទៅក្នុងកម្មវិធីសិក្សាឲ្យស្របតាមការប្រែប្រួលទៅនឹងតម្រូវការទីផ្សារការងារ។
  - បញ្ចូលជំនាញនិងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ស្តីពីការធានាគុណភាព និងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាទៅក្នុងកម្មវិធីសិក្សានៃវិស័យអប់រំ ជាពិសេសថ្នាក់វិទ្យាល័យនិងថ្នាក់ឧត្តមសិក្សា។
  - បញ្ចប់សេចក្តីព្រាងក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជានិងរៀបចំព្រះរាជក្រឹត្យស្តីពីការដាក់ឲ្យដំណើរការអនុវត្តក្របខ័ណ្ឌនេះ។
  - ធ្វើឲ្យមានភាពស៊ីគ្នារវាងក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា និងក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ាន។
  - រៀបចំការប្រកួតប្រជែងជំនាញថ្នាក់ជាតិនិងចូលរួមការប្រកួតប្រជែងជំនាញអាស៊ាន
  - បន្តអភិវឌ្ឍស្តង់ដាជាតិសមត្ថភាពអោយមានការប្រកួតប្រជែងខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងវិស័យសំណង់ មេកានិក សេវាធុរកិច្ច និងបច្ចេកវិទ្យាទូរគមនាគមន៍ព័ត៌មានវិទ្យា។
  - កែលម្អលក្ខណវិនិច្ឆ័យនិងអនុវត្តការទទួលស្គាល់វគ្គកម្មវិធីសិក្សា និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។
  - ធ្វើអធិការកិច្ចលើការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ធ្វើតេស្តកូនជាង ដែលបានហ្វឹកហ្វឺនចប់វគ្គ និងផ្តល់វិញ្ញាបនបត្រនិងបណ្ណទទួលស្គាល់ជំនាញ។

- ពង្រឹងសមត្ថភាពតាមអង្គភាពនីមួយៗក្នុងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិប្រចាំឆ្នាំ ការធានាគុណភាពការងារ និងការគ្រប់គ្រងត្រួតពិនិត្យតាមដាន និងវាយតម្លៃ។
- អភិវឌ្ឍនិងថែទាំនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍមុខជំនាញឲ្យស្របតាមតម្រូវការទីផ្សារការងារ។
- បង្កើតវិធីសាស្ត្រក្នុងការគ្រប់គ្រងជំនាញ ដែលជាយន្តការមួយគ្រប់គ្រងក្នុងការសម្របសម្រួលការអភិវឌ្ឍជំនាញ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើការវិវត្តជំនាញនៅក្នុងតំបន់។ ការបង្កើតវិធីសាស្ត្រនេះ គឺផ្អែកលើចំណេះដឹងដែលមានស្រាប់និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍមូលធនមនុស្សដែលនេះអាចរួមបញ្ចូលទាំងការពង្រឹងតួនាទីរបស់ NTB ផង។
- ជំរុញវិធីសាស្ត្រពហុភាគីក្នុងការគ្រប់គ្រងជំនាញ តាមរយៈការចូលរួមយ៉ាងសកម្មពីសំណាក់រាជរដ្ឋាភិបាល វិស័យឯកជននិងសហជីពនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។
- ភ្ជាប់យុទ្ធសាស្ត្រពាណិជ្ជកម្មទៅនឹងគោលនយោបាយឧស្សាហកម្ម ជាពិសេសឧស្សាហកម្មដែលមានសក្តានុពលខ្លាំង ដូចជាកសិកម្ម តម្លៃបន្ថែមអេឡិចត្រូនិក និងវិស័យកម្មន្តសាលធនស្រាល និងការដំឡើង។
- បង្កើតការតភ្ជាប់ជាលក្ខណៈអន្តរវិស័យឲ្យបានច្បាស់លាស់៖ ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សការតភ្ជាប់រវាងការអភិវឌ្ឍជំនាញ និងវិស័យដទៃទៀត ក៏គួរតែត្រូវបានធ្វើឡើងផងដែរ ឧទាហរណ៍ អាហារូបត្ថម្ភ និងសុខភាព គឺជាធាតុសំខាន់បំផុតសម្រាប់មនុស្សម្នាក់ៗដើម្បីពួកគេអាចមានសុខភាពល្អ និងកាយសម្បទាមាំមួនសម្រាប់ការបណ្តុះបណ្តាលជំនាញ។
- ផ្តល់អាទិភាពចំពោះស្ត្រីភេទជនពិការ ជនបាត់បង់កាលានុវត្តភាព ជនងាយរងគ្រោះ និងសិស្សដែលបានបោះបង់ការសិក្សា ដើម្បីឲ្យពួកគេមានជំនាញនិងមានមុខរបរអាចរួមរស់បានសមរម្យក្នុងសង្គមដូចសមាជិកដទៃទៀត។
- កសាងអគារអន្តេវាសិកដ្ឋានតាមបណ្តាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទូទាំងរាជធានី ខេត្ត។
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជនដើម្បីបង្កើនគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

• ធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

- ជំរុញនិងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន ដើម្បីធានាបានថាកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្លើយតបទៅនឹងការវិវត្ត និងតម្រូវការទី

ផ្សារនៃវិស័យឧស្សាហកម្ម ក៏ដូចជាដើម្បីចូលរួមក្នុងការអភិវឌ្ឍវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈទាំងធនធាននិងការបណ្ដុះបណ្ដាល។

- ➢ សិក្សាស្រាវជ្រាវនិងការវិភាគទៅលើគម្លាតនៃជំនាញ ដើម្បីរកឱ្យឃើញពីកម្រិតជំនាញដែលត្រូវផ្ដល់ឲ្យកម្លាំងពលកម្មនាពេលបច្ចុប្បន្នដោយធៀបទៅនឹងកម្រិតតម្រូវការ និងកម្រិតជំនាញដែលត្រូវផ្គត់ផ្គង់នាពេលអនាគត។
- ➢ រៀបចំគោលនយោបាយ បទប្បញ្ញត្តិនិងអភិបាលកិច្ចនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងនៅតាមអង្គភាពនីមួយៗ។
- ➢ ថែរក្សាប្រព័ន្ធព័ត៌មានវិទ្យា គ្រប់គ្រងការបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ និងប្រព័ន្ធព័ត៌មានទីផ្សារគ្រប់គ្រងការងារ ដែលជាប្រភពយោងមួយសម្រាប់គ្រប់ភាគីពាក់ព័ន្ធទៅនឹងការបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការសម្រេចចិត្តនិងការកសាងផែនការនាពេលអនាគត។

- ពង្រីកសេវារបបសន្តិសុខសង្គមឲ្យបានដល់ផ្នែកធានារ៉ាប់រងសុខភាពនិងរបបប្រាក់សោធន។

**<u>ដំណើរការរបបធានារ៉ាប់រងសុខភាព</u>**

- ➢ សិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអនុវត្តរបបធានារ៉ាប់រងសុខភាព ព្រមទាំងរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងការចុះបញ្ជិកាការបង់វិភាគទាននិងតារកលិក។
- ➢ រៀបចំវិធីសាស្ត្រទូទាត់ថ្លៃសេវាសុខាភិបាល។
- ➢ ផ្សព្វផ្សាយជាសាធារណៈតាមរយៈការធ្វើសិក្ខាសាលាប្រជុំផ្សព្វផ្សាយស្ប៉ត និងខិតបណ្ណផ្សព្វផ្សាយ និងអនុវត្តការផ្ដល់តារកលិកដល់កម្មករនិយោជិត។

**<u>ដំណើរការរបបប្រាក់សោធន</u>**

- ➢ សិក្សាឲ្យបានច្បាស់លាស់ពីលទ្ធភាពនៃកិច្ចដំណើរការរបបប្រាក់សោធន។
- ➢ រៀបចំលិខិតបទដ្ឋានគតិយុត្តនិងបណ្ដុះបណ្ដាលធនធានមនុស្ស។
- ➢ រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការអនុវត្តរបបប្រាក់សោធននិងផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយ។

- ពង្រឹងនិងអភិវឌ្ឍរបបសន្តិសុខសង្គមដល់អ្នកទទួលសេវានៃរបបធានារ៉ាប់រងហានិភ័យការងារសេវារ៉ាប់រងសុខភាពនិងរបបប្រាក់សោធន៖
  - ➢ ពង្រឹងការអនុវត្តច្បាប់ តាមរយៈការចុះធ្វើអធិការកិច្ចតាមបណ្ដាសហគ្រាស គ្រឹះស្ថាន ការចុះអង្កេតគ្រោះថ្នាក់ការងារ និងការចាត់វិធានការរដ្ឋបាលចំពោះសហគ្រាសគ្រឹះស្ថានដែលមិនព្រមអនុវត្តតាមច្បាប់។

- អភិវឌ្ឍគោលនយោបាយធានារ៉ាប់រងហានិភ័យការងារ ពង្រឹងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងចាត់វិធានការបង្ការគ្រោះថ្នាក់ការងារដើម្បីជៀសវាងនិងកាត់បន្ថយនូវករណីគ្រោះថ្នាក់ការងារចំពោះកម្មករនិយោជិត។
- ផ្តល់សេវាបុនទីតិសម្បទាដល់កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ឲ្យទទួលបាននូវការស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាលទ្ធភាពពួកគេក្នុងការចូលរួមដ៏ពេញលេញនិងដោយស្មើភាពក្នុងសកម្មភាពនានារបស់សង្គម។

## ៥.៤- ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ

៤.១៥៥- រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយ ដែលមានវិសាលភាពកាន់តែទូលាយ កាន់តែមានពិពិធភាព កាន់តែស៊ីជម្រៅ និងរឹងមាំ និងមានប្រសិទ្ធភាពដោយផ្អែកលើគោលការណ៍ទីផ្សារ ដើម្បីទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

៤.១៥៦- ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តឲ្យមានប្រសិទ្ធភាពនិងប្រកបដោយផ្លែផ្កានូវ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" ជាពិសេសដោយផ្តោតអាទិភាពលើ៖

- ទី១ ការបន្តអភិវឌ្ឍនិងសម្របសម្រួលក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តជាពិសេសការពង្រឹងយន្តការគ្រប់គ្រង និងត្រួតពិនិត្យ ការពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្សឲ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការធ្វើសមាហរណកម្មប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាទៅក្នុងតំបន់ និងអន្តរជាតិ។
- ទី២ ការបន្តអភិវឌ្ឍយន្តការបង្ការនិងដោះស្រាយវិបត្តិ រួមទាំងយន្តការផ្តល់សញ្ញាជាមុនតាមរយៈការបង្កើនការសម្របសម្រួលស្ថាប័ន ជាពិសេស ការពិនិត្យអំពីភាពចាំបាច់ក្នុងការបង្កើតគណៈកម្មការជាតិស្ថិរភាពហិរញ្ញវត្ថុ ។
- ទី៣ ការបន្តពង្រឹងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាព រួមមានប្រព័ន្ធទូទាត់សងប្រាក់ ការដាក់ឲ្យដំណើរការទីផ្សាររូបិយវត្ថុ/ទីផ្សារអន្តរធនាគារ ការបន្តជំរុញប្រើប្រាស់នូវឧត្តមានុវត្តន៍អន្តរជាតិក្នុងប្រព័ន្ធគណនេយ្យ និងអភិបាលកិច្ចសាជីវកម្ម។
- ទី៤ ការបន្តគាំទ្រនិងជំរុញកំណើនក្នុងវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ សំដៅលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដោយផ្តោតលើការកែលម្អថែមទៀតនូវយន្តការផ្តល់អាជ្ញាបណ្ណ

និងការចុះបញ្ជី ព្រមទាំងយន្តការត្រួតពិនិត្យ និងតាមដានឲ្យមានភាពសាមញ្ញ មានតម្លាភាព មានគណនេយ្យភាព និងមានប្រសិទ្ធភាព ជាពិសេសសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទន្ទឹមនឹងការបន្តធ្វើពិពិធកម្មឧបករណ៍ និងផលិតផលហិរញ្ញវត្ថុ ដូចជាការជំរុញអនុវត្តកិច្ចប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុនិងប្រព័ន្ធចែករំលែកហានិភ័យ។

ទី៥ ការបន្តខិតខំពង្រីកសេវាមីក្រូហិរញ្ញវត្ថុ តាមតម្លៃនិងលក្ខខណ្ឌកាន់តែមានលក្ខណៈអនុគ្រោះ ជាពិសេស សម្រាប់ប្រជាជនក្រីក្រ ក៏ដូចជាសហគមន៍កសិកម្មសំដៅលើកស្ទួយសេដ្ឋកិច្ចជនបទ ទន្ទឹមនឹងការបន្តពង្រីកការផ្តល់ឥណទានដល់សហគ្រាសធុនតូចនិងមធ្យម។

ទី៦ ការបន្តពង្រឹងនិងពង្រីកការអនុវត្តកាតព្វកិច្ចធានារ៉ាប់រង និងការបង្កើតផលិតផលថ្មីៗ ជាពិសេសការពង្រីកការផ្តល់សេវាធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច ដោយរៀបចំនិងកែសម្រួលក្របខ័ណ្ឌគតិយុត្តឲ្យកាន់តែប្រសើរ ជាមួយនឹងការពង្រឹងសមត្ថភាពបញ្ញត្តិករធានារ៉ាប់រង។

ទី៧ ការបន្តអភិវឌ្ឍទីផ្សារមូលបត្រ តាមរយៈការជំរុញ និងការលើកទឹកចិត្តដល់សហគ្រាសនិងក្រុមហ៊ុនឲ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ ការលើកកម្ពស់យន្តការជួញដូរ និងការពិនិត្យអំពីសេចក្តីត្រូវការក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋ។

ទី៨ ការបន្តអភិវឌ្ឍនិងពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គមឲ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព។

ទី៩ ការបន្តអភិវឌ្ឍនិងពង្រឹងអនុវិស័យហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀត រួមមាន បរធនបាលកិច្ច ទីផ្សារអចលនវត្ថុ ព្រមទាំងអាជីវកម្មទទួលទិញ លក់ទ្រព្យបញ្ចាំ និងអាជីវកម្មប្រាតិភោគដោយអនុប្បទាន។

ទី១០ ការបន្តពិនិត្យលទ្ធភាពបង្កើតមជ្ឈមណ្ឌលនៃការអភិវឌ្ឍហិរញ្ញវត្ថុ។

៤.១៥៧- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពខាងលើ ***រាជរដ្ឋាភិបាល*** នឹង៖

### វិស័យធនាគារ

- អនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាស្ថិរភាពថ្លៃ និងរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ។
- ជំរុញការប្រើប្រាស់ប្រាក់រៀលនិងកាត់បន្ថយដុល្លារូបនីយកម្ម។
- ជំរុញការប្រើប្រាស់ឧបករណ៍វិនិយោគជាប្រាក់រៀល ដូចជាបណ្ណរតនាគារ និងបណ្ណបំណុលផ្សេងទៀត។
- សម្របសម្រួលក្នុងចំណោមបញ្ញត្តិករវិស័យហិរញ្ញវត្ថុ ដើម្បីពង្រឹងការត្រួតពិនិត្យធនាគារ។

- ត្រៀមអនុវត្តកិច្ចសន្យានៃអតិក្រមគ្រប់គ្រងទូទាំងវិស័យ សម្រាប់ការពារស្ថិរភាពរូបិយវត្ថុ និងការគ្រប់គ្រងបំណុល។
- លើកកម្ពស់យន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ សម្រាប់ការពារវិបត្តិហិរញ្ញវត្ថុ។
- ពិនិត្យលទ្ធភាពបង្កើតគ្រឹះស្ថានធានាលើប្រាក់បញ្ញើ។
- ដាក់ឲ្យដំណើរការទីផ្សារអន្តរធនាគារនិងអភិវឌ្ឍទីផ្សាររូបិយវត្ថុ។

## វិស័យមីក្រូហិរញ្ញវត្ថុ

- បន្តពង្រឹងប្រព័ន្ធមីក្រូហិរញ្ញវត្ថុឲ្យកាន់តែមានភាពរឹងមាំ មានប្រសិទ្ធភាព និងបម្រើប្រយោជន៍ដល់ស្រទាប់ប្រជាពលរដ្ឋក្រីក្រ ជាមួយនឹងតម្លៃសេវាហិរញ្ញវត្ថុសមស្របអាចទទួលយកបាន និងបន្តពង្រឹងគុណភាពនៃប្រសិទ្ធភាពនិងចីរភាពហិរញ្ញវត្ថុ ជាមួយទិដ្ឋភាពសង្គម។
- ពង្រីកវិសាលភាពនៃសេវាមីក្រូហិរញ្ញវត្ថុឲ្យកាន់តែទូលំទូលាយ។
- អប់រំបណ្តុះបណ្តាលប្រជាពលរដ្ឋគ្រប់ស្រទាប់ឲ្យមានការយល់ដឹង មានសមត្ថភាពក្នុងការទទួលយកសេវាមីក្រូហិរញ្ញវត្ថុ។

## វិស័យមិនមែនធនាគារ

**ការធានារ៉ាប់រង**

- បង្កើនល្បឿនអភិវឌ្ឍឧស្សាហកម្មធានារ៉ាប់រងកម្ពុជា តាមរយៈការពង្រីកវិសាលភាពនៃសេវាធានារ៉ាប់រងឲ្យទូលំទូលាយ រួមទាំងការដាក់ឲ្យមានសេវាធានារ៉ាប់រងអាយុជីវិត។
- ជំរុញលំហូរមូលធន ដែលជាទុនបម្រុងរបស់អាជីវកម្មធានារ៉ាប់រងទៅជាប្រភពទុនវិនិយោគដ៏សំខាន់ក្នុងទីផ្សារហិរញ្ញវត្ថុ។
- លើកទឹកចិត្តឲ្យមានការធានារ៉ាប់រងខ្នាតតូច ដើម្បីបំពេញតម្រូវការជូនប្រជាពលរដ្ឋនៅតាមជនបទដែលមានចំណូលទាប។
- បង្កើតការិយាល័យផ្សះផ្សាវិវាទធានារ៉ាប់រង ដើម្បីបង្កើតឲ្យមានសមភាពនិងយុត្តិធម៌រវាងអ្នកត្រូវបានធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង។
- ដាក់ឲ្យអនុវត្តប្រព័ន្ធជូនដំណឹងហានិភ័យជាមុននិងទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា។
- បង្កើតវិទ្យាស្ថានធានារ៉ាប់រង ដើម្បីបណ្តុះបណ្តាលដល់បញ្ញត្តិករធានារ៉ាប់រង ប្រតិបត្តិករធានារ៉ាប់រង និងសាធារណជន ដើម្បីពង្រឹងគុណភាពនៃការគ្រប់គ្រង ការផ្តល់សេវាធានារ៉ាប់រងប្រកបដោយក្រមវិជ្ជាជីវៈខ្ពស់ និងជំនាញទូទៅក្នុងវិស័យធានារ៉ាប់រង។

**វិស័យសោធន**

- ជំរុញការកៀរគរប្រាក់សន្សំរយៈពេលវែង ដើម្បីបង្កើតបណ្តាញសំណាញ់សុវត្ថិភាពសង្គម។
- កសាងក្របខ័ណ្ឌច្បាប់ ស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពជំនាញ។

- កសាងក្របខណ្ឌច្បាប់ដើម្បីធ្វើបញ្ញត្តិកម្ម ដើម្បីប្រមូលផ្តុំការគ្រប់គ្រងនិងត្រួតពិនិត្យវិស័យសោធន។

**វិស័យមូលបត្រ**

- អភិវឌ្ឍទីផ្សារមូលបត្របំណុល ដែលរួមមានទីផ្សារមូលបត្ររដ្ឋនិងទីផ្សារសញ្ញាបណ្ណសាជីវកម្ម ព្រមទាំងទីផ្សារមូលបត្រផ្សេងៗទៀត។
- បង្កើតក្របខ័ណ្ឌគ្រប់គ្រង រួមទាំងការបង្កើត*ភ្នាក់ងារវាយតម្លៃលទ្ធភាពសង* ដើម្បីគាំទ្រដល់ការបោះផ្សាយលក់មូលបត្របំណុល។
- សិក្សាលទ្ធភាពបង្កើត*ទីផ្សារខុម៉ូឌីធីអនាគត* សំដៅជំរុញការអភិវឌ្ឍផលិតកម្មកសិកម្ម និងឧស្សាហកម្ម។
- ជំរុញនិងពង្រឹងនូវការអនុវត្តអភិបាលកិច្ចសាជីវកម្មល្អ។
- រៀបចំនិងដាក់ឲ្យអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការក្ស័យធន និងបរធនបាលកិច្ចហិរញ្ញវត្ថុនៅក្នុងទីផ្សារមូលបត្រ។
- កសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងៗ ដូចជាប្រព័ន្ធរក្សាទុកមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រនិងប្រព័ន្ធទូទាត់សាច់ប្រាក់។
- បន្តជំរុញការធ្វើពិពិធកម្មឧបករណ៍ហិរញ្ញវត្ថុ និងយន្តការវិនិយោគដើម្បីអភិវឌ្ឍទីផ្សារមូលបត្រឲ្យមានមូលដ្ឋានទូលំទូលាយ។
- ជំរុញប្រតិបត្តិការគ្រឹះស្ថានមិនមែនធនាគារឲ្យស្ថិតក្រោមច្បាប់ស្តីពីបរធនបាលកិច្ច។
- ស្ទង់វាយតម្លៃលើប្រព័ន្ធទីផ្សារមូលបត្រ។
- បង្កើតមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ ក្នុងគោលបំណងទាក់ទាញលំហូរហិរញ្ញវត្ថុ។
- បន្តពង្រឹងប្រព័ន្ធព័ត៌មានវិទ្យារបស់និយ័តករ ដើម្បីលើកកម្ពស់ការបង្ហាញព័ត៌មាន និងការអង្កេត តាមដានទីផ្សារ។
- បន្តអប់រំនិងបណ្តុះបណ្តាលវិនិយោគិន និងអ្នកសារព័ត៌មាន និងការអង្កេតតាមដានទីផ្សារ។
- បន្តអប់រំនិងបណ្តុះបណ្តាលសមត្ថភាពជំនាញរបស់និយ័តករ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ។

## ៦- ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

៤.១៥៨- ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងក្នុងពេលចំពោះមុខទាំងសម្រាប់អនាគត ពិសេសក្នុងពេលដែលកម្ពុជាឈានចូលទៅក្នុង**ប្រទេសមានចំណូលមធ្យមកម្រិតទាប**ក្នុងពេលដ៏ខ្លីខាងមុខ ហើយបន្តឡើងទៅជា**ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០** និងជា**ប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០** តាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិ

បាល។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្ស ជាពិសេស យុវជន គឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញ ការច្នៃប្រឌិត និងនវានុវត្តន៍គ្រប់ផ្នែក គ្រប់វិស័យ ជាពិសេស ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍ ទន្ទឹមនឹងការលើកស្ទួយគុណភាពខាងសុខភាព កាយសម្បទា សីលធម៌ ស្មារតីទទួលខុសត្រូវ និងមនសិការស្នេហាជាតិនិងវិជ្ជាជីវៈ ដោយគ្មានការរើសអើងខាងយេនឌ័ររួមជាមួយនឹងប្រព័ន្ធសុវត្ថិភាពសង្គមគត់មត់។

## ៦.១- ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១៥៩- រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ក្នុងការអនុវត្តយុទ្ធសាស្ត្រ"***អប់រំសម្រាប់ទាំងអស់គ្នា***" តាមរយៈការធានាសមធម៌ក្នុងការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ សម្រាប់កុមារគ្រប់រូប។ សមិទ្ធផលសំខាន់ៗ រួមមានចំនួនសាលារៀន និងគ្រូបង្រៀនព្រមទាំងអត្រាចុះឈ្មោះចូលរៀននៅគ្រប់កម្រិតសិក្សានៃចំណេះទូទៅ បានកើនឡើងជាលំដាប់ ពិសេស នៅតាមតំបន់ជនបទ។

៤.១៦០- ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តគោលការណ៍***ការអប់រំសម្រាប់ទាំងអស់គ្នា*** សំដៅធានាសមធម៌ក្នុងការទទួលបានសេវាអប់រំ បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំគ្រប់កម្រិត ព្រមទាំងបន្តអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំ ដោយផ្តោតអាទិភាពលើ៖

- ទី១ ការបន្តកែលម្អគោលនយោបាយនិងយុទ្ធសាស្ត្រវិស័យអប់រំ ជាពិសេស ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងពិនិត្យតាមដានតាមរយៈប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំដែលមានបច្ចុប្បន្នភាព និងភាពប្រាកដនិយម ផែនការគោលស្តីពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងវិស័យអប់រំ និងគោលនយោបាយស្តីពីការស្រាវជ្រាវ និងការអភិវឌ្ឍក្នុងវិស័យអប់រំដើម្បីកសាងគោលនយោបាយ ក្នុងគោលបំណងកសាងប្រព័ន្ធដែលមានគុណភាពខ្ពស់សម្រាប់កសាងធនធានមនុស្សមានស្តង់ដាខ្ពស់។
- ទី២ ការលើកកម្ពស់ការយល់ដឹងនិងសមត្ថភាពធនធានមនុស្ស ក្នុងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ពិសេសតាមវិស័យអាទិភាពនានា ដូចជា វិស័យកសិកម្ម រួមមានដំណាំកសិកម្ម ការចិញ្ចឹមសត្វ វារីវប្បកម្ម វិស័យឧស្សាហកម្ម ថាមពល សំណង់ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត វិស័យបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ វិស័យសុខាភិបាល និង

វិស័យបរិស្ថាន ជាដើម តាមរយៈវិធានការគន្លឹះមួយចំនួន ដូចជា(១)ការបញ្ជ្រាបការយល់ដឹងអំពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងផលប្រយោជន៍នៃការប្រើប្រាស់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ពិសេសកម្រិតមធ្យមសិក្សាទុតិយភូមិ កម្រិតបណ្តុះបណ្តាលបច្ចេកទេស និងនៅកម្រិតឧត្តមសិក្សា និង(២)ការជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍ រួមទាំងការបង្កើតបណ្តាញស្រាវជ្រាវគំរូរវាងសាកលវិទ្យាល័យ ភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាលនិងសហគ្រាស។

ទី៣ ការបង្កើនលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ តាមរយៈការបន្តជំរុញការកសាងសាលាបឋមសិក្សាឲ្យដល់ភូមិ ការកសាងអនុវិទ្យាល័យឲ្យបានមួយយ៉ាងតិចក្នុងឃុំនីមួយៗ ស្របតាមស្ថានភាពភូមិសាស្ត្រ ការជំរុញឲ្យមានសាកលវិទ្យាល័យ ឬសាខាសាកលវិទ្យាល័យនៅតាមខេត្តនីមួយៗ ស្របតាមលទ្ធភាពនិងស្ថានភាពជាក់ស្តែង ការពង្រាយគ្រូបង្រៀនឲ្យដល់គ្រប់ទីកន្លែង ក្នុងនោះរួមមានការផ្តល់អាទិភាពឲ្យគ្រូបង្រៀនអាចធ្វើការនៅតាមមូលដ្ឋានភូមិ ឃុំរបស់ខ្លួន ការបង្កើនចំនួនអន្តេវាសិកដ្ឋាន ការផ្តល់មធ្យោបាយធ្វើដំណើរ(ដូចជា កង់) ការកាត់បន្ថយចំណាយរបស់មាតាបិតាសិស្ស ការបង្កើនចំណាយសម្រាប់គ្រឹះស្ថានសិក្សា ព្រមទាំងការពង្រីកការចូលរួមពីវិស័យឯកជននិងដៃគូអភិវឌ្ឍពាក់ព័ន្ធផ្សេងទៀត។

ទី៤ ការបន្តអភិវឌ្ឍស្ថាប័ននិងសមត្ថភាពរបស់មន្ត្រីអប់រំ តាមរយៈការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត និងការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធការពង្រឹងរចនាសម្ព័ន្ធការងារនិងការបណ្តុះបណ្តាលជំនាញដល់មន្ត្រី។

ទី៥ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតសិក្សា និងក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញទាំងក្នុងគ្រឹះស្ថានរដ្ឋ និងគ្រឹះស្ថានឯកជនឲ្យស្របទៅតាមកម្រិតស្តង់ដាអន្តរជាតិ និងតម្រូវការអភិវឌ្ឍរបស់ប្រទេសតាមរយៈការពង្រឹងការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការធ្វើអធិការកិច្ច និងការពង្រឹងសមត្ថភាពគ្រប់គ្រង ការលើកទឹកចិត្តគ្រូបង្រៀនក្នុងការបង្កើនសមត្ថភាពបង្រៀន ការពង្រឹងគុណភាពក្នុងការប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ ការលើកកម្ពស់ការសិក្សាភាសាបរទេសដែលចាំបាច់ការកែលម្អលក្ខខណ្ឌនៃការសិក្សា ការបង្កើតបណ្ណាល័យ មន្ទីរពិសោធន៍ និងការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សាព្រមទាំងការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍។

ទី៦ ការបន្តជំរុញលើកកម្ពស់តួនាទីសាសនា ពិសេសគឺព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋក្នុងការចូលរួមផ្តល់ការអប់រំផ្នែកគុណធម៌ សីលធម៌ និងចរិយាធម៌ ព្រមទាំងក្នុងការធានាភាពសុខដុមរមនានៅក្នុងសង្គមកម្ពុជា។

ទី៧ ការជំរុញការរៀបចំ និងការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សំដៅលើកកម្ពស់ផលិតភាពការងាររបស់ពលករ ដោះស្រាយ និងកាត់បន្ថយភាពគ្មានការងារធ្វើរបស់យុវជន ព្រមទាំងបង្កើនចំណូលរបស់ប្រជាជន និងធានាសមធម៌។

ទី៨ ការបន្តពង្រឹងគុណភាពនៃការអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការអភិវឌ្ឍសម្រាប់យុវជននូវជំនាញបច្ចេកទេសនិងជំនាញទន់ ពិសេស ការធ្វើការងារជាក្រុម ការគោរពវិន័យ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងកន្លែងការងារ តាមរយៈការកែលម្អកម្មវិធីបណ្តុះបណ្តាល ការពង្រឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ការបង្កើតស្តង់ដាជាតិ សមត្ថភាព ការត្រួតពិនិត្យ និងការធ្វើតេស្តសមត្ថភាព ការទទួលស្គាល់មុខជំនាញ និងការប្រកួតប្រជែងជំនាញ សំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារពលកម្ម បង្កើនកាលានុវត្តភាពទទួលបានការងារ និងប្រើប្រាស់ឲ្យអស់សក្តានុពលនូវផលលាភប្រជាសាស្ត្ររបស់កម្ពុជា ក៏ដូចជាដើម្បីបង្កើតលក្ខខណ្ឌសមស្របសម្រាប់ពលករកម្ពុជាអាចឈានឡើងទៅកាន់តួនាទីគ្រប់គ្រង និងដឹកនាំ។

ទី៩ ការបន្តជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងគោលនយោបាយជាតិស្តីពីការអប់រំកាយ និងកីឡា តាមរយៈការបំផុសយុវជនឲ្យចូលរួមក្នុងចលនាការងារសង្គម និងសកម្មភាពកីឡាសំដៅប្រែក្លាយយុវជនឲ្យទៅជាធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងការបន្តវេន។

ទី១០ ការបន្តអភិវឌ្ឍពហុកីឡដ្ឋានជាតិ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ព្រមទាំងការរៀបចំបណ្តុះបណ្តាលកីឡាករ កីឡាការិនី តាមវិស័យ ដែលកម្ពុជាមានសក្តានុពល ដើម្បីត្រៀមក្នុងការទទួលធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេមនៅឆ្នាំ២០២៣។

៤.១៦១- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការផ្តល់កាលានុវត្តភាពស្មើៗគ្នាដល់កុមារនិងយុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនមានការរើសអើង។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៦២- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាព ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ ***ក្រសួងអប់រំ យុវជន និងកីឡា*** បានឆ្លើយតបទៅនឹងផលសម្រេចរំពឹងទុករបស់**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨** តាមរយៈការរៀបចំ**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨** ឆ្ពោះទៅដោះស្រាយរាល់បញ្ហាប្រឈមនានាក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពនិងភាពឆ្លើយតបដល់កុមារគ្រប់រូបនៅគ្រប់កម្រិតសិក្សា។ ក្រសួងបានរៀបចំផែនការតាម

អនុវិស័យដូចជា ការអប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ យុវជន និងកីឡា ដែលផ្តោតជាសំខាន់លើតម្រូវការនៃការទទួលបានសេវាអប់រំគុណភាពនិងភាពឆ្លើយតប។ ជាមួយនេះ ក៏ផ្តោតលើការរៀបចំក្របខ័ណ្ឌធានាគុណភាពនិងផ្តល់កាលានុវត្តភាពកាន់តែច្រើនក្នុងការទទួលបានបំណិនដែលពាក់ព័ន្ធ។

៤.១៦៣- ដើម្បីសម្រេចគោលដៅនៃគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងអប់រំ យុវជន និងកីឡា*** បានដាក់ចេញនូវគោលនយោបាយចំនួន៣នៅក្នុង**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨** ដូចខាងក្រោម៖

- គោលនយោបាយទី១៖ ធានាសមធម៌នៃការទទួលបានសេវាអប់រំ តាមរយៈការធ្វើឲ្យកុមារគ្រប់រូបបានចូលរៀននៅសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដែលមានលក្ខណៈកុមារមេត្រីនិងអប់រំបញ្ចូលគ្នា និងមានកាលានុវត្តភាពបន្តការសិក្សាទៅមុខទៀត។ ចំពោះកុមារដែលពុំមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធជម្រើសផ្សេងទៀតនឹងត្រូវផ្តល់លទ្ធភាពឲ្យអ្នកទាំងនោះទទួលបានការអប់រំ។ ដើម្បីសម្រេចគោលនយោបាយនេះ ក្រសួងត្រូវសាងសង់សាលារៀនបន្ថែមទៀត និងផ្តល់គ្រូដែលមានការបណ្តុះបណ្តាលនិងមានគុណភាព។
  - ធានាថាកុមារទាំងអស់ដែលបានចូលរៀននៅថ្នាក់ទី១ យ៉ាងហោចណាស់បានឆ្លងកាត់ថ្នាក់មត្តេយ្យសិក្សា។
  - បង្កើនចំនួនកុមារនិងយុវជន ឲ្យទទួលបានការអប់រំនៅគ្រប់កម្រិត ដោយផ្តោតលើសមធម៌ ការទទួលបានសេវាអប់រំរបស់កុមារនៅតំបន់ជួបការលំបាក និងក្រុមកុមារជួបការលំបាក។
  - បង្កើនកាលានុវត្តភាពដល់សិស្ស ដែលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិឲ្យទទួលបាននូវចំណេះដឹងរឹងមាំ និងជំនាញក្នុងការគិតប្រកបដោយហេតុផល ដែលអាចបណ្តុះបានតាមរយៈការបណ្តុះបណ្តាលបច្ចេកទេស ការអប់រំឧត្តមសិក្សា និងមធ្យោបាយសិក្សាផ្សេងទៀត។
- គោលនយោបាយទី២៖ លើកកម្ពស់គុណភាពនិងភាពឆ្លើយតប តាមរយៈការធ្វើឲ្យកុមារនិងយុវជនគ្រប់រូបទទួលបានការអប់រំដែលមានគុណភាពនិងភាពឆ្លើយតប ដែលអាចឲ្យពួកគេអាចចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយភាពស័ក្តិសិទ្ធិ។ កុមារនិងយុវជននឹងទទួលបានការសិក្សាជំនាញក្នុងការគិត និងពិចារណា និងមានមូលដ្ឋានរឹងមាំលើមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ ភាសាបរទេស សង្គម និងបំណិនជីវិត។ ដើម្បីសម្រេចគោលបំណងនៃគោលនយោបាយនេះ ក្រសួងនឹងអនុវត្តដូចខាងក្រោម៖

- ធ្វើកំណែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេសឲ្យស្របនឹងបទពិសោធល្អៗរបស់អន្តរជាតិ។
- កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឲ្យស្របនឹងកម្មវិធីសិក្សា ដែលបានកែលម្អ និងធ្វើវិក្រឹតការគ្រូបង្រៀន។
- ធានាការអនុវត្តម៉ោងបង្រៀនប្រកបដោយប្រសិទ្ធភាព រួមជាមួយនឹងការផ្តល់គ្រូបង្រៀនដែលបានបណ្តុះបណ្តាលនិងមានគុណភាពគ្រប់គ្រាន់ នៅគ្រប់កម្រិតសិក្សា និងផ្តល់សៀវភៅសិក្សាគោល ព្រមទាំងសម្ភារៈសិក្សានានា។
- ពិនិត្យតាមដានជាប្រព័ន្ធលើលទ្ធផលនៃការសិក្សារបស់សិស្ស តាមរយៈការវាយតម្លៃថ្នាក់ជាតិ នៅថ្នាក់ទី៣ ទី៦ និងទី៨ និងការត្រៀមខ្លួនចូលរួមក្នុងកម្មវិធីវាយតម្លៃថ្នាក់តំបន់និងអន្តរជាតិ។

- គោលនយោបាយទី៣៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ តាមរយៈការផ្តល់សេវាអប់រំ ប្រកបដោយភាពស័ក្តិសិទ្ធិនិងភាពទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងវិជ្ជាជីវៈនឹងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេលវេលា និងអាចពិនិត្យតាមដាននិងរាយការណ៍នូវលទ្ធផលស្របជាមួយនឹងយោបល់ត្រឡប់ ព្រមទាំងយន្តការសម្រាប់កែលម្អគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធី។

៤.១៦៤- ដើម្បីបន្តសម្រេចបានតាមគោលនយោបាយទាំងបីខាងលើ ***ក្រសួងអប់រំ យុវជន និងកីឡា*** នឹងបន្តអនុវត្តកម្មវិធីជាអាទិភាពមួយចំនួន ដូចខាងក្រោម៖

- កម្មវិធីពង្រីកការគាំពារ និងអភិវឌ្ឍន៍កុមារតូចជាមូលដ្ឋាន សម្រាប់ផ្តល់ដល់ជំនាន់ក្រោយនូវប្រជាពលរដ្ឋដែលមានការអប់រំសុខភាព បំណិន និងចំណេះដឹង ដើម្បីចូលរួមការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច តាមរយៈការសាងសង់និងបង្កើនការចូលរៀនឲ្យបាន ៨០%នៃកុមារតូច នៅតាមសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសិក្សាសហគមន៍ និងអប់រំកុមារតូច តាមផ្ទះ តាមខ្នងផ្ទះ និងធានាថា៨០%នៃកុមារអាយុ៥ឆ្នាំ បានបញ្ចប់ការសិក្សានៅមត្តេយ្យរដ្ឋរយៈពេល១ឆ្នាំ។
- កម្មវិធីអភិវឌ្ឍនិងសាងសង់សាលារៀន ធានាថាកុមារទាំងអស់បានចូលរៀននៅបឋមសិក្សា និងចូលរៀនកាន់តែច្រើនឡើងនៅមធ្យមសិក្សា តាមរយៈការសង់សាលារៀនភ្ជាប់ជាមួយនឹងទឹកស្អាត បរិក្ខារសុខភាពនិងអនាម័យ(ជាពិសេស ការពង្រីកសាលាបឋមសិក្សាទៅជាអនុវិទ្យាល័យឲ្យបានច្រើនតាមឃុំ សង្កាត់ ស្របតាមកំណើនសិស្ស) ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន ការផ្តល់សៀវភៅសិក្សាគោល និងបរិក្ខារបណ្ណាល័យ ការបំប៉ននាយកសាលារៀន បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន

បន្ទប់សិក្សាភាសាបរទេស រោងជាងសម្រាប់ការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ កម្មវិធីចុះកម្មសិក្សាដោយសហការជាមួយនិយោជក។

- កម្មវិធីអភិវឌ្ឍប្រព័ន្ធធានាគុណភាពអប់រំនិងគុណភាពសាលារៀន សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ ការអភិវឌ្ឍក្របខ័ណ្ឌគុណភាពនិងឧបករណ៍ ការអភិវឌ្ឍសមត្ថភាពក្នុងការជួយសាលារៀននិងគ្រូបង្រៀន ដើម្បីសម្រេចបានស្តង់ដានិងម៉ោងសិក្សាអប្បបរមា គុណភាពនិងភាពឆ្លើយតប តាមរយៈការអភិវឌ្ឍកម្មវិធីសិក្សាឲ្យមានភាពឆ្លើយតប សៀវភៅសិក្សាគោលនិងសម្ភារៈសិក្សាគ្រប់គ្រាន់ និងការបង្រៀនប្រកបដោយឧត្តមភាព។
- កម្មវិធីពង្រឹងប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិនិងអន្តរជាតិ ពង្រឹងការធ្វើតេស្តថ្នាក់រៀនជាប្រចាំនិងការវាយតម្លៃថ្នាក់ជាតិ ការកែទម្រង់ការប្រឡងថ្នាក់ជាតិ និងការត្រៀមខ្លួនចូលរួមក្នុងកម្មវិធីវាយតម្លៃការសិក្សារបស់សិស្សថ្នាក់អន្តរជាតិ។
- កម្មវិធីអាហារូបករណ៍ ពង្រីកវិសាលភាពការអប់រំនៅដល់បឋមសិក្សា និងមធ្យមសិក្សា និងផ្តោតលើការកំណត់ក្រុមគោលដៅ ការពិនិត្យតាមដាននិងវាយតម្លៃកម្មវិធី។
- កម្មវិធីអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ អនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិថ្នាក់ជាតិ ដើម្បីបង្កើនគុណភាពនៃការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ និងរៀបចំស្ថាប័នសម្របសម្រួល ជាមួយនឹងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការផ្តល់កាលានុវត្តភាពសិក្សាផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ។
- កម្មវិធីគ្រប់គ្រងនិងវាយតម្លៃការបំពេញការងាររបស់បុគ្គលិក សម្រាប់បង្កើនគុណភាពនៃការបង្រៀន ការវាយតម្លៃ ការសរសើរ ការលើកទឹកចិត្ត និងការបន្តអភិវឌ្ឍវិជ្ជាជីវៈជាពិសេស តាមរយៈយន្តការសម្រាប់ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន។
- កម្មវិធីអភិវឌ្ឍឧត្តមសិក្សា កែទម្រង់ប្រព័ន្ធអប់រំនៅឧត្តមសិក្សាឲ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីស្របជាមួយនឹងស្តង់ដាក្នុងតំបន់និងអន្តរជាតិ លើកកម្ពស់គុណភាពនៃដំណើរការរបស់ប្រព័ន្ធ តាមរយៈការតម្រូវឲ្យគ្រឹះស្ថានឧត្តមសិក្សាទាំងអស់គោរពតាមស្តង់ដាអប្បបរមា ផ្តោតជាសំខាន់លើការបង្រៀននិងស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា ការបង្កើនចំនួនគ្រូបង្រៀននិងសាស្ត្រាចារ្យដែលមានគុណភាព (សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត)។ ការពិនិត្យឡើងវិញនិងចេញសេចក្តីណែនាំស្តីពីការកំណត់តម្លៃសិក្សា ការបង្កើនអាហារូបករណ៍ដល់សិស្ស និស្សិតពូកែតាមមុខវិជ្ជាដែលស្របនឹងតម្រូវការទីផ្សារការងារ គម្រោងកម្ចីសិក្សា និងគម្រោងសម្រាប់ធានាការលើកទឹកចិត្តគ្រប់គ្រាន់ ដល់បុគ្គលិកដែលមានគុណវុឌ្ឍិខ្ពស់ និងបុគ្គលិកធម្មតា (ឧទាហរណ៍ អ្នកបច្ចេកទេសបន្ទប់ពិសោធន៍ និងបណ្ណារក្ស)។

- កម្មវិធីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល អភិវឌ្ឍសមត្ថភាព និងការផ្លាស់ប្តូររបៀបរបបការងារដើម្បីអនុវត្តការកសាងផែនការ ការរៀបចំថវិកា និងប្រព័ន្ធពិនិត្យតាមដានផ្អែកលើលទ្ធផលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំនិងហិរញ្ញប្បទាន អភិវឌ្ឍសមត្ថភាពក្នុងការរៀបចំថវិកានិងការអនុវត្ត ការដេញថ្លៃ ការផ្ទេរមូលការងារថវិកាដល់សាលារៀន ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុ និងការពង្រឹងការងារសវនកម្ម។
- កម្មវិធីអក្ខរកម្មនិងរៀនពេញមួយជីវិត ការផ្តួចផ្តើមអនុវត្តកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធដើម្បីកំណត់ក្រុមយុវជននៅក្រៅសាលា និងការកំណត់យន្តការច្បាស់លាស់ ក្នុងការអនុវត្តកម្មវិធីអក្ខរកម្មនិងរៀនពេញមួយជីវិតដែលនឹងត្រូវបន្តផ្តល់និងអភិវឌ្ឍ។
- កម្មវិធីសម្របសម្រួលក្នុងវិស័យនិងអន្តរវិស័យ បង្កើតយន្តការប្រតិបត្តិដែលស្អិតល្មួតនិងរលូន សម្របសម្រួលសម្រាប់អនុវិស័យទាំងអស់។

៤.១៦៥- ដើម្បីដំណោះស្រាយបញ្ហាប្រឈមនានាក្នុងអំឡុងពេលអនុវត្ត ***ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣*** និងផ្អែកលើបទពិសោធកន្លងមក ***ក្រសួងអប់រំ យុវជន និងកីឡា*** នឹងជំរុញល្បឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងអាណត្តិនៃ **ផ.យ.អ.ជ. ២០១៤-២០១៨** ដោយផ្តោតលើ៖

- ការបង្កើនការចូលរៀនក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះនិងសហគមន៍ ជាមួយគ្នានឹងកម្មវិធីបណ្តុះបណ្តាលក្រុមម្តាយនិងគ្រូមត្តេយ្យសហគមន៍។
- ការបង្កើនការចូលរៀននៅមធ្យមសិក្សា ដោយយកចិត្តទុកដាក់លើការកាត់បន្ថយគម្លាតយេនឌ័រ និងយកចិត្តទុកដាក់ជំរុញការបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ។ ការបង្កើនចំនួនអាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេស សិស្សស្រី។ ការបង្កើនចំនួនសាលាមធ្យមសិក្សាបឋមភូមិ តាមរយៈការពង្រីកសាលាបឋមសិក្សាស្របតាមកំណើនសិស្ស។
- ការរៀបចំវិធានការដើម្បីកាត់បន្ថយចំនួនកុមារនៅក្រៅសាលា ការយកចិត្តទុកដាក់បន្ថែមលើកុមារជនជាតិដើមភាគតិច កុមារពិការ និងកុមារក្នុងគ្រួសារក្រីក្រ តាមរយៈកម្មវិធីដែលបានកំណត់។
- ការបង្កើតក្របខ័ណ្ឌការងារនៅថ្នាក់ជាតិ ដើម្បីអនុវត្តយន្តការវាយតម្លៃការសិក្សារបស់សិស្ស។ ការកំណត់និងធានាប្រសិទ្ធភាពនៃការពិនិត្យតាមដានការអនុវត្តម៉ោងសិក្សា ការពង្រឹងការធ្វើតេស្តតាមថ្នាក់រៀនជាប្រចាំ រៀបចំបញ្ចប់និងផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ទី៣ ព្រមទាំងពង្រីកទៅដល់ថ្នាក់ទី៦និងទី៨ ព្រមទាំងការត្រៀមខ្លួនចូលរួមក្នុងកម្មវិធីវាយតម្លៃថ្នាក់តំបន់និងអន្តរជាតិ។ ការលើកកម្ពស់

គុណភាពនិងភាពឆ្លើយតបរបស់កម្មវិធីសិក្សា តាមរយៈការពិនិត្យឡើងវិញកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។

- ការរៀបចំចក្ខុវិស័យសម្រាប់ឧត្តមសិក្សា និងការផ្តោតលើកម្មវិធីអាទិភាព(វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា) ស្របជាមួយស្តង់ដាធានាគុណភាពរបស់អាស៊ាន។
- ការកែលម្អប្រព័ន្ធបែងចែកនិងគ្រប់គ្រងសៀវភៅសិក្សាគោល។ ការធានាថាការផ្គត់ផ្គង់សៀវភៅសិក្សាគោល កម្មវិធីសិក្សាថ្មី និងការផ្តល់សៀវភៅគ្រូដល់គ្រូបង្រៀននៅតំបន់ជួបការលំបាក។
- ការពង្រាយគ្រូបង្រៀនដែលបានបណ្តុះបណ្តាលនិងមានគុណភាព នៅតាមវិទ្យាល័យ និងអនុវិទ្យាល័យដែលបង្កើតថ្មី ពិសេស តំបន់ជួបការលំបាក។ ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ តាមរយៈការងារវិក្រឹតការគ្រូបង្រៀន និងការបន្តអភិវឌ្ឍវិជ្ជាជីវៈនិងការដាក់ឲ្យអនុវត្តប្រព័ន្ធវាយតម្លៃគុណផល។
- ការជំរុញសកម្មភាពអប់រំកាយនិងកីឡានៅតាមសាលារៀន និងសកម្មភាពសមាគមកីឡា ក្លិបកីឡា និងការកសាងហេដ្ឋារចនាសម្ព័ន្ធ។
- ការអនុវត្តកំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការ ដើម្បីជំរុញប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅថ្នាក់ក្រោមជាតិ តាមរយៈការផ្ទេរមុខងារដែលបានកំណត់ដល់អង្គភាពក្រោមឱវាទ និងការចូលរួមក្នុងការកសាងផែនការ ការគ្រប់គ្រង ការអនុវត្ត និងការពិនិត្យតាមដាន។
- ការអភិវឌ្ឍសមត្ថភាពរបស់នាយកសាលា មន្ត្រីគ្រប់គ្រងនៅថ្នាក់មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ ការពង្រឹងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក ក្នុងការពិនិត្យតាមដាននិងគាំទ្រសាលារៀនគ្រប់កម្រិត។
- ការអភិវឌ្ឍនិងអនុវត្តគំនិតផ្តួចផ្តើមកម្មវិធីអប់រំក្រៅប្រព័ន្ធ រួមបញ្ចូលទាំងកម្មវិធីសមមូលសម្រាប់ក្រុមយុវជនក្រៅសាលានិងជនពេញវ័យ ក្នុងការទទួលបានអក្ខរកម្មនិងជំនាញបច្ចេកទេសដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គម វប្បធម៌ និងសេដ្ឋកិច្ច។

៤.១៦៦- សូចនាករ និងចំណុចដៅសំខាន់ៗដែលនឹងត្រូវធ្វើការតាមដានពិនិត្យនិងរាយការណ៍ជាប្រចាំដោយ ***ក្រសួងអប់រំ យុវជន និងកីឡា*** មានបង្ហាញជូននៅក្នុងតារាងទី៤.១១ ខាងក្រោម៖

**តារាងទី៤.១១ សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និងកីឡា**

| សូចនាករសំខាន់ៗ ក្នុងវិស័យអប់រំ | | ឯកតា | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ |
|---|---|---|---|---|---|---|---|---|
| | | | ជាក់ស្តែង | ប៉ាន់ស្មាន | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ |
| ១ | % កុមារអាយុ៥ឆ្នាំ ក្នុងការអប់រំកុមារតូច នៅគ្រប់រូបភាព | % | ៥៦,៥ | ៦២ | ៦៦ | ៧១ | ៧៥ | ៨០ |
| ២ | សាលាបឋមសិក្សា (១-៦) | ចំនួន | ៦ ៩១០ | ៦ ៩១៥ | ៦ ៩៥១ | ៧ ០៧៣ | ៧ ៣០២ | ៧ ៦០៦ |
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | | |
| ៣ | សរុប | % | ៩៧ | ៩៧,៣ | ៩៧,៩ | ៩៨,៦ | ៩៩,៣ | ១០០ |
| ៤ | ប្រុស | % | ៩៧ | ៩៧,៥ | ៩៨,១ | ៩៨,៧ | ៩៩,៤ | ១០០ |
| ៥ | ស្រី | % | ៩៧ | ៩៧,១ | ៩៧,៨ | ៩៨,៥ | ៩៩,២ | ១០០ |
| ៦ | ទីប្រជុំជន | % | ៨៩,៨ | ៩១,៨ | ៩៣,៩ | ៩៥,២ | ៩៧,៩ | ១០០ |
| ៧ | ជនបទ | % | ៩៨,៦ | ៩៨,៩ | ៩៩,២ | ៩៩,៤ | ៩៩,៧ | ១០០ |
| អត្រារួមនៃការសិក្សានៅបឋមសិក្សា | | | | | | | | |
| ៨ | សរុប | % | ១២១,១ | ១១៩,២ | ១១៧,២ | ១១៥,៨ | ១១៥,២ | ១១៥,៥ |
| ៩ | ប្រុស | % | ១២៣,១ | ១២១,៦ | ១១៨,២ | ១១៦,៤ | ១១៥,៥ | ១១៥,៤ |
| ១០ | ស្រី | % | ១១៩ | ១១៧,៧ | ១១៦,១ | ១១៥,២ | ១១៥ | ១១៥,៦ |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | | | |
| ១១ | សរុប | % | ៩១,៥ | ៩៨,៣ | ១០០ | ១០០ | ១០០ | ១០០ |
| ១២ | ប្រុស | % | ៩១,៩ | ៩៨,៧ | ១០០ | ១០០ | ១០០ | ១០០ |
| ១៣ | ស្រី | % | ៩១ | ៩៨ | ១០០ | ១០០ | ១០០ | ១០០ |
| ១៤ | ចំនួនសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ១ ៦២២ | ១ ៦៣២ | ១ ៦៤២ | ១ ៦៥២ | ១ ៦៦២ | ១ ៦៧២ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | | |
| ១៥ | សរុប | % | ៥៦,៥ | ៦០,៤ | ៦៦,៩ | ៧៣,៧ | ៨១,៣ | ៨៧,៤ |
| ១៦ | ប្រុស | % | ៥៦,២ | ៦០,៤ | ៦៧,២ | ៧៤,៤ | ៨២,២ | ៨៨,៩ |
| ១៧ | ស្រី | % | ៥៦,៧ | ៦០,៣ | ៦៦,៥ | ៧៣,១ | ៨០,៤ | ៨៥,៩ |
| ១៨ | ទីប្រជុំជន | % | ៧៨,៤ | ៨០,៧ | ៨៤,៨ | ៨៨,២ | ៩២,៣ | ៩៤,៣ |
| ១៩ | ជនបទ | % | ៥២,៦ | ៥៦,៧ | ៦៣,៦ | ៧១,២ | ៧៩,២ | ៨៦,១ |
| អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២០ | សរុប | % | ៤២,២ | ៤៤,៤ | ៥១,៦ | ៥៧,២ | ៦៧,៣ | ៧៦,៤ |
| ២១ | ប្រុស | % | ៤២ | ៤៤ | ៥១,៧ | ៥៧,៦ | ៦៧,៧ | ៧៧,២ |
| ២២ | ស្រី | % | ២៥,៥ | ២៧,៣ | ៣១,៦ | ៣៥,១ | ៤១,៦ | ៤៧ |
| ២៣ | ចំនួនសាលាមធ្យមសិក្សាទុតិយភូមិ | ចំនួន | ៤៣៣ | ៤៤៣ | ៤៥១ | ៤៩៨ | ៥៦៦ | ៦៦៨ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | | |
| ២៤ | សរុប | % | ២៩,៨ | ២៩,៤ | ៣០,៨ | ៣៣,៩ | ៣៨,៤ | ៤៥,៣ |
| ២៥ | ប្រុស | % | ៣១,៩ | ៣១,៦ | ៣៣,១ | ៣៦,១ | ៤១,១ | ៤៨,៥ |
| ២៦ | ស្រី | % | ២៧,៦ | ២៧,២ | ២៨,៤ | ៣១,៥ | ៣៥,៦ | ៤១,៩ |
| ២៧ | ចំនួនវិទ្យាល័យបច្ចេកទេស | ចំនួន | ៤ | ៤ | ៥ | ៥ | ៦ | ៧ |
| ២៨ | ចំនួនសិស្សនៅមធ្យមសិក្សាបច្ចេកទេស | ចំនួន | ៨៩៧ | ១ ៣១៧ | ១ ៧៣៨ | ២ ១៥៩ | ២ ៥៧៩ | ៣ ០០០ |
| ២៩ | អត្រាអក្ខរជនយុវជន (១៥-២៤ ឆ្នាំ) | % | ៩១,៥ | ៩២,៥ | ៩៣,៥ | ៩៤,៥ | ៩៥,៥ | ៩៦,៥ |
| ៣០ | អត្រាអក្ខរជនជនពេញវ័យ (១៥-៤៥ ឆ្នាំ) | % | n.a | ៨៧,៧ | ៨៨,៤ | ៨៩,១ | ៨៩,៨ | ៩០,៥ |

*ប្រភព: ក្រសួងអប់រំ យុវជន និងកីឡា*

## ៦.២- ការលើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១៦៧- ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញការអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម ***ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល២០០៨-២០១៥*** ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យសុខាភិបាល សំដៅលើកស្ទួយអនាម័យ សុខភាព សុខុមាលភាព និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាឲ្យកាន់តែល្អប្រសើរឡើង ពិសេស សម្រាប់ប្រជាជនក្រីក្រ ជនងាយរងគ្រោះ ស្ត្រី និងកុមារ។ រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតអាទិភាពលើ៖

- ទី១ ការរៀបចំនិងកែលម្អគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យសុខាភិបាល ការពង្រឹង និងកែលម្អក្របខ័ណ្ឌគតិយុត្ត ពិសេសសម្រាប់ការគ្រប់គ្រងសេវាសុខាភិបាលឯកជន ការលើកកម្ពស់អភិបាលកិច្ចល្អ និងការពង្រឹងសមត្ថភាពស្ថាប័នសុខាភិបាលគ្រប់លំដាប់ថ្នាក់ ការលើកកម្ពស់ការយល់ដឹងរបស់គ្រូពេទ្យ មន្ត្រី បុគ្គលិកសុខាភិបាល និងអ្នកប្រើប្រាស់សេវាអំពីសិទ្ធិរបស់អតិថិជន ការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជន

ក្នុងការផ្តល់សេវាសុខភាព ព្រមទាំងការលើកទឹកចិត្តដល់ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍវិស័យសុខាភិបាល។

ទី២ ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងការគ្រប់គ្រងវិស័យសុខាភិបាល តាមរយៈការអភិវឌ្ឍ និងការពង្រីកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សំដៅពង្រឹងប្រព័ន្ធទិន្នន័យព័ត៌មានសុខាភិបាល។

ទី៣ ការបន្តបង្កើនលទ្ធភាពទទួលបានសេវាសុខាភិបាលជូនប្រជាជន តាមរយៈការពង្រីកវិសាលភាពនៃសេវាសុខភាពសាធារណៈឲ្យកាន់តែខិតជិតប្រជាជន ដោយបន្តពង្រឹងហេដ្ឋារចនាសម្ព័ន្ធលើវិស័យនេះ ដូចជាការសាងសង់ឲ្យមានមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព ស្របតាមស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ រួមជាមួយនឹងការបំពាក់ឧបករណ៍ សម្ភារៈ បរិក្ខារពេទ្យ និងឱសថ ព្រមទាំងបុគ្គលិកសុខាភិបាលដែលមានជំនាញសមស្រប។

ទី៤ ការបន្តលើកកម្ពស់សមធម៌ក្នុងការទទួលបាននូវសេវាសុខភាព តាមរយៈការពង្រឹងកម្មវិធីមូលនិធិសមធម៌ និងការបង់តម្លៃជួលសម្រាប់ប្រជាជនក្រីក្រ និងការអភិវឌ្ឍប្រព័ន្ធធានារ៉ាប់រងសុខភាព តាមបរិការណ៍សង្គម សេដ្ឋកិច្ចកម្ពុជា ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ក៏ដូចជាការពារប្រជាជនក្រីក្រពីហានិភ័យនៃចំណាយធំហួសសមត្ថភាពលើការថែទាំសុខភាព។

ទី៥ ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល តាមរយៈពង្រឹងសមត្ថភាពបច្ចេកទេសគ្លីនិក និងសមត្ថភាពគ្រប់គ្រងរបស់គ្រូពេទ្យ បុគ្គលិកពេទ្យ និងមន្ត្រីសុខាភិបាល ដោយផ្តោតលើ (១)ការបង្កើនគុណភាពនៃការបណ្តុះបណ្តាលមូលដ្ឋាននិងការបណ្តុះបណ្តាលបន្ត (២)ការពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ និង(៣)ការបង្កើនបរិមាណការពង្រាយ និងការបែងចែកវេជ្ជបណ្ឌិត ឱសថការី ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាក និងបុគ្គលិកអមវេជ្ជសាស្ត្រទៅគ្រប់មូលដ្ឋានសុខាភិបាលសាធារណៈ ពិសេសក្នុងតំបន់ជនបទដោយផ្តោតអាទិភាពដល់សិស្ស និស្សិតមកពីជនបទក្នុងការប្រឡងចូលសិក្សានៅតាមគ្រឹះស្ថានសិក្សាផ្នែកសុខាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ភូមិ ព្រមទាំងផ្តល់ការលើកទឹកចិត្តសមស្រប រួមទាំងការផ្តល់កន្លែងស្នាក់នៅសមរម្យនៅទីជនបទ។

ទី៦ ការបន្តលើកកម្ពស់ការយល់ដឹងអំពីអនាម័យ និងការលើកស្ទួយស្ថានភាពអនាម័យក្នុងចំណោមប្រជាជន សំដៅថែទាំសុខភាព និងកាត់បន្ថយអត្រាឈឺ និងអត្រាឆ្លងជំងឺនានា។

ទី៧ ការកែលម្អឲ្យកាន់តែប្រសើរឡើងនូវសុខភាពបន្តពូជ និងសុខភាពមាតា ទារក និងកុមារ ព្រមទាំងស្ថានភាពអាហាររូបត្ថម្ភរបស់ស្ត្រីនិងកុមារ តាមរយៈការពង្រីកសេវាសុខភាពបន្តពូជ និងសេវាសុខភាពមាតា ទារក និងកុមារ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ដោយផ្តោតលើការពង្រីកវិសាលភាពគ្របដណ្តប់នៃការសម្រាលកូន

ដោយឆ្មបនិងគ្រូពេទ្យជំនាញ ការពង្រីកសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងសេវាថែទាំទារក ការពង្រីកសេវាផ្តល់មធ្យោបាយពន្យារកំណើត ការបង្កើនអត្រាគ្របដណ្តប់នៃការផ្តល់វ៉ាក់សាំងបង្ការជំងឺដល់កុមារ ពិសេស វ៉ាក់សាំងជំងឺកញ្ជ្រឹល និងជំងឺតេតាណូស ការផ្តល់មីក្រូសារជាតិ និងជីវជាតិដល់ទារកអាយុ១ ០០០ថ្ងៃដំបូង និងសេវាថែទាំព្យាបាលជំងឺកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ព្រមទាំងការផ្តល់សេវាអប់រំនិងសេវាសុខភាពបន្តពូជដល់យុវវ័យ។

ទី៨ ការបន្តកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ ដូចជាមេរោគអេដស៍និងជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម ជំងឺត្រូពិក ដែលមិនចាប់អារម្មណ៍ ព្រមទាំងជំងឺឆ្លងលេចឡើងថ្មីៗ និងជំងឺឆ្លងដែលកើតឡើងសាជាថ្មីម្តងទៀត ពិសេស គឺការខិតខំលុបបំបាត់ជំងឺគ្រុនចាញ់ឲ្យបានទាំងស្រុងនៅឆ្នាំ២០២៥។

ទី៩ ការកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់ ដែលបណ្តាលមកពីជំងឺមិនឆ្លងរ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈដែលពាក់ព័ន្ធនឹងសុវត្ថិភាពចំណីអាហារ ការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់ គ្រោះថ្នាក់ចរាចរណ៍ គ្រោះមហន្តរាយ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

ទី១០ ការពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងដៃគូពាក់ព័ន្ធផ្សេងទៀតសំដៅលើកកម្ពស់សេវាសុខភាពសាធារណៈ ពិសេស សម្រាប់កម្មវិធីសំខាន់ៗមួយចំនួន ដូចជាកម្មវិធីសុខភាពបន្តពូជ និងកម្មវិធីអាហារូបត្ថម្ភ សម្រាប់ស្ត្រីនិងកុមារជាដើម។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៦៨- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាព ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើគោលនយោបាយអាទិភាពខ្ពស់ចំនួន៤ ដូចខាងក្រោម៖

- កែលម្អឲ្យកាន់តែប្រសើរឡើងសុខភាពផ្លូវភេទ បន្តពូជ មាតា និងកុមារ និងអាហារូបត្ថម្ភ។
- កាត់បន្ថយអត្រាឈឺនិងស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ ដូចជាមេរោគអេដស៍/ជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម ជំងឺត្រូពិកដែលមិនចាប់អារម្មណ៍ និងជំងឺឆ្លងលេចឡើងថ្មីៗ និងជំងឺឆ្លងដែលកើតឡើងសាជាថ្មីម្តងទៀត។
- កាត់បន្ថយការឈឺនិងស្លាប់ដែលបណ្តាលមកពីជំងឺមិនឆ្លង រ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់ គ្រោះថ្នាក់ចរាចរណ៍ របួស សុវត្ថិភាពចំណីអាហារ គ្រោះធម្មជាតិ បរិស្ថានសុខភាព បម្រែបម្រួលអាកាសធាតុ។

- ធានាឲ្យប្រព័ន្ធសុខាភិបាលផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋគ្រប់រូបចូលមកប្រើប្រាស់សេវាថែទាំសុខភាពដែលមានគុណភាពនិងប្រកបដោយសមធម៌។

៤.១៦៩- ដើម្បីសម្រេចបាននោលនយោបាយជាអាទិភាពនីមួយៗខាងលើនេះ ***ក្រសួងសុខាភិបាល*** នឹងអនុវត្តកម្មវិធីសកម្មភាព ដូចខាងក្រោម៖

១. *ការធ្វើឲ្យប្រសើរឡើងនូវសុខភាពផ្លូវភេទ បន្តពូជ មាតា ទារក និងកុមារ និងអាហារូបត្ថម្ភ ដោយផ្តោតលើគោលនយោបាយដូចខាងក្រោម៖*

- បង្កើនលទ្ធភាពចូលមកប្រើប្រាស់និងការគ្របដណ្តប់នៃសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសម្រាប់ប្រជាពលរដ្ឋទាំងអស់ ដោយរាប់បញ្ចូលទាំងស្ត្រីវ័យក្មេង បុរសនិងមនុស្សវ័យជំទង់។
- លើកកម្ពស់គុណភាព លទ្ធភាពចូលមកប្រើប្រាស់សេវា និងការគ្របដណ្តប់នៃការថែទាំគភ៌មុនសម្រាល ការសម្រាលកូន ការថែទាំក្រោយសម្រាល ការថែទាំទារក និងការសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងសេវាថែទាំទារកទើបនឹងកើត ព្រមទាំងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។
- បង្កើនគុណភាព លទ្ធភាពចូលប្រើប្រាស់សេវា និងការគ្របដណ្តប់នៃការផ្តល់ថ្នាំបង្ការព្រមទាំងសមាហរណកម្មសេវាគ្រប់គ្រងជំងឺកុមារ ដោយរាប់បញ្ចូលទាំងជំងឺរលាកសួតនិងជំងឺរាគរូស។
- លើកកម្ពស់គុណភាព លទ្ធភាពចូលមកប្រើប្រាស់សេវា និងការគ្របដណ្តប់នៃសេវាអាហារូបត្ថម្ភដើម្បីកាត់បន្ថយកង្វះប្រូតេអ៊ីន ថាមពល និងកង្វះមីក្រូសារជាតិក្នុងចំណោមស្ត្រីនិងកុមារតូច។

៤.១៧០- អន្តរាគមន៍គន្លឹះដើម្បីកែលម្អសុខភាពផ្លូវភេទបន្តពូជ មាតា ទារក កុមារអាយុក្រោមមួយឆ្នាំ កុមារតូច និងអាហារូបត្ថម្ភ៖

### សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ

- បង្កើនតម្រូវការនិងលទ្ធភាពមកទទួលសេវាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ព័ត៌មានប្រឹក្សាយោបល់ ដោយរាប់បញ្ចូលទាំងការពន្យារកំណើត រំលូតមានសុវត្ថិភាព និងការថែទាំការរំលូតគ្រប់ជ្រុងជ្រោយ សេវាស្រឡាញ់យុវវ័យនិងជនរងគ្រោះដោយអំពើហិង្សាផ្នែកយេនឌ័រ។
- ធានាប្រព័ន្ធសន្តិសុខនៃការផ្គត់ផ្គង់ឱសថ បរិក្ខារសម្រាប់សេវាសុខភាពបន្តពូជ។

### សុខភាពមាតានិងទារក

- បង្កើនការសម្រាលកូននៅមូលដ្ឋានសុខាភិបាល ដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល។
- លើកកម្ពស់ការថែទាំមាតានិងទារក ដោយបង្កើនចំនួនសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងថែទាំទារក ដែលមានបុគ្គលិកជំនាញនិងគាំទ្រដោយប្រព័ន្ធបញ្ជូនដំណើរការ។
- ជំរុញការប្រើប្រាស់សំណុំសេវាថែទាំមុននិងក្រោយសម្រាលដែលមានទាំងការប្រឹក្សាយោបល់អំពីអាហារូបត្ថម្ភ និងលើកកម្ពស់ការផ្តល់ជីវជាតិដែកអាស៊ីតហ្វូលិក។
- ពង្រឹងប្រព័ន្ធតាមដានមរណភាពមាតា ដោយរាប់បញ្ចូលទាំងសវនកម្មមរណភាពមាតានិងទារកទើបនឹងកើត។

### ការផ្តល់ថ្នាំបង្ការនិងសុខភាពកុមារ

- លុបបំបាត់ជំងឺកញ្ជ្រឹលនិងជំងឺតេតាណូសលើទារកទើបនឹងកើត។
- រក្សាការគ្របដណ្តប់កម្រិតខ្ពស់នៃការផ្តល់វ៉ាក់សាំងបង្ការជំងឺ និងបញ្ចូលការប្រើប្រាស់វ៉ាក់សាំងថ្មីៗសម្រាប់ក្រុមប្រជាជនចំណុចពិសេសកុមារអាយុក្រោមមួយឆ្នាំ។
- ពង្រឹងប្រព័ន្ធផ្គត់ផ្គង់ ចែកចាយវ៉ាក់សាំង និងការគ្រប់គ្រងប្រព័ន្ធត្រជាក់រក្សាគុណភាពវ៉ាក់សាំង។
- បង្កើនលទ្ធភាពមកទទួលយកសេវាសុខភាពកុមារមានគុណភាព ដោយអនុវត្តពិធីសមាហរណកម្មការគ្រប់គ្រងជំងឺកុមារនិងការចម្លងមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគ ក្នុងការពិនិត្យជំងឺកុមារអាយុក្រោម៥ឆ្នាំ។

### អន្តរាគមន៍ប្រទាក់ក្រឡា

- លើកកម្ពស់គុណភាពសេវានិងព័ត៌មាន នៃសេវាសុខភាពផ្លូវភេទ សុខភាពបន្តពូជមាតាទារក អាយុក្រោម១ឆ្នាំ និងកុមារតូច និងអាហារូបត្ថម្ភ។
- ពង្រឹងការត្រួតពិនិត្យតាមដាន និងការអភិបាលគាំទ្រ ដល់សេវាសុខភាពផ្លូវភេទ សុខភាពបន្តពូជ មាតា ទារក កុមារអាយុក្រោម១ឆ្នាំ និងកុមារតូច និងសេវាអាហារូបត្ថម្ភ។
- ពង្រាយបុគ្គលិកឆ្មបឲ្យមាននៅគ្រប់មណ្ឌលសុខភាព។

២. *កាត់បន្ថយការឈឺនិងស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ ដូចជាមេរោគអេដស៍/ជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម ជំងឺត្រូពិកដែលមិនចាប់អារម្មណ៍ និងជំងឺឆ្លងលេចឡើងថ្មីៗនិងជំងឺឆ្លងដែលកើតឡើតសាជាថ្មីម្តងទៀត ដោយផ្តោតលើគោលដៅដូចខាងក្រោម៖*

- កាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ និងបង្កើនការរស់រានមានជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។

- កាត់បន្ថយអត្រាប្រេវ៉ាឡង់និងអត្រាស្លាប់នៃជំងឺរបេង រក្សាករណីស្រាវជ្រាវរកជំងឺរបេងខ្ពស់ និងរក្សាអត្រាជាសះស្បើយខ្ពស់នៃការព្យាបាលជំងឺរបេង។
- កាត់បន្ថយអត្រាស្លាប់ដោយសារជំងឺគ្រុនចាញ់និងជំងឺគ្រុនឈាម។
- កាត់បន្ថយអត្រាប្រេវ៉ាឡង់ជំងឺដង្កូវព្រូន។
- គ្រប់គ្រងស្ថានការណ៍និងត្រួតពិនិត្យជំងឺឆ្លងលេចឡើងថ្មីៗ និងជំងឺឆ្លងដែលកើតឡើងសាជាថ្មីម្តងទៀត។

៤.១៧១- អន្តរាគមន៍គន្លឹះក្នុងការប្រយុទ្ធនឹងជំងឺឆ្លង មានដូចខាងក្រោម៖

### មេរោគអេដស៍/ជំងឺអេដស៍និងជំងឺកាមរោគ

- ពង្រីកសេវាធ្វើតេស្តរកមេរោគអេដស៍មានគុណភាព ដោយរាប់បញ្ចូលទាំងការផ្តល់ប្រឹក្សានៅមូលដ្ឋានសុខាភិបាលទាំងអស់ ដោយប្រើប្រាស់ឧបករណ៍ជោះចុងម្រាមដៃរកមេរោគអេដស៍ ព្រមទាំងធានាឲ្យមានឃីតសម្រាប់ធ្វើតេស្តរកមេរោគអេដស៍។
- បង្កើនការគ្របដណ្តប់នៃសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅតាមមូលដ្ឋានសុខាភិបាល និងធានាឲ្យមានឱសថប្រឆាំងមេរោគអេដស៍ និងបរិក្ខារដទៃទៀត។
- បង្កើនថវិកាជាតិ ថវិការដៃគូអភិវឌ្ឍ សម្រាប់ទ្រទ្រង់ដល់ការផ្តល់សេវាធ្វើតេស្តរកមេរោគអេដស៍ និងឱសថប្រឆាំងមេរោគអេដស៍។
- ផ្តល់ការបណ្តុះបណ្តាល/រំក្រឹតការស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្ត(រាប់ទាំងការធ្វើតេស្តឬដោយជោះចុងម្រាមដៃ) ព្រមទាំងពង្រឹងកិច្ចប្រជុំបណ្តាញនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។
- ធ្វើអង្កេតឆ្នក់(សង់ទីណែល) ដោយរាប់បញ្ចូលទាំងអង្កេតឆ្នក់ស្តីពីមេរោគអេដស៍ និងអំពីការផ្លាស់ឥរិយាបថជីវសាស្ត្រសមាហរណកម្ម។
- រៀបចំគោលនយោបាយស្តីពីការអនុវត្តសេវាប្រឹក្សា និងធ្វើតេស្តមេរោគអេដស៍ ដើម្បីផ្តល់នូវការទទួលបានសេវាដោយងាយស្រួល និងមានសមធម៌។
- ធ្វើបច្ចុប្បន្នកម្ម អនុវត្ត និងត្រួតពិនិត្យតាមដានផែនការយុទ្ធសាស្ត្រសម្រាប់ជំងឺអេដស៍/មេរោគអេដស៍ និងការការពារ ការថែរក្សា និងការព្យាបាលជំងឺកាមរោគឆ្នាំ២០១៤-២០១៨ ដើម្បីបន្សុីជាមួយក្របខ័ណ្ឌសម្រាប់លុបបំបាត់ការឆ្លងជំងឺអេដស៍ថ្មីនៅកម្ពុជានៅឆ្នាំ២០២០។
- បញ្ចប់សេចក្តីណែនាំ សម្រាប់ការព្យាបាលដោយប្រើឱសថប្រឆាំងនឹងមេរោគអេដស៍សម្រាប់កុមារនិងមនុស្សធំ និងបន្តរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់បន្តការការពារ ការថែរក្សា និងការព្យាបាល។

- លើកកម្ពស់ការផ្តល់សេវាទាក់ទងនឹងមេរោគអេដស៍និងសុខភាពបន្តពូជ ដើម្បីធានាថាប្រជាជននិងអ្នកជំងឺអេដស៍ទទួលបានសេវាពន្យារកំណើត ការរំលូតកូន ដែលមានសុវត្ថិភាព ការថែរក្សាសុខភាពមាតា និងសេវាពាក់ព័ន្ធផ្សេងទៀត។
- ធានាទំនាក់ទំនងរវាងមេរោគអេដស៍/ជំងឺអេដស៍និងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ផ្សេងៗ ដូចជាម្ជុល ថ្នាំស្ពឹក សម្រាប់មនុស្សដែលប្រើគ្រឿងញៀននិងអាចឆ្លងមេរោគអេដស៍។

## ជំងឺរបេង

- ផ្តល់សេវាជំងឺរបេងដោយឥតបង់ថ្លៃសម្រាប់ប្រជាពលរដ្ឋទាំងអស់ ដោយរាប់បញ្ចូលទាំងការស្រាវជ្រាវ ការពិនិត្យកំហាក ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល។
- លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហាជំងឺរបេង រួមជាមួយមេរោគអេដស៍/ជំងឺអេដស៍។
- ផ្គត់ផ្គង់ឧបករណ៍ បរិក្ខារសម្រាប់ការពិនិត្យវិភាគផ្នែកមន្ទីរពិសោធន៍ ការត្រួតពិនិត្យ តាមដាន និងនីតិវិធីធានាគុណភាព/ការគ្រប់គ្រងគុណភាព។ ធានាថាអ្នកផ្តល់សេវាទទួលបានការបណ្តុះបណ្តាលនិងមានសមត្ថភាពក្នុងការពិនិត្យវិភាគ និងការត្រួតពិនិត្យតាមដានជំងឺរបេង។
- ជំរុញការចូលរួមរបស់សហគមន៍ ក្នុងការព្យាបាលជំងឺរបេងដោយវិធីសាស្ត្រដូតស៍។
- លើកកម្ពស់ភាពជាដៃគូរវាងផ្នែកសាធារណៈនិងឯកជនក្នុងការព្យាបាលដោយដូតស៍ចម្រុះ។
- លើកកម្ពស់ការតាមដាននិងការគ្រប់គ្រងជំងឺរបេងដែលស៊ាំនឹងឱសថច្រើនមុខ។
- ធានាឲ្យមានឱសថព្យាបាលជំងឺរបេងជួរទី១និងជួរទី២។

## ជំងឺគ្រុនចាញ់

- លើកកម្ពស់ការស្រាវជ្រាវរកជំងឺគ្រុនចាញ់ និងលទ្ធភាពមកទទួលយកសេវាការធ្វើរោគវិនិច្ឆ័យទាន់ពេល និងទទួលការព្យាលបាលមានប្រសិទ្ធភាព។
- លើកកម្ពស់ការមកទទួលយកសេវាព្យាបាលត្រឹមត្រូវ ដោយបង្ការការព្យាបាលដោយប្រើតែ១មុខ និងឱសថគ្មានគុណភាពក្នុងសេវាសាធារណៈនិងឯកជន។
- បង្កើនលទ្ធភាពមកទទួលបានវិធានការបង្ការ ពិសេស បង្ការការចម្លងដោយមេរោគគ្រុនចាញ់ដែលស៊ាំនឹងឱសថអាតេមីស៊ីនីន។
- បង្កើនការយល់ដឹងរបស់សហគមន៍ និងការផ្លាស់ប្តូរឥរិយាបថក្នុងចំណោមប្រជាជនប្រឈមនឹងហានិភ័យគ្រុនចាញ់ ព្រមទាំងផ្តល់ការគាំទ្រដល់ការគ្រប់គ្រងមេរោគគ្រុនចាញ់ស៊ាំនឹងឱសថអាតេមីស៊ីនីន ចលនាសហគមន៍ និងការតស៊ូមតិ។

## ជំងឺគ្រុនឈាម និងជំងឺ Helminthiasis

- ធានាការគ្របដណ្តប់ខ្ពស់នៃការដាក់ថ្នាំបាណកឃាត (អាបេត/ប៊ីធីអាយ) ទាំងនៅជុំទី១ និងជុំទី២(ក្នុងខែឧសភា និងខែសីហា) ក្នុងតំបន់មានហានិភ័យគ្រុនឈាមខ្ពស់ ព្រមទាំងធានាការផ្គត់ផ្គង់ថ្នាំបាណកឃាតគ្រប់គ្រាន់និងទាន់ពេលវេលា។
- កែលម្អសមត្ថភាពគ្លីនិកក្នុងការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺគ្រុនឈាម។
- ផ្តល់ការអប់រំសុខភាពនិងការបង្ការជំងឺគ្រុនឈាម ដោយមានការចូលរួមពីសហគមន៍ សម្រាប់ករណីផ្ទុះឡើងនៃជំងឺ និងការឆ្លើយតប។
- ផ្តល់ការព្យាបាលជំងឺ Helminthiasis ដោយឱសថផ្សះ ដល់ប្រជាពលរដ្ឋដែលប្រឈមនឹងហានិភ័យ។

### ជំងឺឆ្លងដទៃទៀត

- បង្ការនិងគ្រប់គ្រងជំងឺឆ្លងលេចឡើង និងលេចឡើងសាជាថ្មីម្តងទៀតដោយរាប់បញ្ចូលទាំងការឆ្លើយតបមានប្រសិទ្ធភាពទៅនឹងការផ្ទុះឡើងនៃជំងឺ។
- ផ្តល់ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគ្លីនិក ការតាមដានជំងឺគ្រប់គ្រងភ្នាក់ងារចម្លងជំងឺ។
- ពង្រឹងសមត្ថភាពរបស់ **"ក្រុមការងារឆ្លើយតបរហ័ស"** ក្នុងការតាមដាន និងការឆ្លើយតបតាមរយៈការបណ្តុះបណ្តាលអំពីការអនុវត្តអេពីដេមីសាស្ត្រ។
- រក្សាកិច្ចដំណើរការនៃប្រព័ន្ធប្រកាសអាសន្ន និងបណ្តាញទូរសព្ទទាន់ហេតុការណ៍ ដោយរាប់បញ្ចូលទាំងការតាមដានផ្អែកលើប្រភេទជំងឺផ្តាសាយ និងជំងឺប្រដាប់ដង្ហើមធ្ងន់ធ្ងរនៅគ្រប់ថ្នាក់។
- តាក់តែងច្បាប់ស្តីពីជំងឺឆ្លង។
- ពង្រឹងការអនុវត្តនិយ័តកម្មសុខភាពពិភពលោក។

៣. *កាត់បន្ថយការឈឺនិងស្លាប់ដែលបណ្តាលមកពីជំងឺមិនឆ្លង រ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈដែលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់ គ្រោះថ្នាក់ចរាចរណ៍ របួស សុវត្ថិភាពចំណីអាហារ គ្រោះធម្មជាតិ បរិស្ថានសុខភាព បម្រែបម្រួលអាកាសធាតុ ដោយផ្តោតលើគោលដៅដូចក្រោម៖*

- កាត់បន្ថយការប្រឈមមុខរបស់ប្រជាជននឹងកត្តាហានិភ័យនៃជំងឺមិនឆ្លង ជំងឺរ៉ាំរ៉ៃដែលកើតឡើងញឹកញាប់ដូចជាជំងឺមហារីក ជំងឺទឹកនោមផ្អែម និងជំងឺបេះដូងសរសៃឈាម។
- លើកកម្ពស់ការស្រាវជ្រាវជំងឺទាន់ពេលវេលា ផ្តល់ការបង្ការបឋម និងគ្រប់គ្រងស្ថានភាពធ្ងន់ធ្ងរនៃជំងឺ ដោយរាប់បញ្ចូលទាំងការព្យាបាល ថែទាំសម្រន់ការឈឺចាប់ និងផ្តល់សេវាស្តារនីតិសម្បទា។

- កាត់បន្ថយរបួស និងពិការភាពដែលបណ្តាលមកពីអំពើហិង្សា គ្រោះថ្នាក់ និងមូលហេតុផ្សេងៗទៀត។
- កាត់បន្ថយការប្រើប្រាស់ប្រកបដោយគ្រោះថ្នាក់និងឥទ្ធិពលរបស់គ្រឿងញៀន គ្រឿងស្រវឹង និងថ្នាំជក់ក្នុងចំណោមប្រជាជនទូទៅ។
- លើកកម្ពស់សេវាអប់រំ និងការអនុវត្តវិធានការបង្ការជំងឺសុខភាពផ្លូវចិត្តនិងជំងឺពាក់ព័ន្ធនឹងសុវត្ថិភាពផ្លូវចិត្ត ព្រមទាំងពង្រីកសេវាសុខភាពកម្រិតមូលដ្ឋាន និងកម្រិតគ្រប់ជ្រុងជ្រោយដោយរាប់បញ្ចូលទាំងសេវាបន្សាបការញៀន។
- កាត់បន្ថយភាពពិការភ្នែកនៅតាមតំបន់ភូមិសាស្ត្រ។
- លើកកម្ពស់សុខភាពមាត់ធ្មេញ អនាម័យខ្លួនប្រាណ និងសុវត្ថិភាពចំណីអាហារ។
- កាត់បន្ថយហានិភ័យសុខភាពដែលបណ្តាលមកពីបរិស្ថានកខ្វក់និងបម្រែបម្រួលអាកាសធាតុ។
- ពង្រឹងការត្រៀមបង្ការ ការគ្រប់គ្រង និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងគ្រោះមហន្តរាយ។

៤.១៧២- អន្តរាគមន៍គន្លឹះក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈ មានដូចខាងក្រោមៈ

- ផ្តល់សេវាបង្ការបឋមមានលក្ខណៈសមាហរណកម្ម សម្រាប់ជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ ដោយរាប់បញ្ចូលទាំងរបួស ពិការភាព និងសេវាថែទាំមនុស្សចាស់។
- បង្កើនលទ្ធភាពទទួលបានការស្រាវជ្រាវជំងឺ និងធ្វើរោគវិនិច្ឆ័យទាន់ពេល ពិសេសករណីជំងឺមហារីកសួន និងមហារីកសុដន់ និងផ្តល់សេវាព្យាបាល រួមមានការព្យាបាលសម្រន់ការឈឺចាប់ ការថែទាំ ការស្តារនីតិសម្បទា និងការព្យាបាលដោយចលនា។
- លើកកម្ពស់គុណភាពនៃការថែទាំ និងព្យាបាលជំងឺឆ្លង/ជំងឺរ៉ាំរ៉ៃ នៅមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន។
- ធានាការផ្គត់ផ្គង់ឱសថ បរិក្ខារ និងឧបករណ៍ពេទ្យ សម្រាប់ការផ្តល់សេវាមានគុណភាព និងប្រសិទ្ធភាព។
- បង្កើនការយល់ដឹងក្នុងចំណោមប្រជាពលរដ្ឋ អំពីកត្តាហានិភ័យនៃជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈចម្បងៗ។
- ពង្រីកការគ្រប់គ្រងជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ ក្នុងលក្ខណៈសមាហរណកម្ម នៅមូលដ្ឋានសុខាភិបាលដោយរាប់បញ្ចូលការពង្រឹងការចុះបញ្ជិកាអ្នកជំងឺមហារីក ជំងឺទឹកនោមផ្អែម ជំងឺសម្ពាធឈាមខ្ពស់ និងពិនិត្យលទ្ធភាពចុះបញ្ជិកាអ្នករបួស ព្រមទាំងបណ្តាញអ្នកអប់រំ

ផ្ទាល់សម្រាប់ការបង្ការបឋម ស្រាវជ្រាវជំងឺទាន់ពេល និងគាំទ្រការព្យាបាលថែទាំដោយខ្លួនឯងផ្ទាល់។

- បង្កើនធនធានហិរញ្ញវត្ថុសម្រាប់អន្តរាគមន៍ជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈចម្បង ក្នុងនោះមានគ្រោះថ្នាក់ចរាចរណ៍ សុខភាពបរិស្ថាន និងការត្រៀមបម្រុង និងគ្រប់គ្រងគ្រោះមហន្តរាយ។
- បញ្ចូលកម្មវិធីសិក្សាស្ដីពីការថែទាំមនុស្សចាស់ សុខភាពបរិស្ថាន និងសុខភាពវិជ្ជាជីវៈ ទៅក្នុងកម្មវិធីបណ្ដុះបណ្ដាលមូលដ្ឋាននៅគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។
- ផ្ដល់ការបណ្ដុះបណ្ដាលបន្ត ការហ្វឹកហាត់ និងពង្រឹងការត្រួតពិនិត្យតាមដានក្រោយការបណ្ដុះបណ្ដាលនៅថ្នាក់ផ្ដល់សេវា។
- ពង្រឹងប្រព័ន្ធតាមដានជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ ដោយរាប់បញ្ចូលទម្រង់របាយការណ៍ថ្មី ប្រព័ន្ធចុះបញ្ជិកា និងសូចនាករទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល ធ្វើការអង្កេតទាក់ទងនឹងកត្តាគ្រោះថ្នាក់នៃជំងឺរ៉ាំរ៉ៃ និងអភិវឌ្ឍបែបបទសម្រាប់ការគ្រប់គ្រង និងវាយតម្លៃហានិភ័យសុខភាពនិងបរិស្ថាន។
- បង្កើតបណ្ដាញការងារនិងយន្តការ ដើម្បីសម្របសម្រួលអន្តរាគមន៍ជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- ពង្រឹងនិងពង្រីកការគ្របដណ្ដប់សេវាសុខភាពផ្លូវចិត្ត និងបង្កើនគុណភាពសេវា រួមមានសេវាពិនិត្យព្យាបាល សេវាអប់រំ បង្ការ និងផ្ដល់ប្រឹក្សា ដោយរាប់បញ្ចូលទាំងសេវាបន្សាបការញៀន។
- ពង្រីកការគ្របដណ្ដប់សេវាចក្ខុរោគមានគុណភាពនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ពិសេស មន្ទីរពេទ្យបង្អែកនៅថ្នាក់ស្រុកប្រតិបត្តិ។
- អភិវឌ្ឍ/ធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមទៅវែង ដូចជាជំងឺមិនឆ្លង/រ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈ សុខភាពផ្លូវចិត្តនិងការព្យាបាលបន្សាបគ្រឿងញៀន និងការបង្ការនិងគ្រប់គ្រងភាពពិការភ្នែក។ល។
- បង្កើនលទ្ធភាពទទួលបានសេវាថែទាំមាត់ធ្មេញ ដែលមានគុណភាព និងលើកកម្ពស់ការអនុវត្តអនាម័យ និងសុវត្ថិភាពចំណីអាហារ។
- ផ្ដល់សេវាបោះបង់ចោលការជក់បារី។
- ពង្រឹងការអនុវត្តនីតិក្រម និងវិធានការត្រួតពិនិត្យនានា ទាក់ទងនឹងការគ្រប់គ្រងថ្នាំជក់ គ្រឿងស្រវឹង កំហិតការផ្សាយពាណិជ្ជកម្មនិងការយកពន្ធលើផលិតផលថ្នាំជក់និងគ្រឿងស្រវឹង អនុក្រឹត្យស្ដីពីហានិភ័យសុខភាពការងារ និងរៀបចំសារាចរស្ដីពីបរិស្ថានគ្មានផ្សែងបារី។

- ធ្វើការអង្កេត វាយតម្លៃ និងសិក្សាស្តីអំពីអន្តរាគមន៍នៃជំងឺមិនឆ្លង/រ៉ាំរ៉ៃ ការផ្លាស់ប្តូរឥរិយាបថឆ្ពោះទៅរកគ្រោះថ្នាក់ របួស និងអំពើហិង្សា ការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងសារជាតិគីមី បរិស្ថានសុខភាព និងបម្រែបម្រួលអាកាសធាតុ។
- បណ្តុះបណ្តាលគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពនិងក្រុមទ្រទ្រង់សុខភាពភូមិ។

៤. *ធានាឲ្យប្រព័ន្ធសុខាភិបាលផ្តល់លទ្ធភាពដល់ប្រជាជនគ្រប់រូប បានទទួលសេវាសុខភាពដែលមានគុណភាព និងប្រកបដោយសមធម៌ ដោយផ្តោតលើគោលដៅដូចខាងក្រោម៖*

- ពង្រីកការគ្របដណ្តប់និងកែលម្អគុណភាពឲ្យកាន់តែល្អប្រសើរឡើង ក្នុងការផ្តល់សេវាសុខភាព ដោយរាប់បញ្ចូលទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការធ្វើលទ្ធកម្ម និងការគ្រប់គ្រងបរិក្ខារប្រកបដោយប្រសិទ្ធភាព និងការបំពាក់សម្ភារៈ និងការផ្តល់ឧបករណ៍ពេទ្យ។
- ធានាដល់ការគ្របដណ្តប់ជាសកល ដោយប្រើប្រាស់ធនធានសមស្របនិងមានប្រសិទ្ធភាព ព្រមទាំងពង្រីកការគ្រប់ដណ្តប់នៃយន្តការគាំពារសុខភាពសង្គម។
- ផ្តោតលើការអភិវឌ្ឍធនធានមនុស្ស និងការគ្រប់គ្រងទៅតាមតម្រូវការនៃការផ្តល់សេវាសុខភាព និងបង្កើតបរិស្ថានគាំទ្រសម្រាប់វិជ្ជាជីវៈសុខាភិបាល។
- ធានាការមានព័ត៌មាន/ព័ត៌មានទាក់ទងសុខាភិបាលទាន់ពេលវេលា និងមានគុណភាពខ្ពស់សម្រាប់កសាងគោលនយោបាយ ការសម្រេចចិត្ត និងការអនុវត្ត ត្រួតពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលរបស់កម្មវិធី។
- ពង្រឹងអភិបាលកិច្ចល្អ ការដឹកនាំ ការគ្រប់គ្រង និងយន្តការគណនេយ្យភាព នៅក្នុងបរិបទវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងអភិវឌ្ឍន៍និងពង្រឹងការអនុវត្តច្បាប់សម្រាប់វិស័យសុខាភិបាលទាំងក្នុងផ្នែកសាធារណៈនិងឯកជន។

៤.១៧៣- អន្តរាគមន៍គន្លឹះក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល មានដូចខាងក្រោម៖

### ការផ្តល់សេវាសុខាភិបាល

- បច្ចុប្បន្នកម្មទៀងទាត់នៃផែនការគ្របដណ្តប់សុខាភិបាល(កំណត់អំពីចំនួនស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និងទីតាំងនៃមូលដ្ឋានសុខាភិបាលទាំងអស់នោះ) នៅក្នុងបរិបទវិមជ្ឈការនិងវិសហមជ្ឈការដោយពិចារណាអំពីផលចំណេញក្នុងសេដ្ឋកិច្ច។
- ពង្រីកយន្តការផ្តល់សេវាសាធារណៈដូចជាទីភ្នាក់ងារប្រតិបត្តិការពិសេស និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

- ធានាការផ្គត់ផ្គង់ឱសថ បរិក្ខារគ្រប់គ្រាន់ និងឧបករណ៍ពេទ្យជាមូលដ្ឋានព្រមទាំងមធ្យោបាយដឹកជញ្ជូន យោងតាមសេចក្តីណែនាំស្តីពីសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់។
- បង្កើនការវិនិយោគលើឧបករណ៍ពេទ្យបច្ចេកវិទ្យាខ្ពស់និងបច្ចេកវិទ្យាវេជ្ជសាស្ត្រ។
- លើកកម្ពស់សមត្ថភាព បច្ចេកទេស និងគ្រប់គ្រងនៃសេវាអមវេជ្ជសាស្ត្រ រួមទាំងសេវាមន្ទីរពិសោធន៍ និងសេវាលោហិតសាស្ត្រ។
- អភិវឌ្ឍប្រព័ន្ធទទួលស្គាល់គុណភាពសកល និងប្រតិបត្តិប្រកបដោយសង្គតិភាពនូវស្តង់ដាគុណភាពទូទាំងវិស័យសុខាភិបាល (សាធារណៈ ឯកជន និងឯកជនមិនរកកម្រៃ)។
- អនុវត្តវិធាននានា ដើម្បីគ្រប់គ្រងការឆ្លងរោគ និងកែលម្អការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រនៅតាមមូលដ្ឋានសុខាភិបាល។
- បង្កើតយន្តការលើកទឹកចិត្ត សម្រាប់ការលើកកម្ពស់គុណភាពសេវា ដូចជាការផ្តល់រង្វាន់ និងការទទួលស្គាល់ស្នាដៃ ការលើកសរសើរដល់មូលដ្ឋានសុខាភិបាល។
- លើកកម្ពស់ប្រព័ន្ធគ្រប់គ្រងអចលនទ្រព្យ រួមទាំងការថែទាំជួសជុលឧបករណ៍វេជ្ជសាស្ត្រ អគារ មធ្យោបាយដឹកជញ្ជូន និងឧបករណ៍/សម្ភារៈបរិក្ខារលើមធ្យោបាយ ព័ត៌មានទំនាក់ទំនងនិងបច្ចេកវិទ្យា។
- ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាសំណង់មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព បន្ទប់រង់ចាំការសម្រាល អគារមន្ទីរពេទ្យ ប្រព័ន្ធលូ ចរន្តអគ្គិសនី និងប្រភពទឹកស្អាត ពិសេសនៅតាមមូលដ្ឋានសុខាភិបាលក្នុងតំបន់ជនបទ។

## ហិរញ្ញប្បទានប្រព័ន្ធសុខាភិបាល

- បង្កើនថវិកាជាតិសម្រាប់វិស័យសុខាភិបាលនិងកៀរគរធនធានពីប្រភពផ្សេងៗ ដោយផ្តោតការយកចិត្តទុកដាក់លើការបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយសមធម៌ និងលើកកម្ពស់ប្រសិទ្ធភាពនៃការចំណាយ។
- តម្រង់ទិសការផ្តល់មូលនិធិរបស់ដៃគូអភិវឌ្ឍ ដើម្បីគាំទ្រដល់អន្តរាគមន៍លើអាទិភាពសុខាភិបាលជាតិ ព្រមទាំងពង្រឹងយន្តការសម្របសម្រួល ដោយរាប់បញ្ចូលទាំងជំនួយបច្ចេកទេស។
- លើកកម្ពស់ការប្រតិបត្តិថវិកានិងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ពង្រីកការគ្របដណ្តប់នៃយន្តការហិរញ្ញប្បទានសុខាភិបាលគាំពារជនក្រីក្រ ដូចជា មូលនិធិសមធម៌និងយន្តការជំនួយឧបត្ថម្ភផ្នែកសង្គមសម្រាប់ប្រជាជនក្រីក្រ បណ្ណសុខភាព ការធានារ៉ាប់រងសុខភាពសហគមន៍ ជាដើម។ ធានាការគ្របដណ្តប់សេវាសុខភាពនានាតាមរយៈហិរញ្ញប្បទានសុខភាព ជាពិសេស ផ្តោតលើសុខភាពបន្តពូជ។

- អភិវឌ្ឍ/អនុវត្តសំណុំតារាកាលិកបទដ្ឋាន និងវិធីទូទាត់តម្លៃសេវាសមស្របដល់អ្នកផ្តល់សេវាក្រោមយន្តការហិរញ្ញប្បទានគាំពារជនក្រីក្រ និងទម្រង់ហិរញ្ញប្បទានសុខាភិបាលផ្សេងៗ។
- អភិវឌ្ឍមាគ៌ាឆ្ពោះទៅកាន់ការគ្របដណ្តប់ជាសកល ដោយរាប់បញ្ចូលទាំងការបង្កើត និងកសាងសមត្ថភាពរចនាសម្ព័ន្ធស្ថាប័ន សម្រាប់ការគាំពារសុខភាពសង្គម។
- អភិវឌ្ឍគណនីសុខាភិបាលជាតិនិងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់ជ្រុងជ្រោយ សម្រាប់ការគ្រប់គ្រងនិងផ្តល់របាយការណ៍នៃគម្រោងគាំពារសុខភាពសង្គម។
- វាយតម្លៃ/វិភាគមើលផលប៉ះពាល់នៃអន្តរាគមន៍នៃគោលនយោបាយហិរញ្ញប្បទានសុខាភិបាល។

## ការអភិវឌ្ឍធនធានមនុស្ស

- វិនិយោគលើជំនាញគ្លីនិកឲ្យកាន់តែល្អប្រសើរ តាមរយៈការបណ្តុះបណ្តាលមូលដ្ឋាន (ទាំងនៅគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន) ដោយផ្តោតការយកចិត្តទុកដាក់លើការហ្វឹកហាត់ជាក់ស្តែងផ្នែកគ្លីនិក និងសុខាភិបាលសាធារណៈ។
- អភិវឌ្ឍមានលក្ខណៈជាប្រព័ន្ធសម្រាប់ការបណ្តុះបណ្តាលបន្ត ដោយរាប់បញ្ចូលទាំងការបណ្តុះបណ្តាលលើការគ្រប់គ្រង និងជំនាញជាក់លាក់។
- គាំទ្រដល់ការអភិវឌ្ឍនិងអនុវត្តប្រព័ន្ធទទួលស្គាល់គុណភាពសិក្សា ទាំងគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន។
- ពង្រឹងគុណភាពវិជ្ជាជីវៈ/ការងារ និងក្រមសីលធម៌ ដោយអភិវឌ្ឍនិងអនុវត្តប្រព័ន្ធទទួលស្គាល់គុណភាពវិជ្ជាជីវៈ និងចុះបញ្ជិកាសម្រាប់ ធនធានមនុស្សសុខាភិបាល ក្នុងផ្នែកសាធារណៈនិងឯកជន។
- បន្សុំផែនការអភិវឌ្ឍន៍ធនធានមនុស្សសុខាភិបាលនិងការគ្រប់គ្រងបុគ្គលិក ទៅតាមផែនការវិស័យសុខាភិបាលនិងផែនការគ្របដណ្តប់សុខាភិបាល។
- អភិវឌ្ឍ/អនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងធនធានមនុស្សសុខាភិបាល ក្នុងការពង្រាយបុគ្គលិកសុខាភិបាល ជាពិសេស ទៅកាន់តំបន់ដែលខ្វះបុគ្គលិកបម្រើការងារ។
- លើកកម្ពស់ការគ្រប់គ្រងការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត នៅតាមមូលដ្ឋានសុខាភិបាល ដែលមានប្រភពពីការបង់តម្លៃសេវា មូលនិធិសមធម៌ និងយន្តការហិរញ្ញប្បទានដល់ផ្នែកតម្រូវការ(អ្នកប្រើប្រាស់សេវា) ដទៃទៀត។

### ប្រព័ន្ធព័ត៌មានសុខាភិបាល

- ពិនិត្យឡើងវិញ និងពង្រឹងបញ្ញត្តិ វិធាននានា និងនីតិវិធីរដ្ឋបាល ដែលទាក់ទងនឹងទិន្នន័យសុខាភិបាល ដូចជា ការកត់ត្រា រាយការណ៍ ផ្ទុកនិងទាញយក និងចែកចាយទិន្នន័យ។
- លើកកម្ពស់ការអភិបាលប្រព័ន្ធព័ត៌មានសុខាភិបាល និងការផ្តល់ព័ត៌មានត្រឡប់ដោយផ្តោតការយកចិត្តទុកដាក់លើគុណភាពទិន្នន័យ និងស្របតាមស្តង់ដា។
- ពង្រឹងប្រព័ន្ធគ្រប់គ្រងការកត់ត្រាអំពីអ្នកជំងឺ ដោយរាប់បញ្ចូលនូវការពង្រីកការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីការវេជ្ជសាស្ត្រអ្នកជំងឺ ការរក្សាទុក ការទាញយក និងការប្រើប្រាស់ចំណាត់ថ្នាក់អន្តរជាតិនៃជំងឺ។
- ពង្រីកការចូលរួមរបស់សេវាឯកជន នៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល។
- ពង្រឹងប្រព័ន្ធតាមដានជំងឺ ការធ្វើរោគវិនិច្ឆ័យ ការកំណត់ករណីជំងឺ និងការឆ្លើយតបនឹងការផ្ទុះឡើយនៃជំងឺ។
- អភិវឌ្ឍ/ធ្វើបច្ចុប្បន្នកម្មទៀងទាត់ នូវរបៀបវារៈសម្រាប់ការសិក្សាស្រាវជ្រាវផ្នែកប្រព័ន្ធសុខាភិបាល។
- គាំទ្រការពង្រឹងប្រព័ន្ធចុះអត្រានុកូលដ្ឋាននិងស្ថិតិសំខាន់ៗ ដែលមានកត់ត្រាអំពីហេតុការណ៍សំខាន់ៗ ដូចជា កំណើត ស្លាប់ និងមូលហេតុនៃការស្លាប់។

### អភិបាលកិច្ចប្រព័ន្ធសុខាភិបាល

- ពង្រឹងយន្តការនិយ័តកម្មរបស់ស្ថាប័ន សម្រាប់ការផ្តល់អាជ្ញាបណ្ណដល់ផ្នែកឯកជន បន្តដោយការអនុវត្តប្រព័ន្ធទទួលស្គាល់គុណភាពសកលដែលជាជំហានបន្ទាប់ ក្រោយពីបានបំពេញតាមលក្ខខណ្ឌនៃការចេញអាជ្ញាបណ្ណ។
- អភិវឌ្ឍ/ធ្វើបច្ចុប្បន្នកម្មទៀងទាត់ផែនការវិស័យរយៈពេលមធ្យមទៅរយៈពេលវែង ដោយរាប់បញ្ចូលទាំងផែនការយុទ្ធសាស្ត្រសុខាភិបាល កម្មវិធីវិនិយោគសាធារណៈ ផែនការថវិកា យុទ្ធសាស្ត្រ ផែនការប្រតិបត្តិប្រចាំឆ្នាំ។ល។
- ពង្រឹងលទ្ធកម្មសាធារណៈ និងប្រព័ន្ធភស្តុភារដើម្បីធានាដល់ការផ្គត់ផ្គង់ឱសថបរិក្ខារទាន់ពេលវេលាដល់មូលដ្ឋានសុខាភិបាល។
- លើកកម្ពស់ភាពជាដៃគូរវាងផ្នែកសាធារណៈនិងឯកជន ក្នុងវិស័យសុខាភិបាល។
- ពង្រឹងប្រព័ន្ធចុះបញ្ជិកាផលិតផលឱសថ ដែលរួមមានឱសថសម័យ ឱសថបុរាណ សម្ភារៈ/ឧបករណ៍វេជ្ជសាស្ត្រ និងផលិតផលសម្អាង។
- បង្កើនសមត្ថភាពជាអ្នកដឹកនាំរបស់ក្រសួងសុខាភិបាល រួមមានសមត្ថភាពត្រួតពិនិត្យមុខងារនិយ័តកម្ម ការអភិវឌ្ឍនីតិក្រម និងគោលនយោបាយ ជាដើម ព្រមទាំងការពង្រឹង

រចនាសម្ព័ន្ធស្ថាប័ន និងមុខងារផ្តល់សេវានៅថ្នាក់ប្រតិបត្តិនៅក្នុងបរិបទវិមជ្ឈការនិងវិសហមជ្ឈការ។

- បង្កើនអភិបាលកិច្ចថ្នាក់មូលដ្ឋាន និងការត្រួតពិនិត្យរបស់សហគមន៍លើប្រសិទ្ធភាពនៃសេវា ដោយពង្រឹងគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិ ព្រមទាំងលើកការយល់ដឹងរបស់សហគមន៍ស្តីពីសិទ្ធិអតិថិជននិងសិទ្ធិ/ភារកិច្ចអ្នកផ្តល់សេវា។

៤.១៧៤- ឧបករណ៍គន្លឹះនៃការរៀបចំផែនការ ដើម្បីអនុវត្តមុខងារទាំងអស់នោះ គឺផែនការវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលផ្សារភ្ជាប់នឹងក្របខ័ណ្ឌថវិកាយុទ្ធសាស្ត្រ និងកម្មវិធីវិនិយោគសាធារណៈ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល និងការកសាងថវិកាតាមកម្មវិធី។ មានការរំពឹងទុកគ្រប់ដៃគូសុខាភិបាលទាំងអស់ នឹងប្រើប្រាស់ក្របខ័ណ្ឌនេះ(ដោយរាប់បញ្ចូលទាំងសំណុំសូចនាករដែលបានឯកភាពគ្នា) ដើម្បីពិនិត្យវឌ្ឍនភាពនៃកម្មវិធី គម្រោងក្នុងវិស័យសុខាភិបាល។ ក្រសួងសុខាភិបាល នឹងត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការ ដែលបន្តដោយការវាយតម្លៃនៅពេលបញ្ចប់វដ្តផែនការ យុទ្ធសាស្ត្រ ដើម្បីធ្វើរបាយការណ៍ស្តីពីផលប៉ះពាល់នៃការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល ក្នុងការលើកស្ទួយស្ថានភាពសុខភាពរបស់ប្រជាពលរដ្ឋ។

៤.១៧៥- សូចនាករសំខាន់ៗដែលបានជ្រើសរើស សម្រាប់កម្មវិធីនីមួយៗ ដែលក្រសួងសុខាភិបាល នឹងរាយការណ៍តាមពេលវេលា មានបង្ហាញនៅក្នុងតារាងទី៤.១២ ខាងក្រោម ។

៤.១៧៦- ***អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*** ជាស្ថាប័នជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលមានតួនាទីដឹកនាំ ចាត់ចែង និងសម្របសម្រួលការឆ្លើយតបទៅនឹងជំងឺអេដស៍នៅទូទាំងប្រទេស។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍និងជំងឺអេដស៍ លើកទី៣ ឆ្នាំ២០១១-២០១៥ និងការរៀបចំនូវផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ឆ្នាំ២០១៦-២០២០ ដើម្បីសម្រេចបានគោលដៅបីសូន្យ គឺ (១)មិនមានការចម្លងមេរោគអេដស៍ថ្មី (២)មិនមានការរើសអើងជាមួយអ្នកផ្ទុកមេរោគអេដស៍ និង (៣)មិនមានការស្លាប់ដោយសារមេរោគអេដស៍។

- ដើម្បីលុបបំបាត់ទាំងស្រុងនូវការចម្លងមេរោគអេដស៍ថ្មី ត្រូវពង្រឹងគោលនយោបាយប្រើប្រាស់ស្រោមអនាម័យ និងការផ្សព្វផ្សាយស្រោមអនាម័យ រួមជាមួយនឹងគំនិតផ្តួចផ្តើមបែបវិទ្យាសាស្ត្រថ្មី ដូចជាវិធីបង្ការមុន និងក្រោយ វិធីការពារ និងការព្យាបាលដោយប្រើឱសថប្រឆាំងនឹងមេរោគអេដស៍ ជាដើម។

- ដើម្បីសម្រេចបានទាំងស្រុងនូវការមិនរើសអើងជាមួយអ្នកផ្ទុកមេរោគអេដស៍ ត្រូវបង្កើតឲ្យមានបរិស្ថានអនុគ្រោះទូទាំងប្រទេស ជាពិសេសក្នុងចំណោមក្រុមងាយរងគ្រោះ ព្រមទាំងអ្នករស់នៅជាមួយអ្នកផ្ទុកមេរោគអេដស៍ និងត្រូវពិនិត្យ កែសម្រួលច្បាប់ស្ដីពីអេដស៍ ច្បាប់និងគោលនយោបាយដទៃទៀតដែលទាក់ទងនឹងជំងឺអេដស៍។
- ដើម្បីលុបបំបាត់ការស្លាប់ដោយសារជំងឺអេដស៍ ត្រូវពង្រីកវិសាលភាពការព្យាបាលដោយប្រើឱសថប្រឆាំងនឹងមេរោគអេដស៍ ចាប់ផ្ដើមការអនុវត្តលក្ខណវិនិច្ឆ័យថ្មីនៃការព្យាបាលដោយប្រើឱសថប្រឆាំងនឹងមេរោគអេដស៍ អាស្រ័យតាមចំនួនCD4 តិចជាង ៥០០/$mm^3$ និងលើកកម្ពស់ការរស់នៅរបស់អ្នកកើតមេរោគអេដស៍។
- ពង្រឹងនិងកែលម្អប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃជាតិ រួមទាំងអង្កេតឆ្នាក់ស្ដីពីមេរោគអេដស៍ (សង់ទីណែល) អង្កេតឥរិយាបថ ជាដើម តាមរយៈទិន្នន័យដែលមានគុណភាព និងការគ្រប់គ្រងព័ត៌មាន ការបោះពុម្ព និងការផ្សព្វផ្សាយ។

៤.១៧៧- ***អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍*** នឹងរួមចំណែកក្នុង (១)ការអនុវត្តយុទ្ធសាស្ត្រកម្មវិធី និងគម្រោងដើម្បីបន្តកាត់បន្ថយថែមទៀតនូវចំនួនករណីថ្មីនៃមេរោគអេដស៍ ដោយផ្ដោតលើការពង្រីកអន្តរាគមន៍បង្ការដែលបានកំណត់ (២)ការបង្កើនការគ្របដណ្ដប់និងគុណភាពនៃការថែទាំ ការព្យាបាល និងការគាំទ្រដល់ប្រជាជនដែលមានផ្ទុកមេរោគអេដស៍ និង (៣)ការកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ច និងធនធានមនុស្សបណ្ដាលមកពីជំងឺអេដស៍ទៅលើបុគ្គល គ្រួសារ សហគមន៍ និងសង្គម។ គម្រោងនិងកម្មវិធីទាំងនោះ នឹងតម្រង់ទិសដៅទៅលើះ

- ការបង្កើនការគ្របដណ្ដប់នៃអន្តរាគមន៍បង្ការ ដែលមានប្រសិទ្ធភាព និងការរៀបចំឲ្យមាននូវអន្តរាគមន៍ថ្មីៗបន្ថែមទៀត។
- ការបង្កើនការគ្របដណ្ដប់នៃអន្តរាគមន៍ដែលមានប្រសិទ្ធភាពសម្រាប់ការថែទាំព្យាបាល និងការគាំទ្រ និងការរៀបចំឲ្យមាននូវអន្តរាគមន៍ថ្មីៗបន្ថែមទៀត។
- ការបង្កើនការគ្របដណ្ដប់នៃអន្តរាគមន៍ដែលមានប្រសិទ្ធភាព សម្រាប់ការកាត់បន្ថយផលប៉ះពាល់ និងការរៀបចំឲ្យមាននូវអន្តរាគមន៍ថ្មីៗបន្ថែមទៀត។
- ការពង្រឹងភាពដឹកនាំរបស់ស្ថាប័នរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ការអនុវត្តនូវការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ការធានាឲ្យមានបរិស្ថានគតិយុត្តនិងគោលនយោបាយសាធារណៈមួយដែលគាំទ្រដល់ការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងកម្រិតជាតិ។
- ការបង្កើនប្រភពព័ត៌មានសម្រាប់អ្នករៀបចំគោលនយោបាយនិងអ្នកធ្វើផែនការសម្រាប់កម្មវិធី តាមរយៈការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការសិក្សាស្រាវជ្រាវ។

- ការបង្កើននិងការធ្វើឲ្យមានចីរភាពនិងប្រសិទ្ធភាពក្នុងការកៀរគរ និងការវិភាជធនធានសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ នៅកម្រិតជាតិនិងក្រោមជាតិ។

## តារាងទី៤.១២ សូចនាករសំខាន់ៗនិងចំណុចដៅរបស់វិស័យសុខាភិបាល

| សូចនាករស្នូល | ទិន្នន័យដើមគ្រា | គោលដៅចំណុច | | | | |
|---|---|---|---|---|---|---|
| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
| **១. កម្មវិធីសុខភាពផ្លូវភេទ សុខភាពបន្តពូជ មាតា ទារក និងកុមារ និង អាហារូបត្ថម្ភ** | | | | | | |
| ១. អត្រាមរណភាពមាតា (១០០ ០០០ទារកកើតរស់) | ២០៦ | | ១៤០ | | | ១៣០ |
| ២. អត្រាមរណភាពទារក (១០០០ទារកកើតរស់) | ២៧ | | ២២ | | | ២០ |
| ៣. អត្រាមរណភាពកុមារក្រោម១ឆ្នាំ (១ ០០០ទារកកើតរស់) | ៤៥ | | ៣៥ | | | ៣២ |
| ៤. អត្រាមរណភាពកុមារក្រោម៥ឆ្នាំ (១ ០០០ទារកកើតរស់) | ៥៤ | | ៤៥ | | | ៤២ |
| ៥. %នៃស្ត្រីមិនចង់មានគភ៌ ដែលពុំបានទទួលសេវាពន្យារកំណើត | ១៦,៦ | | ១០ | | | ៨ |
| ៦. អត្រារំលូតកូន/ការរំលូតកូនផ្ទួនៗ | ៥[២៦] | | ៥[២២] | | | ៥[២០] |
| ៧. អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | ៣៤ | ៣៧ | ៤០ | ៤២ | ៤៤ | ៤៦ |
| ៨. %ស្ត្រីមានគភ៌ទទួលការពិនិត្យផ្ទៃពោះយ៉ាងតិច២លើក ដោយបុគ្គលិកសុខាភិបាល | ៨១,២ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ |
| ៩. %ស្ត្រីមានគភ៌ទទួលការពិនិត្យផ្ទៃពោះលើកដំបូង ដោយបុគ្គលិកសុខាភិបាល | ៨៧ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ |
| ១០. %ស្ត្រីមានគភ៌ទទួលការពិនិត្យផ្ទៃពោះលើកទី៤ ដោយបុគ្គលិកសុខាភិបាល | ៦១ | ៦៣ | ៦៤ | ៦៥ | ៦៨ | ៧០ |
| ១១. %ស្ត្រីមានគភ៌បានទទួលជីវជាតិដែក ហ្វូលិក អាស៊ីត ៩០គ្រាប់ | ៨៤ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ |
| ១២. %នៃស្ត្រីមានគភ៌ផ្ទុកមេរោគអេដស៍ ដែលបានទទួលថ្នាំប្រឆាំងជំងឺអេដស៍សម្រាប់បង្ការ ការចម្លងពីម្តាយទៅទារក | ៧៨ | ៨០ | ៨២ | ៨៤ | ៨៦ | ៨៨ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៣. %នៃការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន | ៨០ | ៨៣ | ៨៥ | ៨៧ | ៨៩ | ៩១ |
| ១៤. %នៃការសម្រាលដោយវះកាត់ | ៣,២ | ៣,៥ | ៤ | ៤,២ | ៤,៤ | ៤,៦ |
| ១៥. %នៃមាតាដែលបានចាប់ផ្តើមបំបៅដោះទារកក្រោយសម្រាលដល់៦ខែ | ៧៤ | ៧៥ | ៧៦ | ៧៧ | ៧៨ | ៧៩ |
| ១៦. %នៃកុមារក្រោម១ឆ្នាំបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល | ៩០,១ | ៩៥ | ៩៥ | ៩៥ | ៩៥ | ៩៥ |
| ១៧. %នៃកុមារក្រោម៥ឆ្នាំមានជំងឺរលាកសួតបានទទួលការព្យាបាលដោយថ្នាំផ្សះត្រឹមត្រូវនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ | ៦៥ | ៦៦ | ៦៧ | ៦៨ | ៦៩ | ៧០ |
| ១៨. %នៃកុមារក្រោម៥ឆ្នាំមានជំងឺរាគរូសបានទទួលការព្យាបាលដោយ ORS + Zinc តាមមូលដ្ឋានសុខាភិបាលសាធារណៈ | ៩៥ | ៩៦ | ៩៧ | ៩៨ | ៩៨ | ១០០ |
| ១៩. %នៃកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាវដែលមានផលវិបាកបានទទួលការព្យាបាល | ២៥ | ៣៥ | ៥០ | ៦៥ | ៨០ | ៩០ |
| **២ ជម្ងឺឆ្លង** | | | | | | |
| ២០. ប្រេវ៉ាឡង់ជំងឺអេដស៍ | 0.៧ | | | | | < 0.9 |
| ២១. %នៃអ្នកផ្ទុកមេរោគអេដស៍ដែលប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ នៅរស់ក្រោយការព្យាបាលរយៈពេល១២ខែ | ៩០ | ៩០ | ៩០ | ៩០ | ៩០ | ៩០ |
| ២២. ប្រេវ៉ាឡង់នៃជំងឺរបេងគ្រប់សណ្ឋានលើប្រជាជន ១០០ ០០០នាក់ | ៧២៥ | ៦៩៤ | ៦៥៣ | ៦១២ | ៥៧១ | ៥៣០ |
| ២៣. អត្រាស្លាប់ជំងឺរបេង (ក្នុងចំណោមប្រជាជន ១០០ ០០០នាក់) | ៦៣ | ៦០ | ៥៧ | ៥៤ | ៥១ | ៤៨ |
| ២៤. អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង | ៩១ | ៩១ | ៩១ | ៩១ | ៩១ | ៩១ |
| ២៥. អត្រាស្លាប់នៃជំងឺគ្រុនចាញ់រាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈលើប្រជាជន ១០០ ០០០នាក់ | ០,០៨ | ០,០៨ | ០,០៨ | ០,០៨ | ០,០៨ | ០,០៨ |

| | | | | | | |
|---|---|---|---|---|---|---|
| ២៦. ចំនួនករណីគ្រុនចាញ់ ព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងចំណោមប្រជាជន១ ០០០នាក់ (អាំងស៊ីដង់) | ១,៥ | ២,៩ | ២ | ១,៨៥ | ១,៦៥ | ១,៤៥ |
| ២៧. អត្រាស្លាប់ដោយជំងឺគ្រុនឈាម បានរាយការណ៍ដោយសុខាភិបាលសាធារណៈ ក្នុងអ្នកជំងឺ១០០នាក់ | ០,៣ | ០,៧ | ០,៥ | ០,៥ | ០,៥ | ០,៣ |
| **៣ ជំងឺមិនឆ្លង** | | | | | | |
| ២៨. ប្រេវ៉ាឡង់ជំងឺលើសឈាម ក្នុងចំណោម អាយុ២៥ ទៅ៦៤ឆ្នាំ | ១១,២ | ១១,២ | | | | |
| ២៩. ប្រេវ៉ាឡង់ជំងឺទឹកនោមផ្អែម ក្នុងចំណោម អាយុ២៥ ទៅ៦៤ឆ្នាំ | ២,៩ | ២,៩ | | | | |
| ៣០. ចំនួន និង% ស្ត្រី អាយុ៣០ ទៅ ៤៩ឆ្នាំ បានទទួលតេស្តរកមហារីកមាត់ស្បូនយ៉ាងតិចមួយដង | | ៣៨ ៦០០ | ៤២ ២៦០ | ៤៦ ៧១០ | ៥១ ៣៨០ | ៥៦ ៥២០ |
| ៣១. ចំនួនករណីជំងឺមហារីកមាត់ស្បូនធ្វើរោគវិនិច្ឆ័យថ្មីក្នុងចំណោមស្ត្រីអាយុ២៥ឆ្នាំ ចំនួន១០០ ០០០ នាក់ | | ៣០,៦ | ៣១,២ | ៣១,៨ | ៣២,៥ | ៣៣,១ |
| ៣២. អត្រាប្រេវ៉ាឡង់នៃភាពពិការភ្នែក | ០,៣៨ | ០,៣៥ | ០,៣២ | ០,២៩ | ០,២៧ | ០,២៥ |
| ៣៣. អត្រាវះកាត់ជំងឺភ្នែកឡើងបាយ ក្នុងចំណោមប្រជាជន១០០ ០០០នាក់ | ១ ២០០ | ១ ៣០០ | ១ ៥០០ | ១ ៧០០ | ១ ៩០០ | ២ ០០០ |
| ៣៤. អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ក្នុងចំណោមបុរស និងស្ត្រី | ប: ៤២<br>ស: ១៧ | ប: ៤១<br>ស: ១៦ | ប: ៤០<br>ស: ១៥ | ប: ៣៩<br>ស: ១៤ | ប: ៣៨<br>ស: ១៣ | ប: ៣៧<br>ស: ១២ |
| ៣៥. អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ជាតិអាល់កុលក្នុងចំណោមបុរស និងស្ត្រី | ៥៣ | ៥២ | ៥២ | ៥១ | ៥០ | ៤៩ |
| ៣៦. ចំនួនករណីមនុស្សពេញវ័យមានជំងឺផ្លូវចិត្ត បានទទួលការព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈក្នុងចំណោមប្រជាជន១០ ០០០នាក់ | ២៥ | ៣០ | ៣៥ | ៤០ | ៤៥ | ៥០ |
| ៣៧. អត្រានៃអ្នកញៀនសារជាតិ Opioid បានទទួលការព្យាបាលបន្សាប | ៣០ | ៥០ | ៦០ | >៦០ | >៦០ | >៦០ |
| ៣៨. អត្រាស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | <១១,៦០ | <១១,៦០ | <១១,៦០ | <១១,៦០ | <១១,៦០ | <១១,៦០ |

| | | | | | | |
|---|---|---|---|---|---|---|
| (ប្រជាជន ១០០ ០០០នាក់) | | | | | | |
| **៤ ពង្រឹងប្រព័ន្ធសុខាភិបាល** | | | | | | |
| ៣៩. អត្រាមណ្ឌលសុខាភាព ដែលដាច់ស្តុកឱសថសារវន្ត ១៤មុខ | < ៥ | < ៥ | < ៥ | < ៥ | < ៥ | < ៥ |
| ៤០. អត្រានៃការផ្តល់ឈាមដោយអ្នកស្ម័គ្រចិត្តមិនទទួលផលកម្រៃ | ៥០ | ៥៥ | ៦០ | ៦៥ | ៧០ | ៧៥ |
| ៤១. ការពិគ្រោះជំងឺ (ករណីថ្មី) លើប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ០,៦១ | ០,៦៥ | ០,៧០ | ០,៧៥ | ០,៨០ | ០,៨៥ |
| ៤២. សន្ទស្សន៍នៃភាពពេញចិត្តរបស់អតិថិជនចំពោះសេវាសុខាភិបាល | ៨៦ | ៨៧ | ៨៧ | ៨៨ | ៨៨ | ៨៩ |
| ៤៣. អត្រានៃប្រជាជនរស់ក្រោមបន្ទាត់នៃភាពក្រីក្រត្រូវបានការពារដោយមូលនិធិសមធម៌ | ៨០ | ៩០ | ១០០ | ១០០ | ១០០ | ១០០ |
| ៤៤. អត្រាអាំងស៊ីដង់នៃគ្រោះមហន្តរាយដោយការចំណាយលើសុខភាព* | | | | | | |
| ៤៥. អត្រានៃមណ្ឌលសុខភាព ដែលឆ្មបមធ្យមយ៉ាងតិចមួយនាក់ | ៧៥ | ៨៥ | ១០០ | ១០០ | ១០០ | ១០០ |
| ៤៦. សន្ទស្សន៍នៃគុណភាពព័ត៌មានសុខាភិបាល | ៨៧ | ៩០ | ៩៣ | ៩៦ | ៩៨ | ១០០ |
| ៤៧. អត្រានៃគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដែលដំណើរការ | ៨០ | > ៨៥ | > ៨៥ | > ៨៥ | > ៨៥ | > ៨៥ |

(*) ចំណុចដៅនឹងកំណត់នៅពេលក្រោយ

*ប្រភពៈ ក្រសួងសុខាភិបាល*

## សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

៤.១៧៨- បច្ចុប្បន្ននេះ ***ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ*** បាននិងកំពុងរៀបចំ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** (២០១៤-២០១៨) ដែលតម្រូវឲ្យមានវិស័យអាទិភាពដូចខាងក្រោម ដើម្បីលើកកម្ពស់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភៈ

- បង្កើនភាពមានស្បៀងនិងលទ្ធភាពទទួលបានស្បៀងចម្រុះ(តាមរយៈផលិតកម្មស្បៀងតាមគ្រួសារ) និងលើកកម្ពស់ការយល់ដឹងរបស់សហគមន៍អំពីតម្លៃផ្នែកអាហារូបត្ថម្ភនៃផលិតផលស្បៀងក្នុងមូលដ្ឋាន។
- ធ្វើឲ្យប្រសើរឡើងនូវអាហារូបត្ថម្ភរបស់មាតា និងកុមារតាមរយៈការបង្កើនការថែទាំស្ត្រី និងកុមារក្នុងរយៈពេល១ ០០០ថ្ងៃដំបូងនៃជីវិត តាមរយៈការពង្រីកយន្តការផ្តល់សេវាកែលម្អគុណភាពនៃការអប់រំ និងការពិគ្រោះផ្នែកអាហារូបត្ថម្ភ ដោយប្រើប្រាប់ប្រព័ន្ធ

សុខាភិបាល និងយុទ្ធនាការតាមប្រព័ន្ធឃោសនាផ្សព្វផ្សាយ និងតាមរយៈកម្មវិធីនៅសហគមន៍ ។

- ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារមូលដ្ឋាន និងកំណត់ជាផ្លូវច្បាប់ឲ្យបញ្ចូលជាតិដែកទៅក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ ដើម្បីកាត់បន្ថយកម្រិតខ្ពស់នៃភាពស្លេកស្លាំងរបស់មាតានិងកុមារ ។
- ផ្តល់លទ្ធភាពឲ្យប្រជាពលរដ្ឋក្រីក្រទទួលបានស្បៀងគ្រប់គ្រាន់ រួមទាំងប្រជាជនដែលរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ និងលើកកម្ពស់សេវាអប់រំផ្នែកអាហារូបត្ថម្ភតាមរយៈកម្មវិធីគាំពារសង្គម។
- លើកកម្ពស់លទ្ធភាពក្នុងការទទួលបានទឹកស្អាតនិងអនាម័យ និងបង្កើនចំណេះដឹងអំពីសារៈសំខាន់នៃអនាម័យល្អ។
- ធ្វើប្រពលវប្បកម្មនិងធ្វើពិពិធកម្មប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូច ព្រមទាំងធ្វើឲ្យប្រសើរឡើងនូវការភ្ជាប់ទំនាក់ទំនងទីផ្សារ។
- លើកកម្ពស់និរន្តរភាពនិងធានានូវការទទួលបានដីធ្លីសម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។
- ធ្វើឲ្យប្រសើរឡើងនូវការទទួលបាន និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជលផលនិងព្រៃឈើដែលជាទ្រព្យសម្បត្តិរួម។
- លើកកម្ពស់ការងារនិងកាលានុវត្តភាពប្រាក់ចំណូលសម្រាប់ជនក្រីក្រ ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង និងកំណត់គោលដៅប្រជាជនដែលងាយរងគ្រោះ។
- កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនដែលប្រឈមនឹងបញ្ហាអសន្តិសុខស្បៀង និងការពារពួកគេទប់ទល់នឹងហានិភ័យដោយការធ្វើឲ្យប្រសើរឡើងនូវការត្រៀមលក្ខណៈទប់ទល់និងកាត់បន្ថយគ្រោះមហន្តរាយ ព្រមទាំងលើកកម្ពស់ភាពធន់របស់គ្រួសារទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។
- បញ្ជ្រាបលទ្ធភាពទទួលបានស្បៀងទៅក្នុងសន្តិសុខស្បៀង និងធ្វើឲ្យប្រសើរឡើងនូវអាហារូបត្ថម្ភ គឺជាកម្មវត្ថុមួយសម្រាប់យុទ្ធសាស្ត្រជាតិគាំពារសង្គម។

៤.១៧៩- ដើម្បីអនុវត្តវិស័យជាអាទិភាពខាងលើប្រកបដោយប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវកែលម្អបរិស្ថានគោលនយោបាយ និងស្ថាប័នសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដូចខាងក្រោមៈ

- រៀបចំកសាងផែនការសកម្មភាព និងផែនការវិនិយោគអាហារូបត្ថម្ភ ដើម្បីកែលម្អអាហារូបត្ថម្ភរបស់មាតានិងកុមារ។
- បង្កើតនិងបញ្ចូលកម្មវិធីអាហារូបត្ថម្ភមួយ ដែលមានការចូលរួមពីសហគមន៍ទៅគ្រប់វិស័យនិងអនុវត្តកម្មវិធីនេះនៅថ្នាក់ក្រោមជាតិ។

- បង្កើនអន្តរាគមន៍រួមគ្នាដែលជាការលើកកម្ពស់ការប្រើប្រាស់សេវាអាហារូបត្ថម្ភ ដ៏ល្អប្រសើរជាក់លាក់ ដែលទីបំផុតនាំឲ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភរបស់មាតានិងកុមារ។
- អនុវត្តគោលនយោបាយនិងអនុក្រឹត្យនានា ដើម្បីធានាបាននូវភាពល្អប្រសើរនៃស្ថានភាពអាហារូបត្ថម្ភ។
- ផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិតឲ្យមានភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន ដើម្បីគាំទ្រដល់រដ្ឋាភិបាល លើសេវាអាហារូបត្ថម្ភ “ជាក់លាក់”។
- រៀបចំនិងកែលម្អគោលនយោបាយ គោលការណ៍ណែនាំ ដើម្បីបង្កើនប្រសិទ្ធភាពអន្តរាគមន៍អាហារូបត្ថម្ភជាក់លាក់និងសេវាអាហារូបត្ថម្ភ។
- គាំទ្រការស្រាវជ្រាវដើម្បីបង្កើនភស្តុតាងសម្រាប់បង្កើតគោលនយោបាយ( មីក្រូសារជាតិ ភាពធាត់ ទិន្នន័យតាឡាសមី ផលប៉ះពាល់នៃដំណោះស្រាយថ្មីៗ តាមរយៈភាពជាដៃគូរវាងវិស័យឯកជននិងវិស័យសាធារណៈ ) ។
- គាំទ្រដល់កិច្ចសហការរួមគ្នាដើម្បីបញ្ចូលបញ្ហាអាហារូបត្ថម្ភទៅក្នុងកម្មវិធីទឹកស្អាតនិងអនាម័យ ការអប់រំដំបូងរបស់កុមារនិងនៅកន្លែងការងាររបស់មាតា។
- ពង្រឹងសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន លើបញ្ហាអាហារូបត្ថម្ភដើម្បីផ្តល់សេវាអាហារូបត្ថម្ភមូលដ្ឋានជាក់លាក់។
- ពង្រឹងតួនាទីរបស់***ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទ*** ក្នុងនាមជាស្ថាប័នផ្តល់សេចក្តីណែនាំគោលនយោបាយ និងលើកកម្ពស់ការសម្របសម្រួល និងសមាហរណកម្មការងារដែលទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ក្នុងចំណោមស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា។
- ពង្រឹងក្រុមការងារបច្ចេកទេសគាំពារសង្គមនិងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីសម្របសម្រួលគម្រោងនិងកម្មវិធីឲ្យមានប្រសិទ្ធភាព ដោយផ្អែកលើអាទិភាពដែលត្រូវបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងលើកកម្ពស់ការធ្វើសុខដុមនីយកម្ម និងការសម្របសម្រួលកិច្ចគាំទ្ររបស់ដៃគូអភិវឌ្ឍសម្រាប់បញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា។
- ធានាឲ្យមានការសម្របសម្រួលកម្មវិធីសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រកបដោយប្រសិទ្ធភាព រវាងនាយកដ្ឋានរបស់ក្រសួងនានា អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងវិស័យឯកជន នៅកម្រិតថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។
- កែសម្រួល និងធ្វើការច្របាច់បញ្ចូលគ្នានូវក្របខ័ណ្ឌសូចនាករសម្រាប់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភដោយផ្អែកលើកម្រងសូចនាករមួយ និងគោលដៅជាក់ស្តែង ដែលស្របទៅនឹងរាល់យុទ្ធសាស្ត្រនិងផែនការតាមវិស័យពាក់ព័ន្ធដែលមានស្រាប់។

- បង្កើតនីតិវិធីត្រួតពិនិត្យនិងវាយតម្លៃ និងយន្តការផ្តល់របាយការណ៍សមស្រប ដើម្បីធានាឲ្យការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រកបដោយប្រសិទ្ធភាព និងដើម្បីផ្តល់មតិយោបល់ត្រឡប់ផ្អែកលើភស្តុតាង ក្នុងគោលបំណងអភិវឌ្ឍន៍កម្មវិធី និងអន្តរាគមន៍បន្ថែមទៀត។
- ពង្រឹងសមាហរណកម្មនិងការធ្វើសុខដុមនីយកម្មនៃការគ្រប់គ្រងចំណេះដឹង និងព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា ដើម្បីបង្ហាញអំពីព័ត៌មានសន្តិសុខស្បៀងនិងអាហារូបត្ថម្ភជូនដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត។
- បន្តប្រតិបត្តិការរបស់ក្រុមការងារគ្រប់គ្រងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងក្រុមវិភាគទិន្នន័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងពង្រឹងសមត្ថភាពក្នុងការវិភាគទិន្នន័យដែលទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងផ្តល់នូវធនធានដែលអាចព្យាករទុកជាមុនបានសម្រាប់ភារកិច្ចនេះ។
- ធានាការធ្វើសមាហរណកម្មនិងប្រតិបត្តិការនៃវេបសាយប្រព័ន្ធព័ត៌មានគាំពារសង្គម និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ក្រុមប្រឹក្សាអភិវឌ្ឍវិស័យកសិកម្មនិងជនបទ និងកែលម្អមាតិការបស់ខ្លួនជាទៀងទាត់។
- លើកកម្ពស់ការប្រើប្រាស់ផលិតផលព័ត៌មានសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សម្រាប់រៀបចំផែនការ និងធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- កែសម្រួលឡើងវិញនូវកម្មវិធីបណ្តុះបណ្តាលអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយផ្អែកលើការប៉ាន់ប្រមាណទៅលើផលប៉ះពាល់ និងការពង្រីកការបណ្តុះបណ្តាលនៅកម្រិតថ្នាក់ក្រោមជាតិ តាមរយៈប្រព័ន្ធបណ្តុះបណ្តាលបន្ត។
- អភិវឌ្ឍនិងអនុវត្តផែនការអភិវឌ្ឍន៍ធនធានមនុស្ស ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីលើកកម្ពស់សមត្ថភាពជារួមសម្រាប់ការងារសម្របសម្រួលលើបញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការឃ្លាំមើលគោលនយោបាយនៅកម្រិតថ្នាក់ជាតិ។

៤.១៨០- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ***ក្រសួងសុខាភិបាល*** នឹង៖

- លើកកម្ពស់ការអនុវត្តវិធានចិញ្ចឹមទារកនិងកុមារតូច ជាពិសេស ការបំបៅកូនដោយទឹកដោះម្តាយនិងការផ្តល់អាហារបន្ថែម។
- បង្កើនការគ្របដណ្តប់នៃការផ្តល់បន្ថែមជីវជាតិអានិងថ្នាំទម្លាក់ព្រូន ដោយផ្តោតការយកចិត្តទុកដាក់នៅតំបន់ដែលលំបាកទៅដល់។

- បង្កើនការគ្របដណ្តប់នៃការផ្តល់បន្ថែមអាហារមានផ្ទុកពហុមីក្រូសារជាតិចិញ្ចឹម (ម្សៅពហុមីក្រូសារជាតិសម្រាប់កុមារ អាហារបំប៉ន ទឹកត្រី ទឹកស៊ីអ៊ីវ មានលាយសារជាតិដែក និងអំបិលអ៊ីយ៉ូត)។
- ពង្រឹងការផ្តល់សេវាសមាហរណកម្មតាមមូលដ្ឋាននិងតាមសហគមន៍ ដោយរាប់បញ្ចូលទាំងការពិនិត្យតាមដានការលូតលាស់របស់កុមារនិងផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ។
- ពង្រឹងសេវាគ្រប់គ្រងបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរដែលមានផលវិបាកនៅតាមមន្ទីរពេទ្យ។
- ពង្រឹងការអនុវត្តវិធានច្បាប់ទាក់ទងនឹងអាហារូបត្ថម្ភ ដូចជាកំហិតការផ្សាយពាណិជ្ជកម្ម និងការជំរុញការប្រើប្រាស់ផលិតផលទឹកដោះគោ។

៤.១៨១- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ***ក្រសួងផែនការ*** នឹងលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ តាមរយៈការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ តាមរយៈសកម្មភាពដូចខាងក្រោម៖

- បង្កើតឲ្យមានគោលនយោបាយជាតិ គោលការណ៍ណែនាំបច្ចេកទេស លិខិតបទដ្ឋានគតិយុត្ត ច្បាប់ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារឲ្យបានទូលំទូលាយ និងជំរុញការអនុវត្តខ្លឹមសារច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ដែលមានស្រាប់ឲ្យមានប្រសិទ្ធភាព។
- ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារផ្សេងៗទៀតដែលសមស្រប និងធានាបាននូវគុណភាពសុវត្ថិភាពនិងបរិមាណគ្រប់គ្រាន់តាមតម្រូវការ។
- ជំរុញការដាក់បញ្ចូលកម្រិតឬបរិមាណមីក្រូសារជាតិនីមួយៗទៅក្នុងបញ្ជីស្តង់ដាជាតិ។
- តម្រូវការចាំបាច់នូវការវិភាគទិន្នន័យស្តីពីការបរិភោគចំណីអាហារតាមប្រភេទនីមួយៗ។
- ជំរុញឲ្យមានការផ្សព្វផ្សាយពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិឲ្យបានទូលំទូលាយ។

## ៦.៣- ការអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពសង្គម

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១៨២- រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តពង្រឹងប្រព័ន្ធគាំពារសង្គមឲ្យកាន់តែមានភាពប្រទាក់ក្រឡា ជាប្រព័ន្ធប្រមូលផ្តុំ មានសង្គតិភាព និងប្រសិទ្ធភាព គ្របដណ្តប់ទាំងវិស័យសាធារណៈទាំងវិស័យឯកជន ដែលមានការបែងចែកតួនាទីច្បាស់លាស់រវាងនិងក្នុងកម្រិតនីមួយៗ ពោលគឺកម្រិតគោលនយោបាយ កម្រិតបញ្ញត្តិករ និងកម្រិតប្រតិបត្តិករ។ រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់អាទិភាពលើ៖

ទី១ ការកែលម្អក្របខ័ណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រវិស័យគាំពារសង្គម ក្នុងនោះ រួមមានការធ្វើបច្ចុប្បន្នកម្ម ***យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ២០១១-២០១៥*** និងឯកសារពាក់ព័ន្ធផ្សេងទៀត ដូចជា ***យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០*** ឲ្យមានសង្គតិភាពជាមួយគ្នា និងឆ្លើយតបទៅនឹងគោលដៅខាងលើ។

ទី២ ការបន្តជំរុញអនុវត្ត និងរៀបចំយន្តការសម្របសម្រួលស្ថាប័ន ក៏ដូចជាការធ្វើសុខដុមនីយកម្មលើអន្តរាគមន៍ ដែលមានសម្រាប់ និងការរៀបចំសិក្សា និងវិភាគអំពីមុខសញ្ញាត្រូវគាំពារ ឧបករណ៍សម្រាប់គាំពារនិងយន្តការសម្រាប់អនុវត្តសំដៅបង្កើនប្រសិទ្ធភាព និងបំពេញចន្លោះប្រហោងនៃកិច្ចគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ហើយឈានទៅរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយមួយ តាមរយៈ ការជំរុញអនុម័ត ***ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាជនកម្ពុជា*** ។

ទី៣ ការបន្តពង្រឹងការអនុវត្តគោលនយោបាយជាតិចំពោះអតីតយុទ្ធជន និងគោលនយោបាយជាតិចំពោះអតីតមន្ត្រីរាជការស៊ីវិលឲ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការបន្តពង្រឹងសេវាបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងបេឡាជាតិសម្រាប់អតីតយុទ្ធជន។

ទី៤ ការបន្តអនុវត្តគោលនយោបាយជាតិចំពោះជនពិការ តាមរយៈ ***ក្រុមប្រឹក្សាសកម្មភាពជនពិការ*** ការពង្រឹងការអនុវត្ត ***ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ*** ការជំរុញកិច្ចការពារលើកកម្ពស់សិទ្ធិ និងសុខុមាលភាពជនពិការ ស្របតាម ***អនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ*** ព្រមទាំងការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃសេវារបស់មូលនិធិជនពិការ។

ទី៥ ការបន្តជំរុញអនុវត្ត ***គោលនយោបាយជាតិសម្រាប់មនុស្សចាស់*** តាមរយៈគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ការបន្តពង្រឹងសមាគមមនុស្សចាស់ ការជំរុញកម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ និងកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារឲ្យបានកាន់តែប្រសើរ ជាពិសេស ការជំរុញរៀបចំនិងដំណើរការសេវាជនចាស់ជរា ដើម្បីបណ្តុះបណ្តាលភ្នាក់ងារផ្តល់សេវាថែទាំជនចាស់ជរា។

ទី៦ ការបន្តពង្រឹងយន្តការឆ្លើយតបនឹងគ្រោះមហន្តរាយ ដោយផ្តោតលើការជួយគាំពារដល់ប្រជាជនរងគ្រោះ ទាំងក្នុងនិងក្រោយពេលមានគ្រោះមហន្តរាយ តាមរយៈការពង្រឹងស្ថាប័ននិងយន្តការពាក់ព័ន្ធ ពិសេស គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយបង្កើនថែមទៀតនូវកិច្ចសហការ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយសប្បុរសជននិងដៃគូផ្សេងទៀត។

ទី៧ ការបន្តពង្រឹងយន្តការធានាសន្តិសុខស្បៀង ពិសេស យន្តការ *គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា* ។

ទី៨ ការបន្តអន្តរាគមន៍ក្នុងផ្នែកសុខាភិបាល សំដៅលើកស្ទួយស្ថានភាពអនាម័យ លើកកម្ពស់ការបង្ការជំងឺឆ្លងនិងហានិភ័យផ្នែកសុខភាពផ្សេងទៀត លើកស្ទួយសុខុមាលភាពមាតា ទារក និងកុមារ ដោយផ្តោតការយកចិត្តទុកដាក់ ពិសេស លើអាហារូបត្ថម្ភ ព្រមទាំងពង្រីកវិសាលភាពនៃមូលធិនិសមធម៌ ក៏ដូចជាការធានារ៉ាប់រងសុខភាពសហគមន៍មូលដ្ឋាន និងការធានារ៉ាប់រងសុខភាពដោយស្ម័គ្រចិត្តសម្រាប់មុខសញ្ញាសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ទី៩ ការបន្តអន្តរាគមន៍លើការបង្កើតឱកាសការងារ តាមរយៈការបន្តផ្តល់ការឧបត្ថម្ភឲ្យជនក្រីក្របានទទួល ទាំងការបណ្តុះបណ្តាល និងការបណ្តុះបណ្តាលឡើងវិញនូវជំនាញបច្ចេកទេស វិជ្ជាជីវៈ និងសហគ្រិនភាព ដែលអាចផ្តល់លទ្ធភាពឲ្យពលករដែលមានការពាក់ព័ន្ធ បង្កើតមុខរបរដោយខ្លួនឯង និងអាចរកការងារធ្វើនៅក្នុងទីផ្សារពលកម្ម។

ទី១០ ការបន្តចាត់វិធានការជាកញ្ចប់ ប្រកបដោយភាពទន់ភ្លន់ស្របតាមសភាពការណ៍ជាក់ស្តែង ដើម្បីផ្តល់ការគាំពារដល់ក្រុមជនងាយរងគ្រោះ ក្នុងពេលដែលប្រទេសជាតិត្រូវជួបប្រឈមនឹងសភាពការណ៍នៃវិបត្តិសេដ្ឋកិច្ចជាយថាហេតុណាមួយ។

ទី១១ ការបន្តអនុវត្តវិធានការបែងចែកដីធ្លី តាមរយៈការផ្តល់សម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្មដីជូនដល់ជនក្រីក្រ យោធិនពិការ គ្រួសារយោធាពលីនិងមរណៈ និងអតីតកងកម្លាំងប្រដាប់អាវុធ ដែលគ្មានឬខ្វះដីពិតប្រាកដ ស្របតាមគោលនយោបាយកំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាល។

ទី១២ ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈការពង្រឹងវិសាលភាពនិងអន្តរការីកម្មនៃសេវាមីក្រូហិរញ្ញវត្ថុ និងមីក្រូធានារ៉ាប់រង ដែលមានតម្លៃ និងលក្ខខណ្ឌកាន់តែអនុគ្រោះ រួមទាំងការបន្តអន្តរាគមន៍របស់រដ្ឋក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការបង្កើតមុខរបរតាមយន្តការ *មូលនិធិជាតិបណ្តុះបណ្តាលដើម្បីកាត់បន្ថយភាពក្រីក្រ* ។

ទី១៣ ការបន្តពង្រីកសេវាធានារ៉ាប់រងហានិភ័យការងារ និងការរៀបចំអនុវត្តយន្តការធានារ៉ាប់រងសុខភាព សម្រាប់កម្មករ និយោជិត និងគ្រួសារក្នុងបន្ទុក ព្រមទាំងរបបធានារ៉ាប់រងផ្នែកសោធនសម្រាប់កម្មករ និយោជិត។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៨៣- រាជរដ្ឋាភិបាលកម្ពុជា នៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបង្កើតនិងអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គមមួយ ដែលមានលក្ខណៈទូលំទូលាយ មានចីរភាព ក្នុងគោលបំណងគាំពារដល់ជីវភាពរស់នៅរបស់ជនក្រីក្រនិងជនងាយរងគ្រោះ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិង

ជនបទ បានបោះជំហានយ៉ាងសំខាន់មួយ ក្នុងការបង្កើតបាននូវការឯកភាពលើទស្សនាទានសំខាន់ៗ និងទិសដៅទូលំទូលាយ ដើម្បីបង្កើតគោលនយោបាយស្តីពីបណ្តាញសុវត្ថិភាពសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាណត្តិការងារដល់ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ដើម្បីបង្កើតយន្តការសម្របសម្រួលអន្តរក្រសួង តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តកិច្ចអន្តរាគមន៍ប្រព័ន្ធសុវត្ថិភាពសង្គម សំដៅពង្រឹងស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរបស់ជនក្រីក្រនិងជនងាយរងគ្រោះ។

៤.១៨៤- ***ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទ*** នឹងធានាឲ្យមានការរៀបចំផែនការសម្រាប់អនុវត្តវិធានការគាំពារសង្គម ដោយមានគោលការណ៍ដូចខាងក្រោម៖

- អនុវត្ត និងពង្រីកវិសាលភាពលើកម្មវិធីដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមក្នុងគោលដៅបង្កើតឡើងនូវប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈស៊ីជម្រៅ មានប្រសិទ្ធភាព និងអាចទទួលប្រើបាន។ កម្មវិធីគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះដែលកំពុងរៀបចំបង្កើតឡើង កំពុងអនុវត្ត ឬអនុវត្តក្នុងកម្រិតសាកល្បង(កម្មវិធីសង្គហទានសង្គម កម្មវិធីសំណង់សាធារណៈ អន្តរាគមន៍អាហារូបត្ថម្ភមូលនិធិសមធម៌ និងកម្មវិធីអាហារូបករណ៍ដោយផ្តោតលើសិស្សក្រីក្រ) នឹងត្រូវវាយតម្លៃធ្វើសុខដុមនីយកម្ម និងពង្រីកវិសាលភាព។
  - ពង្រីកវិសាលភាពកម្មវិធីសង្គហទានសង្គមសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារក្រីក្របន្ថែមជាមួយការពង្រឹងការអភិវឌ្ឍកុមារតូច និងការផ្តល់សេវាសុខភាពនិងអាហារូបត្ថម្ភ នឹងត្រូវកំណត់ថាជាឧបករណ៍ចាំបាច់ក្នុងការបង្កើនកម្រិតអាហារូបត្ថម្ភ និងសមត្ថភាពផ្នែកបញ្ញានិងស្មារតីដល់កុមារ ដែលការធ្វើសំបុត្រកំណើតកុមារជាប្រការចាំបាច់បំផុតសម្រាប់ការអនុវត្តនិងការពិនិត្យតាមដានកម្មវិធីនេះ។
  - ពង្រីកវិសាលភាពកម្មវិធីសំណង់សាធារណៈ ដែលអាចជួយដោះស្រាយភាពងាយរងគ្រោះទៅនឹងវិបត្តិ និងនិកម្មភាពជាលក្ខណៈរដូវកាល។
  - ពង្រីកវិសាលភាពកម្មវិធីផ្តល់អាហារនៅសាលារៀន រួមទាំងសម្រាប់ថ្នាក់មត្តេយ្យសិក្សាក្នុងករណីចាំបាច់ដើម្បីបង្កើនលទ្ធផលផ្នែកសិក្សាអប់រំពិសេសសម្រាប់កុមារក្រីក្រ។
  - ពង្រីកវិសាលភាពកម្មវិធីសំណង់សាធារណៈ ដែលអាចជួយដោះស្រាយភាពងាយរងគ្រោះទៅនឹងវិបត្តិនិងនិកម្មភាពជាលក្ខណៈរដូវកាល។
  - ពង្រីកវិសាលភាពកម្មវិធីផ្តល់អាហារនៅសាលារៀន រួមទាំងសម្រាប់ថ្នាក់មត្តេយ្យសិក្សាក្នុងករណីចាំបាច់ ដើម្បីបង្កើនលទ្ធផលផ្នែកសិក្សាអប់រំពិសេសសម្រាប់កុមារក្រីក្រ។

- ពង្រីកវិសាលភាពកម្មវិធីអាហារូបករណ៍ដោយផ្តោតលើសិស្សក្រីក្រ ដើម្បីបង្កើនសន្តិសុខស្បៀងនិងលទ្ធផលផ្នែកសិក្សាអប់រំនិងអាហារូបត្ថម្ភ ពិសេសសម្រាប់កុមារក្រីក្រ។
- ពង្រីកវិសាលភាពមូលនិធិសមធម៌សុខាភិបាល ដែលជាមធ្យោបាយចាំបាច់មួយ ដែលជួយបង្កើនការគាំពារផ្នែកសុខភាពសម្រាប់ជនក្រីក្រ។

- ការកសាងប្រព័ន្ធគាំពារសង្គមដែលមានប្រសិទ្ធភាព និងមានភាពស័ក្តិសិទ្ធិ តម្រូវឲ្យមានសុខដុមនីយកម្មទៅក្នុងកម្មវិធីដែលមានស្រាប់និងកម្មវិធីថ្មី និងពង្រឹងប្រព័ន្ធផ្តល់សេវា។ ប្រព័ន្ធគាំពារសង្គមបែបនេះនឹងផ្តល់លទ្ធភាពក្នុងការកំណត់អត្តសញ្ញាណអ្នកទទួលផលប្រភេទកញ្ចប់លាភការដែលអ្នកទទួលផលទទួលបាន និងការពិនិត្យតាមដានលើការផ្តល់សេវានិងការផ្តល់លាភការ។
  - ពង្រឹងយន្តការកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលមានស្រាប់ នៅតែជាអាទិភាពក្នុងការតម្រង់ធនធានចំពោះក្រុមគ្រួសារដែលជាអាទិភាព។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គួរមានវិសាលភាពលើគ្រប់តំបន់នៃប្រទេសកម្ពុជា ហើយធ្វើបច្ចុប្បកម្មជាប្រចាំ។ ការលើកកម្ពស់ប្រសិទ្ធភាពនៃការកំណត់អត្តសញ្ញាណ(ដោយកាត់បន្ថយកំហុសឆ្គងផ្នែកពុំបានរាប់បញ្ចូលឬការរាប់បញ្ចូលលើស ពិសេស ចំពោះជនជាតិដើមភាគតិច) និងពង្រីកយន្តការនេះឲ្យគ្របដណ្តប់លើពលករទេសន្តប្រវេសន៍ និងគ្រួសាររបស់ពួកគាត់ជាប្រការចាំបាច់បំផុតក្នុងការឈានឆ្ពោះទៅកាន់រៀបចំយន្តការបណ្តឹងត៉វារបស់អ្នកទទួលផល។
  - កំណើននៃចលនការចំណូលស្រុកមកកាន់តំបន់ទីប្រជុំជន ទាមទារឲ្យមានយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រសម្រាប់តំបន់ទីប្រជុំជនដែលធ្វើឲ្យពួកគាត់ជាពិសេសក្រុមជនទេសន្តប្រវេសន៍ក្រីក្រអាចទទួលបានកម្មវិធីគាំពារសង្គម។
  - ផ្សារភ្ជាប់ភាពងាយរងគ្រោះដោយសារអាកាសធាតុ ទៅនឹងប្រព័ន្ធនៃយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដែលអាចអនុញ្ញាតឲ្យគ្រួសារក្រីក្រដែលងាយរងគ្រោះទៅនឹងគ្រោះមហន្តរាយធម្មជាតិអាចទទួលកម្មវិធីជំនួយសង្គមកិច្ច។
  - ធ្វើមូលដ្ឋានូបនីយកម្មលើការធ្វើផែនការ និងការផ្តល់កម្មវិធីគាំពារសង្គមដែលអាចធ្វើឲ្យកម្មវិធីគាំពារសង្គមនិងជំនួយសង្គមកិច្ច អាចឆ្លើយតបដោយផ្ទាល់ចំពោះតម្រូវការនៅកម្រិតមូលដ្ឋាន។ ប្រការនេះគឺត្រូវរួមបញ្ចូលទាំងការកសាងសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំបង្កើត និងអនុវត្តកម្មវិធីគាំពារសង្គម។ ថវិកាឃុំ/សង្កាត់ អាចនឹងត្រូវប្រើប្រាស់កាន់តែច្រើនសម្រាប់អន្តរាគមន៍គាំពារសង្គមដែលអាចរំពឹងទុកមុននិងមានលក្ខណៈជាប្រចាំ។
  - យន្តការផ្តល់សេវាគាំពារសង្គមនិងមុខរបរដែលមានប្រសិទ្ធភាព ស័ក្តិសិទ្ធិ និងទាន់ពេលវេលាក៏ត្រូវបង្កើតឡើង។ យន្តការផ្តល់សេវាសង្គមដែលប្រើប្រាស់គំរូនៃការិយា

លយច្រកចេញចូលតែមួយ នឹងត្រូវអនុវត្តសាកល្បងនិងពង្រីកវិសាលភាពដើម្បីធានាការសម្របសម្រួលលើការគាំពារសង្គមនិងមុខរបរ នៅថ្នាក់ក្រោមជាតិសម្រាប់តំបន់ជនបទ។

- ប្រព័ន្ធដែលមានប្រសិទ្ធភាព និងប្រកបដោយការសម្របសម្រួលសម្រាប់ការពិនិត្យតាមដានលើលទ្ធផលនៃកម្មវិធីគាំពារសង្គមនឹងត្រូវរៀបចំបង្កើតឡើង ដើម្បីធ្វើសុខដុមនីយកម្មទៅលើកម្មវិធីដែលបានអនុវត្ត។ ការសម្រេចចិត្តដែលផ្អែកលើភស្តុតាងលើការផ្តល់កម្មវិធីគាំពារសង្គម នឹងត្រូវធ្វើឡើងតាមរយៈក្របខ័ណ្ឌពិនិត្យតាមដានរួមមួយនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម។

- ពង្រឹងនិងពង្រីកវិសាលភាពកម្មវិធីរបបសន្តិសុខសង្គម និងរៀបចំបង្កើតក្របខ័ណ្ឌយុទ្ធសាស្ត្រ សម្រាប់ពង្រីកទៅកាន់វិស័យក្រៅប្រព័ន្ធ។ កត្តាចលនការវិវត្តផ្នែកប្រជាសាស្ត្រ និងយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតំបន់ទីប្រជុំជន នឹងផ្តល់ជាមូលដ្ឋាននៃការពង្រីករបបសន្តិសុខសង្គមសម្រាប់វិស័យក្រៅប្រព័ន្ធ។

៤.១៨៥- ***ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី*** សុទ្ធតែបានទទួលភារកិច្ច ដើម្បីផ្តល់នូវសេវាសង្គមដល់ប្រជាពលរដ្ឋ និងការពារដល់ក្រុមជនងាយរងគ្រោះឲ្យរួចផុតពីហានិភ័យទាំងឡាយ។ ការធ្វើអន្តរាគមន៍ដោយឡែកនៃបណ្តាញសុវត្ថិភាពសង្គម ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ឧទាហរណ៍ ***ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*** ។ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងការគាំពារសង្គម ***ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*** កំណត់យុទ្ធសាស្ត្រ៣ គឺ (១)បង្កើនប្រសិទ្ធភាពសេវាសង្គមកិច្ច (២)ជំរុញដំណើរការប្រព័ន្ធសន្តិសុខសង្គម និង(៣) ពង្រឹងសមត្ថភាពស្ថាប័ន កៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និងកម្មវិធីការងារអាទិភាពជាក់ស្តែង៨ចំណុច មានដូចខាងក្រោម៖

### លើកកម្ពស់សុខុមាលភាពសង្គមនិងកិច្ចការគ្រួសារ

- បង្កើនអន្តរាគមន៍សង្គមកិច្ច ដើម្បីជួយដល់ប្រជាជនក្រីក្រងាយរងគ្រោះ ជនរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ សង្គមដោយមិនទុកឲ្យប្រជាជនណាម្នាក់ស្លាប់ដោយអត់បាយ ដែលយើងមិនបានដឹង ហើយមិនបានដោះស្រាយ។
- បន្តពង្រីកកម្មវិធីដោះស្រាយជួយប្រជាជនក្រីក្រងាយរងគ្រោះ ទប់ស្កាត់ភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រនៅតាមសហគមន៍ទប់ស្កាត់ទុរគតភាព ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។

- បន្តពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថា ចាត់ទុកជនអនាថាជាជនរងគ្រោះដោយត្រូវទទួលបាននូវការគាំពារផ្នែកសង្គមកិច្ច ការផ្តល់សេវាជូនជនអនាថាដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស និងការបង្កកាលានុវត្តភាពឲ្យស្តារជីវភាពឡើងវិញ និងធ្វើសមាហរណកម្មទៅក្នុងសង្គម។
- ជំរុញការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជួយដល់ជនរងគ្រោះ តាមរយៈការស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មជនរងគ្រោះទៅសហគមន៍វិញដោយគ្មានការរើសអើង។
- បន្តអនុវត្តគោលនយោបាយ បទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- បន្តផ្តល់កម្មវិធីសង្គ្រោះជនរងគ្រោះ និងជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍។
- បន្តអភិវឌ្ឍចលនាគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។ លើកកម្ពស់តួនាទីរបស់គ្រួសារជាកោសិការបស់សង្គម ជាកន្លែងផ្តល់ភាពកក់ក្តៅ និងសុភមង្គលសម្រាប់ប្រជាជនគ្រប់រូប រួមចំណែកក្នុងការអភិវឌ្ឍសង្គម។ បន្តចាត់តាំងទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ឧសភា។
- រៀបចំ និងអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍសហគមន៍ប្រជាជនក្រីក្រនៅតាមសហគមន៍ ដើម្បីទទួលបាននូវកាលានុវត្តភាពសម្រាប់ការកែប្រែជីវភាព។
- បន្តបញ្ជ្រាបការងារយេនឌ័រទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកកម្ពស់តួនាទីស្ត្រី ក្នុងសង្គម លើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ លុបបំបាត់រាល់ទស្សនៈមើលស្រាលស្ត្រី និងបន្តបង្កើនអត្រាស្ត្រីក្នុងតួនាទីដឹកនាំ។

## លើកកម្ពស់សុខុមាលភាពកុមារនិងយុវនីតិសម្បទា

- បន្តជំរុញការផ្សព្វផ្សាយនិងអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ជាពិសេស សិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ«សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ»។ រៀបចំនិងផ្ញើរបាយការណ៍ជាតិលើកទី៤ដល់លើកទី៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ និងរបាយការណ៍ជាតិស្តីពីការអនុវត្តពិធីសារពាក់ព័ន្ធផ្សេងៗ ទៀតជូនអង្គការសហប្រជាជាតិបានទាន់ពេលវេលាប្រកបដោយគុណភាព។
- រៀបចំផែនការជាតិសម្រាប់អភិវឌ្ឍន៍កុមារ ២០១៥-២០២៥ ជំរុញការអនុវត្តផែនការជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ និងបន្តរៀបចំផែនការសកម្មភាពសម្រាប់ការវិភាជថវិកាសង្គមផ្តោតលើវិស័យកុមារ។
- បន្តពង្រឹងពង្រីកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ កៀរគរប្រភពធនធាន និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូ សំដៅលើកកម្ពស់សិទ្ធិកុមារ។

- បន្តអនុវត្តប្រកបដោយជោគជ័យនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលពាក់ព័ន្ធនឹងវិស័យកុមារ ជាអាទិ៍ លើវិស័យសុខាភិបាល ការកាត់បន្ថយអត្រាមរណភាពមាតានិងទារក ការអប់រំ ការបង្កើនអត្រាចូលរៀនរបស់សិស្ស និងគុណភាពអប់រំ។ល។
- បន្តអនុវត្តនូវប្រព័ន្ធសុខុមាលភាពកុមារ គោលនយោបាយថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាសម្រាប់ថែទាំកុមារនៅតាមសហគមន៍។ ជំរុញការអនុវត្តមុខងារលើវិស័យសុខុមាលភាពកុមារតាមប្រព័ន្ធវិសហមជ្ឈការរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។
- បន្តពង្រឹងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌល តាមរយៈការធ្វើអធិការកិច្ច អនុវត្តបទដ្ឋានគតិយុត្ត និងយន្តការដើម្បីរកគ្រួសារល្អសម្រាប់កុមារ។ អនុវត្តអនុសញ្ញាទីក្រុងឡាអេស្តីពីសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។
- ជំរុញការអនុវត្តការងារយុវនីតិសម្បទា និងអនុវត្តនូវកម្មវិធីយុត្តិធម៌អនីតិជន បន្តផ្តល់នូវសេវាការពារសិទ្ធិកុមារតាមផ្លូវច្បាប់ ចំពោះអនីតិជនដែលប្រព្រឹត្តល្មើសនឹងច្បាប់តាមសហគមន៍ តាមពន្ធនាគារ។ ជំរុញការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនដើម្បីការពារសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌ និងទប់ស្កាត់បាតុភាពអសកម្មរបស់អនីតិជន និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុខុមាលភាពកុមារ។
- បន្តអនុវត្តគោលនយោបាយស្តីពីមជ្ឈមណ្ឌលព្យាបាលស្តារនីតិសម្បទា សម្រាប់ជួយជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀន ព្រមជាមួយនោះ ជំរុញគោលនយោបាយលើកទឹកចិត្ត ការព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀនតាមសហគមន៍។

## លើកកម្ពស់សុខុមាលភាពសម្រាប់ជនពិការ

- ជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ស្របតាមគោលនយោបាយជាតិស្តីពីជនពិការ។ តាមរយៈច្បាប់នេះ ជំរុញអនុវត្តគោលនយោបាយការពារ លើកកម្ពស់សិទ្ធិជនពិការ និងលុបបំបាត់ការរើសអើងចំពោះជនពិការ ព្រមទាំងបង្កកាលានុវត្តភាពឲ្យជនពិការបានចូលរួមគ្រប់សកម្មភាពរបស់សង្គម។
- បន្តដំណើរការមូលនិធិជនពិការ ដែលមានភារកិច្ចរកចំណូល និងផ្តល់សេវាជូនជនពិការ ស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ បន្តនិរន្តរភាពកម្មវិធីស្តារលទ្ធភាពពលកម្មជូនជនពិការដោយឥតគិតថ្លៃ រួមទាំងការផ្តល់សោហ៊ុយធ្វើដំណើរ ការស្នាក់នៅ និងការហូបចុក។
- ជំរុញអនុវត្តការផ្តល់របបគោលនយោបាយ ស្តីពីការជួយឧបត្ថម្ភជនពិការក្រីក្រតាមសហគមន៍ ស្របតាមលទ្ធភាពថវិកា។
- បន្តអនុវត្តកម្មវិធីសេវាសហគមន៍សម្រាប់ជនពិការ ផ្តល់សេវាស្តារលទ្ធភាពពលកម្ម ការបង្កើតក្រុមជួយខ្លួនឯង ការអភិវឌ្ឍមុខរបរខ្នាតតូច។ លើកទឹកចិត្តដល់ការបង្កើតអង្គការរបស់ជនពិការដែលដឹកនាំដោយជនពិការផ្ទាល់ ដូចជាសមាគមជនពិការភ្នែក អង្គការ

ជនពិការកម្ពុជា មជ្ឈមណ្ឌលជាតិនៃជនពិការ និងក្រុមជួយខ្លួនឯងរបស់ជនពិការតាមសហគមន៍។

- បន្តផ្តល់កាលានុវត្តការងារដល់ជនពិការចូលបម្រើការងារតាមស្ថាប័នរដ្ឋ២% និងគ្រឹះស្ថានឯកជន១% តាមការកំណត់នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។
- បន្តកម្មវិធីផ្តល់សេវាឲ្យកុមារពិការភ្នែក កុមារគថ្លង់ និងកុមារខ្សោយសតិបញ្ញា តាមរយៈការបង្កើតឲ្យមានមណ្ឌលផ្តល់នូវសេវាពិសេស ជូនដល់កុមារតាមប្រភេទពិការនីមួយៗ និងធ្វើសមាហរណកម្មកុមារពិការទៅក្នុងសហគមន៍ដោយមិនមានការរើសអើង។
- លើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ ការងារព័ត៌មានជាភាសាសញ្ញា និងការអភិវឌ្ឍសេវាអក្សរស្ទាប និងភាសាសញ្ញា។
- ជំរុញការផ្សព្វផ្សាយ អនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" បន្ថែមលើបទដ្ឋានជាតិដែលមានស្រាប់។
- រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០១៤-២០១៨ រួមបញ្ចូលជនពិការដោយសារមីន។

## លើកកម្ពស់សុខុមាលភាពមនុស្សចាស់

- បន្តអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ ចាត់ទុកមនុស្សចាស់ជាធនធានដ៏មានតម្លៃរបស់សង្គម ដែលបានបន្សល់ទុកស្នាដៃ និងមរតកសម្រាប់សង្គមជាតិជំនាន់ក្រោយៗ។ អត្រាមនុស្សចាស់ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅមាន៦%នៃប្រជាពលរដ្ឋ។ អត្រានេះ អាចមាននិន្នាការឡើងជាបន្តបន្ទាប់ ស្របតាមលក្ខណៈប្រជាសាស្ត្រ ការរីកចម្រើននៃវិស័យសុខុមាលភាព និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
- ជំរុញសកម្មភាពគណៈកម្មាធិការជាតិ និងយន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគោលនយោបាយចំពោះមនុស្សចាស់ និងរៀបចំទិវាមនុស្សចាស់ ១តុលា ជារៀងរាល់ឆ្នាំ។
- ជំរុញអនុវត្តនូវកម្មវិធីពីរជាសំខាន់គឺទី១ កម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ និងទី២ កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ។
- បន្តជំរុញកម្មវិធីថែទាំមនុស្សចាស់នៅតាមគ្រួសារ តាមរយៈការផ្សព្វផ្សាយ លើកកម្ពស់ប្រពៃណីទំនៀមទម្លាប់ល្អរបស់គ្រួសារខ្មែរក្នុងការគោរពដឹងគុណចំពោះមនុស្សចាស់។
- បន្តជំរុញកម្មវិធីលើកទឹកចិត្តដល់សហគមន៍ អារាមសាសនា ជាពិសេស ព្រះពុទ្ធសាសនា និងសាសនាដទៃទៀត ក្នុងការជួយដល់សាសនិក ដែលជាជនចាស់ជរាបានជ្រកកោននៅតាមទីអារាម។
- បន្តពង្រឹងនិងពង្រីកសកម្មភាពសមាគមមនុស្សចាស់នៅតាមឃុំ សង្កាត់ សំដៅបង្កើតឲ្យមានកម្មវិធីថែទាំសុខភាព ធនាគារស្រូវ បេឡាមរណសង្គ្រោះ និងការសាមគ្គីជួយគ្នាទៅវិញទៅមក រវាងមនុស្សចាស់ដូចគ្នានៅក្នុងសហគមន៍។
- បន្តលើកទឹកចិត្តសប្បុរសជនឲ្យបង្កើតនូវកម្មវិធីមនុស្សធម៌ ដើម្បីជួយដល់ជនចាស់ជរាដូចជាការជួយសាងសង់ផ្ទះជូនដល់ជនចាស់ជរាក្រីក្រនៅតាមសហគមន៍។

- លើកទឹកចិត្តដល់តស្សុរជន សប្បុរសជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ បន្តយកចិត្តទុកដាក់ផ្តល់អំណោយមនុស្សធម៌ សម្ភារៈ ថវិកា ដល់ជនចាស់ជរាក្រីក្រគ្មានទីពឹង។
- រៀបចំ និងដំណើរការមជ្ឈមណ្ឌលសេវាជនចាស់ជរាកម្ពុជាដើម្បីបណ្តុះបណ្តាលបុគ្គលិកភ្នាក់ងារផ្តល់សេវាថែទាំជនចាស់ជរា។
- លើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជនក្នុងការបង្កើតសេវាថែទាំសុខភាពជនចាស់ជរា។
- បង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយគ្របដណ្តប់លើ វិសាលភាពនៃស្រទាប់ប្រជាជនគ្រប់មជ្ឈដ្ឋានក្នុងសង្គម ធ្វើជាស្នូលនៃសំណាញ់សុវត្ថិភាពសង្គម។ ជំរុញការរៀបចំ និងអនុម័តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាជនទូទៅ។

## លើកកម្ពស់វិស័យអតីតមន្ត្រីរាជការស៊ីវិល

- បន្តអនុវត្តគោលនយោបាយជាតិចំពោះអតីតមន្ត្រីរាជការស៊ីវិល និងបន្តផ្តល់នូវការលើកទឹកចិត្តតាមរយៈការផ្តល់នូវកិត្តិយស សេចក្តីថ្លៃថ្នូរ និងការផ្តល់នូវរបបសន្តិសុខសង្គមស្របតាមលទ្ធភាពនៃសេដ្ឋកិច្ចជាតិ។
- បន្តអនុវត្តគោលការណ៍រដ្ឋបង់ប្រាក់វិភាគទាន៦%នៃប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។
- បន្តដំណើរការរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលមានតាវកាលិក៦មុខរួមមាន៖ ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក។

## លើកកម្ពស់វិស័យអតីតយុទ្ធជន

- បន្តយកចិត្តទុកដាក់លើការងារអតីតយុទ្ធជន ដោយបន្តអនុវត្តគោលនយោបាយជាតិចំពោះអតីតយុទ្ធជន ដោយការគោរពដឹងគុណចំពោះគុណូបការៈដ៏ថ្លៃថ្លារបស់បងប្អូនចំពោះជាតិមាតុភូមិ និងប្រជាជនជាមួយនឹងការយកចិត្តទុកដាក់ដោះស្រាយជីវភាពខាងសម្ភារៈថវិកាជាបន្តបន្ទាប់ ព្រមទាំងផ្តល់កិត្តិយស ការគោរព និងការថែរក្សាសេចក្តីថ្លៃថ្នូរជូនអតីតយុទ្ធជន។
- បន្តយកចិត្តទុកដាក់កែសម្រួលបន្ថែមរបបឧបត្ថម្ភជូនអតីតយុទ្ធជនជាបន្តបន្ទាប់ ស្របតាមសភាពការណ៍ជាក់ស្តែងនៃស្ថានភាពសេដ្ឋកិច្ចជាតិ។
- ជំរុញដំណើរការបេឡាជាតិអតីតយុទ្ធជន ដើម្បីអនុវត្តការគ្រប់គ្រងទិន្នន័យ និងមូលនិធិតាមប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីធានាការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារ តាមធនាគារប្រកបដោយប្រសិទ្ធភាព។
- ជំរុញការរៀបចំអនុក្រឹត្យស្តីពីការកំណត់អត្រាភាគទាន ដើម្បីទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន។
- បន្តអនុវត្តនូវគោលនយោបាយផ្តល់សម្បទាដីសង្គមកិច្ច ការសង់លំនៅឋានជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ និងបង្កើតគម្រោងជាច្រើនដើម្បីកែលម្អជីវភាពយោធិន និងអតីតយុទ្ធជន។

- អភិវឌ្ឍសមាគមអតីតយុទ្ធជនកម្ពុជា សំដៅបន្តជួយដល់អតីតយុទ្ធជនក្នុងការកសាងជីវភាពគ្រួសារ ចូលរួមអភិវឌ្ឍនៅមូលដ្ឋាន ការបន្តសកម្មភាពបេឡាឥណទាន បេឡាមរណសង្គ្រោះ ការសាងសង់ផ្ទះ ការអភិវឌ្ឍនសហគមន៍អតីតយុទ្ធជន។ បង្កលក្ខណៈដល់អតីតយុទ្ធជនឲ្យទទួលបាននូវសេវាសាធារណៈផ្សេងៗ ដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់សម្បទានដីសង្គមកិច្ច ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការទទួលជំនួយសង្គ្រោះបន្ទាន់ ការចូលរួមសកម្មភាពសិល្បៈ កីឡា។ល។
- បន្តនិរន្តរភាពតំបន់អភិវឌ្ឍន៍យុទ្ធជនពិការ ដែលជាអំណោយដ៏ថ្លៃថ្លារបស់***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** និង***សម្តេចកិត្តិព្រឹទ្ធបណ្ឌិត*** និងបន្តសាងសង់ផ្ទះជូនអតីតយុទ្ធជន និងគ្រួសារនៅតាមសហគមន៍ តាមរយៈសមាគមអតីតយុទ្ធជនកម្ពុជាជាបន្តបន្ទាប់ទៀត។

### បង្កើតរបបសន្តិសុខសង្គមសម្រាប់ប្រជាជនទូទៅ

- បង្កើតប្រព័ន្ធសន្តិសុខសង្គមមួយ សម្រាប់ប្រជាជនកម្ពុជាទូទៅជាស្នូលនៃបណ្តាញសុវត្ថិភាពសង្គម។ លើកទឹកចិត្តឲ្យមានការសិក្សា រៀបចំច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាជនទូទៅ សម្រាប់ពិភាក្សាជាមួយគ្រប់អ្នកពាក់ព័ន្ធ និងរៀបចំក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធផ្សេងទៀត។

### ពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ

- បន្តខិតខំកសាងសមត្ថភាពស្ថាប័ន ពង្រឹងស្មារតីទទួលខុសត្រូវមនសិការវិជ្ជាជីវៈរបស់មន្ត្រីសង្គមកិច្ចគ្រប់លំដាប់ថ្នាក់ ដើម្បីឆ្លើយតបទៅនឹងភារកិច្ចក្នុងដំណាក់កាលថ្មីនេះ។
- ជំរុញដំណើរការវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ស្ថាប័នរដ្ឋនិងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការផ្តល់សេវាសង្គមកិច្ច។
- បន្តអនុវត្តនូវកម្មវិធីកំណែទម្រង់លើគ្រប់ផ្នែក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមកិច្ច។
- បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិដើម្បីជួយដល់ជនក្រីក្រងាយរងគ្រោះទាំងអស់។

## ៦.៤- ពង្រឹងការអនុវត្តគោលនយោបាយប្រជាជននិងសមភាពយេនឌ័រ

## គោលនយោបាយប្រជាជន

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១៨៦- ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាល នឹងបន្តកិច្ចខិតខំប្រឹងប្រែងបញ្ចូលគោលនយោបាយប្រជាជនក្នុងគោលនយោបាយ ផែនការ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ចទាំងអស់នៅគ្រប់កម្រិត។

៤.១៨៧- ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការបន្តពង្រឹងការគ្រប់គ្រងជរភាពប្រជាសាស្ត្រ សំដៅធានាបង្កើនគុណភាព ***មូលធនមនុស្ស*** ដែលជាគន្លឹះកំណាត់ភាពប្រកួតប្រជែងរយៈពេលវែងរបស់ប្រទេស ដើម្បីទាញយកផលប្រយោជន៍ និងប្រើប្រាស់ឲ្យអស់លទ្ធភាពនូវសក្តានុពលប្រជាសាស្ត្ររបស់កម្ពុជាសម្រាប់ធានាចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងវឌ្ឍនភាព និងវិបុលភាពរបស់ប្រជាជន។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

- ទី១ ការរៀបចំគោលនយោបាយគ្រប់គ្រងចលនាបម្លាស់ទីរបស់ប្រជាជន គួបផ្សំនឹងការពង្រឹងការងាររៀបចំដែនដីនិងនគរូបនីយកម្ម ដោយផ្តោតលើ (១)ការអភិវឌ្ឍរាជធានីភ្នំពេញ ប៉ូលសេដ្ឋកិច្ចសំខាន់ៗនៅក្នុងប្រទេស ក្រុងរណប និងតំបន់ទីប្រជុំជន ទន្ទឹមនឹងការបង្កើតការងារនៅតាមមូលដ្ឋាន និង (២)ការតភ្ជាប់ក្រុងរណបនិងតំបន់ទីប្រជុំជនទៅនឹងប៉ូលសេដ្ឋកិច្ចសំខាន់ៗឲ្យក្លាយជារបៀងសេដ្ឋកិច្ច។
- ទី២ ការបន្តអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ តាមរយៈការអនុវត្តវិធានការចម្រុះប្រទាក់ក្រឡាក្នុងវិស័យពាក់ព័ន្ធ ជាអាទិ៍ ការអប់រំ ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា បណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងសុខាភិបាល។
- ទី៣ ការបន្តលើកកម្ពស់តួនាទីរបស់យុវជន ក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការពង្រឹងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ការបំពាក់បំប៉នជំនាញបច្ចេកទេស និងសហគ្រិនភាព ព្រមទាំងការពង្រឹងភាពអង់អាចរបស់យុវជន។
- ទី៤ ការបន្តយកចិត្តទុកដាក់បង្កើនក្របខ័ណ្ឌឲ្យយុវជន ដែលជាកម្លាំងបន្តវេនអាចចូលរួមក្នុងការដឹកនាំនិងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការការពាររាល់សមិទ្ធផលសង្គម តាមរយៈការជំរុញការអនុវត្តជាជំហានៗនូវទិសដៅយុវភាវូនីយកម្ម ក្នុងការផ្តល់ការទទួលខុសត្រូវនៅគ្រប់លំដាប់ថ្នាក់។
- ទី៥ ការបន្តជំរុញការបញ្ជ្រាបសេចក្តីត្រូវការរបស់យុវជនទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍគ្រប់វិស័យនិងគ្រប់កម្រិត។

៤.១៨៨- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តដាក់ឲ្យប្រើប្រាស់នូវវិធានការចាំបាច់នានាដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការអភិវឌ្ឍនៅក្នុងវិស័យអប់រំ សុខាភិបាល សមភាពយេនឌ័រ អភិវឌ្ឍន៍ជនបទ ដែលជាវិស័យអាទិភាព។ ដោយមានប្រជាជនវ័យក្មេងអាយុតិចជាង២៤ឆ្នាំប្រមាណ៤១,៩%នោះ ប្រការសំខាន់និងចាំបាច់ត្រូវអនុម័តនូវវិធានការនានា ដើម្បីដាក់បញ្ចូលយុវជនទាំងនោះទៅជាកម្លាំងនាំមុខដ៏សំខាន់សម្រាប់ការអភិវឌ្ឍនៅគ្រប់វិស័យទាំងអស់។ រាជរដ្ឋាភិបាលកម្ពុជានឹងពង្រឹងការគ្រប់គ្រងតំបន់ទីប្រជុំជន និងប្រមូលផ្តុំប្រជាជនច្រើន ដើម្បីធ្វើឲ្យទីក្រុងស្អាតគ្មានសំរាម មានអនាម័យពេញលេញ មានអាកាសធាតុ

បរិសុទ្ធ មានសួនច្បារពណ៌ខៀវស្រងាត់ និងមានកន្លែងសម្រាប់ហាត់ប្រាណចម្រុះ និងរៀបចំការកម្សាន្តបែបវប្បធម៌ជាសាធារណៈ ដើម្បីលើកកម្ពស់គុណភាពនៃសុខភាព និងសីលធម៌។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៨៩- ***គ្រប់ក្រសួង ស្ថាប័នទាំងអស់*** សុទ្ធតែដើរតួក្នុងការអនុវត្តគោលនយោបាយជាតិប្រជាជនរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្រសួង ស្ថាប័ន ដែលសកម្មក្នុងការអនុវត្តគោលនយោបាយរួមមាន ***វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ*** ដែលមានភារកិច្ចក្នុងការប្រមូលទិន្នន័យប្រជាជនជាប្រចាំនិងរៀបចំវិភាគទិន្នន័យទាំងនោះ និង ***អគ្គនាយកដ្ឋានផែនការ*** នៃក្រសួងផែនការមានភារកិច្ចធានាថារាល់បញ្ហាប្រជាជន នឹងត្រូវបានដោះស្រាយនៅក្នុងដំណើរការនៃការរៀបចំផែនការ រួមទាំងបញ្ហាប្រជាជនទាំងឡាយដែលស្ថិតនៅកម្រិតក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចគាំទ្រនិងជំរុញបញ្ហាគោលនយោបាយជាតិប្រជាជន។ នៅក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នទាំងនោះ នឹងផ្តោតជាសំខាន់លើ៖

- ការពិនិត្យកែសម្រួល**គោលនយោបាយជាតិប្រជាជន**ដែលមានស្រាប់ ដោយផ្អែកលើការផ្លាស់ប្តូរឌីណាមិករបស់ប្រជាជន។
- ការពង្រឹងសមត្ថភាព អ្នករៀបចំគោលនយោបាយ សមាជិកសភា អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រង កម្មវិធីអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្តោតការយកចិត្តទុកដាក់លើទិន្នន័យ និងការវិភាគពីបញ្ហាសំខាន់ៗទាក់ទងនឹងប្រជាជននិងភាពក្រីក្រ។
- ការរៀបចំការណែនាំ សម្រាប់បញ្ចូលអថេរសំខាន់ៗ ទាក់ទងនឹងប្រជាជន និងភាពក្រីក្រទៅក្នុងគ្រប់ កម្មវិធីអភិវឌ្ឍន៍ទាំងអស់។
- ការពង្រឹងសមត្ថភាពដល់មន្ត្រីរៀបចំផែនការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចូលបញ្ហាប្រជាជនទៅក្នុងដំណើរការរៀបចំផែនការ។
- ការពង្រឹងសមត្ថភាពស្ថាប័នដើម្បីកំណត់ឡើងពីបញ្ហាប្រជាជន តាមរយៈការវិភាគដោយទៀងទាត់និងតាមដានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយប្រជាជន។
- ការរៀបចំនិងផ្សព្វផ្សាយទិន្នន័យប្រជាជន ដែលបានបំបែកនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- ការបញ្ចូលអថេរប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងភាពក្រីក្រ ទៅក្នុងរបាយការណ៍វឌ្ឍនភាពនៃ***ការអនុវត្តគោលនយោបាយជាតិប្រជាជន ផ.យ.អ.ជ. គ.អ.ស.ក.*** របាយការណ៍តាមវិស័យ និងផែនការតាមវិស័យ និងផែនការថ្នាក់ក្រោមជាតិ។
- ការកសាងសមត្ថភាពដល់អ្នករៀបចំផែនការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីប្រើប្រាស់ទិន្នន័យស្តីពីប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងភាពក្រីក្រ ក៏ដូចជា ការប្រើ

ប្រាស់ទំនាក់ទំនងរបស់កត្តាទាំងនេះ ជាមួយនឹងការរៀបចំកម្មវិធីនិងផែនការអភិវឌ្ឍន៍ និងការធ្វើរបាយការណ៍ស្តីពីការអនុវត្តផែនការនិងកម្មវិធីទាំងនោះ។

- ការរៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទិន្នន័យនិងអថេរប្រជាជន ដែលត្រូវបញ្ចូលទៅក្នុងផែនការ និងកម្មវិធីអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ការរៀបចំផែនការនិងកម្មវិធីអភិវឌ្ឍន៍ប្រកបដោយចីរភាព និងដើម្បីរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការនិងកម្មវិធីអភិវឌ្ឍន៍ទាំងនោះ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- ការរៀបចំកម្រងឯកសារបណ្តុះបណ្តាលនិងឯកសារផ្សេងៗទៀតដែលទាក់ទង នឹងការបំផុសឲ្យមានការយល់ដឹងពីបញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ ភាពក្រីក្រ និងទំនាក់ទំនងនៃបញ្ហាទាំងនេះជាមួយនឹងការអភិវឌ្ឍ។
- ការបង្កើនការយល់ដឹង និងការបណ្តុះបណ្តាលដល់និស្សិតនៅក្នុងសកលវិទ្យាល័យពីបញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ ភាពក្រីក្រ និងទំនាក់ទំនងនៃបញ្ហាទាំងនេះជាមួយនឹងការអភិវឌ្ឍ។
- ការរៀបចំការស្រាវជ្រាវពីតម្រូវការ និងបញ្ហាផ្សេងៗទាក់ទងនឹងបញ្ហាប្រជាជន ដោយផ្អែកលើការផ្លាស់ប្តូរឌីណាមិករបស់ប្រជាជនដល់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។
- ការស្រាវជ្រាវដើម្បីបំពេញតម្រូវការលើទិន្នន័យស្តីពី បញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងភាពក្រីក្រ។

## សមតាពយេនឌ័រ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

៤.១៩០- រាជរដ្ឋាភិបាល បានអនុវត្តផែនការយុទ្ធសាស្ត្រ “**នារីរតនៈទី៣**” ប្រកបដោយជោគជ័យ។ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញអនុម័តច្បាប់និងអនុវត្តច្បាប់ ដើម្បីការពារស្ត្រី ដែលរួមមានច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារលើស្ត្រី និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយគម្លាតយេនឌ័រ តាមរយៈការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារី។ ក្នុងវិស័យសុខាភិបាល រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនសេវាសុខភាពបឋម សុខភាពបន្តពូជ អាហារូបត្ថម្ភ ការទប់ស្កាត់នឹងជំងឺគ្រុនចាញ់ និងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។ ក្នុងវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនតួនាទីភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនិងបានការពារសិទ្ធិរបស់កម្មការិនី តាមរយៈការស្វែងរកការគាំទ្រមតិនិងការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយ។ លើសពីនេះ ស្ត្រីទទួលបានជំនាញ សមត្ថភាព និងតួនាទី ដើម្បីចូលរួមកាន់តែច្រើនឡើងក្នុងការដឹកនាំ និងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតនៃអភិបាលកិច្ច។

សមាមាត្រស្ត្រី ដែលបានជាប់ឆ្នោតជាសមាជិការដ្ឋសភា បានធ្លាក់ចុះពី២១%នៅឆ្នាំ២០០៨ ដល់២០%ក្នុងឆ្នាំ២០១៣។ នៅឆ្នាំ២០០៧ និងឆ្នាំ២០១២ ក្នុងចំណោមសមាជិកដែលជាប់ឆ្នោតទាំងអស់ក្នុងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាស្ត្រីមានការកើនឡើង ១៥% ទៅ១៨% ហើយបច្ចុប្បន្ន មេភូមិជាស្ត្រីមាន៣០%។

៤.១៩១- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ៖

ទី១ ការបន្តលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការពង្រីកកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ការបំពាក់បំប៉នជំនាញបច្ចេកទេស និងសហគ្រិនភាព ព្រមទាំងការពង្រឹងភាពអង់អាចរបស់ស្ត្រី។

ទី២ ការបន្តលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងវិស័យសាធារណៈ តាមរយៈការបង្កើនសមាមាត្រ និងការពង្រឹងសមត្ថភាពស្ត្រីនៅក្នុងជួរថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ទាំងកម្រិតនយោបាយទាំងកម្រិតជំនាញ។

ទី៣ ការបន្តជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពី **ការទប់ស្កាត់អំពើហិង្សាលើស្ត្រីសំដៅលុបបំបាត់ឥរិយាបថប្រើអំពើហិង្សាលើស្ត្រី** និងពង្រីកវប្បធម៌អហិង្សា ដើម្បីរួមចំណែកលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក៏ដូចជាកសាងគ្រួសារមានសុភមង្គល សហគមន៍ និងសង្គមជាតិសុខដុមរមនា។

ទី៤ ការបន្តពង្រឹងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាព ដើម្បីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទទៅស្ត្រីនិងកុមារ។

ទី៥ ការបន្តលើកកម្ពស់សុខុមាលភាពនិងសិទ្ធិរបស់កុមារ ដែលមានកំណត់ក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ រួមមានសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ។

ទី៦ ការបន្តជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍគ្រប់វិស័យនិងគ្រប់កម្រិត។

៤.១៩២- រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភានេះ នឹងបន្តអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់ការរើសអើងប្រឆាំងស្ត្រី អនុសញ្ញាពាក់ព័ន្ធផ្សេងទៀត ដែលទាក់ទងនឹងសមភាពយេនឌ័រនិងសិទ្ធិរបស់ស្ត្រី និងគោលនយោបាយរបស់ខ្លួន សំដៅបង្កើនកាលានុវត្តភាពដល់សិស្ស និស្សិតនារីឲ្យបានចូលរៀនកាន់តែច្រើនថែមទៀត តាមរយៈការបង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្ស និស្សិតនារី កម្មវិធីបំប៉ននៅសាលារៀន គ្រឹះស្ថានសិក្សា ការផ្តល់កន្លែងស្នាក់នៅ និងការធានាដឹកជញ្ជូនទៅមកប្រកបដោយសុវត្ថិភាព សម្រាប់សិស្ស និស្សិតនារី និងការបង្កើនចំនួនគ្រូបង្រៀនជាស្ត្រី។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តលើកដំឡើងតួនាទីរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដោយបន្តពង្រីកកាលានុវត្តភាពការងារសម្រាប់ស្ត្រី និង

បណ្តុះបណ្តាលអំពីរបៀបនៃការតស៊ូមតិក្នុងការឈរឈ្មោះ នៅតាមបណ្តាភូមិ ឃុំ ទូទាំងប្រទេស។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៩៣- រាជរដ្ឋាភិបាលនៅក្នុងអណត្តិទី៥នេះ នឹងបន្តអនុវត្តគោលនយោបាយសមភាពយេនឌ័រ តាមរយៈការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់វិស័យនិងកម្មវិធីអភិវឌ្ឍន៍នានា ដើម្បីកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះរបស់ស្ត្រី ជាពិសេស ស្ត្រីពិការ ស្ត្រីជនជាតិដើមភាគតិច។ រាជរដ្ឋាភិបាល នឹងបន្តការយកចិត្តទុកដាក់ជាពិសេសលើការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី យេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង ការធ្វើសេចក្តីសម្រេចរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈនិងនយោបាយ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី សុខភាពរបស់ស្ត្រី និងការអប់រំសម្រាប់ស្ត្រីនិងកុមារី។

### ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

៤.១៩៤- យុទ្ធសាស្ត្រស្តីពីការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ត្រូវបានបង្កើតឡើងដោយផ្អែកតាម**ក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍**។ យុទ្ធសាស្ត្រនេះជាឯកសារគោលក្នុងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា។

៤.១៩៥- រាជរដ្ឋាភិបាលមានគោលបំណងលុបបំបាត់គម្លាតយេនឌ័រ នៅក្នុងការងារមានប្រាក់កម្រៃ ជាពិសេស នៅក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ខាងក្រោមនេះ គឺជាសកម្មភាពស្នូលសម្រាប់ឆ្នាំ២០១៤-២០១៨៖

- ផ្តល់ការបណ្តុះបណ្តាលជំនាញសម្រាប់ការងារដល់ស្ត្រី៖ តាមរយៈការផ្តល់នូវកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈផ្អែកតាមតម្រូវការទីផ្សារដល់ស្ត្រី ពង្រឹងសេវាអភិវឌ្ឍន៍អាជីវកម្មសម្រាប់ស្ត្រីនៅក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី និងបង្កើនអាហារូបករណ៍ដល់ស្ត្រីនិងក្មេងស្រី។
- ពង្រឹងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ដែលដឹកនាំដោយស្ត្រី៖ តាមរយៈការផ្តល់សេវាអភិវឌ្ឍន៍សហគ្រាស ខ្នាតមីក្រូ តូច និងមធ្យម និងបន្តការធ្វើអន្តរាគមន៍គោលនយោបាយពាក់ព័ន្ធនានា ដើម្បីធានាថាស្ត្រីមានសមត្ថភាពដឹកនាំ និងធ្វើឲ្យសហគ្រាសរបស់ខ្លួនរីកចម្រើននិងផ្លាស់ប្តូរពីវិស័យក្រៅប្រព័ន្ធទៅជាក្នុងប្រព័ន្ធវិញ។
- ធ្វើឲ្យប្រសើរឡើងនូវជីវភាពសហគមន៍ជនបទ ជាពិសេស ស្ត្រីក្រីក្រ៖ ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីអភិវឌ្ឍន៍កសិកម្មជនបទ នឹងធានាបានថាទាំងស្ត្រីជនបទដែលមានមុខរបរពាក់ព័ន្ធកសិកម្ម និងមិនពាក់ព័ន្ធកសិកម្ម ជាពិសេសស្ត្រីដែលងាយរងគ្រោះនិងក្រី

គ្រប់ផុតអាចធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន បង្កើនផលិតភាព និងបង្កើននូវជីវភាពរបស់ខ្លួន។

## កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី

- ការបង្ការបឋមៈ ដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី តាមរយៈយុទ្ធសាស្ត្របង្ការបឋម ដែលសម្របសម្រួលជាពហុវិស័យ ដោយផ្តោតជាពិសេសដល់អ្នកពាក់ព័ន្ធសំខាន់ៗនិងការផ្លាស់ប្តូរជាវិជ្ជមាន។
- កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យៈ ដើម្បីបង្កើននូវការផ្តល់សេវាសមស្របប្រកបដោយគុណភាព និងអាចមានលទ្ធភាពទទួលយកបាន និងការឆ្លើយតបទៅនឹងតម្រូវការផ្សេងៗរបស់ជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី ដោយគ្មានការរើសអើង។
- ច្បាប់និងគោលនយោបាយៈ ដើម្បីធានាថាច្បាប់ និងគោលនយោបាយនានានៅក្នុងប្រទេសកម្ពុជាបានឆ្លើយតបនឹងយេនឌ័រ និងបានការពារសិទ្ធិជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី។
- ការកសាងសមត្ថភាពៈ ដើម្បីបង្កើនសមត្ថភាពនិងធនធានក្នុងវិស័យសំខាន់ៗនៅថ្នាក់ជាតិស្តីពីការរៀបចំបង្កើត ការអនុវត្ត ការធ្វើរបាយការណ៍ ការតាមដាន ការវាយតម្លៃ និងការសហការស្តីពីការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងកិច្ចអន្តរាគមន៍បង្ការផ្សេងៗ។

៤.១៩៦- ជាងនេះទៀត រាជរដ្ឋាភិបាល នឹងបន្តតាមដានយ៉ាងយកចិត្តទុកដាក់នូវករណីអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការជួញដូរមនុស្ស និងពង្រឹងការអនុវត្តច្បាប់ដើម្បីនាំយកជនល្មើសមកធ្វើការកាត់ទោស។

## ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈនិងនយោបាយ

- រៀបចំក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃ និងធ្វើសវនកម្មយេនឌ័រស្តីពីតំណាងនិងការចូលរួមរបស់បុរសនិងស្ត្រីក្នុងវិស័យនយោបាយ និងការធ្វើសេចក្តីសេចក្តីសម្រេច។
- រៀបចំនិងពង្រឹងគោលនយោបាយ ច្បាប់ និងកម្មវិធី ដើម្បីបង្កើនតំណាងស្ត្រីនៅក្នុងវិស័យនយោបាយ និងតួនាទីធ្វើសេចក្តីសម្រេចសំខាន់ៗ។
- រៀបចំនិងអនុវត្តកម្មវិធីកសាងសមត្ថភាព ដល់ស្ត្រីជាថ្នាក់ដឹកនាំដែលកំពុងកាន់តំណែង និងស្ត្រីដែលមានសក្តានុពលនិងគាំទ្រដល់កម្មវិធីផ្តួចផ្តើមផ្សេងៗ រួមទាំងការកៀរគរធនធានដើម្បីលើកកម្ពស់ស្ត្រីនៅក្នុងវិស័យនយោបាយនិងរចនាសម្ព័ន្ធនានា។
- ធ្វើការវិនិយោគក្នុងកម្មវិធីនានាដែលមានគោលដៅពង្រឹងនូវភាពក្លាហាន និងការជឿជាក់ជាអ្នកដឹកនាំដល់ស្ត្រីវ័យក្មេង ដើម្បីធានានូវការចូលរួមដោយស្មើភាពក្នុងភាពជាអ្នកដឹកនាំ នៅតាមសាលារៀន មហាវិទ្យាល័យ និងក្រុមយុវជន និងអង្គការសហគមន៍នានា។

- រៀបចំវិធានការសកម្មភាពជាវិជ្ជមាន សម្រាប់វិស័យណាដែលមានគម្លាតយេនឌ័រខ្លាំង (ឧទាហរណ៍ ការបង្កើនកូតាស្ត្រីនៅក្នុងបញ្ជីរបេក្ខជនបោះឆ្នោតជាដើម)
- បង្កើតនិងគាំទ្រជនបង្គោល ឬក្រុមការងារយេនឌ័រសម្រាប់ស្ត្រីនៅក្នុងសភាដើម្បីបង្កើនទំនាក់ទំនងជាមួយគ្នា និងនៅក្នុងអង្គការសង្គមស៊ីវិលនិងជំរុញឲ្យគណៈកម្មាធិការសភាទាំងអស់បានគិតគូរពីយេនឌ័រនៅរាល់ការសម្រេចចិត្តផ្សេងៗ។

**យេនឌ័រនិងសុខភាព**

- កាត់បន្ថយអត្រាមរណភាពមាតា។
- បង្កើនសមាមាត្រស្ត្រីពិនិត្យផ្ទៃពោះ៤ដង។
- កាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍។
- បង្កើនអាហារូបត្ថម្ភសម្រាប់ស្ត្រីនិងក្មេងស្រី។

**យេនឌ័រនិងវិស័យអប់រំ**

- កាត់បន្ថយអត្រាបោះបង់ការសិក្សារបស់ក្មេងស្រីនៅកម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ។
- បង្កើនអាហារូបករណ៍សម្រាប់សិស្សស្រីនៅកម្រិតមធ្យមសិក្សាទុតិយភូមិនិងឧត្តមសិក្សា។
- លើកកម្ពស់ការយល់ដឹងរបស់ឪពុកម្តាយ ដើម្បីបង្កើនការទទួលបានការអប់រំរបស់ក្មេងស្រី។
- បង្កើនការចូលរួមរបស់ស្ត្រីនៅគ្រប់ផ្នែកនៃការផ្តល់សេវាអប់រំ និងការគ្រប់គ្រង និងលើកកម្ពស់ឥរិយាបថសង្គមឲ្យឆ្លើយតបនឹងយេនឌ័រ។

**យេនឌ័រនិងការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍបៃតង**

- ធានាថាគោលនយោបាយនិងយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រោះមហន្តរាយ បានឆ្លើយតបនឹងយេនឌ័រ។
- បង្កើននូវភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ដល់ស្ត្រីនិងក្មេងស្រី។
- កាត់បន្ថយផលប៉ះពាល់ផ្នែកសុខភាពលើស្ត្រីនិងកុមារ ជាពិសេស ក្នុងអំឡុងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត។
- បង្កើនចំណេះដឹងរបស់ពួកគាត់ស្តីពីវិធានការកាត់បន្ថយ ដើម្បីធានានូវនិរន្តរភាពធនធានធម្មជាតិនិងការការពារបរិស្ថាន។
- កសាងសមត្ថភាពស្ថាប័នរដ្ឋ និងស្ថាប័នពាក់ព័ន្ធស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងផែនការសកម្មភាពនានា ដែលទាក់ទងនឹងបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

## តារាងទី៤.១៣ សូចនាករស្នូលសម្រាប់ការបញ្ជ្រាបយេនឌ័រ ២០១៤-២០១៨

| ការបញ្ជ្រាបយេនឌ័រនៅក្នុងគ្រប់កម្មវិធី និងវិស័យៈ គោលដៅ/ សូចនាករសំខាន់ៗ | | ឯកតា | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|---|
| **១.** សមាមាត្រស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ | | | | | | | | | |
| ១.១ | សមាមាត្រស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ (ចាប់ពីអគ្គនាយកដល់ការិយាល័យនៅថ្នាក់ជាតិនិងក្រោមជាតិ) | % | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ |
| ១.២ | សមាមាត្រស្ត្រីនៅក្នុងវិស័យសាធារណៈ | % | ៣៤ | ៣៥,៥ | ៣៦ | ៣៦,៥ | ៣៧ | ៣៧ | ៣៧ |
| **២.** ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | | | | | | | | | |
| ២.១ | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃ | | | | | | | | |
| | *កសិកម្ម* | % | ៥៣,៨ | ៥២ | ៥១ | ៥០ | ៥០ | ៥០ | ៥០ |
| | *ឧស្សាហកម្ម* | % | ៧០,៨ | ៦០ | ៥៥ | ៥០ | ៥០ | ៥០ | ៥០ |
| | *សេវា* | % | ២៨,៨ | ៣០ | ៣៥ | ៤០ | ៤០ | ៤០ | ៤០ |
| **៣.** យេនឌ័រនិងការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍបៃតង | | | | | | | | | |
| ៣.១ | ចំនួនស្ត្រីជាអ្នកទទួលផលពីកម្មវិធីការប្រែប្រួលអាកាសធាតុ | ចំនួន | ៣០ ៦៩៦ | ៥០ ០០០ | ៧០ ០០០ | ៩០ ០០០ | ១១០ ០០០ | ១៣០ ០០០ | ១៥០ ០០០ |
| **៤.** យេនឌ័រនិងការអប់រំ | | | | | | | | | |
| ៤.១ | អត្រារួមនៃការសិក្សារបស់ក្មេងស្រីនៅមធ្យមសិក្សាទុតិយភូមិ | % | ២៦,៤ | ២៧ | ២៧ | ២៩ | ៣១ | ៣៤ | ៣៧ |
| **៥.** យេនឌ័រក្នុងវិស័យសុខាភិបាល | | | | | | | | | |
| ៥.១ | ភាគរយស្ត្រីពិនិត្យផ្ទៃពោះចំនួន៤ដង | % | ៥២ | ៦១ | ៦៣ | ៦៤ | ៦៥ | ៦៨ | ៧០ |
| **៦.** កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី | | | | | | | | | |
| ៦.១ | ចំនួនគ្រួសារដែលមានបញ្ហាអំពើហិង្សាក្នុងគ្រួសារ | ចំនួន | ២៩ ៨០៨ | ២៧០០០ | ២៥ ០០០ | ២៣ ០០០ | ២០ ០០០ | ១៨ ០០០ | ១៥ ០០០ |

# ជំពូកទី៥

# តម្លៃដែលត្រូវចំណាយ ធនធាន និង ការកំណត់កម្មវិធីចំណាយ

# ជំពូកទី៥

# តម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ

**៥.១-** រាជរដ្ឋាភិបាលកម្ពុជា នឹងពង្រឹងនិងពង្រីកភាពជាដៃគូរវាងក្រសួង ស្ថាប័ន ជាមួយដៃគូអភិវឌ្ឍនានា អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងសង្គមស៊ីវិល ដើម្បីបង្កើនផលប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា។ រាជរដ្ឋាភិបាល ផ្តោតអាទិភាពខ្ពស់លើការទទួលបានធនធានអភិវឌ្ឍន៍ដែលមានគុណភាពខ្ពស់ ទាំងធនធានរូបវន្ត និងធនធានមនុស្ស ដើម្បីជួយពង្រឹងសមត្ថភាពក្នុងប្រទេសដើម្បីផ្តាច់ខ្លួនចេញពីតម្រូវការធនធានពីបរទេសបន្តិចម្តងៗ។ ក្នុងចំណោមអាទិភាពទាំងអស់ កិច្ចប្រឹងប្រែងសំខាន់មួយនឹងធ្វើឡើងដើម្បីប្រើប្រាស់ធនធានសម្រាប់ពង្រឹងសមត្ថភាពនៅគ្រប់កម្រិត ជាពិសេស ថ្នាក់ក្រោមជាតិ និងដើម្បីតម្រង់ធនធានទៅលើការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងប្រជាជនរស់នៅតាមតំបន់ជនបទ។ កិច្ចប្រឹងប្រែងនេះនឹងធ្វើឡើងដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួង ស្ថាប័ន សម្រាប់ផ្តល់សេវាសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាព។ ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតអាទិភាពលើអភិបាលកិច្ចនិងសេវាតាមប្រព័ន្ធអេឡិចត្រូនិកដើម្បីបង្កើនប្រសិទ្ធភាពនិងកាត់បន្ថយចំណាយនានា។

**៥.២-** រាជរដ្ឋាភិបាល កំពុងចាត់វិធានការពង្រឹងសុខដុមនីយកម្មការងារផែនការ ព្រមទាំងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ចំណាយវិនិយោគសាធារណៈ និងហិរញ្ញប្បទានសហប្រតិបត្តិការនៅក្នុងក្រសួង ស្ថាប័នទាំងអស់ ក្នុងក្របខ័ណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដើម្បីធានាភាពស៊ីគ្នារវាងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងអាទិភាពនៅក្នុង *ផ.យ.អ.ជ. ២០១៤-២០១៨* ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលខុសត្រូវលើការងារសម្របសម្រួលហិរញ្ញប្បទាន និងការវិភាជជំនួយអភិវឌ្ឍន៍ផ្លូវការ នឹងចាត់វិធានការដើម្បីពង្រឹងកិច្ចសម្របសម្រួលបន្ថែមទៀតជាមួយដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ដើម្បីពង្រឹងគណនេយ្យភាព និងតម្លាភាពក្នុងការប្រើប្រាស់ធនធានដែលមាន តាមរយៈកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។

## ១. តម្រូវការវិនិយោគសាធារណៈសរុប

**៥.៣-** ដើម្បីប្រមូលបានព័ត៌មានស្តីពីចំណាយនៃតម្រូវការវិនិយោគសាធារណៈ តាមរយៈដំណើរការពីក្រោមឡើងលើ ដោយរួមបញ្ចូលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ ទាក់ទងនឹងកម្មវិធីនិងគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្ត *ផ.យ.អ.ជ.* ដែលមានអាទិភាពខ្ពស់ទាំងអស់ ក្រសួង

ផែនការបានស្នើដល់ក្រសួង ស្ថាប័នទាំងអស់ផ្តល់ព័ត៌មានស្តីពីតម្រូវការវិនិយោគទៀងទាត់ ដើម្បីដាក់បញ្ចូលក្នុង*កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល* ។ ប៉ុន្តែគោលការណ៍នេះ មិនអាចអនុវត្តបាននៅគ្រប់ក្រសួង ស្ថាប័នទេ ដោយសារក្រសួង ស្ថាប័នមួយចំនួន មិនអាចផ្តល់ព័ត៌មានដែលត្រូវការចាំបាច់បាន។ រាជរដ្ឋាភិបាលនឹងពង្រឹងដំណើរការរៀបចំផែនការនិងការវិភាជថវិកា និងសមត្ថភាពរបស់ក្រសួង ស្ថាប័ន ដើម្បីធានាថាទិន្នន័យដែលត្រូវការសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ និងការវិភាជធនធានវិនិយោគសាធារណៈ មានគ្រប់គ្រាន់តាមពេលវេលាដែលត្រូវការ។ *ក.វ.ស. ៣ឆ្នាំរំកិល ២០១៥-២០១៧* និង *ក.វ.ស.* ក្រោយៗទៀត នឹងរៀបចំឡើងតាមវិធីសាស្ត្រដែលជំរុញដល់សុខដុមនីយកម្ម *ក.វ.ស.* និងហិរញ្ញប្បទានសហប្រតិបត្តិការ។ *ក.វ.ស. ២០១៥-២០១៧* នឹងរៀបចំឡើងតាមពេលវេលាកំណត់សម្រាប់រៀបចំ*ថវិកាជាតិសម្រាប់ឆ្នាំ ២០១៥*។

**៥.៤-** ក្នុងជំពូកទី៣ ស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ *ផ.យ.អ.ជ. ២០១៤-២០១៨* មានបង្ហាញពីការព្យាករពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ រួមមានការព្យាករពីតម្រូវការវិនិយោគមូលធន ពីវិនិយោគសាធារណៈនិងវិនិយោគឯកជន ដើម្បីសម្រេចបានកំណើនផ.ស.ស. ដែលកំណត់។ ប៉ុន្តែវិធីសាស្ត្រពីលើចុះក្រោមនេះ មិនបានបញ្ចូលរាល់តម្រូវការសម្រាប់ចំណាយវិនិយោគសាធារណៈ សម្រាប់វិស័យសង្គមកិច្ចទេ ដូចជាធនធានដែលត្រូវការសម្រាប់សម្រេចបានមូលធនមនុស្ស និងចំណុចដៅ*គ.អ.ស.ក.* ការពង្រឹងសមត្ថភាពរបស់ក្រសួង ស្ថាប័ននិងធនធាន ដែលត្រូវការសម្រាប់កាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែការប៉ាន់ស្មាននេះបង្ហាញពីការចូលរួមចំណែកមួយផ្នែកធំនៃតម្រូវការវិនិយោគសាធារណៈសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។

**៥.៥-** ដើម្បីងាយស្រួលដល់ការអានព័ត៌មានដែលមានបង្ហាញក្នុងជំពូកទី៣ ស្តីពីការព្យាករតម្រូវការវិនិយោគមូលធន សម្រាប់ឆ្នាំ២០១៤-២០១៨ ត្រូវបានសង្ខេបជាអត្ថបទ។ មូលធនសរុបវិនិយោគប្រមាណ១០៩ ០១៦,៩ពាន់លានរៀល (២៦,៩៩ពាន់លានដុល្លារអាមេរិក) នឹងត្រូវការដើម្បីសម្រេចអត្រាកំណើន ផ.ស.ស. ដែលបានព្យាករសម្រាប់រយៈពេលនៃ *ផ.យ.អ.ជ. ២០១៤-២០១៨*។

- វិនិយោគមូលធនរបស់វិស័យឯកជន នឹងមានប្រមាណ៧៧ ៩១៥ពាន់លានរៀល (១៩,១ពាន់លានដុល្លារអាមេរិក) ឬ សមមូលនឹង៧១,៥%នៃទុនវិនិយោគសរុប។
- វិនិយោគមូលធនរបស់វិស័យសាធារណៈ នឹងមានប្រមាណ៣១ ១០១,៧ពាន់លានរៀល (៧,៦០ពាន់លានដុល្លារអាមេរិក) សមមូលនឹង២៨,៥%នៃវិនិយោគមូលធនសរុប។

**៥.៦-** ប្រភពធនធានសម្រាប់តម្រូវការវិនិយោគពីក្នុងស្រុកនិងពីក្រៅប្រទេសសម្រាប់ផ្តល់ហិរញ្ញប្បទានដល់តម្រូវការវិនិយោគសរុប៖

- ៥៤ ៦៤៩ពាន់លានរៀល(១៣,៤ ពាន់លានដុល្លារអាមេរិក) សមមូលនឹង៥០,១%នៃវិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្នុងស្រុក។
- ៥៤ ៣៦៧,៦ពាន់លានរៀល(១៣,៣ ពាន់លានដុល្លារអាមេរិក) សមមូលនឹង៤៩,៩%នៃវិនិយោគមូលធនសរុប ត្រូវបានព្យាករថានឹងទទួលពីប្រភពក្រៅប្រទេស។

**តារាងទី ៥.១ វិនិយោគមូលធនដែលត្រូវការចាំបាច់ដើម្បីសម្រេចបានកំណើន ផ.ស.ស. ដែលបានគ្រោងទុក និងធនធានដែលអាចមានសម្រាប់ហិរញ្ញប្បទានដល់ ឆ្នាំ២០១៤-២០១៨**

(គិតជាពាន់លានរៀល)[១]

| ប្រភពហិរញ្ញប្បទាន | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប ២០១៤-១៨ |
|---|---|---|---|---|---|---|
| **វិនិយោគមូលធន សរុប** | **១៧ ៥១១,៥** | **១៩ ៤៣៤,៩** | **២២ ២៥០,៨** | **២១ ៥៦៦,២** | **២៣ ៥៦១,៥** | **១០៩ ០១៦,៩** |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | **៥ ០៣៧,៨** | **៥ ៥៧០,៩** | **៦ ១៧២ ,៥** | **៦ ៨០៨,២** | **៧ ៥១២,៣** | **៣១ ១០១,៧** |
| ➢ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ១ ២៤០,២ | ១ ៣៧១,៤ | ១ ៥១៩,៥ | ១ ៦៧៦,០ | ១ ៨៤៦,៤ | ៧ ៦៥៦,៥ |
| ➢ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[២] | ៣ ៧៩៧,៦ | ៤ ១៩៩,៥ | ៤ ៦៥៣,០ | ៥ ១៣២,២ | ៥ ៦៦៣,០ | ២៣ ៤៤៥,២ |
| • **វិនិយោគមូលធនវិស័យឯកជន** | **១២ ៤៧៣,៨** | **១៣ ៨៦៤,០** | **១៥ ៣៩៣,៧** | **១៧ ១៣៤,៥** | **១៩ ០៤៩,២** | **៧៧ ៩១៥,២** |
| ➢ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៧ ៦៣០,០ | ៨ ៤២៤,៧ | ៩៤៩០,៣ | ១០ ២៨៣,៤ | ១១ ៣៥២,៤ | ៤៦ ៩៩២,៨ |
| ➢ហិរញ្ញប្បទានដោយធនធានក្រៅប្រទេ[២] | ៤ ៨៤៣,៨ | ៥ ៤៣៩,៣ | ៦ ០៩១,៤ | ៦ ៨៥១,១ | ៧ ៦៩៦,៨ | ៣០ ៩៩២,៤ |
| **វិនិយោគមូលធនសរុប** | **១៧ ៥១១,៥** | **១៩ ៤៣៤,៩** | **២២.២៥០,៨** | **២១ ៥៦៦,២** | **២៣ ៥៦១,៥** | **១០៩ ០១៦,៩** |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | ៥ ០៣៧,៨ | ៥ ៥៧០,៩ | ៦ ១៧២,៥ | ៦ ៨០៨,២ | ៧ ៥១២,៣ | ៣១ ១០១,៧ |
| • **វិនិយោគមូលធនវិស័យឯកជន** | ១២ ៤៧៣,៨ | ១៣ ៨៦៤,០ | ១៥ ៣៩៣,៧ | ១៧ ១៣៤,៥ | ១៩ ០៤៩,២ | ៧៧ ៩១៥,២ |
| **វិនិយោគមូលធនសរុប** | **១៧ ៥១១,៥** | **១៩ ៤៣៤,៩** | **២២.២៥០,៨** | **២១ ៥៦៦,២** | **២៣ ៥៦១,៥** | **១០៩ ០១៦,៩** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៨ ៨៧០,២ | ៩ ៧៩៦,១ | ១០ ៨២១,៩ | ១១ ៩៥៩,៤ | ១៣ ២០១,៧ | ៥៤ ៦៤៩,៣ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[២] | ៨៦៤១,៤ | ៩ ៦៣៨,៨ | ១០ ៧៤៤,៣ | ១១ ៩៨៣,៣ | ១៣ ៣៥៩,៨ | ៥៥ ៣៦៧,៦ |
| **វិនិយោគមូលធនវិស័យសាធារណៈ** | ៥ ០៣៧,៨ | ៥ ៥៧០,៩ | ៦ ១៧២,៥ | ៦ ៨០៨,២ | ៧ ៥១២,៣ | ៣១ ១០១,៧ |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ១ ២៤០,២ | ១ ៣៧១,៤ | ១ ៥១៩,៥ | ១ ៦៧៦,០ | ១ ៨៤៩,៤ | ៧ ៦៥៦,៥ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[២] | ៣ ៧៩៧,៦ | ៤ ១៩៩,៥ | ៤ ៦៥៣,០ | ៥ ១៣២,២ | ៥ ៦៦៣,០ | ២៣ ៤៤៥,២ |

ប្រភព÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, [១]១ដុល្លារអាមេរិក ស្មើនឹង ៤១០០ រៀល, [២] គិតតែសមាសភាគវិនិយោគមូលធនប៉ុណ្ណោះ

**៥.៧-** ការអនុវត្តគោលនយោបាយអាទិភាពរបស់ *ផ.យ.អ.ជ. ២០១៤-២០១៨* ដោយជោគជ័យ និងការសម្រេចបានចំណុចដៅទាំងឡាយតម្រូវឲ្យមានការវិនិយោគ ដែលមានការតម្រង់ទិសត្រឹមត្រូវ និងដំណើរការអនុវត្តតាមពេលកំណត់។ ការវិនិយោគទាំងនេះនឹងត្រូវធ្វើឡើងក្នុងវិស័យឯកជនដើម្បីធានាចីរភាពនិងបង្កើនកំណើន និងពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ជាពិសេសសេដ្ឋកិច្ចតាមជនបទ។ លើសពីនេះទៀត ការវិនិយោគទាំងនេះក៏នឹងត្រូវធ្វើឡើងក្នុងវិស័យសាធារណៈ ដើម្បីផ្តល់ការគាំទ្រដល់ការពង្រីក និងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ជាពិសេសសេដ្ឋកិច្ចជនបទនិងតំបន់ដាច់ស្រយាល ដើម្បីកាត់បន្ថយភាពក្រីក្រ បន្តកាត់បន្ថយផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចសកលលោក ជាពិសេស លើអ្នកក្រ គាំទ្រការពង្រីកនិងការផ្តល់សេវាសង្គមកិច្ច ដើម្បីសម្រេចបាននូវចំណុចដៅ *គ.អ.ស.ក.* និងពង្រឹងសមត្ថភាពនៃស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតកម្មវិធី និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។

**៥.៨-** វិនិយោគមូលធនពីវិស័យឯកជនក្រៅប្រទេសមកប្រទេសកំពុងអភិវឌ្ឍ នៅមានភាពមិនច្បាស់លាស់ ដោយសារវិបត្តិហិរញ្ញវត្ថុសកលលោក និងភាពមិនច្បាស់លាស់ផ្នែកសេដ្ឋកិច្ចរបស់ប្រទេសអភិវឌ្ឍ ប៉ុន្តែការវិនិយោគពីប្រទេសក្នុងអាស៊ាននិងប្រទេសចិន អាចនឹងកើនឡើង។ បន្ថែមលើការសម្របសម្រួលលំហូរមូលធនពីប្រភពទាំងនេះ រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការមួយចំនួន ដើម្បីជំរុញការផ្តល់ហិរញ្ញប្បទានរបស់វិស័យឯកជនក្នុងស្រុកពីវិស័យហិរញ្ញវត្ថុក្នុងស្រុក។ ដូចបានបញ្ជាក់ក្នុងជំពូកទី៣ មានឧបករណ៍ហិរញ្ញវត្ថុថ្មីៗជាច្រើនដែលកំពុងលើកទឹកចិត្ត សម្រាប់តម្រង់ទិសការសន្សំឯកជនទៅជាការវិនិយោគ។ លើសពីនេះទៀត កម្រិតនៃប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ សម្រាប់ការវិនិយោគនៅមានកម្រិតទាបនៅឡើយ ហើយប្រាក់បញ្ញើជាមួយធនាគារពាណិជ្ជ មិនទាន់បានប្រើប្រាស់ពេញលេញសម្រាប់ការវិនិយោគនៅក្នុងប្រទេសនៅឡើយ។ ប្រាក់បញ្ញើទាំងនេះមួយចំនួនត្រូវបានយកទៅវិនិយោគនៅកន្លែងផ្សេងទៀត។ ដូចនេះ អាទិភាពរបស់រាជរដ្ឋាភិបាល គឺការតម្រង់ទិសធនធានទាំងនេះសម្រាប់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា។

**៥.៩-** ចំណុចសំខាន់ក្នុងជំពូកនេះ គឺការបង្ហាញលទ្ធភាពធនធានសម្រាប់វិនិយោគវិស័យសាធារណៈ សម្រាប់ការអនុវត្តគោលនយោបាយអាទិភាពក្នុង *ផ.យ.អ.ជ. ២០១៤-២០១៨*។ តម្រូវការវិនិយោគវិស័យសាធារណៈសរុប រួមមាន៖

- តម្រូវការវិនិយោគមូលធនរបស់វិស័យសាធារណៈ។
- តម្រូវការធនធានសម្រាប់ការគាំទ្រមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍ និងពិពិធកម្មសេដ្ឋកិច្ចជនបទដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។
- តម្រូវការធនធានសម្រាប់ពង្រីកសេវាសង្គមកិច្ច ដើម្បីសម្រេចបាននូវចំណុចដៅគ.អ.ស.ក.។

- តម្រូវការធនធានសម្រាប់ការពង្រឹងសមត្ថភាពនៃស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីនិងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។

**៥.១០-** រាជរដ្ឋាភិបាលបានវិភាជថវិកាប្រមាណ៤៦ ២២៥,៣៨ពាន់លានរៀល(១១,២៧ ពាន់លានដុល្លារអាមេរិក) សម្រាប់វិនិយោគវិស័យសាធារណៈ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ ដូចខាងក្រោម៖

- តម្រូវការវិនិយោគមូលធនវិស័យសាធារណៈ មានប្រមាណ៣១ ១០១,៧ពាន់លានរៀល (៧,៦០ ពាន់លានដុល្លារអាមេរិក)។
- តម្រូវការធនធានសម្រាប់ការគាំទ្រមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍ និងពិពិធកម្មសេដ្ឋកិច្ចជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល រួមទាំងការគ្រប់គ្រងគ្រោះមហន្តរាយ មានប្រមាណ៧ ៥៦០,២២ពាន់លានរៀល(១,៨៤ ពាន់លានដុល្លារអាមេរិក)។
- តម្រូវការធនធានសម្រាប់ពង្រីកសេវាសង្គមកិច្ច ដើម្បីសម្រេចបាននូវចំណុចដៅគ.អ.ស.ក. មានប្រមាណ៣ ៧៨១,៧៣ពាន់លានរៀល(៩២២,៣លានដុល្លារអាមេរិក)។
- តម្រូវការធនធានសម្រាប់ការពង្រឹងសមត្ថភាពនៃស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីនិងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពមានប្រមាណ ៣ ៧៨១,៧៣ពាន់លានរៀល(៩២២,៣លានដុល្លារអាមេរិក)។

**តារាងទី ៥.២ ចំណុចដៅនៃការគៀរគរធនធានសម្រាប់វិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០១៤-២០១៨**

| តម្រូវការវិនិយោគវិស័យសាធារណៈ | ២០១៤-២០១៨ | |
|---|---|---|
| | ពាន់លានរៀល | ពាន់លាន ដុល្លារអាមេរិក |
| ១. វិនិយោគមូលធនរបស់វិស័យសាធារណៈ (ការព្យាករម៉ាក្រូសេដ្ឋកិច្ច) | ៣១ ១០១,៧ | ៧,៦០ |
| ២. ការគាំទ្រមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍនិងពិពិធកម្មសេដ្ឋកិច្ចជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល | ៧ ៥៦០,២២ | ១,៨៤ |
| ៣. ការពង្រីកសេវាសង្គមកិច្ច ដើម្បីឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃគ.អ.ស.ក. | ៣ ៧៨១,៧៣ | ០,៩២ |
| ៤. ការគាំទ្រដល់ការពង្រឹងសមត្ថភាពនៃស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីនិងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព | ៣ ៧៨១,៧៣ | ០,៩២ |
| **សរុប** | **៤៦ ២២២,៣៦** | **១១,២៧** |

## ២. ប្រភពហិរញ្ញប្បទានសក្ដានុពលសម្រាប់ចំណាយវិនិយោគសាធារណៈ

**៥.១១-** ក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម រាជរដ្ឋាភិបាល បានវិភាជ៨ ០០៤,៦ពាន់លានរៀល(១,៩៥ពាន់លានដុល្លារអាមេរិក) សម្រាប់ចំណាយមូលធនវិស័យសាធារណៈ ដែលប្រើប្រាស់សម្រាប់កៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍនានានិងវិស័យឯកជន ដើម្បីអនុវត្តគម្រោងវិនិយោគនានា ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ។ គុណភាពនៃតម្រូវការវិនិយោគវិស័យសាធារណៈសរុបគឺ *តម្រូវការវិនិយោគសរុប៤៦ ២២៥,៣៨ពាន់លានរៀល ដកនឹងការវិនិយោគដែលផ្ដល់ហិរញ្ញប្បទានពីរាជរដ្ឋាភិបាល៨ ០០៤,៦ពាន់លានរៀល* ស្មើនឹង៣៨ ២២០,៧៨ពាន់លានរៀល(៩,៣២ពាន់លានដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៤-២០១៨ ឬប្រមាណ៧,៦៤៤ពាន់លានរៀល(១,៨៦ពាន់លានដុល្លារអាមេរិក)ក្នុង១ឆ្នាំ។ ការប៉ាន់ស្មាននេះត្រូវបានធ្វើឡើងនៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយលទ្ធភាពនៃការកែសម្រួលអាចនឹងធ្វើឡើងនៅពេលមានកំណើនសេដ្ឋកិច្ច និងប្រសិទ្ធភាពក្នុងការកៀរគរធនធានក្នុងស្រុក។

**៥.១២-** គម្លាតនេះនឹងត្រូវបំពេញដោយហិរញ្ញប្បទានពី៖

- ហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍប្រពៃណីនានា(ទ្វេភាគី ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល)។
- ហិរញ្ញប្បទានឥណទានសម្បទានពីដៃគូអភិវឌ្ឍ(ភាគច្រើនស្ថាប័នហិរញ្ញវត្ថុពហុភាគី)។
- ធនធានពីប្រភពមិនប្រពៃណី ដោយរួមបញ្ចូលដៃគូអភិវឌ្ឍមិនមែនប្រពៃណី ទាំងហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទានសម្បទាន។
- ប្រភពចំណូលថ្មីពីការអភិវឌ្ឍវិស័យឧស្សាហកម្ម ដូចជាប្រេង ឧស្ម័ន និងរ៉ែ និងពីការដាំដំណាំ និងសម្បទានសេដ្ឋកិច្ចលើវិស័យកសិកម្ម ជាពិសេស កៅស៊ូ។
- ពន្ធបន្ថែម។
- ឥណទានពីប្រភពក្នុងស្រុកតាមរយៈឧបករណ៍ហិរញ្ញវត្ថុថ្មីៗ។

**៥.១៣-** យោងតាមកិច្ចព្រមព្រៀងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ជាមួយដៃគូអភិវឌ្ឍ(ទាំងប្រពៃណីនិងមិនមែនប្រពៃណី) រាជរដ្ឋាភិបាលសង្ឃឹមថាដៃគូអភិវឌ្ឍទាំងអស់នឹងចាត់វិធានការបន្ទាន់ក្នុងការផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ តាមរយៈការគាំទ្រថវិកាដែលបានផ្សារភ្ជាប់ជាមួយចំណុចដៅនៅក្នុងវិស័យនីមួយៗ។ ការអនុម័តការគាំទ្រថវិកាអាចអនុវត្តបានតាម៣វិធី៖

- ពង្រឹងភាពជាម្ចាស់និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលលើគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍អាទិភាពទាំងឡាយ។

- ជំរុញឲ្យមានការតាមដានត្រឹមត្រូវ និងគណនេយ្យភាព និងតម្លាភាពនៃហិរញ្ញប្បទានក្រៅប្រទេស។
- ពង្រឹងគណនេយ្យភាពក្នុងប្រទេសតាមរយៈស្ថាប័ន យន្តការដែលមានស្រាប់ ឬទទួលស្គាល់ដោយប្រទេសសាមីសម្រាប់ការទទួលនិងការប្រើប្រាស់ហិរញ្ញប្បទានក្រៅប្រទេស។

**៥.១៤-** រាជរដ្ឋាភិបាល នឹងបន្តផ្តល់ការយកចិត្តទុកដាក់លើការឆ្ពោះទៅរកការគាំទ្រថវិកាជាយន្តការមួយ សម្រាប់ផ្តល់ការគាំទ្រដល់ដៃគូអភិវឌ្ឍនានា។

**៥.១៥-** ដើម្បីពង្រឹងភាពបន្សុំ និងសុខដុមនីយកម្មនៃកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ជាមួយគោលនយោបាយអាទិភាព *ផ.យ.អ.ជ. ២០១៤-២០១៨* រាជរដ្ឋាភិបាលជំរុញដៃគូអភិវឌ្ឍផ្តល់ការគាំទ្រដល់ការអភិវឌ្ឍដែលមានលក្ខណៈអភិក្រមទូទាំងវិស័យ ឬគោលការណ៍ដោយផ្អែកលើកម្មវិធីសម្រាប់វិស័យសំខាន់ៗ និងដើម្បីផ្តល់ការគាំទ្រសម្រាប់អនុវត្តកម្មវិធីអភិក្រមទូទាំងវិស័យ ដើម្បីសម្រេចបានសមិទ្ធផលរួម និងជៀសវាងការងារត្រួតគ្នា។ រាជរដ្ឋាភិបាល ក៏បានទទួលស្គាល់ថាប្រតិបត្តិការនៃក្រុមការងារបច្ចេកទេស នឹងត្រូវកែសម្រួលឡើងវិញ និងពង្រឹងបន្ថែមដើម្បីអនុវត្តការងារសុខដុមនីយកម្មហិរញ្ញប្បទាន។

**៥.១៦-** រាជរដ្ឋាភិបាល នឹងធ្វើការជាមួយដៃគូអភិវឌ្ឍ ដើម្បីពង្រឹងយន្តការក្រុមការងារបច្ចេកទេសដែលមានស្រាប់ដើម្បីពង្រឹងប្រសិទ្ធភាព ជាពិសេស ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់ការអភិវឌ្ឍធនធានមនុស្សនិងសមត្ថភាពស្ថាប័ន និងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់។ រាជរដ្ឋាភិបាលនឹងសម្របសម្រួលនិងកែសម្រួលតួនាទីរបស់ក្រុមការងារបច្ចេកទេសដើម្បីបង្កើនប្រសិទ្ធភាព។ ជម្រើសទាំងឡាយមានដូចខាងក្រោម៖

- ការកំណត់សមាជិកភាពនៃដៃគូអភិវឌ្ឍនៅក្នុងក្រុមការងារបច្ចេកទេសមួយ ចំពោះដៃគូអភិវឌ្ឍទាំងឡាយណាដែលបានផ្តល់ការគាំទ្រហិរញ្ញវត្ថុ ឬបច្ចេកទេសដល់វិស័យពាក់ព័ន្ធ។ ដៃគូអភិវឌ្ឍផ្សេងទៀត អាចសម្រេចចិត្តចូលរួមក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសក្នុងនាមជាអ្នកសង្កេតការណ៍។
- ដើម្បីពង្រឹងគុណភាពនិងកម្រិតការពិភាក្សានៅក្រុមការងារបច្ចេកទេស រាជរដ្ឋាភិបាលចង់ឃើញពីការចូលរួមរបស់បុគ្គលិកដែលមានជំនាញបច្ចេកទេស ក្នុងការផ្តល់ការណែនាំនិងការគាំទ្រដល់វិស័យនោះ។ ការចូលរួមនៃបុគ្គលិករដ្ឋបាលរបស់ស្ថាប័នដៃគូអភិវឌ្ឍមិនត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងកិច្ចប្រជុំឡើយ។ ដៃគូអភិវឌ្ឍត្រូវបានស្នើឲ្យចាត់

ជំនាញការបច្ចេកទេស ក្នុងផ្នែកនៃវិស័យរបស់ក្រុមការងារបច្ចេកទេស ដើម្បីចូលរួមក្នុងកិច្ចប្រជុំទាំងអស់។

- របៀបវារៈដែលមានព័ត៌មានលម្អិត នឹងផ្សព្វផ្សាយជាមុន ហើយកំណត់ហេតុនៃកិច្ចប្រជុំចុងក្រោយត្រូវបានរក្សាទុក ផ្សព្វផ្សាយ និងទាញយកមកវិញនៅពេលចាំបាច់។

**៥.១៧-** ភាពជាដៃគូសកលកម្រិតខ្ពស់ បានប្រមូលផ្តុំទៅជួយប្រជាជនក្រីក្រ ឬបណ្តាប្រទេសស្ថិតក្នុងអន្តរកាលនិងក្រោយពេលបញ្ចប់សង្គ្រាម ដើម្បីសម្រេចបាន*គ.អ.ស.ក.* និងដើម្បីផ្តល់ហិរញ្ញប្បទានដែលមានតម្រូវការ។ ក្នុងភាពជាដៃគូសកល រាជរដ្ឋាភិបាលនឹងបន្តជំរុញដៃគូអភិវឌ្ឍ ដើម្បីធានាឲ្យហិរញ្ញប្បទានទាំងអស់ត្រូវបានបន្សុីគ្នានិងឈានទៅសម្រេចបានគោលនយោបាយអាទិភាពនៅក្នុង*ផ.យ.អ.ជ. ២០១៤-២០១៨* នៅកម្រិតប្រតិបត្តិការលម្អិតដែលមិនគិតត្រឹមកម្រិតទូលាយឡើយ។ រាជរដ្ឋាភិបាលនឹងជំរុញដៃគូអភិវឌ្ឍធ្វើការរិភាជធនធានឡើងវិញឲ្យបានឆាប់រហ័ស ដោយកាត់បន្ថយពីវិស័យអាទិភាពទាប ខិតខំបន្ថយ*ជំនួយបច្ចេកទេសដែលមានលក្ខណៈដាច់ដោយឡែកៗ* និងធ្វើការងារឆ្ពោះទៅសម្រេចបាននូវ*ការផ្ទេរពិតប្រាកដ* នៃធនធានអភិវឌ្ឍន៍ទៅលើវិស័យអាទិភាព គឺការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ការលើកកម្ពស់ធនធានមនុស្ស ការជួយដល់ជនងាយរងគ្រោះនិងប្រជាជនក្រីក្រនិងពង្រឹងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីផ្តល់កម្មវិធីនិងសេវាប្រកបដោយប្រសិទ្ធភាព។

## ៣. កម្មវិធីចំណាយ: ចំណាយវិនិយោគសាធារណៈ និងហិរញ្ញប្បទានសហប្រតិបត្តិការ

**៥.១៨-** រាជរដ្ឋាភិបាល កំពុងចាត់វិធានការពង្រឹងសុខដុមនីយកម្មការងារផែនការ ផែនការចំណាយវិនិយោគសាធារណៈ ការរិភាជនិងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ មានសមាជិកពីស្ថាប័នរាជរដ្ឋាភិបាលកណ្តាលទាំង៤ដែលដឹកនាំដោយក្រសួងផែនការ ត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំដំណើរការសិក្សានិងវាយតម្លៃឡើងវិញនូវតួនាទីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលព្រមទាំងយន្តការនិងអភិក្រមពាក់ព័ន្ធនឹងការរៀបចំផែនការ ការគ្រប់គ្រង សម្របសម្រួលនិងការអនុវត្តចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ។
- ដឹកនាំដំណើរការសិក្សានិងលើកសំណើវិធានការធ្វើសុខដុមនីយកម្មចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីឲ្យមានការឯកភាពគ្នា

តែមួយ មានលំដាប់លំដោយតាមប្រតិទិន ប្រកបដោយភាពស៊ីចង្វាក់ ដែលអាចបង្កើតបានជាផែនការចំណាយថវិកាដ៏ល្អនិងគ្រប់ជ្រុងជ្រោយ ព្រមទាំងមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រតាមវិស័យ ដូចមានកំណត់ក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

**៥.១៩-** បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងពង្រឹងទំនាក់ទំនងរវាងដំណើរការៈ

- កំណត់តម្រូវការវិនិយោគសាធារណៈ ដែលមានអាទិភាពខ្ពស់ ដូចមានចែងនៅក្នុង *ផ.យ.អ.ជ.* ដែលមានរយៈពេល៥ឆ្នាំ និង *ក.វ.ស. ៣ឆ្នាំរំកិល*។
- កៀរគរធនធានក្រៅប្រទេសពីដៃគូអភិវឌ្ឍប្រពៃណី និងមិនមែនប្រពៃណី។
- រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា។

**៥.២០-** រាជរដ្ឋាភិបាល នឹងកែសម្រួលវិធីសាស្ត្រក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការៀបចំធនធានវិនិយោគសាធារណៈនាពេលអនាគតបន្ថែមទៀត ដែលនឹងក្លាយជាឧបករណ៍ប្រតិបត្តិនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៅក្នុង*ផ.យ.អ.ជ. ២០១៤-២០១៨*។ ដំណើរការនៃការរៀបចំ *ក.វ.ស. ៣ឆ្នាំរំកិល* នឹងពង្រឹងបន្ថែមទៀតដើម្បីធានាថាៈ

- តម្រូវការចំណាយចរន្តបន្ថែមរបស់គម្រោងថ្មីៗដែលប្រើសម្រាប់រៀបចំថវិកាជាតិ គឺជាព័ត៌មានចាំបាច់ ដែលប្រមូលនៅក្នុងការរៀបចំ *ក.វ.ស.*។
- គម្រោងដែលមានក្នុង *ក.វ.ស.* គឺជាគម្រោងដែលមានអាទិភាពខ្ពស់ ហើយក្រសួង ស្ថាប័ននឹងកំណត់លំដាប់អាទិភាពដល់គម្រោងដែលកំពុងស្វែងរកប្រភពហិរញ្ញប្បទាន ដើម្បីអនុវត្តក្នុងរយៈពេលនៃ *ក.វ.ស.* ដែលបានពិចារណាពីបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ដើម្បីកៀរគរហិរញ្ញប្បទានក្រៅប្រទេស ដោយផ្អែកលើនិន្នាការថ្មីៗនេះ។

**៥.២១-** រាជរដ្ឋាភិបាល នឹងធានាថាកម្មវិធី និងគម្រោងនៅក្នុង *ក.វ.ស.* ត្រូវបានពិចារណាសម្រាប់ផ្តល់ហិរញ្ញប្បទានក្នុងពេលរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា។ រាជរដ្ឋាភិបាល ក៏នឹងធានាថាសកម្មភាពកៀរគរធនធាន បានផ្តោតលើការស្វែងរកហិរញ្ញប្បទានសម្រាប់កម្មវិធីនិងគម្រោងនៅក្នុង *ក.វ.ស.*។ ដើម្បីធានាពីភាពស៊ីគ្នារវាងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ជាមួយអាទិភាពវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល ទិន្នន័យដែលប្រមូលប្រចាំឆ្នាំពីដៃគូអភិវឌ្ឍ ដោយរាជរដ្ឋាភិបាលស្តីពីចំណាយពិតប្រាកដ និងចំណាយប៉ាន់ស្មាននៃហិរញ្ញប្បទានរបស់ពួកគេ នឹងត្រូវបានវិភាគដោយក្រសួង ស្ថាប័ន ហើយក្រសួង ស្ថាប័ននីមួយៗនឹងទទួលបានព័ត៌មាន ដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់ថាព័ត៌មានស្តីពីការចំណាយត្រូវបានរាយការណ៍ដល់

ក្រសួង ស្ថាប័ន និងដើម្បីផ្តល់យោបល់ត្រឡប់វិញស្តីពីគម្រោងឬកម្មវិធីដែលមានហិរញ្ញប្បទាន ដែលបានបន្សុីជាមួយគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងគម្រោងឬកម្មវិធីដែលមានហិរញ្ញប្បទាន ដែលមិនបានបន្សុីជាមួយគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

**៥.២២-** ការកែសម្រួលវិធីសាស្ត្រទាំងនេះ នឹងជានាំឲ្យមានទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងគោលនយោបាយអាទិភាព សកម្មភាព កម្មវិធី និងគម្រោងនានារបស់រាជរដ្ឋាភិបាល និងតម្រូវការធនធានវិនិយោគសាធារណៈ ដើម្បីអនុវត្តសកម្មភាពនានាដែលបានគ្រោងទុក។ ដំណើរការនេះនឹងបង្កើតទំនាក់ទំនងជិតស្និទ្ធរវាងតម្រូវការវិនិយោគសាធារណៈ ដែលបានកំណត់ក្នុងដំណើរការរៀបចំផែនការ និងថវិកាវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល និងធនធានសហប្រតិបត្តិការអភិវឌ្ឍន៍ដែលនឹងផ្តល់ហិរញ្ញប្បទានហិរញ្ញប្បទានរយៈពេលមធ្យម ដល់រាជរដ្ឋាភិបាលនៅពេលអនុវត្ត *ផ.យ.អ.ជ.*។ ការកែសម្រួលនេះមានទំនាក់ទំនងនិងមានគោលបំណងកែលម្អយ៉ាងទូលំទូលាយថវិកាជាតិ ដែលបានគ្របដណ្តប់ថវិកាចរន្តនិងថវិកាមូលធន នឹងជានាំឲ្យមានការពង្រឹងប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃការវិភាជថវិកា។

**៥.២៣-** សម្រាប់ *ផ.យ.អ.ជ. ២០១៤-២០១៨* ការវិភាជថវិកាចំណាយចរន្តដោយក្រសួងស្ថាប័ន ក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម មានបង្ហាញក្នុងជំពូកទី៣។ ការវិភាជចំណាយមូលធន និងចំណាយសម្រាប់វិធានការពិសេស ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោកមកលើសេដ្ឋកិច្ចនិងជនងាយរងគ្រោះ និងប្រជាជនក្រីក្រ មានបង្ហាញក្នុងតារាងទី៥.៣។

### តារាងទី ៥.៣ វិភាជន៍តាមវិស័យនិងអនុវិស័យនៃវិនិយោគវិស័យសាធារណៈក្នុងផ.យ.អ.ជ. ២០១៤-២០១៨

| វិស័យ | ភាគរយ | បរិមាណវិភាជន៍ ២០១៤-២០១៨ | |
|---|---|---|---|
| | | ពាន់លានរៀល | លានដុល្លារអាមេរិក |
| **វិស័យសង្គមកិច្ច** | | | |
| អប់រំៈ ក្នុងនោះការអប់រំមូលដ្ឋាន៦០% | ១២ | ៣ ៧៣២,៨ | ៩១០,៤ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| សុខាភិបាល | ១២ | ៣ ៧៣២,៨ | ៩១០,៤ |
| កម្មវិធីជួយកាត់បន្ថយផលប៉ះពាល់ ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុសកលលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| សរុប | ៣២ | ៩ ៩៥៤,២ | ២ ៤២៧,៨ |
| **វិស័យសេដ្ឋកិច្ច** | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| ដំណាំតាមរដូវៈ ស្រូវនិងផ្សេងៗ | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| អភិវឌ្ឍន៍ជនបទ | ១២ | ៣ ៧៣២,៨ | ៩១០,៤ |
| កម្មន្តសាល រ៉ែនិងពាណិជ្ជកម្ម | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| សរុប | ២៤ | ៧ ៤៦៥,៧ | ១ ៨២០,៩ |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ៣ ៧៣២,៨ | ៩១០,៤ |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| ថាមពលនិងអគ្គិសនី | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ៣១១,១ | ៧៥,៨ |
| សរុប | ២១ | ៦ ៥៣២,៥ | ១ ៥៩៣,២ |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | |
| ការបញ្ជ្រាបយេនឌ័រ | ១,៥ | ៤៦៦,៦ | ១១៣,៨ |
| ទេសចរណ៍ | ២ | ៦២២,១ | ១៥១,៧ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| សហគមន៍និងសេវាសង្គម | ៤ | ១ ២៤៤,៣ | ៣០៣,៥ |
| វប្បធម៌និងសិល្បៈ | ១,៥ | ៤៦៦,៦ | ១១៣,៨ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ២ ៤៨៨,៦ | ៦០៦,៩ |
| សរុប | ២១ | ៦ ៥៣២,៥ | ១ ៥៩៣,២ |
| **មិនទាន់បែងចែក** | ២ | ៦២២,១ | ១៥១,៧ |
| សរុបរួម | ១០០ | ៣១ ១០៧,០ | ៧ ៥៨៦,៨ |

# ជំពូកទី៦

# ការតាមដាន
# ត្រួតពិនិត្យ
# និង វាយតម្លៃ

# ជំពូកទី៦

# ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ១- សេចក្តីផ្តើម

៦.១- រាជរដ្ឋាភិបាល បានដាក់ចេញក្របខ័ណ្ឌគោលនយោបាយតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ *ផ.អ.យ.ជ. ២០១៤-២០១៨* ដែលនឹងផ្តល់ឲ្យអ្នករៀបចំផែនការ និងអ្នកអនុវត្ត នូវការវាយតម្លៃវឌ្ឍនភាពដែលទទួលបាននៅតាមគម្រោង កម្មវិធី វិស័យ ឬដំណើរការអភិវឌ្ឍទាំងមូល។ ក្របខ័ណ្ឌនេះរួមមាន៖

- ការយកចិត្តទុកដាក់លើការសម្រេចបានលទ្ធផលអភិវឌ្ឍ។
- ការពង្រឹងសមត្ថភាពនៅក្នុងក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់។
- ការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធ ដូចជាដៃគូអភិវឌ្ឍ វិស័យឯកជន ស្ថាប័នថ្នាក់ក្រោមជាតិជាដើម ក្នុងភាពជាដៃគូដែលមានប្រសិទ្ធភាព ដោយមានការសម្របសម្រួលពីរាជរដ្ឋាភិបាល។

៦.២- ក្របខ័ណ្ឌការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មានគោលបំណងពិពណ៌នាពីសមិទ្ធផលឬកង្វះខាតណាមួយ ដោយពិនិត្យមើលពីលទ្ធផល និងកត្តាដែលពាក់ព័ន្ធទាំងអស់។ លើសពីនេះ ដោយសារដំណើរការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ត្រូវមានភស្តុតាងជាចាំបាច់ ដូចនេះវានឹងធ្វើជាប្រភពទិន្នន័យសំខាន់សម្រាប់សូចនាករមួយចំនួន សម្រាប់ការរៀបចំផែនការ និងកម្មវិធី។

## ២- ក្របខ័ណ្ឌការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ក្នុងវដ្ត ផ.យ.អ.ជ. ២០១៤-២០១៨

### ក- ក្របខ័ណ្ឌលទ្ធផល

៦.៣- ស្នូលនៃក្របខ័ណ្ឌការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ផែនការនេះ គឺក្របខ័ណ្ឌលទ្ធផល ដែលជាការគ្រប់គ្រងមួយសម្រាប់កំណត់លទ្ធផលនិងសកម្មភាពគ្រប់កម្រិត ដូចជាកម្មវិធី/អនុកម្មវិធី ក្រសួង/វិស័យ និងសេដ្ឋកិច្ចទាំងមូល។ ក្របខ័ណ្ឌនេះនឹងកំណត់ពីភាពស៊ីគ្នារវាងកិច្ចប្រឹងប្រែងដែលធ្វើឡើង សម្រាប់ការសម្រេចបានគោលដៅសំខាន់ៗដោយមានសមិទ្ធផលនិងលទ្ធផលជាក់ស្តែង។ ក្របខ័ណ្ឌលទ្ធផល បង្ហាញពីទំនាក់ទំនងរវាងការវិភាជធនធាន ដំណើរការអនុវត្ត/ធាតុចេញ លទ្ធផល និងឥទ្ធិពល។

៦.៤- ក្របខ័ណ្ឌលទ្ធផលនៅកម្រិតគម្រោង ឬកម្មវិធីត្រូវបានបង្ហាញក្នុងចង្វាក់លទ្ធផលដែលកំណត់ពីធនធាន និងសកម្មភាពដែលត្រូវអនុវត្តក្នុងគម្រោង បន្ទាប់មកទៀតផ្សារភ្ជាប់នឹងដំណើរការអនុវត្ត លទ្ធផល និងឥទ្ធិពល។

៦.៥- ក្របខ័ណ្ឌលទ្ធផលសម្រាប់គម្រោង ឬកម្មវិធី មានបង្ហាញក្នុងរូបភាព៦.១ ដោយបានបង្ហាញពីធាតុចូល ធាតុចេញ លទ្ធផល និងឥទ្ធិពល។ *ធាតុចូល*អាចមានដូចជាថវិកា ធនធានមនុស្ស ច្បាប់ ចំណេះដឹង និងធនធានរូបវន្ត។ *ធាតុចេញ* ត្រូវបានបង្កើតចេញពីការប្រើប្រាស់អគារ របាយការណ៍ រោងចក្រ និងម៉ាស៊ីន បុគ្គលិក ជាដើម។ លទ្ធផលទាំងនេះ នឹងអាចជួយដល់កំណើនសេដ្ឋកិច្ច (ឧទាហរណ៍ ការិយាល័យនឹងជួយដល់ការបង្កើនផលិតកម្ម ឬការផ្តល់ សេវាសម្រាប់លើកកម្ពស់ផលិតភាព សម្រាប់យេនឌ័រ *លទ្ធផល* គឺស្ត្រីត្រូវបានទទួលការបណ្តុះបណ្តាលដើម្បីទទួលបានការងារប្រសើរជាងមុន)។ *ឥទ្ធិពល* គឺការលើកកម្ពស់សុខុមាលភាពប្រជាជន ស្ថានភាពស្ត្រីប្រសើរជាងមុន។

៦.៦- រូបភាព៦.១ បង្ហាញពីការវិភាគលើដំណាំកសិកម្ម ដែលបង្ហាញពីទំនាក់ទំនងរវាងធាតុចូល ធាតុចេញ លទ្ធផល និងឥទ្ធិពលៈ

- ធាតុចូល មានដូចជាដី ឥណទាន ជី ចំណេះធ្វើបែបទំនើប ជាដើម ដែលចូលរួមចំណែកដល់ការបង្កើតលទ្ធផល។
- ប្រសិនបើធាតុចូលត្រូវបានប្រើប្រាស់បង្កើតជាលទ្ធផលប្រកបដោយប្រសិទ្ធផលនោះ ធាតុ ចេញនឹងកើតមានដូចជា សេវាវិបុលកម្មប្រសើរជាងមុន បុគ្គលិកបានទទួលការបណ្តុះបណ្តាលជាដើម។
- ប្រសិនបើធាតុចេញទាំងនេះត្រូវបានប្រើប្រាស់សម្រាប់បង្កើតជាលទ្ធផលប្រកបដោយប្រសិទ្ធភាព នោះនឹងជួយបង្កើនទិន្នផលដំណាំ ជួយដល់ការធ្វើពិពិធកម្មដំណាំ និងបង្កើនសកម្មភាពសេដ្ឋកិច្ចក្នុងសេដ្ឋកិច្ចសហគមន៍ ដូចជាការដឹកជញ្ជូន និងការធ្វើទីផ្សារ។
- ប្រសិនបើទិន្នផលបានប្រសើរឡើង និងសមិទ្ធផលផ្សេងៗទៀតជួយដល់កសិករ នោះកម្រិតជីវភាពរបស់ប្រជាជននឹងបានប្រសើរឡើង។

**រូបភាព៦.១ ចង្វាក់លទ្ធផល: ធាតុចូល ធាតុចេញ លទ្ធផល ឥទ្ធិពល**

| ចង្វាក់លទ្ធផល | ការវិភាគលើដំណាំកសិកម្ម |
|---|---|
| ឥទ្ធិពល | ចំណូលនិងអាហារូបត្ថម្ភ ការនាំចេញ ជាដើមប្រសើរជាងមុន →កម្រិតជីវភាពប្រសើរជាងមុន |
| លទ្ធផល | ទិន្នផលប្រសើរជាងមុន ដំណាំកាន់តែច្រើនក្នុង១ឆ្នាំ ពិពិធកម្មដំណាំ និងសកម្មភាពមិនមែនដំណាំ |
| ធាតុចេញ | សេវាវិបុលកម្ម បុគ្គលិកទទួលបានការបណ្តុះបណ្តាល ប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ មធ្យោបាយក្នុងការធ្វើកសិកម្មបែបទំនើប កសិករទទួលបានការបណ្តុះបណ្តាល ជាដើម |
| ធាតុចូល | ដី ឥណទាន គ្រាប់ពូជ ជី ប្រព័ន្ធធារាសាស្ត្រ ចំណេះដឹងពីការធ្វើទំនើបកម្មដីនិងការដាំដុះ តាមរយៈការពង្រឹងសេវាវិបុលកម្ម អាកាសធាតុ ព័ត៌មានទីផ្សារ និងតម្លៃ |

៦.៧- តាមក្របខ័ណ្ឌលទ្ធផល ត្រូវមានការផ្ទៀងផ្ទាត់មួយចំនួន ដូចជាតើអាចសម្រេចបានធាតុចេញដែរឬទេ ដោយប្រើប្រាស់ធាតុចូលដែលបានកំណត់? ឧទាហរណ៍ តើអាចសាងសង់សាលារៀនមួយបានទេ ប្រសិនបើមានស៊ីម៉ងត៍ ដែក ពលកម្ម និងធាតុចូលផ្សេងៗទៀត? បើដូច្នេះទេ តើអាចសម្រេចបានលទ្ធផលដែរឬទេ ប្រសិនបើមានធាតុចេញទាំងអស់ហើយ? ឧទាហរណ៍ តើសាលារៀននឹងមានគ្រប់គ្រាន់សម្រាប់កុមារចូលរៀនដែរឬទេ? គម្រោងទាំងនេះតម្រូវឲ្យមានការអនុវត្តក្នុងគ្រប់ករណីទាំងអស់ ប្រសិនអាចសម្រេចលទ្ធផល។ ប្រសិនគម្រោងនេះត្រូវបានអនុវត្ត ដើម្បីសម្រេចបានលទ្ធផលដែលកើតឡើងពីធាតុចូលសម្រេចបានជាធាតុចេញ និងឈានទៅជាលទ្ធផល/ឥទ្ធិពល ដែលមុនពេលចាប់ផ្តើមអនុវត្តគម្រោងនេះ ត្រូវធ្វើការកំណត់និងវិភាគឲ្យច្បាស់លាស់។ ក្របខ័ណ្ឌលទ្ធផល រួមជាមួយការវិភាគលម្អិតអាចជួយដល់ការកំណត់ក្នុងការរកដំណោះស្រាយសម្រាប់បញ្ហាទាំងឡាយ។ ក្រសួងផែនការកំពុងដំណើរការការងារគម្រោងទាំងនេះ ដែលនឹងមានបង្ហាញនៅផ្នែកខាងក្រោម។ ករណីក្រសួង ស្ថាប័នត្រូវការជំនួយបច្ចេកទេសសម្រាប់ការវិភាគនេះ ក្រសួងផែនការនឹងចូលរួមរៀបចំការវិភាគនេះជាមួយក្រសួង ស្ថាប័ន។

៦.៨- ក្នុងវដ្តផែនការនេះ រាជរដ្ឋាភិបាលស្នើដល់ក្រសួង ស្ថាប័នទាំងអស់ឲ្យរៀបចំក្របខ័ណ្ឌលទ្ធផលនៅ៣កម្រិត គឺកម្រិតជាតិ កម្រិតវិស័យ និងកម្រិតកម្មវិធី ដែលត្រូវមានសង្គតិភាពជាមួយគ្នាទាំង៣កម្រិត។ កម្មវិធីការងារត្រូវផ្សារភ្ជាប់ទៅនឹងលទ្ធផលកម្រិតវិស័យ ហើយលទ្ធផលកម្រិតវិស័យត្រូវផ្សារភ្ជាប់នឹងលទ្ធផលកម្រិតជាតិ។

## ខ- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅកម្រិតក្រសួងនិងវិស័យ

៦.៩- ក្រសួង ស្ថាប័ននីមួយៗមានការទទួលខុសត្រូវ ក្នុងការអនុវត្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ធាតុចូល ធាតុចេញ ដែលការចំណាយរបស់ក្រសួងស្ថាប័ន សម្រាប់

គម្រោង កម្មវិធីផ្សេងៗ ដើម្បីសម្រេចលទ្ធផល។ ការងារនេះ បង្កើតបានជាមូលដ្ឋាននៃក្របខ័ណ្ឌលទ្ធផលនៅកម្រិតគម្រោង/កម្មវិធី ដូចមានក្នុង រូបភាព៦.១។

៦.១០- ក្រសួង ស្ថាប័ន នឹងអនុវត្តគម្រោងនិងកម្មវិធីរបស់ខ្លួន ស្របតាមរចនាសម្ព័ន្ធកម្មវិធី។ រចនាសម្ព័ន្ធកម្មវិធី មានសង្គតិភាពជាមួយថវិកា និងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ក្រសួង ស្ថាប័នមួយអាចមានកម្មវិធីច្រើនសម្រាប់អនុវត្ត រួមទាំងការងាររដ្ឋបាលសម្រាប់ប្រតិបត្តិប្រចាំថ្ងៃ ហើយកម្មវិធីនីមួយៗអាចមានអនុកម្មវិធីនិងសកម្មភាពច្រើន។

៦.១១- រូបភាព៦.២ បង្ហាញពីទំនាក់ទំនងរបស់រចនាសម្ព័ន្ធកម្មវិធី ថវិកា និងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ រូបភាពនេះ បង្ហាញពីឋានានុក្រមលម្អិត ដែលគោលនយោបាយនឹងត្រូវបំបែកជាយុទ្ធសាស្ត្រ ហើយយុទ្ធសាស្ត្រនឹងបំបែកទៅជាកម្មវិធី និងអនុកម្មវិធីដែលអាចអនុវត្តបាន។ សម្រាប់កម្មវិធី និងអនុកម្មវិធីនីមួយៗ ត្រូវផ្សារភ្ជាប់ជាមួយថវិកាសម្រាប់អនុវត្ត ដែលកម្មវិធីនិងថវិកា ត្រូវមានសង្គតិភាពជាមួយគ្នា។ កម្រិតកម្មវិធី គឺជាមូលដ្ឋានសម្រាប់ការកំណត់សូចនាករនិងសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ក្រសួង ស្ថាប័ននឹងត្រូវកំណត់សូចនាករទាំងឡាយ សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៅតាមកម្រិតនីមួយៗ។

**រូបភាព៦.២-រចនាសម្ព័ន្ធកម្មវិធីនិងគោលបំណង កម្រិតក្រសួង ស្ថាប័ន**



## គ- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់ជាតិ

### *ក្របខ័ណ្ឌលទ្ធផលនៅកម្រិតម៉ាក្រូ*

៦.១២- ក្រសួងផែនការមានតួនាទីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសូចនាករលទ្ធផល និងឥទ្ធិពលនៅកម្រិតម៉ាក្រូ ដើម្បីវាយតម្លៃវឌ្ឍនភាព ដែលសម្រេចបានក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងស្ថានភាពសុខុមាលភាពរបស់ប្រជាជន។

៦.១៣- នៅកម្រិតជាតិ/សេដ្ឋកិច្ច លទ្ធផល និងឥទ្ធិពលកើតចេញពីធាតុចូល និងធាតុចេញរបស់គម្រោងនិងកម្មវិធីរបស់ក្រសួង ស្ថាប័ន។ ដូចនេះ មានន័យថា នៅកម្រិតជាតិមិនចាំបាច់វាស់វែងធាតុចូល និងធាតុចេញ ឡើងវិញទេ ដោយសារត្រូវបានលើកឡើងរួចហើយនៅកម្រិតក្រសួង វិស័យ ឬកម្មវិធី។

៦.១៤- ក្នុងន័យនេះ បណ្តាលទ្ធផល និងឥទ្ធិពល កើតចេញមកពីបណ្តុំធាតុចូល ទាំងអស់ដែលជាព័ត៌មានសំខាន់។ លើសពីនេះ ធាតុចូលមួយចំនួនអាចធ្វើការវាស់វែង និងខ្លះទៀតគឺមិនអាចវាស់វែងបាន ដែលទាមទារការប៉ាន់ស្មាន ឬក៏ប្រើអញ្ញតជំនួស។ ឧទាហរណ៍ អត្រាកាត់បន្ថយភាពក្រីក្រ ដែលជាសូចនាករឥទ្ធិពល គឺអាចមានទំនាក់ទំនងគ្នាជាមួយសកម្មភាពមួយចំនួនកើតចេញពីកត្តាទីផ្សារ និងមិនមែនទីផ្សារ កត្តាពីខាងក្រៅ ដូចជា គម្រោងផ្សេងៗ និងគោលនយោបាយ អន្តរាគមន៍ ការវិនិយោគឯកជន និងសាធារណៈ បរិស្ថានខាងក្នុង និងខាងក្រៅ និងលទ្ធភាពនៃការទទួលបានការសិក្សាអប់រំ ឬប្រព័ន្ធផ្សព្វផ្សាយ។ ក៏ប៉ុន្តែ ធាតុចូលមួយចំនួនដែលផ្សារភ្ជាប់ជាមួយនឹងលទ្ធផលឬឥទ្ធិពល(អត្រាភាពក្រីក្រ) គឺមានភាពលំបាកក្នុងការវាស់វែង ជាពិសេស ចំណាយវិនិយោគសាធារណៈ ដោយរដ្ឋាភិបាលនិងពីដៃគូឯកជន ។

៦.១៥- រាជរដ្ឋាភិបាលកម្ពុជា នឹងកែសម្រួលចំណុចដៅរបស់សូចនាករលទ្ធផល និងឥទ្ធិពលនីមួយៗ ដោយផ្អែកលើការវាយតម្លៃលទ្ធផលរបស់ក្របខ័ណ្ឌលទ្ធផលរបស់ក្រសួង ស្ថាប័ន វិស័យឯកជន ដោយផ្អែកលើការវិនិយោគឯកជន និងកត្តាផ្សេងៗទៀត ផ្អែកតាមបទពិសោធកន្លងមក។ សូចនាករទាំងនេះនឹងអាចធ្វើការកែសម្រួល អាស្រ័យលើព័ត៌មានដែលទទួលបានពីប្រភពផ្សេងៗ។ លទ្ធផលនៃការអនុវត្តជាក់ស្តែង នឹងត្រូវធ្វើការប្រៀបធៀបជាមួយចំណុចដៅ ដែលបានកំណត់ និងធ្វើឡើងតាមពេលកំណត់នៅកម្រិតជាតិនិងក្រោមជាតិ។

### *គោលការណ៍*

- **ផ.យ.អ.ជ. ២០១៤-២០១៨** បានកំណត់សូចនាករលទ្ធផលសំខាន់ៗ ស្របតាមគោល

នយោបាយអាទិភាព ដែលមានចែងក្នុង**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**។ ការសម្រេចបានសូចនាករទាំងនេះ ត្រូវតែស៊ីគ្នាជាមួយចំណុចដៅដែលបានកំណត់នៅពេលរៀបចំផែនការ មានដូចជា អត្រាកាត់បន្ថយភាពក្រីក្រ កម្រិតជីវភាពល្អប្រសើរ កំណើន ផ.ស.ស. អប់រំ និងសុខភាព។ ចំណុចដៅនីមួយៗ ត្រូវបានកំណត់ឲ្យមានសង្គតិភាពជាមួយលទ្ធផលតាមកម្មវិធីវិស័យ និងថវិកា។ ប៉ុន្តែ ក្រសួង ស្ថាប័ននីមួយៗ នឹងរៀបចំកម្មវិធី និងថវិការបស់ខ្លួន ដែលមានសង្គតិភាពជាមួយចំណុចដៅជាតិទាំងនេះ។ ដូចនេះ ចំណុចដៅនិងសកម្មភាពជាតិត្រូវផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌលទ្ធផលនៅកម្រិតវិស័យ/ថ្នាក់ក្រោមជាតិ។

- ក្នុងករណីដែលលទ្ធផលពិបាកធ្វើការវាស់វែង ក្រសួងផែនការ ស្នើឲ្យបន្ស៊ីសូចនាករជាតុចេញដែលតំណាងឲ្យលទ្ធផលជាមួយនឹងចំណុចដៅ។ ឧទាហរណ៍ ចំណុចដៅក្នុងទិន្នផលស្រូវតំណាងឲ្យចំណូលរបស់កសិករកើនឡើង ដោយសារការវាស់វែងផ្ទាល់លើចំណូលរបស់កសិករមានការលំបាកនិងចំណាយថវិកាច្រើន។
- ជាទូទៅ មានការលំបាកក្នុងការវាស់វែងសូចនាករអរូប ដូចជាអារម្មណ៍មានសុវត្ថិភាព ក្នុងសហគមន៍ ក្នុងបរិបទនៃអភិបាលកិច្ចល្អ ឬកំណើនបរិយាប័ន្ន ប៉ុន្តែ សូចនាករទាំងនេះសំខាន់សម្រាប់ការរៀបចំផែនការ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ សូចនាករជំនួសត្រូវបានរៀបចំឡើងសម្រាប់សូចនាករអរូប។ ក្រុមការងារជាតិសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានរៀបចំសូចនាករជំនួសចំនួន៣ នៅថ្នាក់ជាតិសម្រាប់ អភិបាលកិច្ច កំណើនបរិយាប័ន្ន និងជំនាញរបស់កម្លាំងពលកម្ម ដែលនឹងត្រូវតាមដានត្រួតពិនិត្យជារៀងរាល់ឆ្នាំ។ នៅដំណាក់កាលនេះ មិនមានចំណុចដៅសម្រាប់សូចនាករជំនួស ហើយគោលបំណងគឺដើម្បីប្រៀបធៀបសមិទ្ធផលក្នុងឆ្នាំថ្មីៗ ធៀបនឹងឆ្នាំគោល ដើម្បីវាយតម្លៃវឌ្ឍនភាពដែលសម្រេចបាន។

៦.១៦- ដំណើរការការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមានលក្ខណៈបត់បែន ដែលអាចបង្កើតសូចនាករថ្មីៗ ដូចជា ការលុបចោលឬកែសម្រួលសូចនាករដែលមានស្រាប់ទៅតាមភាពចាំបាច់។ លក្ខខណ្ឌវិនិច្ឆ័យនៃការបង្កើតសូចនាករថ្មី គឺក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវស្នើសុំការផ្លាស់ប្តូរ ដោយផ្អែកលើក្របខ័ណ្ឌលទ្ធផល បន្ទាប់មកក្រុមការងារជាតិសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងពិនិត្យមើលសូចនាករនោះ និងប្រភពទិន្នន័យសម្រាប់ធ្វើការវាស់វែង។ ទិន្នន័យ ត្រូវបានផលិតថ្មីឡើងជាទៀតទាត់សម្រាប់វាស់វែងសូចនាករទាំងនោះជាប្រចាំ។

## សូចនាករស្នូលនិងសូចនាករបន្ថែម

៦.១៧- ស្របតាមក្របខ័ណ្ឌលទ្ធផលដែលបានរៀបចំឡើងក្នុងជំពូកទី៣ ស្តីពីទស្សនាទានម៉ាក្រូសេដ្ឋកិច្ច មានសូចនាករលទ្ធផលនិងឥទ្ធិពល២ប្រភេទ គឺសូចនាករស្នូល និងសូចនាករបន្ថែម។ សូចនាករទាំង២ប្រភេទនេះ ត្រូវបានរៀបចំឡើងដោយមានគោលបំណងផ្សេងគ្នា។

- សូចនាករស្នូល នឹងត្រូវវាស់វែងនៅកម្រិតខ្ពស់ និងប្រើប្រាស់សម្រាប់ថ្នាក់ដឹកនាំ និងដៃគូអភិវឌ្ឍ។ សូចនាករស្នូលមាន២ប្រភេទ គឺ*ប្រភេទទី១* មានចំនួន២០សូចនាករ ដែលផ្តល់ជាការតម្រង់ទិសដល់អ្នករៀបចំគោលនយោបាយ ពីវឌ្ឍនភាពរបស់សង្គម និងសេដ្ឋកិច្ច *ប្រភេទទី២* មានចំនួន៤៧សូចនាករ ដែលផ្តល់ព័ត៌មានលម្អិតបន្ថែមពីសូចនាករទាំង ២០ នៃប្រភេទទី១។
- សូចនាករបន្ថែម ត្រូវបានបែងចែកជាប្រភេទ គឺសូចនាករបន្ថែមកម្រិតសេដ្ឋកិច្ច និងសូចនាករបន្ថែមកម្រិតវិស័យ។ សូចនាករមួយចំនួនគឺសម្រាប់បំពេញបន្ថែមដល់សូចនាករស្នូល(ឧទាហរណ៍ ផ.ស.ស. តម្លៃបច្ចុប្បន្ន ឬផ្ទៃដីដាំស្រូវ) ចំណែកសូចនាករផ្សេងទៀតមានជាសូចនាករតាមវិស័យ និងផ្តោតលើធាតុចេញ(ឧទាហរណ៍ ដីសហគមន៍ដែលចុះបញ្ជីរបស់ជនជាតិភាគតិច ចំនួនសត្វចិញ្ចឹម)។ សូចនាករទាំងនេះនឹងត្រូវបានវាស់វែងធៀបទៅនឹងចំណុចដៅដែលបានកំណត់ សម្រាប់ថ្នាក់ដឹកនាំក្នុងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍដែលគាំទ្រដល់កម្មវិធីនានា។ កិច្ចការនេះ គឺជាការទទួលខុសត្រូវរបស់ក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការតាមដានសូចនាករទាំងអស់នេះ។

៦.១៨- សម្រាប់ការងារប្រតិបត្តិ សូចនាករស្នូលត្រូវបានបំបែកជា៥ក្រុម ដូចខាងក្រោម៖

- សូចនាករលទ្ធផល ដូចជាកំណើន ផ.ស.ស. ភាពក្រីក្រ ឬវិសមភាព។
- សូចនាករធាតុចេញ ដែលតំណាងឲ្យលទ្ធផល ដូចជាគុល្យភាពចំណាយ ការនាំចូល/ការនាំចេញ អតិផរណា ឬចេនាសម្ព័ន្ធ ផ.ស.ស. និងកម្លាំងពលកម្ម។
- សូចនាករលទ្ធផលតាមវិស័យ ដូចជាអត្រាមរណភាពកុមារ អត្រាមរណភាពមាតា អត្រាបញ្ចប់ការសិក្សា។
- សូចនាករធាតុចេញតាមវិស័យ ដែលតំណាងឲ្យលទ្ធផល ដូចជាអត្រាទិន្នផលដំណាំ ផ្ទៃដីដាំដំណាំ ប្រវែងផ្លូវ ការសម្រាលកូនជាមួយបុគ្គលិកសុខភាព អត្រាសិក្សា។
- សូចនាករជំនួស ដូចជាសូចនាករសម្រាប់អភិបាលកិច្ច ឬកំណើនបរិយាប័ន្ន។

៦.១៩- សូចនាករទាំងអស់មានបង្ហាញក្នុង តារាងទី៦.២ ដែលបំបែកទៅតាមវិស័យ ដើម្បីងាយស្រួលសម្រាប់ការគណនាដូចមានបង្ហាញក្នុង តារាងទី៦.១។ សូចនាករបន្ថែម ក្នុងតារាងទី៦.៣

ភាគច្រើនជាសូចនាករធាតុចេញ ដែលទាក់ទងទៅនឹងសកម្មភាពរបស់ក្រសួង ស្ថាប័ន និងតាមវិស័យ។

៦.២០- ដើម្បីធានាថាចំណុចដៅទាំងអស់ ដែលរាជរដ្ឋាភិបាលបានកែលម្អសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវមានសង្គតិភាពជាមួយកម្មវិធីតាមវិស័យ និងថវិការបស់ខ្លួន ក្រសួងផែនការ នឹងរៀបចំការសិក្សាស្រាវជ្រាវមួយចំនួន ដើម្បីបង្កើតទំនាក់ទំនងរវាងធាតុចូល ធាតុចេញ និងលទ្ធផលនៅកម្រិតម៉ាក្រូ។ ឧទាហរណ៍ ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ បានកំណត់ចំណុចដៅសម្រាប់កំណើន ផ.ស.ស. ក្នុងរង្វង់*៧% ក្នុង១ឆ្នាំ* និងការកាត់បន្ថយភាពក្រីក្រយ៉ាងតិច*១% ក្នុង១ឆ្នាំ*។ ក្រសួងផែនការ នឹងរៀបចំការស្រាវជ្រាវ ដើម្បីប៉ាន់ស្មានពីទំហំនៃការកាត់បន្ថយភាពក្រីក្រ ដែលអាចសម្រេចបាន តាមរយៈកំណើន៧% ជាមួយនឹងកំណើនតាមវិស័យ។ កិច្ចការដូចគ្នានេះដែរ នឹងត្រូវធ្វើឡើងសម្រាប់ភាពក្រីក្រជនបទ និងកំណើនវិស័យកសិកម្ម។

**តារាងទី ៦.១ រចនាសម្ព័ន្ធសូចនាករសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

| | |
|---|---|
| **សូចនាករ ឥទ្ធិពល ចំនួន ២០** | (១) **កំណើនដោយចីរភាព:** កំណើន ផ.ស.ស. កំណើនបរិយាប័ន្ន រចនាសម្ព័ន្ធផ.ស.ស. ទិន្នផលស្រូវ ភាគរយគម្របព្រៃឈើ ផ្ទៃដីបោសសម្អាតមីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមរួច ។ |
| | (២) **ការកាត់បន្ថយភាពក្រីក្រ:** អត្រាភាពក្រីក្រ មេគុណជីនីនៃវិសមភាពការប្រើប្រាស់។ |
| | (៣) **ស្ថិរភាព:** ការវិនិយោគ ។ |
| | (៤) **ការអភិវឌ្ឍមនុស្ស**<br>***ការអប់រំ:*** អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៦(តាមភេទ) អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៩(តាម ភេទ) កម្រិតជំនាញ(សន្ទស្សន៍)។<br>***យេនឌ័រ:*** ភាគរយស្ត្រីកាន់តំណែងសម្រេចចិត្តក្នុងវិស័យសាធារណៈ<br>***សុខភាព:*** ការសម្រាលកូនជាមួយបុគ្គលិកសុខភាព អត្រាមរណភាពកុមារ អត្រាមរណភាពមាតា ភាគរយកុមារក្រិន/ស្លេកស្លាំង/ស្គមស្គាំង។<br>***ទឹក និងអនាម័យ:*** ភាគរយប្រជាជនមានទឹកស្អាតប្រើប្រាស់ ភាគរយប្រជាជនមានអនាម័យល្អ។ |
| **សូចនាករ លទ្ធផល ចំនួន ៤៧** | (១) **ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច:** ចំណូលនិងចំណាយ អតិផរណា វិនិយោគផ្ទាល់ពីបរទេស តុល្យភាពគណនីចរន្ត ការនាំចេញ/ការនាំចូល ហិរញ្ញប្បទានបរទេស។<br>(២) **កំណើនតាមវិស័យ និងការធ្វើពិពិធកម្ម:** អត្រាកំណើនតាមវិស័យ ការមកដល់របស់ |

| | |
|---|---|
| | ភ្ញៀវទេសចរ ការបែងចែកការងារតាមវិស័យ ផ្ទៃដីស្រោចស្រព(ដំណាំគ្រប់ប្រភេទ) ដីសម្រាប់ដំណាំគ្រប់ប្រភេទ ការធ្វើពិពិធកម្មដំណាំ សន្ទស្សន៍អតិរេកនៅទីផ្សារ ចំនួនជនរងគ្រោះដែលបណ្តាលមកពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។<br>(៣) **ការគ្រប់គ្រងធនធានធម្មជាតិ:** ផ្ទៃដីតំបន់អភិរក្សទាំង២៣ តំបន់អភិរក្សសហគមន៍។<br>(៤) **ហេដ្ឋារចនាសម្ព័ន្ធ:** ប្រវែងផ្លូវដែលសាងសង់រួច ប្រវែងផ្លូវដែក ទូរទស្សន៍/វិទ្យុ សារព័ត៌មាន ការប្រើប្រាស់អគ្គិសនីសម្រាប់មនុស្សម្នាក់។<br>(៥) **អភិបាលកិច្ច:** អត្រាផ្តល់បណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីដល់កសិករ វិវាទទាក់ទងនឹងដី/អចលនទ្រព្យ បទឧក្រិដ្ឋ។<br>(៦) **ការអភិវឌ្ឍមនុស្ស**<br>***ភាពក្រីក្រ:*** ភាពក្រីក្រនៅតំបន់ជនបទ ភាពក្រីក្ររបស់កុមារ ភាពក្រីក្រម្ហូបអាហារ។<br>***អប់រំ:*** អត្រាពិតនៃការសិក្សានៅបឋមសិក្សា អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ សមាមាត្រកុមារចូលសិក្សាអាយុ៦-១៧ឆ្នាំ សមាមាត្រនិស្សិតបញ្ចប់មហាវិទ្យាល័យអាយុ១៨-៣៥ឆ្នាំ។<br>***យេនឌ័រ:*** សមាមាត្រស្ត្រីក្នុងវិស័យសាធារណៈ ចំណែកស្ត្រីក្នុងការងារទទួលបានប្រាក់កម្រៃ អត្រាពិតនៃស្ត្រីក្នុងការអប់រំកម្រិតឧត្តមសិក្សា ភាគរយស្ត្រីបញ្ចប់វគ្គបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ សមាមាត្រស្ត្រីមានផ្ទៃពោះទទួលការពិនិត្យផ្ទៃពោះ២ដង ឬច្រើនជាងនេះ ចំនួនគ្រួសារដែលមានបញ្ហាអំពើហិង្សាលើគ្រួសារ។<br>***សុខភាព:*** អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ អត្រាមរណភាពដោយជំងឺគ្រុនចាញ់ ប្រេវ៉ាឡង់ជំងឺរបេង ការចុះបញ្ជីកំណើត កុមារមិនគ្រប់ទម្ងន់ ស្ត្រីអាយុ១៥-៤៩ឆ្នាំដែលខ្វះគ្រាប់ឈាមក្រហម កុមារអាយុ៦-៥៩ខែ ដែលខ្វះគ្រាប់ឈាមក្រហម។<br>***សុខភាពនិងសិទ្ធិក្នុងការបន្តពូជ:*** តម្រូវការមិនបានបំពេញនូវសេវាផែនការគ្រួសារ អត្រាប្រេវ៉ាឡង់ការពន្យារកំណើត អត្រាបង្កើតកូនដោយការវះកាត់។<br>***ទឹកនិងអនាម័យ:*** ការទទួលបានទឹកស្អាតប្រើប្រាស់ ការទទួលបានអនាម័យល្អនៅតាមជនបទ និងទីប្រជុំជន។ |
| **សូចនាករធាតុចេញ** | បញ្ជីសូចនាករជាតុចេញមានបង្ហាញក្នុង តារាងទី៦.២ ហើយក្រសួង ស្ថាប័ន នឹងកំណត់សូចនាករទាំងនោះតាមកម្មវិធី និងគម្រោងតាមវិស័យ។ |
| **សូចនាករធាតុចូល** | សូចនាករតាមគម្រោងនិងកម្មវិធីនឹងត្រូវថែរក្សាដោយក្រសួង ស្ថាប័ន ស្របតាមក្របខ័ណ្ឌលទ្ធផលសម្រាប់កម្មវិធីនីមួយៗ។ |

## ឃ- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់ក្រោមជាតិ

៦.២១- ត្រូវមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពនៅថ្នាក់ក្រោមជាតិ ប៉ុន្តែរហូតដល់ពេលបច្ចុប្បន្ននេះជម្រើសសម្រាប់ការអនុវត្តកិច្ចការនេះនៅមានកម្រិត ដោយសារធនធាន រចនាសម្ព័ន្ធស្ថាប័ន និងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកនៅមានកម្រិតនៅឡើយ។ ដោយ

មានការកែលម្អលើការប្រមូលទិន្នន័យ និងការគ្រប់គ្រងក្នុងក្រសួង ស្ថាប័នមួយចំនួន ទិន្នន័យរដ្ឋបាលតាមខេត្តអាចត្រូវបានបង្កើតជាកម្រងទិន្នន័យក្នុងរដ្ឋផែនការនៅកម្រិតខេត្ត។ លើសពីនេះទៀត ***វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ*** បានពង្រីកទំហំនៃដំណើរការផលិតទិន្នន័យ ដែលតម្រូវឱ្យមានការបង្កើតកម្រងទិន្នន័យពីអង្កេតនានានៅថ្នាក់ក្រោមជាតិ។

- ***វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ*** បានរៀបចំកម្រងទិន្នន័យខេត្តសាកល្បងស្តីពី ផ.ស.ស. សម្រាប់ឆ្នាំ២០០០-២០០៨។ កម្រងទិន្នន័យនេះ ត្រូវបានរៀបចំឡើងសម្រាប់ខេត្តចំនួន៥នៅឆ្នាំ២០១២។ កម្រងទិន្នន័យនេះ នឹងត្រូវកែលម្អបន្ថែមទៀត។ ទិន្នន័យទាំងអស់នេះ នឹងមានសម្រាប់ប្រើប្រាស់នៅឆ្នាំ២០១៥។
- ទិន្នន័យស្តីពីសូចនាករសេដ្ឋកិច្ច សង្គមកិច្ច នឹងត្រូវបានរៀបចំឡើង ដោយប្រើប្រាស់សូចនាករស្ថិតិខេត្ត ដែលក្រសួង ស្ថាប័នផលិតឡើង ដូចជា ផ្ទៃដីដាំដំណាំ អត្រាសិក្សា សេវាសុខភាព ជាដើម។
- ទិន្នន័យឃុំ សង្កាត់ អាចត្រូវបានប្រើប្រាស់សម្រាប់រៀបចំកម្រងទិន្នន័យនៅថ្នាក់ខេត្ត ថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់។ កិច្ចការនេះអាចធ្វើបាននៅពេលទិន្នន័យឃុំ សង្កាត់ក្លាយជាស្ថិតិផ្លូវការ និងត្រូវពិនិត្យវិនិច្ឆ័យដោយសហគមន៍អ្នកប្រើប្រាស់ក្នុងរាជរដ្ឋាភិបាល និងស្ថាប័នស្ថិតិរបស់រាជរដ្ឋាភិបាល។
- ទិន្នន័យអង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជា អាចបំបែកតាមការប៉ាន់ស្មានតាមខេត្ត ដូចជា អត្រាមរណភាពទារក អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ កង្វះអាហារូបត្ថម្ភកុមារ និងសូចនាករផ្សេងៗទៀត។

៦.២២- បញ្ជីសូចនាករ ដែលតម្រូវឱ្យមានការតាមដានត្រួតពិនិត្យ នៅថ្នាក់ក្រោមជាតិ មានបង្ហាញក្នុងតារាងទី៦.៥។

## ខ- ការប្រមូលផ្តុំទិន្នន័យ

៦.២៣- នៅកម្ពុជា ក៏ដូចជាក្នុងពិភពលោក មានស្ថាប័នច្រើនប្រមូលទិន្នន័យស្តីពីបញ្ហាផ្សេងៗ ដូចជាការអភិវឌ្ឍ ហិរញ្ញវត្ថុ បុគ្គលិក ជាដើម ដោយសារស្ថាប័នតែមួយមិនអាចធ្វើកិច្ចការទាំងអស់បាន។ លើសពីនេះ ទិន្នន័យមួយចំនួនមានលក្ខណៈបច្ចេកទេសខ្លាំង ដូចជា សុខាភិបាល ឬកសិកម្ម ហើយក្រសួង ស្ថាប័នពាក់ព័ន្ធមានលទ្ធភាពគ្រប់គ្រាន់ប្រមូលទិន្នន័យតាមវិស័យទាំងនោះ ដែលបង្កើតបានជាទិន្នន័យរដ្ឋបាល ដែលមិនមានស្ថាប័នណាអាចប្រមូលទិន្នន័យទាំងនោះបាន។

៦.២៤- ដោយសារមានស្ថាប័នច្រើនដែលប្រមូលទិន្នន័យ ហើយការសម្របសម្រួលរវាងស្ថាប័ននៅមានកម្រិត ដូចនេះ មិនចាំបាច់មាននិយមន័យរបស់អញ្ញត និងដំណើរការផលិតទិន្នន័យ ដែលមានលក្ខណៈអាចប្រៀបធៀបគ្នាបាននោះទេ។ ស្ថាប័នមួយចំនួនមិនយកតាមនិយមន័យរបស់អញ្ញត ដែលជាតិឬអន្តរជាតិទទួលស្គាល់។ ដូចនេះ មានការលំបាកក្នុងការប្រៀបធៀបទិន្នន័យដូចគ្នាតាមស្ថាប័នផ្សេងគ្នា។ *មានជម្រើសចំនួន៣ សម្រាប់ដោះស្រាយបញ្ហានេះ ដូចខាងក្រោម៖*

- ការកំណត់នូវនិយមន័យរួម និងដំណើរការផលិតទិន្នន័យ ត្រូវបានរៀបចំឡើង ដើម្បីក្រសួង ស្ថាប័នផលិតទិន្នន័យប្រើប្រាស់និយមន័យ និងដំណើរការផលិតទិន្នន័យដូចគ្នា។
- មានការឯកភាពគ្នាក្នុងចំណោមអ្នកប្រើប្រាស់ទិន្នន័យស្តីពីនិយមន័យ និងប្រភពទិន្នន័យសម្រាប់សូចនាករនីមួយៗ សម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ផ.យ.អ.ជ.។ ប្រភពផ្សេងទៀតអាចបន្តបង្កើតទិន្នន័យ សម្រាប់គម្រោងរបស់ខ្លួន ប៉ុន្តែប្រភពទិន្នន័យដែលមានការឯកភាពគ្នាលើនិយមន័យរបស់សូចនាករ ត្រូវបានប្រើសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ផ.យ.អ.ជ.។
- មិនមាននិយមន័យស្តង់ដា និងដំណើរការផលិតទិន្នន័យស្តង់ដា ប៉ុន្តែសហគមន៍អ្នកប្រើប្រាស់ទិន្នន័យត្រូវបានជូនដំណឹង អំពីភាពខុសគ្នាសម្រាប់ប្រភពទិន្នន័យនីមួយៗ ដើម្បីជៀសវាងមានការប្រៀបធៀបអញ្ញតដែលមិនអាចប្រៀបធៀបបាន។

៦.២៥- *ជម្រើសទី១* មានលក្ខណៈល្អ ហើយមិនមានប្រទេសណាមួយប្រើប្រាស់ទេ មានតែប្រទេសតូចៗប៉ុណ្ណោះ។ នៅក្នុងប្រទេសដែលប្រើជម្រើសទី៣ សហគមន៍អ្នកប្រើប្រាស់ រាជរដ្ឋាភិបាល អ្នកវិភាគគោលនយោបាយក្នុងវិស័យឯកជន និងស្ថាប័នអប់រំផ្សេងៗ ត្រូវបានជូនដំណឹងពីភាពផ្សេងគ្នានៃការបកស្រាយទិន្នន័យ នៅពេលទិន្នន័យទាំងនេះត្រូវបានប្រមូលដោយប្រើនិយមន័យផ្សេងគ្នា និងដំណើរការផលិតទិន្នន័យផ្សេងគ្នា។ នៅកម្ពុជា អ្នកប្រើប្រាស់ទិន្នន័យសំខាន់ គឺមន្ត្រីរាជការ អ្នកសិក្សាស្រាវជ្រាវ និងទីប្រឹក្សា ដែលផ្តល់យោបល់ដល់អ្នកដឹកនាំនយោបាយ។ ដោយសារការិយាល័យធិបតេយ្យក្នុងរាជរដ្ឋាភិបាល ដូចប្រទេសកំពុងអភិវឌ្ឍមួយចំនួនដែរនោះ គឺមិនត្រឹមតែមានទីប្រឹក្សាសម្រាប់ធ្វើទំនាក់ទំនង សម្របសម្រួលរវាងក្រសួងស្ថាប័ន និងនៃការសម្របសម្រួលរបស់ទីប្រឹក្សានៅមានកម្រិត ដូច្នេះការជ្រើសរើសយក *ជម្រើសទី៣* អាចនាំមកនូវហានិភ័យនៃការបកស្រាយទិន្នន័យ និងអាចនាំមកនូវសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវ។ ដូចនេះ *ជម្រើសទី២* ហាក់ដូចជាមានលក្ខណៈសមរម្យជាងគេសម្រាប់ស្ថានភាពប្រទេសកម្ពុជា ដោយមានការឯកភាពគ្នាលើនិយមន័យរួម និងប្រភពទិន្នន័យ សម្រាប់សូចនាករស្នូលនិងសូចនាករបន្ថែម។ សូចនាករទាំងនេះអាចត្រូវបានប្រើប្រាស់សម្រាប់ការតាមដានត្រួតពិនិត្យវឌ្ឍនភាព។

៦.២៦- តារាងទី៦.២ និងទី៦.៣ បង្ហាញពីប្រភពទិន្នន័យនិងស្ថាប័នដែលជាអ្នកផលិតទិន្នន័យ។ ក្រុមការងារជាតិសម្រាប់ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផ.យ.អ.ជ. បានឯកភាពគ្នាលើប្រភពទិន្នន័យសម្រាប់សូចនាករស្នូលនិងសូចនាករបន្ថែម។

៦.២៧- ពេលខ្លះមានការបញ្ចូលគ្នារវាងជម្រើសទី១និងជម្រើសទី២ ដូច្នេះ ត្រូវមានការប្រុងប្រយ័ត្នក្នុងការបកស្រាយលទ្ធផល។

## ច- ពង្រឹងប្រព័ន្ធទិន្នន័យរដ្ឋបាល

៦.២៨- នៅក្នុងប្រទេសកម្ពុជា ប្រភពទិន្នន័យមានពីរប្រភេទ គឺទិន្នន័យអង្កេតនិងទិន្នន័យរដ្ឋបាល។

៦.២៩- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការបានរៀបចំជំរឿន និង អង្កេតនានាដោយឯករាជ្យ ឬដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្រសួង ស្ថាប័នពាក់ព័ន្ធទទួលយកលទ្ធផលដែលរកឃើញទៅប្រើប្រាស់និងបកស្រាយ។ ជាក់ស្តែង ទិន្នន័យរដ្ឋបាលគុណភាពនៅមានកម្រិត ដែលតម្រូវឲ្យមានការពង្រឹងបន្ថែមទៀត។ ហើយទិន្នន័យរដ្ឋបាលចំណាយតិចនិងងាយស្រួលក្នុងការថែរក្សា។ បច្ចុប្បន្ន ទិន្នន័យដែលបានបោះពុម្ពផ្សាយសម្រាប់ប្រើប្រាស់មានដូចខាងក្រោម៖

- ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំ។
- ប្រព័ន្ធព័ត៌មានសុខាភិបាល។
- គេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ ផ្តល់ព័ត៌មានស្តីពីលទ្ធផលអង្កេតនានា។

៦.៣០- ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំនិងប្រព័ន្ធព័ត៌មានសុខាភិបាល គឺជាទិន្នន័យរដ្ឋបាល។ ក្នុងរយៈពេលរបស់ **ផ.យ.អ.ជ. ២០១៤-២០១៨** ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងរៀបចំប្រព័ន្ធទិន្នន័យអនឡាញ និងរក្សាទុកជាអេឡិចត្រូនិក។ ក្រសួងអភិវឌ្ឍន៍ជនបទ បានដំណើរការរៀបចំប្រព័ន្ធទិន្នន័យមុនគេ ហើយអាចនឹងបញ្ចប់ប្រព័ន្ធព័ត៌មាននេះក្នុងរយៈពេល១-២ឆ្នាំខាងមុខ។

## ឆ- ករណីសិក្សានិងការសិក្សាខ្នាតតូច

៦.៣១- ដូចបានបញ្ជាក់ក្នុងក្របខ័ណ្ឌលទ្ធផល គឺនឹងមិនមានការកើតឡើងដោយស្វ័យប្រវត្តិនូវជាតុចេញ ប្រសិនបើមានធាតុចូលគ្រប់ទាំងអស់ ឬ ប្រសិនបើមានធាតុចេញរួចរាល់ហើយ នោះលទ្ធផល/ឥទ្ធិពលនឹងមិនសម្រេចបានដោយស្វ័យប្រវត្តិដែរ។ ទាំងនេះអាចបណ្តាលមកពីហេតុផលជាច្រើន ដូចជា៖ *បញ្ហាបច្ចេកទេស នីតិវិធីការងារ កត្តាស្ថាប័ន និង កត្តាខាងក្រៅ*។

៦.៣២- ករណីសិក្សានិងការសិក្សាខ្នាតតូច មានប្រយោជន៍ណាស់ សម្រាប់ការយល់ដឹងពីបញ្ហាទាំងនេះ។ ការសិក្សាខ្នាតតូច មានកំណត់ចំពោះតំបន់ភូមិសាស្ត្រតូច និងមានគោលបំណងជាក់លាក់ ប៉ុន្តែបញ្ហាសម្រាប់ការវិភាគស៊ីជម្រៅ។ ការសិក្សាខ្នាតតូចអាចឆ្លើយតបនឹងបញ្ហាទាំងអស់ដែលរៀបរាប់ខាងលើនេះ។ ការសិក្សាខ្នាតតូចមានប្រយោជន៍ សម្រាប់ការវិភាគគោលនយោបាយ ដូចខាងក្រោម៖

- ការសិក្សាតែ១ដង ដូចជាការគ្រប់គ្រងកសិដ្ឋាន ការសិក្សាពីទីផ្សារ ជាដើម គឺដើម្បីបង្កើតចំណេះដឹងមូលដ្ឋាន។ សនិទានភាព អាចកំណត់ចេញពីការសិក្សាទាំងនេះ ដូចជាកម្លាំងពលកម្មក្នុងវិស័យកសិកម្ម ដែលមានប្រយោជន៍ក្នុងការរៀបចំផែនការការងារទំនាក់ទំនងរវាងទំហំកសិដ្ឋាននិងផលិតភាព ដែលមានក្នុងកំណែទម្រង់ដីធ្លី និង មូលហេតុមិនប្រើបច្ចេកវិទ្យា។
- ការសិក្សាមុននិងក្រោយ ជួយដល់ការវាយតម្លៃឥទ្ធិពលរបស់គម្រោង ឬកម្មវិធីដល់អ្នកទទួលផលប្រយោជន៍ ឬប្រជាជនដែលប៉ះពាល់។
- ការសិក្សាអាចប្រៀបធៀបរវាងអ្នកទទួលផលប្រយោជន៍ និងក្រុមអ្នកតាមដានត្រួតពិនិត្យដែលអាចជួយដល់ការកំណត់ពីឥទ្ធិពលនៃគម្រោងចំពោះប្រជាជន។

៦.៣៣- ការសិក្សានីមួយៗអាចប្រើវិធីពិនិត្យគុណភាព ឬបរិមាណ ឬទាំងពីរវិធី។ បញ្ជីនៃការសិក្សាគំរូ ដែលអាចប្រើប្រាស់នៅតាមវិស័យនីមួយៗមានក្នុងតារាងទី៦.៤។

## ឈ- ប្រធានបទពិសេសសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

៦.៣៤- ក្នុង **ផ.យ.អ.ជ. ២០១៤-២០១៨** រាជរដ្ឋាភិបាលនឹងពិចារណារៀបចំការសិក្សាពិសេសមួយចំនួន ដែលអាចជាអង្កេតខ្នាតធំ ទាក់ទងនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ដូចជាបរិស្ថាន យេនឌ័រ កម្លាំងពលកម្ម ការផ្លាស់ប្តូរលំនៅ ការកាត់បន្ថយគ្រោះមហន្តរាយ អំពើហិង្សាប្រឆាំងនឹងកុមារជាដើម។

៦.៣៥- ***ក្រសួងផែនការ*** នឹងរៀបចំការសិក្សាទាំងអស់នេះ បន្ថែមពីលើកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្រសួងផែនការ នឹងរៀបចំកិច្ចប្រជុំជាមួយនាយកដ្ឋានពាក់ព័ន្ធទាំងអស់នៃក្រសួង ស្ថាប័ន ដើម្បីពិនិត្យមើលពីតម្រូវការ វិធីសាស្ត្រ និងលទ្ធផលពីការសិក្សាឲ្យបានយ៉ាងតិចបំផុតចំនួន១ដងក្នុង១ឆ្នាំ។

## ញ- ភាពប្រឈមទាក់ទងនឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

៦.៣៦- ភាពប្រឈមជាច្រើន ទាក់ទងនឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅតាមក្រសួង ស្ថាប័ន មានដូចខាងក្រោម៖

- ក្រសួង ស្ថាប័នពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំសូចនាករដែលមានលក្ខណៈត្រឹមត្រូវ(ជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ពិតប្រាកដនិងមានពេលវេលាកំណត់) នៅក្នុងវិស័យរបស់ក្រសួង ស្ថាប័ន។
- ក្រសួង ស្ថាប័នពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការប្រមូលទិន្នន័យសម្រាប់វាស់វែងសូចនាកររបស់ខ្លួន។
- រាជរដ្ឋាភិបាលកម្ពុជា ពុំទាន់មានប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សម្រាប់ថ្នាក់ជាតិ និងការអនុវត្តគម្រោងនានារបស់ក្រសួង ស្ថាប័ន ដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។។
- ការសម្របសម្រួលនិងកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួននៅមានកម្រិតក្នុងការរៀបចំផែនការ កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងរបាយការណ៍របស់ជាតិផ្សេងៗ។

## ៤- ការរៀបចំនិងពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

៦.៣៧- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតអាទិភាពលើ៖

- ការរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. និងការអនុវត្តគម្រោងនានារបស់ក្រសួង ស្ថាប័ន ដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដើម្បីគ្រប់គ្រងចំណាយវិនិយោគសាធារណៈ ដែលប្រើប្រាស់ថវិកាជាតិនិងដៃគូអភិវឌ្ឍ និងការសម្រេចបាន។

៦.៣៨- ដើម្បីសម្រេចបានគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល ***ក្រសួងផែនការ*** នឹងអនុវត្តសកម្មភាពដូចខាងក្រោម៖

- រៀបចំប្រព័ន្ធសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. និងការអនុវត្តគម្រោងនានារបស់ក្រសួង ស្ថាប័ន ដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។
- រៀបចំសេចក្តីណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធជាតិសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាតិសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. និងការអនុវត្តគម្រោងនានារបស់ក្រសួង ស្ថាប័ន ដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំសូចនាករដែលមានលក្ខណៈត្រឹមត្រូវ(ជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ពិតប្រាកដ និងមានពេលវេលាកំណត់) ដល់មន្ត្រី

បង្គោលដែលទទួលបន្ទុកការងារផែនការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ។

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធជាតិសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៃអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការអនុវត្តគម្រោងនានារបស់ក្រសួង ស្ថាប័ន ដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដល់មន្ត្រីបង្គោលដែលទទួលបន្ទុកការងារផែនការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងប្រើប្រាស់ទិន្នន័យសម្រាប់វាស់វែងសូចនាករ ដែលមាននៅក្នុង ផ.យ.អ.ជ. ២០១៤-២០១៨ ដល់មន្ត្រីបង្គោលដែលទទួលបន្ទុកការងារផែនការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់។
- ផ្តល់ជាជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការរៀបចំសូចនាករ ការប្រមូលទិន្នន័យ វិភាគទិន្នន័យ និងការប្រើប្រាស់ទិន្នន័យ រៀបចំក្របខ័ណ្ឌលទ្ធផលសម្រាប់វិស័យនីមួយៗ និងការបង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ តាមការស្នើសុំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

៦.៣៩- ដើម្បីសម្រេចបានគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ នឹង៖

- បង្កើតអង្គភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីរួមចំណែកដល់ការពង្រឹងប្រសិទ្ធភាពនៃសកម្មភាពរបស់ក្រសួង ស្ថាប័ន។
- ពង្រឹងសមត្ថភាពស្តីពីស្ថិតិនិងការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃដល់មន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- ពង្រឹងការសម្របសម្រួលនៅក្នុងផ្ទៃក្នុងក្រសួង ស្ថាប័ន ដើម្បីពង្រឹងដំណើរការការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

## តារាងទី ៦.២ សូចនាករស្នូលសម្រាប់ការតាមដាន ត្រួតពិនិត្យនៃផ.យ.អ.ជ. ២០១៤-២០១៨

(*)- គោលដៅនិងចំណុចដៅរបស់គ.អ.ស.ក.

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១ | *ការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ* | | | | | | | | |
| ១.១* | អត្រាភាពក្រីក្រ(កម្ពុជា) | % | ១៨,៨ | ១៧,៨ | ១៦,៨ | ១៥,៨ | ១៤,៨ | ១៣,៨ | អ.ស.ស.ក. (វ.ជ.ស.) |
| ១.២* | អត្រាភាពក្រីក្រ(ជនបទ) | % | ១៩,៧ | ១៨,៧ | ១៧,៧ | ១៦,៧ | ១៥,៧ | ១៤,៧ | អ.ស.ស.ក. (វ.ជ.ស.) |
| ១.៣* | អត្រាភាពក្រីក្រផ្នែកម្ហូបអាហារ | % | < ៥ | < ៥ | < ៥ | < ៥ | < ៥ | < ៥ | អ.ស.ស.ក. (វជស) |
| ១.៤ | មេគុណ Gini នៃវិសមភាពក្នុងការចំណាយលើការប្រើប្រាស់ | % | ០,៣២ | ០,៣២ | ០,៣២ | ០,៣១ | ០,៣១ | ០,៣០ | អ.ស.ស.ក. |
| ១.៥ | អត្រាភាពក្រីក្ររបស់កុមារ | % | ២៣,០ | ២២,០ | ២១,០ | ២០,០ | ១៩,០ | ១៨,០ | អ.ស.ស.ក. |
| ២ | *ការបង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច* | | | | | | | | |
| ២.១ | ស្ថានភាពសេដ្ឋកិច្ច(អត្រានៃការសន្សំនិងការវិនិយោគ) | %នៃផ.ស.ស. | ២៧,២ | ២៥,៨ | ២៦,១ | ២៦,១ | ២៦,៥ | ២៦,៦ | គណនេយ្យជាតិ (វ.ជ.ស.) |
| ២.២ | ទំនាស់អំពីដីធ្លីឬកម្មសិទ្ធិ | ក្នុងប្រ/ជ ១រយពាន់នាក់ | ៣០ (២០១១) | < ៣០ | < ៣០ | < ៣០ | < ៣០ | < ៣០ | អ.ស.ស.ក. |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២.៣ | ការមានអារម្មណ៍សុវត្ថិភាព | % ប្រ/ជ | ៨០ (២០១១) | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | អ.ស.ស.ក. |
| ៣ | ការលើកកម្ពស់ផលិតភាពនិងផលិតកម្មកសិកម្ម | | | | | | | | |
| ៣.១ | ទិន្នផលស្រូវក្នុងមួយហិកតា | តោន | | ៣,១៥ | ៣,១៨ | ៣,២១ | ៣,២៣ | ៣,២៥ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ៣.២ | ផ្ទៃដីដំណាំទាំងអស់ដែលបានស្រោចស្រព | ហ.ត | ១ ៤៨៥ ៦៧០ | ១ ៥១៥ ៦៧០ | ១ ៥៤៥ ៦៧០ | ១ ៥៧៥ ៦៧០ | ១ ៦០៥ ៦៧០ | ១ ៦៣៥ ៦៧០ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ៣.៣ | ផ្ទៃដីដាំដំណាំសរុប | ហ.ត | | ៤ ៨១៤ ៩៣៤ | ៥ ០២៤ ៩៣៤ | ៥ ២៣៤ ៩៣៤ | ៥ ៤៤៤ ៩៣៤ | ៥ ៦៥៤៩៣៤ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ៣.៤ | សន្ទស្សន៍ពិពិធភាវូបនីយកម្មដំណាំ | % នៃតំបន់សរុប | ៣១ | ៣២ | ៣៥ | ៣៥ | ៣៥ | ៣៥ | ក.ក.រ.ន. |
| ៣.៥ | សន្ទស្សន៍ទិន្នផលស្រូវលើស | % | ៥៦ | > ៦០ | > ៦០ | > ៦០ | > ៦០ | > ៦០ | ក.ក.រ.ន./វ.ជ.ស. |
| ៤ | ការលើកកម្ពស់ស្ថានភាពសុខភាព(*) | | | | | | | | |
| ៤.១ | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល | % | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៤.២ | អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ដែលត្រូវបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | % | ១,២៥ | ១ | ០,៨ | ០,៦៥ | ០,៥ | ០,៣៥ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៤.៣ | អត្រាមរណភាពទារក | ក្នុង១០០០ | ៤៥ | | ៣៥ | | | ៣២ | អ.ប.ស.ក. |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| | | កំណើតរស់ | | | | | | | (វ.ជ.ស./ក.ស.ភ.) |
| ៤.៤ | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ | ក្នុង១០០០ កំណើតរស់ | ៥៤ | | ៤៥ | | | ៤២ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៤.៥* | អត្រាមរណភាពមាតា | ក្នុង១សែនពាន់ កំណើតរស់ | ២០៦ | | ១៤០ | | | ១៣០ | ជ.ទ.ប.ក./អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៤.៦ | អត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ | % នៃមនុស្សពេញវ័យអាយុពី១៥-៤៩ឆ្នាំ | ០,៧ | ០,៦ | ០,៥ | ០,៤ | ០,៣ | < ០,១ | ប.ព.វ.ក.ស. (អ.ជ.ប.អ.) |
| ៤.៧ | ប្រេវ៉ាឡង់នៃជំងឺរបេងបេកាវិជ្ជមាន | ក្នុងប្រ/ជ ១សែនពាន់នាក់ | ៧៣៥ | ៦៩៤ | ៦៥៣ | ៦១២ | ៥៧១ | ៥៣០ | ប.ព.វ.ក.ស. (ក.ស.ភ.) |
| ៥ | *ការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និងទឹកស្អាតនិងអនាម័យ* | | | | | | | | |
| ៥.១ | ភាគរយនៃកុមារក្រិនអាយុក្រោម៥ឆ្នាំ (ក្រោមបទដ្ឋាន) | % នៃកុមារសរុបអាយុពី០-៥៩ខែ | ៤០ (២០១០) | | | | | ២៥ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៥.២ | ភាគរយនៃកុមារអាយុក្រោម៥ឆ្នាំដែលមិនគ្រប់ទម្ងន់(ក្រោមបទដ្ឋាន) | % នៃកុមារសរុបអាយុពី០-៥៩ខែ | ២៨ (២០១០) | | | | | ១៩ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៥.៣ | ភាគរយនៃស្ត្រីអាយុពី១៥-៤៩ឆ្នាំដែលមានភាពស្លេកស្លាំង | % នៃស្ត្រីសរុបអាយុពី១៥-៤៩ ឆ្នាំ | ៤៤ | | | | | - | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៥.៤ | ភាគរយនៃកុមារអាយុពី៦-៥៩ខែ ដែលមានភាពស្លេកស្លាំង | % នៃកុមារសរុបអាយុពី៦-៥៩ខែ | ៥៥ | | | | | ៤២ | អ.ស.ប.ក. (វ.ជ.ស./ក.ស.ភ.) |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៦ | *ការលើកកម្ពស់វិស័យអប់រំ* | | | | | | | | |
| | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | | |
| ៦.១ | *សរុប* | % | ៩៧,០ | ៩៧,៣ | ៩៧,៩ | ៩៨,៦ | ៩៩,៣ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.២ | *ស្រី* | % | ៩៧,០ | ៩៧,១ | ៩៧,៨ | ៩៨,៥ | ៩៩,២ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | | |
| ៦.៣ | *សរុប* | % | ៥៦,៥ | ៦០,៤ | ៦៦,៩ | ៧៣,៧ | ៨១,៣ | ៨៧,៤ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.៤ | *ស្រី* | % | ៥៧,៧ | ៦០,៣ | ៦៦,៥ | ៧៣,១ | ៨០,៤ | ៨៥,៩ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| | អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៦ | | | | | | | | |
| ៦.៥ | *សរុប* | % | ៩១,៥ | ៩៨,៣ | ១០០ | ១០០ | ១០០ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.៦ | *ស្រី* | % | ៩១,០ | ៩៨,០ | ១០០ | ១០០ | ១០០ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| | អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៩ | | | | | | | | |
| ៦.៧ | *សរុប* | % | ៤២,២ | ៤៤,៤ | ៦១,៦ | ៥៧,២ | ៦៧,៣ | ៧៦,៤ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.៨ | *ស្រី* | % | ២៥,៥ | ២៧,៣ | ៣១,៦ | ៣៥,១ | ៤១,៦ | ៤៧ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.៩ | សមាមាត្រកុមារក្នុងសាលាដែលមានអាយុពី៦-១៧ឆ្នាំ | %កុមារសរុបដែលមានអាយុពី៦-១៧ឆ្នាំ | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | អ.ស.ស.ក. (វ.ជ.ស.) |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៦.១០ | ភាគរយនៃអ្នកបានបញ្ចប់មហាវិទ្យាល័យដែលមានអាយុពី១៨-៣៥ឆ្នាំ | % | > ៥ | > ៥ | > ៥ | > ៥ | > ៥ | > ៥ | ប. ព. រ. ក. ស./អ. ស. ស. ក. (ក. អ. យ. ក./វ. ជ. ស.) |
| *៧* | *ទឹកស្អាត/អនាម័យ និងការអភិវឌ្ឍជនបទ* | | | | | | | | |
| ៧.១ | លទ្ធភាពទទួលបានប្រភពទឹកស្អាតនៅទីប្រជុំជន | % | > ៨៥ | > ៨៥ | > ៨៥ | > ៨៥ | > ៨៥ | > ៨៥ | អ. ស. ស. ក. (វ. ជ. ស.) |
| ៧.២ | លទ្ធភាពទទួលបានអនាម័យប្រសើរជាងមុននៅទីប្រជុំជន | % | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | អ. ស. ស. ក. (វ. ជ. ស.) |
| ៧.៣ | ផ្លូវជនបទដែលបានស្តារលើប្រវែងផ្លូវសរុប៤០ ០០០ គ. ម. | គ. ម. | ២៧ ៧៥០ | ២៨ ៦០០ | ២៩ ៤៥០ | ៣០ ៣០០ | ៣១ ១៥០ | ៣២ ០០០ | ប. ព. រ. ក. ស. (ក. អ. ជ.) |
| ៧.៤ | លទ្ធភាពទទួលបានប្រភពទឹកស្អាតបរិភោគនៅជនបទ | % | ៤៤,២ | ៤៦,៧ | ៥០,០ | ៥៣,០ | ៦៧,០ | ៦៧,០ | អ. ស. ស. ក. (វ. ជ. ស.) |
| ៧.៥ | លទ្ធភាពអនាម័យប្រសើរជាងមុននៅទីប្រជុំជន | % | ៣៧,៥ | ៤២ | ៤៦ | ៥០ | ៥៥ | ៦០ | អ. ស. ស. ក. (វ. ជ. ស.) |
| *៨* | *ចីរភាពបរិស្ថាន* | | | | | | | | |
| ៨.១ | ផ្ទៃដីតំបន់ការពារធម្មជាតិទាំង២៣កន្លែង | ហ. ត. | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ប. ព. រ. ក. ស. (ក. ក. រ. ន.) |
| ៨.២ | សហគមន៍តំបន់ការពារធម្មជាតិ | ចំនួន | ១២០ | ១៣០ | ១៤០ | ១៤២ | ១៤៥ | ១៥០ | ប. ព. រ. ក. ស. (ក. ប. ស.) |
| ៨.៣ | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | % នៃផ្ទៃដីសរុប | ៥៨,៤ (២០១០) | ៥៩,២ (ប៉ាន់ស្មាន) | ៦០ | ៦០ | ៦០ | ៦០ | ប. ព. រ. ក. ស. (ក. ប. ស.) |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៨.៤ | អត្រាបណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់ជូនប្រជាពលរដ្ឋទូទៅ | % នៃក្បាលដីសរុប | | ៥២ | ៥៧ | ៦២ | ៦៦ | ៧០ | ប.ព.រ.ក.ស. (ក.រ.ជ.ន.ស.) |
| ៨.៥ | ភាគរយនៃប្រជាជនដែលប្រើប្រាស់អុសធ្យូងសម្រាប់ចម្អិនអាហារ | % | | | | | | | ប.ព.រ.ក.ស. (ក.ប.ស.) |
| ៩ | *សមធម៌យេនឌ័រ* | | | | | | | | |
| ៩.១ | សមាមាត្រស្ត្រីដែលកាន់មុខតំណែងជាអ្នកសម្រេចចិត្តក្នុងវិស័យសាធារណៈ | % | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ប.ព.រ.ក.ស. (កកន) |
| ៩.២ | សមាមាត្រស្ត្រីក្នុងវិស័យសាធារណៈ | % | ៣៥ | ៣៦ | ៣៦,៥ | ៣៧ | ៣៧ | ៣៧ | ប.ព.រ.ក.ស. (ក.ក.ន.) |
| | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃ | | | | | | | | |
| ៩.៣ | *កសិកម្ម* | % | ៥២ | ៥១ | ៥០ | ៥០ | ៥០ | ៥០ | ជ.ទ.ប.ក. (វ.ជ.ស.) |
| ៩.៤ | *ឧស្សាហកម្ម* | % | ៦០ | ៥៥ | ៥០ | ៥០ | ៥០ | ៥០ | ជ.ទ.ប.ក. (វ.ជ.ស.) |
| ៩.៥ | *សេវា* | % | ៣០ | ៣៥ | ៤០ | ៤០ | ៤០ | ៤០ | ជ.ទ.ប.ក. (វ.ជ.ស.) |
| ៩.៦ | សមាមាត្រស្ត្រីដែលបានបញ្ចប់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេលវែង | នាក់ | ៨ ០០០ | ៨ ៥០០ | ៩ ០០០ | ៩ ៥០០ | ១០ ០០០ | ១១ ០០០ | ប.ព.រ.ក.ស. (ក.ក.ប.វ.) |
| | យេនឌ័រនិងការអប់រំ | | | | | | | | |
| ៩.៧ | អត្រារួមនៃស្ត្រីសិក្សានៅមធ្យមសិក្សា | % | ២៧,៦ | ២៧,២ | ២៨,៤ | ៣១,៥ | ៣៥,៦ | ៤១,៩ | ក.អ.យ.ក. |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| | ទុតិយភូមិ | | | | | | | | |
| ៩.៨ | អត្រាសរុបនៃស្ត្រីសិក្សានៅឧត្តមសិក្សា | % | ១២ | ១៣ | ១៤ | ១៦ | ១៨ | ២០ | ក.អ.យ.ក. |
| | យេនឌ័រនិងសុខភាព | | | | | | | | |
| ៩.៩ | ភាគរយស្ត្រីទៅពិនិត្យផ្ទៃពោះយ៉ាងតិច ២ដង | % | ៨៧ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ | ប.ព.វ.ក.ស. (ក.ស.ក.) |
| | យេនឌ័រនិងអំពើហិង្សា | | | | | | | | |
| ៩.១០ | ចំនួនគ្រួសារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ | ចំនួន | ២៧ 000 | ២៥ 000 | ២៣ 000 | ២០ 000 | ១៨ 000 | ១៥ 000 | ប.ព.វ.ក.ស. (ក.ក.ន.) |
| | យេនឌ័រនិងបម្រែបម្រួលអាកាសធាតុ | | | | | | | | |
| ៩.១១ | មេគ្រួសារជាស្ត្រីដែលបានទទួលផលពីកម្មវិធីប្រែប្រួលអាកាសធាតុ | ចំនួន | ៥0 000 | ៧0 000 | ៩0 000 | ១១0 000 | ១៣0 000 | ១៥0 000 | ប.ព.វ.ក.ស. (ក.ក.ន.) |
| ៩.១២ | ចំនួនគ្រួសារដែលមានលទ្ធភាពទទួលបានទឹកស្អាតពេញមួយឆ្នាំ | ចំនួន | ១ ៩00 000 | ២ 000 000 | ២ ១00 000 | ២ ២00 000 | ២ ៣00 000 | ២ ៤00 000 | ប.ព.វ.ក.ស. (ក.ក.ន.) |
| ១០ | *សមាហរណកម្មកម្ពុជាទៅក្នុងពិភពលោក* | | | | | | | | |
| ១០.១ | វិនិយោគផ្ទាល់ពីបរទេស | % *ផ.ស.ស.* | ១៣,៤ | ១៣,0 | ១៣,១ | ១៣,១ | ១៣,១ | ១៣,២ | ប.ព.វ.ក.ស. (ធ.ជ.ក.) |
| ១០.២ | ការនាំចេញ នាំចូល(ទំនិញ) | % *ផ.ស.ស.* | ១0៤,៦ | ១0៥,៨ | ១0៨,២ | ១0៨,៩ | ១១១ | ១១១,២ | ប.ព.វ.ក.ស. (ធ.ជ.ក.) |
| ១០.៣ | តុល្យភាពគណនីចរន្ត | % *ផ.ស.ស.* | -៩,៥ | -៩,៣ | -៨,៨ | -៨,១ | -៦,៧ | -៥,២ | ក.ស.ហ. |
| ១០.៤ | និន្នាការនៃជំនួយអភិវឌ្ឍ | *លានដុល្លារ* | ១ ៥៦៦,៤ | ១ ២៤២,២ | ១ 000,៨ | | | | ក.អ.ក. |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១១ | *ការធ្វើឱ្យមានស្ថិរភាពកំណើនម៉ាក្រូសេដ្ឋកិច្ចខ្ពស់* | | | | | | | | |
| ១១.១ | កំណើន *ផ.ស.ស.* ប្រចាំឆ្នាំ | % | ៧,៦ | ៧,០ | ៧,០ | ៧,០ | ៧,០ | ៧,០ | ក.ស.ហ. |
| ១១.២ | *ផ.ស.ស.* សម្រាប់មនុស្សម្នាក់ (តម្លៃបច្ចុប្បន្ន) | ពាន់រៀល | ៤ ២៤៨ | ៤ ៦៧០ | ៥ ០៧២ | ៥ ៥២៣ | ៥ ៩៤៩ | ៦ ៤៧២ | ក.ស.ហ. |
| ១១.៣ | សន្ទស្សន៍កំណើនបរិយាប័ន្ន (ឆ្នាំគោល = ២០១៣=១០០) | ចំនួន | ១០៧ | ១១៤,៥ | ១២២,៥ | ១៣១,១ | ១៤០,៣ | | ក.ស.ហ. |
| | *រចនាសម្ព័ន្ធនៃផសស* | | | | | | | | |
| ១១.៤ | *កសិកម្ម* | % នៃ *ផ.ស.ស.* សរុប | ២៦,៦ | ២៥,៦ | ២៥,១ | ២៤,៤ | ២៣,៨ | ២៣,១ | ក.ស.ហ. |
| ១១.៥ | *ឧស្សាហកម្ម* | % នៃ *ផ.ស.ស.* សរុប | ៣១,៦ | ៣២,៦ | ៣៣,២ | ៣៣,៨ | ៣៤,៤ | ៣៥,០ | ក.ស.ហ. |
| ១១.៦ | *សេវា* | % នៃ *ផ.ស.ស.* សរុប | ៤១,៨ | ៤១,៨ | ៤១,៧ | ៤១,៨ | ៤១,៨ | ៤១,៩ | ក.ស.ហ. |
| | ការប្រែប្រួលអត្រាកំណើនតាមវិស័យ (គិតតម្លៃឆ្នាំ២០០៦) | | | | | | | | |
| ១១.៧ | *កសិកម្ម* | % នៃ *ផ.ស.ស.* សរុប | ៤,២ | ៤,២ | ៤ | ៤ | ៤ | ៤ | ក.ស.ហ. |
| ១១.៨ | *ឧស្សាហកម្ម* | % នៃ *ផ.ស.ស.* សរុប | ៩,៣ | ៩,៩ | ៩,៣ | ៩,១ | ៨,៨ | ៨,៨ | ក.ស.ហ. |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១១.៩ | សេវា | % នៃ ផ.ស.ស. សរុប | ៨,៨ | ៦,៨ | ៧,១ | ៧,១ | ៧,២ | ៧,២ | ក.ស.ហ. |
| | អត្រាអតិផរណា(ការប្រែប្រួលជា%) | | | | | | | | |
| ១១.១០ | ការប្រែប្រួលជាមធ្យមប្រចាំឆ្នាំ | % | ៣ | ៣,៣ | ៣,៥ | ៣,៥ | ៣,៥ | ៣,៥ | គណនេយ្យជាតិ (វ.ជ.ស.) |
| ១២ | ការកែលម្អការគ្រប់គ្រងថវិកា | | | | | | | | |
| ១២.១ | ចំណូលថវិការដ្ឋសរុប | % ផ.ស.ស. | ១៤,៣ | ១៥,១ | ១៥,៦ | ១៦,១ | ១៦,៥ | ១៦,៩ | ប.ព.វ.ក.ស. (ក.ស.ហ.) |
| ១២.២ | ចំណាយថវិការដ្ឋសរុប | % ផ.ស.ស. | ១៩,៥ | ១៩,៩ | ១៩,៨ | ១៩,៩ | ១៩,៩ | ១៩,៩ | ប.ព.វ.ក.ស. (ក.ស.ហ.) |
| ១៣ | ការងារ | | | | | | | | |
| | ការបែងចែកភាពមានការងារធ្វើតាមវិស័យ (១៥-៦៤ឆ្នាំ) | | | | | | | | |
| ១៣.១ | កសិកម្ម | % | ៦២ (២០១១) | ៦០ | ៥៩ | ៥៨ | ៥៧ | ៥៧ | ជ.ទ.ប.ក. (វ.ជ.ស.) |
| ១៣.២ | ឧស្សាហកម្ម | % | ១០ (២០១១) | ១១ | ១១ | ១២ | ១២ | ១៣ | ជ.ទ.ប.ក. (វ.ជ.ស.) |
| ១៣.៣ | សេវា | % | ២៨ (២០១១) | ២៩ | ៣០ | ៣០ | ៣១ | ៣១ | ជ.ទ.ប.ក. (វ.ជ.ស.) |
| ១៤ | ហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១៤.១ | ប្រវែងផ្លូវកៅស៊ូ នៃប្រវែងសរុប១១ ៩១៤គម. (ផ្លូវជាតិនិងផ្លូវខេត្ត) | គ.ម. | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ប.ព.វ.ក.ស. (ក.ស.ដ.) |
| ១៤.២ | ផ្លូវដែកដែលបានស្តារឡើងវិញនិងសង់ថ្មី | គ.ម. | ២៦៦ | ៣៨៦ | ២៥៧ | ៣១៩ | ២៤៨ | ២៤៨ | ប.ព.វ.ក.ស. (ក.ស.ដ.) |
| ១៤.៣ | ទេសចរអន្តរជាតិ | លាននាក់ | ៤,០៥ | ៤,៥៣ | ៥,០០ | ៥,៥២ | ៦,១០ | ៦,៧០ | ប.ព.វ.ក.ស. (ក.ទ.) |
| | លទ្ធភាពទទួលបានព័ត៌មានសាធារណៈ នៃប្រជាជនសរុប | | | | | | | | |
| ១៤.៤ | *វិទ្យុនិងទូរទស្សន៍* | % | ៨៥ | ៨៦ | ៨៧ | ៨៨ | ៨៩ | ៩០ | ប.ព.វ.ក.ស. (ក.ព.ម.) |
| ១៤.៥ | *ទស្សនាវដ្តី/សារព័ត៌មាន* | % | ៤,២ | ៤,៦ | ៥,០ | ៥,២ | ៥,៥ | ៥,៨ | ប.ព.វ.ក.ស. (ក.ព.ម.) |
| *១៥* | *ថាមពល* | | | | | | | | |
| ១៥.១ | លទ្ធភាពទទួលបានអគ្គិសនី | គវម៉ | ២៧២ | ៣០០ | ៣៣០ | ៣៦៣ | ៣៩៩ | ៤៣៩ | ប.ព.វ.ក.ស. (ក.វ.ថ.) |
| *១៦* | *ការបោសសម្អាតមីន ការជួយសង្គ្រោះជនរងគ្រោះ* | | | | | | | | |
| ១៦.១ | ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ | ចំនួន | ១៦៧ | ១៥១ | ១៣៦ | ១២២ | ១១០ | ៩៩ | ប.ព.វ.ក.ស. (អ.ម.ក.) |
| ១៦.២ | ផ្ទៃដីសរុបដែលបានបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម | ហ.ត. | ៨ ៧០៨ | ៩ ១៤៣ | ៩ ៦០០ | ១០ ០៨០ | ១០ ៥៨៤ | ១១ ១១៣ | ប.ព.វ.ក.ស. (អ.ម.ក.) |

## តារាងទី ៦.៣-សូចនាករបន្ថែម

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១.១ | ផ.ស.ស. ពិត (តម្លៃថេរឆ្នាំ២០០០) | ពាន់លានរៀល | ៦៤ ១៤១ | ៧០ ៧១៨ | ៧៧ ៥១០ | ៨៤ ៨៣៨ | ៩២៨២១ | ១០១ ៥៣៧ | គណនេយ្យជាតិ (វ.ជ.ស.) |
| ១.២ | ទុនបម្រុងបរទេសដុល | ចំនួនខែនាំចូលទំនិញ និងសេវា | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ប.ព.រ.ក.ស. (ធ.ជ.ក.) |
| ១.៣ | ការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី | % | | ២៨ | | | | ៥០ | ប.ព.រ.ក.ស. (គ.ជ.ទ៊/ក.អ.ក.) |
| ១.៤ | ការប្រើប្រាស់ប្រព័ន្ធជាតិ | % | | ៣២ | | | | ៥០ | ប.ព.រ.ក.ស. (គ.ជ.ទ៊/ក.អ.ក.) |
| ២.១ | ផ្ទៃដីដាំដុះដំណាំស្រូវ | លានហ.ត. | | ៣,១០ | ៣,១៥ | ៣,២០ | ៣,២៨ | ៣,៣៤ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.២ | រៀបចំនិងពង្រឹងសមត្ថភាពកសិករប្រើប្រាស់ទឹក | កន្លែង | ៤៣៤ | ៥ | ៥ | ៥ | ៥ | ៥ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ២.៣ | សាងសង់ស្ថានីយបូមទឹក | កន្លែង | ៣០ | ៥ | ៥ | ៥ | ៥ | ៥ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ២.៤ | ដំឡើងស្ថានីយជលសាស្ត្រ | កន្លែង | ១៩ | ៨ | ៨ | ៨ | ៨ | ៨ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ២.៥ | ដំឡើងស្ថានីយឧតុនិយម | កន្លែង | ២១ | ៤ | ៤ | ៤ | ៤ | ៤ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ២.៦ | ផ្ទៃដីដាំដុះដំណាំកៅស៊ូ | ពាន់ហ.ត. | | ៣០៦ ៥០០ | ៣៣៤ ៥០០ | ៣៦២ ៥០០ | ៣៨៤ ៥០០ | ៤០៤ ៥០០ | ប.ព.រ.ក.ស. |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | (ក.ក.រ.ន.) |
| ២.៧ | ផលិតកម្មជ័រស្ងួត | តោន | | ១៣៧ ៥២០ | ១៨១៥៦០ | ២៤០ ៨០០ | ៣០០ ៨០០ | ៣៤០ ៩៣០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| | ផលិតកម្មចិញ្ចឹមសត្វ | | | | | | | | |
| ២.៨ | ផលិតកម្មសត្វគ្រប់ប្រភេទក្នុងកំណើន៣% | លានក្បាល | | ៣៥,៨៦ | ៣៦,៩៣ | ៣៨,០៣ | ៣៩,១៧ | ៤០,៣៤ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.៩ | សត្វដែលទទួលបានវ៉ាក់សាំង | % | | ១០ | ១២ | ១៥ | ១៧ | ២០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.១០ | ចំនួនសត្តឃាតដ្ឋានដែលអនុវត្តអនាម័យល្អតាមបទដ្ឋានបច្ចេកទេស | ចំនួនកន្លែង | | ២៥ | ៥០ | ៧៥ | ១០០ | ១២៥ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| | *ការអភិវឌ្ឍជនបទ* | | | | | | | | |
| ២.១១ | ប្រវែងផ្លូវជនបទដែលបានក្រាលកៅស៊ូពីរជាន់ ឬបេតុង | គ.ម. | ១២៥ | ៥៥០ | ៩៨០ | ១ ៤៣០ | ១ ៨៨០ | ២ ៣៣០ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១២ | ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ | ក្រុម | ៨០ | ១០០ | ១៣០ | ១៦០ | ១៩០ | ២២០ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៣ | ចំនួនភូមិដែលបានបណ្តុះបណ្តាលគ.អ.ភ. ស្តីពីផែនការអភិវឌ្ឍន៍ភូមិ | ភូមិ | ៦៧៣ | ១ ៦១០ | ១ ៨០០ | ២ ០០០ | ២ ២០០ | ២ ៤០០ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៤ | សិក្សានិងសាងសង់សាកល្បងផ្លូវជនបទក្រាលកៅស៊ូ៤៥០គមដែលអាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុ១០០% | គ.ម. | ០ | ០ | ៦៧,៥០ | ១៥៧,៥ | ២៧០ | ៣៦០ | ប.ព.រ.ក.ស. (ក.អ.ជ.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២.១៥ | កសាងសមត្ថភាពគ.អ.ភស្តីពីជម្រើសនៃបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិង ប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្របមួយ ដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន | គ.អ.ភ. | 0 | 0 | ១ ៨៥៤ | ២ ៤៧២ | ៣ ០៩០ | ៣ ៧០៨ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៦ | ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ ទឹក ដែលមានការកែលម្អប្រកបដោយចីរភាព (ក្រុមចំណាយ២៥%ទាបបំផុត) | % | ៤២ | ៤៤,២ | ៤៦,៧០ | ៥០ | ៥៣ | ៦៧ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៧ | ភាគរយប្រជាជនជនបទទទួលបានសេវា អនាម័យ ដែលមានការកែលម្អប្រកបដោយ ចីរភាព (ក្រុមចំណាយ២៥%ទាបបំផុត) | % | ៣៣,៣ | ៣៧,៥ | ៤២ | ៤៦ | ៥០ | ៥៥ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៨ | សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជី | ចំនួន សហគមន៍ | - | ១៨ | ២៨ | ៣៨ | ៤៨ | ៥៨ | ប.ព.រ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.១៩ | ដំណោះស្រាយទំនាស់ដីធ្លី | ករណី | | ៤ ៨៥០ | ៥ ០៥០ | ៥ ២៥០ | ៥ ៤៥០ | ៥ ៦៥០ | ប.ព.រ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.២០ | សម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារ ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | | ៣៥ ០០០ | ៣៧ ០០០ | ៣៩ ០០០ | ៤១ ០០០ | ៤៣ ០០០ | ប.ព.រ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.២១ | ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ | ចំនួន | | ១៤៥ | ១៦៥ | ១៨៥ | ២០៥ | ២២៥ | ប.ព.រ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.២២ | ប្លង់គោលថ្នាក់ស្រុក ខណ្ឌ | ចំនួន | | ២២ | ២៥ | ២៨ | ៣១ | ៣៤ | ប.ព.រ.ក.ស. (ក.រ.ដ.ន.ស.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២.២៣ | ប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង | ចំនួន | | ១៨ | ២០ | ២២ | ២៤ | ២៦ | ប.ព.រ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.២៤ | ផែនការរៀបចំដែនដីថ្នាក់ខេត្ត | ចំនួន | | ១ | ២ | ៣ | ៤ | ៥ | ប.ព.រ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.២៥ | សមាមាត្រនៃផ្ទៃដីបានបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | % | ៥,៥ | ៤,៧ | ៥ | ៥,៣ | ៥,៥ | ៥,៨ | ប.ព.រ.ក.ស. (អ.ម.ក.) |
| ២.២៦ | ផលិតកម្មវារីវប្បកម្មកើន១៥% (តោន) | តោន | | ៩៧ ៨០០ | ១១២ ៥០០ | ១២៩ ៤០០ | ១៤៨ ៨០០ | ១៧១ ១៧០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.២៧ | សហគមន៍នេសាទ | ចំនួន | | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.២៨ | ផលិតកម្មនេសាទ | ពាន់តោន | | ៧៥២ | ៧៩០ | ៨២៩ | ៨៧០ | ៩១០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.២៩ | សហគមន៍ព្រៃឈើ | សហគមន៍ | | ៥០០ | ៥២០ | ៥៥០ | ៥៧០ | ៦០០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.៣០ | ការដាំដុះឈើឡើងវិញ (គិតចាប់ពីឆ្នាំ១៩៨៥) | ពាន់ហ.ត. | | ២០ ២៨០ | ២២ ៣០០ | ២៤ ៥០០ | ២៧០០០ | ២៩ ៧០០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.៣១ | ឧទ្យានុរក្សក្នុងតំបន់ការពារធម្មជាតិ | ចំនួន | ៩៦០ | ១ ០០០ | ១ ០៥០ | ១ ១០០ | ១ ១០០ | ១ ១៥០ | ប.ព.រ.ក.ស. (ក.ប.ស.) |
| ២.៣២ | ការកំណត់ព្រំប្រទល់និងផែនទី សម្រាប់តំបន់ការពារធម្មជាតិ | ចំនួនបង្គោលព្រំ | ៨២០ | ៨២០ | ៩០៦ | ១ ១៥៦ | ១ ២៥៦ | ១ ៣៥៦ | ប.ព.រ.ក.ស. (ក.ប.ស.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២.៣៣ | តំបន់រ៉ាមសារ | ចំនួន | ៣ | ៤ | ៤ | ៥ | ៥ | ៥ | ប.ព.រ.ក.ស. (ក.ប.ស.) |
| ២.៣៤ | ផលធៀបនៃចំណាយពាក់ព័ន្ធនឹងអាកាសធាតុធៀបនឹងផ.ស.ស. | % | ១,៣០ | ១,៣៥ | ១,៣៩ | ១,៤៣ | ១,៤៧ | ១,៥០ | ប.ព.រ.ក.ស. (ក.ប.ស.) |
| ២.៣៥ | ការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ក្រសួង ស្ថាប័ន | ១១ | ១៣ | ១៥ | ១៧ | ១៩ | ២១ | ប.ព.រ.ក.ស. (ក.ប.ស.) |
| ២.៣៦ | ចំនួនឃុំដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ | ឃុំ | ៦៥០ | ៦០០ | ៥៥០ | ៥០០ | ៤៥០ | ៤០០ | ប.ព.រ.ក.ស. (ក.ប.ស.) |
| ២.៣៧ | ឥណទានកាបូនបានពីយន្តការអភិវឌ្ឍន៍ស្អាត និងយន្តការផ្សេងៗ (REDD+ និងទីផ្សារស្ម័គ្រចិត្ត) | $GgCO_2$-eq | ២ ០៥០ ០០០ | ២ ១០០ ០០០ | ២ ១៥០ ០០០ | ២ ២០០ ០០០ | ២ ២៥០ ០០០ | ២ ៣០០ ០០០ | ប.ព.រ.ក.ស. (ក.ប.ស.) |
| ៣.១ | ជើងហោះហើរ | | | | | | | | |
| ៣.១.១ | *អន្តរជាតិ* | ចំនួន | ៤៤ ២៦០ | ៤៨ ៦៨៦ | ៥៣ ៥៥៥ | ៥៨ ៩១០ | ៦៤ ៨០១ | ៧១ ២៨១ | ប.ព.រ.ក.ស. (រ.អ.ស.រ.) |
| ៣.១.២ | *ក្នុងស្រុក* | ចំនួន | ៩ ៤០០ | ១០ ៣៤០ | ១១ ៣៧៤ | ១២ ៥១២ | ១៣ ៧៦៣ | ១៥ ១៣៩ | ប.ព.រ.ក.ស. (រ.អ.ស.រ.) |
| ៣.២ | អ្នកដំណើរតាមផ្លូវអាកាស | | | | | | | | |
| ៣.២.១ | *អន្តរជាតិ* | នាក់ | ៤ ៣១១ ៥៤៩ | ៤ ៧៤២ ៧០៤ | ៥ ២១៦ ៩៧៤ | ៥ ៧៣៨ ៦៧១ | ៦ ៣១២ ៥៣៨ | ៦ ៩៤៣ ៧៩២ | ប.ព.រ.ក.ស. (រ.អ.ស.រ.) |
| ៣.២.២ | *ក្នុងស្រុក* | នាក់ | ២៩៦ ៤១៣ | ៣២៦ ០៥៤ | ៣៥៨ ៦៥៩ | ៣៩៤ ៥២៥ | ៤៣៣ ៩៧៧ | ៤៧៧ ៣៧៥ | ប ប.ព.រ.ក.ស. (រ.អ.ស.រ.) |
| ៣.៣ | បរិមាណទំនិញ | | | | | | | | |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៣.៣.១ | *អន្តរជាតិ* | តោន | ៣១ ៩៧៧ | ៣៥ ១៧៥ | ៣៨ ៦៩៣ | ៤២ ៥៦២ | ៤៦ ៨១៨ | ៥១ ៤៩៩ | ប.ព.រ.ក.ស. (រ.អ.ស.វ.) |
| ៣.៣.២ | *ក្នុងស្រុក* | តោន | ៥១៦ | ៥៦៨ | ៦២៥ | ៦៨៧ | ៧៥៦ | ៨៣២ | ប.ព.រ.ក.ស. (រ.អ.ស.វ.) |
| ៣.៤ | ការផលិតអគ្គិសនីក្នុងស្រុក | លាន គវម៉ | ១ ៨១៩ | ២ ៤៤០,៤៤ | ៣ ១០៧,៤៤ | ៣ ៨១៤,៤៤ | ៤ ២៣៤,០៣ | ៤ ៦១៥,០៩ | ប.ព.រ.ក.ស. (ក.ឱ.រ.ថ.) |
| ៣.៥ | ការនាំចូលអគ្គិសនី | លាន គវម៉ | ២ ៤៧៨,១៦ | ២ ៦០៩,៥៦ | ២ ៦០៩,៥៦ | ២ ៦០៩,៥៦ | ៤ ១៨៦,៣៦ | ៤ ១៨៦,៣៦ | ប.ព.រ.ក.ស. (ក.ឱ.រ.ថ.) |
| ៣.៦ | អត្រាអ្នកប្រើប្រាស់ទូរស័ព្ទ | ក្នុងចំណោមប្រជាជន ១០០នាក់ | ១៥៩,១៩ | ១៨៩,៨៦ | ២២៦,៤១ | ២៧០,០៥ | ៣២២,២៣ | ៣៨៤,៥០ | ប.ព.រ.ក.ស. (ក.ប.ទ.) |
| ៣.៧ | អ្នកប្រើប្រាស់អ៊ិនធឺណិត | នាក់ | ៤,៣៣ | ៦,៩៣ | ១១,០៩ | ១៣,៤១ | ១៦,២៣ | ១៩,៦៤ | ប.ព.រ.ក.ស. (ក.ប.ទ.) |
| ៤.១ | សេវាចុះបញ្ជីពាណិជ្ជកម្ម | ក្រុមហ៊ុន | ៣ ៦០៣ | ៣ ៧៨២ | ៣ ៩៧១ | ៤ ១៦៩ | ៤ ៣៧៧ | ៤ ៥៩៥ | ប.ព.រ.ក.ស. (ក.ព.ណ.) |
| ៤.២ | សេវាកម្មចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម | ក្រុមហ៊ុន | ៤ ៦៣៦ | ៤ ៧២៨ | ៤ ៨២១ | ៤ ៩១៤ | ៥ ០០៧ | ៥ ០៩៩ | ប.ព.រ.ក.ស. (ក.ព.ណ.) |
| ៤.៣ | សេវាចុះឈ្មោះការិយាល័យតំណាងពាណិជ្ជកម្មនិងសាខាក្រុមហ៊ុនបរទេសក្នុងបញ្ជីពាណិជ្ជកម្ម | ក្រុមហ៊ុន | ២៧ | ២៨ | ២៩ | ៣០ | ៣២ | ៣២ | ប.ព.រ.ក.ស. (ក.ព.ណ.) |
| ៤.៤ | ចំណូលទេសចរណ៍ | លានដុល្លារ | ២ ៥៤៧ | ២ ៨០២ | ៣ ០៥៤ | ៣ ៣៥៩ | ៣ ៧២៩ | ៤ ១៣៩ | ប.ព.រ.ក.ស. |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | (ក.ព.ណ.) |
| ៤.៥ | ជួសជុលប្រាសាទបុរាណ | កន្លែង | ០៣ | ០២ | ០៣ | ០៣ | ០៣ | ០៣ | ប.ព.វ.ក.ស. (ក.វ.វ.) |
| ៤.៦ | កំណាយស្ថានីយបុរាណវិទ្យា | កន្លែង | ០១ | ០១ | ០២ | ០២ | ០២ | ០២ | ប.ព.វ.ក.ស. (ក.វ.វ.) |
| ៤.៧ | និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ | ចំនួន | ៤០ ០០០ | ៤៥ ០០០ | ៥០ ០០០ | ៥៥ ០០០ | ៦០ ០០០ | ៦៥ ០០០ | អ.ស.ស.ក. (វ.ជ.ស.) |
| ៤.៨ | អតីតយុទ្ធជនដែលកំពុងទទួលរបប | ចំនួន | ៩៤ ៩៥៩ | ៩៨ ៦៣៤ | ១០១ ៣០៩ | ១០៣ ៩៨៤ | ១០៦ ៦៥៩ | ១០៩ ៣៣៤ | អ.ស.ស.ក./ ជ.ទ.ប.ក. (វ.ជ.ស.) |
| ៤.៩ | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា | ចំនួន | ២៥ ៩៦៧ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ប.ព.វ.ក.ស. (ក.ក.ប.វ.) |
| ៤.១០ | ចំនួនកុមារដែលរស់នៅក្នុងមណ្ឌលថែទាំកុមារក្នុងចំណោមកុមារ១០០ ០០០នាក់ | ចំនួន | ១០៦៧៩ | ១០៣១០ | ៩៩៤២ | ៩៥៧៤ | ៩២០៥ | ៨ ៨៣៧ | ប.ព.វ.ក.ស. (ក.ស.អ.យ.) |
| ៤.១១ | កុមារទទួលបានការថែទាំនៅសហគមន៍ | ចំនួន | ៨៥ ៩២១ | ៩០ ០០០ | ៩៥ ០០០ | ១០០ ០០០ | ១០៥ ០០០ | ១១០ ០០០ | ប.ព.វ.ក.ស. (ក.ស.អ.យ.) |
| ៥.១ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | | |
| ៥.១.១ | *សរុប* | % | ៩៧,០ | ៩៧,៣ | ៩៧,៩ | ៩៨,៦ | ៩៩,៣ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.១.២ | *ទីប្រជុំជន* | % | ៨៩,៨ | ៩១,៨ | ៩៣,៩ | ៩៥,២ | ៩៧,៩ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.១.៣ | *ជនបទ* | % | ៩៨,៦ | ៩៨,៩ | ៩៩,២ | ៩៩,៤ | ៩៩,៧ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.២ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | | |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៥.២.១ | *សរុប* | % | ៥៦,៥ | ៦០,៤ | ៦៦,៩ | ៧៣,៧ | ៨១,៣ | ៨៧,៤ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.២.២ | *ទីប្រជុំជន* | % | ៧៨,៤ | ៨០,៧ | ៨៤,៨ | ៨៨,២ | ៩២,៣ | ៩៤,៣ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.២.៣ | *ជនបទ* | % | ៥២,៦ | ៥៦,៧ | ៦៣,៦ | ៧១,២ | ៧៩,២ | ៨៦,១ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.៣ | សន្ទស្សន៍យុត្តភាពយេនឌ័រនៃអត្រាពិតនៃការសិក្សានៅបឋមសិក្សា | % | ១ | ០,៩៩ | ០,៩៩ | ០,៩៩ | ០,៩៩ | ១ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៤ | សន្ទស្សន៍យុត្តភាពយេនឌ័រនៃអត្រាពិតនៃការសិក្សា នៅមធ្យមសិក្សាបឋមភូមិ | % | ០,៩៧ | ០,៩៧ | ០,៩៦ | ០,៩៦ | ០,៩៧ | ០,៩៦ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៥ | សន្ទស្សន៍យុត្តភាពយេនឌ័រនៃអត្រាពិតនៃការសិក្សា នៅមធ្យមសិក្សាទុតិយភូមិ | % | ០,៨៦ | ០,៨៩ | ០,៩១ | ០,៩០ | ០,៨៦ | ០,៨៣ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៦ | សន្ទស្សន៍យុត្តភាពយេនឌ័រនៅឧត្តមសិក្សា | % | ០,៧២ | ០,៧៣ | ០,៧៥ | ០,៧៧ | ០,៧៨ | ០,៨ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| | អត្រាត្រួតថ្នាក់ | | | | | | | | |
| ៥.៧ | *បឋមសិក្សា* | % | ៤ | ៤ | ៣ | ៣ | ៣ | ២ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៨ | *មធ្យមសិក្សាបឋមភូមិ* | % | ១,៥ | ១,៥ | ១,៣ | ១,៣ | ១ | ១ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៩ | សមាមាត្រស្ត្រីមានផ្ទៃពោះដែលបានប្រើប្រាស់សេវាថែទាំសុខភាពមុនពេលសម្រាល ២ដង ឬច្រើនដង ដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល | % | ៨៧ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ | ប.ព.រ.ក.ស. (ក.ស.ភ.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៥.១០ | សមាមាត្រអាសនៈនៅក្នុងព្រឹទ្ធសភា | % | ១៤,៧ | ១៤,៧ | ១៤,៧ | ១៤,៧ | ៣០ | ៣០ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១១ | សមាមាត្រស្ត្រីក្នុងរដ្ឋសភា | % | ២០ | ២០ | ២០ | ២០ | ២០ | ៣០ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១២ | សមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សា | | | | | | | | |
| ៥.១២.១ | *រាជធានី ខេត្ត* | % | ១០ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១២.២ | *ខណ្ឌ ស្រុក* | % | ១២,៦៨ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១២.៣ | *ក្រុមប្រឹក្សាឃុំ/សង្កាត់* | | ១៨ | ១៨ | ១៨ | ១៨ | ២៥ | ២៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១៣ | សមាមាត្រស្ត្រីជាអគ្គនាយក | % | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១៤ | សមាមាត្រស្ត្រីជាប្រធាននាយកដ្ឋាន | % | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៦ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១៥ | សមាមាត្រស្ត្រីជាប្រធានខុទ្ទកាល័យ/ប្រធានមន្ទីរ | % | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១៦ | អត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងគ្រួសារ | ចំនួន | ១២,៨ | ១២,៨ | ១១,៥ | ១១,៥ | ១១,៥ | ១១,៥ | មូលដ្ឋានទិន្នន័យឃុំសង្កាត់ |
| ៥.១៧ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | % | ៣៧ | ៣៩ | ៥១ | ៥២ | ៥៣ | ៥៤ | ប.ព.រ.ក.ស. (ក.ស.ភ.) |

## តារាងទី៦.៤ បញ្ជីការសិក្សាសម្រាប់វិស័យអាទិភាពចំនួន៣

**កសិកម្ម**

- ទំហំកសិកម្មនិងផលិតភាពដី/ពលកម្ម និងភាពចំណេញ
- ការប្រើដី/ប្រព័ន្ធធារាសាស្ត្រ រួមទាំងផលប៉ះពាល់លើអេកូឡូស៊ី
- ការបង្ហូរទឹកចេញ
- កសិកម្មដោយប្រើម៉ាស៊ីន
- រចនាសម្ព័ន្ធនៃប្រាក់ចំណូលពីកសិកម្ម
- ទីផ្សារការងារនៅជនបទនិងប្រាក់កម្រៃ
- ដំណាំរួមផ្សំ/ការជួលដីធ្វើកសិកម្ម
- ការប្រើពូជស្រូវដែលផ្ដល់ទិន្នផលខ្ពស់
- ការធ្វើទីផ្សារ ការធ្វើកសិកម្មដោយមានកិច្ចសន្យា ការរក្សាទុក សំណល់ និងតម្លៃ
- ឥទ្ធិពលនៃឥណទាន(តាមប្រភេទឥណទាន)
- ទំនាក់ទំនងទីផ្សារនិងចំណូលរបស់កសិករ
- ការដាំដំណាំ ការចិញ្ចឹមត្រី ការចិញ្ចឹមសត្វ ប្រព័ន្ធដំណាំ
- ផ្លូវថ្នល់ ព័ត៌មានទំនាក់ទំនងគ្នា និងតម្លៃផលិតផលកសិកម្ម/ប្រាក់ចំណេញ
- ឥទ្ធិពលនៃបច្ចេកវិទ្យាព័ត៌មានស្ដីពីតម្លៃ
- ការចែកចាយទឹក តម្លៃសម្រាប់អ្នកប្រើប្រាស់ សហគមន៍អ្នកប្រើប្រាស់ទឹក

**អភិវឌ្ឍន៍ជនបទ**

- ចំណេះដឹង ឥរិយាបថ និងការអនុវត្ត ទាក់ទងនឹងសុខភាព ទឹក អនាម័យ ការប្រើប្រាស់ និងការអភិរក្សទឹកស្អាត និងសុខភាពកុមារ
- អនាម័យនិងសុខភាពកុមារ/សុខភាពទូទៅ
- ឥទ្ធិពលនៃការប្រើប្រាស់ទឹកអណ្ដូងលើសុខភាព
- ឥទ្ធិពលនៃផ្លូវជនបទលើការអប់រំ សុខភាព ជាដើម(តាមភេទ)
- ការផ្ទេរប្រាក់និងឥទ្ធិពលរបស់វា
- អាហារ/ប្រាក់សម្រាប់កម្មវិធីការងារ
- ឥទ្ធិពលនៃកម្មវិធីអាហារូបត្ថម្ភលើសុខភាព ការចូលរៀន ស្ថានភាពស្ត្រី
- ឥទ្ធិពលនៃសម្បទានដីសង្គមកិច្ចលើជីវភាពរស់នៅតាមជនបទ
- ឥទ្ធិពលនៃការបែងចែកជំនាញលើជីវភាពរស់នៅ

**កុមារ/ការអប់រំ**

- អាហារូបត្ថម្ភនិងកង្វះអាហារូបត្ថម្ភ
- ការការពារកុមារនិងសិទ្ធិកុមារ ពលកម្មកុមារ
- តម្រូវការអប់រំពិសេស
- ការចូលសិក្សារបស់កុមារ
- គុណភាពនៃការអប់រំ
- បញ្ហានិងតម្រូវការរបស់យុវតី
- តម្រូវការការបណ្ដុះបណ្ដាលនិងការងារ

## តារាងទី៦.៥ សូចនាករជ្រើសរើសនៅថ្នាក់ក្រោមជាតិ

| ខេត្ត | អប់រំ | | ទឹក និង អនាម័យ | | ស្ថានភាពរស់នៅ | | សុខាភិបាល | |
|---|---|---|---|---|---|---|---|---|
| | Completion Rate Primary (2012-2013) (%) | Completion Rate Lr. Sec. (2012-2013) (%) | % Population getting Safe Water (CDB) 2011 | % Population accessing Hygienic Latrines 2011 | Poverty rate 2011 (%) | Paddy yield rate 2011 (tons/ha) | IMR 2010 (per 1,000 live births) | % Attended births 2012 |
| បន្ទាយមានជ័យ | 90.8 | 32.1 | 15.93 | 40.89 | 21.3 | 1.93 | 61 | 67 |
| បាត់ដំបង | 86.5 | 32.9 | 27.81 | 47.82 | 20.1 | 1.68 | 45 | 62 |
| កំពង់ចាម | 92.8 | 36.5 | 44.48 | 31.91 | 19.0 | 2.14 | 54 | 65 |
| កំពង់ឆ្នាំង | 92 | 38.6 | 37.26 | 29.33 | 20.1 | 1.97 | 78 | 64 |
| កំពង់ស្ពឺ | 92.7 | 33.3 | 63.01 | 28.43 | 17.5 | 1.77 | 65 | 57 |
| កំពង់ធំ | 86.4 | 34.9 | 34.04 | 37.88 | 22.9 | 1.58 | 57 | 45 |
| កំពត | 94.2 | 44.8 | 23.11 | 29.04 | 20.3 | 2.5 | 60 | 67 |
| កណ្តាល | 100 | 51.3 | 42.57 | 51.59 | 15.0 | 2.65 | 61 | 56 |
| កោះកុង | 75 | 37.3 | 38.27 | 44.91 | 22.7 | 2.07 | 50 | 50 |
| ក្រចេះ | 72.5 | 32.5 | 35.95 | 29.11 | 22.9 | 2.1 | 76 | 45 |
| មណ្ឌលគិរី | 57 | 25.8 | 35.09 | 27.56 | 26.1 | 2.37 | 82 | 42 |
| រាជធានីភ្នំពេញ | 84.6 | 54.9 | 74.92 | 93.39 | 3.1 | 2.29 | 13 | 45 |
| ព្រះវិហារ | 81 | 37.2 | 60.28 | 18.73 | 25.2 | 1.7 | 95 | 62 |
| ព្រៃវែង | 93.6 | 40.1 | 88.21 | 24.34 | 16.6 | 2.04 | 64 | 70 |
| ពោធិសាត់ | 81.2 | 32.2 | 34.26 | 28.21 | 22.3 | 2.28 | 50 | 71 |
| រតនៈគិរី | 59.9 | 24 | 19.09 | 23.17 | 28.6 | 1.96 | 82 | 50 |
| សៀមរាប | 88.4 | 37 | 33.85 | 32 | 21.3 | 1.66 | 50 | 79 |
| ព្រះសីហនុ | 73.3 | 33.6 | 74.84 | 56.6 | 11.9 | 2.1 | 50 | 61 |
| ស្ទឹងត្រែង | 60.1 | 30.8 | 33.93 | 30.96 | 24.8 | 1.95 | 95 | 48 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ស្វាយរៀង | 100 | 45 | 76.3 | 36.72 | 14.3 | 1.57 | 78 | 90 |
| តាកែវ | 100 | 54.7 | 24.69 | 35.55 | 16.2 | 2.45 | 68 | 76 |
| ឧត្តរមានជ័យ | 80.3 | 25.9 | 34.99 | 30.99 | 27.9 | 1.42 | 42 | 78 |
| កែប | 82.4 | 41.2 | 14.75 | 40.53 | 17.4 | 2.24 | 60 | 67 |
| ប៉ៃលិន | 65.2 | 31.3 | 58.28 | 40.87 | 17.7 | 2.02 | 45 | 74 |

ប្រភព÷ *Education: EMIS; Water/sanitation: CDB; Poverty rate: CSES/CDB; Paddy yield rate: CDB; IMR: CDHS; Attended births: HMINote: Targets are not set yet. They will have to be fixed in consultation with sub-national authorities and the concerned ministries.*

## ជំពូកទី៧

# សេចក្ដីសន្និដ្ឋាន

# ជំពូកទី៧

# សេចក្តីសន្និដ្ឋាន

**៧.១-** តាមរយៈ ការរៀបចំផែនការ និងការវិនិយោគ ដែលមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយ លើវិស័យហេដ្ឋារចនាសម្ព័ន្ធនិងមូលធនមនុស្ស ដែលជាកត្តាចម្បងសម្រាប់ *ព្រះរាជាណាចក្រកម្ពុជា* បានវិវឌ្ឍខ្លួនពីប្រទេសដែលខ្ទេចខ្ទាំដោយសង្គ្រាមស៊ីវិលទៅជាប្រទេសមួយដែលមានសក្តានុពលសេដ្ឋកិច្ចនិងជាប្រទេសគោលដៅនៃការវិនិយោគពីបរទេស។ សមិទ្ធផលទាំងអស់នេះ ស្តែងចេញតាមរយៈភាពជាសហគ្រិននិងការវិនិយោគឯកជន ដែលកើនឡើងជាបន្តបន្ទាប់និងដែលរួមចំណែកដល់កំណើន ផ.ស.ស. ប្រចាំឆ្នាំជាមធ្យម ៦-៧% ក្នុងរយៈពេលវែង ផ.ស.ស. សម្រាប់មនុស្សម្នាក់ កើនលើសពី១ ០០០ដុល្លារអាមេរិក សម្រាប់ឆ្នាំ២០១៣ និងអត្រាភាពក្រីក្របន្តថយចុះជាងពាក់កណ្តាល ក្នុងរយៈពេល១០ទៅ១២ឆ្នាំនៃការអនុវត្តបណ្តាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កន្លងមក។ ក្នុងន័យនេះ ទំហំវិនិយោគឯកជននាពេលបច្ចុប្បន្នមានសមាមាត្រខ្ពស់ជាងទំហំវិនិយោគសាធារណៈ។ ការអនុវត្ត ប្រកបដោយជោគជ័យនូវបណ្តាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ បាននាំកម្ពុជាឲ្យចាកចេញពីប្រទេសនាំចូលស្បៀង ឈានឡើងទៅជាប្រទេសមួយក្នុងចំណោមប្រទេសទាំង១០ ដែលបាននាំចេញអង្ករទៅក្រៅប្រទេស និងក្នុងចំណោមប្រទេសទាំង១៥ ដែលបានផលិតអង្ករច្រើនជាងគេនៅក្នុងពិភពលោក។ វឌ្ឍនភាពសំខាន់ៗ ក៏បានបន្តមាននៅក្នុងវិស័យនិងកិច្ចសហប្រតិបត្តិការមួយចំនួន រួមមាន ឧស្សាហកម្មវាយនភណ្ឌ ដែលបានអនុញ្ញាតឲ្យកម្ពុជា ក្លាយជាអ្នកផលិតនិងនាំចេញផលិតផលវាយនភណ្ឌ ប្រទេសកម្ពុជា បានក្លាយទៅជាគោលដៅទេសចរណ៍ និងជាសមាជិកភាពនៃសហគមន៍អាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងសហគមន៍តំបន់និងអន្តរជាតិ ។ កម្ពុជា ក៏បានជំរុញកំណើន បរិមាណគ្រឹះស្ថានអប់រំ នៅទូទាំងប្រទេស ដែលបឋមសិក្សាបានប្រមាណជា៧ ០០០ និងគ្រឹះស្ថានឧត្តមសិក្សាបានច្រើនជាង១០០)។

**៧.២-** សម្រាប់ការអភិវឌ្ឍប្រទេស ក្នុងដំណាក់កាល ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** *(ផ.យ.អ.ជ.) ២០១៤-២០១៨ រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តប្តេជ្ញាអនុវត្ត**ការងារដើម្បីឈានទៅ**សម្រេចវឌ្ឍនភាពថ្មីៗបន្ថែមទៀត ក៏ដូចជា បញ្ចប់ឲ្យរួចរាល់នូវគោលនយោបាយ កម្មវិធី និងផែនការសកម្មភាព ដែលមិនទាន់បានដោះស្រាយ នាអាណត្តិកន្លងមក និងត្រៀមទប់ទល់និង

កាត់បន្ថយភាពប្រឈមនាពេលអនាគត ដែលការងារប្រឈមទាំងនោះ រួមបញ្ចូល ទាំងការធ្វើសមាហរណកម្មពេញលេញក្នុងសហគមន៍អាស៊ាន និងការកាត់បន្ថយជំនួយសម្បទានពីខាងក្រៅ។ ក្នុងន័យនេះ ក៏ដូចជាវដ្តនៃការដំណើរការរៀបចំ *ផែនការយុទ្ធអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងសកម្មភាព* តម្រូវឲ្យមានការគិតគូរច្បាស់លាស់ និងជំរុញអនុវត្ត រួមមាន៖

- ការបង្កើនចំណូលថវិកាជាតិ ពីប្រភពពន្ធ គយ និងមិនមែនពន្ធគយ ប្រកបដោយចីរភាព និងស៊ីជម្រៅ ។
- ការពង្រឹកគុណភាពមូលធនមនុស្ស ផ្នែកឧស្សាហូបនីយកម្ម និងសេចក្តីសុខក្សេមក្សាន្ត របស់ប្រជាជន។
- ការលើកកម្ពស់សមត្ថភាព ក្នុងក្រសួង ស្ថាប័នរដ្ឋាភិបាល ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ សំដៅផ្តល់សេវាសាធារណៈ ដល់ប្រជាជន វិស័យឯកជន និងដៃគូនានាតាមរយៈធ្វើឲ្យទំនាក់ទំនងនិងការបែងចែកព័ត៌មាន រវាងក្រសួង ស្ថាប័ន ការធ្វើសមាណហរណកម្ម ការងាររវាងថ្នាក់ជាតិ និងបណ្តាក្រសួងនៅថ្នាក់ជាតិឲ្យកាន់តែប្រសើរ និងការជំរុញអភិបាលកិច្ចអេឡិកត្រូនិក(អភិបាលកិច្ចផ្អែកលើបច្ចេកវិទ្យា)។

៧.៣- ***ផ.យ.អ.ជ. ២០១៤-២០១៨*** គឺជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ដូចមានចែងក្នុង *យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣* ។ គោលបំណង របស់ ***ផ.យ.អ.ជ. ២០១៤-២០១៨*** គឺដើម្បីធានាដល់ការបន្សុីគ្នារវាងផែនការសកម្មភាព កម្មវិធីនិងគម្រោងរបស់បណ្តាក្រសួង ស្ថាប័នជាតិនិងថ្នាក់ក្រោមជាតិ ដែលត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់*រាជរដ្ឋាភិបាលកម្ពុជា* ដែលបានកំណត់ក្នុង*យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣* ។ ក្នុងន័យនេះ ***ផ.យ.អ.ជ. ២០១៤-២០១៨*** ក៏ធានា ផងដែរថា បណ្តាយុទ្ធសាស្រ្តដែលបានលើកឡើងដោយក្រសួង ស្ថាប័នជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់ផលប៉ះពាល់មកលើប្រទេសកម្ពុជា ដែលរួមមាន ការចាកផុតពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួចមកជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងការកាត់បន្ថយនូវជំនួយឥតសំណងនិងជំនួយបច្ចេកទេស។ ទន្ទឹមនេះ ***ផ.យ.អ.ជ. ២០១៤-២០១៨*** ក៏មានគោលបំណងធានាថា រាល់បណ្តាគោលនយោបាយ ដែលបានរៀបចំឡើង គឺធ្វើយ៉ាងណាដើម្បីគ្រប់គ្រងការធ្វើសមាហរណកម្មឲ្យបានពេញលេញក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។ *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងរៀបចំជាប្រព័ន្ធនិងជាលំដាប់លំដោយនូវវិធានការជាច្រើន សំដៅកាត់បន្ថយឥទ្ធិពលអវិជ្ជមាននៃសេដ្ឋកិច្ចរបស់ប្រទេសជឿនលឿនដែលបន្តការធ្លាក់ចុះ និងកត្តាសេដ្ឋកិច្ចថ្មីៗផ្សេងទៀតមកលើប្រព័ន្ធហិរញ្ញវត្ថុនិងសេដ្ឋកិច្ច

របស់កម្ពុជា ព្រមទាំងសំដៅការពារនូវសមិទ្ធផលនានាដែលសម្រេចបានដោយកិច្ចខិតខំយ៉ាងលំបាកកន្លងមក។ សូចនាករម៉ាក្រូសេដ្ឋកិច្ច ឆ្លុះបញ្ចាំងឲ្យឃើញនូវគោលបំណងការពារសមិទ្ធផលចម្បងកន្លងមករបស់ *ផ.យ.អ.ជ. ២០១៤-២០១៨*ដែលរួមមាន ការសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ក្នុងអត្រាយ៉ាងហោចណាស់ប្រមាណ៧% ជាមធ្យមក្នុងមួយឆ្នាំ និងការកាត់បន្ថយអត្រានៃភាពក្រីក្រលើសពី១% ក្នុងមួយឆ្នាំ។

៧.៤- *ផ.យ.អ.ជ. ២០១៤-២០១៨* ក៏បានលើកឡើងពីតម្រូវការធនធានហិរញ្ញប្បទានដែលមានចំនួនច្រើនជាងការអនុវត្ត *ផ.យ.អ.ជ.* មុនៗ។ ទោះបីជាដូចនេះក្តី*រាជរដ្ឋាភិបាលកម្ពុជា* ជឿជាក់ថា ធនធានហិរញ្ញប្បទានគាំទ្រពីដៃគូអភិវឌ្ឍ គឺជាចលករជំរុញមួយដ៏សំខាន់ដើម្បីពន្លឿនការវិនិយោគ សកម្មភាព សមត្ថភាពនិងរចនាសម្ព័ន្ធស្ថាប័ន ឲ្យបានសម្រេចរួមគ្នាក្នុងពេលតែមួយ។ ចលករជំរុញនេះ មានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា ដែលកំពុងយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពបុគ្គលនិងស្ថាប័នរបស់រដ្ឋាភិបាល។

៧.៥- ដំណើរការនៃការរៀបចំ *ផ.យ.អ.ជ.* នេះ បានបង្ហាញពីវិធីសាស្ត្រថ្មៃប្រឌិត ដែលរួមមាន ការប្រមែប្រមូលព័ត៌មានតាមរបៀប នីតិវិធី *ពីក្រោមឡើងលើ* សំដៅធ្វើការកំណត់នូវ*អ្នកទទួលខុសត្រូវ សកម្មភាពសំខាន់ៗ*នឹងត្រូវអនុវត្ត និង*ថវិកា*ដែលត្រូវចំណាយក្នុងការអនុវត្តផែនការ សកម្មភាព ដែលបានស្នើឡើង ក៏ដូចជា នីតិវិធី *ពីលើចុះក្រោម* ដែលពឹងផ្អែកលើការវិភាគបែបបរិមាណ អំពីនិន្នាការនៃការវិវត្តរបស់ស្ថានភាពរួមនៃសេដ្ឋកិច្ច។ បន្ថែមលើវិធីសាស្ត្រខាងលើនេះ *ក្រសួងផែនការ* បានអនុវត្តការងារជាក់លាក់មួយចំនួន ដើម្បីធានាឲ្យមានការចូលរួមយ៉ាងសកម្ម ពីក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ព្រមជាមួយគ្នានឹងការធានាផងដែរថាបណ្តាដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលដទៃទៀត ត្រូវបានផ្តល់នូវកាលានុវត្តភាព ដើម្បីចូលរួមយ៉ាងសកម្មក្នុងការកំណត់និយមន័យលទ្ធផល (ដូចជា ផលប៉ះពាល់របស់គោលនយោបាយ កម្មវិធី និងគម្រោងសកម្មភាព) ក្នុងដំណើរការនៃការរៀបចំធាតុចូលនិងចំណុចដៅទាំងឡាយ។

៧.៦- ដំណើរការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៅក្នុង *ផ.យ.អ.ជ.* នេះ ក៏បានលើកឡើងពី*ក្របខ័ណ្ឌលទ្ធផល* ដើម្បីធានាថា រាល់ធាតុចូល គឺឆ្លើយតបនឹងសកម្មភាព ធាតុចេញលទ្ធផល និងផលប៉ះពាល់ យ៉ាងត្រឹមត្រូវ។ ដើម្បីបន្តដំណើរការរៀបចំកែលម្អ សូចនាករនិងចំណុចដៅសំខាន់ៗ សម្រាប់ការតាមដាន ត្រួតពិនិត្យ សម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត *ផ.យ.អ.ជ. ២០១៤-២០១៨ ក្រសួងផែនការ* បានបង្កើតនូវ *ក្រុមការងារជាតិសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ផ.យ.អ.ជ.* ដែលដឹកនាំដោយ *ក្រសួងផែនការ*។ ដូចដែលបានលើកឡើងក្នុងជំពូកទី៦ ក្រុមការងារជាតិបានយកចិត្តទុកដាក់ខ្ពស់ក្នុងការបំពេញ

ភារកិច្ចរៀបចំឲ្យមាននិយាមនូវនិយមន័យរបស់បណ្តាសូចនាករ និងការកំណត់និយមន័យសូចនាករថ្មីផ្សេងៗ ដើម្បីបង្កបរិយាកាសងាយស្រួលក្នុងការតាមដានត្រួតពិនិត្យនូវលទ្ធផលដែលសម្រេចបានពីការចំណាយ សម្រាប់ការអនុវត្តផែនការ។ ក្រុមការងារជាតិ គឺជា*គណៈកម្មាធិការកណ្តាល* និងមានតួនាទីតាមដានរាល់វឌ្ឍនភាពកំឡុងពេលអនុវត្ត*ផ.យ.អ.ជ. ២០១៤-២០១៨*។ ក្នុងន័យនេះ កិច្ចការរបស់ក្រុមការងារជាតិ រួមមាន ការលើកកម្ពស់ដំណើរនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការ ប្រសិនបើមានការចាំបាច់។ ដូច្នេះ *ផ.យ.អ.ជ. ២០១៤-២០១៨* ធានាបាននូវភាពទន់ភ្លន់ក្នុងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ក្រុមការងារជាតិក៏បានរៀបចំឲ្យមានឋានានុក្រមនៃសូចនាករទាំងឡាយដោយបានរៀបចំពីកម្រិតខ្ពស់(ចាប់ពីកម្រិត សេដ្ឋកិច្ច កម្រិតអន្តរវិស័យ ។ល។) កម្រិតបន្ទាប់(ធាតុចេញ/លទ្ធផល តាមវិស័យ)និងកម្រិតបន្ទាប់ក្រោមបង្អស់ គឺជាធាតុចេញ/លទ្ធផល តាមអនុវិស័យ និងកម្រិតក្រោមបង្អស់ គឺជាធាតុចូល ។ *ផ.យ.អ.ជ. ២០១៤-២០១៨* ក៏បានបញ្ចូលផងដែរនូវសូចនាករថ្នាក់ក្រោមជាតិ ដែលជាកិច្ចការដំបូងសម្រាប់តាមដានត្រួតពិនិត្យវិសមភាពនៅតាមតំបន់នានា ទូទាំងប្រទេសកម្ពុជា៕

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

# ពាក្យបំព្រួញ

| | |
|---|---|
| ក.ក.ប.វ. | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក.ក.ន. | ក្រសួងកិច្ចការនារី |
| ក.ក.រ.ន. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក.ធ.ទ.ឧ. | ក្រសួងធនធានទឹកនិងឧតុនិយម |
| ក.ទ.ច. | ក្រសួងទេសចរណ៍ |
| ក.ទ.រ.ព.អ. | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |
| ក.ប.ទ. | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ក.ប.ស. | ក្រសួងបរិស្ថាន |
| ក.រ.ដ.ន.ស. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក.ស.ដ. | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ក.ស.ភ. | ក្រសួងសុខាភិបាល |
| ក.ស.ហ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ក.អ.ជ. | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ក.អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| ក.វ.វ. | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ក.វ.ស. | កម្មវិធីវិនិយោគសាធារណៈ |
| គ.ជ.នា./ក.អ.ក. | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.ម. | គីឡូម៉ែត្រ |
| គ.ម.² | គីឡូម៉ែត្រការ៉េ |
| គ.វ.ម៉. | គីឡូវ៉ាត់ម៉ោង |
| គ.អ.ស.ក. | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| គ.អ.ភ. | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| ជ.ទ.ប.ក. | ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា |
| ធ.ជ.ក. | ធនាគារជាតិនៃកម្ពុជា |
| ទ.ឃ.ស. | ទិន្នន័យឃុំ សង្កាត់ |
| ប.ព.រ.ក.ស. | ប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់ក្រសួង ស្ថាប័ន |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ម. | ម៉ែត្រ |

| | |
|---|---|
| *ម.៣* | ម៉ែត្រត្រីគុណ |
| *ម.ជ.គ.ច.* | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| រ.អ.ស.វ. | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |
| វ.ជ.ស. | វិទ្យាស្ថានជាតិស្ថិតិ |
| ហ.ត. | ហិកតា |
| អ.ជ.ប.អ. | អាជ្ញាធរជាតិប្រឆាំងនឹងជំងឺអេដស៍ |
| អ.ម.ក. | អាជ្ញាធរមីនកម្ពុជា |
| អ.ប.ស.ក. | អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា |
| អ.ស.ស.ក. | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |

## ឧបសម្ព័ន្ធទី២

# គេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា

| | ក្រសួង ស្ថាប័ន | គេហទំព័រ(www) |
|---|---|---|
| ១ | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | cdc- crdb.gov.kh |
| ២ | គណៈកម្មាធិការវិនិយោគកម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | cib-cdc.gov.kh |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | civilaviation.gov.kh |
| ៤ | អាជ្ញាធរជាតិកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | cmaa.gov.kh |
| ៥ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | |
| ៦ | សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា | card.gov.kh |
| ៧ | ក្រសួងព័ត៌មាន | information.gov.kh |
| ៨ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | maff.gov.kh |
| ៩ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | mcfa.gov.kh |
| ១០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | mef.gov.kh |
| ១១ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | mfaic.gov.kh |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | mlmupc.gov.kh |
| ១៣ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | mlvt.gov.kh |
| ១៤ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | mnasrl.gov.kh |
| ១៥ | ក្រសួងពាណិជ្ជកម្ម | moc.gov.kh |
| ១៦ | ក្រសួងធម្មការនិងសាសនា | mocar.gov.kh |
| ១៧ | ក្រសួងការពារជាតិ | mod.gov.kh |
| ១៨ | ក្រសួងបរិស្ថាន | moe.gov.kh |
| ១៩ | ក្រសួងអប់រំ យុវជន និងកីឡា | moeys.gov.kh |
| ២០ | ក្រសួងសុខាភិបាល | moh.gov.kh |
| ២១ | ក្រសួងមហាផ្ទៃ | moi.gov.kh |
| ២២ | ក្រសួងយុត្តិធម៌ | moj.gov.kh |
| ២៣ | ក្រសួងផែនការ | mop.gov.kh |
| ២៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | mosalvy.gov.kh |
| ២៥ | ក្រសួងទេសចរណ៍ | mot.gov.org |
| ២៦ | ក្រសួងកិច្ចការនារី | mowa.gov.kh |
| ២៧ | ក្រសួងធនធានទឹកនិងឧតុនិយម | mowram.gov.kh |
| ២៨ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | mptc.gov.kh |
| ២៩ | ក្រសួងសាធារណការនិងដឹកជញ្ជូន | mpwt.gov.kh |
| ៣០ | ក្រសួងអភិវឌ្ឍន៍ជនបទ | mrd.gov.kh |
| ៣១ | ក្រសួងមុខងារសាធារណៈ | sspf.gov.kh |

| | | |
|---|---|---|
| ៣២ | ក្រសួងរ៉ែ និង ថាមពល | |
| ៣៣ | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | naa.org.kh |
| ៣៤ | ធនាគារជាតិនៃកម្ពុជា | nbc.org.kh |
| ៣៥ | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ncdd.gov.kh |
| ៣៦ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ncdm.gov.kh |
| ៣៧ | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | cnmc.gov.h |
| ៣៨ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ | cnm.gov.kh |
| ៣៩ | វិទ្យាស្ថានជាតិស្ថិតិ | nis.gov.kh |
| ៤០ | សាលារាជធានីភ្នំពេញ | phnompenh.gov.kh |
| ៤១ | ទីស្តីការគណៈរដ្ឋមន្ត្រី | pressocm.gov.kh |
| ៤២ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | snec.gov.kh |